# របត់នយោបាយ

## សីហនុ - លន់ នល់ - ប៉ុល ពត - ជា ស៊ីម - ហេង សំរិន - ហ៊ុន សែន



៩ វិច្ឆិកា ១៩៥៣



៧ មករា ១៩៧៩

## ភាគ ៥

(ពីឆ្នាំ ១៩៦៣ ដល់ឆ្នាំ ១៩៦៨)



១៨ មីនា ១៩៧០



១៧ មេសា ១៩៧៥







**ឈឹម សេរីតួន**



# របត់នយោបាយ

សីហនុ ~ លន់ នល់ ~ ប៉ុល ពត ~ ជា ស៊ីម ~ ហេង សំរិន ~ ហ៊ុន សែន

ភាគ ៥

ហាមថតចម្លង

ស្លាកដៃនេះត្រូវបានចុះបញ្ជីលេខ Ⓡ ៦៨៣/២១ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១ នៅនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៃក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ។

***-សហការីពិនិត្យអក្ខរាវិរុទ្ធ៖***

ឯកឧត្តម អេង វុទ្ធី អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ

វេជ្ជបណ្ឌិត អ៊ុន សុវណ្ណា

***-ការីកុំព្យូទ័រ***

ហែម សុជា

ឈឹម មករា

ប៉ោ កុសល

ចាន់ ពិសុទ្ធ

ឈឹម ពុទ្ធី

រក្សាសិទ្ធិ© ឈឹម សេរីក្លូន គ.ស.២០២៣

ISBN-13 : 978-9924-9698-4-6

# អារម្ភកថា

ឯកសារប្រវត្តិសាស្ត្រ មានចំណងជើងថា **របត់នយោបាយ** នេះ បានបោះពុម្ពជាសៀវភៅចំនួន **៤ភាគ** រួចមកហើយ ដោយបានរៀបរាប់ពីព្រឹត្តិការណ៍នយោបាយសំខាន់ៗ របស់ប្រទេសជាតិ ចាប់ពីពេល**សម្តេចសីហនុ** បានឡើងសោយរាជសម្បត្តិក្នុងឆ្នាំ១៩៤១មក...។

សម្រាប់ **ភាគទី៥** នេះ ខ្ញុំបាទបានធ្វើការសិក្សាស្រាវជ្រាវពីប្រវត្តិតស៊ូរបស់អ្នកនយោបាយមួយចំនួន ចង់ផ្លាស់ប្តូររបបគ្រប់គ្រងរាជានិយម និងសង្គមរាស្ត្រនិយមដឹកនាំដោយ**សម្តេចសីហនុ** ដែលពួកគេចាត់ទុកថា ជាមេខ្លោងរបបសក្តិភូមិ ផ្តាច់ការ ជិះជាន់សង្កត់សង្កិនប្រជាជននោះ ឱ្យទៅជារបបគ្រប់គ្រងថ្មីមួយគឺរបបកុម្មុយនិស្ត ដឹកនាំដោយវណ្ណៈកសិករ និងកម្មករ វិញ។

ជាមួយគ្នានេះ ខ្ញុំបាទក៏បានសិក្សាស្រាវជ្រាវពីវត្តមានកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលចូលមកបោះទីតាំងនៅលើទឹកដីកម្ពុជាកាន់តែច្រើនឡើងៗ នៅចុងទសវត្សរ៍ឆ្នាំ១៩៦០ និងពីបំណងរបស់**សម្តេចសីហនុ** ដែលចង់ស្តារទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក ឡើងវិញ ផងដែរ មុនពេលមានព្រឹត្តិការណ៍រដ្ឋប្រហារខែមីនាឆ្នាំ១៩៧០ ។

ក្នុងឱកាសនេះដែរ ខ្ញុំបាទសូមលំអោនកាយគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ**សម្តេចក្រឡាហោមស ខេង** សមាជិកឧត្តមទីប្រឹក្សាព្រះមហាក្សត្រ ដែលបានជួយឧបត្ថម្ភគាំទ្រទាំងស្រុងក្នុងការបោះពុម្ពសៀវភៅ **របត់នយោបាយ** តាំងពី**ភាគទី១** រហូតដល់**ភាគទី៥** នេះ ដើម្បីទុកជាឯកសារប្រវត្តិសាស្ត្រសម្រាប់កូនខ្មែរជំនាន់ក្រោយៗទៀត។

ជាចុងក្រោយ ប្រសិនបើសៀវភៅប្រវត្តិសាស្ត្រនេះ មានចំណុចខុសឆ្គងខ្វះខាត ឬលើសលោះត្រង់ចំណុចណាមួយ សូម **សម្តេច ទ្រង់ ឯកឧត្តម អស់លោក លោកស្រី** និងប្រិយមិត្តអ្នកអានទាំងអស់មេត្តាខន្តីអភ័យទោស ដោយក្តីអនុគ្រោះ។

ថ្ងៃពុធ ១៣កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣

**ឈឹម សេរីត្នួន**

# មាតិកា


●១៩៥ ប្រវត្តិ ស ខេង ពីក្មេងដល់វ័យសិក្សា.............................................................1

●១៩៦ ពេលទៅព្រៃជាមួយឪពុក សាច់មាន់ឆាខ្ញី ស្នាដៃម៉ែ
មិនអាចបំភ្លេចបាន.............................................................10

●១៩៧ អនុវិទ្យាល័យកំចាយមារ ជាកន្លែងតស៊ូដើម្បីចំណេះ.............................................14

●១៩៨ យុវជន ស ខេង ចូលជាសមាជិកចលនាយុវជនរាជសង្គមនិយមខ្មែរ ..................18

●១៩៩ កងជីវពល ពួនចាំបាញ់សម្លាប់ឪពុកមារ ជាអ្នកតស៊ូ.............................................21

●២០០ ស្រុកកំចាយមារ ក្លាយជាអនុខេត្ត .............................................................23

●២០១ យុវជន ស ខេង និងបងថ្លៃ ឈុន ឈាន ទិញមាន់ជ្រូក
ទៅលក់ឱ្យកងទ័ពវៀតកុង .............................................................25

●២០២ គេចពីយន្តហោះអាមេរិក បាចថ្នាំគីមីទៅជួបនារីជាប្អូនស្រីមិត្តភក្តិ......................29

●២០៣ ខៀវ សំផន និងហ៊ូ យន់ បាត់ខ្លួនពីក្រុងភ្នំពេញ .............................................32

●២០៤ កេង វ៉ាន់សាក់ ត្រូវសមត្ថកិច្ចចាប់ខ្លួនជាលើកទី២.............................................36

●២០៥ សម្តេចសីហនុ ផ្សារទំនាក់ទំនងការទូតជាមួយវៀតកុង និងវៀតណាមខាងជើង ..39

●២០៦ សម្តេចសីហនុ ចង់ផ្តាច់ទំនាក់ទំនងការទូតជាមួយចិន ......................................43

●២០៧ សាស្ត្រាចារ្យកាំង ហ៊្កិកអ៊ាវ ហៅឌុច ញុះញង់ឱ្យសិស្ស
បះបោរប្រឆាំងនឹងសម្តេចសីហនុ.............................................................46

●២០៨ តុលាការសម្តេចសីហនុ កាត់ទោស កាំង ហ៊្កិចអ៊ាវ ហៅឌុច ឱ្យជាប់គុក២០ឆ្នាំ.....51

●២០៩ សម្តេចសីហនុ រំលាយចោលសមាគមមិត្តភាពកម្ពុជា-ចិន ..................................54

●២១០ សម្តេចសីហនុ ឱ្យគេយកខៀវ សំផន និងហ៊ូ យន់
ទៅសម្លាប់មែនឬ?.............................................................59

●២១១ ជីវិតខៀវ សំផន ក្នុងតំបន់តស៊ូខ្មែរក្រហម.............................................................64

•២១២ ភោគ ឆាយ កូនអ្នកក្រក្រី តែល្បីជាសិស្សពូកែ.............................................69
•២១៣ ចៅកែស្រូវនៅខេត្តពោធិ៍សាត់ ស្វាត់ៗ លើកកូនក្រមុំឱ្យភោគ ឆាយ ..................73
•២១៤ ភោគ ឆាយ ចូលរួមជាមួយខ្មែរក្រហម តាមរយៈអ៊ុច វ៉ែន ................................79
•២១៥ ហ៊ូ នឹម ពីក្មេងក្រីក្រកំព្រីកំព្រា ក្លាយជាអ្នកនយោបាយល្បីឈ្មោះ......................85
•២១៦ ពួកខ្មែរក្រហម ជួយហ៊ូ នឹម ឱ្យជាប់ឆ្នោតជាតំណាងរាស្ត្រ ..............................92
•២១៧ ហ៊ូ នឹម បង្ខំចិត្តរត់ចូលព្រៃ ទៅតស៊ូជាមួយខ្មែរក្រហម....................................97
•២១៨ ខ្មែរក្រហម និងខ្មែរខៀវ ប៉ុនប៉ងផ្តួលរំលំសម្តេចសីហនុ ................................103
•២១៩ ចិន ចង់នាំបដិវត្តន៍វប្បធម៌ចូលប្រទេសខ្មែរ .............................................. 112
•២២០ សម្តេចសីហនុ ចង់ភ្ជាប់ទំនាក់ទំនង ការទូតជាមួយអាមេរិក វិញ ................... 117
•២២១ បេះដូងក្រហមរបស់យុវជនដាំ ផេង .........................................................126
•២២២ ដាំ ផេង ស៊ូស្លាប់ដើម្បីបុព្វហេតុបដិវត្តន៍......................................................134
•២២៣ ប្រវត្តិតស៊ូរបស់នង សួន ហៅជ័យ សួន................................................... 141
•២២៤ ប្រវត្តិតស៊ូ នៃ សា៉ាន់ ហៅយ៉ា ហៅអាចារ្យសៀង.............................................145
•២២៥ ប្រវត្តិតស៊ូរបស់មេខ្មែរក្រហម សួស នៅ ហៅឈូក ........................................155
•២២៦ ជីវិតតស៊ូរបស់មេខ្មែរក្រហម វន វ៉េត ........................................................159
•២២៧ សាស្ត្រាចារ្យ កុយ ធួន ក្លាយជាមេខ្មែរក្រហម................................................166
•២២៨ ចាន់ ម៉ុន ហៅ តុល ចូលខ្មែរក្រហម តាមរយៈ កែ ពក ....................................172
•២២៩ តូច ភឿន មិនសូវចូលចិត្ត ភោគ ឆាយ ជាអ្នកតស៊ូដូចគ្នា .............................175
•២៣០ ប្រវត្តិតស៊ូរបស់ជួ ដេត ហៅស៊ី បក្ខជននៃបក្សកុម្មុយនិស្តឥណ្ឌូចិន................. 181
•២៣១ សាស្ត្រាចារ្យពីរនាក់ប្តីប្រពន្ធ ទីវ អុល និងឡេង ស៊ីមហាក់ ស្មោះស្ម័គ្រធ្វើបដិវត្តន៍183
•២៣២ គង់ សុផល ហៅកឺ ក្មួយអាចារ្យហែម ចៀវ អ្នកតស៊ូនៅភ្នំវាយចាប ................. 188
•២៣៣ សាស្ត្រាចារ្យខែក ប៉ែន ហៅស៊ូ បំផុសកូនសិស្សឱ្យរត់ចូលព្រៃ .......................195
•២៣៤ សាស្ត្រាចារ្យ អ៊ុំ ឈឿន ហៅម៉ែ បោះបង់ប្រាក់ខែ-ប្រពន្ធកូន ទៅតស៊ូនៅភ្នំឱរ៉ាល់199

•២៣៥ ម៉ែន ជុន ហៅហឹង្ស មន្ត្រីធនាគារជាតិ ចូលព្រៃតស៊ូ ....................................202
•២៣៦ ហួត សម្បត្តិ បែកបាក់សាមគ្គីគ្នាជាមួយ សម សារី......................................205
•២៣៧ ហេង ពេជ្រ ហៅ ធន និស្សិតមកពីសហភាពសូវៀត
ប៉ូលិសឃាត់ខ្លួននៅពោធិ៍ចិនតុង ........................................................................ 211
•២៣៨ ហៃ គឹមស៊ាង និស្សិតក្រហមនៅសូវៀត សុំចូលជាសមាជិក
ចលនាសង្គមរាស្ត្រនិយម .....................................................................................218
•២៣៩ ខ្មែរក្រហមបង្កការអុកឡុកខាងក្នុង កងទ័ពវៀតកុង ចូលមកកាន់តែច្រើន........220
•២៤០ សម្តចសីហនុ ៖ សម្លាប់ខ្មែរក្រហម មិនខ្លាចចុះនរកទេ ...................................224
•២៤១ ក្រោយពីរួចផុតជីវិត ទៀ សង្វាន ត្រូវបានដូរឈ្មោះមកជា ទៀ បាញ់ ...............231
•២៤២ ទៀ បាញ់ ដឹកនាំកម្លាំងចូលរោងចក្រអារឈើ
របស់ប្អូនញ៉ឹក ជូឡុង ដើម្បីរកស្បៀង ..................................................................239
•២៤៣ ខ្មែរក្រហមធ្វើសង្គ្រាមឈ្លប សម្តេចសីហនុ ឲ្យទាហានចេញបង្ក្រាប................246
•២៤៤ ទាហានរាជរដ្ឋាភិបាល បោសសម្អាតពួកខ្មែរក្រហម,
ប៉ះទង្គិចគ្នាជាមួយពួកវៀតកុង ..........................................................................253
•២៤៥ ខ្មែរក្រហម មានសមត្ថភាព ត្រឹមតែធ្វើសង្គ្រាមឈ្លបប៉ុណ្ណោះ ..........................259
•២៤៦ ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម និងប៉ុក ដឹសកុមារ ជួបជុំគ្នានៅលើខ្នងភ្នំឱរ៉ាល់...263
•២៤៧ សឺន សាន លាឈប់ពីតំណែងឧបនាយករដ្ឋមន្ត្រី ទៅរក្សាសីលទាន ...............265
•២៤៨ មេដឹកនាំថៃ ដាក់ សុង សាក់ ជនជាតិថៃ
ជាមេខ្មែរសេរីជំនួស ឡឹក សំអឿន ហៅផ្កាយព្រឹក ..................................................277
•២៤៩ កងទ័ពខ្មែរសេរី ដែលថៃ គ្រប់គ្រង នាំគ្នាមកចុះចូលជាមួយសម្តេចសីហនុ .......285
•២៥០ ជីវិតរបស់ សម រង្ស៊ី ពេលទៅដល់ក្រុងប៉ារីស ដំបូង .......................................293
•២៥១ សម រង្ស៊ី ចាប់ចិត្តស្នេហា លើជូឡុង សូម្ប៉ា តាំងពីអាយុ១០ឆ្នាំ .......................297

# ១៩៥
# ប្រវត្តិ ស ខេង ពីក្មេងដល់វ័យសិក្សា



ស ខេង កើតនៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៥១ នៅភូមិពោធិ៍ទង ឃុំកញ្ច្រៀច ស្រុកកញ្ច្រៀច ខេត្តព្រៃវែង ចំណែកឪពុករបស់កុមារ ស ខេង ឈ្មោះ ស ប៊ិត កើតក្នុងឆ្នាំ ១៩២២ ក្នុងគ្រួសារកសិករក្រីក្រមួយ នៅភូមិអណ្តូងស្អាត ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សម័យនោះ នៅក្នុងឃុំក្របៅ ក៏ដូចជាឃុំនានានៅតាមតំបន់ដាច់ស្រយាលចុងកាត់មាត់ញកផ្សេងៗទៀត នៅទូទាំងប្រទេសដែរ រាជការខ្មែរឋិតនៅក្រោមអាណាព្យាបាលបារាំង ក៏មិនទាន់មានលទ្ធភាពបង្កើតសាលារៀនថ្នាក់មត្តេយ្យសិក្សា និងថ្នាក់បឋមសិក្សាដូចសម័យបច្ចុប្បន្ននេះទេ ដូច្នេះ ប្រជាកសិករមានតែយកកូនចៅទៅផ្ញើជាមួយព្រះសង្ឃនៅតាមវត្តអារាមនានា ដើម្បីបានរៀនសូត្រ ចេះអាននិងសរសេរអក្សរ លេខនព្វន្តនឹងគេ។

តាមប្រពៃណីពីបុរាណ ប្រជាកសិករភាគច្រើនឱ្យកូនចៅសាងផ្នួស ដើម្បីរៀនសូត្រធម៌អាថ៌ ទ្រទ្រង់ព្រះពុទ្ធសាសនាផង និងបានចេះដឹងអក្សរសាស្ត្រផង។ សម័យនោះដែរ

## របត់នយោបាយ

កុមារ ស ប៊ិត បានរៀនសូត្រនៅតាមវត្ត ចេះអាន និងសរសេរបន្តិចបន្តួចប៉ុណ្ណោះ។

ម្តាយរបស់កុមារ ស ខេង ឈ្មោះម៉ក់ សែម កើតក្នុងឆ្នាំ១៩២១ នៅភូមិអណ្តូងស្អាត ឃុំក្របៅ ជាមួយជាមួយឪពុកគាត់ដែរ។ ដោយសារជីវភាពគ្រួសារមានការលំបាក គាត់មិនបានចូលសាលា សិក្សារៀនសូត្រអ្វីឡើយ។ ម្យ៉ាងទៀត កាលសម័យនោះ នៅតាមតំបន់ជនបទដាច់ស្រយាល គ្មានក្មេងស្រីណាបានចូលសាលាសិក្សារៀនសូត្រឡើយ។ តែយ៉ាងណាជីតារបស់កុមារី ម៉ក់ សែម ជួយបង្ហាត់បង្រៀនឱ្យចេះអានអក្សរបន្តិចបន្តួចដែរ។

ស ខេង មានបងប្អូន៩នាក់ គឺទី១- ឈ្មោះស ស៊ន់ ភេទស្រី កើតឆ្នាំ១៩៤៨, ទី២- ឈ្មោះស លន់ ភេទស្រី កើតឆ្នាំ ១៩៤៩, ទី៣- ឈ្មោះស ខេង(រូបគាត់ផ្ទាល់) កើតឆ្នាំ ១៩៥១, ទី៤- ឈ្មោះស ថន ហៅស ថេង ភេទប្រុស កើតឆ្នាំ១៩៥៣, ទី៥- ឈ្មោះស បាន ភេទប្រុស កើតឆ្នាំ១៩៥៥, ទី៦- ស សឿន ភេទស្រី កើតឆ្នាំ១៩៥៧, ទី៧- ឈ្មោះស ចេង ភេទស្រី កើតឆ្នាំ១៩៥៩, ទី៨-ឈ្មោះស សុខុម ភេទស្រី កើតឆ្នាំ១៩៦១ និងទី៩- ឈ្មោះ ស សុខឿន ភេទស្រី កើតឆ្នាំ ១៩៦៤។

ក្រោយពីប្រទេសជប៉ុន ចុះចាញ់សង្គ្រាមលោកលើកទី២ ក្នុងឆ្នាំ១៩៤៥ ពួកអាណា - និគមបារាំង បានចូលមកត្រួតត្រាឧបទ្វីបឥណ្ឌូចិន ឡើងវិញ។ ពេលនោះ កងទ័ពវៀតមិញមកពីវៀតណាមភាគខាងជើង បានចូលមកបោះទីតាំងឈរជើងនៅពាសពេញប្រទេសកម្ពុជា ហើយចលនាខ្មែរឥស្សរៈជាច្រើនក្រុម ក៏ចាប់ផ្តើមកើតមានឡើងនៅគ្រប់ទិសទី ពិសេសនៅតំបន់ជនបទ និងព្រៃភ្នំ ដើម្បីធ្វើសង្គ្រាមតស៊ូបណ្តេញពួកបារាំង ឱ្យចាកចេញឧបទ្វីបឥណ្ឌូចិនវិញ។

ពេលនោះ រាជការខ្មែរ-បារាំង បានបង្ខំប្រជាកសិកររស់នៅរាយប៉ាយតាមតំបន់ព្រៃភ្នំ និងតំបន់ជនបទដាច់ស្រយាល ដែលជាតំបន់ប្រទាញប្រទង់ជាមួយពួកវៀតមិញ និងខ្មែរឥស្សរៈនោះ ឱ្យរុះរើផ្ទះសម្បែងផ្លាស់ប្តូរទីតាំងមករស់នៅប្រមូលផ្តុំគ្នាបង្កើតភូមិធំៗនៅជិតបន្ទាយទាហាន ឬនៅជិតសាលាស្រុក ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងផង ការពារសន្តិសុខផង និងដើម្បីកុំឱ្យពួកវៀតមិញ និងខ្មែរឥស្សរៈចូលមកធ្វើសកម្មភាពលួចប្លន់ ឬអូសទាញ

អ្នកភូមិឲ្យចូលរួមចលនាតស៊ូជាមួយពួកគេ ដោយងាយស្រួលពេកផងដែរ។

ដោយឡែក នៅស្រុកកំចាយមារ រាជការខ្មែរ-បារាំងខេត្តព្រៃវែង បានបង្ខំ អ្នកភូមិអណ្ដូងស្អាត ក៏ដូចជាអ្នកភូមិផ្សេងទៀតដែលនៅតាមដងព្រៃនានានៅក្នុងឃុំក្របៅ ឲ្យរុះរើផ្ទះសម្បែងផ្លាស់ប្ដូរទីតាំងទៅរស់នៅស្រុកកញ្ជ្រៀច វិញ។ ពេលនោះ កសិករឈ្មោះស ប៊ិត ក៏បាននាំប្រពន្ធកូនចាកចេញពីភូមិអណ្ដូងស្អាត ជាភូមិកំណើត ទៅរស់នៅភូមិពោធិ៍ទង ឃុំកញ្ជ្រៀច ក្បែរទីតាំងសាលាស្រុកកញ្ជ្រៀច ដែលមានចម្ងាយប្រហែល២០គីឡូម៉ែត្រ ពីភូមិអណ្ដូងស្អាត នោះ។

នៅក្នុងឆ្នាំ១៩៤៩ ចលនាតស៊ូខ្មែរឥស្សរៈដែលគាំទ្រដោយពួកវៀតមិញ បានប្រកាសខ្លួនឯងថា នៅទូទាំងប្រទេស ពួកគេបានកាន់កាប់ត្រួតត្រាភូមិ ចំនួន៤១៨ភូមិ, ស្រុកចំនួន៤០ស្រុក និងខេត្តចំនួន ១០ខេត្ត។

ក្រោយមក ពួកបារាំង និងរាជការខ្មែរនៅខេត្តព្រៃវែង ក៏បានវាយរុញច្រានពួកវៀតមិញ និងខ្មែរឥស្សរៈ ឱ្យដកថយចេញពីភូមិឃុំជាច្រើន និងបានពង្រីកទឹកដីត្រួតត្រារបស់ខ្លួនកាន់តែធំឡើងៗជាលំដាប់ ក្នុងនោះ ក៏មានភូមិអណ្ដូងស្អាត ឃុំក្របៅ ស្រុកកំចាយមារ ជាទឹកដីកំណើតរបស់គ្រួសារកសិករឈ្មោះស ប៊ិត ផងដែរ។ តែយ៉ាងណា កសិករឈ្មោះស ប៊ិត មិនទាន់នាំប្រពន្ធកូនវិលត្រលប់មករស់នៅភូមិកំណើតរបស់ខ្លួននៅភូមិអណ្ដូងស្អាត វិញទេ។

រហូតដល់ក្រោយពេលប្រពន្ធគាត់សម្រាលបានកូនទី៣ ឈ្មោះស ខេង នៅក្នុងខែមិថុនា ឆ្នាំ១៩៥១ រយៈពេល៤-៥ខែ បានរឹងដៃរឹងជើងស្រួលបួល ទើបគាត់សម្រេចចិត្តនាំប្រពន្ធកូនចាកចេញពីភូមិពោធិ៍ទង ឃុំកញ្ជ្រៀច ស្រុកកញ្ជ្រៀច មករស់នៅភូមិអណ្ដូង ស្អាត ឃុំក្របៅ ស្រុកកំចាយមារ ជាស្រុកកំណើតរបស់គាត់វិញ។

ក្រោយពីបានវិលត្រលប់មករស់នៅក្នុងភូមិកំណើតវិញ ក្រៅពីមុខរបរជាអ្នកធ្វើស្រែចម្ការ កសិករ ស ប៊ិត ជាឪពុករបស់កុមារ ស ខេង តែងតែឆ្លៀតចូលព្រៃរកអនុផលព្រៃឈើ ដូចជាបោចវល្លិ ឬរកផ្ដៅ រកជ័រចុង ជ័រទឹកទៅលក់ ដើម្បីយកប្រាក់មកចិញ្ចឹមកូនៗដែលកាន់តែកើនច្រើនឡើងៗ ជាលំដាប់។ តែទោះបីមានជីវភាពលំបាកខ្វះខាតយ៉ាងណាក៏ដោយ ក៏ក្រុម

គ្រួសារនេះរស់នៅ ដោយសុខដុមរមនានឹងគ្នា ដែលអាចចាត់ទុកជាគ្រួសារគំរូមួយ នៅក្នុងភូមិ។

ថ្វីដ្បិតតែ ជីតាខាងឪពុក និងជីតាខាងម្ដាយរបស់កុមារស ខេង ពុំបានសិក្សារៀនសូត្រចេះដឹងជ្រៅជ្រះយ៉ាងណាក៏ដោយ ក៏ពួកគាត់តែងតែអប់រំទូន្មានប្រដៅប្រដៅកូនចៅទាំងអស់ឲ្យស្រលាញ់ការងារ ខិតខំរៀនសូត្រ និងប្រកាន់ខ្ជាប់នូវគុណធម៌ សីលធម៌ជាធំ ស្គាល់ចាស់ស្គាល់ទុំ សុភាពរាបសា ព្រមទាំងឱ្យចេះសន្តោសប្រណី យល់អធ្យាស្រ័យគ្នាទៅវិញទៅមកផងដែរ។

ដោយមានការអប់រំទូន្មានប្រដៅប្រដៅពីជីដូនជីតា ពីម្ដាយឪពុក គួបផ្សំចរិតធម្មជាតិពីកំណើតមកផង កុមារស ខេង បានក្លាយជាក្មេងមានចរិតស្លូតបូត សុភាពរាបសា គោរពឱនលំទោន ស្គាល់ចាស់ស្គាល់ទុំ ចូលចិត្តជួយយកអាសាអ្នកដទៃ មានប្រាជ្ញាឈ្លាសវៃ និងទទួលបានការរាប់អានស្រលាញ់ចូលចិត្ត ការកោតសរសើរពីសំណាក់អ្នកភូមិផងរបងជាមួយទាំងក្មេងចាស់ប្រុសស្រី។

ក្រោយបង្កើតរបបសង្គមរាស្ត្រនិយមក្នុងឆ្នាំ១៩៥៥ រាជការសម្ដេចសីហនុ ក៏បានសាងសង់សាលាបឋមសិក្សាមួយខ្នងនៅក្នុងបរិវេណវត្តក្របៅ (ស្ថិតនៅខាងកើតភូមិអណ្ដូងស្អាត) ក្នុងឃុំក្របៅ ដើម្បីឱ្យកូនចៅអ្នកភូមិក្បែរៗនោះបានសិក្សារៀនសូត្រ។

សម័យនោះ ដោយសារតែបញ្ហាជីវភាពខ្វះខាត កុមារស ខេង ក៏ដូចជាកូនចៅប្រជាកសិករផ្សេងៗទៀត ដែលរស់នៅតំបន់ជនបទដាច់ស្រយាលភាគច្រើនដែរ ម្ដាយឪពុកមិនមានលទ្ធភាពឱ្យកូនចៅចាប់ពីអាយុ៦ ឬ៧ឆ្នាំ ចូលរៀនថ្នាក់ដំបូងនៃសាលាបឋមសិក្សា ដូចកូនចៅអ្នកនៅទីក្រុងឡើយ គឺរហូតចូលដល់វ័យ១០ឆ្នាំ ទើបកុមារ ស ខេង មានលទ្ធភាពបានចូលរៀនថ្នាក់ទី១២ ឆ្នាំសិក្សា១៩៦១-៦២ (ស្មើថ្នាក់ទី១ បច្ចុប្បន្ន)នៅសាលាបឋមសិក្សាវត្តក្របៅ ដែលនៅចម្ងាយពីផ្ទះប្រហែលជាង១គីឡូម៉ែត្រ ប៉ុណ្ណោះ។

ពេលនោះ អ្វីដែលជាអនុស្សាវរីយ៍ មិនអាចបំភ្លេចបាន ពេលទៅរៀនដំបូង នៅសាលាបឋមសិក្សាវត្តក្របៅ(បច្ចុប្បន្នដូរឈ្មោះមកជា សាលាបឋមសិក្សាក្របៅចាស់)នោះ គឺមនោ-



**ទីតាំងភូមិសាស្ត្រភូមិអណ្ដូងស្អាត ឃុំក្របៅ សម័យបច្ចុប្បន្ន**

សញ្ចេតនាដ៏ជ្រាលជ្រៅរបស់ឪពុកគាត់ ចំពោះគាត់។

ស ខេង បានរម្លឹកថា ៖ ជារៀងរាល់ថ្ងៃ ក្នុងរយៈពេលជិត១០ថ្ងៃជាប់ៗគ្នា ឪពុកខ្ញុំតែងតែយកបាយទៅឲ្យខ្ញុំដាទៀងទាត់ នៅវេលាម៉ោង៩ព្រឹក។ ពេលនោះ ខ្ញុំខ្មាសមិត្តភក្តិណាស់។ ខ្ញុំអង្វរពុក សូមពុកកុំឲ្យយកបាយមកឱ្យខ្ញុំបែបនេះទៀត។ តែពុកមិនព្រម...។ នេះជាការបញ្ជាក់ពីមនោសញ្ចេតនាដ៏ជ្រាលជ្រៅរបស់ឪពុកខ្ញុំ ដែលចង់លើកទឹកចិត្តឱ្យកូនព្យាយាមតស៊ូរៀនសូត្របានចេះដឹងនឹងគេ ហើយនេះ ធ្វើឲ្យខ្ញុំកាន់តែខិតខំរៀនសូត្រទ្វេដងថែមទៀតផងដែរ។

សម័យនោះ នៅសាលាបឋមសិក្សាវត្តក្របៅ មានតែ៣ថ្នាក់ប៉ុណ្ណោះ គឺថ្នាក់ទី១២, ថ្នាក់ទី១១ និងថ្នាក់ទី១០ (ស្មើនឹងថ្នាក់ទី១, ទី២ និងទី៣ បច្ចុប្បន្ន)។ ដោយសារការព្យាយាមខិតខំរៀនសូត្រ កុមារ ស ខេង ទទួលពិន្ទុល្អ ត្រូវបានឡើងថ្នាក់ជារៀងរាល់ឆ្នាំ។ ឆ្នាំសិក្សា ១៩៦២-៦៣ បានឡើងថ្នាក់ទី១១ និងឆ្នាំសិក្សា១៩៦៣-៦៤ បានឡើងថ្នាក់ទី១០។

ក្រោយពេលបញ្ចប់ការសិក្សាថ្នាក់ទី១០ នៅក្នុងឆ្នាំសិក្សា១៩៦៣-៦៤ នៅសាលាបឋមសិក្សាវត្តក្របៅ កុមារស ខេង មានបំណងចង់បន្តការសិក្សាថ្នាក់ទី៩ នៅសាលាបឋម

សិក្សាវត្តកំចាយមារ ទៀតដែរ តែដោយសារនៅឆ្ងាយពីផ្ទះផង និងចង់សម្រាលបន្ទុកម្តាយឪពុក ដែលមានជីវភាពលំបាកខ្វះខាតផងដែរ គាត់ក៏ប្តូរចិត្តសុំម្តាយឪពុកសាងផ្នួសនៅវត្តក្របៅ ដើម្បីសិក្សាគម្ពីរធម៌អាថ៌ អក្សរសាស្ត្រខ្មែរ-បាលី បង្កើនចំណេះដឹងបន្តទៀត តាមរយៈមាគ៌ាព្រះពុទ្ធសាសនា។

តែម្តាយឪពុកគាត់ជំទាស់នឹងបំណងសាងផ្នួសនេះ ព្រោះអ្នកមានគុណប្រាថ្នាចង់ឲ្យកូនប្រុសច្បងម្នាក់នេះបានសិក្សារៀនសូត្រនៅសាលាចំណេះទូទៅ ឱ្យជ្រៅជ្រះខ្ពង់ខ្ពស់ ដើម្បីចូលប្រលូកក្នុងកិច្ចការសង្គមនឹងគេ។

ទីបំផុត ម្តាយឪពុក ក៏ជំរុញ និងលើកទឹកចិត្តឱ្យគាត់ចូលរៀនថ្នាក់ទី៩(ស្មើថ្នាក់ទី៤បច្ចុប្បន្ន)ឆ្នាំសិក្សា១៩៦៤-៦៥ នៅសាលាបឋមសិក្សាវត្តកំចាយមារ ស្ថិតនៅក្នុងឃុំក្រញូងស្រុកកំចាយមារ បន្តទៀត ព្រោះនៅសាលាបឋមសិក្សាវត្តកំចាយមារនោះ មានបង្រៀនសិស្សចាប់ពីថ្នាក់ទី១២ រហូតដល់ថ្នាក់ទី៧ (ស្មើថ្នាក់ទី៦ បច្ចុប្បន្ន) ជាថ្នាក់ត្រូវបញ្ចប់ការសិក្សានៅថ្នាក់បឋមភូមិ។

បើធ្វើដំណើរពីភូមិអណ្តូងស្អាត ទៅទិសខាងលិច ទីតាំងសាលាបឋមសិក្សាវត្តកំចាយមារ ឋិតនៅត្រង់ផ្លូវបំបែកជាពីរ ដោយផ្លូវមួយបែកទៅខាងស្តាំដៃ ជាផ្លូវឆ្ពោះទៅទីរួមស្រុកកញ្ជ្រៀច និងផ្លូវមួយទៀត បែកទៅខាងឆ្វេងដៃ ជាផ្លូវឆ្ពោះទៅទីរួមស្រុកកំចាយមារ មានចម្ងាយពីផ្ទះរបស់គាត់ប្រហែល៥គីឡូម៉ែត្រ។

សម័យឆ្នាំ១៩៦៤-៦៥នោះ តាមដងផ្លូវ(ផ្លូវជាតិលេខ៨)ពីផ្ទះទៅសាលាបឋមសិក្សាវត្តកំចាយមារ កុំថាឡើយដល់ទៅមានកង់ជិះ សូម្បីតែទ្រនាប់ជើង ក៏កុមារ ស ខេង គ្មានពាក់ផង។ គាត់ត្រូវដើរទៅរៀនដោយបាតជើងទទេ ចេញពីភូមិអណ្តូងស្អាត កាត់តាមផ្លូវលំនៅកណ្តាលព្រៃ ដែលនៅរដូវវស្សាមានភ្លៀងធ្លាក់ លំបាកធ្វើដំណើរណាស់ ពេលខ្លះរអិលដួលកប់ភក់ ប្រឡាក់ខោអាវឡើងខ្មៅកខ្វក់។ តែបើនៅរដូវប្រាំង រាំងស្ងួតវិញ ផ្លូវ ត្រូវបែកខ្សាច់ដោយសារការបររទេះគោក្របី ពេលដើរទៅសាលា ធូលីដីហុយមកប្រឡាក់ឡើងសស្រមកតាំងពីខ្នងជើងរហូតដល់ក្បាលជង្គង់ ។

តែទោះបីផ្លូវឆ្ងាយ ពិបាកធ្វើដំណើរយ៉ាងណា ក៏កុមារម្នាក់នេះតាំងចិត្តជាស្រេចហើយថា ត្រូវតែខិតខំសិក្សារៀនសូត្រឱ្យបានចេះដឹងខ្ពង់ខ្ពស់ សមតាមបំណងរបស់ម្តាយឪពុកផង និងដើម្បីអនាគតខ្លួនឯងផងដែរ។

សូមបញ្ជាក់ថា ក្រោយពេលចាកចេញពីភូមិពោធិ៍ទង ឃុំកញ្ជៀច ក្បែរទីតាំងសាលាស្រុកកញ្ជៀច មករស់នៅភូមិអណ្តូងស្អាត ឃុំក្របៅ ស្រុកកំចាយមារ ជាស្រុកកំណើតរបស់គាត់វិញ កាលពីឆ្នាំ១៩៥១នោះ ម្តាយឪពុករបស់កុមារស ខេង មិនទាន់មានលទ្ធភាពសាងសង់ផ្ទះ ដើម្បីស្នាក់នៅឱ្យបានសមរម្យនឹងគេនៅឡើយទេ គឺគ្រួសារគាត់រស់នៅក្នុងផ្ទះមួយ សសរធ្វើពីកូនដើមឈើតូចៗ បាំងជញ្ជាំង និងប្រក់ដំបូល ដោយកណ្តបស្លឹកត្នោតប៉ុណ្ណោះ។

រហូតដល់ឆ្នាំ១៩៦៥ ម្តាយឪពុកគាត់ក៏នៅតែមិនអាចសន្សំប្រាក់កាសគ្រប់គ្រាន់ ដើម្បីសាងសង់ផ្ទះសមរម្យមួយដូចបំណងប្រាថ្នាបានដែរ។ តែដោយអាណិតកូនលំបាកដើរទៅរៀនឆ្ងាយពេក ម្តាយឪពុកគាត់ក៏បានសម្រេចចិត្តដកប្រាក់ដែលខំសន្សំទុកសាងសង់ផ្ទះជាយូរឆ្នាំមកហើយនោះ ចំនួន៧០០រៀល យកទៅទិញកង់ជំនំមួយគ្រឿង ផលិតនៅប្រទេសចិន ដើម្បីឱ្យគាត់ជិះទៅរៀននៅសាលាបឋមសិក្សាវត្តកំចាយមារនោះ កុំឱ្យលំបាកដើរទៀត។

ប៉ុន្តែ កង់នោះលំបាកជិះណាស់ ដោយសារម្យ៉ាងវាធ្ងន់ពេក និងម្យ៉ាងទៀត គាត់ក៏នៅតូចជើងខ្លី ជាន់ឈ្នាន់មិនដល់។ ពេលខ្លះ ជិះទៅ ត្រូវដួលច្រងាប់ច្រងិលតែម្នាក់ឯង ក៏មាន។

ដោយសារឃើញកូនពិបាកជិះកង់ពីផ្ទះនៅភូមិអណ្តូងស្អាត ឃុំក្របៅ ទៅរៀននៅសាលាបឋមសិក្សាវត្តកំចាយមារ នៅឯឃុំក្រញូង ដែលមានចម្ងាយប្រមាណ៥គីឡូម៉ែត្រនោះ កសិករ ស ប៊ិត ជាឪពុក ក៏បានទៅថ្វាយបង្គំព្រះតេជគុណព្រះគ្រូចៅអធិការវត្ត ព្រះនាមជា សុំឱ្យកុមារ ស ខេង ជាកូនបានស្នាក់នៅក្នុងវត្តកំចាយមារ ដើម្បីងាយស្រួលក្នុងការសិក្សា ព្រោះសាលាដែលគាត់រៀននោះ ក៏ឋិតនៅក្នុងវត្តមួយនេះស្រាប់ដែរ ពិសេសចំណេញពេលវេលា និងមិនពិបាកជិះកង់ទៅរៀនជាប់ភក់ល្បាប់នៅរដូវវស្សាដូចមុនទៀត ។

ព្រះគ្រូចៅអធិការវត្តកំចាយមារ ក៏មិនចង្អៀតចង្អល់អ្វីឡើយ ព្រះអង្គក៏បានអនុញ្ញាត

ឲ្យកុមារ ស ខេង ស្នាក់នៅដោយទឹកព្រះទ័យជ្រះថ្លា។ ប៉ុន្តែបញ្ហាអង្ករ និងម្ហូបអាហារផ្សេងៗ ត្រូវដោះស្រាយដោយខ្លួនឯង លើកលែងតែពេលមានបុណ្យទានក្នុងវត្តម្តងៗ ចង្ហាន់នៅសល់ពីព្រះសង្ឃឆាន់ កុមារស ខេង ក៏ដូចជាកូនសិស្សទាំងអស់ដែលស្នាក់នៅក្នុងវត្ត អាចទទួលទានបាន ដោយមិនចាំបាច់ដាំបាយ និងរកម្ហូបខ្លួនឯងទេ។

អំឡុងពេលស្នាក់នៅ ដើម្បីរៀនសូត្រនៅសាលាបឋមសិក្សាវត្តកំចាយមារនោះ ជារៀងល្ងាចថ្ងៃសៅរ៍ គាត់ត្រូវធ្វើដំណើរទៅយកស្បៀងអាហារពីផ្ទះនៅភូមិអណ្តូងស្អាត ឃុំក្របៅ និងឆ្លៀតពេលជួយធ្វើការងារឪពុកម្តាយក្រុមគ្រួសារផងដែរ។ លុះដល់ថ្ងៃព្រឹកថ្ងៃចន្ទ ពេលភ្លឺស្រាងៗ ត្រូវយកអង្ករម្ហូបអាហារពីផ្ទះ ត្រលប់មកវត្តកំចាយមារវិញ ដើម្បីចូលរៀនឱ្យទាន់ពេលវេលា។

ពេលស្នាក់នៅវត្តកំចាយមារនោះដែរ មិត្តភក្តិទាំងអស់ ក៏ដូចជាព្រះសង្ឃគង់នៅក្នុងវត្តដែរ មានការប្រាស្រ័យទាក់ទងស្រលាញ់រាប់អានគ្នា ប្រៀបដូចជាបងប្អូន។ ពេលបានចំណីអាហារណាឆ្ងាញ់ តែងតែរំលែកចែកគ្នាទទួលទានទៅវិញទៅមក។ លើសពីនេះទៅទៀត សូម្បីលោកគ្រូៗដែលផ្លាស់ពីស្រុកខេត្តឆ្ងាយៗ មកស្នាក់នៅក្នុងវត្តនោះដែរ ដូចជាលោកគ្រូញ៉ែន និងលោកគ្រូធឹង មកពីខេត្តតាកែវ ព្រមទាំងលោកគ្រូយ៉ុន មានស្រុកកំណើតនៅក្នុងខេត្តព្រៃវែងដែរ តែនៅឆ្ងាយពីស្រុកកំចាយមារ ជាដើម ពេលខ្លះ លោកគ្រូៗទាំងអស់នោះ ក៏បានមកទទួលទានបាយជុំគ្នាជាមួយពួកគាត់ជាសិស្សដែរ។

ដោយសារតែជីវិតក្មេងវត្តនេះដែរ កុមារ ស ខេង ក៏បានទទួលនូវការទូន្មានប្រៀនប្រដៅអំពីសីលធម៌ គុណធម៌ពីសំណាក់ព្រះសង្ឃ អាចារ្យ និងពីចាស់ទុំក្នុងវត្តជាបន្តបន្ទាប់ ធ្វើឱ្យគាត់កាន់តែមានចរិតឫកពាស្លូតបូតរមទមថែមទៀត និងបានយល់ដឹងពីតម្លៃនៃពុទ្ធសាសនា វប្បធម៌ប្រពៃណីទំនៀមទម្លាប់ខ្មែរផងដែរ។

ក្រៅពីការខិតខំសិក្សា កុមារស ខេង ក៏បានចូលរួមយ៉ាងសកម្មការងារក្នុងវត្តអារាម ដូចជា បោសសម្អាតទីធ្លាវត្ត ដងទឹកដាក់ពាង និងកិច្ចការវត្តផ្សេងៗទៀត ហើយទទួលបាននូវការកោតសរសើរពីសំណាក់ព្រះសង្ឃ និងពុទ្ធបរិស័ទចំណុះជើងវត្តថា ជាក្មេងឧស្សាហ៍

ព្យាយាម សុភាពរាបសាគួរឱ្យស្រលាញ់រាប់អាន។

បើនិយាយពីក្នុងចំណោមសិស្សដូចគ្នានៅសាលាវត្តកំចាយមារ នោះវិញ មិនថាតែមិត្តរួមថ្នាក់ទេ សូម្បីតែពួកសិស្សប្អូនដែលរៀនថ្នាក់ក្រោមគាត់ និងពួកសិស្សច្បងដែលរៀនថ្នាក់លើគាត់ ក៏លាន់មាត់សរសើរថា កុមារ ស ខេង ឧស្សាហ៍ព្យាយាមសិក្សារៀនសូត្រទាំងថ្ងៃទាំងយប់ រហូតក្លាយជាសិស្សពូកែស្ទើរតែគ្រប់មុខវិជ្ជា។

# ១៩៦
# ពេលទៅព្រៃជាមួយឪពុក សាច់មាន់ឆាខ្ញី ស្នាដៃម៉ែ មិនអាចបំភ្លេចបាន



**លោកតាស ប៊ិត និងលោកយាយម៉ក់ សែម ឪពុកម្តាយកុមារស ខេង**

ក្នុងឆ្នាំ១៩៦៤ ឪពុកម្តាយកុមារ ស ខេង មានគម្រោងសាងសង់ផ្ទះឈើមួយតាមរបៀបផ្ទះខ្មែរពីបុរាណ ទំហំ៨ម៉ែត្រគុណនឹង៨ម៉ែត្រ មានជំបូល២ខ្នង និងជើងសសរ២ម៉ែត្រ ដាក់កំណល់ជើងតាងស៊ីម៉ងត៍កន្លះម៉ែត្រទៀត មានកម្ពស់ពីដី ២ម៉ែត្រកន្លះ។

ដើម្បីសាងសង់ផ្ទះឈើជំបូល២ខ្នងនោះ ឪពុកគាត់ត្រូវការសសរចំនួន១៦ដើម ហើយបើតាមជំនឿខ្មែរពីបុរាណ ចាស់ៗតម្រូវឱ្យយកដើមកកោះ ចំនួន១៥ដើម និងដើមសំព័រ ចំនួន ១ដើម មិនឱ្យយកដើមកកោះមកធ្វើសសរផ្ទះទាំង១៦ដើមទេ គឺត្រូវយកដើមឈើ១ដើម ផ្សេងទៀត ក្រៅពីដើមកកោះនោះ មកធ្វើជាសសររួមគ្នា បើមិនដូច្នេះទេ ម្ចាស់ផ្ទះនោះ

រស់នៅមិនបានសុខសប្បាយទេ គឺអាចជួបនឹងគ្រោះឧបទ្រពចង្រៃផ្សេងៗជាមិនខាន។

ពេលនោះ ម្ដាយឪពុកគាត់មិនមែនពឹងផ្អែកតែទៅលើប្រាក់កាសដែលខំសន្សៃសន្សំ យកទៅទិញឈើគេយកមកសាងសង់ឱ្យរួចរាល់ភ្លាមៗនោះបានទេ គឺឪពុកគាត់ត្រូវបររទេះក្របី ឆ្លងពីស្រុកកំចាយមារ ខេត្តព្រៃវែង ចូលទៅដល់ព្រៃជ្រៅ នៅក្នុងស្រុករមាសហែក ខេត្តស្វាយរៀង ដើម្បីរកកាប់ដើមឈើល្អៗ យកមកធ្វើជាសសរ។

ទាក់ទងអនុស្សាវរីយ៍ពីរឿងជិះរទេះក្របីចូលព្រៃជ្រៅជាមួយឪពុក ទៅដឹកសសរដើមឈើមកធ្វើផ្ទះនេះ ស ខេង បានរម្លឹកថា៖ ក្នុងអំឡុងពេលចាប់ផ្តើមគម្រោងសាងសង់ផ្ទះថ្មីនោះ ឪពុកគាត់ត្រូវជិះរទេះក្របីទៅដឹកសសរនៅក្នុងព្រៃជ្រៅមួយ ស្ថិតនៅក្នុងឃុំអណ្តូងត្របែក ស្រុករមាសហែក ខេត្តស្វាយរៀង មានចម្ងាយប្រហែល៧ ទៅ៨ គីឡូម៉ែត្រពីផ្ទះគាត់នៅភូមិអណ្តូងស្អាត ប៉ុណ្ណោះ។ ប៉ុន្តែការធ្វើដំណើរតាមរទេះក្របី កាត់ព្រៃ និងឆ្លងស្ទឹងផងដែរ ត្រូវចំណាយពេលតាំងពីព្រលឹមស្រាងៗ រហូតដល់ជិតថ្ងៃត្រង់ ទើបទៅដល់គោលដៅ។

ក្នុងមួយជើងៗ រទេះក្របីរបស់ឪពុកគាត់ ដឹកសសរដើមកកោះ បានតែ២ដើមប៉ុណ្ណោះ។ ដូច្នេះ ទម្រាំចូលព្រៃកាប់ និងដឹកសសរដើមកកោះ ចំនួន១៥ដើម និងសសរដើមសំព័រចំនួន ១ដើម ឪពុកគាត់ត្រូវប្រើរយៈពេល៣ឆ្នាំ។ នេះគិតតាំងពីការដឹកដើមឈើផ្សេងៗទៀត មកអារធ្វើជាផ្ទោង ផ្ដាន រនុក រនូត ផងដែរ។

ស ខេង បានបន្តថា ក្នុងអំឡុងឆ្នាំ១៩៦៤ ពេលកំពុងសិក្សានៅថ្នាក់ទី១០ សាលាបឋមសិក្សាវត្តក្របៅ មានថ្ងៃមួយ គាត់បានសុំឪពុកជិះរទេះក្របីជាមួយ ដើម្បីចូលព្រៃជ្រៅទៅដឹកសសរនោះ បានម្ដងដែរ។ ពេលនោះ ក៏មានលោកជំទប់ទី១ ឃុំក្របៅ ឈ្មោះហ៊ឹម និងអ្នកភូមិ៤-៥នាក់ទៀត ក៏បានបររទេះក្របីទៅជាមួយ ដើម្បីដឹកសសរដើមកកោះ មកធ្វើផ្ទះរបស់ពួកគេដែរ។

ពេលទៅដល់ក្បែរព្រំដែនប្រទេសកម្ពុជា និងវៀតណាម មានស្ទឹងមួយ ដូច្នេះពួកគាត់ត្រូវបររទេះក្របីឆ្លងកាត់ស្ទឹងនោះ ទើបចូលទៅដល់ព្រៃជ្រៅ នៅក្នុងឃុំអណ្តូងត្របែក ស្រុករមាសហែក ខេត្តស្វាយរៀង ជាកន្លែងដឹកសសរនោះ។

## របត់នយោបាយ

ក្រោយពីនាំគ្នាលើកសសរដើមកកោះដាក់លើរទេះ ចងនឹងខ្សែព្រ័ត្រយ៉ាងណែនរួចរាល់គ្រប់គ្នាហើយ ពួកគាត់ក៏នាំគ្នាបររទេះក្របីកាត់ព្រៃ ដើម្បីឆ្លងស្ទឹងដែលនៅរដូវប្រាំង ទឹកស្រករាក់នៅត្រឹមក្បាលជង្គង់ ឬចង្កេះ វិលត្រលប់មកផ្ទះវិញ។ ពេលឡើងចំណោតនៅមាត់ច្រាំងស្ទឹង ដោយសារខ្លាចរទេះផ្ទុកសសរដើមកកោះ២ដើមនោះ រអិលថយមកក្រោយវិញ ឪពុកគាត់ក៏ស្រែកបង្អុះដើម្បីបំបោលក្របីឲ្យប្រឹងទាញរទេះឡើងទៅលើមាត់ច្រាំង។

តែដោយសារកង់រទេះម្ខាងឡើងទៅចំលើដីទួលខ្ពស់បន្តិច បណ្តាលឱ្យរទេះឪពុកគាត់ក្លូកបះជើង។ ប៉ុន្តែ សំណាងល្អ គាត់ និងឪពុកមិនមានគ្រោះថ្នាក់អ្វីឡើយ ហើយសសរទាំង២ដែលចងផ្អោបជាប់នៅរទេះនោះ ក៏មិនដាច់ពីចំណងដែរ។

ភ្លាមៗនោះ ជំទប់ទី១ ឃុំក្របៅ ឈ្មោះហ៊ឹម និងអ្នកភូមិជាម្ចាស់រទេះក្របី ៤-៥នាក់ទៀត ដែលរួមដំណើរជាមួយគ្នា ក៏រត់ស្ទុះស្ទារមកជួយលើករទេះបញ្ឈរវិញដែរ។ តែលើកមិនរួច ចាំបាច់ត្រូវតែនាំគ្នាស្រាយចំណង និងលើកសសរចេញពីរទេះសិន ទើបអាចលើករទេះបញ្ឈរឡើងវិញបាន រួចនាំគ្នាលើកសសរដាក់លើរទេះ និងចងរឹតឱ្យជាប់ដូចដើមវិញ។

ស ខេង បញ្ជាក់ថា៖ ពេលនោះ ខ្ញុំអាយុប្រហែល១៣-១៤ឆ្នាំ បានត្រឹមតែជួយលើករទេះ និងសសរនោះបន្តិចបន្តួចប៉ុណ្ណោះ។ លុះលើកសសរដាក់លើរទេះ និងចងឱ្យជាប់រួចរាល់ហើយ ក៏ជុំគ្នាហូបបាយដោយសប្បាយរីករាយ។ ខ្ញុំបើកកញ្ចប់បាយ ដែលម្តាយខ្ញុំរៀបចំឱ្យមកពីផ្ទះ ឃើញឆាសាច់មាន់ជាមួយខ្ញី...។ កំពុងតែហត់ផង ឃ្លានផង ពេលនោះបានសាច់មាន់ឆាខ្ញី ស្នាដៃម៉ែ ពិតជាឆ្ងាញ់មែនទែន ដែលមួយជីវិតនេះ ខ្ញុំចងចាំជានិច្ច មិនអាចបំភ្លេចបានឡើយ។

ស ខេង បញ្ជាក់បន្ថែមថា៖ ទម្រាំសាងសង់ផ្ទះមួយមានដំបូល២ខ្នង ប្រក់ស្លឹកត្នោតជញ្ជាំងស្លឹកត្នោត និងរនាបឫស្សី កម្ពស់ពីដី២ម៉ែត្រកន្លះ(គិតទាំងជើងតាង) បណ្តោយ ៨ម៉ែត្រ និងទទឹង៨ម៉ែត្រ ឪពុកគាត់ត្រូវប្រើរយៈពេលដល់ទៅ៣ឆ្នាំ គឺចាប់ផ្តើមចូលព្រៃជ្រៅទៅកាប់ដើមកកោះធ្វើសសរ តាំងពីឆ្នាំ១៩៦៤ រហូតដល់ឆ្នាំ១៩៦៧ ទើបហើយរួចរាល់ បានប្រពន្ធកូនរស់នៅសមរម្យនឹងគេ។

ក្រោយមក ឪពុកម្តាយគាត់ខំប្រឹងរកស៊ីធ្វើស្រែសន្សៃសន្សំប្រាក់កាស រហូតមានលទ្ធភាពរុះរើដំបូលប្រក់ស្លឹកត្នោតនោះចេញ ហើយប្រក់ក្បឿងជំនួសទាំង២ខ្នងវិញ តែជញ្ជាំងនៅតែប្រើកណ្តាបស្លឹកត្នោតវាយដែកគោលគាបជាមួយបន្ទះឫស្សី ដដែល។

ក្រុមគ្រួសារគាត់រស់នៅក្រោមដំបូលផ្ទះក្បឿង២ខ្នងនោះយ៉ាងសុខសាន្ត រហូតដល់ប្រទេសជាតិមានព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ហើយភ្លើងសង្គ្រាមក៏ចាប់ផ្តើមឆាបឆេះឡើង។

# ១៩៧
# អនុវិទ្យាល័យកំចាយមារ ជាកន្លែងតស៊ូដើម្បីចំណេះ



**ទីតាំងអនុវិទ្យាល័យកំចាយមារ**
**បច្ចុប្បន្នក្លាយជាសាកលវិទ្យាល័យជា ស៊ីម កំចាយមារ**

នៅសាលាបឋមសិក្សាវត្តកំចាយមារ កុមារស ខេង រៀនថ្នាក់ទី៩ (ស្មើថ្នាក់ទី៤ បច្ចុប្បន្ន) នៅឆ្នាំសិក្សា១៩៦៤-៦៥, រៀនថ្នាក់ទី៨ (ស្មើថ្នាក់ទី៥ បច្ចុប្បន្ន) នៅឆ្នាំសិក្សា១៩៦៥-៦៦ និងរៀនថ្នាក់ទី៧ (ស្មើថ្នាក់ទី៦ បច្ចុប្បន្ន) នៅឆ្នាំសិក្សា១៩៦៦-៦៧។ ឆ្នាំសិក្សាទាំង៣ថ្នាក់នេះ គាត់ទទួលបានលទ្ធផលល្អគួរឱ្យកោតសរសើរ។

ពិសេស ក្រោយបញ្ចប់ការសិក្សាថ្នាក់ទី៧ ឆ្នាំសិក្សា១៩៦៦-៦៧ គាត់បានប្រលងជាប់ចូលរៀនថ្នាក់ទី៦ទំនើបជាតិ (ឆ្នាំសិក្សា១៩៦៧-៦៨) នៅអនុវិទ្យាល័យកំចាយមារ ធ្វើឱ្យម្ដាយឪពុកគាត់សប្បាយរីករាយជាទីបំផុត។

អនុវិទ្យាល័យមួយនេះ ត្រូវបានបង្កើតឡើងដំបូងគេ នៅក្នុងស្រុកកំចាយមារ នាឆ្នាំ១៩៦៦ មានអគារ២ខ្នង ក្នុងមួយខ្នងៗចែកចេញជា៣បន្ទប់ សរុបទាំងអស់មាន៦បន្ទប់ ក្នុងនោះ ១បន្ទប់ យកធ្វើជាទីចាត់ការ។

អនុវិទ្យាល័យកំចាយមារ មានទីតាំងនៅក្នុងភូមិដោរ ឃុំស្មោងខាងជើង ចម្ងាយប្រមាណជា១០គីឡូម៉ែត្រ ពីភូមិអណ្ដូងស្អាត ជាភូមិកំណើតរបស់យុវជន ស ខេង គឺឆ្ងាយជាងកាលរៀននៅសាលាបឋមសិក្សាវត្តកំចាយមារ ប្រមាណជា៥គីឡូម៉ែត្រថែមទៀត ។ តែយុវជនវ័យជំទង់រូបនេះនៅតែមានឆន្ទៈមោះមុតក្នុងការសិក្សា ទោះបីអនុវិទ្យាល័យនៅឆ្ងាយយ៉ាងណាក៏មិនមែនជាឧបសគ្គ ដែលត្រូវរាថយនោះឡើយ។

ដើម្បីសម្រួលដល់ការរៀនសូត្រនៅអនុវិទ្យាល័យកំចាយមារ ដែលនៅឆ្ងាយពីផ្ទះដល់ទៅចម្ងាយប្រមាណ១០គីឡូម៉ែត្រនោះ ដោយមានការយល់ព្រមពីឪពុកម្ដាយផងដែរ យុវជន ស ខេង ក៏បានរួមគ្នាជាមួយយុវសិស្សចំនួន៩នាក់ទៀត ដែលទើបតែប្រលងជាប់ចូលរៀនថ្នាក់ទី៦ ទំនើបជាតិដូចគ្នា នៅក្នុងនោះមានមិត្តភក្តិខ្លះមកពីឃុំក្របៅ ជាមួយគ្នា និងខ្លះទៀតមកពីឃុំផ្សេងៗទៀត មកជួលផ្ទះមួយ ដែលម្ចាស់ខណ្ឌចែកផ្ទះជាពីរល្វែង គឺម្ខាងគ្រួសារម្ចាស់ផ្ទះទុកស្នាក់នៅខ្លួនឯង និងម្ខាងទៀតជួលឱ្យពួកគាត់ស្នាក់នៅរួមគ្នា ដើម្បីរៀនសូត្រ។

ម្ចាស់ផ្ទះនោះ ឈ្មោះតាខ្មៅ មានដើមកំណើតជាជនជាតិចិន នៅភូមិជោរ៍។ គាត់យកថ្លៃឈ្នួលផ្ទះ ក្នុងមួយខែ តែ១០០រៀលប៉ុណ្ណោះ ទោះបីសិស្សស្នាក់នៅប៉ុន្មាននាក់ ក៏ដោយ។

ចម្ងាយផ្លូវពីផ្ទះជួលនោះ ទៅអនុវិទ្យាល័យកំចាយមារ ដែលពួកគាត់ទៅរៀននោះមានប្រវែងប្រហែលតែ៥០០ម៉ែត្រប៉ុណ្ណោះ។ តែលើកំណាត់ផ្លូវខ្លីនេះ មានស្ពានពីរ គឺស្ពានធំមួយធ្វើពីដែកបែឡេ ប្រវែងប្រហែល៣០ម៉ែត្រ និងស្ពានឈើតូចមួយទៀត ធ្វើរបៀបជាស្នូ មានប្រវែងប្រហែល៦-៧ ម៉ែត្រ។ ពេលមានភ្លៀងធ្លាក់ម្តងៗនៅលើកំណាត់ផ្លូវនេះ បែកភក់ល្បាប់ ដើរមិនស្រួលរអិលដួលអុកគូទមិនខាន។ បើអ្នកជិះកង់វិញ ត្រូវជាប់ភក់ មិនអាចជិះបានទេ ទាល់តែលើកកង់លីដាក់លើស្មា ទើបធ្វើដំណើរទៅមុខបាន។

កាលនោះ ទីតាំងភូមិសាស្ត្រនៅត្រង់អនុវិទ្យាល័យកំចាយមារ (បច្ចុប្បន្ន ក្លាយជាវិទ្យាល័យហ៊ុន សែន កំចាយមារ និងសាកលវិទ្យាល័យជា ស៊ីម កំចាយមារ) ស្ថិតនៅក្បែរមាត់ស្ទឹងជោរ៍។ ជារៀងរាល់ឆ្នាំ នៅរដូវវស្សា ស្ទឹងនេះមានទឹកហូរក្ដួចត្របាញ់ធ្លាក់ទៅតាមបណ្ដោយស្ទឹងដល់ទីរួមស្រុករមាសហែក ខេត្តស្វាយរៀង។

មិត្តភក្តិដែលស្នាក់នៅផ្ទះជួលជាមួយយុវជន ស ខេង ពេលនោះ រួមមាន ស្បោង សារ៉ាត, សឿង ហេន ហៅហៃ, កន ចែម ជាកូនមេឃុំក្របៅ, ហ៊ឹម ញ៉ិល (ជាកូនជំទប់ទី១ឃុំក្របៅ ឈ្មោះហ៊ឹម ដែលធ្លាប់បររទេះក្របីទៅដឹកសសរដើមកកោះ យកមកធ្វើផ្ទះ ជាមួយឪពុក ស ខេង កាលពីឆ្នាំ១៩៦៤), ធឹង និង ធុន (ពីរនាក់បងប្អូនបង្កើតជាកូនប្រជាជនធម្មតា), មម ឡាង អ្នកភូមិអណ្ដូងស្អាត ជាមួយគ្នា, ស៊ី និងឈ្មោះកូយ ជាដើម។ បច្ចុប្បន្ន មិត្តភក្តិដែល



**ទីតាំងអតីតផ្ទះតាខ្មែរ ដែលយុវជនស ខេង និងមិត្តភក្តិ ធ្លាប់ជួលស្នាក់នៅ**

ស្នាក់នៅផ្ទះជួលជាមួយយុវជន ស ខេង នៅរស់តែ២នាក់ប៉ុណ្ណោះ គឺ ស្បោង សារ៉ាត បច្ចុប្បន្នជាប្រធានក្រុមប្រឹក្សាខេត្តព្រៃវែង និងកូយ។

ដូចកាលនៅរៀនថ្នាក់ទី៩, ថ្នាក់ទី៨ និងថ្នាក់ទី៧ នៅសាលាបឋមសិក្សាវត្តកំចាយមារដែរ គឺនៅល្ងាចថ្ងៃសៅរ៍ យុវជនស ខេង តែងតែធ្វើដំណើរទៅផ្ទះនៅភូមិអណ្តូងស្អាត ឃុំក្របៅ ដើម្បីជួយធ្វើការម្តាយឪពុកផង និងយកអង្ករ ព្រមទាំងម្ហូបអាហារមួយចំនួន ដូចជាក្តាមប្រៃ និងស្ពៃជ្រក់ ជាដើម មកទុកទទួលទានក្នុងពេលស្នាក់នៅរៀនសូត្រនៅអនុវិទ្យាល័យកំចាយមារនោះ ជារៀងរាល់សប្តាហ៍។

ជាធម្មតា ក្តាមប្រៃ និងស្ពៃជ្រក់ គឺជាអាហារប្រចាំថ្ងៃដ៏មានឱជារស និងបាំបាច់បំផុតសម្រាប់យុវជនស ខេង និងមិត្តភក្តិស្នាក់នៅជាមួយ។ ប៉ុន្តែយូរៗម្តង ពួកគាត់បានរៃអង្គាសប្រាក់គ្នា ដើម្បីទិញស៊ុបគុយទាវ យកមកទទួលទាន ដើម្បីឲ្យបានឆ្ងាញ់មាត់ម្តងម្កាលដែរ។

ក្រោយពីស្នាក់នៅផ្ទះជួលរួមគ្នា មិនបានប៉ុន្មានផង ដោយសង្កេតឃើញថា យុវជន ស ខេង ជាកូនកសិករក្រីក្រ តែមានចរិតឫកពាស្លូតបូតសុភាពរាបសា និងព្យាយាមយក

ចិត្តទុកដាក់ក្នុងការរៀនសូត្រទៀតនោះ  ធ្វើឱ្យយុវសិស្សទាំង៩នាក់ដែលស្នាក់នៅផ្ទះជួលជាមួយ កាន់តែអាណិតស្រលាញ់រាប់អានយុវជនស ខេង ជិតស្និទ្ធឡើងៗ រហូតដល់លែងឱ្យគាត់ចេញថ្លៃឈ្នួលផ្ទះ ដោយពួកគេនាំគ្នាជានាជួយចេញជំនួសទៀតផង។ មិនតែប៉ុណ្ណោះពួកគេតែងកោតសរសើរពីប្រាជ្ញាឈ្លាសវៃរបស់យុវជនសិស្ស ស ខេង ថា ឱ្យតែសាស្ត្រាចារ្យបង្រៀនពន្យល់មុខវិជ្ជា ឬមេរៀនអ្វីមួយ គាត់តែងតែចាប់បាន ចាំចេះជានិច្ច។

លើសពីនេះទៅទៀត ទោះបីគាត់ចូលចិត្តសិក្សាមុខវិជ្ជាអក្សរសាស្ត្រ និងប្រវត្តិសាស្ត្រក៏ពិតមែន តែនៅពេលណាមិត្តភក្តិទាំងនោះមានចម្ងល់ ឬមិនយល់ពីមេរៀន ឬមុខវិជ្ជាណាមួយផ្សេងទៀត គាត់តែងតែយកចិត្តទុកដាក់ជួយពន្យល់ ដោយគ្មានអល់អែក ឬលាក់លៀមអ្វីបន្តិចឡើយ។ សូម្បីតែសាស្ត្រាចារ្យនៅក្នុងអនុវិទ្យាល័យ ក៏នាំគ្នាកោតសរសើរពីប្រាជ្ញាឈ្លាសវៃរបស់គាត់មិនដាច់ពីមាត់ដែរ។

កត្តាដូចខាងលើនេះហើយ ដែលកាន់តែជំរុញទឹកចិត្តយុវសិស្សស ខេង ឱ្យកាន់តែប្រឹងប្រែងព្យាយាមថែមទៀត ហើយប្តេជ្ញាក្នុងចិត្តតាំងពីពេលនោះមកថា នឹងខិតខំបន្តការរៀនសូត្ររហូតដល់ចប់ថ្នាក់ឧត្តមសិក្សា។

# ១៩៨
# យុវជន ស ខេង ចូលជាសមាជិកចលនាយុវជនរាជសង្គមនិយមខ្មែរ



**ឯកសណ្ឋានចលនាយុវជនរាជសង្គមនិយមខ្មែរ**

ពេលយុវជនស ខេង ចូលរៀនថ្នាក់ទី៦ទំនើបជាតិឆ្នាំសិក្សា១៩៦៧-៦៨នោះ គេតម្រូវឱ្យចូលជាសមាជិកចលនាយុវជនរាជសង្គមនិយមខ្មែរ ដែលពាក្យសាមញ្ញហៅថាយុវ៉ែ ដូចយុវជន-យុវនារីនៅតាមអនុវិទ្យាល័យ, វិទ្យាល័យ, មហាវិទ្យាល័យ, សាកលវិទ្យាល័យ ក៏ដូចជាមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៅទូទាំងប្រទេសដែរ។

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៥៥ សម្តេចសីហនុ បានបង្កើតចលនាមួយ ហៅថាចលនាសង្គមរាស្ត្រនិយម ហើយព្រះអង្គក៏គង់ជាព្រះប្រធានចលនានេះផងដែរ។ ក្រោយចលនាសង្គមរាស្ត្រនិយមរបស់ព្រះអង្គឈ្នះឆ្នោត ឡើងកាន់អំណាចក្នុងឆ្នាំ១៩៥៥មក នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៥៧ ព្រះអង្គក៏បានបង្កើតអង្គការមួយ ហៅថា ចលនាយុវជនរាជសង្គមនិយមខ្មែរ (JSRK = Jeuness Siocialiste Royal Khmer) ហៅខ្លីថា យុវ៉ែ។

ដើម្បីចូលជាសមាជិករបស់ចលនាយុវជនរាជសង្គមនិយមខ្មែរ (JSRK = Jeuness Siocialiste Royal Khmer) ឬយុវ៉ែនេះ ចាំបាច់ត្រូវមានប័ណ្ណសំគាល់ មានបិទរូបថតពាក់

ឯកសណ្ឋានយុវនៃត្រឹមត្រូវដែរ។

ពេលនោះផ្សារដោវ៍ ទីរួមស្រុកកំចាយមារ ពុំមានហាងថតរូបទេ ដូច្នេះដើម្បីបានរូបថតពាក់ឯកសណ្ឋាននឹងគេ យុវជនស ខេង ត្រូវធ្វើដំណើរដោយជិះកង់ម្នាក់ឯងតាមផ្លូវដីដ៏លំបាក ពីទីរួមស្រុកកំចាយមារ ទៅទីរួមខេត្តព្រៃវែង ក្នុងចម្ងាយប្រហែល៤៥គីឡូម៉ែត្រ។

គាត់ត្រូវចេញដំណើរពីផ្ទះជួលរបស់តាខ្មែរ នៅភូមិដោវ៍ ឃុំស្មោងខាងជើង ស្រុកកំចាយមារនោះ តាំងពីម៉ោង៦ព្រឹក រហូតដល់ម៉ោង១១ និង៣០នាទី ទើបដល់ទីរួមខេត្តព្រៃវែង។ ពេលទៅដល់ គាត់ក៏មិនដឹងថា ហាងថតរូបនៅត្រង់ណាដែរ ទាល់តែសួរគេ ទើបរកហាងថតរូបនោះឃើញ។

ក្រោយពីរកឃើញហាង និងបានថតរូបរួចហើយ គាត់ក៏សុំម្ចាស់ហាងផ្តិតឲ្យបានលឿនបំផុត ព្រោះគាត់គ្មានស្គាល់បងប្អូនពូមីងសាច់ញាតិណាម្នាក់នៅទីរួមខេត្តព្រៃវែង ដើម្បីស្នាក់នៅដេកចាំយករូបថត ពេលព្រឹកស្អែកនោះទេ។ ម្ចាស់ហាងថតរូប ក៏បានយល់ព្រមផ្តិតរូបថតឲ្យបាននៅថ្ងៃនោះដែរ តែត្រូវប្រើរយៈពេលយូរបន្តិច។

គាត់ទៅទិញបាយហូប ហើយអង្គុយរង់ចាំ រហូតដល់ម៉ោង៣រសៀល ទើបម្ចាស់ហាងផ្តិតរូបថតរួចរាល់។ ក្រោយពីឱ្យប្រាក់ថ្លៃថតរូបមក គាត់ក៏ប្រញាប់ប្រញាល់ឡើងជិះកង់វិលត្រលប់ទៅផ្សារដោវ៍ ទីរួមស្រុកកំចាយមារ វិញ។

ពេលជិះកង់ទៅដល់ភូមិដូនកឹង ឃុំដូនកឹង ស្រាប់តែមានអាការៈមិនស្រួលខ្លួន អស់កម្លាំងល្វិតល្វៃដៃជើង គាត់ក៏ឈប់សម្រាកយកកម្លាំងបន្តិច នៅក្រោមដើមឈើធំមួយ រយៈពេល១០នាទី។ លុះបានស្រួលខ្លួនឡើងវិញបន្តិច គាត់ក៏ឡើងជាក់កង់ទៅមុខបន្តទៀត បានតែមួយភ្លែត ស្រាប់តែចាប់ផ្តើមមានអាការៈអស់កម្លាំងល្វិតល្វៃដៃជើងជាថ្មីម្តងទៀត។

ពេលនោះ គាត់ឃើញតូបលក់ផ្លែចេក និងទឹកម៉ាណាត់( ទឹកម៉ាណាត់នេះ ដបមានរាងកំប៉ោងដូចដប ទឹកត្រចៀកកាំសព្វថ្ងៃ តែរសជាតិវាមិនសូវផ្អែមដូចទឹកក្រូចទេ ) គាត់ក៏ឈប់ សម្រាកនៅក្រោមសំយាបតូបនោះ។ ដោយសល់លុយ១៥រៀលនៅក្នុងហោប៉ៅដែរ គាត់ក៏ទិញចេកទុំបីផ្លែ និងទឹកម៉ាណាត់មួយដប អស់ប្រាក់៥រៀល។ គាត់អង្គុយហូបចេក

# របត់នយោបាយ

បណ្តើរ ដដែកលេងជាមួយនឹងបងស្រីជាអ្នកលក់បណ្តើរ រហូតស្រួលខ្លួនមានកម្លាំងគ្រាន់បើឡើងវិញ ក៏លាបងស្រីជាអ្នកលក់ ធ្វើដំណើរទៅមុខទៀត រហូតដល់ផ្ទះជួលនៅភូមិដោរ៍ ស្រុកកំចាយមារ ដោយសុវត្ថិភាព។

បន្ទាប់មក គាត់ក៏យករូបថតនោះទៅបិទលើកប័ណ្ណសមាជិករបស់ចលនាយុវជនរាជសង្គមនិយមខ្មែរ(កាតយុវ៉ន) ដើម្បីយកទៅឱ្យនាយកអនុវិទ្យាល័យ ដែលជាប្រធានចលនាយុវជនរាជសង្គមនិយមខ្មែរ ប្រចាំអនុវិទ្យាល័យកំចាយមារ ចុះហត្ថលេខា និងបោះត្រាដើម្បីប្រើប្រាស់ជាផ្លូវការ។

# ១៩៩
# កងជីវពល ពួនចាំបាញ់សម្លាប់ឪពុកមារ ជាអ្នកតស៊ូ

នៅពេលយុវជន ស ខេង បានឡើងថ្នាក់ទី៥ទំនើបជាតិ(ឆ្នាំសិក្សា១៩៦៨-៦៩) ម្ដាយឪពុករបស់គាត់ហាក់ដូចជាមានមោទកភាពចំពោះកូនប្រុសម្នាក់នេះខ្លាំងណាស់។ ទោះបីមានជីវភាពក្រលំបាកយ៉ាងណា ម្ដាយឪពុកគាត់បានប្រមែប្រមូលលុយដែលខំសន្សំបានទាំងប៉ុន្មាន យកទៅទិញកង់ម៉ាកប៉ឺហ្សូ ពណ៌ខៀវតួស្រីថ្មីសន្លាងមួយគ្រឿងឱ្យគាត់ជិះ។

ទឹកចិត្តដ៏ថ្លៃថ្លារបស់អ្នកមានគុណនេះ ធ្វើឱ្យយុវជនស ខេង សប្បាយរីករាយយ៉ាងខ្លាំង ហើយកាន់តែខិតខំរៀនសូត្រទ្វេដងថែមទៀត។

ក្រោយពេលទទួលបានកង់ថ្មី ពីអ្នកមានគុណភ្លាម យុវជន ស ខេង ក៏ឡើងជិះសាកល្បងសំដៅទៅទិសខាងលិចបានចម្ងាយពីផ្ទះប្រមាណ៣០០ម៉ែត្រ ក៏ឈប់កង់បញ្ឈរទុកនៅលើផ្លូវ ហើយដើរចូលទៅក្នុងព្រៃ ដើម្បីបត់ជើងតូច។ ចៃដន្យ ស្រាប់តែប្រទះឃើញបុរសម្នាក់មានមាឌធំខ្ពស់ សម្បុរសណ្ដែកបាយ កំពុងកាន់កាំភ្លើងវែងមួយដើម ម៉ាកថុមសុន (Thompson) ដែលមើលទៅហាក់ដូចជាកំពុងឈរពួនចាំលបបាញ់នរណាម្នាក់?។

ពេលនោះ គ្រាន់តែងាកមកឃើញយុវជន ស ខេង ភ្លាម បុរសឈរកាន់កាំភ្លើងនោះក៏គេចខ្លួនបាត់ ទំនងជាខ្លាចយុវជន ស ខេង ស្គាល់អត្តសញ្ញាណរបស់ខ្លួន។ តែទោះបីយ៉ាងណា យុវជន ស ខេង បានស្គាល់អត្តសញ្ញាណច្បាស់ទៅហើយ។

ជននោះឈ្មោះ សឿង គាត់ជាអតីតអ្នកតស៊ូខ្មែរក្រហម ដែលបានសុំចុះចូលជាមួយរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម របស់សម្ដេចសីហនុ កាលពីប៉ុន្មានឆ្នាំកន្លងទៅ ហើយត្រូវបានរាជការអាជ្ញាធរមូលដ្ឋាន តែងតាំងឲ្យគាត់ធ្វើជាកងជីវពលប្រចាំឃុំក្របៅ ដើម្បីតាមដានសកម្មភាពពួកអ្នកតស៊ូខ្មែរក្រហមកំពុងលាក់ខ្លួនក្នុងព្រៃក្បែរៗភូមិនានា នៅក្នុងមូលដ្ឋានឃុំក្របៅ នោះ។

ស ខេង បានរម្លឹកថា៖ កងជីវពលឃុំ ឈ្មោះសឿង ដែលកាន់កាំភ្លើងទៅឈរត្រៀម

នៅក្នុងព្រៃ ក្បែរផ្លូវដែលខ្ញុំឈប់កង់ចុះទៅបត់ជើងតូចនោះ គឺដើម្បីលបចាំមើលអ្នកតស៊ូខ្មែរក្រហមម្នាក់ឈ្មោះ ស ចុន ហៅតឹក ក្រោយពីគេយកការណ៍ដឹងថា មានបំណងនឹងលួចចូលមកទាក់ទងខ្សែរយៈតស៊ូសម្ងាត់នៅក្នុងភូមិអណ្តូងស្អាត... ។

ស ចុន ហៅតឹក នេះ ជាប្អូនបង្កើតរបស់ឪពុកខ្ញុំ គ្រាន់តែម្តាយផ្សេងគ្នា។ កងជីវពលឃុំ ឈ្មោះសឿង ចាំឃ្លាំមើលក្រែងឈ្មោះស ចុន ហៅតឹក ជាពូរបស់ខ្ញុំ លួចចូលមកទាក់ទងគ្នាជាមួយឪពុករបស់ខ្ញុំ។ ខ្ញុំគិតថា បើសិនជាពូរបស់ខ្ញុំចេញពីព្រៃមកមែននោះ ឈ្មោះសឿងប្រហែលជាបាញ់សម្លាប់ពូខ្ញុំជាមិនខាន។

ស ខេង បញ្ជាក់បន្ថែមថា ខ្ញុំមិនដឹងពូរបស់ខ្ញុំម្នាក់នេះ មានខ្សែរយៈទាក់ទងជាមួយឪពុកខ្ញុំយ៉ាងណានោះទេ គឺខ្ញុំគ្រាន់តែដឹងថា ឪពុកខ្ញុំមិនដែលបានចូលព្រៃតស៊ូជាមួយពួកតស៊ូខ្មែរក្រហមម្តងណាឡើយ។ តែទោះបីយ៉ាងនេះក៏ដោយ ខ្ញុំក៏មានការភិតភ័យយ៉ាងខ្លាំង ហើយប្រញាប់ប្រញាល់ជិះកង់ត្រលប់មកផ្ទះវិញយ៉ាងលឿន ដើម្បីជម្រាបម្តាយឪពុករបស់ខ្ញុំ ឲ្យបានជ្រាបពីបញ្ហានេះ។

ចាប់ពីពេលនោះមក ក្រុមគ្រួសារខ្ញុំមានការព្រួយបារម្ភពីរឿងសន្តិសុខផ្ទាល់ខ្លួនខ្លះៗដែរ ពិសេសឪពុករបស់ខ្ញុំក៏លែងសូវហ៊ានធ្វើដំណើរចូលព្រៃជ្រៅញឹកញាប់ដូចមុនៗទៀតដែរ។

# ២០០
# ស្រុកកំចាយមារ ក្លាយជាអនុខេត្ត



**កងយុវជ័នៗ នាំគ្នាស្វាគមន៍សម្ដេចសីហនុ យាងទៅសម្ពោធអគារសិក្សា នៅស្រុកពារាំង ខេត្តព្រៃវែង ថ្ងៃ១០ ខែមេសា ១៩៦៨**

កាលសម័យនោះដែរ មានបន្ទាយទាហានរាជរដ្ឋាភិបាលមួយ តាំងនៅខាងកើតភូមិអណ្ដូងស្អាត ចម្ងាយប្រហែលជាង១គីឡូម៉ែត្រ និងនៅខាងត្បូងភូមិកន្លែងជ្រៅ ចម្ងាយប្រហែល ២០០ម៉ែត្រ ហើយមានចម្ងាយពីខ្សែបន្ទាត់ព្រំដែនប្រមាណ៥គីឡូម៉ែត្រប៉ុណ្ណោះ។ ( បច្ចុប្បន្ន ទីតាំងអតីតបន្ទាយទាហាននោះ ត្រូវបានកសាងអនុវិទ្យាល័យមួយ គឺអនុវិទ្យាល័យសម្ដេច ឪ )។

មេបញ្ជាការទាហាននៅបន្ទាយនោះ ឈ្មោះប៉ាន់ ថៃ ជាអតីតមេចលនាតស៊ូខ្មែរសេរី។ ក្រោយពេលចុះចូលជាមួយរាជរដ្ឋាភិបាល ឈ្មោះប៉ាន់ ថៃ ត្រូវបានតែងតាំងឲ្យទៅធ្វើជាមេបញ្ជាការនៅបន្ទាយនេះ នៅក្នុងឆ្នាំ១៩៦៨។ តួនាទី ភារកិច្ចរបស់ពួកទាហាននៅបន្ទាយនោះ គឺទី១. ល្បាតការពារតាមបណ្ដោយព្រំដែនកម្ពុជា-វៀតណាម និងទី២. រក្សាការពារសន្តិសុខ ពិសេសបង្ក្រាបសកម្មភាពចលនាតស៊ូរបស់ពួកខ្មែរក្រហម។

## របត់នយោបាយ

ថ្ងៃមួយ វេលាម៉ោង៨ យប់ ពួកទាហាននៅបន្ទាយនោះ បាននាំគ្នាចូលទៅក្នុងភូមិ បាញ់សម្លាប់អ្នកភូមិម្នាក់ ឈ្មោះ ស៊ុន ដែលគេសង្ស័យថាជាពួកខ្មែរក្រហម បណ្តាលឱ្យស្លាប់យ៉ាងអាណោចអាធ័មបំផុត។ ពេលនោះ មិនមែនមានតែឈ្មោះ ស៊ុន ម្នាក់ប៉ុណ្ណោះទេ ដែលត្រូវពួកទាហាននោះបាញ់សម្លាប់ គឺអ្នកភូមិជាប្រជាជនស្លូតត្រង់ ដល់ទៅ៧-៨នាក់ទៀត ក៏ត្រូវបាញ់សម្លាប់ចោលៗដោយសារតែពួកគេសង្ស័យថាជាពួកអ្នកតស៊ូខ្មែរក្រហមនោះដែរ។

នៅក្នុងឆ្នាំ១៩៦៩ ជាមួយនឹងការបើកប្រតិបត្តិការសឹកបង្ក្រាបចលនាតស៊ូខ្មែរក្រហមផង និងដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងរក្សាការពារសន្តិសុខផង សម្តេចសីហនុ បានបង្កើតឱ្យមានអនុខេត្តមួយចំនួន ដូចជា៖ អនុខេត្តកំពង់សិលា, អនុខេត្តថ្មកែវ, អនុខេត្តអណ្តូងពេជ្រ, អនុខេត្តស្រែកានាគ, អនុខេត្តផ្ការំចេក, អនុខេត្តរតនមណ្ឌល និងអនុខេត្តកំចាយមារ ជាដើម។

អនុខេត្តកំចាយមារ ត្រូវបានបង្កើតឡើងតាមព្រះរាជក្រមលេខ ៤០៤/៦៩។ អនុខេត្តនេះ រួមមាន៣ស្រុក គឺ ស្រុកកំចាយមារ, ស្រុកមេសាង (កាត់យកពីខេត្តព្រៃវែង) និងស្រុកពញាក្រែក (កាត់យកពីខេត្តកំពង់ចាម បច្ចុប្បន្ន ខេត្តត្បូងឃ្មុំ)។

តាមកម្មវិធីដែលបានគ្រោងទុក សម្តេចសីហនុ ជាព្រះប្រមុខរដ្ឋត្រូវយាងជាព្រះរាជអធិបតី ដើម្បីប្រកាសព្រះរាជក្រឹត្យ បង្កើតអនុខេត្តកំចាយមារនេះ ។ តែទីបំផុត អ៊ឹង ហុងសាឌ ឧបនាយករដ្ឋមន្ត្រីទី៣ នៃរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ត្រូវអញ្ជើញជាព្រះរាជតំណាងក្នុងពិធីប្រកាសនោះវិញ។

ក្នុងពិធីនោះ យុវជនស ខេង ក៏បានទៅចូលរួមទទួលស្វាគមន៍ជាមួយលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ប្រជារាស្ត្រ និងមន្ត្រីរាជការប្រមាណជាពី៥០០ទៅ៦០០នាក់ ផងដែរ។ យ៉ៃ ស៊ុនឌី ជាមេបញ្ជាការកងវរសេនាតូច ដែលបោះទីតាំងការពារព្រំដែន និងសន្តិសុខ នៅក្នុងភូមិសាស្ត្រស្រុកកំចាយមារ នោះ ត្រូវបានតែងតាំងជាអភិបាលអនុខេត្តកំចាយមារនេះ។

# ២០១
# យុវជន ស ខេង និងបងថ្លៃ ឈុន ឈាន ទិញមាន់ជ្រូកទៅលក់ឱ្យកងទ័ពវៀតកុង



**កងទ័ពវៀតកុងនៅក្នុងព្រៃ**

ក្នុងឆ្នាំ១៩៦៩ កងទ័ពវៀតកុង-វៀតណាមខាងជើង បានចូលមកបោះទីតាំងតាមបណ្តោយព្រំដែននៅក្នុងទឹកដីកម្ពុជា កាន់តែច្រើនឡើងៗ ពិសេសនៅក្នុងព្រៃនាទឹកដីខេត្តស្វាយរៀង ដើម្បីតស៊ូធ្វើសង្គ្រាមតទល់ជាមួយកងទ័ពវៀតណាមខាងត្បូង និងកងទ័ពអាមេរិក។

ពេលនោះ មានពួកឈ្មួញ និងមន្ត្រីធំៗនៅទីក្រុងភ្នំពេញ នាំគ្នារត់ពន្ធដឹកថ្នាំពេទ្យ ដឹកស្រូវអង្ករទាំងរថយន្តៗ យកទៅលក់ឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលចូលមកបោះទីតាំងតាមបណ្តោយព្រំដែននោះ។

ប្រជាកសិករជាអ្នកភូមិអ្នកស្រុកនៅក្បែរៗនោះឃើញដូច្នេះ ក៏នាំគ្នារត់ពន្ធ ដឹកស្រូវអង្ករ បន្លែត្រីសាច់ និងគ្រឿងសម្ភារៈផ្សេងៗទៀតតាមកង់ ទៅលក់ឲ្យកងទ័ពវៀតកុង-វៀតណាម

ខាងជើងនោះដែរ។

ឆ្លៀតឱកាសឈប់សម្រាកវិស្សមកាលសិក្សា យុវជនស ខេង និងបងថ្លៃគាត់ឈ្មោះឈុន ឈាន (ជាប្ដីបងស្រីទី១របស់គាត់ ឈ្មោះស ស៊ន់) ក៏បានបបួលគ្នារកស៊ីរត់ពន្ធនឹងគេដែរ ក្រែងចំណេញបានថវិកាខ្លះ គ្រាន់យកមកទិញសម្ភារសិក្សា និងសម្លៀកបំពាក់ដោយខ្លួនឯង សម្រាប់ទៅរៀនសូត្រ ។

ស ខេង រម្លឹកថា នៅជើងទី១ គាត់ និងបងថ្លៃគាត់ឈ្មោះឈុន ឈាន បានគិតគ្នាថា ដោយសារដើមទុនតិចពេក យើងមានតែរកទិញបន្លែត្រកួន, ត្រឡាច,ល្ពៅ យកទៅលក់ឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ប៉ុណ្ណោះ។ ប៉ុន្តែ បន្លែទាំងនោះ កុំថាឡើយនៅក្នុងភូមិរបស់ពួកគាត់ សូម្បីនៅផ្សារទីរួមស្រុកកំចាយមារ ក៏ពិបាករកទិញដែរ។ ដូច្នេះ ពួកគាត់ត្រូវជិះកង់ទៅដល់ផ្សារអូររាំងឪ នៅក្នុងទឹកដីខេត្តកំពង់ចាម (បច្ចុប្បន្នខេត្តត្បូងឃ្មុំ)ដែលមានចម្ងាយប្រមាណ៤០គីឡូម៉ែត្រ ពីភូមិគាត់ ហើយផ្លូវក៏លំបាកណាស់ដែរ។

ពួកគាត់ទាំងពីរនាក់ នាំគ្នាជិះកង់ចេញពីផ្ទះតាំងពីម៉ោង៦ព្រឹក ដើម្បីទៅទិញបន្លែពីផ្សារអូររាំងឪ រហូតដល់ពេលព្រលប់ ទើបវិលត្រលប់មកដល់ផ្ទះវិញ ហើយទុកបន្លែនោះនៅនឹងផ្ទះមួយយប់។ លុះស្អែកឡើង ពេលព្រលឹមស្រាងៗ ក៏នាំគ្នាជិះកង់ដឹកបន្តទៅកាន់តំបន់ព្រំដែន ដែលជាកន្លែងកងទ័ពវៀតកុង-វៀតណាមខាងជើង បោះទីតាំងឈរជើង។ តែពេលទៅដល់ពាក់កណ្ដាលផ្លូវ ត្រូវឆ្លងកាត់មុខបន្ទាយទាហានរបស់រាជរដ្ឋាភិបាលមួយកន្លែង ពួកគាត់បារម្ភថា បើទាហានយាមនៅមុខបន្ទាយនោះឃាត់សួរនាំ ពួកគាត់មិនដឹងជាគិតយ៉ាងណាទេ ?។

តែសំណាងល្អ ប្រហែលជាទាហាននោះ ឃើញពួកគាត់ដឹកបន្លែត្រកួន, ត្រឡាច, ល្ពៅ កំប៉ិកកំប៉ុកបន្តិចបន្តួច គេមិនឃាត់សួរនាំអ្វីឡើយ ហើយពេលឆ្លងផុតពីមុខបន្ទាយនោះ ពួកគាត់មានអារម្មណ៍សប្បាយរីករាយក្រៃលែង។

ក្រោយលក់បន្លែត្រកួន, ត្រឡាច និងល្ពៅបន្តិចបន្តួចនេះ ឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង រួច ទូរទាត់ទៅ ការរកស៊ីជួញដូរជើងទី១នេះ ពួកគាត់ម្នាក់ៗចំណេញបានប្រាក់

ប្រមាណ៣០០រៀលដែរ។

ដោយសារឃើញថា គ្រាន់តែលក់បន្លែកំប៉ិកកំប៉ុកបន្តិចបន្តួច បានប្រាក់ចំណេញច្រើនងាយៗដូច្នេះ ជើងទី២ ពួកគាត់ក៏ស្រុះស្រួលគ្នា ជិះកង់ទៅទិញមាន់នៅផ្សារអូរាំងឪ យកទៅលក់ឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ម្តងវិញ ក្រែងបានប្រាក់ចំណេញច្រើនជាងរត់ពន្ធបន្លែកំប៉ិកកំប៉ុក។

លុះទិញមាន់បានហើយ ពេលជឹកត្រលប់មកវិញដល់មុខសាលាស្រុកកញ្ច្រៀច ប្រហែលម៉ោង៤រសៀល ស្រាប់តែមានមន្ត្រីប៉ូលិសម្នាក់ ចេញមកឃាត់សួរនាំបន្តិច ក៏ទារលុយ២០រៀល។ គាត់ក៏និយាយអង្វរថា៖ ខ្ញុំនៅសល់តែ២០ រៀលប៉ុណ្ណោះ បើឱ្យលោកអស់ទៅ ពេលកង់ខូច ខ្ញុំគ្មានលុយជួសជុលទេ។ លោកយកតែ១០រៀល បានហើយ។ មន្ត្រីប៉ូលិសនោះ ក៏មានចិត្តអាណិតគាត់ជាសិស្សសាលាដែរ ប្រាប់ថា អើ! ១០រៀល ក៏បានដែរ ហើយធ្វើដំណើរទៅចុះ ព្រោះល្ងាចហើយ។

ជើងទី២នេះ ពួកគាត់លក់មាន់ឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង បានប្រាក់ចំណេញក្នុងម្នាក់ៗ ៤០០រៀល ធ្វើឱ្យពួកគាត់សប្បាយរីករាយជាទីបំផុត។ លុះដល់ជើងទី៣ ពួកគាត់បានស្រុះស្រួលមូលមាត់គ្នាទៅទិញជ្រូកពីផ្សារអូរាំងឪ រត់ពន្ធយកទៅលក់ឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង បន្តទៀត ព្រោះសង្ឃឹមថា នឹងបានប្រាក់ចំណេញច្រើនជាងលក់មាន់ទៅទៀត។

ពួកគាត់ជឹកជ្រូកទម្ងន់ប្រហែល៥០ទៅ៦០គីឡូក្រាម ម្នាក់មួយក្បាលៗ។ ពេលជឹកឆ្លងកាត់បន្ទាយទាហានរាជរដ្ឋាភិបាល ដែលនៅខាងកើតភូមិអណ្តូងស្អាត ចម្ងាយប្រហែលជាង១គីឡូម៉ែត្រនោះ គ្មានឃើញទាហានណាម្នាក់ចេញមកឃាត់សួរនាំអ្វីទេ។ ពួកគាត់ក៏ធ្វើដំណើរបន្តតាមផ្លូវទៅទិសខាងកើតឈៀងខាងត្បូង ចូលទៅក្នុងទឹកដីខេត្តស្វាយរៀង សំដៅទៅរកទីតាំងអង្គភាពកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលនៅខាងក្រោយកំពង់ម៉ឺនជ័យប្រមាណ២គីឡូម៉ែត្រ។

ពេលទៅដល់ពាក់កណ្តាលផ្លូវ ស្រាប់មានពួកទាហាន និងប៉ូលិសស្រុករមាសហែក

## របត់នយោបាយ

មួយក្រុម មកស្ទាក់ឃាត់ចាប់យកជ្រូកទាំងអស់ ហើយប្រាប់ថា៖ បើចង់តវ៉ា ទៅតវ៉ានៅសាលាស្រុករមាសហែក !។ តែពួកគាត់ពុំមានលទ្ធភាពទៅតវ៉ានោះទេ ព្រោះបើសិនទៅ ក៏ត្រូវបង់លុយ ឬអាចថាសូកគេ ទើបបានជ្រូកនោះមកវិញ។

ពួកគាត់មិនអាចរកលុយឯណាទៅបង់ ឬទៅសូកគេបានទេ ព្រោះទាំងប្រាក់ដើម ទាំងប្រាក់ចំណេញបានពីលក់បន្លែ និងលក់មាន់ ពួកគាត់ប្រមូលយកទៅទិញជ្រូក២ក្បាលនោះអស់ហើយ។

ទីបំផុត ពួកគាត់មានតែបង្ខំចិត្តវិលត្រលប់មកផ្ទះវិញ ដោយដៃទទេ។ ដូច្នេះជើងទី៣ នេះ ត្រូវខាតបង់ទាំងស្រុង គ្មានសល់អ្វីឡើយ។

# ២០២
# គេចពីយន្តហោះអាមេរិក បាចថ្នាំគីមី ទៅជួបនារីជាប្អូនស្រីមិត្តភក្តិ



**យន្តហោះអាមេរិក បាចសារធាតុគីមីក្នុងទឹកដីខ្មែរ នាខែមីនា ឆ្នាំ១៩៦៩**

ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៦៩ កងទ័ពសហរដ្ឋអាមេរិក ចាប់ផ្ដើមបើកយុទ្ធនាការទម្លាក់គ្រាប់បែករយៈពេល១៤ខែ ដើម្បីកម្ទេចទីតាំងកងទ័ពវៀតកុង-វៀតណាមខាងជើងទាំងឡាយ ដែលស្ថិតនៅក្នុងទឹកដីកម្ពុជា។

យុទ្ធនាការទម្លាក់គ្រាប់បែកយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលមិនធ្លាប់មានពីមុនមកនេះ គឺជាគំនិតផ្ដួចផ្ដើមរបស់ហង់រី គីស្ស៊ីងហ្គ័រ (Henry Kissinger) ជាទីប្រឹក្សាសន្តិសុខជាតិរបស់ប្រធានាធិបតីសហរដ្ឋអាមេរិក រីឆាដ និចសុន (Richard Nixon)ដោយពុំមានការសុំអនុម័តឯកភាពពីសភាសហរដ្ឋអាមេរិកឡើយ ហើយក៏ពុំមានការយល់ព្រមដោយពេញលេញ និងជាចំហពីប្រធានាធិបតីសហរដ្ឋអាមេរិក រីឆាដ និចសុន (Richard Nixon)ដែរ។

យុទ្ធនាការទម្លាក់គ្រាប់បែបនេះ មានឈ្មោះថា ប្រតិបត្តិការម៉ឺនុយ (Menu= បញ្ជីរាយឈ្មោះមុខម្ហូប) ធ្វើឡើងដើម្បីកម្ទេចកងទ័ពវៀតកុង-វៀតណាមខាងជើងឱ្យនៅសល់តិចបំផុត និងជួយពង្រឹងកងទ័ពវៀតណាមខាងត្បូងឱ្យបានរឹងមាំ មុននឹងកងទ័ពសហរដ្ឋអាមេរិក ត្រូវដកទៅប្រទេសរបស់ពួកគេវិញ។

## របត់នយោបាយ

អ្នកបើកយន្តហោះទាំងអស់នោះ ទម្លាក់គ្រាប់បែកពុំមានធ្វើការបែងចែកថា កន្លែងណាជាភូមិ ដែលប្រជារាស្ត្រខ្មែររស់នៅ កន្លែងណាជាទីតាំងកងទ័ពវៀតកុង-វៀតណាមខាងជើងនោះទេ គឺពួកគេទម្លាក់គ្រាប់បែកមកលើភូមិខ្មែរ បណ្ដាលឱ្យប្រជាកសិករខ្មែរជាច្រើននាក់ត្រូវបាត់បង់ជីវិត និងរងរបួស។

ចាប់ពីថ្ងៃទី១៤ ខែមេសា (ថ្ងៃចូលឆ្នាំខ្មែរ) រហូតដល់ខែថ្ងៃ១២ ខែឧសភា ឆ្នាំ១៩៦៩ យន្តហោះអាមេរិក ជាច្រើនគ្រឿងបានហោះចូលមកទម្លាក់គ្រាប់បែក និងបាចម្សៅគីមីពណ៌លឿងពីយន្តហោះទៅលើចម្ការកៅស៊ូ និងព្រៃមួយចំនួន នៅក្នុងភូមិសាស្ត្រស្រុកមេមត់ ស្រុកពញាក្រែក និងស្រុកកំចាយមារ ជាទឹកដីខ្មែរ ដើម្បីធ្វើឲ្យស្លឹកឈើជ្រុះអស់ ងាយស្រួលក្នុងការរុករកកម្ទេចកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលចូលមកបោះទីតាំងនៅក្នុងទឹកដីកម្ពុជា។

ស ខេង បានឱ្យដឹងថា ម្សៅគីមីពណ៌លឿងនេះ មិនត្រឹមតែធ្វើឲ្យជ្រុះស្លឹកឈើប៉ុណ្ណោះទេ ថែមទាំងធ្វើឲ្យប៉ះពាល់ដល់សុខភាពមនុស្សថែមទៀតផង។ ជាពិសេសចំហាយវា ក៏អាចធ្វើឱ្យស្ត្រីមានផ្ទៃពោះខ្លះ ពេលសម្រាលកូនមក កូននោះមិនគ្រប់លក្ខណៈផងដែរ។ ជាក់ស្ដែង លោកជំទាវ ញ៉ែម សឿន ភរិយារបស់សម្ដេចជា ស៊ីម (កាលនោះ រស់នៅភូមិឃុំជាមួយគ្នា) នៅចុងឆ្នាំ ១៩៧០ សម្រាលបានកូនប្រុស ឈ្មោះ ជា ធា កំបុតដៃម្ខាងពីកំណើតមកតែម្ដង។

ដោយមិនអាចស៊ូទ្រាំនឹងការបាចម្សៅគីមីពណ៌លឿងនៅតាមបណ្ដោយព្រំដែនខ្មែរ-វៀតណាម នោះបាន ក្រុមគ្រួសារយុវជន ស ខេង ក៏ដូចជាគ្រួសារអ្នកភូមិផ្សេងៗទៀតនៅភូមិអណ្ដូងស្អាត ក៏ដូចជានៅភូមិក្បែរៗគ្នានោះដែរ បាននាំគ្នារត់កៀសខ្លួនចេញពីភូមិ ទៅពួនសំងំនៅក្នុងព្រៃប៉ែកខាងលិច ចម្ងាយប្រហែល៤គីឡូម៉ែត្រ។

ទោះជានាំគ្នារត់កៀសខ្លួនចូលសំងំទៅក្នុងព្រៃ យ៉ាងនេះក្ដី ក៏យន្តហោះស៊ើបការណ៍របស់កងទ័ពសហរដ្ឋអាមេរិក នៅតែហោះឆ្វែលពីលើជារៀងរាល់ថ្ងៃ ធ្វើឱ្យពួកអ្នកភូមិមានការភ័យខ្លាចជាទីបំផុត សូម្បីតែបង្កាត់ភ្លើងដាំបាយ ក៏មិនហ៊ានផង ព្រោះខ្លាចយន្តហោះស៊ើបការណ៍នោះ មើលឃើញផ្សែងហុយឡើង វាទាក់ទងហៅយន្តហោះគ្នាវាឱ្យមកទម្លាក់គ្រាប់បែក

ឬបាញ់កំទេច។

ដោយសារខ្លាចយន្តហោះមកទម្លាក់គ្រាប់បែក ឬបាញ់កំទេចផង ហើយការរស់នៅលាក់ខ្លួនពួនក្នុងព្រៃក៏មានការលំបាកណាស់ដែរ មួយសប្តាហ៍ក្រោយមក រាជការអាជ្ញាធរស្រុក ក៏បានជម្លៀសអ្នកភូមិចេញពីព្រៃ ក្នុងទឹកដីឃុំក្របៅនោះ ឲ្យទៅស្នាក់នៅខាងលិចវត្តកំចាយមារ ឃុំក្រញូង វិញ។

ស ខេង បានឱ្យដឹងបន្តថា ពេលទៅដល់ខាងលិចវត្តកំចាយមារនោះ គាត់ក៏ជួបមិត្តភក្តិម្នាក់ឈ្មោះកូវ ស៊ីវ៉ាន ជាមិត្តជិតស្និទ្ធ ធ្លាប់រៀននៅសាលាបឋមសិក្សាវត្តកំចាយមារ ជាមួយគ្នា កាលពីឆ្នាំ១៩៦៤ ដល់ឆ្នាំ១៩៦៧។ ពេលនោះ មិត្តភក្តិជិតស្និទ្ធឈ្មោះកូវ ស៊ីវ៉ាន ក៏បានទៅសុំម្តាយឪពុកគេ ដើម្បីឱ្យក្រុមគ្រួសារគាត់បានស្នាក់នៅផ្ទះជាមួយផង។

ដោយយល់ឃើញថា ជាមិត្តភក្តិជិតស្និទ្ធរបស់កូន អ៊ុំប្រុសឈ្មោះស៊ុន និងប្រពន្ធ ជាម្ចាស់ផ្ទះ ក៏ទទួលឱ្យក្រុមគ្រួសារគាត់ស្នាក់នៅជាមួយដោយរីករាយរាក់ទាក់ គ្មានទើសទាល់អ្វីបន្តិចឡើយ។ ពេលនោះ អ៊ុំស៊ុន ជាម្ចាស់ផ្ទះ ក៏មានកូនក្រមុំម្នាក់ឈ្មោះ កូវ គឹមស៊្រួ (ជាប្អូនស្រីរបស់ កូវ ស៊ីវ៉ាន)ផងដែរ។

ក្រោយពីរស់នៅជាមួយគ្នាមិនបានប៉ុន្មានថ្ងៃផង ចាស់ទុំជាម្តាយឪពុកគាត់ និងម្តាយឪពុកក្រមុំកូវ គឹមស៊្រួ ជាម្ចាស់ផ្ទះ កាន់តែស្រលាញ់រាប់អានគ្នាខ្លាំងឡើងៗ រហូតដល់មានបំណងចង់ផ្សំផ្គុំគាត់ និងក្រមុំកូវ គឹមស៊្រួ ជាប្តីប្រពន្ធនឹងគ្នាទៀតផង ខណៈ រូបគាត់ផ្ទាល់ និងក្រមុំកូនម្ចាស់ផ្ទះ ក៏មានចិត្តប្រតិព័ទ្ធលើគ្នាទៅវិញទៅមកផងដែរ។ តែយ៉ាងណា គាត់ពិចារណាថា គាត់ទើបមានអាយុ មិនដល់២០ ឆ្នាំផង ឯការរៀនសូត្រក៏មិនទាន់ចប់ទៀត តើមានលទ្ធភាពឯណា ដើម្បីកសាងអនាគតគ្រួសារមួយឱ្យបានល្អនោះ? ។ គាត់ក៏បានសន្យាទៅខាងស្រីថា រង់ចាំពីរ ឬបីឆ្នាំទៀតសិន ចាំរៀបការ...។

តែក្រោយពីមានព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដោយមិនអាចរង់ចាំតទៅទៀតបាន ក្រមុំកូវ គឹមស៊្រួ ក៏បានរៀបការកសាងអនាគតជាមួយកំលោះផ្សេងទៀតបាត់ទៅ។

# ២០៣
# ខៀវ សំផន និងហ៊ូ យន់ បាត់ខ្លួនពីក្រុងភ្នំពេញ



**ហ៊ូ យន់ កាលនៅជារដ្ឋលេខាធិការក្រសួងហិរញ្ញវត្ថុ**

នៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៦៧ សម្តេចសីហនុ បានចោទប្រកាន់ខៀវ សំផន, ហ៊ូ យន់ និងហ៊ូ នឹម ជាសាធារណៈថា ជាអ្នកនាំភ្លើងឱ្យមានការបះបោរនៅសំឡូត ហើយព្រះអង្គបានគំរាមថា នឹងចាប់អ្នកទាំងបីនេះបញ្ជូនទៅឱ្យតុលាការសឹកផ្តន្ទាទោសទៀតផង។

២ថ្ងៃក្រោយមក គឺថ្ងៃទី២៤ ខែមេសា ខៀវ សំផន និងហ៊ូ យន់ ក៏ត្រូវបាត់ខ្លួនពីក្រុងភ្នំពេញ។ នៅថ្ងៃបាត់ខ្លួនតំណាងរាស្ត្រទាំងពីរនាក់នេះ ពួកតំណាងរាស្ត្រដែលមាននិន្នាការអភិរក្សនិយម និងស្តាំនិយមមួយចំនួនបានទាមទារឱ្យប្រធានរដ្ឋសភាបើកអង្គប្រជុំវិសាមញ្ញមួយ ដើម្បីដកអភ័យឯកសិទ្ធិតំណាងរាស្ត្ររបស់ហ៊ូ នឹម ផងដែរ។ ប៉ុន្តែ ពួកគេមិនអាចរកសំឡេងឱ្យបានគ្រប់គ្រាន់ ដើម្បីដកអភ័យឯកសិទ្ធិហ៊ូ នឹម បានទេ។

បន្ទាប់មក ក៏លេចឮដំណឹងថា ខៀវ សំផន និងហ៊ូ យន់ ត្រូវពួកប៉ូលិសសម្ងាត់ចាប់យកទៅសម្លាប់ និងយកសាកសពយកទៅបោះចោលនៅជ្រោះពេជ្រនិល បាត់ហើយ។

នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៦៧ ដោយយកលេសថា ត្រូវចេញព្យាបាលមុខរបួសដែលបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍ ឧត្តមសេនីយ៍លន់ នល់ លាលែងពីតំណែងពីនាយករដ្ឋមន្រ្តី ហើយបានចេញដំណើរទៅក្រៅប្រទេស។

នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៦៧ សម្តេចសីហនុ បានរៀបចំសមាសភាពគណៈរដ្ឋមន្រ្តីថ្មីមួយ បន្តពីរាជរដ្ឋាភិបាលរបស់ឧត្តមសេនីយ៍លន់ នល់ ដោយព្រះអង្គសព្វព្រះទ័យគង់ជានាយករដ្ឋមន្រ្តីផ្ទាល់តែម្តង, សឺន សាន ជាឧបនាយករដ្ឋមន្ត្រី, អ៊ឹង ហុងសាធ ជាទេសរដ្ឋមន្រ្តីទទួលបន្ទុកមហាផ្ទៃ សន្តិសុខ ការពារលើផ្ទៃប្រទេស ធម្មការ និងទំនាក់ទំនងសភា, ចៅ សេង ជាទេសរដ្ឋមន្រ្តីទទួលបន្ទុកសេដ្ឋកិច្ច, ទូច គីម ជាទេសរដ្ឋមន្រ្តីទទួលបន្ទុកផែនការ និងហិរញ្ញវត្ថុ, ព្រះអង្គម្ចាស់នរោត្តម ភូរិស្សារ៉ា ជារដ្ឋមន្រ្តីការបរទេស, សូ ណែម ជារដ្ឋមន្រ្តីសាធារណសុខាភិបាល , អ្នកស្រី ទិប ម៉ម ជារដ្ឋមន្រ្តីសង្គមកិច្ច និងការងារ, វណ្ណ ម៉ូលីវណ្ណ ជារដ្ឋមន្រ្តីអប់រំជាតិ, ងួន ឆាយគ្រី ជា រដ្ឋមន្រ្តីសាធារណៈ និងទូរគមនាគមន៍, ដួង សំអុល ជារដ្ឋមន្រ្តីការពារជាតិ, ទេព ហ៊ិន ជារដ្ឋមន្រ្តីយុត្តិធម៌, គាត ឈន់ ជាអនុរដ្ឋលេខាធិការសេដ្ឋកិច្ចជាតិ ទទួលបន្ទុកកសិកម្ម, អ្នកស្រីជិន រ៉ែន ជាអនុរដ្ឋលេខាធិការព័ត៌មាន, អ្នកស្រីអ៊ឹង មឹង ជាអនុរដ្ឋលេខាធិការទេសចរណ៍, ប៉ែន ថុល ជាអនុរដ្ឋលេខាធិការសេដ្ឋកិច្ចជាតិ ទទួលបន្ទុកពាណិជ្ជកម្ម, អ៊ុំ ម៉ាន្នូរិន (បងថ្លៃព្រះអង្គ)ជាអនុរដ្ឋលេខាធិការមហាផ្ទៃ ទទួលបន្ទុកសន្តិសុខជាតិ និងការពារលើផ្ទៃប្រទេស, អ៊ុក ម៉ូត ជាអនុរដ្ឋលេខាធិការមហាផ្ទៃ ទទួលបន្ទុកធម្មការ, កែវ អន ជាអនុរដ្ឋលេខាធិការទូរគមនាគមន៍ និងប៉ាវ អ៊ិត ជាអនុរដ្ឋលេខាធិការទីស្តីការគណៈ- រដ្ឋមន្រ្តី ទទួលបន្ទុកបេសកកម្មពិសេស។

ដើមខែឧសភាឆ្នាំ១៩៦៧ សម្តេចសីហនុ បានយាងទៅបំពេញព្រះរាជទស្សនកិច្ចនៅតំបន់សំឡូត។ នៅទីនោះ ព្រះអង្គបានអំពាវនាវដល់អ្នកស្រុកទាំងឡាយ ដែលបានរត់ចូលព្រៃ ឲ្យនាំគ្នាវិលត្រលប់មកផ្ទះសម្បែងវិញ។ ព្រះអង្គបានប្រកាសថា បងប្អូនកូនចៅណា

ដែលបានរត់ចោលផ្ទះសម្បែងទៅចូលព្រៃ ដោយសារខ្លាចមានការចោទប្រកាន់ថា មានជាប់ពាក់ព័ន្ធជាមួយពួកខ្មែរក្រហមនោះ សូមបងប្អូនកូនចៅ វិលត្រលប់ទៅផ្ទះសម្បែងវិញ ហើយបើទោះបីជាបងប្អូនកូនចៅរត់ចូលព្រៃដោយសារមូលហេតុអ្វីក៏ដោយ ក៏ព្រះអង្គអត់ឱន មិនយកទោសពៃរ៍អ្វីទាំងអស់។

ពេលនោះដែរ ទីតាំងតស៊ូពួកខ្មែរក្រហមដ៏ធំមួយនៅភ្នំវាយចាប ដែលនៅក្នុងស្រុករតនមណ្ឌល ជាប់នឹងតំបន់សំឡូត នោះ ត្រូវបានទាហានរាជរដ្ឋាភិបាលមួយកងវរសេនាធំទៅហ៊ុមព័ទ្ធ ក្នុងបំណងវាយកម្ទេចឱ្យវិនាសសូន្យ តែម្តង។

បន្ទាប់មក ពួក«ទាហានរបស់លន់ នល់ បានចូលទៅកាន់កាប់ភ្នំវាយចាប អស់រយៈពេល៣ខែ ហើយបានបន្តរុករកកម្ទេចពួកខ្មែរក្រហម ដែលលាក់ខ្លួននៅតំបន់នោះ ស្លាប់មួយចំនួន និងចាប់ខ្លួនបានច្រើននាក់។

ក្រោយមក មេខ្មែរក្រហមឈ្មោះរស់ ញឹម ហៅមូល សម្បត្តិ ជាលេខាគណៈកម្មាធិការបក្សភូមិភាគពាយ័ព្យ ចាត់ទុកថា ភ្នំវាយចាបនោះ គឺជាមូលដ្ឋានតស៊ូបដិវត្តន៍ដែលមានវីរភាពបំផុត ដោយសារយុវជនបដិវត្តន៍នៅទីនោះ មានឆន្ទៈតស៊ូប្រកបដោយស្មារតីស្នេហាជាតិស្នេហាបដិវត្តន៍ដ៏ខ្ពង់ខ្ពស់ បើទោះបីពួកទាហានរាជរដ្ឋាភិបាលមានទាំងរថក្រោះ និងយន្តហោះទម្លាក់គ្រាប់បែកជួយអន្តរាគមន៍យ៉ាងណាក៏ដោយ ក៏កងទ័ពគាត់បានធ្វើការវាយទម្លាយការហ៊ុមព័ទ្ធនោះ ដើម្បីដកថយចេញពីភ្នំវាយចាប បានដោយជោគជ័យដែរ។

រស់ ញឹម ហៅ មូល សម្បត្តិ បន្ថែមទៀតថា ថ្វីបើពេលនោះ ប្រជាជន និងយុវជនបដិវត្តន៍យើងជាច្រើនត្រូវបានបាត់បង់ជីវិតក៏ដោយ ក៏វាមានតម្លៃធំធេងខ្លាំងណាស់ ព្រោះវាបានផ្លាស់ប្តូរនូវបទពិសោធមួយយ៉ាងសំខាន់ ក្នុងការតស៊ូប្រដាប់អាវុធផងដែរ។

ពេលនោះ មេខ្មែរក្រហមម្នាក់ឈ្មោះចាន់ ចក្រី ហៅសមមិត្តមាន ក៏បានចេញមកសារភាព ដោយនាំនូវអាវុធ២ដើមមកជាមួយផង។ ក្រោយពីទទួលបានការលើកលែងទោសពីរាជរដ្ឋាភិបាល ចាន់ ចក្រី ក៏បានធ្វើដំណើរទៅរស់នៅឯប៉ែកខាងកើតប្រទេស វិញម្តង។

នៅក្នុងឆ្នាំ១៩៧១ គឺក្រោយពេលភ្លើងសង្គ្រាមឆាបឆេះប្រទេសកម្ពុជា បានជាង១

ឆ្នាំ ចាន់ ចក្រី បានលេចមុខជាថ្មី ជាប្រធានវរសេនាធំលេខ១៧៣ របស់កងទ័ពខ្មែរក្រហម ដែលបោះទីតាំងឈរជើងនៅក្នុងតំបន់២០, តំបន់២៣ និងតំបន់២៤ ក្នុងភូមិភាគបូព៌ា។

ក្រោយជ័យជម្នះ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ចាន់ ចក្រី ត្រូវបានតែងតាំង ជាអនុប្រធានអគ្គសេនាធិការកងទ័ពនៃរបបកម្ពុជាប្រជាធិបតេយ្យ។

ថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៧៦ ចាន់ ចក្រី ត្រូវមេខ្មែរក្រហម ប៉ុល ពត បញ្ជាឱ្យគេចាប់យកទៅដាក់មន្ទីរស.២១ (គុកទួលស្លែង)ពីបទក្បត់បដិវត្តន៍ និងជាប់ទាក់ទិនរឿងដែលគាត់បានសម្លាប់យុវជនពីរនាក់ ក្នុងនោះមានម្នាក់ជានីរសាររបស់ រស់ ញឹម ហៅមូល សម្បត្តិ ជាលេខាបក្សភូមិភាគពាយ័ព្យ ដើម្បីយកកាំភ្លើង២ដើម ទៅចុះចូលជាមួយពួកទាហានលន់ នល់ ដែលចុះទៅបង្ក្រាបពួកខ្មែរក្រហមនៅភ្នំវាយចាប ក្នុងឆ្នាំ១៩៦៧ នោះផងដែរ។

នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៦៧ សម្តេចសីហនុ បានប្រកាសថាឧទ្ទាមកម្មនៅតំបន់សំឡូតនោះ ត្រូវបានបញ្ចប់ ហើយគ្រួសារកសិករច្រើនពាន់គ្រួសារ បានវិលត្រលប់មករស់នៅតាមផ្ទះសម្បែងរបស់ពួកគេដូចមុនវិញ។ ប៉ុន្តែប្រហែលព្រះអង្គមិនបានដឹងពីរឿងពួកទាហានលន់ នល់ ដែលបើកប្រតិបត្តិការបង្ក្រាបពួកខ្មែរក្រហមនៅសំឡូត និងភ្នំវាយចាបនោះ បានបាញ់សម្លាប់ប្រជារាស្ត្រ និងលួចឆក់ប្លន់ទ្រព្យសម្បត្តិអ្នកស្រុក ឬក៏មានប្រជារាស្ត្ររាប់រយគ្រួសារទៀត រត់ចូលព្រៃ តាមពួកខ្មែរក្រហមឡើយ។

# ២០៤
# កេង វ៉ាន់សាក់ ត្រូវសមត្ថកិច្ចចាប់ខ្លួនជាលើកទី២



**កេង វ៉ាន់សាក់ កាលនៅជានិស្សិត**

កេង វ៉ាន់សាក់ កើតនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩២៥ ក្នុងភូមិកំពង់បឹង ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។ ម្តាយឈ្មោះ ជៀស ហាន ជាអ្នកខេត្តពោធិ៍សាត់ ជាប់ខ្សែស្រឡាយជាញាតិវង្សជាមួយនឹងម្ចាស់ក្សត្រីមល្លិកា ជាមហេសីរបស់ព្រះអង្គម្ចាស់នរោត្តម យុគន្ធរ។ ឪពុកឈ្មោះ កេង ស៊ីផាន់។ តែ កេង វ៉ាន់សាក់ ធ្លាប់ទម្លាយឱ្យដឹងជាសាធារណៈថា កេង ស៊ីផាន់ នេះគ្រាន់តែជាឪពុកឧបកិច្ចរបស់គាត់តែប៉ុណ្ណោះ ហើយឪពុកឧបកិច្ចរូបនេះតែងតែធ្វើទុក្ខបុកម្នេញមកលើរូបគាត់តាំងពីកុមារភាពរហូតមក។

នៅក្នុងឆ្នាំ ១៩៤៦ គាត់ប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិភាគ២ (បាក់ឌុប) ផ្នែកទស្សនវិជ្ជា រួចបន្តការសិក្សានៅប្រទេសបារាំង ទៀត ។

ពេលទៅសិក្សានៅប្រទេសបារាំង ពីឆ្នាំ១៩៤៧ នោះ គាត់ក៏បានធ្វើគ្រូជំនួយភាសាខ្មែរ

នៅសាលាភាសាចុងបូព៌ាប្រទេស នៅក្រុងបារីស ផងដែរ។ រហូតដល់ឆ្នាំ១៩៥១ គាត់បានប្រលងជាប់បរិញ្ញាបត្រផ្នែកទស្សនវិជ្ជានៅសាកលវិទ្យាល័យស៊កបោន (Sorbonne) ក្រុងបារីស ហើយគាត់បានរៀបការជាមួយស្រីជាជនជាតិបារាំងម្នាក់ ឈ្មោះស៊ូយស្ហាន កុលលើវីល (Suzanne colleville) ជាគ្រូបង្រៀនភាសាឡាវ នៅសាលាភាសាចុងបូព៌ាប្រទេសជាមួយគ្នានោះដែរ។ ស្រីជាជនជាតិបារាំងម្នាក់នេះ ក៏មានសញ្ញាបត្រផ្នែកភាសាខ្មែរ និងភាសាសៀម ផងដែរ។

នៅឆ្នាំ១៩៥២ កេង វ៉ាន់សាក់ បានបង្កើតម៉ាស៊ីនអង្គុលីលេខជាអក្សរខ្មែរ រួចហើយបាននាំភរិយាមកប្រទេសកម្ពុជា បំពេញការងារជាសាស្ត្រាចារ្យនៅវិទ្យាល័យព្រះស៊ីសុវត្ថិ។ ក្នុងឆ្នាំ១៩៥៥ គាត់បានចូលប្រឡូកក្នុងឆាកនយោបាយ ក្នុងនាមជាអគ្គលេខាធិការរបស់គណបក្សប្រជាធិបតេយ្យ ដែលបង្កើតឡើងដោយព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស តាំងពីឆ្នាំ១៩៤៧ ដើម្បីប្រជែងអំណាចជាមួយចលនាសង្គមរាស្ត្រនិយម របស់សម្ដេចសីហនុ។

តែក្រោយលទ្ធផលនៃការបោះឆ្នោត គណបក្សប្រជាធិបតេយ្យ មិនត្រឹមតែរកអាសនៈ១នៅក្នុងសភា មិនបានទេ គឺ កេង វ៉ាន់សាក់ ជាអគ្គលេខាធិការ ត្រូវគេចោទប្រកាន់ថា បានរៀបចំផែនការបាញ់សម្លាប់មេដឹកនាំចលនាសង្គមរាស្ត្រនិយម ហើយត្រូវគេចាប់ដាក់គុកពីថ្ងៃទី១៣ ខែកញ្ញា រហូតដល់ថ្ងៃទី១០ ខែតុលា១៩៥៥ ទើបគេដោះលែងឱ្យមានសេរីភាពវិញ។

ក្នុងអំឡុងពេលជាប់គុកនោះ គាត់បានតែងកំណាព្យវែងមួយមានចំណងជើងថាៈ គុកកាមកិលេស ដែលមានខ្លឹមសារលន្លង់លន្លោចខ្លោចផ្សាបំផុត។

ក្រោយពេលបានរួចខ្លួន ចេញពីគុកវិញ កំណាព្យដែលមានចំណងជើងថាៈ គុកកាមកិលេសនេះ គាត់បានបោះពុម្ពផ្សាយជាសៀវភៅ។

ពីឆ្នាំ១៩៥៨ ដល់ឆ្នាំ១៩៦២ គាត់ត្រូវបានតែងតាំងជាព្រឹទ្ធបុរសមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ នៅសាកលវិទ្យាល័យសង្គមរាស្ត្រនិយម និងជាចាងហ្វាងវិទ្យាស្ថានជាតិគរុកោសល្យ។ ពេលនោះដែរ គាត់ក៏បានទៅបង្រៀនមុខវិជ្ជាអក្សរសាស្ត្រ វប្បធម៌ អរិយធម៌




**កែង វ៉ាន់សាក់ កាលនៅជាចាងហ្វាងវិទ្យាស្ថានគរុកោសល្យ(រូបពាក់អាវស) និងសុន សេន (រូបពាក់អាវធំពណ៌ខ្មៅ)**

ខ្មែរនៅមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ និងនៅពុទ្ធិកវិទ្យាល័យព្រះសីហនុរាជ ផងដែរ។

លុះមកដល់ពាក់កណ្តាលឆ្នាំ ១៩៦៨ រាជរដ្ឋាភិបាលសម្តេចសីហនុ បានបញ្ឈប់គាត់ពីតំណែងជាព្រឹទ្ធបុរស និងលែងឱ្យបង្រៀននៅមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ ព្រមទាំងនៅពុទ្ធិកវិទ្យាល័យព្រះសីហនុរាជ នោះទៀត ដោយចោទប្រកាន់ថា គាត់ជាអ្នកឃោសនាបំបះបំបោរពួកនិស្សិត និងសាមណនិស្សិត ឱ្យប្រឆាំងនឹងរាជរដ្ឋាភិបាល ហើយកម្លាំងសមត្ថកិច្ចនៅក្រសួងសន្តិសុខជាតិ បាននាំគ្នាទៅឆែកឆេរុករើផ្ទះគាត់ រកឃើញសៀវភៅកុម្មុយនិស្តរបស់កាលម៉ាក្ស និងម៉ៅ សេទុង ព្រមទាំងទស្សនាវដ្តីមកពីប្រទេសចិន ជាច្រើនក្បាលនៅបណ្ណាល័យផ្ទាល់របស់គាត់។

ពេលនោះ គាត់ក៏ត្រូវបានកម្លាំងសមត្ថកិច្ចចាប់យកទៅឃុំនៅរាជបណ្ឌិត្យសភានគរបាល ជាមួយ សូ ណែម (រដ្ឋមន្ត្រីក្រសួងសាធារណសុខាភិបាល) និងភឹង គុន សាកលវិទ្យាធិការនៃសាកលវិទ្យាល័យសង្គមរាស្ត្រនិយម។

# ២០៥
# សម្ដេចសីហនុ ផ្សារទំនាក់ទំនងការទូត ជាមួយវៀតកុង និងវៀតណាមខាងជើង



**សម្ដេចសីហនុ និងង្វៀន ហ៊ីវ ថ**
**ប្រធានរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង**

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៦៧ ជាថ្ងៃបុណ្យចូលឆ្នាំខ្មែរចុងក្រោយ មេដឹកនាំកំពូលវៀតណាមខាងជើង ហូ ជីមិញ បានផ្ញើសារលិខិតមកថ្វាយ សម្ដេចសីហនុ។ សារលិខិតនោះ បានបញ្ជាក់ថា ទោះបីជាពួកសត្រូវចក្រពត្តិអាមេរិក បង្កើនការព្យាយាមមួយទ្វេជាពីរ ដើម្បីដាក់នឹមត្រួតត្រាលើប្រជាជននៅឥណ្ឌូចិន ក៏ដោយ ក៏ប្រជាជនដែលរួបរួមគ្នាយ៉ាងជិតស្និទ្ធបំផុតនេះ ប្រាកដជាដណ្ដើមបានជ័យជម្នះផ្ដាច់ព្រ័ត្រ និងកសាងសុភមង្គលរបស់ខ្លួន ក្នុងឯករាជ្យភាព និងសេរីភាពយ៉ាងពិតប្រាកដ បានដូចបំណងដែរ។

ជាមួយគ្នានោះ ហូ ជីមិញ ក៏បានថ្វាយសព្ទសាធុការពរចំពោះសម្ដេចសីហនុ ដោយ

របត់នយោបាយ

បញ្ជាក់ជាថ្មីអំពីចំណងសាមគ្គីភាពរបស់ប្រជាជនកម្ពុជា និងវៀតណាម ពិសេសបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងស្មោះស្ម័គ្របំផុត ចំពោះព្រះអង្គ ព្រមទាំងរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដែលបានជួយឧបត្ថម្ភគាំទ្រចំពោះបុព្វហេតុតស៊ូដ៏ត្រឹមត្រូវរបស់ប្រជាជនវៀតណាម ក្នុងការធ្វើសង្គ្រាមប្រឆាំងនឹងការឈ្លានពានរបស់ពួកចក្រពត្តិអាមេរិក។

លិខិតនោះបន្តទៀតថា កម្ពុជា ប្រាថ្នាឱ្យរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង (វៀតកុង) តាំងស្ថានតំណាងជាផ្លូវការមួយនៅទីក្រុងភ្នំពេញ ដើម្បីទទួលបាននូវឯកសិទ្ធិជាផ្លូវទូត។

ជាមួយគ្នានេះដែរ សម្តេចសីហនុ បានផ្ញើលិខិតមួយទៀតទៅឱ្យនាយករដ្ឋមន្ត្រីវៀតណាមខាងជើង ផាំ វ៉ាន់ដុង ឱ្យដំឡើងទំនាក់ទំនងរវាងប្រទេសទាំងពីរ ដល់ថ្នាក់ឯកអគ្គរាជទូត និងឯកអគ្គរដ្ឋទូតទៀតផង។

នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៦៧ កាសែតបារាំង ឡឺម៉ុងដ៍ បានចុះផ្សាយថា តុល្យភាពនៃការបើកប្រតិបត្តិការសឹករបស់កងយោធពលខេមរភូមិន្ទ ដើម្បីបោសសម្អាតពួកឧទ្ទាមខ្មែរក្រហម នៅតំបន់សំឡូត ភាគខាងត្បូងនៃខេត្តបាត់ដំបង ដែលធ្វើឡើងកាលពីថ្ងៃទី០៦ ដល់ថ្ងៃទី៣០ ខែមេសានោះ បណ្តាលឱ្យពួកខ្មែរក្រហមស្លាប់ ១៩នាក់ និងចាប់ខ្លួនបាន ១៤០នាក់ ហើយប្រមូលបានកាំភ្លើងកែច្នៃមួយចំនួន និងកាំភ្លើងវែងធម្មតាចំនួន៣ ដើម។ ចំណែក ខាងកងយោធពលខេមរភូមិន្ទ ស្លាប់៤នាក់ និងរងរបួស៤នាក់។

ជាមួយការបង្ក្រាបពួកខ្មែរក្រហមនេះដែរ សម្តេចសីហនុ ក៏មិនភ្លេចធ្វើការវាយបំបាក់ចលនាតស៊ូខ្មែរសេរីរបស់សឺង ង៉ុកថាញ់ ដែលមានទីតាំងនៅក្នុងទឹកដីវៀតណាមខាងត្បូង និងប្រទេសថៃ ផងដែរ។ តាមរបាយការណ៍របស់អគ្គសេនាធិការដ្ឋានកងយោធពលខេមរភូមិន្ទ បានឱ្យដឹងថា ចាប់ពីដើមខែមករា រហូតដល់ចុងខែធ្នូ ឆ្នាំ១៩៦៦ កងទ័ពខ្មែរសេរី បានលួចឆ្លងដែនចូលមកក្នុងទឹកដីកម្ពុជា ចំនួន៣០០លើក ហើយត្រូវកងទ័ពរាជរដ្ឋាភិបាល បាញ់ស្លាប់ និងរងរបួសមួយចំនួន។

ចំណែកនៅក្នុងប្រទេសថៃវិញ នៅភាគឦសានទីក្រុងបាងកក ចលនាកុម្មុយនិស្តថៃ ដែលមានឈ្មោះថា រណសិរ្សមាតុភូមិ ក៏បានធ្វើសកម្មភាពយ៉ាងខ្លាំងក្លាដែរ ហើយបណ្តាញ



**ពួកកុម្មុយនិស្តថៃ**

សារព័ត៌មានថៃ មួយចំនួន ក៏បានអំពាវនាវឱ្យសហរដ្ឋអាមេរិក ជួយបង្ក្រាបពួកកុម្មុយនិស្តថៃ នោះផងដែរ។

ឆ្លើយតបតាមការអំពាវនាវរបស់សម្តេចសីហនុ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៦៧ ដែលព្រះអង្គបានស្នើសុំឱ្យសហគមន៍អន្តរជាតិនានាគោរពអធិបតេយ្យភាព បូរណភាពទឹកដីកម្ពុជា និងទទួលស្គាល់បន្ទាត់ព្រំដែនរបស់ប្រទេសកម្ពុជា ជាមួយប្រទេសជិតខាង ពិសេសគឺប្រទេសវៀតណាមខាងត្បូង ដែលគាំទ្រដោយសហរដ្ឋអាមេរិក តាមផែនទី ដែលចូលជាធរមាននៅក្នុងឆ្នាំ១៩៥៤នោះមក នៅថ្ងៃទី៣១ ខែឧសភា រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង (វៀតកុង) ប្រកាសទទួលស្គាល់ខ្សែបន្ទាត់ព្រំដែនកម្ពុជា តាមផែនទីឆ្នាំ១៩៥៤ នោះ។

បន្ទាប់មក នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ១៩៦៧ សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (វៀតណាមខាងជើង)ប្រកាសទទួលស្គាល់ផែនទីឆ្នាំ១៩៥៤ តាមការអំពាវនាវរបស់សម្តេចសីហនុ នោះដែរ។

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៦៧ ទីភ្នាក់ងារបារាំង អាអេហ្វប៉េ(AFP) បានដកស្រង់ខ្លឹមសារនៃលិខិតសម្តេចសីហនុ ផ្ញើទៅឱ្យ ង្វៀន ហ៊ីវ ថ ប្រធានរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង(វៀតកុង)ថា៖ ការទទួលស្គាល់ខ្សែបន្ទាត់ព្រំដែនកម្ពុជា របស់រណសិរ្សជាតិរំដោះ

## របត់នយោបាយ

វៀតណាមខាងត្បូង(វៀតកុង)បានបញ្ចប់នូវការប្រឈមមុខគ្នាតាំងពីអតីតកាលរបស់ប្រទេសទាំងពីរជាស្ថាពរ ហើយបានបំបាត់នូវភាពសៅហ្មងនៃការមិនទុកចិត្តគ្នា រវាងជនជាតិទាំងពីរ ផងដែរ។

ថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៦៧ រណសិរ្សជាតិរំដោះជាតិវៀតណាម(វៀតកុង)បានបើកស្ថានតំណាងអចិន្ត្រៃយ៍របស់ខ្លួននៅទីក្រុងភ្នំពេញ តាមកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នវៀតណាមខាងត្បូង(វៀតកុង)ជាមួយរាជរដ្ឋាភិបាលកម្ពុជា។

ពីរថ្ងៃក្រោយមក នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៦៧ ស្ថានតំណាងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម(វៀតណាមខាងជើង)ប្រចាំក្រុងភ្នំពេញ ត្រូវបានឡើងឋានៈជាស្ថានឯកអគ្គរដ្ឋទូត។

# ២០៦
# សម្តេចសីហនុ ចង់ផ្តាច់ទំនាក់ទំនងការទូតជាមួយចិន




**សម្តេចសីហនុ ជាមួយ មេដឹកនាំចិន ម៉ៅ សេទុង និងជូ អេនឡាយ**
**(ខែកុម្ភៈ ឆ្នាំ១៩៥៦)**

នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៦៧ កាសែតពួកឆ្វេងនិយម បានសរសេរបទវិចារណកថាមួយ មានខ្លឹមសារជាអាទិថា នយោបាយរបស់ពួកចក្រពត្តិអាមេរិក និងបរិវារ នៅតែជានយោបាយល្មោភសង្គ្រាម និងនៅតែប្រើវិធីដដែលៗ អូសទាញប្រទេសតតិយលោកដទៃទៀត ដើម្បីបំណងចុងក្រោយរបស់វា។ ប៉ុន្តែ ជាមួយកម្ពុជា ដែលប្រឆាំងនឹងចក្រពត្តិ ក្រោមការដឹកនាំដ៏ប្រុងប្រយ័ត្នរបស់សម្តេចសហជីវិន ព្រះប្រមុខរដ្ឋ (សម្តេចសីហនុ) បំណងរបស់ខ្មាំងសត្រូវរបស់យើងគ្រប់ប្រភេទនឹងត្រូវរលាយទាំងស្រុងជាមិនខាន។

## របត់នយោបាយ

ចំណែកនៅក្នុងព្រៃនៃភូមិភាគឦសាន តាមរយៈការស្តាប់វិទ្យុប៉េកាំង ដែលផ្សាយសំឡេងជាភាសាខ្មែរ មេខ្មែរក្រហម សាឡុត ស និងសហការីមួយចំនួន ក៏ប្រហែលជាបានដឹងពីការប្រែប្រួលសភាពការណ៍នៅប្រទេសចិន ដោយសារបដិវត្តន៍វប្បធម៌នោះដែរ។

ជាមួយគ្នានោះ សមាគមមិត្តភាពកម្ពុជា-ចិន ដែលមាន ហ៊ូ នឹម ជាប្រធាន ហាក់ដូចជាមានតួនាទីសំខាន់ក្នុងការផ្សព្វផ្សាយចលនាបដិវត្តន៍របស់ចិន និងជាកន្លែងប្រមូលផ្តុំសិស្ស និស្សិត បញ្ញវន្ត ដែលលង់តាមទ្រឹស្តីរបស់លទ្ធិកុម្មុយនិស្តនៅក្នុងប្រទេសផងដែរ ហើយជនជាតិចិនជាច្រើន ដែលមករស់នៅលើទឹកដីកម្ពុជា ក៏មិនខ្លាចនឹងប្រកាសថា ពួកគេ គឺជាពួកម៉ៅនិយម នោះដែរ។

កូនខ្មែរកាត់ចិនជាច្រើន បាននាំគ្នាហែក្បួនបាតុកម្មនៅមុខស្ថានទូតសហភាពសូវៀតស្រែកថ្កោលទោសមេដឹកនាំក្រុងមូស្គូ ថា ជាពួកសេរីនិយម ហើយសិស្ស និស្សិត បញ្ញវន្តខ្មែរដែលមាននិន្នាការឆ្វេងនិយម បានសម្តែងការគាំទ្រសមាគមមិត្តភាពកម្ពុជា-ចិន ដែលលើកសរសើរពីមេដឹកនាំចិន ម៉ៅ សេទុង ផងដែរ។

ជាមួយគ្នានេះ សមាគមមិត្តភាពកម្ពុជា-ចិន បានចែកចាយកូនសៀវភៅក្រហម ដែលនិយាយពីការធ្វើបដិវត្តន៍នៅប្រទេសចិន ដើម្បីផ្សព្វផ្សាយទៅក្នុងស្រទាប់យុវជនខ្មែរ ទៀតផង។

ពេលនោះដែរ ពួកឆ្វេងនិយម ក៏បានចេញផ្សាយកាសែតថ្មីមួយឈ្មោះ កាសែតសុរិយា ដោយមានខ្មែរកម្ពុជាក្រោមម្នាក់ឈ្មោះ សុខ ឡាយ ជាចាងហ្វាង។ សុខ ឡាយ នេះ ពីមុនធ្លាប់ធ្វើជាអ្នកនិពន្ធឱ្យកាសែតបញ្ញាសីលា ដែលមាន ជូ ដេត ហៅស៊ី ជាចាងហ្វាង។

សម្តេចសីហនុ ចាត់ទុកថា កាសែតសុរិយា គ្រាន់តែជាសារជាតិរបស់កាសែតប្រជាជន ដែលអាជ្ញាធរព្រះអង្គបិទលែងឱ្យចេញផ្សាយពីមុនតែប៉ុណ្ណោះ។ ព្រះអង្គយល់ថា ពេលនេះ ពួកឆ្វេងនិយមកាន់តែព្រហើនជាងពេលណាៗទាំងអស់។

នៅក្នុងពេលធ្វើបដិវត្តន៍វប្បធម៌ នាដើមឆ្នាំ១៩៦៧នោះ អតីតអ្នកការទូតចិនជ្រុលនិយមម្នាក់ នៅក្រុងហ្សាការតា ប្រទេសឥណ្ឌូណេស៊ី បានឡើងធ្វើជារដ្ឋមន្ត្រីក្រសួងការបរទេស ក៏បានកាត់ផ្តាច់ចំណងការទូតជាមួយប្រទេសភូមា និងធ្វើឱ្យមានបញ្ហាទំនាក់ទំនងការទូត

ជាមួយប្រទេសនេប៉ាល់ និងប្រទេសកម្ពុជា ផងដែរ បើទោះបីប្រទេសទាំងបីនេះ ធ្លាប់តែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយប្រទេសចិន យ៉ាងណាក៏ដោយ។

ពេលនោះ សម្តេចសីហនុ បម្រុងដកទូតខ្មែរនៅក្រុងប៉េកាំង ឱ្យវិលត្រលប់មកមាតុប្រទេសវិញដែរ ប៉ុន្តែ ដោយសារនាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ បានសុំឱ្យព្រះអង្គមេត្តាអភ័យទោសលើចំណុចខុសឆ្គងទាំងប៉ុន្មាននោះ ទើបព្រះអង្គប្តូរព្រះទ័យវិញ។

---

# ២០៧
# សាស្ត្រាចារ្យកាំង ហ្គិកអ៊ាវ ហៅឌុច
# ញុះញង់ឱ្យសិស្សបះបោរប្រឆាំងនឹងសម្តេចសីហនុ



**កាំង ហ្គិកអ៊ាវ កាលនៅជាសិស្ស**

កាំង ហ្គិកអ៊ាវ កើតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ ក្នុងគ្រួសារ ដែលជាប់សែស្រឡាយជាជនជាតិចិនក្រីក្រមួយ ក្នុងភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ។ ឪពុកឈ្មោះកាំង គី ម្តាយឈ្មោះកាំង គីមស៊ីវ និងមានបងប្អូន៥នាក់(ប្រុស១ ស្រី៤)ក្នុងនោះ កាំង ហ្គិកអ៊ាវជាកូនច្បង។

កាលពីកុមារ កាំង ហ្គិកអ៊ាវ បានចូលរៀន នៅសាលាវត្តពោធិ៍អណ្តែត ដែលមានទីតាំងស្ថិតនៅក្បែរភូមិ ដែលគាត់រស់នៅ។ បន្ទាប់មកទៀត គាត់បានចូលរៀននៅសាលាបឋមសិក្សាកំពង់ចិន ដែលនៅមិនឆ្ងាយប៉ុន្មានពីសាលាវត្តពោធិ៍អណ្តែតនោះដែរ ។

តាំងពីតូចមក កាំង ហ្គិកអ៊ាវ មិនសូវដើរលេងផ្តេសផ្តាសឆ្ងាយពីផ្ទះទេ គឺគាត់តែងតែសំងំនៅក្នុងផ្ទះដើម្បីអានសៀវភៅ។

នៅក្នុងឆ្នាំ១៩៦១ ពេលមានវ័យ១៩ឆ្នាំ កាំង ហ្កិកអ៊ាវ បានប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (សញ្ញាបត្រឌីប្លូម) និងបានបន្តការសិក្សានៅវិទ្យាល័យព្រះសួរ្យវង្ស ទី២ នៅក្រុងសៀមរាប បន្តទៀត ដោយរៀនថ្នាក់ទី២ ទំនើបជាតិ នៅក្នុងឆ្នាំ១៩៦២។

ប៉ុន្តែ ឆ្នាំនោះ គាត់បានប្រលងផ្លោះជាប់មធ្យមសិក្សាបត្រភាគ១(បាក់អង)និងបានមកបន្តការសិក្សាថ្នាក់ទីបញ្ចប់ផ្នែកគណិតវិទ្យា នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៦៣ ហើយបានប្រលងជាប់មធ្យមសិក្សាបត្រភាគ២(បាក់ឌុប) ដោយបានទទួលនិទ្ទេសល្អ ទៀតផង។

ក្រោយប្រលងជាប់មធ្យមសិក្សាបត្រភាគ២ កាំង ហ្កិក អ៊ាវ មានបំណងចង់ធ្វើជាសាស្ត្រាចារ្យផ្នែកគណិតវិទ្យា។ នៅក្នុងឆ្នាំ១៩៦៤ គាត់ក៏បានប្រលងជាប់ក្របខ័ណ្ឌជាសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិ ។

ពេលសិក្សានៅសាលាគរុកោសល្យជាន់ខ្ពស់ គាត់មានទំនាក់ទំនងជាមួយសាស្ត្រាចារ្យម្នាក់ ឈ្មោះ កែ គឹមហួត ជាអ្នកប្រឆាំងយ៉ាងប្តូរផ្តាច់នឹងរបបរាជានិយម និងសង្គមរាស្ត្រនិយមរបស់សម្តេចសីហនុ និងមានទំនាក់ទំនងជាមួយមេខ្មែរក្រហមម្នាក់ទៀត ដែលជាអ្នកគ្រប់គ្រងនៅសាលាគរុកោសល្យនោះដែរ គឺសុន សេន ។

ដោយសារមានទំនាក់ទំនងជាមួយសាស្ត្រាចារ្យជាជនកុម្មុយនិស្តទាំង២នាក់នេះ ធ្វើឱ្យកាំង ហ្កិកអ៊ាវ កាន់តែមានគំនិតធ្វើបដិវត្តន៍ ហើយគាត់តែងតែនិយាយវាយប្រហារប្រឆាំងនឹងរបបរាជានិយមសក្តិភូមិ នាយទុន ដែលបានជិះជាន់សង្កត់សង្កិន កេងប្រវ័ញ្ចមកលើប្រជាជនជាវណ្ណៈកម្មករ កសិករ ។

នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៦៥ កាំង ហ្កិកអ៊ាវ ទទួលសញ្ញាបត្រគរុកោសល្យ ហើយបានក្លាយទៅជាសាស្ត្រាចារ្យផ្នែកគណិតវិទ្យា នៅអនុវិទ្យាល័យបល្ល័ង្គ (ស្រុកបារាយណ៍)។

នៅក្នុងអំឡុងឆ្នាំ១៩៦៥-១៩៦៦ ដោយសារគាត់ជាសាស្ត្រាចារ្យ មានប្រាក់បៀវត្សនោះ អង្គការបដិវត្តន៍ មិនចាត់តាំងគាត់ជាសមាជិកសម្ព័ន្ធយុវកក(យុវជនកុម្មុយនិស្តកម្ពុជា) ទេ គឺចាត់តាំងគាត់ជាជនបង្គោលនៅក្នុងអង្គការមហាជនទៅវិញ។

## របត់នយោបាយ

ដើមឆ្នាំ១៩៦៧ ដោយអង្គការបដិវត្តន៍តម្រូវឱ្យអ្នកតស៊ូម្នាក់ៗ ត្រូវជ្រើសរើសឈ្មោះបដិវត្តន៍នោះ ពេលគាត់ស្នាក់នៅផ្ទះជួលមួយ នៅផ្លូវលេខ១៦៣ ក្បែរផ្សារទួលទំពូង សាស្ត្រាចារ្យ ឆាយ គឹមហ៊ា ជាលេខាសាខាបក្សបានឱ្យគាត់ជ្រើសរើសឈ្មោះបដិវត្តន៍មួយមកប្រើជាសម្ងាត់ដូចអ្នកតស៊ូបដិវត្តន៍ផ្សេងៗទៀតដែរ។ គាត់ក៏បានជ្រើសរើសយកឈ្មោះឌុច ធ្វើជាឈ្មោះបដិវត្តន៍របស់គាត់ផងដែរ។

មូលហេតុ ដែលធ្វើឱ្យគាត់សម្រេចចិត្តជ្រើសរើសយកឈ្មោះ ឌុច ធ្វើជាឈ្មោះបដិវត្តន៍របស់គាត់នោះ គឺដោយសារកាលនៅវ័យកុមារ ជីតាខាងម្តាយគាត់តែងសរសើរពីស្នាដៃជាងម្នាក់ ឈ្មោះឌុច ជាអ្នកធ្វើពុទ្ធបដិមាមួយអង្គពីស៊ីម៉ងត៍ នៅក្នុងវត្តជាភូមិកំណើតរបស់គាត់ ហើយគាត់ក៏បានដក់អារម្មណ៍នឹងជាងចម្លាក់ ឈ្មោះឌុច តាំងពីពេលនោះមក។

លុះពេលគាត់បានចូលរៀននៅសាលាបឋមសិក្សា មានសៀវភៅរៀនអានមួយ ធ្វើឱ្យគាត់ចាប់អារម្មណ៍បំផុតទៅលើអត្ថបទមួយដែលសរសេរថា៖ គ្រូឱ្យសិស្សឈ្មោះឌុច ឡើងអានសៀវភៅ។ ពេលនោះ ឌុច ក្រោកឈរត្រង់ខ្លួន ក្បាលមិនងឹកងាក ហើយអានមួយៗច្បាស់ៗ។ សិស្សឈ្មោះឌុច នៅក្នុងអត្ថបទសៀវភៅរៀនអាននោះ ក៏ធ្វើឱ្យគាត់នៅចងចាំជានិច្ចដែរ។

ឈ្មោះឌុច ជាឈ្មោះសាមញ្ញធម្មតារបស់ជនជាតិខ្មែរ ហើយគាត់ក៏ដឹងដែរថា ឈ្មោះកាំង ហ្កិចអ៊ាវ ជាឈ្មោះដើមរបស់គាត់ គឺជាឈ្មោះរបស់ជនជាតិចិន។ នៅទីបំផុត ក្រោយពីកម្លាំងសមត្ថកិច្ចរបស់សម្តេចសីហនុ ចាប់ខ្លួនអ្នកតស៊ូបដិវត្តន៍ជាង១០នាក់ យកទៅដាក់គុកក្នុងនោះក៏មានសាស្ត្រាចារ្យ ឆាយ គឹមហ៊ា ផងដែរ គាត់បានសម្រេចចិត្តចូលរួមក្នុងចលនាតស៊ូបដិវត្តន៍ពេញទំហឹងតែម្តង ជាមួយមិត្តភក្តិជិតស្និទ្ធមួយចំនួន ដែលកំពុងសិក្សាជានិស្សិតសាស្ត្រាចារ្យសាលាគរុកោសល្យជាន់ខ្ពស់នោះ រួមមាន៖ កង សារ៉ន អតីតសិស្សជំនាន់ទី១ នៅអនុវិទ្យាល័យកំពង់ធំ, ហូ ងា ជាមិត្តភក្តិរបស់គាត់តាំងពីវ័យកុមារ និងអ៊ិន លន ហៅណាត ដែលនៅក្នុងសង្គ្រាមមុនឆ្នាំ១៩៧៥ ជាប្រធានកងពលលេ១២ របស់ភូមិភាគពិសេស។ ក្រោយចលនាតស៊ូបដិវត្តន៍ ទទួលបានជ័យជម្នះថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ អ៊ិន លន ហៅ

ណាត មានតួនាទីជាប្រធានមន្ទីរ ស.២១(គុកទួលស្លែង)រហូតដល់ខែមីនា ១៩៧៦។

នៅដើមខែតុលា ឆ្នាំ១៩៦៧ វន វ៉េត ជាមេដឹកនាំចលនាតស៊ូបដិវត្តន៍ខ្មែរក្រហម ប្រចាំទីក្រុងភ្នំពេញ ប្រាប់ កាំង ហ្គិចអ៊ាវ ហៅសមមិត្តឌុច ថា អង្គការបដិវត្តន៍បានសម្រេច ឱ្យគាត់ចូលជាបក្ខជនត្រៀមហើយ តែការធ្វើពិធីបញ្ចូលជាបក្ខជនត្រៀមនេះ ត្រូវធ្វើនៅឯជនបទ។

នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៦៧ នៅក្នុងព្រៃមួយ ក្នុងភូមិសាស្រ្ត ស្រុកចម្ការលើ មេខ្មែរក្រហម កែ ពក អនុលេខាបក្សភូមិភាគឧត្តរ ក៏បានធ្វើពិធីបញ្ចូលគាត់ជាបក្ខជនត្រៀម។ គាត់បានប្តេជ្ញាចិត្តនៅមុខទង់បក្សថា គាត់ហ៊ានស្លាប់ខ្លួនដើម្បីបក្ស និងហ៊ានធ្វើពលីកម្មគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុតស៊ូរំដោះប្រជាជាតិប្រជាជន ឱ្យរួចផុតពីការជិះជាន់របស់ពួកចក្រពត្តិនិយម ពួកសក្តិភូមិ និងនាយទុនប្រតិកិរិយា។

ពេលធ្វើជាសាស្រ្តាចារ្យបង្រៀននៅអនុវិទ្យាល័យបល្ល័ង្ក និងជាជនបង្គោលរបស់បក្សកុម្មុយនិស្តផងនោះ គាត់ចេះប្រើវិធីសាស្រ្តធ្វើឱ្យកូនសិស្សទាំងអស់ស្រលាញ់ និងចូលចិត្តគាត់ជាងសាស្រ្តាចារ្យផ្សេងៗទៀត ហើយគាត់បានបញ្ចុះបញ្ចូលសិស្សមួយចំនួន ឱ្យដើរតាមគំនិតកុម្មុយនិស្តនិយមដូចគាត់ផងដែរ ។

កាំង ហ្គិចអ៊ាវ ហៅឌុច ក៏ដូច ម៉ម ណៃ ហៅចាន់ ជាចាងហ្វាងអនុវិទ្យាល័យបល្ល័ង្ក នោះដែរ ជាកម្លាំងបង្កប់របស់ខ្មែរក្រហម បានបំផុសសិស្សានុសិស្សឱ្យនាំគ្នាបះបោរវាយបំផ្លាញផ្ទះលក់ទំនិញ ដុតបំផ្លាញរថយន្តឈ្នួល និងបាចខិត្តប័ណ្ណ នៅទីប្រជុំជនស្ទន់ តាមបណ្តោយផ្លូវជាតិលេខ៦ ត្រង់ថ្នល់បំបែកទៅទីរួមខេត្តកំពង់ធំ និងកំពង់ចាម និងបានចោទប្រកាន់ត្រង់ៗថា សម្តេចសីហនុ ជាអ្នកសម្លាប់ខៀវ សំផន និងហ៊ូ យន់ ហើយបានអំពាវនាវឱ្យប្រជាជននាំគ្នាក្រោកឡើងតស៊ូប្រឆាំងនឹងព្រះអង្គទៀតផង។

អ្នកសរសេរខ្លឹមសារខិត្តប័ណ្ណនេះ ត្រូវបានគេសង្ស័យថា គ្មាននរណាក្រៅពី ម៉ម ណៃ ហៅចាន់ ជាចាងហ្វាងអនុវិទ្យាល័យបល្ល័ង្ក នោះទេ។

នៅពេលប្រលងបញ្ចប់ការសិក្សានៅសាលាគរុកោសល្យជាន់ខ្ពស់ នាដើមទសវត្សរ៍ឆ្នាំ

១៩៦០ ម៉ម ណៃ ហៅចាន់ ទទួលបានចំណាត់ថ្នាក់លេខ១ ហើយត្រូវចេញបម្រើការងារនៅវិទ្យាល័យកំពង់ធំ។ មួយឆ្នាំក្រោយមក គាត់ត្រូវបានតែងតាំងជាចាងហ្វាងអនុវិទ្យាល័យបល្ល័ង្ក (ស្រុកបារាយណ៍)។

នៅដើមខែមីនា ឆ្នាំ១៩៦៨ ម៉ម ណៃ ហៅចាន់ ត្រូវសមត្ថកិច្ចរាជការសម្តេចសីហនុចាប់ខ្លួន ហើយតុលាការសឹកបានផ្តន្ទាទោសដាក់ពន្ធនាគារជាច្រើនឆ្នាំ។ តែក្រោយថ្ងៃរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ពួកលន់ នល់ បានដោះលែងគាត់ឱ្យមានសេរីភាពវិញ និងបានចូលបម្រើការងារជាសាស្ត្រាចារ្យក្នុងរបបសាធារណរដ្ឋខ្មែរ បន្តទៀត។

ក្នុងឆ្នាំ១៩៧៣ គាត់បានចូលរួមដឹកនាំគ្រូបង្រៀន និងសាស្ត្រាចារ្យធ្វើបាតុកម្ម ដ៏ហិង្សាមួយនៅសាលាគរុកោសល្យ (វិទ្យាស្ថានជាតិអប់រំ សព្វថ្ងៃ)។ ក្រោយបាតុកម្មដ៏ហិង្សានោះ គាត់ក៏បានរត់គេចខ្លួនចេញពីទីក្រុងភ្នំពេញ ចូលទៅក្នុងទឹកដីតំបន់រំដោះរបស់ចលនាតស៊ូខ្មែរក្រហម។

# ២០៨
# តុលាការសម្តេចសីហនុ កាត់ទោស កាំង ហ្កិចអ៊ាវ ហៅឌុច ឱ្យជាប់គុក២០ឆ្នាំ



**ពន្ធនាគារ ប៉េហ្ស៊ី សម័យសង្គមរាស្ត្រនិយម**

នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៦៨ សាស្ត្រាចារ្យកាំង ហ្កិចអ៊ាវ ហៅឌុច ត្រូវមេប៉ូលិសម្នាក់ឈ្មោះស្រី យិនសឿង មានស្រុកកំណើតនៅភូមិជាមួយគ្នា ចូលរៀនមុនគាត់មួយឆ្នាំ បានដឹកនាំកម្លាំងសមត្ថកិច្ចមួយក្រុម មកចាប់ខ្លួនគាត់ពីស្រុកចំការលើ ខេត្តកំពង់ចាម បញ្ជូនទៅសេនាធិការដ្ឋានកងរាជតម្រួត នៅក្បែរអង់តែនទូរទស្សន៍ទួលគោក ដែលមាន អ៊ុំ ម៉ាន្នូរិន (បងថ្លៃសម្តេចសីហនុ)ជាមេធំជាងគេ។

ពេលគេឃុំឃាំងនៅសេនាធិការដ្ឋានកងរាជតម្រួតនោះ គាត់មានសេរីភាព អាចនិយាយស្តីទាក់ទងជាមួយមន្ត្រីកងរាជតម្រួត ដែលធ្វើការនៅសេនាធិការដ្ឋាននោះ ដោយគ្មានការហាមឃាត់អ្វីឡើយ។ ពេលនោះដែរ មានមន្ត្រីកងរាជតម្រួតពាក់សក្តិ២ម្នាក់ ឈ្មោះជា លាងហន ជាអ្នកសួរចម្លើយគាត់។ តែកងរាជតម្រួតសក្តិ២ម្នាក់នេះ មិនបានធ្វើទារុណកម្មវាយដំបង្ខំឱ្យគាត់ឆ្លើយសារភាពនោះទេ គឺគ្រាន់តែមានការសម្លុតគំរាមខ្លះៗប៉ុណ្ណោះ។ ដោយឡែកខ្មែរក្រហមជាកសិករ៣នាក់ទៀត ដែលនៅកន្លែងឃុំឃាំងជាមួយគ្នា ត្រូវកងរាជតម្រួតធ្វើ

ទារុណកម្មវាយសួរចម្លើយខ្លះៗដែរ។

ប៉ុន្មានថ្ងៃក្រោយមក កាំង ហ្កិចអ៊ាវ ហៅឌុច ត្រូវសមត្ថកិច្ចបញ្ជូនទៅសេនាធិការដ្ឋានកងរាជអាវុធហត្ថក្រុងភ្នំពេញ និងសេនាធិការដ្ឋានកងរាជអាវុធហត្ថផ្ទៃប្រទេស ដើម្បីឃុំឃាំង និងសួរចម្លើយបន្តទៀត ហើយត្រូវមេបន្ទប់ឃុំឃាំង ជាអ្នកទោសដូចគ្នា ហាមគាត់ មិនឱ្យនិយាយស្តីទាក់ទងគ្នាជាមួយអ្នកទោសផ្សេងទៀត។

លុះដល់ខែឧសភា ឆ្នាំ១៩៦៨ ដដែល គាត់ត្រូវបានសមត្ថកិច្ចបញ្ជូនទៅដាក់នៅពន្ធនាគារព្រៃស បន្តទៀត ដោយតុលាការមិនបានបើកសវនាការអ្វីឡើយ។ នៅពន្ធនាគារព្រៃស មេបន្ទប់ឃុំឃាំង ជាអ្នកទោសដូចគ្នា កាចសាហាវណាស់ ប្រសិនបើអ្នកទោសណាម្នាក់ធ្វើអ្វីខុសនឹងបទបញ្ជាតែបន្តិច មេបន្ទប់នោះនឹងរាយការណ៍ ឬវាយទាត់ជាក់ជាមិនខាន។

នៅពន្ធនាគារព្រៃស នោះដែរ កាំង ហ្កិចអ៊ាវ ហៅឌុច បានឃើញសមត្ថកិច្ចលួចបញ្ចេញអ្នកទោសខ្មែរក្រហម ២នាក់ គឺម្នាក់ឈ្មោះឡោ សាត ជាគ្រូបង្រៀន និងម្នាក់ទៀតឈ្មោះឈាង ហុក ជាកសិករ យកទៅសម្លាប់ចោលស្ងាត់ៗ ហើយក៏មានសមត្ថកិច្ចខ្លះ បានលួចប្រាប់គាត់ឱ្យប្រយ័ត្នខ្លួនផងដែរ។

ពេលនោះ គាត់គិតថា បើតុលាការកាត់ទោសគាត់ ឱ្យគេយកទៅប្រហារជីវិតនៅត្រពាំងក្រឡឹង ដូចពួកខ្មែរសេរី ឈ្មោះព្រាប អ៊ិន កាលពីដើមឆ្នាំ១៩៦៤ គាត់សម្រេចចិត្តជាស្រេចហើយថា មុនពេលគេបាញ់ប្រហារ គាត់នឹងលើកដៃឡើងលើ ហើយស្រែកជ័យឃោសខ្លាំងៗថា ជយោ! បក្សកុម្មុយនិស្តកម្ពុជា។ ទន្ទឹមនឹងនោះ គាត់ក៏បានគិតដែរថា បើតុលាការមិនកាត់ទោសប្រហារជីវិត ហើយកាត់ទោសគាត់ឱ្យជាប់គុកមួយជីវិត គឺមានតែស៊ូទ្រាំជាប់គុកមួយជីវិត អ៊ីចឹងទៅ។ នេះជាមនសិការស្មារតី ត្រៀមធ្វើពលីកម្មជាប់ជានិច្ចរបស់គាត់ ដើម្បីបដិវត្តន៍។ គាត់ប្តេជ្ញាចិត្តថា ទោះបីនៅក្នុងកាលៈទេសៈបែបណា ក៏ស្មារតីបដិវត្តន៍របស់គាត់មិនរាថយជាដាច់ខាត។

ក្រោយពីឃុំឃាំងនៅពន្ធនាគារព្រៃស អស់រយៈពេលជាង១ឆ្នាំ នៅក្នុងខែមិថុនា ឆ្នាំ១៩៦៩ សមត្ថកិច្ចក៏បានបញ្ជូនទៅដាក់នៅពន្ធនាគារសង់ត្រាល់ (គុកធំ) នៅក្រោយវត្ត

ឧណ្ណាលោម ជាបន្តទៀត។

នៅក្នុងខែមិថុនា ឆ្នាំ១៩៦៩ តុលាការសឹកបានបើកសវនាការជំនុំជម្រះ ដោយមានមេធាវីវ័យចំណាស់ម្នាក់ ឈ្មោះមួង ដាវខាំ ជាអ្នកការពារក្ដីឱ្យគាត់។ តុលាការ សឹកចោទប្រកាន់គាត់ពីបទប្រឆាំងនឹងក្ដីសុខសាន្តរបស់ព្រះនគរ និងចូលដៃចូលជើងជាមួយពួកបរទេសបំផ្លាញប្រទេសជាតិខ្លួនឯង ហើយបានផ្ដន្ទាទោសឱ្យគាត់ជាប់ពន្ធនាគារ២០ឆ្នាំ និងបង្ខំឱ្យធ្វើការជាទម្ងន់។

ក្រោយពេលដឹងថា តុលាការផ្ដន្ទាទោសឱ្យគាត់ដាក់ពន្ធនាគារ២០ឆ្នាំ ម្ដាយគាត់ក៏បានរត់ទៅជួបបងប្អូនជីទួតមួយរបស់គាត់ ដែលមានកូនម្នាក់ជាក្មួយប្រសារបស់នាយករដ្ឋមន្ត្រី លន់ នល់ ដើម្បីទាក់ទងឱ្យជួយធ្វើអន្តរាគមន៍ បានរួចទោសវិញ។ ពេលនោះ លន់ នល់ ក៏អនុគ្រោះជួយធ្វើអន្តរាគមន៍ឱ្យគាត់បានរួចទោសវិញដែរ តែបានដាក់លក្ខខណ្ឌឱ្យគាត់សរសេរលិខិតសុំទោសជាមុនសិន។ គាត់បានអង្វរម្ដាយថា ពេលនេះ គាត់កំពុងតោងមែកឈើរបស់ខ្មែរក្រហម បើគាត់បោះបង់មែកឈើរបស់ខ្មែរក្រហម ទៅតោងមែកឈើរបស់លន់ នល់... សួរថា តើ លន់ នល់ ទុកចិត្តគាត់ឬទេ? ។ ដូច្នេះ លន់ នល់ ក៏មិនទុកចិត្តគាត់ ហើយខ្មែរក្រហមក៏លែងទុកចិត្តគាត់ដែរ។ ចុងក្រោយ គាត់សម្រេចចិត្តជាប់គុក២០ឆ្នាំ វិញ ប្រសើរជាង។

ក្រោយពេលតុលាការផ្ដន្ទាទោសឱ្យគាត់ជាប់គុក២០ឆ្នាំ នៅពន្ធនាគារសង់ត្រាល់នោះ គាត់បានជួបសាស្ត្រាចារ្យទេព សៀន មេដឹកនាំសម្ងាត់របស់សាខាបក្ស ជាអ្នកទោសនៅក្នុងពន្ធនាគារនោះដែរ ហើយបើទោះបីជាក្លាយជាអ្នកទោសរស់នៅតែក្នុងគុក ក៏ដោយ ក៏ពួកគាត់នៅតែប្ដេជ្ញាចិត្តតស៊ូធ្វើបដិវត្តន៍បន្តទៅទៀត ដោយគ្មានរាថយឡើយ។

នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៦៩ សាស្ត្រាចារ្យទេព សៀន មេដឹកនាំសាខាបក្សក៏បានឧទ្ទេសនាមទទួលស្គាល់គាត់ជាបក្ខជនពេញសិទ្ធិ នៅក្នុងពន្ធនាគារនោះតែម្ដង ដោយសង្ឃឹមជឿជាក់ថា ចលនាតស៊ូបដិវត្តន៍របស់ពួកគាត់នឹងទទួលបានជោគជ័យនាពេលខាងមុខជាមិនខាន។

# ២០៩
# សម្តេចសីហនុ រំលាយចោលសមាគមមិត្តភាពកម្ពុជា-ចិន



**សម្តេចសីហនុ**

ក្រោយ ខៀវ សំផន និងហ៊ូ យន់ រត់ចូលព្រៃ ហ៊ូ នឹម ក៏ចង់រត់គេចខ្លួនដែរ តែ វន វ៉េត ជាមេខ្មែរក្រហម ដឹកនាំចលនាតស៊ូសម្ងាត់នៅទីក្រុងភ្នំពេញ បានណែនាំគាត់ឱ្យនៅរង់ចាំមើលសភាពការណ៍មួយរយៈសិន។

ប៉ុន្មានថ្ងៃក្រោយមក ហ៊ូ នឹម បានចេញសេចក្តីថ្លែងការណ៍បង្ហាញពីភាពស្មោះត្រង់របស់គាត់ចំពោះសម្តេចសីហនុ ម្តងហើយម្តងទៀត។ តែយ៉ាងណា ក៏នៅតែមានជនអនាមិកលួចបាចខិត្តប័ណ្ណទម្លាក់កំហុសទៅលើសម្តេចសីហនុ ថាព្រះអង្គបានឱ្យគេយកខៀវ សំផន និង ហ៊ូ យន់ ទៅសម្លាប់ចោល ហើយបំផុសញុះញង់ឱ្យប្រជារាស្ត្រសិស្សនិស្សិតងើបឡើងប្រឆាំងនឹងព្រះអង្គ។ ពួកអ្នកលួចបាចខិត្តប័ណ្ណនោះ គ្មាននរណាក្រៅពីពួកខ្មែរក្រហមឡើយ។

ប្រហែលមួយខែក្រោយមក សម្តេចសីហនុ ក៏បានឱ្យគេរៀបចំបោះឆ្នោតនៅមណ្ឌល

បោះឆ្នោតស្អាង ខេត្តកណ្ដាលម្ដងទៀត ដើម្បីជ្រើសរើសតំណាងរាស្ដ្រថ្មីម្នាក់ទៀត មកជំនួស កៅអីរបស់ ខៀវ សំផន នៅក្នុងរដ្ឋសភា និងនៅមណ្ឌលបោះឆ្នោតកងមាស ក្នុងខេត្តកំពង់ចាម ម្នាក់ទៀត ដើម្បីជំនួស ហ៊ូ យន់។ ពេលនោះ ហ៊ូ នឹម បានធ្វើការជំទាស់មិនឱ្យមានការរៀបចំបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រថ្មីនោះទេ ដោយគាត់ទាមទារឱ្យរង់ចាំ មួយរយៈទៀតសិន ។

ហ៊ូ នឹម ប្រាកដជាដឹងច្បាស់ថា គ្មាននរណាសម្លាប់ ខៀវ សំផន និងហ៊ូ យន់ ទេ ហើយគាត់យល់ថា ទាំង២នាក់នេះ គ្រាន់តែរត់គេចខ្លួនមួយរយៈសិនប៉ុណ្ណោះ ហើយអាចវិលត្រលប់មកកាន់តំណែងជាតំណាងរាស្ដ្រនេះវិញ នៅថ្ងៃណាមួយមិនខាន។ តែ ហ៊ូ នឹម ក៏មិនហ៊ានប្រកាសប្រាប់អ្នកគាំទ្រចលនាតស៊ូខ្មែរក្រហមឱ្យដឹងថា ខៀវ សំផន និងហ៊ូ យន់ នៅរស់នោះដែរ។

នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៦៧ នៅក្នុងសន្និសីទកាសែតមួយ សម្ដេចសីហនុ មានបន្ទូលចោទសួរថា ហេតុអ្វី បានជាហ៊ូ នឹម ជំទាស់មិនឱ្យមានការបោះឆ្នោតជ្រើសរើសតំណាងរាស្ដ្រថ្មី ដើម្បីជំនួសខៀវ សំផន និង ហ៊ូ យន់ ហើយទទូចឱ្យយើងរង់ចាំអ្នកទាំង២ នាក់នេះ ត្រលប់មកកាន់តំណែងតំណាងរាស្ដ្ររបស់ពួកគេវិញ ?

ព្រះអង្គមានបន្ទូលថា ម៉ម ណៃ (ចាងហ្វាងអនុវិទ្យាល័យបល្ល័ង្ក) និងហ៊ូ នឹម ជាមនុស្សប្រភេទដូចគ្នា។ តែ ហ៊ូ នឹម ជាមនុស្សដ៏មានពិសពុលបំផុត ព្រោះគាត់ជាមនុស្សលាក់ពុតជាងគេ ហើយពួកឆ្វេងនិយម ដែលស្និទ្ធជាមួយចិនកុម្មុយនិស្ដ កំពុងបន្តធ្វើសកម្មភាពវិទ្ធង្សនា យ៉ាងខ្លាំងក្លាចំពោះសង្គមជាតិ។

ពេលនោះដែរ ព្រះអង្គក៏បានអះអាងថា ពួកមេប៉ូលិស និងពួកមេទាហានបានទូលប្រាប់ព្រះអង្គហើយថា គ្មាននរណាសម្លាប់ ខៀវ សំផន និង ហ៊ូ យន់ ទេ គឺពួកគេកំពុងរស់រានមានជីវិតនៅឡើយ។ ប៉ុន្តែ មិនសូវមាននរណាជឿបន្ទូលអះអាងរបស់ព្រះអង្គនេះទេ ។

នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៦៧ សម្ដេចសីហនុ ប្រកាសនៅក្នុងសន្និសីទកាសែតមួយ ថា ព្រះអង្គនឹងរំលាយចោលសមាគមមិត្តភាពរវាងកម្ពុជា និងបរទេសនានាទាំងអស់ចោល ព្រោះការប្រជុំ ឬការតាំងពិព័រណ៍របស់សមាគមនេះ សុទ្ធតែរៀបចំឡើង ផ្ទុយពីស្ថានភាព

វប្បធម៌ សិល្បៈ សេដ្ឋកិច្ចរបស់ជាតិ ដើម្បីធ្វើវិទ្ធង្សនាប្រឆាំងនឹងជាតិឯងតែប៉ុណ្ណោះ ពិសេស គឺសមាគមមិត្តភាពកម្ពុជា-ចិន តែម្តង។

នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៦៧ សម្តេចសីហនុ ក៏បានប្រកាសរំលាយសមាគមមិត្តភាពកម្ពុជា-ចិន លែងឱ្យមាននៅក្នុងប្រទេសតទៅទៀត ដើម្បីកុំឱ្យសមាគមនេះ ធ្វើសកម្មភាពបញ្ចុះបញ្ចូលពួកយុវជនសិស្សនិស្សិតឱ្យឈ្លក់វង្វេងនឹងមនោគមវិជ្ជាម៉ៅនិយម កុម្មុយនិស្តនិយម តាមរយៈការផ្សព្វផ្សាយពីការធ្វើបដិវត្តន៍វប្បធម៌នៅប្រទេសចិន ពិសេសគឺការបោះពុម្ពផ្សព្វផ្សាយសៀវភៅតូចៗ ដែលគេឱ្យឈ្មោះថា សៀវភៅទង់ក្រហម ជាដើម។

ដំណឹងស្តីពីការបិទសមាគមនេះ ត្រូវបានភ្នាក់ងារយកព័ត៌មានរបស់កាសែតស៊ីនហួប្រចាំទីក្រុងភ្នំពេញ រាយការណ៍ទៅឱ្យរដ្ឋាភិបាលក្រុងប៉េកាំង បានដឹងភ្លាមៗនៅក្នុងថ្ងៃទី០២ ខែកញ្ញា នោះផងដែរ។ ប៉ុន្តែ ទោះបីជាយ៉ាងនេះក៏ដោយ ក៏២ថ្ងៃក្រោយមក គឺនៅថ្ងៃទី០៤ ខែកញ្ញា សមាគមមិត្តភាពចិន-កម្ពុជា នៅទីក្រុងប៉េកាំង ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេស នៃសាធារណរដ្ឋប្រជាមានិតចិន ក៏បានផ្ញើសារលិខិតមួយមកមេដឹកនាំសមាគមមិត្តភាពកម្ពុជា-ចិន ដើម្បីស្វាគមន៍អបអរសាទរខួបឆ្នាំទី៣ នៃការបង្កើតសមាគមនោះទៅវិញ។ សារលិខិតនោះក៏បានសរសេរដែរថា ពួកចក្រពត្តិនិយម ពួកសេរីនិយម និង ពួកប្រតិកិរិយាគ្រប់ប្រភេទកំពុងភ័យខ្លាច និងស្អប់ខ្ពើមមិត្តភាព និងសាមគ្គីភាពរបស់សមាគមនេះខ្លាំងណាស់ ហើយពួកគេបានរិះរកគ្រប់មធ្យោបាយ ដើម្បីបង្កទំនាស់ផ្ទៃក្នុង និងធ្វើវិច្ឆេទកម្មបំផ្លាញសមាគមនេះ ប៉ុន្តែការធ្វើដូច្នេះ គឺមិនខុសពីពួកគេ លើកដុំថ្មទម្លាក់លើខ្នងជើងរបស់ពួកគេយ៉ាងឆ្កួតលេលានោះឡើយ ហើយទង្វើនេះពិតជានឹងទទួលបរាជ័យជាមិនខាន ។

នេះអាចចាត់ទុកថា ជាការវាយប្រហាររបស់មេដឹកនាំសមាគមមិត្តភាពចិន-កម្ពុជា នៅទីក្រុងប៉េកាំង មកលើសម្តេច សីហនុ យ៉ាងដូច្នេះដែរ បើទោះបីការលើកឡើងខាងលើនេះ មិនបាននិយាយឱ្យចំព្រះនាមព្រះអង្គ ក៏ដោយ ។

បើតាមខ្លឹមសារនៃសារលិខិតនោះ ទោះបីសម្តេចសីហនុ មិនមែនជាពួកចក្រពត្តិ

និយម ឬពួកសេរីនិយម ក៏សមាគមមិត្តភាពចិន-កម្ពុជា នៅទីក្រុងប៉េកាំង ចាត់ទុកព្រះអង្គជាពួកប្រតិកិរិយាដែរ។ ជាមួយគ្នានេះដែរ អ្នកឆ្លើយឆ្លងកាសែតស៊ីនហួ ប្រចាំក្រុងភ្នំពេញ បានរាយការណ៍ទៅទីក្រុងប៉េកាំង ថា ពួកកម្មករកម្ពុជា បាននាំគ្នាតាក់តែងកំណាព្យមួយ ដោយសម្ដែងការកោតសរសើរប្រធានម៉ៅ និងនាំគ្នាស្រែកច្រៀងថា ប្រធានម៉ៅ គឺជាព្រះអាទិត្យក្រហមនៅក្នុងបេះដូងរបស់ពួកគេទៀតផង។

តាមការពិត មិនមែនពួកកម្មករកម្ពុជា នាំគ្នាតាក់តែងកំណាព្យសរសើរប្រធានម៉ៅ ដូចអ្នកឆ្លើយឆ្លងកាសែតស៊ីនហួ បានរាយការណ៍នោះទេ គឺពួកមេខ្មែរក្រហម ជាអ្នកតាក់តែងកំណាព្យនោះ ឱ្យពួកកម្មករកម្ពុជា នាំគ្នាស្រែកច្រៀងតែប៉ុណ្ណោះ។

បន្ទាប់មក សម្ដេចសីហនុ បានបិទព្រឹត្តិបត្រព័ត៌មានស៊ីនហួ នៅទីក្រុងភ្នំពេញ លែងឱ្យចែកផ្សាយតទៅទៀត ហើយព្រះអង្គក្រោធពិរោធយ៉ាងខ្លាំងចំពោះ ភោគ ឆាយ ដែលបានយកខ្លឹមសារទាំងស្រុងនៃលិខិតជូនពររបស់សហគមមិត្តភាពចិន-កម្ពុជា មកពីក្រុងប៉េកាំងនោះ ទៅចុះផ្សាយនៅលើទំព័រកាសែតឡា ដេប៉េស្ហ ( LA DEPECHE ) នៅថ្ងៃទី០៩ ខែកញ្ញា។

ដោយសាររឿងនេះ ព្រះអង្គប្រកាសបិទសមាគមនិស្សិតខ្មែររបស់ ភោគ ឆាយ នោះ និងបិទរោងពុម្ពចិន លែងឱ្យបោះពុម្ពកូនសៀវភៅ និងឯកសារផ្សេងៗទៀតរបស់ពួកខ្មែរក្រហមផងដែរ។

ជាមួយគ្នានោះ ព្រះអង្គក៏បានបណ្ដេញ សូ ណែម ចេញពីតំណែងរដ្ឋមន្ត្រីក្រសួងសាធារណសុខាភិបាល និង ចៅ សេង ចេញពីតំណែងទេសរដ្ឋមន្ត្រី ទទួលបន្ទុកសេដ្ឋកិច្ច ផងដែរ។

មិនតែប៉ុណ្ណោះ ព្រះអង្គក៏បានប្រកាស ឱ្យផ្អាកការបោះពុម្ពផ្សាយកាសែតឯកជនទាំងអស់ មិនថា កាសែតនោះមាននិន្នាការឆ្វេងនិយម ឬស្ដាំនិយមឡើយ គឺត្រូវផ្អាកទាំងអស់។

លើសពីនេះទៅទៀត ព្រះអង្គថែមទាំងមានគម្រោងបណ្ដេញឯកអគ្គរដ្ឋទូតចិន ឱ្យចាកចេញពីកម្ពុជា ទៀតផង។ តែដោយមានអន្តរាគមន៍ពី ជូ អេនឡាយ ព្រះអង្គបង្វែរព្រះទ័យបោះបង់ចោលគម្រោងការនេះវិញ។ ប៉ុន្តែ ទោះបីយ៉ាងនេះក៏ដោយ ក៏ស្ថានទូតចិននៅទីក្រុងភ្នំពេញ ដែលស្ថិតនៅតាមបណ្ដោយមហាវិថីម៉ៅ សេទុង ត្រូវហាមឃាត់មិនឱ្យប្រជារាស្ត្រ

ខ្មែរ ឬអាណិកជនចិនណាម្នាក់ចេញចូលជាដាច់ខាត បើទោះបីជាមានពិធីជាផ្លូវការអ្វីក៏ដោយ។

ពេលនោះ ក៏មានយុវជនចិន នៅក្រុងភ្នំពេញ មួយចំនួនបានរំលោភបំពានលើការហាមឃាត់នេះ ក៏ត្រូវកម្លាំងសមត្ថកិច្ចប៉ូលិសចាប់ខ្លួនយកទៅវាយធ្វើទារុណកម្ម ហើយកាសែត ស៊ីនហួ និងខ្សែភាពយន្ត ព្រមទាំងរូបថតទាំងឡាយ ដែលនាំមកពីប្រទេសចិន ត្រូវបានហាមឃាត់មិនឱ្យផ្សព្វផ្សាយ ឬត្រូវដកទុកទៀតផង។ តែរដ្ឋាភិបាលចិន មិនមានបញ្ចេញប្រតិកម្មអ្វីមួយចំពោះសម្ដេចសីហនុ ពីរឿងនេះឡើយ ។

# ២១០
# សម្តេចសីហនុ ឱ្យគេយកខៀវ សំផន និងហ៊ូ យន់ ទៅសម្លាប់មែនឬ?



**សម្តេចសីហនុ**

ក្រោយពីសម្តេចសីហនុ ចោទប្រកាន់ថា ខៀវ សំផន និងហ៊ូ យន់ ជាមេនាំបំបះបំបោរប្រជាកសិករនៅសំឡូត ឱ្យងើបឡើងប្រឆាំងនឹងរាជរដ្ឋាភិបាល ព្រមទាំងគំរាមនាំខ្លួនទៅឲ្យតុលាការសឹកកាត់ទោសមក ពួកគាត់ទាំងពីរក៏មានការព្រួយបារម្ភពីបញ្ហាសន្តិសុខផ្ទាល់ខ្លួនណាស់ដែរ។

ពេលនោះ មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា ក៏បានលួចផ្ញើសំបុត្រមួយតាមរយៈមិត្តភក្តិម្នាក់ធ្លាប់រៀនជាមួយគ្នានៅវិទ្យាល័យព្រះស៊ីសុវត្ថិ មកឱ្យខៀវ សំផន។ ក្នុងសំបុត្រនោះ មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា សុំឱ្យគាត់រត់គេចខ្លួនទៅកន្លែងណាមួយនៅតំបន់ជនបទ ដោយពួកគេជាអ្នកចាត់ចែងនាំចេញពីក្រុងភ្នំពេញ។ ដោយពិនិត្យឃើញថា សំបុត្រនោះ មានការវិភាគសភាពការណ៍ល្អិតល្អន់បង្គួរ ដែលនាំឲ្យគាត់មិនមានការសង្ស័យអ្វីចំពោះម្ចាស់សំបុត្រនោះ។

ម្យ៉ាងទៀត អ្នកនាំយកសំបុត្រនេះមកឲ្យគាត់ ជាមនុស្សធ្លាប់ស្គាល់គ្នាច្បាស់ កាលនៅរៀនវិទ្យាល័យព្រះស៊ីសុវត្ថិ ជាមួយគ្នា ហើយគាត់ក៏ធ្លាប់បានចូលប្រជុំនៅទីស្នាក់ការសមាគមអតីតសិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ ជាមួយគ្នាហូរហែមកដែរ គាត់ក៏សម្រេចចិត្តចាកចេញពីក្រុងភ្នំពេញ តាមការណែនាំរបស់មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា។

ដល់វេលាកំណត់ចេញដំណើរ នៅពេលព្រលប់ ខៀវ សំផន និងហ៊ូ យន់ ត្រូវបានគេឱ្យឡើងលើរថយន្តមួយគ្រឿង ចេញទៅតាមផ្លូវជាតិលេខ៣។ នៅពេលទៅដល់ខាងកើតទីប្រជុំជនអង្គតាសោម (ស្រុកត្រាំកក់ ខេត្តតាកែវ) រថយន្តក៏ឈប់ដាក់ពួកគាត់ចុះ។ នៅទីនោះមានកសិករមួយក្រុមរង់ចាំទទួល និងដឹកពួកគាត់តាមកង់ចុះពីលើថ្នល់ជាតិ។

ខៀវ សំផន សង្កេតឃើញថា ពួកគេមានវិធានការការពារពួកគាត់ហ្មត់ចត់ណាស់។ ពេលចុះពីលើថ្នល់ជាតិ មានមនុស្សឈរយាម និងប្រើពាក្យសម្ងាត់បណ្តាក់គ្នាតាមផ្លូវ។ ដោយសារផ្កាយនៅខាងលើ ធ្វើឱ្យពួកគាត់សម្លឹងឃើញពន្លឺព្រាលៗនៅតាមផ្លូវ។

មិនដល់កន្លះម៉ោងផង ពួកគេក៏បាននាំពួកគាត់ទៅដល់គោលដៅ នៅក្នុងភូមិដាងទង ឃុំដាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ។ គេបានអញ្ជើញពួកគាត់ឲ្យឡើងទៅលើផ្ទះក្បឿងធំមួយ ហើយពេលឡើងទៅដល់ គាត់ឃើញមនុស្សម្នាក់ ដែលគាត់មិនធ្លាប់ស្គាល់ពីមុនមក កំពុងអង្គុយរង់ចាំពួកគាត់នៅលើផ្ទះក្បឿងធំនោះ។ បន្តិចក្រោយមក ទើបដឹងថាមនុស្សម្នាក់នោះ ឈ្មោះ តាម៉ុក។

តាម៉ុក អញ្ជើញពួកគាត់ និងម្ចាស់ផ្ទះអង្គុយជុំគ្នាក្រោមពន្លឺចង្កៀងប្រេងកាតធ្វើអំពីកំប៉ុងទឹកដោះគោមួយ។ តាមពន្លឺព្រាលៗនៃចង្កៀងប្រេងកាតនោះ ខៀវ សំផន ពិនិត្យឃើញថា តាម៉ុក មើលទៅដូចជាកសិករផ្សេងៗទៀតនៅក្នុងភូមិនោះដែរ។ តាម៉ុក ស្លៀកខោខ្មៅពាក់អាវខ្មៅដៃខ្លី អត់មានដាក់ឡេវ ដៃកាន់ក្រមាមួយ។

ពិធីស្វាគមន៍នៃការមកដល់របស់ពួកគាត់ គ្មានអ្វីវែងឆ្ងាយទេ គឺតាម៉ុក គ្រាន់តែសួរសុខទុក្ខអំពីការធ្វើដំណើរតាមផ្លូវ រួចផ្តាំពួកគាត់កុំឱ្យចុះពីផ្ទះ លើកលែងតែពេលយប់ដើម្បីបត់ជើង និងងូតទឹក ហើយកុំឲ្យពួកគាត់និយាយឮៗពេកតែប៉ុណ្ណោះ។

ដាមួយគ្នានោះ តាម៉ុក ក៏បានណែនាំម្ចាស់ផ្ទះ និងគ្រួសារថា ដាច់ខាតកុំឲ្យនរណាផ្សេងទៀតឡើងលើផ្ទះនេះឲ្យសោះ ហើយងាកមកនិយាយប្រាប់ពួកគាត់ថា កុំឲ្យពួកគាត់មានការព្រួយបារម្ភពីបញ្ហាសន្តិសុខអី រួចក៏លាចេញទៅវិញបាត់។

នៅទីនោះដំបូង ខៀវ សំផន មិនសូវមានការធុញថប់ក្នុងចិត្តប៉ុន្មានទេ។ តែបួនប្រាំថ្ងៃក្រោយមក គាត់ព្រួយចិត្តគិតច្រើន និងអស់សង្ឃឹមខ្លាំង ហើយគាត់ក៏មិនបានយកចិត្តទុកដាក់លើអ្វីៗដែលនៅជុំវិញខ្លួនគាត់ដែរ។ ប៉ុន្តែ ហ៊ូ យន់ បាននិយាយពាក្យកំប្លែង ដើម្បីលេងសើចខ្លះៗ។ នៅក្បែរមាត់បង្អួច ហ៊ូ យន់ អង្គុយច្រៀងបទចម្រៀងរបស់ស៊ីន ស៊ីសាមុត មានចំណងជើងថា ចម្ប៉ាបាត់ដំបង ដោយសំឡេងហ៊ឹមៗ។

ខៀវ សំផន នៅតែសោកស្តាយ ព្រោះមុនពេលចេញមក គាត់មិនបានជម្រាបលាម្តាយរបស់គាត់ សូម្បីមួយម៉ាត់។ គាត់នឹកឃើញពាក្យទូន្មានរបស់ម្តាយគាត់ដែលថា ពងមាន់កុំជល់នឹងថ្ម។ គាត់សោកស្តាយណាស់ ព្រោះមិនបានស្តាប់តាមការទូន្មានរបស់ម្តាយគាត់។ ឥឡូវ លទ្ធផលវាយ៉ាងនេះ។

ខៀវ សំផន បញ្ជាក់ថា មូលហេតុដែលគាត់សុខចិត្តគេចខ្លួនចេញពីក្រុងភ្នំពេញ នៅពេលនោះគឺចាកចេញទាំងបង្ខំចិត្ត។ មិនមែនជាការសម្រេចចិត្តដោយមានចេតនា ចង់បោះបង់ការងារជាអ្នកតំណាងរាស្ត្រនៅក្នុងរដ្ឋសភា ទៅជ្រើសរើសយកការតស៊ូបដិវត្តន៍អីនោះទេ។ គាត់នៅតែមិនអស់ចិត្តពីរឿងសម្តេចសីហនុ ចោទប្រកាន់មកលើគាត់ថាជាអ្នកធ្វើវិទ្ធង្សនាញុះញង់ឱ្យប្រជារាស្ត្រជាកសិករនៅសំឡូត បះបោរប្រឆាំងនឹងព្រះអង្គ។

គាត់ចេះតែចោទសួរខ្លួនឯង ដដែលៗថា តើកាសែតអ្នកសង្កេតការណ៍ (Observa_teur) របស់គាត់ ជាអ្នកធ្វើវិទ្ធង្សនា បំផុសញុះញង់ឱ្យប្រជារាស្ត្រជាកសិករនៅសំឡូត ងើបឡើងបះបោរប្រឆាំងនឹងព្រះអង្គយ៉ាងម៉េចទៅ? បើកាសែតរបស់គាត់ចេញផ្សាយជាភាសាបារាំង សម្រាប់តែអ្នកមានកម្រិតវប្បធម៌ខ្ពស់គួរសម ចេះភាសាបារាំងទេ ទើបអានបាន? តើកាសែតនេះអាចទៅញុះញង់ប្រជារាស្ត្រជាកសិករដែលមិនចេះភាសាបារាំង នៅសំឡូតនោះបានដែរឬទេ?។

## របត់នយោបាយ

កាសែតនេះចុះផ្សាយអ្វីៗ គឺដើម្បីចង់ឲ្យប្រទេសកម្ពុជា បានរីកចម្រើនខាងសេដ្ឋកិច្ច និងសង្គម ព្រមទាំងមានកិត្តិយសខ្ពង់ខ្ពស់ ដូចប្រទេសជាតិគេផ្សេងទៀតប៉ុណ្ណោះ។ គាត់មានអារម្មណ៍សោកស្តាយ ព្រោះត្រូវខកខានលែងបានធ្វើសកម្មភាពនៅក្នុងសង្គម ដូចដែលគាត់ព្យាយាមធ្វើតាំងពីឆ្នាំ១៩៥៩នោះទៀតហើយ។

តែពីមួយថ្ងៃ ទៅមួយថ្ងៃ នៅខាងក្រោមផ្ទះ ដែលគាត់ស្នាក់នៅនោះ គាត់ឮអ្នកភូមិជជែកគ្នាដោយបន្លឺពាក្យប្លែកៗគួរឱ្យចាប់អារម្មណ៍ ដូចជាពាក្យថា ឯករាជ្យម្ចាស់ការ, ខ្លួនទីពឹងខ្លួន ឬខ្លួនធ្វើម្ចាស់របស់ខ្លួន... ជាដើម។ ពេលខ្លះ ពួកគាត់បានឮសូរអ្នកភូមិជជែកគ្នាពីបទពិសោធនៃការតស៊ូកន្លងមក ឬពីការដកស្រង់មេរៀន ដែលត្រូវរៀនសូត្រពីកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ជាដើម។

គាត់មិននឹកស្មានថា ពួកអ្នកភូមិនៅទីនេះជជែកគ្នាដោយប្រើពាក្យប្លែកៗ គួរឱ្យចាប់អារម្មណ៍របៀបនេះសោះ? គាត់មានការភ្ញាក់ផ្អើល និងងឿងឆ្ងល់ជាខ្លាំង ហើយគាត់កាន់តែយកចិត្តទុកដាក់តាមស្តាប់ពួកគេ ថែមទៀត។

ស្តាប់ពួកកសិករទាំងនោះយូរៗទៅ ទើបគាត់ដឹងថា ពួកមេដឹកនាំខ្មែរក្រហម នៅទីនោះបានជួយចាត់តាំងឱ្យមានសមាគមកសិករច្រើនបែប ច្រើនយ៉ាង រួមមានតាំងពីសមាគមស្រូវសម្រាប់ជួយឧបត្ថម្ភកសិករណាដែលមានការខ្វះខាតស្រូវហូបចុក នៅរដូវធ្វើស្រែខែវស្សា។

បង្កើតឱ្យមានក្រុមប្រវាស់ដៃ ជួយភ្ជួររាស់សាបព្រោះដកស្ទូងគ្នា ទៅវិញទៅមក។ រហូតដល់បង្កើតសមាគម ដើម្បីទិញថ្នាំពេទ្យ ឬប្រេងកាតសម្រាប់យកមកលក់ចែកគ្នាប្រើ ដោយគិតតម្លៃសមរម្យ។ ដោយសារការផ្តោតអារម្មណ៍ទៅលើសកម្មភាពប្លែកៗដូចខាងលើនេះ ទើបពួកគាត់អាចសំងំរស់នៅក្នុងភូមិជាងទងនោះ បាន៤ខែ ទោះបីមិនបានចេញទៅណាមកណា ក៏ដោយ ក៏ពួកគាត់មិនសូវអផ្សុកប៉ុន្មានដែរ។

តែបើពួកគាត់ត្រូវការទិញអ្វីហូប អ្នកភូមិអាចទៅទិញឲ្យបាននៅផ្សារអង្គតាសោម។ ក្រោយមក តាម៉ុក ក៏បានមកប្រាប់ពួកគាត់ថា គេនឹងនាំពួកគាត់ចូលទៅកាន់តែឆ្ងាយពីផ្លូវជាតិជាងមុនទៅទៀត។ តែមិនប្រាប់ពួកគាត់ថា ទៅណាពិតប្រាកដទេ។ តាម៉ុក គ្រាន់តែប្រាប់

ពួកគាត់ថា សំខាន់បំផុត គឺកុំឲ្យគេចាប់ពួកគាត់បាន ដូច្នេះគេមិនឱ្យពួកគាត់នៅមួយកន្លែងយូរពេកទេ។

ក្រោយចាកចេញពីភូមិដាងទង ទៅរស់នៅកន្លែងថ្មីនោះបានមួយរយៈខ្លី ហ៊ូ យន់ ក៏ចាប់ផ្តើមធុញទ្រាន់នឹងការរស់នៅរបៀបលាក់ខ្លួននេះ រហូតដល់កើតការមួម៉ៅ។

ថ្ងៃមួយ ហ៊ូ យន់ ងើបពីដំណេកពេលភ្លឺស្រាងៗ ហើយបត់ខោអាវមុងភួយរបស់គាត់ដាក់ក្នុងសម្ពាយ។ ដោយមានការងឿងឆ្ងល់ ខៀវ សំផន ក៏សួរថា បងរៀបចំទៅណាហ្នឹង? គាត់ឆ្លើយមកវិញដោយកំបុតកំបុយថា ខ្ញុំទៅផ្ទះវិញហើយ!។

ខៀវ សំផន ប្រាប់ថា មកដល់ពេលនេះហើយ ត្រលប់ទៅវិញមិនបានទេ។ បើបងត្រលប់ទៅវិញ ចំពោះរូបបងផ្ទាល់ ក៏ដូចជាបងប្អូនទាំងអស់ ដែលបានជួយលាក់បំពួនពួកយើងពិតជាមានគ្រោះថ្នាក់ណាស់។ ហ៊ូ យន់ ឆ្លើយមកវិញថា ខ្ញុំមិនមែនកូនក្មេងទេ។ ពេលនោះ ខៀវ សំផន ក៏មិនដឹងរកពាក្យពេចន៍អ្វីនិយាយតទៅទៀតដែរ តែគាត់ទទូចសុំឲ្យ ហ៊ូ យន់ រង់ចាំជួបពិភាក្សាគ្នាជាមួយតាម៉ុក សិន ។

ពេលព្រលប់ទើប តាម៉ុក មកដល់ ក៏សម្របសម្រួលឲ្យហ៊ូ យន់ ត្រលប់ទៅស្នាក់នៅឯភូមិដាងទង វិញ។ ចំណែក ខៀវ សំផន ត្រូវតាម៉ុក នាំបន្តដំណើរតាំងពីក្បែរផ្លូវជាតិលេខ៣ រហូតដល់ជើងភ្នំឱរ៉ាល់ ឱ្យទៅស្នាក់កន្លែងផ្សេងមួយទៀត ដោយដើរកាត់ពីភូមិមួយទៅភូមិមួយ ដែលអ្នកភូមិទាំងអស់នោះសុទ្ធតែជាខ្សែរយៈសម្ងាត់របស់ពួកខ្មែរក្រហម។

# ២១១
# ជីវិតខៀវ សំផន ក្នុងតំបន់តស៊ូខ្មែរក្រហម



**ខៀវ សំផនសម្ដែងជាតួនាងសីតា ក្នុងរឿងរាមកេរ្តិ៍ នៅក្រុងបារីស ឆ្នាំ១៩៥៧**

នៅកន្លែងថ្មីនោះ ខៀវ សំផន មិននឹកស្មានថា ជាខ្សែរយៈចាត់តាំងរបស់ពួកខ្មែរក្រហមទេ។ ទីនោះ មានតែផ្ទះខ្ទមតូចៗ៤ សង់ខ្ពស់ពីដីនៅក្រោមម្លប់ដើមស្វាយធំមួយតែប៉ុណ្ណោះ។ ពិតមែនហើយ នៅទីនោះមិនសូវមានអ្នកដំណើរចេញចូលទេ តែពេលខ្លះ ក៏មានឈ្មួញចិនចូលមករកទិញជ្រូកដែរ។ គេឲ្យគាត់នៅក្នុងកុង(ជង្រុក)ដាក់ស្រូវមួយ ដើម្បីលាក់ខ្លួន កុំឲ្យអ្នកដំណើរមកពីឆ្ងាយឃើញ។

ខៀវ សំផន រម្លឹកថា ពេលព្រឹក ម្ចាស់ផ្ទះខ្ទម ដែលគាត់ស្នាក់នៅនោះ ចេញទៅធ្វើស្រែបាត់អស់ រហូតដល់ពេលល្ងាច ទើបត្រលប់មកវិញ នៅសល់តែកូនស្រីតូចម្នាក់អាយុប្រហែល១២ឆ្នាំ នៅជាមួយប្អូនតូចគេម្នាក់។ ចំណែកម្ចាស់ផ្ទះខ្ទម៣គ្រួសារទៀត នាំកូនចៅទៅរកបោចផ្ដៅនៅក្នុងព្រៃជ្រៅអស់។ បីទៅបួនថ្ងៃ ទើបពួកគាត់ត្រលប់មកវិញ ហើយយកផ្ដៅទៅលក់នៅជិតត្រពាំងក្រឡឹង តាមផ្លូវជាតិលេខ៤ ដោយចំណាយពេលទាំងទៅទាំងមក

ប្រហែលមួយថ្ងៃ។ ។

ក្មេងស្រីជាកូនម្ចាស់ផ្ទះខ្ទមនោះ ក្រោកពីព្រឹក បុកស្រូវ ឯប្អូនៗគេស្រាតននលវារលេងនៅនឹងដី។ នាងតែងតែលើកបាយឱ្យគាត់ ដែលសំងំលាក់ខ្លួននៅក្នុងខ្ទមនោះទទួលទានដោយទៀងទាត់។ រាល់ថ្ងៃ មានបាយ និងមានជ្រក់សម្បកឪឡឹកជាមួយជីរនាងវង លាយអំបិលតិចៗ។ ពេលខ្លះក៏មានត្រីងៀត។ ពេលខ្លះក៏មានសម្លត្រួយល្ពៅ និងសម្លជំទ្បូងឈាមមាន់ ជាដើម។

ថ្ងៃមួយ មានយាយម្នាក់នៅខ្ទមក្បែរនោះ បានកាន់ចេកមួយស្និតដើរមកឡើងជណ្ដើរខ្ទមរបស់គាត់ស្នាក់នៅ ដោយយកដៃម្ខាងរាវស្ទាបកាំជណ្ដើរ។ ឃើញដូច្នេះ គាត់ក៏ស្ទុះទៅជួយកាន់ដៃគាត់ឡើងឲ្យផុតពីកាំជណ្ដើរ។ យាយយកដៃស្ទាបក្បាល និងថ្ពាល់គាត់ និងបង្ហូរទឹកភ្នែករហាម ហើយពោលថា កូនអើយ! សាច់ទន់ល្អក់ ចុះម្ដេចក៏មកនៅទីនេះនឹងគេដែរ។ ចំពោះម៉ែមិនអីទេ ម៉ែធ្លាប់តែប៉ុណ្ណឹងទៅហើយ។ ចុះកូនឯង...។

ខៀវ សំផន រញ្ជួលចិត្តជាខ្លាំង ក៏តបទៅវិញថា មិនអីទេម៉ែ!។ ម៉ែ និងមាមីងនៅទីនេះល្អណាស់។ ដូច្នេះគ្មានអ្វីដែលថា ខ្ញុំនៅទីនេះជាមួយមិនបាននោះទេ។

ខៀវ សំផន យល់ឃើញថា យាយកសិកររូបនោះបានសម្ដែងមនោសញ្ចេតនាអាណិតស្រលាញ់គាត់ដោយស្មោះពិតប្រាកដណាស់ ហើយយាយប្រាកដជាដឹងថា គាត់មានឋានៈក្នុងសង្គមខ្ពង់ខ្ពស់ណាស់។ ដូច្នេះនាំឲ្យគាត់កាន់តែគិតវែងឆ្ងាយថា សង្គមជាតិយើង ម៉េចក៏ជីវភាពមានអ្នកមាន និងអ្នកក្រ ខុសគ្នាដល់ម្លឹង។

តែពេលនោះ ខៀវ សំផន ក៏មានការរំភើបចិត្តខ្លាំងណាស់ដែរ ពីព្រោះគាត់កំពុងមើលឃើញកម្លាំងថ្មីមួយ ដែលជាកម្លាំងជាតិពិតប្រាកដកំពុងលេចចេញជារូបរាងឡើង ហើយចាក់ឫសជ្រៅទៅក្នុងសន្ដានចិត្តកសិករនៅតាមតំបន់ជនបទ នៅចំពេល ដែលហេតុការណ៍ជាច្រើនបង្ហាញសញ្ញាឲ្យឃើញថា ប្រទេសជាតិកំពុងរមៀលធ្លាក់ចុះទៅមាត់ជ្រោះជ្រៅនៃគ្រោះមហន្តរាយដ៏ធំមួយ។ គាត់យល់ឃើញថា កម្លាំងនេះអាចដើរតួដូចបក្សកុម្មុយនិស្តបារាំង នៅពេលប្រទេសបារាំង ត្រូវពួកណាហ្ស៊ីអាល្លឺម៉ង់ ចូលឈ្លានពាននោះដែរ។

## របត់នយោបាយ

ខៀវ សំផន រម្លឹកថា នៅពេលគាត់ស្នាក់នៅក្នុងផ្ទះខ្ទមតូចចង្អៀតជាមួយកសិករនោះ យូរៗ ម្តង តាម៉ុក ស្លៀកខោជើងខ្លី ពាក់អាវដៃខ្លីព៌ណខ្មៅ ពេលខ្លះគាត់អត់ពាក់អាវ បញ្ចេញ រោមពេញទ្រូង និងពូថៅមួយសៀតនៅក្នុងក្រមាក្រវាត់នៅនឹងចង្កេះ បានជិះកង់កញ្ចាស់ មួយគ្រឿងមកសួរសុខទុក្ខគាត់ដោយរាក់ទាក់ ហើយប្រាប់គាត់ថា ទើបតែមកពីធ្វើការនៅ ឈូក នៅកំពត ឬនៅព្រៃនប់ រួចចេញទៅវិញបាត់ ដោយមិនប្រាប់គាត់ថា ទៅណាទេ?។

ក្រោយពីបានឃើញសកម្មភាពរបស់ តាម៉ុក គាត់គិតថា ប្រសិនបើគាត់វិញ ពុំអាច ធ្វើដូច តាម៉ុក បានទេ។ គាត់កាន់តែមានមោទកភាពចំពោះតាម៉ុក ដែលគ្រាន់តែជាកសិករ ម្នាក់ បានក្លាយទៅជាអ្នកដឹកនាំដ៏សំខាន់នៅក្នុងចលនាតស៊ូជាតិ និងមានសមត្ថភាពពន្យល់ កសិករនៅតាមជនបទ ឱ្យមានជំនឿ និងស្ម័គ្រចិត្តចូលរួមក្នុងចលនាតស៊ូជាមួយគាត់យ៉ាង ប្តូរផ្តាច់។

តែខៀវ សំផន មិនដែលឮតាម៉ុក និយាយពីរចនាសម្ព័ន្ធចាត់តាំងរបស់បក្សកុម្មុយនិស្ត កម្ពុជា ម្តងណាទេ ពោលគឺមិនដែលនិយាយថា នរណាជាអ្នកដឹកនាំចលនាតស៊ូនោះ ហើយ កំពុងនៅឯណាដែរ? ។

ខៀវ សំផន ក៏យល់ដែរថា នេះជាវិន័យនៃការតស៊ូសម្ងាត់ ហើយគាត់ក៏មិនចង់ដឹងពី រឿងហ្នឹងដែរ ប៉ុន្តែ តាម៉ុក បាននិយាយពីសភាពការណ៍ទូទៅនៅក្នុងប្រទេសថា តាំងពីពេល គាត់(ខៀវ សំផន) ចេញពីទីក្រុងភ្នំពេញមក សភាពការណ៍កាន់តែអាក្រក់ទៅៗ ពិសេស សភាពការណ៍នៅភ្នំវ៉ាយចាប នៅស្រុកសំឡូត។

តាម៉ុក និយាយថា រហូតមកដល់ពេលនេះ ពួកលន់ នល់ នៅតែបន្តកាត់កបងប្អូន កសិករយើង អស់ជាង១០០០នាក់ហើយ ។ ឥឡូវនេះមានការរាតត្បាតដល់ទីក្រុងភ្នំពេញ និងគ្រប់កន្លែងផ្សេងៗទៀត។ ដូច្នេះ បើយើងមិនហ៊ានតស៊ូដោយអាវុធទេ យើងច្បាស់ជា ត្រូវគេកាត់កទាំងអស់គ្នាហើយ។

ពេលនោះ ខៀវ សំផន មានកូនវិទ្យុមួយ ដើម្បីស្តាប់ព័ត៌មានផ្សេងៗដែរ។ គាត់ក៏បាន ដឹងថា សម្តេចសីហនុ ខ្ទាល់ខ្ទាំងនឹងតំណាងរាស្ត្រ ហ៊ូ នឹម និងជាប្រធានសមាគមមិត្តភាព

កម្ពុជា-ចិន។

វិទ្យុបានផ្សាយថា ព្រឹត្តិការណ៍នៅសំឡូត ធ្វើឲ្យព្រះអង្គតូចព្រះទ័យយ៉ាងខ្លាំង ដោយព្រះអង្គមិននឹកស្មានទាល់តែសោះថា កសិករនៅទីនោះ អាចបះបោរប្រឆាំងនឹងព្រះអង្គយ៉ាងដូច្នេះ?។

តទ្បូវអ្នកស្រាវជ្រាវបានរកឃើញអស់ហើយ មូលហេតុអ្វីដែលនាំឲ្យកសិករនាំគ្នាបះបោរ ហើយតើកសិករបះបោរប្រឆាំងនឹងអ្នកណា?

ព្រះអង្គមានការមន្ទិលសង្ស័យយ៉ាងខ្លាំងថា ការបះបោរទាំងអស់នោះ គឺមកពីឥទ្ធិពលរបស់មហាបដិវត្តន៍វប្បធម៌របស់ចិន។ ដូច្នេះ ព្រះអង្គក៏បានចេញព្រះរាជបញ្ជា ឲ្យបិទសមាគមមិត្តភាពកម្ពុជា-ចិន កុំឱ្យមានទៅទៀត។

ក្រោយពីមានព្រះរាជបញ្ជាយ៉ាងនេះមក សមាគមមិត្តភាពកម្ពុជា-ចិន ក៏បានប្រារព្ធធ្វើពិធីរម្លឹកខួបថ្ងៃជ័យជម្នះបដិវត្តន៍របស់បក្សកុម្មុយនិស្តចិន និងថ្ងៃបង្កើតរបបសាធារណរដ្ឋប្រជាមានិតចិន ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៩ យ៉ាងគគ្រឹកគគ្រេង ដោយមានការជប់លៀង ព្រមទាំងមានការតាំងពិព័រណ៍ និងការសម្តែងសិល្បៈចម្រៀងរបាំប្រជាប្រិយចិន និងខ្មែរ រហូតដល់មានសុន្ទរកថាលើកសរសើរសមាគមមិត្តភាពកម្ពុជា-ចិន នេះទៀតផង។

សម្តេចសីហនុ យល់ថា ការរៀបចំពិធីរម្លឹកខួប មានទាំងការសម្តែងសិល្បៈចម្រៀងរបាំប្រជាប្រិយចិន រហូតដល់មានសុន្ទរកថាលើកសរសើរសមាគមមិត្តភាពកម្ពុជា-ចិន នេះជាការបញ្ជោះបោះសោកមកលើព្រះអង្គ។

ខៀវ សំផន យល់ថា លន់ នល់ ចេះតែបន្តបញ្ជោះសម្តេចសីហនុ ហើយទាំងនេះវាស្របទៅនឹងអ្វីដែលតាម៉ុក បានប្រាប់គាត់ថា រឿងរ៉ាវនៅសំឡូត មិនបានដោះស្រាយគ្នាតាមសន្តិវិធីបានទេ។ ផ្ទុយទៅវិញ ការបង្ក្រាបរាតត្បាតនៅកន្លែងនោះ នៅតែបន្តទៀត ហើយបានរីករាលដាលទៅទីក្រុងភ្នំពេញ និងកន្លែងផ្សេងៗទៀត។

ចំណែក ហ៊ូ នឹម (តំណាងរាស្ត្រឆ្វេងនិយម) ដែលនៅសល់ចុងក្រោយក្នុងរដ្ឋសភា ក៏មិនអាចរំពឹងលើអភ័យឯកសិទ្ធិសភារបស់ខ្លួនបានទៀតដែរ។ បក្សកុម្មុយនិស្តកម្ពុជា កំពុងតែ

ប្រឈមនឹងគ្រោះថ្នាក់ ដូច្នេះបើពួកគេមិនតស៊ូដោយអាវុធទេ ពួក លន់ លន់ នឹងកម្ទេចអស់ជាមិនខាន។ ប៉ុន្តែ ពេលនេះ បក្សកុម្មុយនិស្តកម្ពុជា គ្មានកាំភ្លើងនៅនឹងដៃទាល់តែសោះ។

ពេលនោះដែរ ខៀវ សំផន យល់ថា គាត់ក៏ត្រូវត្រៀមខ្លួនឆ្លងកាត់សភាពការណ៍ដ៏គ្រោះថ្នាក់បំផុត ហើយបញ្ហាសំខាន់មួយទៀត គឺបញ្ហាសុខភាព ព្រោះគាត់ស្នាក់នៅក្នុងផ្ទះខ្ទមចង្អៀត គ្មានពន្លឺថ្ងៃ ដូច្នេះពេលភ្លឺស្រាងៗ គាត់ក្រោកឡើងហាត់ប្រាណ រត់ជុំវិញផ្ទះខ្ទមរួចទៅអង្គុយសំងំអាំងថ្ងៃនៅកណ្តាលព្រៃឫស្សីព្រិច ដែលគាត់បានកាប់ឆ្ការទុកមួយប្រលោះរួចជាស្រេច។

# ២១២
# ភោគ ឆាយ កូនអ្នកក្រក្រី តែល្បីជាសិស្សពូកែ



**ភោគ ឆាយ**

ភោគ ឆាយ កើតនៅក្នុងឆ្នាំ១៩៣៦ នៅភូមិស្វាយព្រៃ ឃុំលំចង់ ស្រុកសំរោង ខេត្តតាកែវ។ ម្តាយឈ្មោះ នាង ហួន ឪពុកឈ្មោះ ហ៊ូ ជួរ មានមុខរបរជាអ្នករកស៊ីផង និងធ្វើស្រែផង។ មានប្អូនស្រីម្នាក់ និងប្រុសម្នាក់។ ពេលគាត់មានអាយុ៦ឆ្នាំ ឪពុកក៏បានស្លាប់ចោលគាត់ដោយសារជំងឺ។ ក្រោយឪពុកស្លាប់ទៅ ក៏ត្រូវម្តាយយកទៅឱ្យស្នាក់នៅវត្តជាមួយព្រះសង្ឃ។

បន្ទាប់មក ម្តាយគាត់បានយកប្តីម្នាក់ទៀត ឈ្មោះ ភោគ សុង ជាអ្នកចូលចិត្តលេងល្បែងស៊ីសង មិនសូវគិតគូររឿងរកស៊ីចិញ្ចឹមប្រពន្ធកូនទេ។ ពេលមានអាយុ៨ឆ្នាំ គាត់ក៏បានចូលរៀនសាលាបឋមសិក្សានៅក្នុងស្រុកកំណើត ដែលពេលនោះរៀនជាភាសាបារាំង។ បន្ទាប់មក នៅក្នុងឆ្នាំ១៩៤៩ ពេលមានអាយុ១៣ឆ្នាំ គាត់បានទទួលអាហារូបករណ៍ទៅរៀននៅទីរួមខេត្តតាកែវ។

មុនពេលចេញទៅរៀននៅក្នុងទីរួមខេត្តតាកែវ ម្តាយគាត់បានទូន្មានថា ៖ «កូនឯង កុំធ្វើតាមឪពុកចុងកូនឯងឱ្យសោះ។ កុំលេងល្បែងពាលា។ កូនគិតតែពីខំរៀនសូត្រទៅ ក្រែង

ធំឡើង មានតម្រិះបានធ្វើនាម៉ឺន មានប្រាក់ខែ គ្រាន់បានម្ដាយពឹងពាក់ដោយសារផង»។

ម្ដាយរបស់គាត់ស្រលាញ់គាត់ណាស់ ហើយក៏កាចណាស់ដែរ ដូច្នេះហើយបានជាមុនពេលលាម្ដាយមករៀននៅក្នុងទីរួមខេត្តតាកែវ គាត់បានប្ដេជ្ញាថា នឹងខំរៀនឱ្យអស់ពីចិត្តពីថ្លើម។ នៅអំឡុងឆ្នាំ១៩៥០ នៅខេត្តតាកែវ មានចលនាបាតុកម្មប្រឆាំងបារាំង និងចៅហ្វាយខេត្តតាកែវ ឈ្មោះ ជា ជិនកុក និងចាងហ្វាងសាលាឈ្មោះ ចាន់ ។ ពេលនោះគាត់ក៏បានចូលរួមយ៉ាងសកម្មក្នុងបាតុកម្មមួយនោះដែរ។

បាតុកម្មនោះរៀបចំឡើងដោយ ឈូក ម៉ឹងម៉ៅ ជាអធិការបឋមសិក្សា ជាមួយ ព្រំ ថៅស៊ូ ជាអនុរក្សគ្រប់គ្រងសិស្សចំនួន៣០នាក់ ដែលស្នាក់អាស្រ័យនៅក្នុងសាលាអាហារូបករណ៍នោះផងដែរ។ ព្រំ ថៅស៊ូ នេះ ក៏ធ្លាប់ជាគ្រូរបស់គាត់កាលរៀននៅថ្នាក់មធ្យមដ្ឋានទី២ ឯស្រុកកំណើតដែរ។ ក្នុងការរៀបចំបាតុកម្មនោះ ឈូក ម៉ឹងម៉ៅ ជាអធិការបឋមសិក្សាមិនចេញមុខមាត់ទេ គឺទុកឱ្យគ្រូព្រំ ថៅស៊ូ ជាអ្នកបំផុសសិស្ស។

ភោគ ឆាយ បានរម្លឹកថា ពេលល្ងាច គ្រូព្រំ ថៅស៊ូ បានប្រជុំសិស្សជាសម្ងាត់នៅក្នុងសាលាអាហារូបករណ៍ ហើយនិយាយថា ព្រឹកស្អែក យើងត្រូវធ្វើបាតុកម្ម។ អ្នកណាចូលរួមក្នុងបាតុកម្ម គាត់នឹងជួយឱ្យប្រលងជាប់ ហើយបានអាហារូបករណ៍សម្រាប់រៀននៅឆ្នាំក្រោយទៀតផង។ សិស្សទាំងអស់ ក្នុងនោះមានរូបគាត់ផងដែរ ក៏បានលើកដៃស្ម័គ្រចិត្តគ្រប់ៗគ្នា។

លុះព្រឹកឡើង ពួកគាត់ជាង២០នាក់ក្នុងចំណោមសិស្សទាំងអស់៣០នាក់ ក៏នាំគ្នារៀបជាក្បួនហែនៅតាមផ្លូវថ្នល់បណ្ដើរ និងស្រែកដេរចៅហ្វាយខេត្តឈ្មោះ ជា ជិនកុក និងចាងហ្វាងសាលាឈ្មោះ ចាន់ ថា៖ "ជាពួកខ្ញុំកញ្ជះបារាំង..."។

លុះពីរបីថ្ងៃ ក្រោយមក ពួកគាត់ជាង២០នាក់ ដែលនាំគ្នាធ្វើបាតុកម្មនោះ ត្រូវគេបណ្ដេញចេញពីសាលា លែងឱ្យរៀនបន្តទៀត។ ពេលនោះ គាត់មានតែត្រលប់មកផ្ទះវិញក្រោយពីដឹងរឿងហេតុ ម្ដាយគាត់បន្ទោសថា៖ " ម៉ែឱ្យឯងទៅរៀន ម៉េចឯងទៅធ្វើផ្ដេសផ្ដាសអ៊ីចឹង តើបានសាលាឯណានឹងរៀនទៀត? "»។

លុះដល់ឆ្នាំ១៩៥២ នៅខេត្តកំពត រាជរដ្ឋាភិបាលបានបង្កើតអនុវិទ្យាល័យមួយហៅ

ថា អនុវិទ្យាល័យព្រះរាជសម្ភារ។ គាត់ក៏បានប្រលងជាប់អាហារូបករណ៍ ចូលបន្តការសិក្សានៅអនុវិទ្យាល័យនោះ អស់រយៈពេល៤ឆ្នាំ រហូតប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (ឌីប្លូម)។ ពេលនោះ ម្ដាយក៏បានអង្វរឱ្យគាត់ឈប់រៀនបន្តទៀត ហើយរកការងារធ្វើ ដើម្បីម្ដាយគាត់បានពឹងពាក់ ព្រោះឪពុកចុងគាត់កាន់តែជរាណាស់ទៅហើយ។ ប៉ុន្តែ គាត់នៅតែចង់បន្តការរៀនសូត្រឱ្យបានខ្ពស់ថែមទៀត ដោយប្រាថ្នាចង់បានបុណ្យសក្តិធំ មានមុខមាត់ មានប្រាក់ខែច្រើនចាយមិនខ្វះ មិនលំបាកវេទនា។ ហេតុនេះហើយ ក្រោយពីប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ(ឌីប្លូម)នៅក្នុងឆ្នាំ១៩៥៦ គាត់ក៏សម្រេចចិត្ត មកបន្តការសិក្សារៀនសូត្រនៅវិទ្យាល័យ ឯទីក្រុងភ្នំពេញ ទៀត។

មកដល់ក្រុងភ្នំពេញ ដំបូង គោគ ឆាយ បានសុំព្រះសង្ឃស្នាក់នៅជាមួយក្នុងវត្តប្រយូរវង្ស និងបានប្រលងជាប់អាហារូបករណ៍ ចូលរៀននៅសាលាបារាំងមួយ ឈ្មោះវិទ្យាល័យដេកាដ។

ក្នុងពេលសិក្សានៅវិទ្យាល័យ ដេកាដ នោះ គាត់ខិតខំយកចិត្តគ្រូៗបារាំងណាស់ ដើម្បីឱ្យគ្រូបារាំងទាំងអស់នោះ ស្រលាញ់រាប់អាន ហើយផ្ដល់អាហារូបករណ៍បន្តទៀត រហូតដល់ចប់ចុង ចប់ដើម។ ជាមួយគ្នានោះដែរ គាត់ក៏ចូលចិត្តទាក់ទងរាប់អានជិតស្និទ្ធតែជាមួយកូននាម៉ឺន កូនអ្នកមានដែលរៀនជាមួយគ្នានោះផងដែរ ធ្វើឱ្យគាត់ប្រែក្លាយជាមនុស្សខុសពីមុន។ ពីដើម គាត់ធ្លាប់តែមានចរិតស្លូតបូត ញញើតញញើមខ្លាចគេឯង ចេះគួរសម គោរពចាស់ទុំណាស់ តែចាប់តាំងពីឆ្នាំ១៩៥៨មក គាត់ផ្លាស់ប្ដូរអត្តចរិតអាកប្បកិរិយា ទៅជាប្រងេងប្រងាង ហើយច្រើនមានអំនួតអួតអាងអំពីបុគ្គលខ្លួនដែលរៀនពូកែ ចូលចិត្តនិយាយតែភាសាបារាំង ហើយមានគំនិតចង់ទៅបន្តការសិក្សានៅឯបរទេសទៀតផង។

នៅក្នុងខែ៦ ឆ្នាំ១៩៥៨ ឪពុកចុងគាត់ បានធ្វើមរណកាលដោយជំងឺ។ ម្ដាយគាត់បានសុំអង្វរឱ្យគាត់ឈប់រៀនជាថ្មីម្ដងទៀត ហើយរកការងារធ្វើ ដើម្បីម្ដាយបានពឹងពាក់ផង។ ម្ដងនេះ គាត់ក៏បានយល់ព្រមតាមការអង្វររបស់ម្ដាយ ដោយបោះបង់គំនិត ដែលធ្លាប់គិតថានឹងទៅបន្តការសិក្សានៅឯបរទេសនោះ ចោលវិញ។

## របត់នយោបាយ

ក្នុងឆ្នាំ១៩៥៩ ក្រោយពីប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិភាគ២ (បាក់ឌុប) មក គាត់បានចុះឈ្មោះបន្តការសិក្សានៅមហាវិទ្យាល័យច្បាប់បន្តទៀត ហើយឆ្លៀតដើរបង្រៀននៅតាមសាលាឯកជនមួយចំនួន ដើម្បីបានប្រាក់សម្រាប់ចាយវាយខ្លួនឯងផង និងផ្ញើទៅឱ្យម្ដាយនៅឯស្រុកផង ។

ពីឆ្នាំ១៩៥៩ ដល់៦០ គាត់បង្រៀននៅវិទ្យាល័យឯកជនចតុមុខ, ពីឆ្នាំ១៩៦០ ដល់ ១៩៦១ នៅវិទ្យាល័យឯកជនខេមរា, ពីឆ្នាំ១៩៦១ ដល់១៩៦២ នៅវិទ្យាល័យឯកជនចំរើនវិជ្ជា និងវិទ្យាល័យប្រសើរសិក្សា ។

ភោគ ឆាយ បានបញ្ជាក់ថា វិទ្យាល័យខេមរា ជាសាលារបស់លន់ ណុន ជាប្អូន លន់ នល់។ នៅវិទ្យាល័យខេមរា គាត់បង្រៀនមុខវិជ្ជាភូមិសាស្ត្រ និងប្រវត្តិសាស្ត្រ។

លន់ ណុន បានប្រាប់គាត់ថា ឱ្យជួយបង្រៀននៅសាលាខេមរា នេះទៅ ថ្ងៃក្រោយយើងនឹងបានរាប់អានគ្នាតទៅទៀត។ ដូច្នោះហើយ ទើបបានជាពេលនោះ គាត់ខំយកចិត្តលន់ ណុន ខិតខំបង្រៀនណាស់ ដើម្បីឱ្យ លន់ ណុន ស្រលាញ់ចូលចិត្តគាត់ផង និងឱ្យម៉ោងគាត់បានបង្រៀនច្រើនផង ដើម្បីបានប្រាក់ខែច្រើន។ ពេលនោះ គាត់បានធ្វើជាប្រធានសមាគមសិស្សចំរើនវិជ្ជាផងដែរ។ គាត់ស្គាល់ អ៊ុច វ៉េន នៅមហាវិទ្យាល័យច្បាប់ ហើយអ៊ុច វ៉េន បានហៅគាត់ឱ្យមកបង្រៀននៅសាលាចំរើនវិជ្ជា។ គាត់សុខចិត្តមកបង្រៀននៅសាលាចំរើនវិជ្ជានោះដែរ តែគ្មានគិតអ្វីក្រៅពីប្រាក់ខែនោះឡើយ។

# ២១៣
# ចៅកែស្រុករនៅខេត្តពោធិ៍សាត់ស្វាត់។ លើកកូនក្រមុំឱ្យភោគ ឆាយ

ភោគ ឆាយ បានឱ្យដឹងថា ពេលនោះ អ៊ុច វ៉ែន ដែលជាអតីតសាស្ត្រាចារ្យ ជាអតីតតំណាងរាស្ត្រ និងជាអតីតសមាជិកគណៈរដ្ឋមន្ត្រីច្រើនលើកមកហើយនោះ ធ្វើជាលេខាធិការបណ្ណាល័យនៅមហាវិទ្យាល័យច្បាប់។ គាត់ស្គាល់ អ៊ុច វ៉ែន ដោយសារគាត់ចូលទៅខ្ចីសៀវភៅពីគាត់នៅបណ្ណាល័យ យកមកអានញឹកញាប់។

អ៊ុច វ៉ែន បានឱ្យសៀវភៅចម្រើនល្អៗមកឱ្យគាត់អាន ហើយ អ៊ុច វ៉ែន ចង់ឱ្យគាត់ងាកទៅរកផ្លូវបដិវត្តន៍ ប៉ុន្តែគាត់មិនសូវយកចិត្តទុកដាក់ទេ គាត់គិតតែពីបុគ្គលគាត់ គឺគិតតែខំរៀនយកសញ្ញាបត្រ ដើម្បីមានកេរ្តិ៍ឈ្មោះ និងស្នាដៃ។ ក្នុងរយៈពេលរៀននៅមហាវិទ្យាល័យច្បាប់នោះដែរ ក្រៅពី អ៊ុច វ៉ែន គាត់បានស្គាល់ និងមានទំនាក់ទំនងជិតស្និទ្ធជាមួយ សារិន ឆាក។

សារិន ឆាក ធ្វើការនៅក្រសួងការបរទេស តែបានឆ្លៀតមករៀននៅមហាវិទ្យាល័យច្បាប់នៅថ្នាក់ជាមួយគាត់ដែរ។ ក្នុងឆ្នាំ១៩៦១ ដល់១៩៦២ សារិន ឆាក បានរៀបចំបង្កើតឱ្យមានសមាគមនិស្សិតមហាវិទ្យាល័យច្បាប់នោះ ហើយ សារិន ឆាក ក៏ត្រូវបានគេជ្រើសរើសឱ្យធ្វើជាប្រធានសមាគម។ កាលនោះ គាត់ក៏ចូលរួមធ្វើជាសមាជិកនៃសមាគមនោះដែរ ដោយទទួលភារៈខាងបោះពុម្ពផ្សាយទស្សនាវដ្តី។

ភោគ ឆាយ បានឱ្យដឹងបន្ថែមថា នៅមហាវិទ្យាល័យច្បាប់ គាត់បានទាក់ទងយកចិត្តយកថ្លើម និងគោរពមនុស្សម្នាក់ទៀតគឺ ហ៊ូ យន់ ។ ហ៊ូ យន់ ធ្វើជាគ្រូគាត់ បង្រៀនផ្នែកខាងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ១៩៦១ ដល់១៩៦២ ។ ហ៊ូ យន់ តែងតែហៅគាត់ទៅប្រជុំជាមួយនិស្សិតមួយចំនួនទៀត ដើម្បីពិភាក្សាពីបញ្ហានយោបាយស្រុកទេស រហូតធ្វើឱ្យគាត់ចូលចិត្តខាងនយោបាយបន្តិចម្តងៗ ហើយស្តាប់បង្គាប់ ហ៊ូ យន់ គោរព ហ៊ូ យន់ និងទាក់ទង



LA DEPECHE
DU CAMBODGE
QUOTIDIEN KHMER D'INFORMATION
BUREAU: 51, Vithei Botum Sorlyavong
PHNOM-PENH
Téléphone 3248 — Boite postale n° 542
Directeur politique : SIM - VAR
Directeur de publication : CHAU SENG
CAMBODGE : 4 RIELS

ជាមួយ ហ៊ូ យន់ ជារៀងរហូតមក។ ពេលនោះ អ៊ុច វ៉ែន ធ្វើការនៅវិទ្យាល័យចំរើនវិជ្ជាផង និងធ្វើការនៅខាងកាសែតបារាំងឈ្មោះ "ឡាដេប៉ែស្ហ" ដែលមានស៊ឹម វ៉ា ជាចាងហ្វាងនយោបាយ។

តាមរយៈ អ៊ុច វ៉ែន គាត់ក៏បានស្គាល់ និងជិតស្និទ្ធជាមួយ ចៅ សេង ចាងហ្វាងការផ្សាយកាសែតបារាំងឈ្មោះ "ឡាដេប៉ែស្ហ" ទៀតដែរ ។ ចៅ សេង ក៏អនុគ្រោះឱ្យគាត់ចូលសរសេរកាសែត "ឡាដេប៉ែស្ហ" ដោយឱ្យប្រាក់ខែគាត់ ៣៥០០រៀលក្នុងមួយខែ។ មូលហេតុដែលគាត់ឆ្លៀតមកសរសេរកាសែតឡាដេប៉ែស្ហ បន្ថែមទៀតនេះ គឺគ្មានអ្វីក្រៅពីចង់បានប្រាក់ខែច្រើន និងបានកេរ្តិ៍ឈ្មោះតែប៉ុណ្ណោះ។ តែពេលនោះ គាត់ពុំដែលបានជួប ស៊ឹម វ៉ា ជាចាងហ្វាងនយោបាយ ទេ ព្រោះកាលនោះ ស៊ឹម វ៉ា ទៅធ្វើឯកអគ្គរាជទូតនៅឯប្រទេសជប៉ុន។

ភោគ ឆាយ បានឱ្យដឹងថា ចៅ សេង ជាចាងហ្វាងការផ្សាយកាសែតឡាដេប៉ែស្ហ និង អ៊ុច វ៉ែន ជាចាងហ្វាងរង ។ ក្រៅពីនេះមាន ប៉ុក ដឺសកុមារ, រស់ ដេដ្ឋូរ និង សូ ណៃម ។ ប៉ុក ដឺសកុមារ និង រស់ ដេដ្ឋូរ មានអាយុច្រើនជាងគាត់ពីបួនទៅប្រាំឆ្នាំ ធ្វើការនៅក្រសួងការបរទេសផងដែរ ។ ចំណែក សូ ណៃម ធ្វើជាតំណាងរាស្ត្រ។ ពេលនោះ ភោគ ឆាយ ចាត់ទុក អ៊ុច វ៉ែន ជាអ្នកបដិវត្តន៍រៀមច្បងម្នាក់ និងមានគំនិតចង់ចូលរួមតស៊ូជាមួយចលនាខ្មែរក្រហមដែរ តែគាត់មិនបានដឹងច្បាស់ថា អ៊ុច វ៉ែន មានតួនាទីអ្វីនៅក្នុងជួរមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា នោះទេ ?។

យូរៗម្តង គាត់ឃើញ ហ៊ូ នឹម ក៏មកចូលរួមសរសេរកាសែតឡាដេប៉ែស្ហ ដែរ តែសរសេរ

ជាប្រយោល។ គាត់ជិតស្និទ្ធជាមួយ ប៉ុក ជឹសកុមារ ជាងគេ ព្រោះគេជាកូនកាត់បារាំង ចូលចិត្ត និយាយបារាំង ដែលត្រូវនឹងអត្តចរិតរបស់គាត់។

ភោគ ឆាយ រៀននៅមហាវិទ្យាល័យច្បាប់ផង និងសរសេរកាសែតឡាដេប៉ែស្ហ ផង រហូតដល់ខែកុម្ភៈ ឆ្នាំ១៩៦៣ ក៏បានប្រលងចេញពីសាលាច្បាប់។ ដោយមានការជួយជ្រោមជ្រែងពី ប៉ុកជឹស កុមារ និង សារិន ឆាក ដែលកាលនោះធ្វើជាអគ្គលេខាក្រសួង គាត់ក៏ទៅសុំការងារធ្វើនៅឯក្រសួងការបរទេស។ ក្នុងដើមខែមេសា ឆ្នាំ១៩៦៣ គាត់ក៏បានចូលធ្វើការនៅក្រសួងការបរទេស និងបានទទួលប្រាក់ខែ ៤០០០រៀល។

លុះដល់ថ្ងៃទី២៨ ខែ៧ ឆ្នាំ១៩៦៣ ដោយមានមិត្តភក្តិជួយផ្គូផ្គងផង គាត់បានរៀបការជាមួយក្រមុំជាកូនចៅចិនម្នាក់ ឈ្មោះសៀក គីម ជាកូនស្រីរបស់ឈ្មួញស្រូវម្នាក់ ឈ្មោះ ឃាម ទ្រី នៅត្រពាំងជង ស្រុកបាកាន ខេត្តពោធិ៍សាត់។ ឪពុកក្មេកគាត់ ឈ្មោះ ឃាម ទ្រី ជាប់សាច់ឈាមជាមួយម្តាយរបស់ ងុយ កាន់ ជានាយទុនធំម្នាក់ នៅទីក្រុងភ្នំពេញ។

ពេលរៀបការនោះ វន វ៉េត (មេដឹកនាំចលនាតស៊ូសម្ងាត់របស់ខ្មែរក្រហមប្រចាំទីក្រុងភ្នំពេញ), ប៉ុក ជឹសកុមារ និងរស់ ដេដ្ឋូរ ក៏បានទៅចូលរួមដែរ។ តែ ងុយ កាន់ មិនបានមកចូលរួមក្នុងពិធីមង្គលការរបស់ពួកគាត់ទេ ព្រោះគាត់ខឹងនឹងឪពុកក្មេកគាត់ ដែលបានលើកកូនក្រមុំឱ្យគាត់ជាអ្នកសរសេរកាសែតឡាដេប៉ែស្ហ ព្រោះ ងុយ កាន់ នោះ ចាត់ទុកថា អ្នកសរសេរកាសែតមួយនេះ គឺជាពួកខ្មែរក្រហម។ តែតាមពិត ពេលនោះ គាត់អត់មានគោលជំហរបដិវត្តន៍អ្វីទាល់តែសោះ។

ឪពុកក្មេក បានទូន្មានគាត់ថា បើគេមិនរវល់នឹងយើង យើងក៏កុំទៅអំពល់គេ។ គេមាន ឱ្យគេមានតែគេចុះ។ តែគាត់ពុំបានធ្វើតាមបណ្តាំរបស់ឪពុកក្មេកទេ។

បន្ទាប់ពីរៀបការហើយ គាត់បានទៅជួបគួរសមនឹង ងុយ ថាន់ ជាកូនច្បងរបស់ ងុយ កាន់ ជាអ្នកគ្រប់គ្រងក្រុមហ៊ុនមួយ ឈ្មោះក្រុមហ៊ុនងុយ កាន់ ជាឈ្មោះឪពុកគេ។ ងុយ ថាន់ រាប់អានរាក់ទាក់នឹងគាត់ខ្លាំងណាស់ ហើយឧស្សាហ៍ហៅគាត់ទៅពិសាបាយនៅផ្ទះគេជាញឹកញាប់ទៀតផង។

## របត់នយោបាយ

ក្រោយពីបានស្គាល់ ង៉ុយ ថាន់ បាន៣ខែ ស្រាប់តែនៅខែវិច្ឆិកា ឆ្នាំ១៩៦៣ សម្ដេចសីហនុ បានប្រកាសធ្វើជាតូបនីយកម្មទាំងមុខរបរធនាគារ ទាំងមុខរបរពាណិជ្ជកម្មក្រៅប្រទេស។ ពេលនោះ នាយទុនជាច្រើនក្នុងនោះ មាននាយទុនឈ្មោះ សុង សាក់ ក៏បាននាំគ្នារត់ចេញទៅក្រៅប្រទេស។ ឯគ្រួសារ ង៉ុយ កាន់ ក៏រៀបចំខ្លួននាំគ្នារត់ទៅក្រៅប្រទេស ដែរ។

ព្រឹកមួយ នាចុងខែវិច្ឆិកា ឆ្នាំ១៩៦៣ ង៉ុយ ថាន់ បានឱ្យមនុស្សមកហៅគាត់ទៅជួបជាសម្ងាត់នៅផ្ទះរបស់គេ ហើយប្រាប់គាត់ថា ព្រឹកស្អែក គេត្រូវចេញទៅហុងកុងហើយ ក្រុមហ៊ុនត្រូវបិទទ្វារមួយរយៈ។ ចំណែកផ្ទះសំបែងរបស់គេ គេទុកឱ្យសាច់ថ្លៃម្នាក់ថែរក្សា ហើយគេក៏ស្នើគាត់ជួយមើលការខុសត្រូវឱ្យផង។

ង៉ុយ ថាន់ ប្រាប់គាត់ថា បើគាត់អត់ផ្ទះនៅ គាត់អាចមកស្នាក់នៅឯផ្ទះគេនេះបាន ប៉ុន្តែគាត់ឆ្លើយថា គាត់មានផ្ទះជួលល្អបង្គួរស្នាក់នៅហើយ តែជីវភាពរស់នៅ ពុំសូវគ្រប់គ្រាន់។

ពេលនោះ ង៉ុយ ថាន់ តបវិញថា ៖ «បញ្ហាជីវភាពប្អូនកុំព្រួយអី ខ្ញុំធានាបាន តែខ្ញុំមានបញ្ហាមួយទៀត គឺចង់ស្នើឱ្យប្អូនឈប់ធ្វើការនៅក្រសួងការបរទេស ហើយមករួមធ្វើការជំនួញជាមួយមិត្តយើងវិញ។ ភោគ ឆាយ ឆ្លើយវិញថា ខ្ញុំកំពុងចង់សុំឈប់ធ្វើការនៅក្រសួងការបរទេសផង បើបងជួយរ៉ាប់រងខាងជីវភាព ខ្ញុំពេញចិត្តណាស់ហើយ»។

ង៉ុយ ថាន់ និយាយថា ៖ «អ៊ីចឹងល្អហើយ ល្ងាចនេះមកហូបបាយជាមួយគ្នា ខ្ញុំនាំឱ្យស្គាល់មិត្តភក្តិពីរបីនាក់ទៀត»។ បន្ទាប់មក ភោគ ឆាយ បានទទួលប្រាក់មានចំនួន១០ ម៉ឺនរៀល ពី ង៉ុយ ថាន់ ហើយត្រលប់មកផ្ទះវិញ។

លុះដល់ពេលល្ងាច ភោគ ឆាយ បានត្រលប់ទៅផ្ទះ ង៉ុយ ថាន់ វិញ។ ង៉ុយ ថាន់ បានណែនាំគាត់ឱ្យស្គាល់ឈ្មួញម្នាក់ឈ្មោះ គី សៀនហូ ជាឈ្មួញស្រូវ និងដង្វោឈើនៅបាត់ដំបង និងម្នាក់ទៀតឈ្មោះ វ៉ាន់ ទិព្វសុវណ្ណ ជាឈ្មួញរកស៊ីប្តូរប្រាក់បរទេស និងជាតំណាងភ្នាក់ងារដឹកជញ្ជូនផ្សេងៗ។

ពេលពិសាបាយល្ងាចរួច ង៉ុយ ថាន់ បានបញ្ជាក់ប្រាប់គាត់ម្តងទៀតថា ៖ «ព្រឹកស្អែកនេះ ខ្ញុំចេញដំណើរទៅហុងកុង ហើយ ថ្ងៃក្រោយយើងគង់តែជួបគ្នាវិញទេ។ បើមានការខ្វះខាត

អ្វី សូមប្អូនទាក់ទងនឹងអ្នកទាំងពីរនេះចុះ។ អ្នកទាំងពីរនេះគឺជាមនុស្សនៅក្នុងគ្រួសារយើងតែមួយទេ»។

ភោគ ឆាយ បានបញ្ជាក់ថា នៅក្នុងខែ១២ ឆ្នាំ១៩៦៣ សម្តេចសីហនុ បានឱ្យបញ្ជាឱ្យ ចៅ សៅ រៀបចំធនាគារពាណិជ្ជកម្មរដ្ឋមួយ ឈ្មោះ "ធនាគារឥណទានជាតិ"។ កាលនោះ ចៅ សៅ ធ្វើជាប្រធានអគ្គនាយក ហើយបានហៅ អ៊ុច វ៉ែន ឱ្យមកធ្វើជាអគ្គនាយករង។

បន្ទាប់មក អ៊ុច វ៉ែន ក៏បានហៅ ប៉ុក ដឹសកុមារ ពីក្រសួងការបរទេសឱ្យមកជួយធ្វើការនៅធនាគារឥណទានជាតិ នោះទៀត។

ក្រោយពេលរៀបការហើយ ប្រាក់ដែលឪពុកក្មេកចងដៃ ៣ម៉ឺនរៀល ភោគ ឆាយ ក៏ចាយអស់។ ឯប្រាក់ខែក្រសួង ឡើងបាន៤៥០០រៀល ចាយក៏ពុំគ្រប់គ្រាន់ ព្រោះគាត់ទម្លាប់ចាយវាយហ៊ឺហា ខ្ជះខ្ជាយ តាំងពីកាលនៅជានិស្សិតមកម្ល៉េះ ដូច្នេះជីវភាពរស់នៅរបស់គាត់ដាច់ឆ្ងាយពីជីវភាពរបស់មហាជនជាកសិករ និងកម្មករ ដែលក្នុងសម័យនោះ កម្មករម្នាក់ៗអាចរកប្រាក់បានយ៉ាងច្រើនពី៦០០រៀល ទៅ១២០០រៀលប៉ុណ្ណោះ ក្នុងមួយខែ។

ចាប់តាំងពីពេលនោះមក ការងារនៅឯក្រសួងការបរទេស ធ្វើឱ្យគាត់កាន់តែធុញទ្រាន់ឡើងៗ ដោយសារប្រាក់ខែចាយមិនគ្រប់គ្រាន់ ហើយឃើញរដ្ឋមន្ត្រី ហួត សម្បត្តិ គិតតែពុករលួយស៊ីសំណូកសូកប៉ាន់ គាត់បានយករឿងនេះទៅពិគ្រោះជាមួយប៉ុក ដឹសកុមារ។ ពេលនោះ ប៉ុក ដឹសកុមារ បាននិយាយថា ខ្លួនក៏បម្រុងចេញពីក្រសួងការបរទេសដែរ ព្រោះនៅក្រសួងការបរទេសប្រាក់ខែតិចចាយមិនគ្រាន់ទេ។ ដូច្នោះ បើយើងទៅធ្វើការនៅធនាគារឥណទានជាតិ យើងបានប្រាក់១៥០០០រៀលក្នុងមួយខែ គឺបីដងច្រើនជាងនៅក្រសួងការបរទេស។

គាត់ក៏យល់ព្រម ពីព្រោះគាត់ចង់បានប្រាក់ខែច្រើន ដើម្បីចាយវាយជាមួយប្រពន្ធឱ្យបានគ្រប់គ្រាន់ផង ហើយផ្ញើទៅជួយផ្គត់ផ្គង់ម្តាយនៅឯស្រុកផង។ ប៉ុក ដឹសកុមារ និយាយប្រាប់គាត់ទៀតថា អ៊ុច វ៉ែន ក៏ទៅធ្វើជាអគ្គនាយករងនៅធនាគារនោះដែរ ឯ ចៅ សៅ ជាប្រធានអគ្គនាយក។ ដូច្នេះ ក្រុមកាសែតឡាដេប៉ែស្ហយើង ទៅនៅជុំគ្នានៅធនាគារនោះ តែ

ម្តងទៅ។

ពេលនោះ អ៊ុច វ៉ែន ជាអគ្គនាយករង ក៏បានយល់ព្រមទទួល ប៉ុក ជីសកុមារ និងភោគ ឆាយ ឱ្យចូលធ្វើការនៅធនាគារឥណទានជាតិនោះដែរ។ ប៉ុន្តែ អ៊ុច វ៉ែន ប្រាប់ឱ្យទាំង២នាក់នេះ រង់ចាំមួយរយៈសិន ពីព្រោះការរៀបចំធនាគារឥណទានជាតិនោះ ក៏ពុំទាន់រួចរាល់ ហើយការដោះស្រាយបញ្ហាប្រាក់កាសជាមួយបារាំង ក៏ពុំទាន់ដាច់ស្រេចដែរ។

# ២១៤
# ភោគ ឆាយ ចូលរួមជាមួយខ្មែរក្រហម តាមរយៈអ៊ុច វ៉េន



**អ៊ុច វ៉េន**

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៦៣ ភោគ ឆាយ បានលាឈប់ពីក្រសួងការបរទេស ក្រោយពីធ្វើការនៅទីនោះ បានត្រឹមតែរយៈពេល៧ខែ។ ការលាឈប់នោះ ក៏ដើម្បីឱ្យស្របតាមបណ្តាំរបស់ ង៉ុយ ថាន់ ផងដែរ។

នៅថ្ងៃទី៣ ខែមករា ១៩៦៤ ក្នុងរយៈពេលកំពុងរង់ចាំចូលបម្រើការងារថ្មីនៅធនាគារឥណទានជាតិ គាត់បានរួមដំណើរជាមួយ វ៉ាន់ ទិព្វសុវណ្ណ ទៅទីរួមខេត្តបាត់ដំបង ដើម្បីជួប គី សៀនហូ ពិភាក្សាគ្នាអំពីគម្រោងការផ្សេងៗ។

ពេលទៅដល់ទីរួមខេត្តបាត់ដំបង ល្ងាចនោះ វ៉ាន់ ទិព្វសុវណ្ណ និងគី សៀនហូ បានរៀបចំពិធីបញ្ចូល ភោគ ឆាយ ទៅក្នុងចលនាតស៊ូខ្មែរក្រហមខ្សែខាងបាត់ដំបង ដោយបាន

ប្ដេជ្ញាប្ដូរស្លាប់រស់ជាមួយគ្នាផងដែរ។ ក្នុងឱកាសនោះ វ៉ាន់ ទិព្វសុវណ្ណ ប្រាប់គាត់ថា ៖ ត្រូវរក្សាការសម្ងាត់ កុំឱ្យនរណាដឹងថា ពួកគាត់ជាខ្សែខាងបាត់ដំបងឱ្យសោះ ហើយក្នុងការទាក់ទងគ្នា គឺត្រូវប្រើលេខសម្ងាត់ គឺ វ៉ាន់ ទិព្វសុវណ្ណ លេខ១, គឺ សៀនហូ លេខ២, និងគាត់( ភោគ ឆាយ ) លេខ៣។

លុះត្រលប់មកភ្នំពេញវិញ គឺ សៀនហូ បានប្រគល់ប្រាក់១០ម៉ឺនរៀលឱ្យគាត់ទៀត ហើយថាបើមានការអ្វីទៀតឱ្យទាក់ទងនឹង វ៉ាន់ ទិព្វសុវណ្ណ ចុះ។ វ៉ាន់ ទិព្វសុវណ្ណ បានប្រាប់គាត់ថា ៖ គ្នាយើងមានច្រើនណាស់នៅភ្នំពេញ តែមានខ្សែដោយឡែក។ នង សួន ដែលកំពុងនៅក្នុងគុកសព្វថ្ងៃ និងហ៊ូ យន់ ក៏នៅក្នុងក្រុមរបស់យើងដែរ។

នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៦៤ តាមរយៈ អ៊ុច វ៉ែន និង ប៉ុក ដឹសកុមារ គាត់ក៏បានចូលធ្វើការនៅធនាគារឥណទានជាតិ ដោយមានតួនាទីជានាយកផ្នែកឥណទាន។

ក្រោយពេលបានចូលធ្វើការជានាយកផ្នែកឥណទាន នៅធនាគារឥណទានជាតិមក គាត់មានចិត្តគំនិតកាន់តែភ្លើតភ្លើន, ជីវភាពកាន់តែហ៊ឺហា, បាយទឹកជប់លៀងតែជាមួយនាយទុន និងពួកអ្នកមានៗ។

អ៊ុច វ៉ែន អគ្គនាយករងធនាគារឥណទានជាតិ បានណែនាំគាត់ថា បើភ្ញៀវអញ្ជើញទៅហូបបាយ ត្រូវតែទទួល ព្រោះយើងត្រូវប្រមូលឈ្មួញ ប្រមូលម៉ូយឱ្យគេមករកស៊ីជាមួយធនាគារយើង។ ដូច្នេះ ពីមួយថ្ងៃទៅមួយថ្ងៃ គាត់ជាប់នឹងការជប់លៀងមិនសូវលស់ពេល ហើយឈ្មួញ ដែលហៅខ្ញុំទៅជប់លៀងញឹកញាប់ជាងគេ គឺ វ៉ាន់ ទិព្វសុវណ្ណ។

វ៉ាន់ ទិព្វសុវណ្ណ ឧស្សាហ៍ចេញចូលធនាគារដាក់ប្រាក់ និងដកប្រាក់។ ដំបូងមិត្ត មឿន ហៅមិត្ត រឺត ជាបណ្ដាញសម្ងាត់ខ្មែរក្រហម ដែលពេលនោះនៅធ្វើការនៅជាប់នឹងគាត់ បានឱ្យដឹងថា វ៉ាន់ ទិព្វសុវណ្ណ មានហាងមួយនៅទល់មុខធនាគារ ឆៀងខាងលិចបន្តិច។ តែក្នុងហាងនោះ គ្មានមានទំនិញអីទេ មានតែតុ២ និងអង្គុលីលេខ១ ហើយមានមនុស្សតែពីរនាក់ ម្នាក់គឺ វ៉ាន់ ទិព្វសុវណ្ណ និងម្នាក់ទៀតឈ្មោះ យុត រាងចំណាស់បន្តិច។

រាល់ព្រឹកព្រលឹម ភោគ ឆាយ និងប៉ុក ដឹសកុមារ តែងទៅរកពិសាគុយទាវកាហ្វេនៅ

ហាងមួយទល់មុខរបស់ហាង វ៉ាន់ ទិព្វសុវណ្ណ នោះដែរ ហើយវ៉ាន់ ទិព្វសុវណ្ណ តែងមកចូលរួមតុកាហ្វេជាមួយគាត់ និង ប៉ុក ជឹសកុមារ ជានិច្ច។ ជួនកាល ឈ្មោះ យុត ក៏មកចូលតុរួមកាហ្វេមួយភ្លែត ក៏លាចូលទៅហាងគាត់វិញ។

ពេលនោះ វ៉ាន់ ទិព្វសុវណ្ណ បានប្រាប់គាត់ថា យុត ជាអ្នកតស៊ូជើងចាស់ម្នាក់នៅក្នុងក្រុមអាចារ្យ តក់ (កៅ តក់)កាលសម័យតស៊ូប្រឆាំងបារាំង។ គាត់ចេះភាសាថៃស្ទាត់ ហើយឧស្សាហ៍ចេញចូលស្រុកថៃ ទៀតផង។

ក្រោយមក ទើបគាត់ដឹងថា វ៉ាន់ ទិព្វសុវណ្ណ មានកំណើតនៅបាត់ដំបង គឺនៅតាមផ្លូវទៅប៉ៃលិន ចម្ងាយប្រហែល១០គីឡូម៉ែត្រ ពីក្រុងបាត់ដំបង។ វ៉ាន់ ទិព្វសុវណ្ណ ប្រាប់គាត់ថា គេជាអ្នកតស៊ូសម័យអាណានិគមបារាំងម្នាក់ដែរ គឺកាលសម័យនោះគេជាប់នឹងខ្សែ ស៊ីវហេង។ ក្រោយពីសន្និសញ្ញាក្រុង ហ្សឺណែវ គេធ្វើឈ្មួញស្រូវជាមួយ គី សៀនហូ នៅបាត់ដំបង ហើយទាក់ទងជាមួយ ងុយ កាន់ តាំងពីនោះមក។

តាមរយៈ វ៉ាន់ ទិព្វសុវណ្ណ ធ្វើឱ្យគាត់កាន់តែជិតស្និទ្ធជាមួយ ហ៊ូ យន់ និង អ៊ុច វ៉ែន ដូច្នេះ គាត់ក៏កាន់តែមានជំនឿលើ វ៉ាន់ ទិព្វសុវណ្ណ ខ្លាំងឡើងៗ។

នៅព្រឹកថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៦៤ ភោគ ឆាយ បានទៅរួមក្នុងពិធីបញ្ចប់វគ្គសិក្សាប្រចាំឆ្នាំដែលរៀបចំឡើងដោយសមាគមសិស្សវិទ្យាល័យកម្ពុជបុត្រ ក្រោមអធិបតីភាពរបស់ ហ៊ូ យន់ ។

ពេលនោះ គាត់បានជួបភ្ញៀវជាច្រើន ក្នុងនោះក៏មាន វ៉ាន់ ទិព្វសុវណ្ណ និងនិស្សិតមួយចំនួន មានជាអាទិ វ៉ាន់ ពីនី, ឈុន សុខងួន និងទួន សុខផល្លា។ ឈុន សុខងួន និង ទួន សុខផល្លា ជានិស្សិតសាលាវិស្វករ បានណែនាំគាត់ឱ្យស្គាល់សាស្ត្រាចារ្យ ឃួន ធុច (កុយ ធួន) ជាគ្រូរបស់របស់ពួកគេ កាលនៅរៀន ឯខេត្តកំពង់ចាម។ ពេលនោះហើយ ដែលគាត់បានស្គាល់ ឃួន ធុច (កុយ ធួន)ជាលើកដំបូង។

តាមរយៈ វ៉ាន់ ទិព្វសុវណ្ណ នៅយប់ថ្ងៃទី២៥ ខែមិថុនា ហ៊ូ យន់ បានហៅគាត់ឱ្យចូលរួមប្រជុំក្នុងផ្ទះបណ្តែតទឹកមួយនៅជ្រោយអំពិល ។ កម្មវិធីប្រជុំនេះ រៀបចំដោយសា

ស្ត្រាចារ្យ ឃួន ធុច (កុយ ធួន) មានអ្នកចូលរួមប្រជុំ៨នាក់ គឺ ហ៊ូ យន់ ប្រធានអង្គប្រជុំ, ហ៊ូ នឹម, សាស្ត្រាចារ្យ ឃួន ធុច ,ប៉ុក ដឹសកុមារ, ទីវ អុល, វ៉ាន់ ទិព្វសុវណ្ណ, រូបគាត់(ភោគ ឆាយ) និងក្រឡាបញ្ជីម្នាក់ទៀត មិនស្គាល់ឈ្មោះ។

របៀបវារៈប្រជុំពេលនោះគឺ ពិនិត្យសភាពការណ៍នយោបាយ និងការរៀបចំចាត់តាំងកម្លាំងមហាជន។ ក្រោយពីបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់មក អង្គប្រជុំបានសម្រេចថា នៅក្រុងភ្នំពេញ ត្រូវប្រមូលកម្លាំងមហាជន, ចាត់តាំងកម្លាំងមហាជន ពិសេសកម្លាំងយុវជន, និស្សិត និងសិស្ស ដើម្បីធ្វើសកម្មភាព...។

បន្ទាប់មក មានការបែងចែកភារកិច្ចគ្នា គឺ ទីវ អុល ជាអ្នកដឹកនាំគ្រប់គ្រងសមាគមគ្រូ និងសមាគមសិស្សវិទ្យាល័យចំរើនវិជ្ជា ឱ្យណែន ហើយធ្វើសហការជាមួយសមាគមផ្សេងៗ ឱ្យបានជិតស្និទ្ធបំផុត។ ចំណែក ប៉ុក ដឹសកុមារ ជាអ្នកតម្រង់ទិសនយោបាយ កាសែតឡាដេប៉ែស្ហ និងជំរុញឱ្យមានការបង្កើតសមាគមអ្នកនិពន្ធកាសែតមួយ។ ឯ ភោគ ឆាយ រួមជាមួយនិស្សិតមួយចំនួនទៀត ត្រូវសហការគ្នាបង្កើតសមាគមទូទៅរបស់និស្សិត។

ពេលនោះ ភោគ ឆាយ បានទទួលយល់ព្រមក្នុងការបង្កើតសមាគមទូទៅរបស់និស្សិតនោះ តែបានលើកពីការលំបាកមួយចំនួន។ ហ៊ូ យន់ និយាយថា ចាំឱ្យសមាជិកយើងម្នាក់ចុះទៅជួយដោយសម្ងាត់។ លុះត្រលប់មកវិញ វ៉ាន់ ទិព្វសុវណ្ណ យកប្រាក់៥ម៉ឺនរៀល មកឱ្យគាត់ ទុកដើម្បីរៀបចំបង្កើតសមាគមនិស្សិតនោះផងដែរ។ តែ វ៉ាន់ ទិព្វសុវណ្ណ ប្រាប់ថា កុំឱ្យនរណាដឹងថា ប្រាក់៥ម៉ឺនរៀលនោះ ជាប្រាក់របស់ខ្លួន ឱ្យថា ប្រាក់នោះជាប្រាក់របស់គាត់ផ្ទាល់ទៅវិញ។ ប៉ុន្តែ ដោយសារពេលនោះ ពួកនិស្សិតកំពុងប្រលង ហើយបន្ទាប់មកជាពេលវិស្សមកាលទៀតនោះ គាត់មិនអាចទាក់ទងប្រមូលពួកនិស្សិតដើម្បីរៀបចំបង្កើតសមាគមនិស្សិតនោះ បានទេ។

រហូតដល់ថ្ងៃ២២ ខែធ្នូ ឆ្នាំ១៩៦៤ ទើបភោគ ឆាយ អាចមានលទ្ធភាពបង្កើតសមាគមនិស្សិតមួយដែលមានឈ្មោះថា "សមាគមទូទៅនៃនិស្សិតខ្មែរនៅកម្ពុជា"។ គាត់ត្រូវបានជ្រើសរើសជាប្រធាន, វ៉ាន់ ពីនី ជាអនុប្រធានទី១, ឈុន សុខង្វួន ជាអនុប្រធានទី២, ទួន

សុខផល្លា ជាអគ្គលេខាធិការ, កង សារ៉ន ជាអគ្គលេខាធិការរងទី១, ម៉ែ សាខន ជាអគ្គលេខាធិការរងទី២, ប៉ុក កាណៃល ជាហិរញ្ញិក។

ក្រោយពេលប្រកាសបង្កើតសមាគមនិស្សិតនេះមក វ៉ាន់ ទិព្វសុវណ្ណ, ថៅ សេង, ហ៊ូ យន់, ហ៊ូ នឹម, សាស្ត្រាចារ្យ ឃួន ធុច, ប៉ុក ជឹសកុមារ និងអ៊ុច វ៉ែន ជាដើម ក៏បានធ្វើប្រាក់កាសមកជួយឧបត្ថម្ភសមាគមជាបន្តបន្ទាប់។ ពិសេសសម្តេចសីហនុ ក៏បានជួយឧបត្ថម្ភប្រាក់កាសច្រើនគួរសមដែរ។

ភោគ ឆាយ បានបញ្ជាក់ថា ការពិត សមាគមនេះមានតែឈ្មោះទេ មិនមានធ្វើសកម្មភាពតស៊ូអ្វីឡើយ។ ផ្ទុយទៅវិញ គឺសិស្សនៅវិទ្យាល័យចំរើនវិជ្ជា និងវិទ្យាល័យកម្ពុជបុត្រ ដឹកនាំដោយសាស្ត្រាចារ្យ ទីវ អុល និងសិស្សនៅវិទ្យាល័យតាខ្មៅ ដឹកនាំដោយសាស្ត្រាចារ្យ កែ គឹម ហួត ហៅសុត ជាអ្នកធ្វើសកម្មភាពតស៊ូជាក់ស្តែង។ ចំណែករូបគាត់ជាប្រធានសមាគមនិស្សិតនេះ គ្រាន់តែបានចេញមុខទៅចូលរួមក្នុងពិធីផ្សេងៗជាចំហប៉ុណ្ណោះ។

មិនយូរប៉ុន្មាន គាត់បានសុំលាលែង និងរំលាយសមាគមនិស្សិតនេះច្រើនដងដែរ ដើម្បីទៅធ្វើការតស៊ូសម្ងាត់វិញ តែមេដឹកនាំគាត់ប្រាប់គាត់មិនឱ្យរំលាយសមាគមនិស្សិតនេះទេ គឺទុកសមាគមនិស្សិតនេះ ដើម្បីធ្វើជារបាំងឱ្យសិស្សនៅវិទ្យាល័យចំរើនវិជ្ជា នៅវិទ្យាល័យកម្ពុជបុត្រ និងសិស្សនៅវិទ្យាល័យតាខ្មៅ ធ្វើសកម្មភាព ។

រហូតដល់ឆ្នាំ១៩៦៥ ទើបគាត់ដឹងថា មានបក្សកុម្មុយនិស្តកម្ពុជា ជាអ្នកដឹកនាំចលនាតស៊ូបដិវត្តន៍ ហើយគាត់បានសុំចូលបក្សជាច្រើនដងដែរ។ តែអ៊ុច វ៉ែន និងប៉ុក ជឹសកុមារ ចេះតែប្រាប់ថា កុំអាលៗ។ ប៉ុន្តែយូរៗម្តង អ្នកទាំង២នាក់នេះ ក៏បានផ្តល់ព្រឹត្តិបត្រសំឡេងប្រជាពលករ មកឲ្យគាត់អានដែរ។ ដូច្នេះ ចាប់ពីពេលនោះមក គាត់កាន់តែចង់ធ្វើបដិវត្តន៍ឡើងៗ។

ពេលនោះដែរ ដោយឃើញសមាគមមិត្តភាពកម្ពុជា-ចិន មានបញ្ញាជនចម្រើនជាច្រើនចូលរួម គាត់ក៏បានចូលរួមជាសមាជិកមួយរូបនឹងគេដែរ ប៉ុន្តែពេលនោះ គាត់មិនទាន់បានរៀនសូត្រពីគោលនយោបាយរបស់បក្ស ដូច្នេះ គាត់ក៏មានគោលជំហរម្តងឆ្វេង ម្តងស្តាំ ។

ពិសេស គាត់ឃើញខៀវ សំផន ហ៊ូ យន់ និងហ៊ូ នឹម ចូលក្នុងសមាគមមិត្តភាពកម្ពុជា-ចិន គាត់ក៏ពេញចិត្តចូលរួមក្នុងសមាគមនេះដែរ ព្រោះពេលនោះគាត់មិនទាន់ស្គាល់រចនាសម្ព័ន្ធដឹកនាំបក្សច្បាស់លាស់ ហើយគាត់គោរព និងគិតថា បុគ្គលទាំង៣នាក់នេះជាមេដឹកនាំបដិវត្តន៍ទៀតផង។

នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៦៩ ភោគ ឆាយ ក៏ត្រូវសម្តេចសីហនុ បញ្ជាឲ្យចាប់ខ្លួន និងវាយធ្វើទារុណកម្មសួរចម្លើយ ហើយឱ្យតុលាការសឹកកាត់ទោសដាក់ពន្ធនាគារព្រៃស។ នៅទីនោះ ភោគ ឆាយ ក៏បានជួប នង សួន មេដឹកនាំគណបក្សប្រជាជន ដែលមានទោសជាប់គុកអស់មួយជីវិតនោះដែរ ។

នៅក្នុងពន្ធនាគារព្រៃស សូម្បីប្រពន្ធ និងបងប្អូនរបស់ភោគ ឆាយ ក៏មិនត្រូវអនុញ្ញាតឱ្យចូលសួរសុខទុក្ខដែរ ប៉ុន្តែ ដោយសារក្រុមគ្រួសារខាងប្រពន្ធភោគ ឆាយ ជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ និងស្គាល់រាជវង្សានុវង្សច្រើន ពិសេសគឺ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ នោះ ឪពុកម្តាយក្មេក និងប្រពន្ធគាត់ ក៏មានឱកាសបានចូលថ្វាយបង្គំព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ ដើម្បីសុំឱ្យព្រះរាជទានទោស ។

ក្រោយមក ក្នុងឱកាសធ្វើសមាជជាតិនៅទីវាលព្រះមេរុ នៅក្នុងខែធ្នូ ឆ្នាំ១៩៦៩ សម្តេចសីហនុ ក៏បានប្រកាសថា ព្រះអង្គនឹងដោះលែងគាត់ឱ្យមានសេរីភាពវិញ។ ចាប់ពីពេលនោះមក ប្រពន្ធនិងក្រុមគ្រួសារគាត់ ក៏បានគេអនុញ្ញាតឱ្យចូលសួរសុខទុក្ខគាត់នៅក្នុងពន្ធនាគារព្រៃសផងដែរ។ ប៉ុន្តែ រហូតដល់ខែកុម្ភៈ ឆ្នាំ១៩៧០ ទើប ភោគ ឆាយ បានរួចចេញពីពន្ធនាគារព្រៃស មកជួបជុំប្រពន្ធ និងក្រុមគ្រួសារវិញ ។

នៅពេលចាប់ខ្លួន ភោគ ឆាយ នៅក្នុងខែតុលានោះ ឈ្មោះវ៉ាន់ ទិព្វសុវណ្ណ ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនដែរ ហើយគាត់ត្រូវបាត់បង់ជីវិតនៅក្នុងស្នងការដ្ឋានប៉ូលិស នៅពេលនោះទៅ។

# ២១៥
# ហ៊ូ នឹម ពីក្មេងក្រីក្រកំព្រើកំព្រា ក្លាយជាអ្នកនយោបាយល្បីឈ្មោះ



ហ៊ូ នឹម

បើតាមចម្លើយសារភាពនៅក្នុងពេលមេខ្មែរក្រហមប៉ុល ពត បញ្ជាឱ្យចាប់ខ្លួនបញ្ជូនយកទៅដាក់នៅមន្ទីរឃុំឃាំង ស-២១(គុកទួលស្លែង)ហ៊ូ នឹម បានសរសេររៀបរាប់ថា គាត់កើតនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៣០ (ឆ្នាំមមី) នៅឃុំមៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ ក្នុងឆ្នាំ១៩៣៦ ពេលមានអាយុ៦ឆ្នាំ ឪពុករបស់គាត់ឈ្មោះ ហ៊ូ បានទទួលមរណភាពដោយជំងឺ។ ម្ដាយគាត់ឈ្មោះស៊ន ជាស្រីមេម៉ាយដើរស៊ីឈ្នួលដួលព័ទ្ធគេពីស្រុកមួយទៅស្រុកមួយ។

ក្រោយមក ម្ដាយគាត់បានយកប្ដីមួយទៀត ជាកសិករក្រីក្រដែរ ក៏បានយកគាត់ទៅផ្ញើនឹងព្រះសង្ឃនៅវត្តមៀន នៅក្នុងឃុំមៀន នោះដែរ។ ព្រះសង្ឃព្រះនាម សំ ឃ និងព្រះសង្ឃព្រះនាម ញ៉ែប នៅ ក៏បានជួយចិញ្ចឹម និងផ្ទុងផ្ដើមគាត់ឱ្យបានរៀនសូត្រនៅសាលាវត្តមៀន

និងសាលាបឋមសិក្សាព្រៃទទឹង រហូតដល់អនុវិទ្យាល័យកំពង់ចាម។

ឆ្នាំ១៩៥១ ហ៊ូ នឹម បានប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ( ឌីប្លូម ) រួចបានមកស្នាក់នៅវត្តឧណ្ណាលោម ដើម្បីសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិ បន្តទៀត។ ដោយមានការជួយឧបត្ថម្ភពីក្រុមគ្រួសារក្រមុំម្នាក់នៅទន្លេបិទ ឈ្មោះ វ៉ា ឡាន ជាអ្នកមានជីវភាពធូរធារ គាត់អាចមានលទ្ធភាពរៀនសូត្រ រហូតប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិភាគ១ ( បាក់អង ) និងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិភាគ២( បាក់ឌុប )។

ហ៊ូ នឹម មានជំហរប្រឆាំងអាណានិគមបារាំង តាំងពីនៅជាសិស្សនៅវិទ្យាល័យព្រះស៊ីសុវត្ថិនោះ មកម្ល៉េះ ហើយក៏ដូចសិស្ស និស្សិត មន្ត្រីរាជការ ព្រមទាំងមហាជនផ្សេងៗទៀតដែរ គាត់យល់ឃើញថា សឺង ង៉ុកថាញ់ ជាអ្នកស្នេហាជាតិ ជាមេដឹកនាំទាមទារឯករាជ្យពីអាណានិគមបារាំង។

ក្រោយពេលបារាំង ដោះលែង សឺង ង៉ុកថាញ់ ពីប្រទេសបារាំង វិញ។ នៅថ្ងៃទី ០៩ ខែតុលា ឆ្នាំ១៩៥១ សិស្ស និស្សិត មន្ត្រីរាជការ ព្រមទាំងមហាជនយ៉ាងច្រើនកុះករ ក្នុងនោះ មានរូបគាត់ម្នាក់ដែរ បាននាំគ្នាហែក្បួនទៅឈរទទួលស្វាគមន៍ សឺង ង៉ុកថាញ់ តាមដងផ្លូវពីអាកាសយានដ្ឋានពោធិ៍ចិនតុង ចូលមកទីក្រុងភ្នំពេញ ដោយក្តីរំភើបរីករាយបំផុត។

នៅឆ្នាំ១៩៥២ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ មានចលនាមួយគាំទ្រ សឺង ង៉ុកថាញ់ ដែលបានរត់ចូលព្រៃនៅភ្នំដងរែក ដើម្បីទាមទារឯករាជ្យពីអាណានិគមបារាំង។ អ៊ុង ស៊ីម ជាមេចលនានេះ បានបំផុសសិស្សមួយចំនួនឲ្យរត់ចូលព្រៃជាមួយខ្លួន ដើម្បីតស៊ូទាមទារឯករាជ្យក្រោមការដឹកនាំរបស់ សឺង ង៉ុកថាញ់ ។ ពេលនោះ អ៊ុង ស៊ីម ក៏បានបញ្ចុះបញ្ចូល ហ៊ូ នឹម ឱ្យរត់ចូលព្រៃដែរ តែគាត់មិនបានទៅជាមួយទេ ហើយគាត់បានទៅរៀបការជាក្រមុំឈ្មោះ វ៉ា ឡាន នៅទន្លេបិទនោះ។

ជាមួយគ្នានោះដែរ គាត់បានចូលសិក្សានៅវិទ្យាស្ថានច្បាប់ និងសេដ្ឋកិច្ច (នៅខាងក្រោយវិទ្យាល័យព្រះស៊ីសុវត្ថិ) បន្តទៀត ព្រមទាំងឆ្លៀតឱកាសចាប់អាជីពជាគ្រូបង្រៀននៅវិទ្យាល័យកម្ពុជបុត្រ (វិទ្យាល័យឯកជន) ដើម្បីជីវភាពគ្រួសារផងដែរ។ ក្នុងឆ្នាំ១៩៥៥ ក្រោយ

សន្និសញ្ញាក្រុងហ្សឺណែវ គាត់បានចូលរួមជួយឃោសនាឱ្យប្រជារាស្ត្របោះឆ្នោតឱ្យគណបក្សប្រជាធិបតេយ្យ ពិសេសបេក្ខជនមកពីប្រជាចលនារបស់ សឺង ង៉ុកថាញ់។

ក្រោយពេលបោះឆ្នោត សមត្ថកិច្ចក៏រកចាប់គាត់ដែរ។ តែគាត់បាន ម៉ៅ សាយ (រដ្ឋមន្ត្រីថវិកា) និងផ្លែក ភឺន (រដ្ឋមន្ត្រីផែនការ កសិកម្ម និងចិញ្ចឹមសត្វ) ជួយអន្តរាគមន៍ឱ្យបានអាហារូបករណ៍ទៅរៀនសាលាគយ និងច្បាប់ នៅប្រទេសបារាំង។ ពេលនោះ គាត់បានជួបហ៊ូ យន់ និងយៀង ខាអុន ជជែកគ្នាពីរឿងធ្វើបដិវត្តន៍ដែរ តែមិនទាន់ចុះសម្រុងគ្នា ដោយពេលនោះ គាត់មិនទាន់មានសមានចិត្តទៅលើក្រុមប្រជាជនទេ ព្រោះឮថាក្រុមនេះស្ថិតនៅក្រោមអំណាចវៀតណាម និងបក្សកុម្មុយនិស្តឥណ្ឌូចិន ។

ឆ្នាំ១៩៥៧ គាត់ប្រលងជាប់បរិញ្ញាបត្រឆ្នាំទី២ ផ្នែកគយ និងច្បាប់ បារាំងឱ្យគាត់ចុះ ទៅធ្វើកម្មសិក្សាត្រួតពិនិត្យទំនិញ នៅកំពង់ផែម៉ាកសី រយៈពេល១ខែ ក៏វិលត្រលប់មកមាតុប្រទេសវិញ។ ពេលមកដល់ប្រទេសវិញ គាត់បានចូលបម្រើការងារប្រធានការិយាល័យច្បាប់នៅក្រសួងគយ បាន៣ខែ ក៏បានឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ។ តែដើម្បីឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្ររបស់ចលនាសង្គមរាស្ត្រនិយម បាន ត្រូវមានអ្នកធានា២នាក់។ គាត់ក៏បានទៅជួប ផ្លែក ភឺន (រដ្ឋមន្ត្រីកសិកម្ម ផែនការ និងឧស្សាហកម្ម) ហើយ ផ្លែក ភឺន បាននាំគាត់ទៅជួប ម៉ៅ សាយ ឱ្យជួយធានាបាន២នាក់ ដើម្បីឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ។

បន្ទាប់មក ម៉ៅ សាយ បានជួយគាត់ឱ្យទៅសរសេរអត្ថបទឱ្យកាសែតប្រជាសេរី របស់ ស៊ឹម វ៉ា និងកាសែតជឺ រ៉េអាល់លីតេ ដើម្បីបានប្រាក់កម្រៃចិញ្ចឹមគ្រួសារ។ ក្រោយពេលជាប់ឆ្នោតជាអ្នកតំណាងរាស្ត្រ គាត់បានរួមធ្វើសកម្មភាពនយោបាយជាមួយ អ៊ុច វ៉ែន, ហ៊ូ យន់ និងខៀវ សំផន។ នៅក្នុងឆ្នាំ១៩៥៩ គាត់បានចូលរួមជាសមាជិកគណៈប្រតិភូអ្នកសារព័ត៌មានកម្ពុជា ទៅបំពេញទស្សនកិច្ចនៅអឺរ៉ុបខាងកើត។ គណៈប្រតិភូនេះ មានសឺង គឿកថ ចាងហ្វាងកាសែតមាតុភូមិ ជាប្រធាន និងមានតំណាងពួកកាសែតស្តាំនិយមទាំងអស់ជាសមាជិក។

ពេលនោះ គណៈប្រតិភូអ្នកសារព័ត៌មានកម្ពុជា បានទៅបំពេញទស្សនកិច្ចនៅសហភាពសូវៀត, ប៉ូឡូញ, ឆេកូស្លូវ៉ាគី, អាល្លឺម៉ង់ខាងកើត និងអារ៉ាប់រួម ដែលសុទ្ធសឹងជាប្រទេស

សង្គមនិយម។

ហ៊ូ នឹម បានរម្លឹកថា នៅដើមឆ្នាំ១៩៦១ គាត់ត្រូវបានជ្រើសតាំងជាអនុប្រធានរដ្ឋសភា ហើយរដ្ឋសភាបានចាត់តាំងគាត់ឲ្យធ្វើជាសមាជិកគណៈប្រតិភូដឹកនាំដោយសម្តេចសីហនុ ទៅចូលរួមសន្និសីទបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធលើកទី១ នៅក្រុងបែលក្រាដ សាធារណរដ្ឋសែរប៊ី រួចហើយបន្តទៅចូលរួមប្រជុំមហាសន្និបាតអង្គការសហប្រជាជាតិទៀត។

នៅក្នុងគណៈកម្មការទី៤ នៃអង្គការសហប្រជាជាតិ ហ៊ូ នឹម ឡើងថ្លែងយោបល់ប្រឆាំងពួកចក្រពត្តិនិយម និងការពារចលនាតស៊ូបដិវត្តន៍អាហ្វ្រិក។ ឈ្មោះគាត់ និងយោបល់គាត់ មានកត់ត្រាទុកជាឯកសារនៅក្នុងបណ្ណាសាររបស់អង្គការសហប្រជាជាតិ។

ក្នុងឆ្នាំ១៩៦២ គាត់ធ្វើជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មផង និងជាប្រធានគណៈកម្មការសេដ្ឋកិច្ច នៅក្នុងរដ្ឋសភាផង គាត់បានឡើងមានមតិប្រឆាំងនឹង ឡុង បូរ៉េត, ឌុក រ៉ាស៊ី និងកន្លារ ដឺម៉ុងតេរ៉ូ ដែលគាំទ្រពាណិជ្ជកររឈ្មោះសុង សាក់ ហើយបានលើកដៃអនុម័តសម្រេចបិទធនាគារភ្នំពេញ របស់សុង សាក់ នោះទៀតផង។

ក្នុងឆ្នាំ១៩៦២នោះដែរ សម្តេចសីហនុ បានតែងតាំងគាត់ជាសមាជិកគណៈប្រតិភូដែលមានព្រះអង្គជាប្រធាន ទៅបំពេញទស្សកិច្ចជាផ្លូវការនៅប្រទេសឥណ្ឌូណេស៊ី ផងដែរ។

ពីឆ្នាំ១៩៥៧ ដល់ឆ្នាំ១៩៦២ គាត់ឧស្សាហ៍ជួបជុំ ជាមួយ អ៊ុច វ៉ែន, ខៀវ សំផន និង ហ៊ូ យន់ ពិភាក្សាគ្នាពីបញ្ហាប្រទេសជាតិ ហើយ អ៊ុច វ៉ែន បានយកឯកសារទ្រឹស្តីកុម្មុយនិស្តរបស់ ឡេនីន ដែលនិយាយពីការធ្វើបដិវត្តន៍ មកឱ្យគាត់អានផងដែរ។

ឆ្នាំ១៩៦៣ គាត់បានចូលបម្រើការងារជាអ្នកនិពន្ធឱ្យទស្សនាវដ្តីអ្នកជាតិនិយម របស់សម្តេច សីហនុ។ ពេលនោះ គាត់ត្រូវបានតែងតាំងជាសមាជិកគណៈប្រតិភូអ្នកសារព័ត៌មានកម្ពុជា មានសឺង គៀកថ ជាប្រធាន ទៅបំពេញទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន រួចបន្តទៅប្រទេសកូរ៉េខាងជើងទៀត។ គាត់មានការចាប់អារម្មណ៍ជាខ្លាំង ចំពោះការលូតលាស់របស់ប្រទេសកុម្មុយនិស្តទាំងពីរនេះ។

បន្ទាប់មក គាត់បានទៅធ្វើទស្សនកិច្ចនៅប្រទេសវៀតណាមខាងជើង ជាបន្តទៀត។

នៅទីក្រុងហាណូយ ហូ ជីមិញ និងផាំ វ៉ាន់ដុង បានទទួលគាត់ និងគ្រួសារគាត់យ៉ាងរាក់ទាក់ ហើយពួកមេដឹកនាំកុម្មុយនិស្តវៀតណាម ទាំង២នាក់នេះ ប្រាប់គាត់ថា បើនៅកម្ពុជា មានការលំបាក ឬមានឧបសគ្គអ្វី មិនអាចនៅកើត សូមមកនៅប្រទេសវៀតណាមខាងជើង យើងនឹងទទួលដោយរីករាយ។ ពេលនោះ គាត់មិនសូវចូលចិត្តវៀតណាមខាងជើង ប៉ុន្មានទេ តែមានសមានចិត្តចំពោះចិន និងកូរ៉េខាងជើង។

ពេលគាត់កំពុងធ្វើទស្សនកិច្ចនៅប្រទេសវៀតណាមខាងជើង ម៉ៅ សាយ បានស្នើទៅសម្តេចសីហនុ ឲ្យដកឈ្មោះគាត់ចេញពីចលនាសង្គមរាស្ត្រនិយម និងពីទស្សនាវដ្តីអ្នកជាតិនិយម។ ពេលវិលត្រលប់មកពីប្រទេសវៀតណាមខាងជើង វិញ គាត់សរសេរអត្ថបទ ជាច្រើនទាក់ទងនឹងការរីកចម្រើនរបស់បដិវត្តន៍នៅប្រទេសចិន និងប្រទេសកូរ៉េខាងជើង ព្រមទាំងអត្ថបទតិចតួច ទាក់ទងនឹងការរីកចម្រើនរបស់បដិវត្តន៍នៅវៀតណាមខាងជើង យកទៅចុះផ្សាយនៅលើទំព័រកាសែតឡា ដេប៉ែស្ហ ព្រោះពេលនោះ សម្តេចសីហនុ លែងឱ្យធ្វើការនៅទស្សនាវដ្តី អ្នកជាតិនិយម ទៀតហើយ។

ពេលត្រលប់មកពីបំពេញទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន គាត់ចាប់ផ្តើមយកចិត្តទុកដាក់អានសៀវភៅផ្សេងៗជាស្នាដៃនិពន្ធរបស់ ម៉ៅ សេទុង ហើយថែមទាំងបានបកប្រែស្នាដៃនិពន្ធរបស់ ម៉ៅ សេទុង ជាភាសាខ្មែរ យកទៅចុះផ្សាយនៅលើទំព័រកាសែតទៀតផង។

ក្នុងឆ្នាំ១៩៦៣នោះដែរ គាត់ ជាមួយហ៊ូ យន់ និងអ៊ុច វ៉ែន តែងមានទំនាស់គ្នាពីបញ្ហាសូវៀត និងចិន។ គាត់ប្រឆាំងពួកសេរីនិយមសូវៀត ហើយគាំទ្រចិន តែ ហ៊ូ យន់ និងអ៊ុច វ៉ែន គាំទ្រសូវៀត។ ពេលនោះ គាត់មិនដែលបានឃើញ ឬបានអានឯកសារ និងលក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា ទេ ហើយក៏មិនដឹងច្បាស់ថា នរណាជាមេដឹកនាំបក្សដែរ គាត់នឹកស្មានថា អ៊ុច វ៉ែន, ខៀវ សំផន ឬហ៊ូ យន់ ?

មានពេលមួយ កំពុងជិះរថយន្តជាមួយគ្នា គាត់បាននិយាយលេងជាមួយ ប៉ុក ដឹសកុមារ និងភោគ ឆាយ ថា បើ ហ៊ូ យន់ និងអ៊ុច វ៉ែន គាំទ្រពួកសេរីអ៊ីចឹង ពួកយើងបង្កើត

បក្សថ្មីមួយទៀតទៅ...ព្រោះគាត់ធ្លាប់ឮ វ៉ាន់ ទិព្វសុវណ្ណ និយាយលេងបែបនេះដែរ។

ហ៊ូ នឹម បានរម្លឹកបន្តថា ក្នុង១៩៦៤ គាត់ចាប់ផ្តើមបង្កើតគណៈកម្មការមួយ ដើម្បីឈានទៅបង្កើតសមាគមមិត្តភាពកម្ពុជា-ចិន។ គណៈកម្មការនោះ រួមមាន ហ៊ិន ឌី ជាប្រធាន ព្រមទាំងមាន មាស សាអែម, ភី ធានឡាយ, អ៊ាប គឹមជន, ហ៊ីង កន្ធែល, សូ ណៃម, ហ៊ូ យន់ និងគាត់ ជាសមាជិក ។

គណៈកម្មការនេះបានរៀបចំលក្ខន្តិកៈសមាគមយកទៅតម្កល់ទុកនៅសាលាដំបូងតាមច្បាប់ និងបានប្រមូលសមាជិកផ្សេងៗទៀតជាបន្តបន្ទាប់។ សមាជិកភាគច្រើន គឺពួកស្តាំនិយម ហើយគណៈកម្មការនេះ បានជ្រើសរើសគណៈកម្មការនាយកស្ថាពរមួយ រួមមាន ទ្បេង ង៉ែត ជាប្រធាន, ហ៊ិន ឌី អនុប្រធានទី១, សូ ណៃម អនុប្រធានទី២, គាត់(ហ៊ូ នឹម) អគ្គលេខាធិការ, វ៉ាន់ ទិព្វសុវណ្ណ គណនេយ្យ, ភី ធានឡាយ, ស្វាយ បូរី, អ៊ាប គឹមជន និងហ៊ូ យន់ ជាទីប្រឹក្សា។

ពេលធ្វើពិធីសម្ពោធសមាគមមិត្តភាពកម្ពុជា-ចិន ជាផ្លូវការ នៅរោងកុនភ្នំពេញ ខាងសមាគមមិត្តភាពចិន-កម្ពុជា នៅក្រុងប៉េកាំង បានបញ្ជូនប្រធានរបស់សមាគមគេ គឺ ទិន ស៊ីលីង ជាអនុរដ្ឋមន្ត្រី មកចូលរួមដែរ។

ពេលនោះដែរ ទន្ទឹមគ្នានឹងការងារជាអ្នកតំណាងរាស្ត្រ គាត់ក៏បានឆ្លៀតឱកាសសរសេរនិក្ខេបបទចំនួន២ ដើម្បីយកសញ្ញាបត្រថ្នាក់បណ្ឌិតនៅមហាវិទ្យាល័យច្បាប់។ និក្ខេបបទទី១ នៅឆ្នាំ១៩៦១ និង១៩៦២ គាត់សរសេរនិក្ខេបបទមានចំណងជើងថា ស្ថានការណ៍ និងលក្ខណៈនៃកម្ពុជាក្រោម ដែលជាទឹកដីខ្មែរ។

និក្ខេបបទទី២ មានចំណងជើងថា ឆ្វេង (ពួកកុម្មុយនិស្តនិយម) និងចម្រើន (ពួកលម្អៀងទៅរកកុម្មុយនិស្ត)។ គាត់សរសេរពីបរាជ័យនៃការធ្វើកំណែទម្រង់សេដ្ឋកិច្ចនៅកម្ពុជា ដោយបានបញ្ជាក់ច្បាស់ពីក្រុមហ៊ុនអាហារណែនីហារណែជាតិ ហៅកាត់ថា "សូណិចស៊ីម" ត្រូវខាតបង់ប្រាក់ ចំនួន៧០០លានរៀល ជារៀងរាល់ឆ្នាំ ក្នុងការនាំអង្ករចេញ តាំងពីបង្កើតក្រុមហ៊ុនរដ្ឋមួយនេះមក។

គាត់សរសេរពីមូលហេតុនៃការបរាជ័យនេះថា មកពីរបបសេដ្ឋកិច្ចជិះជាន់ ដោយបានបង្ហាញពីតួលេខ ឬស្ថិតិថ្មីៗ ដែលបញ្ជាក់អំពីពួកសក្តិភូមិម្ចាស់ដីនាយទុនមួយក្តាប់តូច ការប្រមូលកាន់កាប់ដីធ្លីរបស់កសិករ ហើយកសិករអត់ដីធ្លីធ្វើស្រែចម្ការ, អំពីទម្ងន់នៃពន្ធដារគ្រប់ជំពូក និងការខាតបង់របស់ក្រុមហ៊ុនសូណិចស៊ីម ដែលត្រូវធ្លាក់ទៅលើកម្មករ និងកសិករក្រីក្រ។

គាត់សន្និដ្ឋានថា ដោយរបបសេដ្ឋកិច្ចនៅមានលក្ខណៈជិះជាន់បែបនេះ ការកែទម្រង់សេដ្ឋកិច្ចមិនគ្រាន់តែត្រូវបរាជ័យ និងធ្វើឲ្យសេដ្ឋកិច្ចកាន់តែធ្លាក់ទៅក្នុងមហាវិបត្តិនោះទេ គឺថែមទាំងធ្វើឱ្យមានទំនាស់រវាងវណ្ណៈកម្មករកសិករ និងវណ្ណៈសក្តិភូមិម្ចាស់ដីនាយទុន កាន់តែពុះកញ្ជ្រោលឡើងថែមទៀតផងដែរ។ ដូច្នេះមានតែការធ្វើបដិវត្តន៍ទេ ទើបដោះស្រាយបញ្ហានេះបាន។

ហ៊ូ នឹម បានរម្លឹកបន្តទៀតថា នៅក្នុងរដ្ឋសភា គាត់គាំទ្រសម្តេចសីហនុ ដែលបានផ្តាច់ចំណងការទូតជាមួយសហរដ្ឋអាមេរិក។

ជាមួយគ្នានោះ គាត់បានចូលរួមក្នុងគណៈកម្មការទទួលពាក្យបណ្តឹងរដ្ឋសភា ទៅជួយដោះស្រាយបញ្ហាដីធ្លីជូនប្រជាជន១០០គ្រួសារនៅខេត្តព្រៃវែង ដែលត្រូវ លន់ នល់ បានរឹបអូសយកពីមុន មកជូនទៅប្រជាជនវិញ ហើយបានទៅជួយដោះស្រាយបញ្ហាដីធ្លីជូនប្រជាជននៅក្រវ៉ា បាក់ស្នា នៅព្រៃទទឹង នៅកងមាស និងនៅខេត្តបាត់ដំបង ជាដើម។

# ២១៦
# ពួកខ្មែរក្រហម ជួយហ៊ូ នឹម ឱ្យជាប់ឆ្នោតជាតំណាងរាស្ត្រ

ក្នុងឆ្នាំ១៩៦៥ សមាគមមិត្តភាពចិន-កម្ពុជា នៅក្រុងប៉េកាំង បានអញ្ជើញគណៈប្រតិភូសមាគមមិត្តភាពកម្ពុជា-ចិន នៅភ្នំពេញ ទៅទស្សនកិច្ចនៅក្រុងប៉េកាំង។ ពេលនោះគាត់ធ្វើជាប្រធានគណៈប្រតិភូ, វ៉ាន់ ទិព្វសុវណ្ណ, សំ ថាំង, អុល ចាន់, ស្វាយ បូរី, ភី ធានឡាយ និងអ៊ាប គឹមជន ជាសមាជិក។

ពេលគាត់ដឹកនាំគណៈប្រតិភូសមាគមមិត្តភាពកម្ពុជា-ចិន ទៅបំពេញទស្សនកិច្ចនៅក្រុងប៉េកាំងនោះ មិនទាន់ផ្ទុះមហាបដិវត្តន៍វប្បធម៌នៅឡើយទេ។ ហេតុនេះ នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ បានទទួលជួបសំណេះសំណាលជាមួយគណៈប្រតិភូគាត់ ហើយបន្ទាប់មកប្រធានាធិបតីចិន លីវ ចាវជី ក៏បានទទួលជួបសំណេះសំណាលជាមួយគណៈប្រតិភូគាត់ដែរ។ ក្រោយពេល គណៈប្រតិភូគាត់ត្រលប់មកកម្ពុជា វិញ ទើបផ្ទុះមហាបដិវត្តន៍វប្បធម៌ «ថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៦៦» ទម្លាក់លីវ ចាវជី និងចាប់យកទៅដាក់ពន្ធនាគារ។

ពេលគាត់កំពុងបំពេញទស្សនកិច្ចនៅក្រុងប៉េកាំងនោះ នៅឥណ្ឌូនេស៊ី ស៊ូហារតូ បានធ្វើរដ្ឋប្រហារទម្លាក់ស៊ូកាណូ ហើយបង្ក្រាបបក្សកុម្មុយនិស្តឥណ្ឌូនេស៊ី យ៉ាងរង្គាល។

ក្រោយព្រឹត្តិការណ៍នៅឥណ្ឌូនេស៊ីនោះ ខៀវ សំផន បានណែនាំគាត់ឲ្យទៅជួប សឺន សាន (ពេលនោះ សឺន សាន ជាឧបនាយករដ្ឋមន្ត្រី) ដើម្បីពិភាក្សាគ្នាពីបញ្ហាប្រទេសជាតិថា បើពួកស្តាំនិយមបានឡើងកាន់អំណាច ខ្លាចមានគ្រោះថ្នាក់របស់ប្រទេសជាតិ ដូចពួកស្តាំនិយម នៅឥណ្ឌូនេស៊ី។

តាមរយៈការពិភាក្សាគ្នានេះ គាត់សង្ឃឹមថា សឺន សាន នឹងយកបញ្ហាពួកស្តាំនិយមកាន់អំណាច អាចបង្កគ្រោះថ្នាក់ដល់ប្រទេសទៅទូលសម្តេចសីហនុ បានដឹងជាមិនខាន។ ជាមួយគ្នានោះគាត់ បានចូលរួមជាមួយ ប៉ុក ដឺសកុមារ សរសេរបទវិចារណកថា ពីរដ្ឋប្រហារ

នៅតណ្ឌនេស៊ីនោះ ចុះផ្សាយនៅលើទំព័រកាសែតឡាដេប៉ែស្ហ ផងដែរ។

នៅក្នុងឆ្នាំ១៩៦៥ គាត់មានទំនាក់ទំនងជាខ្សែរយៈជាមួយមេដឹកនាំសម្ងាត់របស់ពួកខ្មែរក្រហមម្នាក់នៅព្រៃទទឹង ឈ្មោះស្រេង (ឈ្មោះដើម ឈូក ឆាង ឬ ជ ឆាន) ជាអនុលេខាបក្សកុម្មុយនិស្ត នៅភូមិភាគឧត្តរ ។

ចាប់ពីពាក់កណ្តាលឆ្នាំ១៩៦៦មក គាត់មានសកម្មភាពមមាញឹកជាងគេ គឺការរៀបចំឈរឈ្មោះបោះឆ្នោតជ្រើសរើសតំណាង សាជាថ្មី។ ក្នុងពេលនោះ គាត់ និងមេដឹកនាំសម្ងាត់របស់ពួកខ្មែរក្រហម ឈ្មោះស្រេង បានជួបសហការគ្នាយ៉ាងជិតស្និទ្ធបំផុត។

កាលបោះឆ្នោតអាណត្តិមុនៗ សម្តេចស៊ីហនុ និងគណៈកម្មការសង្គមរាស្ត្រនិយមជាអ្នកជ្រើសរើសបេក្ខជន តែលើកនេះពួកលន់ នល់ បានស្នើសុំកុំឲ្យសម្តេចសីហនុ ជាអ្នកជ្រើសរើសបេក្ខជនដូចមុនៗទៀត គឺទុកឱ្យបេក្ខជនសង្គមរាស្ត្រនិយមឈរឈ្មោះដោយសេរី បើនរណាឈ្នះឆ្នោត អ្នកនោះបានធ្វើតំណាងរាស្ត្រ។

ពេលនោះ មេដឹកនាំសម្ងាត់របស់ពួកមេដឹកនាំខ្មែរក្រហម គឺ កុយ ធួន ហៅធុច (លេខាបក្សកុម្មុយនិស្តភូមិភាគឧត្តរ) និងឈ្មោះ ស្រេង (អនុលេខាបក្សកុម្មុយនិស្តភូមិភាគឧត្តរ) ក៏បានជួយជ្រោមជ្រែងឃោសនារកសំឡេងឆ្នោតឱ្យគាត់យ៉ាងផុលផុសដែរ។

ប្រពន្ធសាស្ត្រាចារ្យ ទីវ អុល (សោម ពេញ) ឈ្មោះឡេង ស៊ឹមហាក់ ហៅសី ខ្សែរយៈសម្ងាត់របស់ពួកមេដឹកនាំខ្មែរក្រហម នៅក្នុងក្រុងភ្នំពេញ បានទៅជួបគាត់នៅផ្ទះ(ក្រោយពេទ្យលោកសង្ឃ)ប្រាប់គាត់ថា ខ្លួនទទួលការណែនាំពីមូលដ្ឋានតស៊ូ ឲ្យគាត់រៀបចំបោះពុម្ពខិតប័ណ្ណពីប្រវត្តិរូបរបស់គាត់ យកទៅឃោសនារកការគាំទ្រ។

គាត់ក៏រៀបចំបោះពុម្ពខិត្តប័ណ្ណពីប្រវត្តិរូបរបស់គាត់ តាមការណែនាំរបស់ឈ្មោះ ឡេង ស៊ឹមហាក់ ហៅសី នោះ។

ម្តងនេះ ពេលគាត់ចុះទៅឃោសនារកសំឡេងឆ្នោតនៅមណ្ឌលជ្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម គាត់មិនស្នាក់នៅផ្ទះរបស់ឈ្មោះ កៅ នៅព្រៃទទឹង ដែលអាជ្ញាធរចាប់យកទៅដាក់គុកនោះទេ។ គាត់ស្នាក់នៅផ្ទះរបស់គ្រូបង្រៀនម្នាក់ឈ្មោះ ទុំ យ៉ន។

ពេលនោះ ឈ្មោះស្រេង (អនុលេខាភូមិភាគឧត្តរ ) បានចាត់នីរសារសម្ងាត់ពីរនាក់ឲ្យមកជួបទាក់ទងគាត់នៅភូមិមៀន ដោយប្រើពាក្យសម្ងាត់ថា កុក។ គាត់ក៏បានបញ្ជូនខិត្តប័ណ្ណឃោសនាបោះឆ្នោតរបស់គាត់ទៅតាមរយៈនីរសារសម្ងាត់ពីរនាក់នោះ យកទៅឱ្យឈ្មោះស្រេង ដើម្បីចាត់ចែងចែកជូនដល់ប្រជាជននៅតាមភូមិឃុំឆ្ងាយៗបន្តទៀត ហើយគាត់ក៏បានទុកខិត្តប័ណ្ណនោះមួយចំនួន សម្រាប់ចែកខ្លួនឯងផងដែរ។

គាត់ត្រូវឈរឈ្មោះប្រជែងនឹងបេក្ខជន៣នាក់ គឺ១.ឈ្មោះជុំ សារុន ជាតំណាងឲ្យលន់ នល់។ ២. សុះ សាអ៊ិន តំណាងឲ្យ អ៊ី ទុយ និង៣.ឈ្មោះវ៉ា គឹមគុន តំណាងឲ្យ គូ រុន។ ការឃោសនារកសំឡេងឆ្នោតនៅពេលនោះមានភាពតានតឹងខ្លាំងណាស់។ ពួក ជុំ សារុន និងសុះ សាអ៊ិន ទៅឃោសនាដល់កន្លែងខ្លះ ត្រូវពួកយុវជនចោលដុំថ្ម។

សភាពការណ៍កាន់តែតានតឹងឡើងៗ នៅពេលយប់មួយ មេដឹកនាំខ្មែរក្រហម ឈ្មោះស្រេង បានចាត់ខ្សែរយៈសម្ងាត់ម្នាក់ជាគ្រូបង្រៀននៅព្រៃទទឹង ឈ្មោះម៉ី សន ហៅផាំ ដែលធ្លាប់រៀននៅវិទ្យាល័យជាមួយគាត់ ឱ្យមកទទួលគាត់យកទៅពិភាក្សាការងារនៅផ្ទះសម្ងាត់មួយ នៅមុខវត្តតាមាក់។

គាត់ និងឈ្មោះស្រេង បានប្រជុំគ្នាពិនិត្យពីលទ្ធផលឃោសនា, ពីសភាពការណ៍ខាងអ្នកតស៊ូយើង និងសភាពការណ៍ខាងអ្នកកាន់អំណាច ហើយដាក់វិធានការវាយសម្រុកនៅថ្ងៃបោះឆ្នោត។ តែមុនថ្ងៃបោះឆ្នោតមួយថ្ងៃ គូ រុន បានបញ្ជូនគិញសម្ងាត់មកពេញស្រុកព្រៃឈរមានកាំភ្លើងខ្លីដើរសម្លុត កុំឲ្យប្រជាជនបោះឆ្នោតឲ្យគាត់។ លុះដល់ថ្ងៃបោះឆ្នោត លន់ នល់ក៏បានបញ្ជូនប្រពន្ធទាហានឱ្យមកជួយបោះឆ្នោតផងដែរ។ តែទីបំផុត បេក្ខជន ជុំ សារុន, បេក្ខជន សុះ សាអ៊ិន និងបេក្ខជន វ៉ា គឹមគុន ត្រូវចាញ់ទាំង៣ ហើយពួកនេះរកបំផ្លាញហឹបឆ្នោតទៀតផង។

ដល់ពេលប្រកាសលទ្ធផលបោះឆ្នោតជាផ្លូវការ នៅតាមមណ្ឌលបោះឆ្នោតទូទាំងប្រទេស ពួកលន់ នល់ ជាប់ឆ្នោតទាំងអស់ លើកលែងតែ ខៀវ សំផន ជាប់ឆ្នោតនៅមណ្ឌលស្អាង, ហ៊ូ យន់ ជាប់ឆ្នោតនៅមណ្ឌលកងមាស និងគាត់( ហ៊ូ នឹម )ជាប់ឆ្នោតនៅមណ្ឌលជ្រៃវៀន។

ថ្ងៃប្រជុំសភាដំបូង ពេលចប់ប្រជុំ ពួកគេលើក លន់ នល់ សែងស្រែកហ៊ោកញ្ជ្រៀវពេញរដ្ឋសភា។

លុះដល់ពេលអនុម័តតែងតាំងរាជរដ្ឋាភិបាលថ្មី លន់ នល់ បានឡើងជានាយករដ្ឋមន្ត្រី។ ពេល លន់ នល់ ឡើងដឹកនាំរាជរដ្ឋាភិបាល សម្ដេចសីហនុ ចាប់ផ្ដើមដឹងខ្លួនខ្លះៗដែរ តែវាកាន់តែជ្រុលពេលទៅហើយ។ ហេតុនេះ ដើម្បីទប់ទល់ជាមួយពួកស្ដាំនិយម សម្ដេចសីហនុ ក៏បានបង្កើតស្ថាប័នថ្មីមួយដែលហៅថា បរៈរាជរដ្ឋាភិបាល( រដ្ឋាភិបាលស្រមោល) ដោយយកគាត់ (ហ៊ូ នឹម), ខៀវ សំផន, ហ៊ូ យន់, ភោគ ឆាយ និងសូ ណៃម ជាពួកឆ្វេងនិយមធ្វើជាសមាជិកបរៈរាជរដ្ឋាភិបាលនោះ។ តែមិនយូរប៉ុន្មាន លន់ នល់ បានស្នើឲ្យសម្ដេចសីហនុ រំលាយស្ថាប័នបរៈរាជរដ្ឋាភិបាលនោះ ចោលវិញ។

ចាប់ពីពេលនោះមក កម្លាំងសមត្ថកិច្ចបានបង្កើនការតាមដានគាត់ជាប់ជានិច្ច តាំងពីពេលគាត់ធ្វើដំណើរទៅប្រជុំរដ្ឋសភា មកផ្ទះ និងពេលគាត់កំពុងរៀបចំតាំងពិព័រណ៍សម្ភារៈវប្បធម៌សិល្បៈរបស់សមាគមមិត្តភាពកម្ពុជា-ចិន ។

ហ៊ូ នឹម បានសរសេររម្លឹកថា ក្នុងឆ្នាំ១៩៦៧ មានចលនាបះបោរនៅសំឡូត។ ពេលនោះមានមហាជននាំគ្នាធ្វើបាតុកម្មប្រឆាំងរដ្ឋាភិបាលលន់ នល់ នៅមុខបរៈរាជរដ្ឋាភិបាល និងនៅមុខរដ្ឋសភាយ៉ាងខ្លាំងក្លាបំផុត។

សម្ដេចសីហនុ ត្រលប់មកពីបំពេញទស្សនកិច្ចនៅប្រទេសបារាំងវិញ ធ្វើសមាជនៅវាលមេរុ ចោទរូបគាត់(ហ៊ូ នឹម), ខៀវ សំផន និងហ៊ូ យន់ ថាជាអ្នកញុះញង់ឱ្យប្រជាជនងើបបំបះបំបោរនៅសំឡូតនោះ។

មិនតែប៉ុណ្ណោះ សម្ដេចសីហនុ បានហៅ ខៀវ សំផន ឲ្យទៅតទល់គ្នានៅស្រុកស្អាងជាមណ្ឌលដែលខៀវ សំផន ជាប់ឆ្នោតជាតំណាងរាស្ត្រនោះទៀតផង។

ពេលសភាពការណ៍កំពុងតានតឹងបែបនេះ ចំពេលគាត់កំពុងបើកពិធីតាំងពិព័រណ៍វប្បធម៌ និងសិល្បៈរបស់សាធារណរដ្ឋប្រជាមានិតចិន នៅអគារមួយស្ថិតនៅខាងជើងធនាគារជាតិកម្ពុជា ហើយមានមហាជននាំគ្នាចូលទស្សនាយ៉ាងច្រើនកុះករ។

ពេលនោះហើយ ដែលសម្តេចសីហនុ ហៅគាត់ឱ្យទៅតទល់គ្នានៅព្រៃទទឹង ដោយមានមហាជនចូលរួមច្រើនកកកុញពេញសាលាស្រុក។ គាត់ឈរជាមួយមហាជននៅខាងក្រោមវេទិកា មានមហាជនមួយចំនួនត្រៀមប្រយុទ្ធជាស្រេច។ តែពេលនោះ សម្តេចសីហនុ គ្រាន់តែមានបន្ទូលកំញើញគាត់ពីលើវេទិកា រួចក៏យាងត្រលប់មកភ្នំពេញ វិញ។ ឯការតាំងពិព័រណ៍ចេះតែបន្តទៅទៀត។

បន្ទាប់ពីនោះ គឺនៅពាក់កណ្តាលឆ្នាំ១៩៦៧ ក៏មានការត្រៀមធ្វើបុណ្យខួបកំណើតនៃការបង្កើតសមាគមមិត្តភាពកម្ពុជា-ចិន។ ក្នុងពេលនោះហើយ នៅវេលាយប់មួយ មេដឹកនាំរបស់ពួកខ្មែរក្រហម ឈ្មោះស្រេង បាននាំគាត់ទៅជួប កុយ ធួន ហៅធុច (លេខាបក្សកុម្មុយនិស្តភូមិភាគឧត្តរ) ជាសម្ងាត់ នៅក្នុងភូមិកាប់ទូក នៅខាងត្បូងព្រៃទទឹង។

ហ៊ូ នឹម បានសរសេរបញ្ជាក់ពីទំនាក់ទំនងរបស់គាត់ជាមួយ ភោគ ឆាយ ថា គាត់ស្គាល់ ភោគ ឆាយ កាលគាត់នៅជាមហាជនចំហ (កាលមិនទាន់មានទំនាក់ទំនងជាមួយពួកខ្មែរក្រហម)។

ពេលនោះ ភោគ ឆាយ នៅក្នុងសមាគមនិស្សិត, នៅក្នុងអង្គភាពកាសែត និងក្នុងសមាគមមិត្តភាពកម្ពុជា-ចិន ផងដែរ បានធ្វើសកម្មភាពប្រឆាំងនឹងពួកចក្រពត្តិនិយម និងពួកសេរីនិយមយ៉ាងសកម្មបំផុត។

កាលនោះ គាត់ក៏ពុំទាន់ស្គាល់បក្សកុម្មុយនិស្តកម្ពុជា(ខ្មែរក្រហម) ច្បាស់ដែរ គ្រាន់តែដឹងថា ជាគណបក្សប្រជាជនប៉ុណ្ណោះ ហើយគាត់មានខៀវ សំផន និងប្រពន្ធទីវ អុល ឈ្មោះឡេង ស៊ីមហាក់ ហៅសី ជាខ្សែរយៈទាក់ទង។ ចំណែក ភោគ ឆាយ គាត់មិនដឹងថា ជាខ្សែរយៈខាងណានោះទេ? នរណាជាអ្នកចាត់តាំងភោគ ឆាយ ឲ្យធ្វើអ្វីក្នុងចលនាតស៊ូខ្មែរក្រហម គាត់ក៏មិនដឹងដែរ។ កាលរៀននៅមហាវិទ្យាល័យ ពេលធ្វើនិក្ខេបបទ គាត់ត្រូវប្តូរយោបល់គ្នាជាមួយ ភោគ ឆាយ ។

# ២១៧
# ហ៊ូ នឹម បង្ខំចិត្តរត់ចូលព្រៃ ទៅតស៊ូជាមួយខ្មែរក្រហម

ដើមខែកញ្ញា ឆ្នាំ១៩៦៧ សម្តេចសីហនុ បានប្រកាសប្រាប់អ្នកកាសែតអន្តរជាតិថា ព្រះអង្គបានលុបចោលជាមោឃៈនូវគម្រោងដំណើរមកទស្សនកិច្ចនៅប្រទេសកម្ពុជា របស់នាយករដ្ឋមន្ត្រីប្រទេសជប៉ុន សាតូ ដោយសារតែរដ្ឋាភិបាលប្រទេសនេះមិនព្រមទទួលស្គាល់អធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ប្រទេសកម្ពុជា។

ប៉ុន្តែ ព្រះអង្គក៏មានបន្ទូលបញ្ជាក់ដែរថា ព្រះអង្គ នឹងទុកឱកាសរហូតដល់ខែមករា ឆ្នាំ១៩៦៨ ដើម្បីឱ្យមេដឹកនាំប្រទេសជប៉ុន ក៏ដូចជាប្រទេសអង់គ្លេស ប្រទេសអូស្ត្រាលី និងប្រទេសហ្វីលីពីន ដែលជាសម្ព័ន្ធមិត្តរបស់អាមេរិក ធ្វើការពិចារណាឡើងវិញ។

ប្រសិនបើពួកគេនៅតែមិនព្រមទទួលស្គាល់អធិបតេយ្យភាព និងបូរណភាពទឹកដីកម្ពុជាបច្ចុប្បន្នទៀតនោះ ព្រះអង្គនឹងកោះហៅប្រធានស្ថានបេសកកម្ម និងឯកអគ្គរាជទូតកម្ពុជា ប្រចាំនៅបណ្តាប្រទេសទាំងប៉ុន្មាននេះ ឱ្យវិលត្រលប់មកមាតុប្រទេសវិញ ហើយផ្តាច់ចំណងការទូតនឹងគ្នាតែម្តង ។

ក្រោយពីបដិវត្តន៍វប្បធម៌នៅប្រទេសចិន ធ្វើឱ្យមានការជ្រួលច្របល់ចលាចលវឹកវរអនាធិបតេយ្យអស់រយៈពេលជាច្រើនខែមក ជូ អេនឡាយ បានធ្វើការគ្រប់គ្រងស្ថានការណ៍របស់ប្រទេសចិន ឲ្យល្អប្រសើរឡើងវិញ នៅក្នុងសប្តាហ៍ទី១ ខែកញ្ញា ឆ្នាំ១៩៦៧ ។

នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៦៧ ជូ អេនឡាយ ក៏ បានជួបពិភាក្សាគ្នាជាមួយឯកអគ្គ-រាជទូតកម្ពុជា នៅទីក្រុងប៉េកាំង ដោយគាត់បានសម្តែងការកោតសរសើរចំពោះសម្តេចសីហនុ ហើយថាប្រទេសកម្ពុជា ជាទីតាំងដ៏សំខាន់មួយនៅតណ្ឌចិន ក៏ដូចជានៅអាស៊ីអាគ្នេយ៍ទាំងមូល ផងដែរ ។

ចំណែកសម្តេចសីហនុ វិញបានថ្លែងថា ព្រះអង្គមិនចង់ឱ្យប្រទេសកម្ពុជា ក្លាយទៅជាទីតាំងសំខាន់អ្វីចំពោះប្រទេសចិន ដែលជាមហាអំណាចកុម្មុយនិស្តនោះទេ គឺព្រះអង្គចង់បាន

## របត់នយោបាយ

ការគាំទ្រពីជូ អេនឡាយ គឺគ្រាន់តែដើម្បីធ្វើឱ្យប្រទេសកម្ពុជា មានស្ថេរភាពនយោបាយ ប៉ុណ្ណោះ។

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៦៧ សម្ដេចសីហនុ បានប្រាប់កាសែតអេភី (AP) របស់អាមេរិក ថា បើប្រជាជនចិន នាំគ្នាធ្វើបាតុកម្មប្រឆាំងនឹងស្ថានទូតព្រះអង្គនៅទីក្រុងប៉េកាំង ព្រះអង្គនឹងឱ្យមន្ត្រីទូតរបស់ព្រះអង្គនៅក្រុងប៉េកាំង ត្រលប់មកមាតុប្រទេសវិញ។ តែព្រះអង្គមិនផ្ដាច់ចំណងការទូតជាមួយចិនប្រជាមានិត នោះឡើយ យើងនៅតែជាមិត្តនឹងគ្នាប្រសិន បើមេដឹកនាំចិន មិនមានបំណងលូកដៃចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសកម្ពុជា ទេ។

ក្រោយពីសម្ដេចសីហនុ ប្រកាសបិទសមាគមមិត្តភាពកម្ពុជា-ចិន បានរយៈពេលប៉ុន្មានថ្ងៃ នៅមណ្ឌលបោះឆ្នោតជ្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ដែលហ៊ូ នឹម បានជាប់ឆ្នោតជាតំណាងរាស្ត្រនោះ គេឃើញមានស្នាមមេដៃប្រជារាស្ត្រប្រមាណ៧០០នាក់ នៅក្នុងលិខិតតវ៉ាទាមទារឱ្យសម្ដេចសីហនុ បើកសមាគមមិត្តភាពកម្ពុជា-ចិន ឡើងវិញ។

ការពិត កុយ ធួន ហៅឃួន ដែលជាមេដឹកនាំចលនាតស៊ូសម្ងាត់របស់ពួកខ្មែរក្រហមនៅភូមិភាគឧត្តរ បានប្រើល្បិចបោកបញ្ឆោតឱ្យប្រជារាស្ត្រឱ្យនាំគ្នាផ្ដិតមេដៃលើលិខិតនោះដើម្បីស្នើសុំឱ្យសម្ដេចសីហនុ ជួយកសាងទំនប់ទឹកមួយនៅក្នុងខេត្តកំពង់ចាម។

ប៉ុន្តែ ក្រោយពីបានស្នាមមេដៃប្រជាកសិករប្រមាណ៧០០នាក់រួចមក កុយ ធួន ហៅឃួន ក៏បានយកស្នាមមេដៃនោះ មកដាក់ភ្ជាប់ជាមួយលិខិតតវ៉ាទាមទារឱ្យសម្ដេចសីហនុ បើកសមាគមមិត្តភាពកម្ពុជា-ចិន នោះឡើងវិញ ហើយឱ្យតំណាងប្រជាកសិករយកលិខិតនោះមកប្រគល់ឱ្យ ហ៊ូ នឹម នៅទីក្រុងភ្នំពេញ ដើម្បីបញ្ជូនឱ្យប្រធានរដ្ឋសភាបន្តទៀត។សម្ដេចសីហនុ ក្រោធ ពិរោធយ៉ាងខ្លាំងជាមួយហ៊ូ នឹម ពីបញ្ហាក្លែងបន្លំលិខិតនេះ។

មិនយូរប៉ុន្មាន ប្រជារាស្ត្រនៅមណ្ឌលបោះឆ្នោតជ្រៃវៀន ក៏បានដឹងរឿងនេះដែរ ហើយពួកគក៏មានការខឹងសម្បានឹងហ៊ូ នឹម មិនស្ទើរដែរ ។ ពួកគេនាំគ្នាសួរ ហ៊ូ នឹម ថា ហេតុអ្វី បានជាធ្វើដូច្នេះ ? ហ៊ូ នឹម ឆ្លើយថា គាត់មិនមែនជាអ្នកធ្វើលិខិតនោះទេ គឺគាត់បានទទួលលិខិតនេះ ពីប្រជាជន ដែលយកមកប្រគល់ឱ្យគាត់នៅទីក្រុងភ្នំពេញ ហើយគាត់ក៏បញ្ជូនឱ្យប្រធាន

រដ្ឋសភាតែម្តងទៅ។

នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦៧ បានឱ្យគេរៀបចំអង្គប្រជុំពិសេសមួយនៅក្នុងបរិវេណសាលាស្រុកព្រៃឈរ ខេត្តកំពង់ចាម។ នៅលើវេទិកាក្រៅពីសម្តេចសីហនុ គេឃើញមានមន្ត្រីជាន់ខ្ពស់ជាច្រើននាក់ ទៅពីទីក្រុងភ្នំពេញ ពិសេសមានគូ រុន មេប៉ូលិសធំ ព្រមទាំងចៅហ្វាយខេត្ត ចៅហ្វាយស្រុក ផងដែរ ។

ហ៊ូ នឹម ជាតំណាងរាស្ត្រប្រចាំមណ្ឌលជ្រៃវៀន ក៏បានធ្វើដំណើរពីក្រុងភ្នំពេញ ទៅចូលរួមក្នុងអង្គប្រជុំពិសេសនោះដែរ តែគាត់មិនបានឡើងទៅអង្គុយលើវេទិកាទេ គឺគាត់ឈរជាមួយប្រជារាស្ត្រ ដែលនៅខាងក្រោម ។

ក្រោយពីសម្តេចសីហនុ ទតឃើញ ហ៊ូ នឹម កំពុងឈរក្នុងហ្វូងប្រជារាស្ត្រនៅខាងមុខវេទិកា ព្រះអង្គក៏មានបន្ទូលថា៖ ភោគ ឆាយ ជាមនុស្សសាហាវជាងគេក្នុងចំណោមជនមួយក្តាប់តូច ដែលធ្វើការបម្រើចិនកុម្មុយនិស្ត។ តែមនុស្ស ដែលអាក្រក់ជាងគេ ហើយមិនស្មោះត្រង់នោះ គឺ ហ៊ូ នឹម... ។ សហជីវិនហ៊ូ នឹម ជាមនុស្សលាក់ពុត ផ្អែមល្ហែមតែខាងក្រៅ ឯខាងក្នុងមានពិសពុលខ្លាំងណាស់ សម្តី ដែលគាត់និយាយចេញមកគួរឱ្យចង់ស្តាប់ ដូចព្រះសង្ឃសូត្រធម៌អ៊ីចឹង ពាក្យសម្តីគាត់ផ្អែមដូចទឹកឃ្មុំ តែគាត់ជាខ្លាលាក់ក្រចក...។

សម្តេចសីហនុ មានបន្ទូលខ្លាំងៗទៀតថា ប្រសិនបើអ្នកឯងជាមនុស្សស្មោះត្រង់ ជាជនកុម្មុយនិស្តពិតប្រាកដមែននោះ អ្នកឯងត្រូវតែក្លាហានចំពោះទង្វើរបស់ខ្លួន។ បើអ្នកឯងហ៊ានលូកភ្លើង ដោយសារតែមនោគមវិជ្ជានយោបាយមែននោះ មិនគួរខ្លាចនឹងតស៊ូនៅទីភ្លឺទេ ហើយដើម្បីមនោគមវិជ្ជានយោបាយនោះ អ្នកឯងគួរតែហ៊ានទទួលខុសត្រូវក្នុងរឿងនេះ និងហ៊ានប្រឈមមុខទល់នឹងផលវិបាកទាំងឡាយតែម្នាក់ឯងបានហើយ។ អ្នកឯងក្លាហានបានតែពីក្រោយខ្នងប៉ុណ្ណោះ ។

សម្តេចសីហនុ មានបន្ទូលបន្ថែមទៀតថា ហ៊ូ នឹម និងមិត្តភក្តិគាត់បានដកខ្លួនចេញពីចលនាសង្គមរាស្ត្រនិយមហើយ ដូច្នេះពួកគេគួរតែនាំគ្នាទៅរស់នៅឯប្រទេសចិនកុម្មុយនិស្តទើបជាការប្រសើរ។

ទោះបីសម្តេចសីហនុ ហាក់ដូចជាប្រើអំណាចចាប់បង្ខំហ៊ូ នឹម ឲ្យចេញមុខមកទទួលខុសត្រូវចំពោះស្នាមមេដៃប្រជារាស្ត្រប្រមាណ ៧០០នាក់ ដែលស្នើសុំឱ្យសាងសង់ទំនប់ទឹកមួយ មកក្លែងបន្លំជាលិខិតទាមទារឱ្យបើកសមាគមមិត្តភាពកម្ពុជា-ចិន នោះឡើងវិញ ក៏ពិតមែន ក៏ព្រះអង្គមិនទាន់ឱ្យគេធ្វើបាប ឬចាប់ខ្លួនហ៊ូ នឹម ដែរ។

ក្រោយពីសម្តេចសីហនុ បើកអង្គប្រជុំនៅក្នុងបរិវេណសាលាស្រុកព្រៃឈរ មានបន្ទូលវាយប្រហារខ្លាំងៗទៅលើ ហ៊ូ នឹម នោះមក ក៏មានខិត្តប័ណ្ណជាច្រើន ដែលមានដាក់អក្សរថាស្មើក្រហម ត្រូវបានគេបាចពាសពេញភូមិស្រុក។

ខិត្តប័ណ្ណនោះបានសរសេរថា គូ រុន(មេប៉ូលិស)គឺជាកូនជីងរបស់សីហនុ ធ្វើបាបសង្កត់សង្កិនជិះជាន់បានតែប្រជាជនតូចតាចប៉ុណ្ណោះ តែមិនហ៊ានធ្វើអ្វី ចំពោះពួកនាយទុន និងពួកគហបតីទេ។ ដូច្នេះប្រជាជនខ្មែរ ត្រូវតែនាំគ្នាក្រោកឡើងតស៊ូផ្តួលរម្លំរបបពុករលួយផ្តាច់ការ ប្រឆាំងនឹងប្រជាជនខ្លួនឯងនេះ...។

នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៦៧ សម្តេចសីហនុ បានប្រកាសថា ហ៊ូ នឹម និងអ្នកចូលដៃជើងជាមួយគាត់ទាំងអស់សុទ្ធតែជាជនក្បត់ ហើយពួកនេះត្រូវតែយកទៅឱ្យតុលាការសឹកកាត់ទោស និងសម្លាប់ចោល។ ប្រសិនបើ ហ៊ូ នឹម មិនទៅនៅស្រុកចិនទេ គឺគាត់នៅតែបំពានមកលើព្រះអង្គបន្តទៀត។

សម្តេចសីហនុ បានថ្លែងថា ប្រសិនបើមេដឹកនាំចិន ចង់បង្កឱ្យមានចលាចលវឹកវរនៅកម្ពុជា ដូចដែលកាសែតហុងកុង បានចុះផ្សាយមែននោះ ព្រះអង្គសូមឱ្យមេដឹកនាំចិនធ្វើការពិចារណាឱ្យបានច្បាស់លាស់ជាមុនសិន។

ឧបមាថា បើព្រះអង្គពុំមានអាវុធយុទ្ធភណ្ឌគ្រប់គ្រាន់ ដើម្បីទប់ទល់ជាមួយពួកឧទ្ទាមខ្មែរក្រហមទេ ព្រះអង្គនឹងប្រគល់ភារកិច្ចនេះទៅឱ្យមេទ័ពរបស់ព្រះអង្គ(លន់ នល់) ហើយមេទ័ពនេះប្រាកដជាងាកទៅរកអាមេរិក ជាមិនខាន។

ដោយមិនហ៊ានប្រឈមមុខជាមួយសម្តេចសីហនុ តទៅទៀត និងដោយមានការណែនាំពីប៉ុក ដឹសកុមារ ជាបណ្តាញតស៊ូសម្ងាត់របស់មេដឹកនាំខ្មែរក្រហមផងដែរ នៅថ្ងៃទី០៧

ខែតុលា ឆ្នាំ១៩៦៧ ខណៈកំពុងមានភ្លៀងធ្លាក់ខ្លាំង កម្លាំងបង្កប់របស់ពួកខ្មែរក្រហមម្នាក់ឈ្មោះសមមិត្តគុន ដែលនៅក្រោមការដឹកនាំចាត់ចែងរបស់ វន វ៉េត ក៏បាននាំ ហ៊ូ នឹម ចេញពីផ្ទះបងថ្លៃរបស់គាត់នៅជិតពេទ្យលោកសង្ឃ ដោយយកអាវភ្លៀងមកគ្របពីលើក្បាលគាត់ដើម្បីកុំឱ្យពួកប៉ូលិសសម្ងាត់ស្លៀកពាក់ស៊ីវិលកំពុងតាមដានសកម្មភាពរបស់គាត់នោះ មើលស្គាល់ផងដែរ ។

ក្រោយពេល ហ៊ូ នឹម រត់ចូលព្រៃបានបីថ្ងៃ ប្រពន្ធហ៊ូ នឹម ឈ្មោះ រ៉ា ឡាន ដែលមានផ្ទៃពោះ៨ខែហើយនោះ បានអះអាងថា កម្លាំងសមត្ថកិច្ចឡើងឆែកឆេរផ្ទះគាត់រុករកឯកសារ និងបាននាំគ្នាទៅព័ទ្ធចាប់បងប្រុសគាត់ ដែលនៅផ្ទះជិតគ្នានោះ វាយទាត់ដាក់រហូតបាក់ឆ្អឹងជំនីរ និងបាក់ធ្មេញ ដើម្បីសួរចម្លើយ។ តែបងប្រុសគាត់នោះ មិនព្រមឆ្លើយអ្វីទាំងអស់។

ពេលនោះដែរ ស្រាប់តែឃើញភ្លើងឆាបឆេះផ្ទះបងប្រុសគាត់ កម្លាំងសមត្ថកិច្ចស្រែកថា៖ បងប្រុសគាត់ដុតផ្ទះដើម្បីសម្លាប់ខ្លួនឯង តែមិនស្លាប់ គ្រាន់តែរងរបួសធ្ងន់។ រួចកម្លាំងសមត្ថកិច្ចក៏បានបញ្ជូនទៅមន្ទីរពេទ្យ។

បីថ្ងៃក្រោយមក សមត្ថកិច្ចប្រាប់ថា៖ បងប្រុសគាត់ស្លាប់ហើយ ឱ្យប្រពន្ធទៅយកសពមកធ្វើបុណ្យបូជា។

ប្រពន្ធហ៊ូ នឹម ឈ្មោះ រ៉ា ឡាន បានអះអាងថា គឺកម្លាំងសមត្ថកិច្ចជាអ្នកយកប្រេងសាំងទៅចាក់ដុតផ្ទះ ដើម្បីសម្លាប់បងប្រុសរបស់គាត់។ តែពួកគេបែរជាស្រែកថា៖ បងរបស់គាត់ជាអ្នកដុតភ្លើង ដើម្បីសម្លាប់ខ្លួនឯងទៅវិញ។

ក្រោយពីសម្រាលកូនបានជាង១ឆ្នាំកន្លះ កម្លាំងបង្កប់របស់ពួកខ្មែរក្រហម ក៏បាននាំប្រពន្ធហ៊ូ នឹម យកទៅឱ្យរស់នៅក្នុងព្រៃជាមួយគាត់ដែរ។

តែមានសាក្សីម្នាក់ (សព្វថ្ងៃធ្វើការនៅបណ្ណាល័យជាតិ) បានឱ្យដឹងថា កាលសម័យនោះ គ្រួសារគាត់មានផ្ទះនៅក្រោយមន្ទីរពេទ្យព្រះសង្ឃ ជាប់គ្នានឹងផ្ទះហ៊ូ នឹម។ នៅពេលកម្លាំងសមត្ថកិច្ចប៉ូលិស ទៅរកចាប់បងប្រុសបង្កើតរបស់ប្រពន្ធ ហ៊ូ នឹម ដែលកំពុងពួនសំងំនៅក្នុងផ្ទះ បងប្រុសនោះក៏ បានយកភួយមកគ្របដណ្ដប់ខ្លួន ហើយយកប្រេងសាំងមក

ស្រោចពីលើ រួចស្រែកគំរាមថា បើកម្លាំងសមត្ថកិច្ចប៉ូលិស ចូលមកចាប់គាត់ គាត់នឹងកេះដែកកេះ ឱ្យភ្លើងឆាបឆេះដើម្បីសម្លាប់ខ្លួន។

ពេលនោះ កម្លាំងសមត្ថកិច្ចប៉ូលិស បានស្រែកលួងលោមទៅវិញថា កុំធ្វើផ្ដេសផ្ដាសឱ្យសោះ ព្រោះគ្មាននរណាមកចាប់យកទៅធ្វើអ្វីទេ គឺគេគ្រាន់តែនាំយកទៅសាកសួរប៉ុណ្ណោះ។ តែបងប្រុសនោះ មិនព្រមបើកទ្វារឱ្យកម្លាំងសមត្ថកិច្ចប៉ូលិសចូលចាប់គាត់ដោយងាយៗឡើយ។

ទីបំផុត កម្លាំងសមត្ថកិច្ចប៉ូលិសត្រូវបង្ខំចិត្តនាំគ្នាទម្លាយទ្វារ ស្រាប់តែបងប្រុសនោះកេះដែកកេះ បណ្ដាលឱ្យភ្លើងឆាបឆេះភួយ ដែលគ្របដណ្ដប់ខ្លួននោះ យ៉ាងសន្ធោសន្ធៅ កម្លាំងសមត្ថកិច្ចប៉ូលិសក៏នាំគ្នាជួយពន្លត់ដែរ តែយ៉ាងណា បងប្រុសនោះរងរបួសធ្ងន់ ត្រូវបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យកាល់ម៉ែត។ ប៉ុន្មានថ្ងៃក្រោយមក គាត់ក៏បាត់បង់ជីវិតទៅ។

ក្រោយពេល ហ៊ូ នឹម រត់ទៅតស៊ូនៅក្នុងព្រៃនោះ អ៊ុច វ៉េន អគ្គនាយករងធនាគារឥណទានជាតិ និងប៉ុក ដឺសកុមារ ក៏រត់ចូលព្រៃដែរ។ នៅក្នុងឆ្នាំ១៩៦៩ អ៊ុច វ៉េន ក៏ត្រូវបាត់បង់ជីវិតនៅព្រៃនៃខេត្តកំពង់ចាម ដោយសារមានជំងឺគ្រុនចាញ់ ។

ចំណែកបញ្ញវន្តមួយចំនួនទៀត ដែលសម្ដេចសីហនុ ចាត់ទុកថា ជាខ្មែរស៊ីជម្ពូ មិនក្រហមឆ្អិនឆ្អៅពេក គឺ ភឹង គុន សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, កេង វ៉ាន់សាក់ ជាចាងហ្វាងវិទ្យាស្ថានគរុកោសល្យ និងជាអតីតមេដឹកនាំគណបក្សប្រជាធិបតេយ្យ, ចៅ សៅ អគ្គនាយកធនាគារឥណទានជាតិ និងជាអតីតរដ្ឋលេខាធិការក្រសួងផែនការ ព្រមទាំង សូ ណែម អតីតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក៏ត្រូវចាប់ខ្លួនយកឃុំទុកនៅគិរីរម្យ អស់រយៈពេល ៦ខែ ទើបដោះលែងឱ្យមានសេរីភាពវិញ។

# ២១៨
# ខ្មែរក្រហម និងខ្មែរខៀវ ប៉ុនប៉ងផ្តួលរំលំសម្តេចសីហនុ



**សម្តេចសីហនុ និងយុវជនរាជសង្គមនិយមខ្មែរ(យុវ័ន)**

ចាប់ពីឆ្នាំ១៩៦៧ មក សម្តេចសីហនុ មិនអនុញ្ញាតឱ្យអ្នកកាសែតបរទេសណា ដែលព្រះអង្គយល់ថា បានសរសេរអត្ថបទមួលបង្កាច់ និងនិយាយអាក្រក់ពីរបបគ្រប់គ្រងរបស់ព្រះអង្គ ចូលមកយកព័ត៌មាននៅក្នុងប្រទេសឡើយ គឺមានតែអ្នកកាសែតបរទេសណា ដែលបានសរសេរអត្ថបទមិនប៉ះពាល់ដល់ព្រះអង្គប៉ុណ្ណោះ ទើបអនុញ្ញាតឱ្យចូលយកព័ត៌មានក្នុងប្រទេសរបស់ព្រះអង្គ។

ប៉ុន្តែ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ព្រះអង្គសព្វព្រះទ័យក្នុងការសរសេរលិខិតនានាជាច្រើនទំព័រ ដើម្បីធ្វើការបកស្រាយបំភ្លឺ ដល់កាសែតនៅបរទេសទាំងអស់ ដែលបានចុះផ្សាយអត្ថបទអវិជ្ជមានទាំងឡាយណា ដែលមិនសមស្របតាមការពិតជាក់ស្តែងរបស់ព្រះអង្គផ្ទាល់ និងប្រទេសរបស់ព្រះអង្គ ផងដែរ។

## របត់នយោបាយ

កន្លងមក ព្រះអង្គធ្លាប់ជំរុញឱ្យប្រជារាស្ត្ររបស់ព្រះអង្គ ធ្វើបាតុកម្មប្រឆាំងនឹងទស្សនាវដ្ដី ថែម (Time) ដែលបានចុះផ្សាយព័ត៌មានបំពានមកលើព្រះអង្គ។ ប៉ុន្តែ អ្នកកាសែតដែលព្រះអង្គតែងតែអនុញ្ញាតឱ្យចូលជួបធ្វើសម្ភាសផ្ទាល់មុខផ្ទាល់ ជាញឹកញាប់នោះ គឺកាសែតបារាំង អាអេហ្វប៉េ(AFP) និងកាសែតរ៉យទ័រ(Reuters)។

កាលនោះ ក្រៅពីកាសែតបារាំង ទាំង២នេះ កាសែតបរទេសមួយចំនួនទៀត ក៏មានអ្នកឆ្លើយឆ្លងព័ត៌មានរបស់ខ្លួននៅទីក្រុងភ្នំពេញ ដែរ ដូចជា កាសែតរបស់ចិន ឈ្មោះស៊ីនហួ (Xinhua), កាសែតអាមេរិក យូភីអាយ(UPI= United Press Internation), កាសែតអេភី (AP= Associated Press), បណ្ដាញព័ត៌មានតេឡេក្រាហ្វិក របស់វៀណាមខាងជើង, ទីភ្នាក់ងារព័ត៌មានហែហ្វុង របស់ពួករៀតកុង, កាសែត តាន់យុក របស់ពួកយូហ្គោស្លាវី, កាសែតអាសាហ៊ី និងទូរទស្សន៍ NHK របស់ជប៉ុន ផងដែរ។

ចំណែក រាជរដ្ឋាភិបាលកម្ពុជា ក៏មានសារព័ត៌មាន ឈ្មោះទីភ្នាក់ងារសារព័ត៌មានខ្មែរ (AKP= Agence Khmer de Press)មួយដែរ។ ប៉ុន្តែ រាល់អត្ថបទទាំងឡាយ ដែលត្រូវចុះផ្សាយលើទំព័រទីភ្នាក់ងារសារព័ត៌មានខ្មែរ(AKP)នេះ ត្រូវដាក់ថ្វាយសម្ដេចសីហនុ ដើម្បីត្រួតពិនិត្យជាមុនសិន។ សុន្ទរកថាទាំងឡាយរបស់សម្ដេចសីហនុ ត្រូវបានគេយកទៅចុះផ្សាយទាំងស្រុងនៅក្នុងសារព័ត៌មាននេះ ហើយយកទៅចាក់ផ្សាយទាំងស្រុង តាមវិទ្យុជាតិផងដែរ។

សម្ដេចសីហនុ បានរៀបចំឱ្យមានការតាំងពិព័រណ៍ជាអចិន្ត្រៃយ៍បង្ហាញពីសមិទ្ធផលទាំងឡាយ របស់ចលនាសង្គមរាស្ត្រនិយមរបស់ព្រះអង្គ ដើម្បីឱ្យកាសែតបរទេសទាំងឡាយ ដែលមានសមានចិត្តជាមួយព្រះអង្គ យកទៅផ្សព្វផ្សាយ ដើម្បីឱ្យពិភពលោកបានដឹងពីការរីកចម្រើនរបស់កម្ពុជា។

នៅក្នុងឆ្នាំ១៩៦៥ ព្រះអង្គបានបង្កើតទស្សនាវដ្ដីប្រចាំខែចំនួន២ គឺទស្សនាវដ្ដី កាំប៉ុយហ្សា (Kambuja) និងទស្សនាវដ្ដី ឡឺ សង្គម(Le Sangkum)។

ទស្សនាវដ្ដីកាំប៉ុយហ្សា(Kambuja) ផ្សព្វផ្សាយពីព័ត៌មានបច្ចុប្បន្នភាព ស្ដីពីសកម្មភាពរបស់ព្រះអង្គ យាងទៅសម្ពោធសមិទ្ធផលផ្សេងៗ អមដោយរូបភាពពណ៌ធម្មជាតិ និងដកស្រង់

អត្ថបទទាំងឡាយ ដែលកាសែតបរទេសចុះផ្សាយសរសើរពីព្រះអង្គ ឬធ្វើអត្ថាធិប្បាយ ពីប្រទេសកម្ពុជា មកចុះផ្សាយបន្ត។

ចំណែកទស្សនាវដ្ដី ឡឺ សង្គម ផ្សព្វផ្សាយពីគោលនយោបាយរបស់ព្រះអង្គ តាមរយៈអត្ថបទស្រាវជ្រាវ, បទវិចារណកថា ជាស្នាព្រះហស្ដរបស់ព្រះអង្គ, ការងារសម្ងាត់ខ្លះៗរបស់ប្រទេសជាតិ, ការជួបសន្ទនារបស់គណៈរដ្ឋមន្ត្រីជាមួយឥស្សរជនបរទេសនានាជាដើម។

នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៦៧ សម្ដេច សីហនុ បានចេញព្រះរាជក្រឹត្យ ឱ្យបិទសារព័ត៌មានក្នុងស្រុកទាំងអស់ លែងឱ្យចេញផ្សាយបន្តទៀត ហើយព្រះអង្គបង្កើតកាសែតចំនួន៤ បោះពុម្ពជាភាសាខ្មែរ បារាំង ចិន និងវៀតណាម ជំនួសវិញ និងដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ(Censure) របស់ក្រសួងព័ត៌មាន ។

ជាមួយគ្នានោះ សៀវភៅទាក់ទងរឿងនយោបាយរបស់បរទេសទាំងអស់ ក៏ព្រះអង្គមិនអនុញ្ញាតឱ្យនាំចូលមកក្នុងប្រទេសដែរ ទោះបីទស្សនាវដ្ដី និយាយពីវិទ្យាសាស្ត្រ មកពីប្រទេសចិន ឬមកពីប្រទេសកុម្មុយនិស្តផ្សេងទៀត ក៏ព្រះអង្គមិនឱ្យនាំចូលដែរ ហើយអ្នកឆ្លើយឆ្លងព័ត៌មាន ដែលឧស្សាហ៍សរសេរទិតៀនព្រះអង្គ ដូចជាអ្នកឆ្លើយឆ្លងព័ត៌មានកាសែតឡឺ ម៉ុង (Le monde)ជាដើម ក៏មានឈ្មោះនៅក្នុងបញ្ជីតាមដានរបស់ពួកប៉ូលិសដែរ ទោះបីជាជនបរទេស ក៏ដោយ។

នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៦៧ សម្ដេចសីហនុ ថ្លែងសង្កថាទៅកាន់សភាទាំងពីរ (រដ្ឋសភា និងក្រុមប្រឹក្សានៃព្រះរាជាណាចក្រ)ពាក់ព័ន្ធពីបញ្ហាខ្មែរក្រហម និងខ្មែរខៀវ មានបំណងផ្ដល់រំលំនយោបាយអព្យាក្រឹតរបស់ព្រះអង្គ ថា៖ ដូចសហជីវិន សហជីវិនីជ្រាបស្រាប់ហើយ បញ្ហាដែលគួរឱ្យព្រួយបារម្ភជាងគេ គឺបញ្ហាសំឡូត។ តែឥឡូវនេះបញ្ហាសំឡូត ត្រូវបានដោះស្រាយហើយ ដោយសារការខ្នះខ្នែងរបស់ខ្ញុំ និងរបស់សហជីវិន សហជីវិនីជាអ្នកជាតិនិយមពិតប្រាកដ បានជួយខ្ញុំក្នុងការធ្វើឱ្យពួកអ្នកស្រុក ដែលទទួលបាបគ្រោះដោយពាក្យឃោសនារបស់ខ្មែរក្រហម ភ្ញាក់ស្មារតីថា ពីមុន ពួកគាត់ពិតជាចាញ់បោកគេ ប្រាកដមែន ។

## របត់នយោបាយ

បងប្អូនកូនចៅជនរួមជាតិយើងក្នុងតំបន់នោះទាំងប៉ុន្មាន បានធ្វើសច្ចាថា អំណឹះតទៅ ពួកគាត់នឹងតាំងខ្លួនជាពលរដ្ឋដែលស្មោះត្រង់បំផុតចំពោះខ្ញុំ ចំពោះព្រះរាជបល្ល័ង្ក និងចលនាសង្គមរាស្ត្រនិយម ព្រមទាំងតាំងចិត្តថា មុននឹងជឿតាមនរណា ពួកគាត់នឹងពិចារណាឱ្យបានច្បាស់លាស់ជាមុនសិន។

បងប្អូនកូនចៅយ៉ាងសន្ធឹកសន្ធាប់ បាននាំគ្នាមកសម្តែងនូវទឹកចិត្តស្វាមីភ័ក្តិស្មោះត្រង់ចំពោះខ្ញុំ នៅទីក្រុងភ្នំពេញ ជាបន្តបន្ទាប់ ហើយខ្ញុំព្រះករុណាប្រាប់ពួកគាត់វិញថា សូមកុំនាំគ្នាអញ្ជើញមកទៀត ពីព្រោះការធ្វើដំណើរពីស្រុកភូមិ មករាជធានីភ្នំពេញ នាំឱ្យខាតពេលវេលា និងចុះសោហ៊ុយច្រើនណាស់។

ក្នុងអំឡុងប៉ុន្មានខែចុងក្រោយនេះ នៅគ្រប់ទិសទីតាមខេត្តនានាទាំងអស់ ប្រជារាស្ត្រយើងដ៏ច្រើនលើសលុប បានសម្តែងឲ្យឃើញនូវឧត្តមគតិជួយស្ថាបនាប្រទេសជាតិយ៉ាងត្រេកត្រអាលបំផុត។ បើដូច្នេះ ចុះហេតុដូចម្តេច បានជាពួកខ្មែរជាសត្វក្រពើវង្វេងបឹងមួយក្រុមតូច បែរជាចង់ជាន់ពន្លិចនូវលទ្ធិជាតិនិយម និងចង់បំផ្លាញឯកភាពជាតិទៅវិញ?

ពួកខ្មែរក្រហម ចេះតែបន្តនូវសកម្មភាពធ្វើវិទ្ធង្សនារបស់ខ្លួនឥតឈប់ឈរ ជាអាទិ៍ នៅក្នុងចំណោមយុវជនយើង។ លទ្ធិកុម្មុយនិស្ត ដែលពួកគេនាំចូលមកពីក្រៅនោះ គ្មាននាំអ្វីឲ្យមានការរីកចម្រើនលូតលាស់ ក្រៅតែពីការលោយអត្តសញ្ញាណជាតិខ្លួនឯង និងការបាត់បង់ឯករាជ្យជាតិតែប៉ុណ្ណោះ។

ដូច្នេះ ខ្ញុំជាអ្នកទទួលខុសត្រូវចំពោះកិច្ចទ្រទ្រង់ឯករាជ្យ និងសន្តិភាពនៅក្នុងផ្ទៃនៃកម្ពុជរដ្ឋ និងចំពោះសុភមង្គលដល់ជនរួមជាតិយើងទាំង៦លានកន្លះ ខ្ញុំមិនអាចបណ្តោយឲ្យពួកនេះរំលោភបំពានលើមាគ៌ានយោបាយ ដែលផ្ទុយនឹងឧត្តមប្រយោជន៍ជាតិ និងឧត្តមគតិរបស់ប្រជារាស្ត្រជាអ្នកជាតិនិយម តាមអំពើចិត្តបាននោះឡើយ។

សម្តេចសីហនុ ថ្លែងបន្តថា ខ្ញុំបានបញ្ជាក់ជាច្រើនលើកច្រើនគ្រាមកហើយថា ខ្ញុំមិនប្រឆាំងនឹងលទ្ធិកុម្មុយនិស្ត មុនពេលទទួលការពិសោធនោះទេ។ លទ្ធិអ្វីក៏ដោយឱ្យតែចេញពីឆន្ទៈរបស់ប្រជារាស្ត្រពិតៗ ខ្ញុំព្រមទទួលយកបានទាំងអស់។

នៅហាណូយ គេកាន់លទ្ធិកុម្មុយនិស្តវៀតណាម, នៅប៉េកាំង គេកាន់លទ្ធិកុម្មុយនិស្តចិន, នៅព្យុងយ៉ាង គេកាន់លទ្ធិកុម្មុយនិស្តកូរ៉េ, នៅឡាហាវ៉ាន គេកាន់លទ្ធិកុម្មុយនិស្តគុយបា។ ចំណែកនៅភ្នំពេញ ពួកខ្មែរក្រហមបង្ខំឱ្យកាន់លទ្ធិកុម្មុយនិស្តមួយដែលមិនមែនជាលទ្ធិកុម្មុយនិស្តខ្មែរ ដើម្បីដឹកនាំប្រទេសកម្ពុជានោះ វាប្រាកដជានឹងទទួលនូវការប្រមាថមើលងាយ ឬការចំអកឡកឡឺយពីសំណាក់សកលលោកទាំងមូលជាមិនខាន។

ពួកខ្មែរក្រហមគ្មានសមត្ថភាពអ្វី ក្រៅពីទ្រឹស្តី ដែលពួកគេបានទន្ទេញចាំមាត់ពីគ្រូរបស់ពួកគេ ដោយមិនរវល់ដល់ផលប្រយោជន៍របស់ប្រទេសជាតិ និងសុភមង្គលរបស់ប្រជារាស្ត្រយើង សូម្បីបន្តិចឡើយ។

ដូចខ្ញុំបានជម្រាបរួចមកហើយថា ខ្ញុំនឹងមិនញញើតក្នុងការចាត់វិធានការយ៉ាងម៉ឺងម៉ាត់ជាការចាំបាច់លើពួកនាំចង្រៃដល់សង្គមជាតិយើងទាំងអស់នេះទេ។

ខ្ញុំតែងតែក្រើនរម្លឹក សូមឱ្យពួកទាំងអស់នេះ បម្រើប្រជារាស្ត្រដោយពិតប្រាកដ តាមរយៈចលនាសង្គមរាស្ត្រនិយម ឬយ៉ាងហោចណាស់ ក៏ត្រូវគោរពច្បាប់ជាតិទៅចុះ។ ក៏ប៉ុន្តែ ពួកអកុសលទាំងនេះបានធ្វើឲ្យខ្លួននិរាសចេញពីសហគមន៍ជាតិខ្លួនឯង ដោយប្តូរផ្តាច់ស្ម័គ្រចិត្តដើរតាមពួកគ្រូអាចារ្យបរទេសរបស់ពួកគេទៅវិញ។ ហេតុនេះ សូមពួកទាំងអស់នេះ កុំងឿងឆ្ងល់ចំពោះផលកម្ម ដែលពួកខ្លួនបានទទួលឲ្យសោះ។

សម្តេចសីហនុ ថ្លែងទៀតថា ចំណែកពួកខ្មែរខៀវ ក៏គួរឲ្យយើងស្អប់ខ្ពើមដូចពួកខ្មែរក្រហមដែរនោះ ពួកគេបានប្ញងសួងចង់ឲ្យប្រទេសយើងក្លាយជាប្រទេសចំណុះរបស់សហរដ្ឋអាមេរិក។ ពួកនេះផ្ញើអនាគតរបស់ខ្លួនលើពួកខ្មែរសេរីក្បត់ជាតិ សង្ឃឹមថា បានឡើងកាន់អំណាច ដោយសារមេដឹកនាំនៅក្រុងព្រៃនគរ និងមេដឹកនាំនៅក្រុងបាងកក ជាបច្ចាមិត្តរបស់យើង សហការជាមួយសហរដ្ឋអាមេរិក ជួយជាកម្លាំង។

ពេលនេះ ពួកខ្មែរខៀវទាំងនោះ គិតតែបន្តុះបង្អាប់ជាតិឯង និងចាក់រុកឲ្យពួកកាសែតចក្រពត្តិនិយមសរសេរបន្ទាបបន្ថោកចលនាសង្គមរាស្ត្រនិយម និងសមិទ្ធផលដែលចលនាសង្គមរាស្ត្រនិយមកសាងបាន និងបង្ខូចបង្ខាច់ខ្ញុំផងដែរ។ ប៉ុន្តែ ខ្ញុំសូមជម្រាបដោយត្រង់ថា

## របត់នយោបាយ

ពួកខ្មែរខៀវនេះ ពុំអាចធ្វើឱ្យយើងទទួលគ្រោះថ្នាក់អ្វីបានទេ ពីព្រោះក្រៅពីក្រុមពាណិជ្ជករលោភលន់ពន់ប្រមាណមួយក្រុមតូច គ្មានអ្នកណាគេជឿតាមពួកនេះទេ។

អាស្រ័យហេតុនេះ ឥទ្ធិពលនយោបាយរបស់ខ្មែរខៀវ មិនបានជិតដាមអ្វីបន្តិចដល់ប្រជារាស្ត្រយើងទេ។ ប្រជារាស្ត្រយើងនៅតែស្មោះត្រង់ចំពោះរាជបល្ល័ង្ក ចំពោះព្រះពុទ្ធសាសនា ចំពោះសង្គមនិយមព្រះពុទ្ធសាសនា គឺថានៅតែស្មោះត្រង់ចំពោះសង្គមជាតិយើង ដូចពីពេលមុនជារៀងដរាប។ ក៏ប៉ុន្តែ ខ្ញុំសុំឱ្យសហជីវិនសហជីវិនីជាអ្នកជាតិនិយមទាំងអស់ប្រយ័ត្នឱ្យមែនទែន ចំពោះការធ្វើវិទ្ធង្សនារបស់ពួកនេះ ព្រោះវាអាចជាការគំរាមកំហែងដល់សន្តិភាពខាងផ្លូវចិត្ត ខាងនយោបាយរបស់ជាតិយើង។

ចំណែកបញ្ហាសេដ្ឋកិច្ច និងសង្គមកិច្ចចេះតែលូតលាស់ទៅមុខជានិច្ច ទោះបីយើងមានការលំបាកខាងហិរញ្ញវត្ថុក៏ដោយ ក៏ល្បឿននៃការស្ថាបនាផ្លូវថ្នល់ សាលារៀន គិលានដ្ឋាន និងមន្ទីរពេទ្យ គ្មានថមថយទេ គឺមានតែលឿនថែមទៀត។ ក្នុងពេលនេះដែរ ខ្ញុំរកតែពេលទទួលការយាងរបស់ចៅហ្វាយខេត្តនានា ឱ្យទៅសម្ពោធសមិទ្ធផលថ្មីៗ ពុំបានអស់ផង។ ការនេះបង្ហាញឲ្យឃើញច្បាស់ថា សង្គមជាតិយើងមិនមែនជិតដាច់ខ្យល់ ដូចពួកខ្មែរខៀវខិតខំផ្សាយបន្ទុះបង្អាប់យើងនោះទេ។

ជាមួយគ្នានេះ ការរៀបចំខាងផ្នែកឧស្សាហកម្ម ឱ្យមានរបៀបរៀបរយ កំពុងតែប្រព្រឹត្តទៅជាលំដាប់។ សហគ្រាសរដ្ឋ បានទទួលការគ្រប់គ្រងមានរបៀបរៀបរយ ហើយសង្ឃឹមថានឹងបានចំណេញច្រើនជាងពេលមុន។ ឯខាងរោងចក្រឯកជន យើងត្រូវតែបោសសម្អាត ពីព្រោះនៅមានរោងចក្រខ្លះបានស្រូបយករូបិយប័ណ្ណបរទេសអស់ច្រើនណាស់ ដោយពុំសូវសមហេតុផល។

ហេតុនេះខ្ញុំសង្ឃឹមថា នៅពេលមជ្ឈដ្ឋានសេដ្ឋកិច្ចខ្លះសុំឲ្យធ្វើអន្តរាគមន៍ សហជីវិនសហជីវិនីជាអ្នកតំណាងរាស្ត្រ និងសមាជិកក្រុមប្រឹក្សានៃព្រះរាជាណាចក្រកម្ពុជា ប្រាកដជាមានការថ្លឹងថ្លែងពិចារណាដោយប្រុងប្រយ័ត្នជាមិនខាន។ តែខាងរបរកសិកម្មវិញ គឺឃើញថាមានការកក់ក្តៅច្រើន បើគ្មានហេតុអ្វីចម្លែកទេ យើងសង្ឃឹមថានឹងបានផលស្រូវច្រើនជាង

ឆ្នាំមុន។

ក្នុងឱកាសនេះ ខ្ញុំសូមថ្លែងនូវសេចក្ដីកោតសរសើរជាអតិបរមាចំពោះសហជីវិន សហជីវិនី ដែលបានផ្ដល់នូវជំនួយផ្ទាល់ខ្លួនដល់កសិករយើងនៅតាមមណ្ឌលបោះឆ្នោតរបស់ខ្លួន ហើយយើងត្រូវតែជួយដោះស្រាយបញ្ហាទឹក បញ្ហាពូជស្រូវ និងបញ្ហាជី ដល់កសិករយើងផងដែរ។

ខ្ញុំសង្ឃឹមថា អ្នកតំណាងរាស្ត្រ និងសមាជិកក្រុមប្រឹក្សានៃព្រះរាជាណាចក្រ មានលទ្ធភាពក្នុងការជួយពង្រីកកសិកម្មយើងបានយ៉ាងពិតប្រាកដ ដោយរួបរួមយ៉ាងជិតស្និទ្ធជាមួយពួកមន្ត្រីរដ្ឋបាល និងពួកបច្ចេកទេសយើង។ ហេតុនេះ ខ្ញុំសុំឱ្យសហជីវិន សហជីវិនីគ្រប់រូប មេត្តាជួយរាជរដ្ឋាភិបាល និងខ្ញុំក្នុងកិច្ចការជាមូលដ្ឋាននេះ គឺជួយបង្កើនផលិតផល និងជួយសេដ្ឋកិច្ចជាតិយើង ឱ្យកាន់តែមានជំហររឹងប៉ឹងឡើង។

ពេលនេះជាងពេលណាទាំងអស់ យើងត្រូវពឹងផ្អែកលើខ្លួនយើង។ យើងត្រូវមានករណីយកិច្ចសង្ឃឹមលើខ្លួនយើងតែម្យ៉ាងប៉ុណ្ណោះ។ ប្រជាជាតិយើងត្រូវតម្កល់ចិត្តឲ្យនឹង នៅពេលណាមិត្តបរទេសគេកាត់បន្ថយជំនួយ ឬក៏ផ្ដាច់ជំនួយទាំងស្រុងរបស់គេ ពីព្រោះយើងមិនមែនចង់បានជំនួយពីបរទេសទាំងនោះ រហូតដល់ទៅសុខចិត្តធ្វើឱ្យបាត់បង់ឯករាជ្យភាពជាតិ និងបាត់បង់សន្តិភាពជាតិនោះទេ។

ក្នុងសម័យនេះ ពួកយក្ស(មហាអំណាច)ជានិមិត្តរូបនៃការពង្រឹង និងប្រជែងមនោគមវិជ្ជាគ្នា ដែលអាចនាំឲ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងសកលលោក វិនាសអន្តរាយបាន។

ហេតុនេះ ការដែលយើងពឹងលើជំនួយរបស់គេ ដោយឥតអៀនខ្មាស ដាច់ខាតវានឹងប្រទាញប្រទង់យើងឲ្យចូលក្នុងបក្សពួកខាងនេះ ឬខាងនោះ គឺនាំឱ្យមានការវិនាសអន្តរាយដល់ប្រទេសជាតិយើង។

ជំនួយបរទេសណាដែលប៉ះពាល់ដល់ឯករាជ្យភាពជាតិ មិនមែនជាការប្រសើរទេ ទោះបីជំនួយនោះញ៉ាំងឱ្យសេដ្ឋកិច្ចរីកដុះដាលបែបណាក៏ដោយ ក៏ជំនួយនោះនឹងក្លាយទៅជាថ្នាំពុលបណ្ដាលឲ្យស្លាប់បង់បាន កាលណាជំនួយនេះនាំឲ្យបាត់បង់នូវឯកភាពជាតិ និងសន្តិភាព។

## របត់នយោបាយ

តើប្រទេសថៃ អាចរស់បាននឹងជំនួយខាងហិរញ្ញវត្ថុ ខាងសេដ្ឋកិច្ច និងយោធា ដែលសហរដ្ឋអាមេរិក បំប៉នដល់ខ្លួន ដោយមិនសន្សំសំចៃបានទេ? តើខ្មែរយើងសុខចិត្តទទួលជំនួយទាំងនេះ ជាថ្នូរនឹងការបាត់បង់ឯករាជ្យទាំងស្រុង, ការពុករលួយដល់សង្គម និងដល់សេដ្ឋកិច្ច ព្រមទាំងការកើតអសន្តិសុខ និងចម្បាំងគ្នាឯងបានឬទេ?។

ការពិត នៅគ្រប់ទីកន្លែងទាំងអស់ក្នុងលោកយើងនេះ គេសង្កេតឃើញនូវផលអាក្រក់នៃជំនួយបរទេសទាំងនេះ ដែលតែងតែមានថ្នូរអាក្រក់ជាដរាប។ ក៏ប៉ុន្តែពួកគេខិតខំបិទបាំងថ្នូរអាក្រក់នោះ ដូចជានៅក្នុងសន្និសីទបណ្ដុំសេដ្ឋកិច្ច នៃក្រុងអាល់ហ្សេ ជាដើម។

នៅក្នុងសន្និសីទបណ្ដុំសេដ្ឋកិច្ចនោះ ពួកអ្នកតំណាងប្រទេសអាហ្វ្រិក អាស៊ី និងអាមេរិកឡាទីន អង្វរសុំឲ្យពួកមហាអំណាចផ្ដល់ជំនួយខាងសម្ភារៈ និងខាងហិរញ្ញវត្ថុ។ ជាការគួរឲ្យអាម៉ាស់មុខណាស់ ពួកមហាអំណាចមហាសេដ្ឋីទាំងនោះ ចាត់ទុកខ្លួនគេថាគ្មានជំពាក់ទាក់ទិនអ្វីជាមួយប្រទេសក្រីក្រ និងតូចតាចទេ។

យើងត្រូវយល់ឱ្យច្បាស់ពាក្យដែលហៅថា ជំនួយ គឺត្រូវតែសងគេវិញជាដាច់ខាត តាមរបៀបជាអកុសលណាមួយជាមិនខាន ព្រមទាំងមានការប្រាក់យ៉ាងធ្ងន់ធ្ងរថែមទៀតផង។ ចំណែកខាងខ្មែរយើង យើងពេញចិត្តនឹងខ្លួនយើងណាស់ យើងមិនអាចលះបង់នូវកិត្តិយសនិងភាពថ្លៃថ្នូររបស់ជាតិយើងបានទេ។ ហេតុនេះយើងត្រូវពឹងផ្អែកលើកម្លាំងផ្ទាល់របស់យើងដោយឈរលើឯករាជ្យជាតិយើង ឈរលើសន្តិភាពក្នុងសង្គមជាតិយើង ឈរលើភោគទ្រព្យនិងការងារផ្ទាល់របស់យើងឲ្យបានដើរទៅមុខជានិច្ច។

អាស្រ័យហេតុនេះ ខ្ញុំសូមឲ្យសភាទាំងពីររកផ្លូវដោះស្រាយនូវបញ្ហាសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់យើងតាមលក្ខណៈជាតិ និងតាមលក្ខណៈប្រាកដនិយម ជាអាទិ ត្រូវដោះស្រាយបញ្ហានានាឱ្យបានឆាប់រហ័សដើម្បីឱ្យបានទាន់ល្បឿនដែលខ្ញុំខិតខំរុញខាងរាជរដ្ឋាភិបាល។

ក្នុងបំណងនេះ សូមសហជីវិនសហជីវិនីមេត្តាពិភាក្សា ហើយអនុម័តដោយរួសរាន់នូវសេចក្ដីព្រាងច្បាប់ ស្ដីអំពីការបែងចែកនូវសកម្មភាពខាងសេដ្ឋកិច្ចជាផ្នែកៗ និងសេចក្ដីព្រាងច្បាប់ស្ដីអំពីថវិកាប្រចួនឆ្នាំ១៩៦៧ នេះ ផងដែរ។

ក្នុងវិស័យសង្គមកិច្ច យើងមានការផ្តើមគំនិតថ្មីៗដែលខ្ញុំសូមឱ្យសហជីវិនសហជីវិនី មេត្តាជួយចូលរួមជាកម្លាំងផងដែរ គឺការកែប្រែទម្រង់នៃការសិក្សា និងការរៀបចំសាលាឯកជន ឱ្យមានរបៀបរៀបរយឡើងវិញ ឬការប្រយុទ្ធជាថ្មីចំពោះអនក្ខរកម្ម ដែលសហជីវិនសហជីវិនី ត្រូវជួយជាវិភាគទានឲ្យបានទូលំទូលាយបំផុត។

ឯយុវជនរាជសង្គមនិយមខ្មែរយើង ក៏មានភាពស្វាហាប់ឡើងវិញជាលំដាប់រាល់ថ្ងៃ ដូចដើមវិញហើយ។ ខ្ញុំយល់ថា សមាជិកនៃសភាទាំងពីរអាចជួយអ្នកទទួលខុសត្រូវនៅតាម បណ្តាខេត្តនានាបានយ៉ាងស័ក្តិសិទ្ធិ។

សរុបទៅ បើទោះបីយើងមានការលំបាកក្នុងបច្ចុប្បន្នកាលនេះ ទោះបើយើងនៅមាន ឧបសគ្គដែលត្រូវពុះពារ និងមានបញ្ហាដែលដោះស្រាយថែមទៀតក៏ដោយ ក៏យើងអាចមាន សេចក្តីកក់ក្តៅ ចំពោះអនាគតដ៏ខ្លីរបស់យើងបាន ឲ្យតែយើងមានគតិបណ្ឌិត និងកម្លាំង ធន់ល្មមក្នុងការតាំងខ្លួនយើងនៅជាចៅហ្វាយលើជោគវាសនារបស់ខ្លួនយើង គឺថាបើយើង នៅតែតាំងខ្លួនយើងជាអ្នកជាតិនិយម យ៉ាងរឹងមាំដដែល។

# ២១៩
# ចិន ចង់នាំបដិវត្តន៍វប្បធម៌ចូលប្រទេសខ្មែរ




**បដិវត្តន៍វប្បធម៌នៅប្រទេសចិន**

ចំណែកបញ្ហាទំនាក់ទំនងការបរទេសវិញ សម្តេចសីហនុ ថ្លែងទៅកាន់សភាទាំងពីរថា៖ ដូចសហជីវិនសហជីវិនីជ្រាបហើយ ការប្រាស្រ័យទាក់ទងរវាងយើង និងប្រទេសចិនមានភាពល្អក់កករ បណ្តាលមកពីចិនចង់នាំបដិវត្តន៍វប្បធម៌ ចូលមកក្នុងប្រទេសយើង។

ខ្ញុំត្រូវតែទប់ទល់នឹងការបញ្ចូលនូវមនោគមវិជ្ជា ដែលជាការគំរាមកំហែងដល់ស្ថេរភាព និងសន្តិភាពខាងក្នុងផ្ទៃប្រទេស ហើយសូមរម្លឹកថា ការប្រាស្រ័យទាក់ទងទំនាក់ទំនងខ្មែរ និងចិន ត្រូវយកគោលការណ៍សន្និសីទក្រុងបានឌុង ជាមូលដ្ឋានតែម្យ៉ាងប៉ុណ្ណោះ។ មិនត្រូវយកគោលការណ៍អ្វីដទៃទៀតមកលាយឡំជាដាច់ខាត។

យើងរិះរកផ្លូវស្រោចស្រង់មិត្តភាពយើងជាមួយនឹងប្រទេសចិន ឡើងវិញ ហើយបើតាមខ្ញុំស្មានមើលទៅ ប្រហែលជាមេដឹកនាំក្រុងប៉េកាំង ក៏យល់រឿងនេះដែរថា ប្រទេសកម្ពុជា

បានសម្រេចដាច់ខាតថា នឹងតម្កល់អព្យាក្រឹតរបស់ខ្លួន និងអត្តសញ្ញាណជាតិរបស់ខ្លួន ជាខ្មែរ។

មានពួកខ្មែរខៀវខ្លះ ជាពិសេសក្នុងមជ្ឈដ្ឋានបរទេសខាងលោកសេរីខ្លះ បានប្រកាសថា សីហនុ ទើបតែភ្ញាក់ខ្លួនបើកភ្នែកធំៗ ហើយមុខជាងាកមកស្រវាឱបអាមេរិក វិញ ជាមិនខាន។

ក្នុងរឿងនេះ សូមអ្នកទាំងនោះកុំប្រទ្បាំឱ្យសោះ យើងនឹងមិនអាចធ្វើជាអ្នកសមគំនិត ឬជាបាវព្រាវរបស់អាមេរិក ជាដាច់ខាត។ ពិតប្រាកដណាស់ ប្រទេសកម្ពុជា មិនមែនជាប្រទេសវៀតណាម របស់ង្វៀង កាវគី ឬជាប្រទេសថៃឡង់ របស់ ថៈណម គិតទិខៈចន (Thanom Kitti Kachorn) នោះទេ។ ដរាបណា ក្រុងវ៉ាស៊ីនតោន មិនបានបំពេញនូវលក្ខខណ្ឌ ដែលខ្ញុំបានកំណត់រួចមកហើយនោះទេ ដរាបនោះការប្រាស្រ័យទាក់ទងជាធម្មតា រវាងយើង និងអាមេរិកាំង គ្មានផ្លូវនឹងកើតឡើងវិញបានឡើយ។

ការប្រាស្រ័យទាក់ទងរបស់យើងជាមួយបរទេស ផ្អែកលើនយោបាយបដិការជានិច្ច គឺយើងធ្វើមិត្តជាមួយតែប្រទេសទាំងឡាយណា ដែលជាមិត្តយើង និងប្រទេសទាំងឡាយណាជាសត្រូវជាមួយនឹងប្រទេស ដែលយកយើងជាសត្រូវប៉ុណ្ណោះ។ ប្រទេសទាំងឡាយណា ដែលគោរពឯករាជ្យ និងអព្យាក្រឹតយើង ហើយទទួលស្គាល់បូរណភាពនៃដែនដីយើង ក្នុងបរិវេណនៃព្រំដែនសព្វថ្ងៃ យើងចាត់ទុកប្រទេសនោះជាមិត្តយើង។ ប្រទេសដទៃទៀតក្រៅពីនេះ យើងមិនត្រូវការទេ ។

ក្នុងរឿងនេះសេចក្តីថ្លែងការណ៍ទទួលស្គាល់ មិនទទួលស្គាល់ ឬមិនច្បាស់លាស់របស់រដ្ឋាភិបាលនានាលើព្រំប្រទល់នៃដែនដីយើងក្នុងបច្ចុប្បន្នកាល ជាវិញ្ញាសាមួយដ៏មានសារសំខាន់។

ប៉ុន្តែ មកទល់នឹងពេលនេះ សេចក្តីថ្លែងការណ៍ ដែលយើងទទួលទាំងប៉ុន្មាន សុទ្ធសឹងជាកិច្ចធានាអះអាងក្នុងបច្ចុប្បន្នកាល និងអនាគតកាលរបស់យើង ទល់នឹងនយោបាយពង្រីកទឹកដី ដោយចារកម្មរបស់អ្នកជិតខាងយើង។ ជោគជ័យថ្មីៗរបស់យើង ខាងការទូតមានសភាពគួរឱ្យកក់ក្តៅជាពន់ពេកណាស់។ នៅទ្វីបអាហ្វ្រិក យើងបានរកឃើញនូវមិត្តថ្មីៗទៀត គឺប្រទេសម៉ូរីតានី, និងប្រទេសសេណេហ្កាល់ ដែលទើបនឹងទទួលស្គាល់ព្រំប្រទល់ដែនយើង

សព្វថ្ងៃ ហើយថែមទាំងស្នើសុំឱ្យមានទំនាក់ទំនងថ្នាក់ឯកអគ្គរដ្ឋទូត ជាមួយនឹងយើងទៀតផង។

ចំណែក មិត្តជំនាន់មុនរបស់យើង គឺសាធារណរដ្ឋអារ៉ាប់រួម និងប្រទេសអាល់ហ្សេរី បានផ្តល់យើងនូវជំនួយយ៉ាងគាប់ប្រសើរបំផុត គឺបានទ្រទ្រង់យើងយ៉ាងច្បាស់លាស់ ទល់នឹងបំណងវាតទឹកដីរបស់របបគ្រប់គ្រងក្រុងព្រៃនគរ និងក្រុងបាងកក។ មួយវិញទៀត សហព័ន្ធអាល្លឺម៉ង់ បានទទួលគោរពទាំងស្រុង ចំពោះព្រំប្រទល់យើងសព្វថ្ងៃ ព្រមទាំងទទួលស្គាល់សភាពជាស្ថាពរនៃព្រំប្រទល់នេះ មិនត្រូវអ្នកណាមកប៉ះពាល់បានឡើយ។

ម្យ៉ាងទៀត ខ្ញុំទើបនឹងបានទទួលពីប្រទេសហ្វីលីពីន ដែលជាប្រទេសចូលខាងអាមេរិកាំង នូវសេចក្តីថ្លែងការណ៍ទទួលគោរព និងទទួលស្គាល់ចំពោះបូរណភាពទឹកដីក្នុងបរិវេណនៃព្រំប្រទល់ដែនខ្មែរយើងសព្វថ្ងៃ។ ចំពោះផែនការថ្មី នៃពួកអាមេរិកាំង ឃើញថា បើទោះបីមានការបង្ខិតបង្ខំរបស់ពួកចក្រពត្តិនិយមបែបណាក៏ដោយ ក៏កិច្ចខិតខំប្រឹងប្រែងរបស់យើងដើម្បីតទល់នឹងបំណងវាតទឹកដីរបស់អ្នកជិតខាងយើង តែងតែបានទទួលជោគជ័យជានិច្ចទាំងក្នុងបច្ចុប្បន្នកាល និងអនាគតកាល។

ពួកអាមេរិកាំង ដឹងខ្លួនច្បាស់អំពីជោគជ័យ ដែលពួកវាទើបនឹងបានទទួល ហើយបើយោងទៅតាមសារព័ត៌មានរបស់វាឃើញថា វាមានផែនការថ្មីសម្រាប់បម្រើប្រយោជន៍របស់ប្រទេសថៃឡង់ដ៍ និងប្រទេសវៀតណាមខាងត្បូង ជារណបរបស់វា។

ផែនការនេះ វាបានស្នើសុំឱ្យប្រទេសកម្ពុជា ចូលរួមក្នុងសន្និសីទមួយជាមួយនឹងអ្នកតំណាងក្រុងបាងកក និងក្រុងព្រៃនគរ ដើម្បីសម្របសម្រួលគ្នាអំពីបញ្ហាព្រំដែនយើង ដែលគេថា មានលក្ខណៈមិនជាក់លាក់។

សន្និសីទនេះនឹងរាលដាលចេញពីកម្មវត្ថុដើម ហើយគេចង់ឲ្យមានការអញ្ជើញសហរដ្ឋអាមេរិក,សហភាពសូវៀត និងប្រទេសចិន ចូលរួមប្រជុំផង ដើម្បីសម្រុះសម្រួលគ្នាអំពីវាសនារបស់វៀតណាម។ ក្នុងចម្លើយរបស់ប្រទេសកម្ពុជា ចំពោះឧបាយកលរបស់អាមេរិកាំង នេះ គឺការពុំព្រមទទួលស្គាល់ជាដាច់ខាត ព្រំប្រទល់ដែនយើងសព្វថ្ងៃមានសភាពជាក់លាក់បំផុត

ហើយមានប្រទេសជាច្រើនទទួលស្គាល់ថែមទៀតផង ទោះជាគេសំអាងលើលេសបែបណាក៏ដោយ ក៏យើងមិនត្រូវយល់ព្រមឲ្យគេលើកមកជជែកវែកញែកទៀតឡើយ។

ការដែលនឹកឃើញថាមានកិច្ចចរចា ឬកិច្ចសន្ទនាលើបញ្ហានេះដែលបានទទួលការអារកាត់ស្រេចបាច់រួចហើយនោះ ជាការគួរឲ្យអស់សំណើចណាស់។ រីឯសេចក្តីស្នើសុំឱ្យមានការសម្រុះសម្រួលគ្នារឿងវៀតណាម ដោយពួកមហាអំណាចវិញ ប្រទេសកម្ពុជា ដោយគោរពតាមគោលការណ៍របស់ខ្លួនយ៉ាងខ្ជាប់ខ្ជួន នឹងជំទាស់ជាដាច់ខាត ហើយមុខជានឹងគាំទ្រជានិច្ច ហើយយ៉ាងម៉ឺងម៉ាត់បំផុតទៀតផង ចំពោះឧត្តមប្រយោជន៍នៃប្រជាជាតិវៀតណាម ដែលទទួលរងការឈ្លានពានយ៉ាងអយុត្តិធម៌ ហើយដែលត្រូវកងកម្លាំងអាមេរិកាំង និងពួកស៊ីឈ្នួលវាយដណ្តើមយកទឹកដីទាំងកំរោល។

ឥរិយាបថរបស់រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង និងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម(វៀតណាមខាងជើង)មានសភាពត្រឹមត្រូវណាស់ ពួកអ្នករាតត្បាតត្រូវតែដកថយចេញពីវៀតណាម ដោយគ្មានលក្ខខណ្ឌអ្វីដល់បន្តិចឡើយ ហើយយើងត្រូវតែទុកឲ្យជនជាតិវៀតណាម ដោះស្រាយកិច្ចការផ្ទាល់របស់គេដោយខ្លួនគេផ្ទាល់។

យើងមិនទទួលយល់ព្រមឲ្យមហាអំណាចបរទេសណាមួយ ឬច្រើនគ្នាមានសិទ្ធិចូលមកបំផ្លាញឯករាជ្យពេញបរិបូររបស់ប្រទេសមួយទៀតទេ។ ចក្រពត្តិនិយមអាមេរិក និងពួកអ្នកសមគំនិតរបស់គេ នៅតែបន្តការឃោសនាចោទប្រកាន់លើកម្ពុជា ហើយនៅតែចូលរួមរាតត្បាតយើងជានិច្ច។ ជារៀងរាល់ថ្ងៃ នៅតាមទល់ដែន កងទ័ពដ៏ក្លាហានរបស់យើងត្រូវរុញច្រានពួកខ្មាំង ដែលស្ទាបស្ទង់សមត្ថភាព និងសន្ទុះចិត្តតទល់របស់យើង។

យើងទទួលការបាត់បង់ជីវិតមនុស្ស និងការបំផ្លាញអំពីវា។ ប៉ុន្តែពួកបច្ចាមិត្តនៃយើងត្រូវតែដឹងឲ្យច្បាស់ថា យើងមិនបណ្តោយឱ្យវាធ្វើអ្វីបានតាមចិត្តជាដាច់ខាត។

សរុបទៅពួកមហាអំណាចនៃបរទេសខ្លះ បានតិះដៀលមួលបង្កាច់ប្រមាថមើលងាយកម្ពុជរដ្ឋយើង។ តែកម្ពុជរដ្ឋយើងនៅតែមានការកិត្យានុភាព និងទទួលសេចក្តីរាប់អានពីគ្រប់ទិសទីក្នុងសកលលោក។ កិត្យានុភាព និងសេចក្តីរាប់អានដែលប្រទេសដទៃជាច្រើនចង់បាន

ដូចប្រទេសយើងដែរ តែធ្វើពុំកើត។

ប្រទេសកម្ពុជាស្ថិតនៅក្នុងឋានៈខ្ពង់ខ្ពស់បែបនេះជានិច្ចតទៅ ដរាបណាជនរួមជាតិយើងនៅតែថែរក្សាឯកភាព សាមគ្គីធម៌របស់ខ្លួនឱ្យបានគង់វង្ស។ ហេតុនេះ ខ្ញុំសុំឲ្យអ្នកតំណាងរាស្ត្រ និងសមាជិកក្រុមប្រឹក្សានៃព្រះរាជាណាចក្រកម្ពុជា កុំសំចៃកម្លាំងក្នុងការផ្ដត់ផ្ដង់ឯកភាព និងសាមគ្គីភាពនេះនៅផ្ទៃក្នុងនៃសភាទាំងពីរ និងនៅក្នុងមណ្ឌលបោះឆ្នោតរៀងៗខ្លួន។

# ២២០
# សម្តេចសីហនុ ចង់ភ្ជាប់ទំនាក់ទំនង ការទូតជាមួយអាមេរិក វិញ



**ជំនួបពិភាក្សារវាងសម្តេចសីហនុ និងឆេស្ទ័រ បូវឡេស បេសកជនពិសេសប្រធានាធិបតីចន សុន**

ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៦៧ ហ្សាក្គី លីន កេណ្ណឌី ( Jacque Line Kennedy ) ជាភរិយាសពលោក ចន កេណ្ណឌី ( John Kennedy ) អតីតប្រធានាធិបតីអាមេរិក មកបំពេញទស្សនកិច្ចជាផ្លូវការនៅប្រទេសកម្ពុជា។ នៅក្នុងដំណើរទស្សនកិច្ចនោះ សម្តេចសីហនុ បានបង្ហើបប្រាប់អ្នកស្រីហ្សាក្គី លីន កេណ្ណឌី ពីបំណងរបស់ព្រះអង្គ ដែលចង់ស្តារទំនាក់ទំនងការទូតឡើងវិញ ជាមួយរដ្ឋាភិបាលក្រុងវ៉ាស៊ីនតោន ដែរ។ ប៉ុន្តែព្រះអង្គបានទាមទារឱ្យសហរដ្ឋអាមេរិក ទទួលស្គាល់អធិបតេយ្យភាព បូរណភាព ទឹកដីរបស់កម្ពុជាជាមុនសិន។

ប្រធានាធិបតី ចន សុន មានបំណងចង់ទទួលស្គាល់ខ្សែបន្ទាត់ព្រំដែនរបស់កម្ពុជាដែលមានស្រាប់នោះដែរ ប៉ុន្តែលោកមានការព្រួយបារម្ភកាន់តែខ្លាំងឡើង ដោយសារតែវត្តមាន




**សម្តេចសីហនុ និងលោកជំទាវ ហ្សាក់គ្លី លីន កេណ្ណឌី**
**ជាភរិយាសពចន កេណ្ណឌី**

របស់កងទ័ពវៀតកុង-វៀតណាមខាងជើង នៅក្នុងទឹកដីកម្ពុជា កាន់តែកើនមានច្រើនឡើងៗ ហើយសម្តេចសីហនុ ក៏មានការខ្វាយខ្វល់ពីរឿងនេះខ្លាំងដែរ។

ក្នុងឱកាសបំពេញទស្សនកិច្ចនោះ អ្នកស្រីហ្សាក្គី លីន ក៏បានចូលគាល់សម្តែងការគួរសម ជាមួយព្រះមហាក្សត្រិយានីកុសុមៈ និងបានអញ្ជើញទៅទស្សនាប្រាង្គប្រាសាទខ្មែរ នៅឯខេត្តសៀមរាប ផងដែរ។

នៅទីក្រុងព្រះសីហនុ សម្តេចសីហនុ និងអ្នកស្រីហ្សាក្គី លីន ក៏បានយាងនិងអញ្ជើញជាអធិបតី នៅក្នុងពិធីសម្ពោធវុក្ខវិថីមួយ ដែលព្រះអង្គដាក់ឈ្មោះថា វុក្ខវិថី ចន កេណ្ណឌី (John Kennedy) ដែលជាឈ្មោះអតីតប្រធានាធិបតីអាមេរិក ជាស្វាមីរបស់អ្នកស្រី។

បន្ទាប់ពីដំណើរទស្សនកិច្ចរបស់អ្នកស្រីហ្សាក្គី លីន កេណ្ណឌី កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៦៧មក នៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៦៨ ប្រធានាធិបតីអាមេរិក ចន សុន បានចាត់ឱ្យឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំប្រទេសឥណ្ឌា ឈ្មោះឆេស្ទ័រ បូវឡេស (Chester



កម្រងរូបភាពពេលជំនួបសម្តេចសីហនុ និងគណៈប្រតិភូអាមេរិក
ដឹកនាំដោយឆេស្ទ័រ បូវឡេស ក្នុងខែមករា ឆ្នាំ១៩៦៨



ឆេស្ទ័រ បូវឡេស កាលមកជួបពិភាក្សាជាមួយសម្ដេចសីហនុ ក្នុងឆ្នាំ១៩៦១

Bowles) ក្នុងនាមជាបេសកជនពិសេស ដឹកនាំគណៈប្រតិភូមួយក្រុម ធ្វើដំណើរតាមយន្តហោះ មកទីក្រុងភ្នំពេញ ដើម្បីសិក្សាស្រាវជ្រាវ និងស្ទាបស្ទង់ក្នុងការផ្សារទំនាក់ទំនងការទូតជាមួយប្រទេសកម្ពុជា ឡើងវិញ។

ក្រោយពីបានជួបប្រជុំការងារជាមួយមន្ត្រីរាជរដ្ឋាភិបាលអស់រយៈពេល២លើកមក នៅព្រឹកថ្ងៃទី១០ ខែមករា សម្ដេចសីហនុ ក៏បានជួបពិភាក្សាជាមួយគណៈប្រតិភូអាមេរិកនេះ ដោយផ្ដោតការយកចិត្តទុកដាក់ពីបញ្ហាផ្សារទំនាក់ទំនងការទូតគ្នាឡើងវិញ អស់រយៈពេលមួយម៉ោងកន្លះ។

នៅថ្ងៃទី១១ ខែមករា សម្ដេចសីហនុ បានរៀបចំពិធីជប់លៀងមួយជូនដល់ឆេស្ទ័រ បូវឡេស (Chester Bowles) ជាបេសកជនពិសេសរបស់ប្រធានាធិបតីចន សុន និងគណៈប្រតិភូ នៅក្នុងព្រះរាជដំណាក់ចំការមន ក្នុងបរិយាកាសរីករាយស្និទ្ធស្នាលបំផុត។

សូមបញ្ជាក់ផងដែរថា ឆេស្ទ័រ បូវឡេស (Chester Bowles) ធ្លាប់ជាទីប្រឹក្សារបស់ប្រធានាធិបតីអាមេរិក ចន កេណ្ណឌី(John Kennedy) បានអញ្ជើញមកបំពេញទស្សនកិច្ច

និងជួបពិភាក្សាជាមួយសម្ដេចសីហនុ ក្នុងឆ្នាំ១៩៦១ ម្ដងរួចមកហើយផងដែរ។

ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៦៨ សម្ដេចសីហនុ សម្រេចព្រះទ័យយល់ព្រមទទួលជំនួយសេដ្ឋកិច្ច យោធាពីសហរដ្ឋអាមេរិក វិញ ។ បន្ទាប់មក នៅខែកញ្ញា ឆ្នាំ១៩៦៨ ប្រធានាធិបតី ចន សុន( John Son ) ក៏បានចាត់ឱ្យតំណាងពិសេសរបស់លោកម្នាក់ទៀត ឈ្មោះអឺហ្សេន ប្លេក( Eugene Black ) ធ្វើដំណើរមកប្រទេសកម្ពុជា ដើម្បីធ្វើសិក្ខាសាលាមួយ អំពីទស្សនៈផ្សេងៗរបស់សហរដ្ឋអាមេរិក ស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ចនៅតំបន់អាស៊ីអាគ្នេយ៍ ផងដែរ។

ចាប់ពីពេលនោះមក សម្ដេច សីហនុ ហាក់ដូចជាផ្លាស់ប្ដូរគោលជំហរនយោបាយទោរទន់បន្តិចទៅរកសហរដ្ឋអាមេរិក វិញ។ នៅថ្ងៃទី១១ ខែ វិច្ឆិកា ឆ្នាំ១៩៦៨ ក្រុមទាហានជើងទឹកអាមេរិក នៅលើនាវាចម្បាំងមួយគ្រឿងមានគ្នា១១នាក់ ដែលកងទ័ពជើងទឹកកម្ពុជាចាប់បានជាឈ្លើយសឹកនៅក្នុងដែនសមុទ្រកម្ពុជា នោះ បានក្លាយជាភ្ញៀវកិត្តិយសរបស់កម្ពុជាទៅវិញ ដោយសម្ដេចសីហនុ អនុញ្ញាតឱ្យពួកគេចូលរួមក្នុងពិធីបុណ្យ និងពិធីជប់លៀងធំៗ ព្រមទាំងឱ្យដើរកម្សាន្តសប្បាយដោយសេរី និងមានស្រីស្អាតៗតាមកំដរទៀតផង ហើយទីបំផុត នៅក្នុងថ្ងៃបុណ្យណូអែល ឈ្លើយសឹកអាមេរិក ទាំង១១នាក់នោះ ត្រូវបានដោះលែងវិញ។

គួររម្លឹកថា ក្រោយជាប់ឆ្នោតជាប្រធានាធិបតីសហរដ្ឋអាមេរិក នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៦០ ដោយមានការឱ្យយោបល់ពីទីប្រឹក្សាផងនោះ ចន កេណ្ណឺឌី ( John Kennedy ) បានបញ្ជូនទីប្រឹក្សាយោធាចំនួន៤០០នាក់ ទៅកាន់ប្រទេសវៀតណាមខាងត្បូង ដើម្បីជួយបង្ហាត់បង្រៀនពីក្បួនយុទ្ធសាស្ត្រធ្វើសង្គ្រាម និងប្រើប្រាស់អាវុធយុទ្ធភណ្ឌ ដែលជាជំនួយរបស់សហរដ្ឋអាមេរិក ហើយមួយឆ្នាំក្រោយមក ទីប្រឹក្សាយោធាអាមេរិក នៅវៀតណាមខាងត្បូង បានកើតឡើង ដល់១៦០០០ នាក់។

ក្រោយប្រធានាធិបតី កេណ្ណឺឌី ត្រូវបានគេលួចធ្វើឃាត ក្នុងខែវិច្ឆិកា ឆ្នាំ១៩៦៣ មកប្រធានាធិបតី ចន សុន( John son) ជាអ្នកបន្តវេន បានបង្កើនកងទ័ពរបស់ខ្លួននៅក្នុងសង្គ្រាមវៀតណាមខាងត្បូង ដល់១២៥.០០០នាក់ ហើយនៅចុងឆ្នាំដដែលនោះ បានកើន

ដល់១៨៥.០០០នាក់ ។

មិនតែប៉ុណ្ណោះ នៅចុងឆ្នាំ១៩៦៧ កងទ័ពអាមេរិក បានកើនឡើង ដល់៥១០.០០០នាក់ ហើយនៅខែធ្នូ ឆ្នាំ១៩៦៧ បានកើនឡើង ដល់៥៨០.០០០នាក់។ ប៉ុន្តែ ក្រោយពី រីឆាដ និចសុន (Richard Nixon) បានជាប់ឆ្នោតប្រធានាធិបតី នៅក្នុងឆ្នាំ១៩៦៩ មក ចំនួននេះត្រូវកាត់បន្ថយ នៅត្រឹមចំនួន៥៤៩.០០០នាក់ ហើយមកដល់ខែកុម្ភៈ ឆ្នាំ១៩៧២ ត្រូវកាត់បន្ថយ នៅត្រឹមចំនួន១៣៣.៧០០នាក់។

នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៦៨ កាសែតយូភីអាយ (UPI) បានដកស្រង់បន្ទូលសម្តេចសីហនុ ថា បើទោះបីនៅក្នុងស្ថានការណ៍បែបណាក៏ដោយ ព្រះអង្គសន្យាប្រឆាំងដាច់ខាតចំពោះការរីករាលដាលណាមួយរបស់សង្គ្រាមនៅអាស៊ីអាគ្នេយ៍ មកលើមាតុភូមិកម្ពុជារបស់ព្រះអង្គ ហើយព្រះអង្គនឹងអនុញ្ញាតឱ្យកងទ័ពអាមេរិក នៅវៀតណាមខាងត្បូង ដេញតាមពួកវៀតកុង ឆ្លងកាត់ខ្សែបន្ទាត់ព្រំដែនកម្ពុជា តាមកាលៈទេសៈចាំបាច់មួយចំនួន។

ប៉ុន្តែ ក្នុងករណី ដែលអាមេរិក នៅវៀតណាមខាងត្បូង បញ្ជូនកងទ័ពរបស់របបរដ្ឋការក្រុងព្រៃនគរ ចូលក្នុងទឹកដីកម្ពុជានោះ ទោះបីប្រទេសព្រះអង្គមានប្រជារាស្ត្រតែ៦,៥លាននាក់ និងកងទ័ពប្រមាណ ៣៥០០០នាក់ ក៏ដោយ ក៏ព្រះអង្គត្រូវតែវាយតបតវិញដែរ។ ព្រះអង្គចង់មានបន្ទូលថា ប្រសិនបើកងទ័ពអាមេរិក ដេញតាមវាយកងទ័ពវៀតកុង មិនចូលជ្រៀមកក្នុងទឹកដីកម្ពុជា និងមិនធ្វើឱ្យបាត់បង់អាយុជីវិតប្រជារាស្ត្រ, ទ្រព្យសម្បត្តិ, ភូមិឋានរបស់កម្ពុជាទេ ព្រះអង្គក៏មិនឱ្យកងទ័ពព្រះអង្គវាយតបតកងទ័ពអាមេរិក វិញដែរ។

ទាក់ទងដល់បញ្ហាគ្រឿងអាវុធយុទ្ធភណ្ឌ និងស្បៀងអាហារជាជំនួយរបស់ចិន និងសូវៀត ដែលបញ្ជូនមកតាមកំពង់ផែក្រុងព្រះសីហនុ កាន់តែកើនច្រើនឡើងៗ និងបញ្ហា ដែលព្រះអង្គបានអនុញ្ញាតឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង បោះទីតាំងឈរជើងនៅតាមបណ្តោយព្រំដែនប្រទេសរបស់ព្រះអង្គនោះ សម្តេចសីហនុ បានមានបន្ទូលថា ៖ "ការពិតយើងមិនបានគប់គិតជាមួយពួកវៀតកុង-វៀតណាមខាងជើងទេ យើងបានដាក់ពួកនេះឱ្យនៅក្រៅទឹកដីយើង។ ទឹកដីយើងមិនមែនជាមូលដ្ឋានសម្រាប់ពួកគេទេ។ ប្រសិនបើមាន

អង្គភាពកងទ័ពពួកគេណាមួយ បានជ្រៀតចូលមកក្នុងទឹកដីយើង យើងត្រូវតែផ្តន្ទាទោស ព្រោះមេដឹកនាំវៀតកុង-វៀតណាមខាងជើង បានទទួលស្គាល់ និងសន្យាថា គោរពបូរណភាពទឹកដីយើងរួចហើយ។

ព្រះអង្គបានបន្ថែមទៀតថា ជាមួយគ្នានេះ បញ្ហាព្រំដែន ក៏ជាឧបសគ្គធំមួយដល់ទំនាក់ទំនងល្អរវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក ជាងបញ្ហាសង្គ្រាមនៅវៀតណាមខាងត្បូងទៅទៀត តែបើអាមេរិក ត្រៀមខ្លួនទទួលស្គាល់បញ្ហាព្រំដែននេះ គឺអាចមានការសម្របសម្រួលគ្នា ដើម្បីរៀបចំឱ្យមានទំនាក់ទំនងការទូតជាមួយគ្នា ឡើងវិញ។

តែទោះបីយ៉ាងនេះ ក៏ដោយ ក៏សម្តេចសីហនុ បានបញ្ជាក់ថា ក្នុងអំឡុងពេលអ្នកការទូតអាមេរិក ឈ្មោះឆេស្ទ័រ បូវឡេស (Chester Bowles) ចូលជួបព្រះអង្គនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី១០ ខែមករា កន្លងមកនោះ មិនបានធ្វើការសម្របសម្រួលគ្នាណាមួយពីបញ្ហាភ្ជាប់ទំនាក់ទំនងការទូតគ្នាឡើងវិញនោះទេ ប៉ុន្តែដំណើរទស្សនកិច្ចនេះ អាចជួយបន្ធូរភាពតានតឹងក្នុងបច្ចុប្បន្ន រវាងប្រទេសទាំងពីរ បានខ្លះដែរ ។

ពេលនោះ មេដឹកនាំចិន និងវៀតណាមខាងជើង ក៏មានការព្រួយបារម្ភចំពោះគោលជំហររបស់សម្តេចសីហនុ ងាកទៅរកសហរដ្ឋអាមេរិក ដែរ។ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៦៨ សម្តេចសីហនុ មានបន្ទូលប្រាប់អ្នកកាសែតបរទេសថា នៅក្នុងការជួបសន្ទនាជាមួយឯកអគ្គរាជទូតកម្ពុជានៅទីក្រុងប៉េកាំង សេនាប្រមុខ ចេន យី រដ្ឋមន្ត្រីការបរទេសចិន បាននិយាយថា រដ្ឋាភិបាលចិន ទទួលស្គាល់តែរដ្ឋាភិបាលស្របច្បាប់របស់កម្ពុជា ដែលស្ថិតនៅក្រោមការដឹកនាំរបស់ព្រះអង្គតែប៉ុណ្ណោះ ហើយចិនក៏មិនជ្រៀតជ្រែកដល់កិច្ចការផ្ទៃក្នុងរបស់កម្ពុជា ដែរ។

ជាមួយគ្នានោះ ព្រះអង្គក៏បានបន្តថា ឯកអគ្គរដ្ឋទូតវៀតណាមខាងជើង នៅក្រុងភ្នំពេញ ក៏បានអះអាងប្រាប់ព្រះអង្គដែរថា វៀតណាមខាងជើង ចៀសវាងជាដាច់ខាតមិនផ្តួលរម្លំរបបគ្រប់គ្រងដែលដឹកនាំដោយព្រះអង្គឡើយ ទោះបីក្រោយពេលពួកគេទទួលបានជ័យជម្នះនៅវៀតណាមខាងត្បូង ក៏ដោយ ហើយថ្មីៗនេះ តំណាងរណសិរ្សជាតិរំដោះវៀតណាម (វៀតកុង) ក៏បានប្រកាន់គោលជំហរ ដូចគ្នានេះដែរ ។

នៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ កងទ័ពឧទ្ទាមខ្មែរក្រហម បានបើកការវាយប្រយុទ្ធគ្នាជាមួយពួកទាហាន និងប៉ូលិសរបស់រាជរដ្ឋាភិបាល នៅបាយដំរាំ ក្នុងស្រុកបាណន់ ខេត្តបាត់ដំបង។ ក្នុងការវាយប្រយុទ្ធគ្នានោះ ពួកឧទ្ទាមខ្មែរក្រហម ប្រមាណ២០នាក់ ត្រូវបាញ់សម្លាប់ និងចាប់ខ្លួនបាន។ ប៉ុន្តែ ស្ពានឈើជាច្រើនកន្លែងនៅក្នុងស្រុកសំឡូត ក៏ត្រូវពួកឧទ្ទាមខ្មែរក្រហម ដុតបំផ្លាញចោលដែរ ។

នៅថ្ងៃទី១៨ ខែមករា កងទ័ពឧទ្ទាមខ្មែរក្រហម បានពួនស្ទាក់បាញ់សម្លាប់កងតម្រួតខេត្ត ៣នាក់ នៅតាមផ្លូវ ។

បន្ទាប់មកទៀត ពួកឧទ្ទាមខ្មែរក្រហម បានវាយប្រហារទៅលើបន្ទាយមួយ នៅក្នុងស្រុកបាណន់ ខេត្តបាត់ដំបង ធ្វើឱ្យទាហានរាជរដ្ឋាភិបាលនៅក្នុងបន្ទាយនោះ រត់ខ្ចាត់ខ្ចាយ និងដណ្តើមកាំភ្លើងបានប្រមាណ១០ ដើម។

ចំណែក នៅបន្ទាយថ្វាក ដែលឋិតនៅខាងជើងភ្នំវាយចាប ពួកឧទ្ទាមខ្មែរក្រហម បានបើកការវាយប្រហារ និងសម្លាប់ទាហានរាជរដ្ឋាភិបាល បានមួយចំនួនទៀត។ ជាមួយគ្នានោះ ពួកឧទ្ទាមខ្មែរក្រហម បានកៀរអ្នកស្រុកប្រមាណ៥០០គ្រួសារ ឱ្យទៅរស់នៅក្នុងព្រៃជាមួយពួកគេ។

នៅចុងខែមករា ឆ្នាំ១៩៦៨ ដោយសារការរំជើបរំជួលនេះ នៅក្នុងរយៈពេលមិនដល់មួយឆ្នាំផង សម្តេចសីហនុ ក៏បានផ្លាស់ប្តូរចៅហ្វាយខេត្តបាត់ដំបង ជាលើកទី២ទៀត ហើយព្រះអង្គបានតែងតាំងឧត្តមសេនីយ៍ឯក លន់ នល់ ជានាយអគ្គត្រួតពិនិត្យទាហាន និងប៉ូលិស ព្រមទាំងឱ្យមានឋានៈស្មើរដ្ឋមន្ត្រី ផងដែរ។

នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៦៨ សម្តេចសីហនុ បានរអ៊ូរទាំដាក់ពួកមេទាហានរបស់ព្រះអង្គថា មិនគួរណាបណ្តែតបណ្តោយឱ្យពួកឧទ្ទាមខ្មែរក្រហម វាយប្រហារស្ទើរតែពាសពេញខេត្តបាត់ដំបង យ៉ាងនេះសោះ។

ក្រោយមក ពួកមេទាហានរបស់ព្រះអង្គបានរាយការណ៍ថា នៅភាគខាងត្បូងខេត្តបាត់ដំបង ពួកឧទ្ទាមខ្មែរក្រហម មានកងទ័ពប្រមាណ៥០០នាក់ ក្នុងនោះមាន២០០នាក់









**នាយទាហាន និងប្រជាពលរដ្ឋ ដែលត្រូវពួកខ្មែរក្រហមបាញ់សម្លាប់ និងរងរបួស**

ជាកម្លាំងប្រដាប់អាវុធ ហើយជំរំពួកឧទ្ទាមខ្មែរក្រហមជាច្រើនត្រូវបានសាងសង់ឡើង ក្នុងនោះក៏មានកន្លែងលាក់សម្ភារៈព័ស្តុភារ ប្រមាណ១៥កន្លែងផងដែរ។

ដោយសារការប្រយុទ្ធតស៊ូដោយអាវុធ របស់ពួកខ្មែរក្រហមនៅបាយដំរាំ ធ្វើឱ្យកក្រើកពេញផ្ទៃប្រទេសនោះហើយ ទើបក្រោយមក មេដឹកនាំខ្មែរក្រហមក៏បានជ្រើសរើសយកថ្ងៃទី ១៧ ខែមករា ឆ្នាំ១៩៦៨ នោះ ធ្វើជាថ្ងៃកំណើតនៃការបង្កើតកងទ័ពបដិវត្តន៍របស់ពួកគេ។

# ២២១
# បេះដូងក្រហមរបស់យុវជនដាំ ផេង



**ខ្លោងទ្វារវត្តសារាវ័នតេជោ សាងសង់ក្នុងឆ្នាំ១៩៣២**

នៅក្នុងឆ្នាំ១៩៧៣ ពេលកំពុងធ្វើសង្គ្រាមផ្តួលរម្លំរបបសាធារណរដ្ឋខ្មែរ ទស្សនាវដ្តី យុវជន យុវនារី របស់ពួកមេដឹកនាំខ្មែរក្រហម បានផ្សព្វផ្សាយពីវីរភាពតស៊ូរបស់យុវជនម្នាក់ ឈ្មោះ ដាំ ផេង មានខ្លឹមសារដើមទាំងស្រុងដូចខាង ក្រោម ៖

យុវជន ដាំ ផេង បានចាប់កំណើត ក្នុងគ្រួសារកសិករក្រីក្រមួយ នៅឃុំព្រៃឃ្នេស ស្រុកបាភ្នំ ខេត្តព្រៃវែង (សព្វថ្ងៃឃុំព្រៃឃ្នេស ស្ថិតនៅក្នុងស្រុកមេសាង)។

គ្រួសារ ដាំ ផេង មានជីវភាពលំបាកវេទនាបំផុត។ ការហូបចុកពុំគ្រប់គ្រាន់ សម្លៀកបំពាក់ក៏ខ្វះខាត។ ពេលឈឺគ្មានថ្នាំសង្កូវសម្រាប់ព្យាបាល បណ្តាលឱ្យបងប្អូនប្រុសស្រីរបស់ ដាំ ផេង ត្រូវស្លាប់ជាបន្តបន្ទាប់។ មិនយូរប៉ុន្មាន ឪពុកម្តាយដាំ ផេង ក៏ឈឺ និងស្លាប់ទៀត។ ទីបំផុត គ្រួសារមួយនេះ នៅសល់តែមនុស្សពីរនាក់ គឺបងស្រីគាត់ម្នាក់ និងដាំ ផេង ម្នាក់ ប៉ុណ្ណោះ។

ពេលនោះ ដាំ ផេង មានអាយុប្រហែល៧ ឬ៨ឆ្នាំ។ ឯបងស្រីគាត់ ទើបពេញវ័យជំទង់ ត្រូវធ្លាក់ខ្លួនជាក្មេងកំព្រា គ្មានទីពឹង។ បងស្រីគាត់ត្រូវបានប្រជាជនក្នុងភូមិយកទៅចិញ្ចឹម។

ចំណែក ដាំ ផេង ត្រូវបានព្រះសង្ឃយកទៅចិញ្ចឹមនៅវត្ត ឲ្យបានរៀនសូត្រអក្សរលេខនព្វន្ត នឹងគេ។

ក្នុងអំឡុងពេលស្នាក់នៅវត្តនោះ ក្រៅពីកិច្ចការបម្រើព្រះសង្ឃ ដាំ ផេង ជាក្មេងម្នាក់ មានបញ្ញាស្មារតីវាងវៃក្នុងការៀនសូត្រ គួរឱ្យកោតសរសើរ។

ក្រោយរៀនចប់សាលាបឋមសិក្សានៅស្រុកកំណើត ដោយឃើញ ដាំ ផេង មានបញ្ញាស្មារតីវាងវៃក្នុងការរៀនសូត្រ ព្រះសង្ឃដែលជាអ្នកយកគាត់ទៅជួយចិញ្ចឹមឱ្យរៀនសូត្រនោះ ក៏បាននាំ ដាំ ផេង ទៅទីក្រុងភ្នំពេញ យកទៅផ្ញើនឹងព្រះសង្ឃនៅវត្តសារាវ័នតេជោ ដើម្បីឲ្យបន្តការសិក្សាទៅមុខទៀត។

ពេលនោះ ឆ្នាំ១៩៦១ ដាំ ផេង វ័យជំទង់ បានប្រលងចូលរៀនថ្នាក់ទី៦ទំនើបជាតិ នៅវិទ្យាល័យព្រះយុគន្ធរ។ ពេលស្នាក់នៅបន្តការសិក្សាក្នុងវត្តសារាវ័នតេជោ នោះ គាត់ត្រូវគិតគូរដោះស្រាយជីវភាពដោយខ្លួនឯងទាំងអស់ ព្រោះក្នុងសង្គមពួកសក្តិភូមិ គ្មានគិតគូរជួយឧបត្ថម្ភអ្វីដល់ការសិក្សារបស់សិស្សក្រីក្របន្តិចឡើយ។

ពួកវាមានតែពង្វក់បំពុលយុវជនឲ្យភ្លើតភ្លើនទៅតាមមនោគមវិជ្ជា,ទៅតាមវប្បធម៌របស់ពួកវា ដើម្បីកុំកូនចៅប្រជាជនក្រីក្របានរៀនសូត្រដូចកូនចៅពួកវា។ ម្ល៉ោះហើយ យុវជន ដាំ ផេង ក៏ដូចជាយុវជនជាកូនចៅអ្នកក្រីក្រផ្សេងទៀតដែរ បើចង់បន្តការសិក្សាទៅមុខ ត្រូវបង្ខំចិត្តឆ្លៀតពេលលក់កម្លាំងពលកម្មឲ្យពួកសក្តិភូមិម្ចាស់ដី ពួកនាយទុន ពេលសម្រាកពីការរៀនសូត្រ ដើម្បីបានប្រាក់បន្តិចបន្តួច គ្រាន់ទិញសៀវភៅរៀន, ទិញខោអាវស្លៀកពាក់ និងទិញម្ហូបចំណីខ្លះៗ។

យុវជន ដាំ ផេង រៀនពេលថ្ងៃនៅសាលា ពេលយប់ត្រូវឆ្លៀតលក់នំប៉័ង ឬដួលស៊ីក្លូគេរត់ គ្រាន់បានកម្រៃខ្លះផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ។ ពេលបុណ្យទាន ឬវិស្សមកាលដែលជាពេលឈប់សម្រាកយូរថ្ងៃ គាត់ទៅស៊ីឈ្នួលរែកកំបោរ រែកឥដ្ឋនៅការដ្ឋានសំណង់ផ្សេងៗ ជាមួយកម្មករឯទៀតៗ។

ទស្សនាវដ្តីយុវជន-យុវនារីបដិវត្តន៍ របស់បក្សកុម្មុយនិស្តកម្ពុជា បានសរសេរបញ្ជាក់

ថា៖ ណាមួយត្រូវខំរៀនឲ្យទាន់គេនៅសាលាផង ណាមួយខំដើរស៊ីឈ្នួលគេចិញ្ចឹមជីវិតផង ម៉្លោះហើយ ដាំ ផេង ត្រូវហត់នឿយទាំងផ្លូវកាយចិត្ត និងបញ្ញាទាំងយប់ទាំងថ្ងៃ គ្មានពេលសម្រាកឡើយ។

ដោយសារការហត់នឿយហួសកម្លាំង ការហូបចុកក៏ខ្វះខាត ហើយដេកមិនបានគ្រប់គ្រាន់ទៀត ម្នាក់ៗទម្រាំបានសញ្ញាបត្រឌីប្លូម បាក់អង ឬបាក់ឱបមួយសន្លឹកៗ សិស្សៗជាកូនចៅអ្នកក្រីក្រ ត្រូវខូចខ្លួនប្រាណអស់។ ខ្លះរបេងស៊ីសួត ខ្លះទៀតទៅជាឆ្កួតឡប់សតិ សុខភាពចុះខ្សោយរហូត។

នៅក្នុងឆ្នាំ១៩៦០ អង្គការយុវជនបដិវត្តន៍ ដែលនៅពេលនោះមានឈ្មោះថា សម្ព័ន្ធយុវជនកម្ពុជាប្រជាធិបតេយ្យ (យុវកប) បានចាប់បដិសន្ធិឡើងក្រោមការដឹកនាំរបស់អង្គការបដិវត្តន៍កម្ពុជា ចលនាតស៊ូរបស់យុវជននៅទីក្រុងភ្នំពេញ ក៏ចាប់ផ្ដើមផុលផុសក្រើករំពើតឡើងដែរ។

នៅក្នុងឆ្នាំ១៩៦១ យុវជន ដាំ ផេង ក៏បានចូលរួមក្នុងអង្គការយុវជនកម្ពុជាប្រជាធិបតេយ្យ (យុវកប)នេះដែរ។ ចាប់ពីពេលនោះមក ដាំ ផេង បានទទួលការអប់រំថែបំប៉នទាំងនយោបាយសតិអារម្មណ៍ និងចាត់តាំងបដិវត្តន៍ពីអង្គការបដិវត្តន៍ ជាប់រហូតមក។

យុវជន ដាំ ផេង ចាប់ផ្ដើមភ្លឺភ្នែក ហើយមើលឃើញវែងឆ្ងាយច្បាស់លាស់ជាងឆ្លុះកែវយឹតទៅទៀត។ គាត់ឃើញទុក្ខលំបាកវេទនារបស់ប្រជាជន ក្រោមការជិះជាន់ដ៏សែនធ្ងន់ធ្ងររបស់ពួកចក្រពត្តិអាមេរិក ពួកសក្តិភូមិ នាយទុន និងមើលឃើញច្បាស់នូវគ្រោះអាសន្នដែលប្រទេសជាតិគាត់ កំពុងស្ថិតនៅក្រោមការគំរាមកំហែងរបស់ចក្រពត្តិអាមេរិក ជារៀងរាល់ថ្ងៃ។

នៅតាមព្រំដែន ឈាមប្រជាជនកម្ពុជាប្រុសស្រីក្មេងចាស់ត្រូវហូររាល់ថ្ងៃ ដោយសារអំពើឈ្លានពានរបស់ចក្រពត្តិអាមេរិក ព្រមទាំងក្រុងព្រៃនគរ និងបាងកក ជាបរិវារ ទាំងតាមជើងគោក ជើងអាកាស។

សម្រែកមាតុភូមិជាទីស្នេហា ដង្ហើយហៅកុលបុត្រកុលធីតាឲ្យក្រោកឈរឡើងការពារទឹកដីបានលាន់ឮរំពងដល់បេះដូងដ៏ក្មេងខ្ចី និងបរិសុទ្ធរបស់យុវជន ដាំ ផេង និងយុវជន-

យុវនារីកម្ពុជា ឯទៀតទាំងអស់។

យុវជនដាំ ផេង ចាប់ផ្តើមពិចារណាថា អាត្មាខ្លួន ដែលបានខិតខំចំណាយពេលវេលា ចំណាយកម្លាំងកាយចិត្តគំនិតបញ្ញា និងចំណាយយុវវ័យរបស់ខ្លួនយ៉ាងពេញទំហឹងសព្វថ្ងៃនេះ ដើម្បីបានសញ្ញាបត្រ,បុណ្យសក្តិ, លាភសក្ការៈផ្ទាល់ខ្លួនទៅថ្ងៃក្រោយទៀតនោះ គឺជាការឥតប្រយោជន៍ ព្រោះគ្មានបានបម្រើប្រទេសជាតិ គ្មានបានផលអ្វីដល់ប្រជាជនបន្តិចសោះ ហើយផ្ទុយទៅវិញតម្រិះវិជ្ជា និងការយល់ដឹងរបស់ខ្លួននេះ វាគ្រាន់តែជាការបម្រើពួកចក្រពត្តិនិយមពួកសក្តិភូមិ នាយទុន ដើម្បីជិះជាន់ប្លន់កាប់សម្លាប់ប្រជាជនឯងតែប៉ុណ្ណោះ។

ដោយសារអង្គការបដិវត្តន៍ ជាអ្នកឃោសនាអប់រំណែនាំ យុវជន ដាំ ផេង ក៏ដូចជាយុវជន យុវនារីផ្សេងទៀតដែរ បានភ្ញាក់ខ្លួនទាន់ពេលវេលា នាំគ្នាបង្វែរសកម្មភាពរបស់ខ្លួនទាំងអស់ទៅជាសកម្មភាពបម្រើប្រទេសជាតិ បម្រើប្រជាជន និងបម្រើវណ្ណៈក្រីក្រវិញ។

នៅវិទ្យាល័យព្រះយុគន្ធរ ក៏ដូចនៅវិទ្យាល័យ អនុវិទ្យាល័យផ្សេងៗទៀតនៅក្នុងទីក្រុងភ្នំពេញ ដែរ យុវជន ដាំ ផេង ដែលមានអាកប្បកិរិយាស្លូតបូត និងសុភាពរាបសាបានប្រាស្រ័យទាក់ទង ជិតស្និទ្ធជាមួយយុវជន-យុវនារីឯទៀត ទាំងអស់។

ទស្សនាវដ្តីរបស់បក្សកុម្មុយនិស្តកម្ពុជា ដដែលនោះ បានសរសេរបន្តថា ចុងឆ្នាំ១៩៦៣ និងដើមឆ្នាំ១៩៦៤ ចក្រពត្តិអាមេរិក និងបរិវារក្រុងព្រៃនគរ-បាងកក បានធ្វើការគំរាមកំហែង និងគាបសង្កត់យ៉ាងខ្លាំងមកលើឯករាជ្យភាព សន្តិភាព អព្យាក្រឹតភាព និងបូរណភាពដែនដីនៃកម្ពុជា។ ពេលនោះ ប្រទេសកម្ពុជា ស្ថិតនៅចំពោះមុខគ្រោះអាសន្ននៃរដ្ឋប្រហារយោធារបស់ឆ្កែចក្រពត្តិអាមេរិក ដែលមានអាលន់ នល់ ជាមេខ្លោង។

តែពួកវណ្ណៈកាន់អំណាចជំនាន់នោះ (សម្តេចសីហនុ) បែរជាចង់សារភាពសម្រុះសម្រួលជាមួយចក្រពត្តិអាមេរិក និងបរិវារ ដើម្បីសុំសេចក្តីសុខសាន្តពីពួកវាទៅវិញ ទោះបីប្រទេសជាតិធ្លាក់ទៅជាខ្ញុំគេ ក៏គេមិនខ្មាសអៀនដែរ។ ដូច្នេះអង្គការបដិវត្តន៍កម្ពុជា ក្នុងឋានៈជាអ្នកតំណាង និងការពារផលប្រយោជន៍ប្រទេសជាតិ និងប្រជាជនកម្ពុជាទាំងមូល បានដឹកនាំប្រជាជន យុវជន-យុវនារីនៅទូទាំងប្រទេស ឱ្យក្រោកឡើងធ្វើការតស៊ូតាមគ្រប់រូបភាព

ប្រឆាំងចក្រពត្តិអាមេរិក និងបរិវារ ហើយគាបសង្កត់ និងអូសទាញអ្នកកាន់អំណាចជំនាន់នោះ (សម្តេចសីហនុ) កុំឲ្យសារភាពជាមួយខ្មាំង។

ក្រោមការដឹកនាំដ៏ភ្លឺស្វាង របស់អង្គការបដិវត្តន៍ យុវជន ដាំ ផេង បានចុះប្រលូកឃោសនាអប់រំបកអាក្រាតនូវឧបាយកល និងបទឧក្រិដ្ឋរបស់ចក្រពត្តិអាមេរិក និងបរិវារក្រុងព្រៃនគរ-បាងកក ដែលប៉ុនប៉ងសម្លាប់ឯករាជ្យ សន្តិភាព អព្យាក្រឹតភាពនៃកម្ពុជាយើងយ៉ាងក្លៀវក្លាអង់អាចបំផុត រួមមានៈ ចលនាបាចខិត្តប័ណ្ណ, ចលនាបាតុកម្ម កូដកម្ម និងមីទ្ទីញជាដើម រហូតដល់ពួកវណ្ណៈកាន់អំណាច(សម្តេចសីហនុ) បង្ខំចិត្តទាត់ចោលជំនួយដ៏មានពិសពុលរបស់ចក្រពត្តិអាមេរិក ទាំងសោកស្តាយនៅខែវិច្ឆិកា ឆ្នាំ១៩៦៣។ នេះជាជ័យជម្នះដ៏ត្រចះត្រចង់មួយរបស់ប្រជាជន យុវជន-យុវនារីយើង ក្រោមការដឹកនាំដ៏ភ្លឺស្វាងរបស់អង្គការបដិវត្តន៍កម្ពុជា។

តាមការណែនាំរបស់អង្គការបដិវត្តន៍ នៅក្នុងខែមករា ឆ្នាំ១៩៦៤ យុវជន ដាំ ផេង បានចូលរួមដឹកនាំបំផុសចលនាយុវជននៅតាមសាលា ឱ្យធ្វើកូដកម្ម ធ្វើបាតុកម្ម ធ្វើមីទ្ទីញនៅវាលព្រះមេរុ នៅមុខវាំង និងនៅមុខរដ្ឋសភា ដើម្បីស្រែកបកអាក្រាតផែនការ និងសកម្មភាពឧក្រិដ្ឋរបស់ចក្រពត្តិអាមេរិក និងបរិវារ ដែលប៉ុនប៉ងសម្លាប់ឯករាជ្យ សន្តិភាព អព្យាក្រឹតនៃកម្ពុជា និងអំពើជ្រៀតជ្រែកឈ្លានពានរបស់វាដែលបាញ់រះទម្លាក់គ្រាប់បែកទៅលើភូមិក ទ្រព្យសម្បត្តិផលដំណាំ និងសម្លាប់ប្រជាជនស្លូតត្រង់ទាំងប្រុសស្រីក្មេងចាស់នៅតាមព្រំដែន ជារៀងរាល់ថ្ងៃ ហើយទាមទារឱ្យពួកវណ្ណៈកាន់អំណាច(សម្តេចសីហនុ)ជំនាន់នោះ ផ្តាច់ចំណងការទូតជាមួយចក្រពត្តិអាមេរិក និងបរិវារទាំងអស់។ តែពួកវណ្ណៈកាន់អំណាចប្រតិកិរិយា (សម្តេចសីហនុ) វាមិនត្រឹមតែមិនគោរពតាមសំណូមពររបស់ប្រជាជនយុវជនយើងប៉ុណ្ណោះទេ គឺវាថែមទាំងបង្កើនសកម្មភាពតាមដានលួចចាប់សម្លាប់បំបាត់ដានគំរាមកំហែងសន្តិសុខដល់ប្រជាជនយុវជន-យុវនារីស្នេហាជាតិយើងទៀតផង។

ទោះបីយ៉ាងនេះក៏ដោយ អង្គការយុវជនកម្ពុជាប្រជាធិបតេយ្យ( យុវកប )នៅតែបន្តដឹកនាំចលនាតស៊ូនៅក្នុងទីក្រុងភ្នំពេញតាមគ្រប់រូបភាព និងតាមលទ្ធភាពយ៉ាងឈ្លាសវៃប៉ិន

ប្រសប់ និងអង់អាចក្លៀវក្លាបំផុត ដោយដឹកនាំបំផុសឱ្យយុវជន-យុវនារីជាសិស្សនិស្សិត ចូលរួមធ្វើកូដកម្ម បាតុកម្ម ធ្វើមីទ្ទីញតូចមធ្យមធំ ប្រឆាំងចក្រពត្តិអាមេរិក និងបរិវារ ជាបន្ត បន្ទាប់នៅតាមអនុវិទ្យាល័យ, វិទ្យាល័យ និងមហាវិទ្យាល័យ ពាសពេញទីក្រុងភ្នំពេញ។

រហូតដល់ខែមីនា ឆ្នាំ១៩៦៤ ក្រោមការដឹកនាំរបស់អង្គការបដិវត្តន៍ មហាបាតុកម្ម បាតុយ៉ាងសម្បើមអស្ចារ្យមួយ បានផ្ទុះឡើងដូចភ្នំភ្លើងនៅកណ្តាលទីក្រុងភ្នំពេញ វាយកម្ទេច ស្ថានទូតចក្រពត្តិអាមេរិក ខ្ទេចខ្ទីអស់គ្មានសល់។

នេះជាមហាជ័យជម្នះរបស់យើងមួយទៀត ដែលល្បីខ្ទរខ្ទារនៅទូទាំងសកលលោក ធ្វើឲ្យចក្រពត្តិអាមេរិក និងបរិវារ អាម៉ាស់មុខយ៉ាងខ្លាំង។ បន្ទាប់ពីមហាបាតុកម្មដ៏កក្រើក នេះមក ទោះបីពួកវណ្ណៈកាន់អំណាច(សម្តេចសីហនុ) បង្កើនកម្មភាពតាមដាន សម្លុត គំរាម ចាប់ចងអ្នកស្នេហាជាតិកាន់តែខ្លាំងឡើងៗយ៉ាងណា ក៏ចលនាតស៊ូរបស់យុវជន-យុវនារី យើងនៅតែមានសន្ទុះឆាបឆេះសន្ធោសន្ធៅឡើងៗ ហើយរាលដាលពីទីក្រុងភ្នំពេញ រហូតដល់ ទីរួមខេត្តនានាទូទាំងប្រទេស។

ពេលនោះ អង្គការបដិវត្តន៍បានអំពាវនាវដល់កម្មាភិបាល និងយុវជនបដិវត្តន៍មួយចំនួន ឲ្យលះបង់ការសិក្សា ដើម្បីចេញទៅដឹកនាំអង្គការយុវជនបដិវត្តន៍ និងចលនាតស៊ូយុវជន ជាសិស្សនិស្សិត ដែលកំពុងតែផុលផុសសម្បើមអស្ចារ្យ។

ពេលនោះ នៅចុងឆ្នាំ១៩៦៥ យុវជន ដាំ ផេង កំពុងរៀនថ្នាក់ទី២ទំនើបជាតិ នៃវិទ្យា ល័យព្រះយុគន្ធរ បានសម្រេចចិត្តបោះបង់ការសិក្សា ហើយស្ម័គ្រចិត្តដោយរីករាយក្នុងសកម្ម ភាពដឹកនាំចលនាតស៊ូរបស់អង្គការយុវជន កម្ពុជាប្រជាធិបតេយ្យ(យុវកប) តាមការអំពាវនាវ របស់អង្គការបដិវត្តន៍ ។

មិនយូរប៉ុន្មាន ដោយពិនិត្យឃើញស្មារតីអង់អាចក្លាហានសកម្មប្រយុទ្ធ ស្មារតីលះបង់ ទ្រាំទ្រការលំបាកគ្រប់បែបយ៉ាង និងគោលជំហរប្រយុទ្ធដាច់ខាត ដាំ ផេង ត្រូវបានអង្គការ បដិវត្តន៍ប្រគល់តួនាទីជាលេខាសម្ព័ន្ធយុវកប(យុវជនកម្ពុជាប្រជាធិបតេយ្យ)ប្រចាំទីក្រុង ភ្នំពេញ។

## របត់នយោបាយ

ក្រោយពីមាននាទីជាលេខាសម្ព័ន្ធយុវកប (យុវជនកម្ពុជាប្រជាធិបតេយ្យ) ទីក្រុងភ្នំពេញមក មិត្តដាំ ផេង ត្រូវលាក់ខ្លួនរស់នៅក្នុងបន្ទប់បួនជ្រុងតូចមួយ មិនអាចដើរហើរទៅណាផ្ដេសផ្ដាសបានដូចមុនឡើយ។ តែមិត្តគ្មានធុញថប់អ្វីដែរ។ ផ្ទុយទៅវិញ គាត់សំងំខិតខំរៀនសូត្រលត់ដំហ្វឹកហ្វឺនខ្លួនក្នុងចលនាតស៊ូ ដើម្បីកសាងគោលជំហរនយោបាយ សតិអារម្មណ៍ចាត់តាំងបដិវត្តន៍ឲ្យដល់ខ្លួនមិត្តជាលំដាប់។

ព្រមជាមួយគ្នានោះ មិត្តដាំ ផេង បានដឹកនាំពង្រឹងពង្រីក និងកែលម្អការដឹកនាំគ្រប់-គ្រងរបស់អង្គការយុវជនបដិវត្តន៍ដោយស្មារតីម្ចាស់ការច្នៃប្រតិដ្ឋ និងទទួលខុសត្រូវខ្ពស់ចំពោះបដិវត្តន៍ និងប្រជាជនជានិច្ច។

ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់អង្គការបដិវត្តន៍កម្ពុជា ទាំងនៅទីក្រុង និងទីប្រជុំជនផ្សារ ទាំងនៅជនបទស្រែចម្ការចុងកាត់មាត់ញក ភ្លើងកំហឹងជាតិទាមទារឲ្យកាត់ផ្ដាច់ចំណងការទូតជាមួយចក្រពត្តិអាមេរិក និងបរិវារ លាន់ឮកងរំពងពុះកញ្ជ្រោលកាន់តែខ្លាំងឡើងៗនៅទូទាំងប្រទេស ធ្វើឲ្យចក្រពត្តិអាមេរិក និងបរិវារ មានការព្រួយបារម្ភជាខ្លាំង និងរឹតតែភ័យញ័ររន្ធត់នៅចំពោះមុខចលនាតស៊ូរបស់ប្រជាជន យុវជន-យុវនារីយើង។

ពេលនោះ ពួកវណ្ណៈកាន់អំណាច (សម្ដេចសីហនុ) ក៏មានការភិតភ័យ ហើយខិតខំរកគ្រប់វិធីទាំងក្ដៅទាំងត្រជាក់ ដើម្បីពន្លត់ភ្លើងកំហឹងជាតិនេះដែរ តែមិនអាចពន្លត់បាន។ ភ្លើងកំហឹងជាតិនេះកាន់តែឆាបឆេះសន្ធោសន្ធៅខ្លាំងឡើងៗ រហូតដល់ខែមេសា ឆ្នាំ ១៩៦៥ ពួកវណ្ណៈកាន់អំណាចត្រូវបង្ខំចិត្តកាត់ផ្ដាច់ចំណងការទូតជាមួយចក្រពត្តិអាមេរិក និងបរិវារទាំងអស់ ដោយក្ដីអាឡោះអាល័យបំផុត។

ក្រោយចក្រពត្តិអាមេរិក និងបរិវារ ត្រូវបរាជ័យយ៉ាងធ្ងន់ធ្ងរ និងយ៉ាងអាម៉ាស់បំផុតនៅកម្ពុជាមក ពួកវាខិតខំរិះរកឧបាយកលពិសពុលខ្មៅងងឹត ដោយសហការជាមួយពួកអាវណ្ណៈកាន់អំណាចប្រតិកិរិយាជាសម្ងាត់ ដើម្បីកម្ទេចចលនាស្នេហាជាតិទាំងអស់។ ដូច្នេះហើយបានជានៅចុងឆ្នាំ ១៩៦៦ ក្រោមការញ៉ាក់ខ្សែរបស់សេអ៊ីអា ពួកវាបានបង្កើតរដ្ឋសភាយោរយៅហ្វាស៊ីសមួយឡើង នៅទីក្រុងភ្នំពេញ។

ក្រោយពេលបង្កើតឱ្យមានរដ្ឋសភាក្បត់ជាតិនេះភ្លាម ពួកវាបានតែងតាំងអាលន់ នល់ ឲ្យធ្វើជានាយករដ្ឋមន្ត្រី ក្រោមកិច្ចបញ្ជារបស់ចក្រពត្តិអាមេរិក តែម្តង។ នេះជារដ្ឋប្រហារស្រប ច្បាប់មួយ ដែលចក្រពត្តិអាមេរិក-បរិវារ ធ្វើឡើង ដើម្បីឱ្យពួកអាក្បត់លន់ នល់ ដណ្តើម អំណាចត្រួតត្រាគ្រប់គ្រងប្រទេសកម្ពុជាយើង។ ពេលបានឡើងកាន់អំណាចភ្លាម រដ្ឋាភិបាល ក្បត់ជាតិនេះ ក៏ចាប់ផ្តើមធ្វើសកម្មភាពបង្ករឿងហេតុ ធ្វើទុក្ខបុកម្នេញ និងបង្ក្រាបរាតត្បាត ចាប់ចងកាប់សម្លាប់ប្រជាជនស្លូតត្រង់ និងអ្នកស្នេហាជាតិដោយទ្រង់ទ្រាយធំភ្លាមៗដែរ។

នៅក្នុងខែមីនា ឆ្នាំ១៩៦៧ ពួកវាបានបង្កសង្គ្រាមផ្ទៃក្នុងឱ្យឆេះសន្ធោសន្ធៅនៅខេត្ត បាត់ដំបង តាមបញ្ជារបស់ចក្រពត្តិអាមេរិក ទាំងស្រុង។ តែអង្គការបដិវត្តន៍កម្ពុជា ដ៏អង់ អាចក្លាហាន និងឈ្លាសវៃបានបំផុសចលនាតស៊ូនយោបាយយ៉ាងគគ្រឹកគគ្រេងនៅទូទាំង ប្រទេស ដើម្បីទប់ទល់ និងវាយបំបាក់ផែនការឧក្រិដ្ឋនេះ។

ពិសេស នៅដើមខែឧសភា ឆ្នាំ១៩៦៧ ចលនាតស៊ូរបស់យុវជន-យុវនារីនៅទីក្រុង ភ្នំពេញ ដែលនៅជាប់នឹងក្បាលម៉ាស៊ីនដឹកនាំរបស់ពួកខ្មាំង បានបកអាក្រាត និងវាយបំបែក ផែនការឧក្រិដ្ឋរបស់ចក្រពត្តិអាមេរិក និងបរិវារ ព្រមទាំងពួកអាក្បត់ លន់ នល់ ឱ្យបរាជ័យ យ៉ាងអាម៉ាស់មួយលើកទៀត។

តែពួកវណ្ណៈកាន់អំណាចប្រតិកិរិយាក្បត់ជាតិ ក្រោមបញ្ជារបស់ចក្រពត្តិអាមេរិក នៅតែ រិះរកវិធី និងឧបាយកលផ្សេងទៀត ដើម្បីពន្លត់ភ្លើងកំហឹងជាតិ និងភ្លើងកំហឹងវណ្ណៈ ដែល កំពុងតែឆាបឆេះយ៉ាងខ្លាំងនោះ រួចឈានទៅកម្ទេចកម្លាំងបដិវត្តន៍ស្នេហាជាតិទាំងអស់តែ ម្តង។ ដូច្នេះ វាក៏ចាប់ផ្តើមអនុវត្តនយោបាយហ្វាស៊ីសភាវូបនីយកម្ម និងពាលាភាវូបនីយកម្ម យ៉ាងសកម្មទាំងនៅទីក្រុង ទាំងនៅជនបទស្រែចម្ការចុងកាត់មាត់ញក។ តែអង្គការបដិវត្តន៍ បានដឹកនាំប្រជាជន យុវជន-យុវនារី វាយកម្ទេចនយោបាយឧក្រិដ្ឋទាំង៣ខាងលើនេះដោយ ជោគជ័យ។

# ២២២
# ដាំ ផេង ស៊ូស្លាប់ដើម្បីបុព្វហេតុបដិវត្តន៍



**ទង់បក្សកុម្មុយនិស្ត(រូបកណ្ដៀវតំណាងឱ្យវណ្ណៈកសិករ និងរូបញញួរតំណាងឱ្យវណ្ណៈកម្មករ)**

នៅដើមឆ្នាំ១៩៦៨ ពួកខ្មាំងបានបង្កសង្គ្រាមផ្ទៃក្នុងជាថ្មីម្ដងទៀត ប៉ុនប៉ងកម្ទេចកម្លាំងបដិវត្តន៍ និងចលនាតស៊ូស្នេហាជាតិទាំងអស់ក្នុងរយៈពេលតែមួយព្រឹបប៉ុណ្ណោះ។ តែអង្គការបដិវត្តន៍ដ៏ឈ្លាសវៃ បានដឹកនាំតស៊ូធ្វើសង្គ្រាមបដិវត្តន៍ ដើម្បីប្រឆាំងតបតវិញ ហើយការតស៊ូ ធ្វើសង្គ្រាមបដិវត្តន៍វាយសម្រុកទៅលើខ្មាំងវិញនេះ បានរីករាលដាលពីខេត្តមួយឆ្លងទៅខេត្តមួយ យ៉ាងឆាប់រហ័ស។

នៅភ្នំពេញ អង្គការបដិវត្តន៍បានបំផុស និងដឹកនាំចលនាតស៊ូនយោបាយតទៅទៀតតាមគ្រប់រូបភាព ទាំងចំហស្របច្បាប់ ទាំងពាក់កណ្ដាលចំហ ពាក់កណ្ដាលស្របច្បាប់ ទាំងសម្ងាត់ ពាសពេញទីក្រុង។ តែពួកខ្មាំង ក៏បានបង្កើននយោបាយហ្វាស៊ីសភាវូបនីយកម្មដល់កម្រិតខ្ពស់បំផុត ដោយដុតបំផ្លាញខ្មែច ចាប់ខ្មែច សម្លាប់ខ្មែច ដោយគ្មានរើសមុខ ឬជំនុំជម្រះឡើយ ហើយបានបង្កើនការរាតត្បាតទាំងយប់ទាំងថ្ងៃ ដោយទ្រង់ទ្រាយធំទៀតផង។

ទោះបីមានគ្រោះថ្នាក់ដល់អាយុជីវិតយ៉ាងណាក៏ដោយ ក៏មិត្តដាំ ផេង និងអ្នកតស៊ូ

យើងទាំងអស់នៅទីក្រុងភ្នំពេញ នៅតែពុះពារគ្រប់ឧបសគ្គប្រយុទ្ធបំពេញភារកិច្ចដែលអង្គការបដិវត្តន៍ប្រគល់ឲ្យ បានជាប់ជានិច្ច។

តែជាអកុសល នៅក្នុងខែសីហា ឆ្នាំ១៩៦៨ ក្នុងពេលកំពុងបំពេញភារកិច្ចដ៏រុងរឿងរបស់ខ្លួន នៅក្នុងទីក្រុងភ្នំពេញ មិត្តដាំ ផេង ត្រូវពួកខ្មាំងចាប់ខ្លួនបាន។ ពួកអាក្បត់ខ្ញុំកញ្ជះដាច់ថ្លៃរបស់ចក្រពត្តិអាមេរិក វាគ្មានសង្ស័យអ្វីឡើយ ព្រោះវាធ្លាប់ស្គាល់មុខស្គាល់ឈ្មោះ និងស្គាល់ប្រវត្តិតស៊ូរបស់យុវជន ដាំ ផេង កាលនៅជាសិស្សវិទ្យាល័យព្រះយុគន្ធរ ច្បាស់លាស់ណាស់។ ពួកវាគ្មានចាំបាច់សួរបញ្ជាក់អ្វីទៀតទេ។ តែពួកវាចង់ដឹង នរណាខ្លះជាមេដឹកនាំចលនាតស៊ូបដិវត្តន៍នៅខាងលើ។

ដូច្នេះ ពួកវាបានយកមិត្តដាំ ផេង ទៅវាយធ្វើទារុណកម្មយ៉ាងឃោរឃៅព្រៃផ្សៃបំផុត ដើម្បីជំរិតយកចម្លើយ។ នៅចំពោះមុខទារុណកម្មដ៏ព្រៃផ្សៃបំផុតនោះ មិត្តគ្មានភិតភ័យតក់ស្លុតអ្វីបន្តិចឡើយ។ មិត្តគិតថា ជីវិតបដិវត្តរបស់មិត្តត្រូវចប់ត្រឹមនេះ ក៏ពិតមែន តែយុទ្ធមិត្តឯទៀតនឹងបន្តការប្រយុទ្ធកម្ទេចខ្មាំងបន្តទៀតរហូតដល់ទីអវសាន។ មិត្តត្រូវស្លាប់ក្នុងឋានៈរុងរឿងឧដុង្គឧត្តម មិនស្លាប់ក្នុងឋានៈជាជនក្បត់ជាតិ ជាជនកំសាកសារភាពប្រាប់ ខ្មាំង ក្បត់បងប្អូនរួមវណ្ណៈឡើយ។

មិត្តដាំ ផេង ប្តេជ្ញាថា នឹងប្រយុទ្ធជាមួយខ្មាំងរហូតដល់ដង្ហើមចុងក្រោយបំផុត។ គិតដូច្នេះហើយ មិត្តរក្សាជំហរ និងអាកប្បកិរិយានឹងនរ តែមោះមុត ក្នុងឋានៈជាអ្នកវាយ សម្រុកខ្មាំងវិញលើគ្រប់បញ្ហា ហើយមិត្តពើងទ្រូងដើរចូលទៅក្នុងកន្លែងធ្វើទារុណកម្មយ៉ាងអង់អាចក្លាហាន។ ភ្នែកទាំងគូរបស់មិត្តសម្លក់សម្លឹងពួកអាពេជ្ឈឃាដ ដែលនៅរង់ចាំក្នុងកន្លែងធ្វើទារុណកម្មនោះស្ទើរឆ្កុះដល់ឆ្អឹង ដោយក្តីស្អប់ខ្ពើមជាទីបំផុត។

ពេលខ្មាំងចាប់ផ្តើមសួរចម្លើយជាលើកដំបូង មិត្តឆ្លើយតបទៅវាវិញ ដោយភ្លើងកំហឹងពុះពោរពេញឱរ៉ាថា៖ ពួកឯងជាជនក្បត់ជាតិ ជាឆ្កែបម្រើដាច់ថ្លៃរបស់ចក្រពត្តិអាមេរិក។ ពួកអញជាអ្នកស្នេហាជាតិ ជាអ្នកការពារប្រទេសជាតិ ជាអ្នកសង្គ្រោះជាតិ និងរំដោះប្រជាជនឲ្យផុតពីអំពើជ្រៀតជ្រែកឈ្លានពានរបស់ចក្រពត្តិអាមេរិក-បរិវារ និងឲ្យរួចផុតអំពីការជិះជាន់

សង្កត់សង្កិនរបស់ពួកអាវណ្ណៈកាន់អំណាចប្រតិកិរិយាក្បត់ជាតិឯងរាល់គ្នា។ នេះជាព្រំដែនយ៉ាងច្បាស់លាស់ រវាងពួកអាឯង និងពួកអញ។ ដូច្នេះអញគ្មានពាក្យអ្វី និយាយជាមួយពួកឯងរាល់គ្នាទេ។ ចង់ធ្វើអីអញ ធ្វើទៅ មិនបាច់សួរអញច្រើនទេ។

ថាហើយ មិត្តក៏ស្ដោះទឹកមាត់ រួចងាកមុខចេញធ្វើហី លែងនិយាយឆ្លងឆ្លើយជាមួយពួកវារហូត។ ខ្មាំងចាប់ផ្ដើមធ្វើទារុណកម្មយ៉ាងព្រៃផ្សៃលើរាងកាយមិត្តទាំងយប់ទាំងថ្ងៃជាប់គ្នាបីយប់បីថ្ងៃ។ មិត្តខាំមាត់សង្កត់ចិត្ត គ្មានស្រែកថ្ងូរអ្វីមួយអ៊ឺះ ឡើយ។ ក្នុងមួយថ្ងៃៗ មិត្តត្រូវពួកវាវាយបញ្ច្រកទឹកសាប៊ូ និងទឹកត្រី សន្លប់បាត់ស្មារតីច្រើនដងរាប់មិនអស់។ តែពេលដឹងខ្លួនឡើងវិញ មិត្តតែងតែស្រែកបកអាក្រាត និងប្រកាសថ្កោលទោសឧក្រិដ្ឋទៅលើនយោបាយ និងសកម្មភាពជ្រៀតជ្រែកឈ្លានពានបំផ្លិចបំផ្លាញរបស់ចក្រពត្តិអាមេរិក និងបរិវារ ដើម្បីប៉ុនប៉ងសម្លាប់ឯករាជ្យ សន្តិភាព អព្យាក្រឹតរបស់កម្ពុជា ព្រមទាំងប្រកាសថ្កោលទោសពួកអាក្បត់ លន់ នល់ សិរិមតៈ ដែលជាអ្នកបម្រើចក្រពត្តិអាមេរិក ក្នុងការបំផ្លិចបំផ្លាញ និងសម្លាប់ប្រជាជាតិ និងប្រជាជនឯងផងដែរ។

និយាយរួម មិត្តដាំ ផេង ស្ទាត់មាត់ មិនស្រែកបកអាក្រាត និងប្រកាសថ្កោលទោសពួកវា តែនៅពេលណា ដែលពួកវាវាយបញ្ច្រកទឹកសាប៊ូ និងទឹកត្រី ឱ្យសន្លប់បាត់ស្មារតីប៉ុណ្ណោះ។

ខ្មាំងទាល់តម្រិះ ព្រោះវាធ្វើទារុណកម្មយ៉ាងណា ក៏មិត្តនៅតែមិនសារភាពដដែល។ ដូច្នេះពួកវាដូរវិធីត្រជាក់ម្ដងវិញៗ។ ពួកវាលួងលោមបញ្ចុកបញ្ចើគ្រប់បែបយ៉ាង ពេលខ្លះវាយកស្រីញីមកទាក់ទាញទឹកចិត្ត ពេលខ្លះពួកវាសន្យាឲ្យតួនាទីបុណ្យសក្តិ និងសន្យាឲ្យទៅបន្តការសិក្សានៅបរទេស រួមមានៈ ប្រទេសបារាំង និងសហរដ្ឋអាមេរិក ជាដើមទៀត ឱ្យតែមិត្តសុខចិត្តប្រាប់ឈ្មោះ ប្រាប់កន្លែង និងអត្តសញ្ញាណមេដឹកនាំតស៊ូខាងលើៗដល់ពួកវា។

ចាប់តាំងពីចាប់យកមិត្តដាំ ផេង យកទៅឃុំឃាំង ពួកខ្មាំងមិនដែលហ៊ានដាក់មិត្តនៅជុំជាមួយអ្នកទោសឯទៀតទេ។ ពួកវាដាក់ឃុំឃាំងមិត្តនៅក្នុងបន្ទប់ងងឹតតូចមួយដាច់ឆ្ងាយពីគេឯង។ ក្រោយពីពួកវាចាប់យកទៅវាយធ្វើទារុណកម្មតែប៉ុន្មានថ្ងៃប៉ុណ្ណោះ ខ្លួនប្រាណ

មិត្តត្រូវបែកឈាមដាំហើមទាំងដុំៗក៏ពិតមែន តែឆន្ទៈប្រយុទ្ធតស៊ូ ដើម្បីបដិវត្តន៍របស់មិត្ត នៅតែរឹងមាំជាងដែកថែបទៅទៀត។

ជារៀងរាល់ពេលខ្មាំងចាប់ប្រកៀកមិត្តបណ្តើរចេញពីបន្ទប់ងងឹត យកទៅកន្លែងធ្វើទារុណកម្មសួរចម្លើយ ដោយដើរកាត់មុខបន្ទប់ឃុំឃាំងយុទ្ធមិត្តជាអ្នកតស៊ូបដិវត្តន៍ដូចគ្នាដទៃទៀត ពួកគេនាំគ្នារត់ស្រ មកអើតសម្លឹងមើលក្នុងទឹកមុខព្រួយបារម្ភចំពោះអាយុជីវិតរបស់មិត្ត។ ពេលនោះ មិត្តដាំ ផេង ដែលកាន់តែទុរន់ទុរាហត់ហេវឈឺចុកចាប់ពេញទាំងខ្លួនប្រាណណាធ្ងន់នឹងច្រវាក់ដែក ដែលខ្មាំងចងភ្ជាប់នៅជើងទាំងសងខាង ឈានដើរស្ទើរមិនរួចនោះបានក្រឡេកងាកទៅរកពួកអ្នកទោសជាយុទ្ធមិត្តជាអ្នកតស៊ូបដិវត្តន៍ទាំងនោះ ហើយលើកដៃទាំង២ ដែលជាប់ច្រវាក់ឡើងលើ និងស្រែកខ្លាំងៗថា៖ ជយោ! បដិវត្តន៍កម្ពុជា ដ៏រុងរឿង, ជយោ! ប្រជាជនកម្ពុជា ដ៏អង់អាចក្លាហាន, បដិវត្តន៍កម្ពុជា ពិតជាឈ្នះ បរាជ័យចក្រពត្តិអាមេរិក-បរិវារ និងពួកអាឆ្កែបម្រើវា...។

ពេលនោះ សម្រែកបន្ទរថា៖ ជយោ! បដិវត្តន៍ និងសម្រែកបរាជ័យ! ចក្រពត្តិ បានលាន់ឮកងរំពងចេញពីគ្រប់បន្ទប់ឃុំឃាំង ហើយមិត្តព្យាយាមញញឹមដាក់យុទ្ធមិត្តទាំងអស់នោះវិញ ដើម្បីបង្ហាញទឹកចិត្តកុំឲ្យអ្នកតស៊ូទាំងអស់ព្រួយបារម្ភចំពោះជីវិតរបស់មិត្ត តែត្រូវនាំគ្នាតស៊ូប្រយុទ្ធដាច់ខាតជាមួយខ្មាំងបន្តទៀត។

យប់មួយ បន្ទាប់ពីត្រូវពួកខ្មាំងវាយធ្វើទារុណកម្មកាន់តែសាហាវឃោរឃៅព្រៃផ្សៃមក មិត្តដាំ ផេង ក៏សន្លប់បាត់ស្មារតីធ្ងន់ធ្ងរលើសសព្វដង រួចពួកខ្មាំងបានអូសយកមកដាក់នៅក្នុងបន្ទប់ងងឹតវិញ។

ក្រោយពីបានដឹងខ្លួន ឈាមធ្លាក់ទាំងដុំៗ មិត្តដឹងខ្លួនថា មិត្តពិតជាស្លាប់ ហើយខំប្រវេប្រវាតោងក្រោកឡើង យកឈាមរបស់មិត្តសរសេរកំណាព្យនៅលើជញ្ជាំងថា ៖ បេះដូងក្រហម ខ្ញុំថ្នាក់ខ្ញុំថ្នម លត់ដំរាល់ថ្ងៃ ទុកជូនបដិវត្តន៍ ដ៏មានតម្លៃ ជូនអ្នកក្រក្រី វណ្ណៈអធន។ ពេលនេះហើយណា ជនកម្ពុជា ត្រូវការទាន់ហន់យកបេះដូងខ្ញុំ ទៅដោះទុក្ខធ្ងន់ បុត្រប្រជាជនរីករាយបូជា។

## របត់នយោបាយ

មិត្ត ដាំ ផេង យកឈាមសរសេរកំណាព្យក្នុងជីវិតចុងក្រោយនេះ ដើម្បីសម្តែងនូវមនោសញ្ចេតនាដ៏ល្អបរិសុទ្ធចំពោះអង្គការបដិវត្តន៍ ប្រជាជន និងវណ្ណៈក្រីក្រ ដែលមិត្តគោរពបម្រើស្មោះត្រង់ និងស្រលាញ់លើសអាយុជីវិតរបស់មិត្តទៅទៀត។

ព្រឹកស្អែកឡើង គេឃើញមិត្តដាំ ផេង បានពលីជីវិតដ៏ក្មេងខ្ចីនៅក្នុងបន្ទប់ងងឹត ប្រកបដោយកិត្តិយសរុងរឿងឧដុង្គឧត្តមអស្ចារ្យ ដើម្បីការពារប្រទេសជាតិ និងរំដោះប្រជាជន ពិសេសប្រជាជនក្រីក្រឲ្យចាកផុតពីខ្ញុំកញ្ជះបរទេស និងទុក្ខវេទនាសព្វបែបយ៉ាង។

ចុងបញ្ចប់ ទស្សនាវដ្តីយុវជន-យុវនារីបដិវត្តន៍ របស់បក្សកុម្មុយនិស្តកម្ពុជា បានធ្វើបទអត្ថាធិប្បាយថា ពួកខ្មាំងអាចវាយដំច្រំជាក់លើរូបរាងកាយឱ្យបែកសាច់ហូរឈាមបាក់ឆ្អឹងឆ្អែងខ្ទេចខ្ទាំអស់ រហូតដល់ផ្តាច់ផ្តិលអាយុជីវិតមិត្តដាំ ផេង បាន។ តែពួកខ្មាំងពុំអាចវាយបំបាក់ឬធ្វើឲ្យរង្គោះរង្គើឆន្ទៈប្រយុទ្ធដាច់ខាតរបស់មិត្តដាំ ផេង បានឡើយ។

នៅចំពោះមុខគោលជំហរប្រយុទ្ធដាច់ខាតរបស់មិត្តដាំ ផេង យ៉ាងនេះ ទោះបីពួកខ្មាំងមានគ្រឿងសាស្ត្រាវុធទំនើបៗ និងឧបករណ៍ឃោរឃៅហ្វាស៊ីសច្រើនយ៉ាងណា ក៏ត្រូវតែចាញ់។ ឯមិត្តដាំ ផេង គឺឈ្នះ មិត្តស្លាប់ក្នុងឋានៈជាអ្នកវាយសម្រុកជាអ្នកឈ្នះជារៀងរហូតទៅ។ ចំណែកយុទ្ធមិត្តឯទៀតរាប់ម៉ឺន រាប់សែន រាប់លាននាក់ ដែលនៅឯក្រោយបានប្តេជ្ញាលើកជ្រោងគ្រវីទង់ប្រយុទ្ធនេះតាមគន្លងដ៏ល្អប្រពៃរបស់មិត្តដាំ ផេង បន្តប្រយុទ្ធវាយសម្រុកកម្ទេចខ្មាំង រហូតបានរំដោះទឹកដីកម្ពុជា ជាទីស្នេហាទាំងស្រុង និងជាស្ថាពរ។

នេះជាមហាជ័យជម្នះរួមរបស់បដិវត្តន៍ និងប្រជាជនកម្ពុជា យើង។ តែក៏ជាមហាជ័យជម្នះរបស់វិញ្ញាណក្ខន្ធមិត្តដាំ ផេង និងយុទ្ធជនកម្មាភិបាលយើងទាំងអស់ ដែលបានពលីជីវិតនៅលើសមរភូមិប្រយុទ្ធនឹងខ្មាំងគ្រប់ទិសទី។ ជីវិតរបស់មិត្តដាំ ផេង គឺជាជីវិតតស៊ូតស៊ូរហូតដល់ដង្ហើមចុងក្រោយ ដោយឈរលើគោលជំហរដាច់ខាតប្រយុទ្ធ គ្មានខ្លាចលំបាកគ្មានខ្លាចស្លាប់ និងជំហរវាយសម្រុកជាប់ជានិច្ច ទោះត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃខ្មាំងហើយក៏ដោយ។ នេះជាគោលជំហររបស់ជនបដិវត្តន៍ ដែលរស់នៅថ្លៃថ្លា ហើយស្លាប់ទៅវិញ ក៏អស្ចារ្យរុងរឿងឧដុង្គឧត្តមបំផុត។

ប្រវត្តិវីរភាពដ៏អង់អាចក្លាហាន ស៊ូប្តូរជីវិតដើម្បីបដិវត្តន៍របស់យុវជនដាំ ផេង ដូចបានរៀបរាប់ខាងលើនេះ ត្រូវបានចុះផ្សាយតាមរយៈទស្សនាវដ្តីយុវជន-យុវនារីបដិវត្តន៍ របស់បក្សកុម្មុយនិស្តកម្ពុជា ចេញផ្សាយលេខ៣ ឆ្នាំ១៩៧៣ គឺក្នុងអំឡុងធ្វើសង្គ្រាមផ្តួលរម្លំរបបសាធារណរដ្ឋខ្មែរ។ រឿងរ៉ាវប្រវត្តិតស៊ូប្តូរជីវិតដើម្បីបដិវត្តន៍នេះ មានចំណងជើងថា៖ បេះដូងក្រហមរបស់យុវជន ដាំ ផេង ។ តែគេមិនបានដឹងថា មេខ្មែរក្រហមរូបណាជាអ្នកចងក្រងតាក់តែងរឿងរ៉ាវប្រវត្តិតស៊ូរបស់យុវជនដាំ ផេង នេះទេ។

ក្នុងអំឡុងសង្គ្រាម ដែលពួកមេដឹកនាំខ្មែរក្រហម (បក្សកុម្មុយនិស្តកម្ពុជា) ហៅថាសង្គ្រាមវាយពួកចក្រពត្តិអាមេរិក និងបនក្បត់លន់ នល់ ពីឆ្នាំ១៩៧៣មក រឿងរ៉ាវប្រវត្តិតស៊ូរបស់សមមិត្ត ដាំ ផេង នេះ ត្រូវក្រុមសិល្បៈមជ្ឈិម, សិល្បៈភូមិភាគ, សិល្បៈតំបន់ និងសិល្បៈស្រុក យកទៅសម្តែងជាឆាកល្ខោនមានចំណងជើងថា បេះដូងក្រហមរបស់យុវជនដាំ ផេង ដើម្បីឱ្យកម្មាភិបាល យុទ្ធជន យុវជន យុវនារី និងប្រជាជនទស្សនាជាការកម្សាន្តផង និងអប់រំសតិអារម្មណ៍នយោបាយ ព្រមទាំងឱ្យមានការចងកំហឹងវណ្ណៈ ដើម្បីចូលរួមធ្វើបដិវត្តន៍ឱ្យកាន់តែខ្លាំងក្លាមហាអស្ចារ្យ មហាលោតផ្លោះ ថែមទៀត។

ទាក់ទងប្រវត្តិតស៊ូរបស់សមមិត្ត ដាំ ផេង នេះ បើតាមចម្លើយសារភាពរបស់ ស៊ាត ផៃ ហៅសមមិត្តទុំ ជាអតីតសិស្សជំនិតរបស់ សាឡុត ស និងខៀវ ប៉ុណ្ណារី ដែលបានរត់ចូលព្រៃតស៊ូជាមួយសាឡុត ស តាំងពីឆ្នាំ១៩៦៣ ហើយបានឡើងឋានៈជាអនុប្រធានសេនាធិការកងទ័ពនៃរបបកម្ពុជាប្រជាធិបតេយ្យ ជំនួស ចាន់ ចក្រី ក្នុងឆ្នាំ១៩៧៦ បន្សល់ទុកនៅក្នុងមន្ទីរ ស-២១(គុកទួលស្លែង) បានឱ្យដឹងថា ក្នុងឆ្នាំ១៩៦៣ ពេលកូនស្រីច្បងរបស់គាត់ (ស៊ាត ផៃ ហៅសមមិត្តទុំ) ឈ្មោះស៊ាត សូផា ហៅសាត អាយុ៨ឆ្នាំ គាត់បានរត់ចូលព្រៃតស៊ូជាមួយសាឡុត ស (ប៉ុល ពត)ដោយទុកចោលកូនៗ និងប្រពន្ធឱ្យរស់នៅលំបាកវេទនា ហើយត្រូវសមត្ថកិច្ចគិញ-ប៉ូលិសមកធ្វើទុក្ខបុកម្នេញថែមទៀត។

តែក្រោយមក សមមិត្ត ដាំ ផេង ជាសាច់ថ្លៃ(ប្រពន្ធស៊ាត ផៃ និងប្រពន្ធ ដាំ ផេង ជាបងប្អូនបង្កើតនឹងគ្នា)បានយកកូនស្រីច្បងរបស់គាត់ ឈ្មោះស៊ាត សូផា ទៅជួយចិញ្ចឹម

ហើយកូនស្រីគាត់ក៏ស្រលាញ់ស្និទ្ធស្នាលជាមួយដាំ ផេង ដូចឪពុកបង្កើតដែរ។ ទោះបី កូនស្រីនោះមានអាយុ១២ឆ្នាំហើយក៏ដោយ ក៏វានៅតែឱប.ក ដាំ ផេង ជាពូថ្លៃយ៉ាងស្និទ្ធស្នាលដែរ។ ពេលនោះ ដាំ ផេង ក៏បានបង្ហាត់បង្រៀនកូនស្រីគាត់ឱ្យចេះច្រៀងចម្រៀងបដិវត្តន៍ជាច្រើនបទ និងបង្ហាត់បង្រៀនក្បាច់គុនខ្លះៗទៀតផង។

ក្រៅពីកូនស្រីច្បងឈ្មោះស៊ាត សូផា គាត់មានកូនប្រុសៗ៣នាក់ទៀតដែរ តែកូនស្រីច្បងឈ្មោះស៊ាត សូផា នេះ ពេលដល់វ័យជំទង់ បែរជាមានចរិតដូចមនុស្សប្រុសទៅវិញ។ តែគាត់ស្រលាញ់កូនស្រីនេះ ជាងកូនប្រុសៗទាំង៣នាក់ ព្រោះគាត់មានកូនស្រីតែម្នាក់នេះ ហើយនាងដឹងខុសត្រូវជាងប្អូនប្រុសៗ។

ស៊ាត ផៃ ហៅសមមិត្តទុំ បានឱ្យដឹងថា នៅពេលសមត្ថកិច្ចគិញ-ប៉ូលិសចាប់ ដាំ ផេង និងប្រពន្ធ យកទៅដាក់គុកក្នុងឆ្នាំ១៩៦៨នោះ កូនស្រីច្បងរបស់គាត់ឈ្មោះ ស៊ាត សូផា អាយុ១៣ឆ្នាំ ក៏ត្រូវពួកវាចាប់យកទៅដាក់គុកដែរ។ ដូច្នេះហើយ បានជាគាត់អាណិតស្រលាញ់កូនម្នាក់នេះ ជាងគេ។

# ២២៣
# ប្រវត្តិតស៊ូរបស់នង សួន ហៅជ័យ សួន



**នង សួន**

ក្រោយសន្ធិសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៥៤ យុទ្ធជន និងកម្មាភិបាលដឹកនាំចលនាតស៊ូខ្មែរឥស្សរៈរបស់បក្សប្រជាជនបដិវត្តន៍ខ្មែរ ជាង១ពាន់នាក់ បានធ្វើដំណើរជាមួយពួកវៀតមិញទៅរស់នៅវៀតណាមភាគខាងជើង។

ចំណែក នង សួន និងកែវ មាស ព្រមទាំងមេដឹកនាំបក្សប្រជាជនបដិវត្តន៍ខ្មែរមួយចំនួននៅក្នុងប្រទេស បានបង្កើតគណបក្សមួយ ឈ្មោះគណបក្សប្រជាជន ដើម្បីប្រកួតប្រជែងក្នុងការបោះឆ្នោតឆ្នាំ១៩៥៥ តាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវ។

គោលបំណងសំខាន់របស់ពួកគាត់ក្នុងការបង្កើតគណបក្សប្រជាជន នេះឡើង មាន២យ៉ាង គឺ៖ ទី១. បន្តការតស៊ូ ដើម្បីផលប្រយោជន៍ប្រទេសជាតិ និងប្រជាជន ដែលត្រូវគេជិះជាន់ក្នុងប្រទេសបន្តទៀត។

ទី២. ដណ្តើមរដ្ឋអំណាចពីពួកសក្តិភូមិ នាយទុនប្រតិកិរិយា ដោយឆ្លងតាមរយៈការតស៊ូស្របច្បាប់ ដើម្បីដណ្តើមកៅអីក្នុងសភាពីនីតិកាលមួយទៅនីតិកាលមួយ។

ដោយសារគោលបំណងទាំង២នេះ អតីតមេដឹកនាំចលនាតស៊ូរបស់បក្សប្រជាជនបដិវត្តន៍ខ្មែរ នៅគ្រប់ខេត្ត បានឯកភាពគ្នាបង្កើតគណបក្សជាចំហស្របច្បាប់មួយ ហៅថាគណបក្សប្រជាជន ឬហៅថាក្រុមប្រជាជន នេះឡើង។

នង សួន បានរម្លឹកថា ពេលនោះ សមាសភាពដឹកនាំគណបក្សប្រជាជន មាននៅគ្រប់ខេត្ត សុទ្ធតែជាអតីតអ្នកតស៊ូ៩ឆ្នាំ(ពីឆ្នាំ១៩៤៥ ដល់ឆ្នាំ១៩៥៤)ទាំងអស់។ គោលនយោបាយរបស់គណបក្សប្រជាជន នៅក្នុងប្រទេស គឺអនុវត្តតាមមាគ៌ានយោបាយ កាលពីសម័យតស៊ូប្រឆាំងនឹងពួកអាណានិគមនិយមបារាំង ។ ឯគោលនយោបាយក្រៅប្រទេស គឺអនុវត្តតាមមាគ៌ាគោលនយោបាយរបស់បក្សកុម្មុយនិស្តឥណ្ឌូចិន (វៀតណាម កម្ពុជា និងឡាវ)។

នង សួន មានជំនឿជឿជាក់ថា គណបក្សប្រជាជន ជាតំណាងពេញសិទ្ធិ ពេញលក្ខណៈឲ្យផលប្រយោជន៍ប្រជាជាតិ និងប្រជាជនខ្មែរនៅទូទាំងប្រទេស ដែលត្រូវគេជិះជាន់ ហើយជាការចូលរួមជាវិភាគទានដ៏តិចតួចស្តួចស្តើងដល់ចលនាបដិវត្តន៍ ដល់ចលនាតស៊ូរបស់ប្រជាជននៅលើសកលលោក ដែលត្រូវគេជិះជាន់ផងដែរ។ ចំណែកគណបក្សដទៃទៀត មិនមែនជាតំណាងឲ្យផលប្រយោជន៍ជាតិ និងប្រជាជន ដែលត្រូវគេជិះជាន់ឡើយ។

ដោយសារមានជំនឿជឿជាក់បែបនេះ នង សួន បានប្តេជ្ញាថា ទោះបីនៅក្នុងកាលៈ-ទេសៈណាក៏ដោយ ក៏គាត់មិនរាថយជាដាច់ខាត គាត់ហ៊ានបូជាជីវិត ដើម្បីបម្រើសំណូមពររបស់គណបក្សប្រជាជន ។

ពេលនោះ ក្រុមប្រជាជនមានមោទកភាពថា គណបក្សប្រជាជនរបស់ខ្លួនមានតួនាទីសំខាន់ជាងគណបក្សដទៃទៀត ដូចជា គណបក្សប្រជាធិបតេយ្យ, គណបក្សសេរីភាព និងចលនាសង្គមរាស្ត្រនិយម របស់សម្តេចសីហនុ ទៀតផង។

គណបក្សប្រជាជន ជាគណបក្សចំហស្របច្បាប់ ក៏ពិតមែន តែផ្ទៃក្នុង និងសម្ងាត់ស្ថិតនៅក្រោមការដឹកនាំរបស់គណៈកម្មាធិការបក្សមួយ ដែលរួមមាន៖ កែវ មាស ជា

លេខា, នង សួន និងប៉ែនយុទ្ធ ជាសមាជិក។

លុះដល់ខែវិច្ឆិកា ឆ្នាំ១៩៦១ សមាសភាពដឹកនាំគណៈកម្មាធិការបក្ស មានការផ្លាស់ប្តូរខ្លះ ដើម្បីត្រៀមចូលរួមក្នុងការបោះឆ្នោតឆ្នាំ១៩៦២ គឺ កែវ មាស នៅជាលេខាគណៈកម្មាធិការបក្សដដែល, នង សួន ជាអនុលេខា, នៃ សារ៉ាន់ ហៅយ៉ា ជាសមាជិកអចិន្ត្រៃយ៍, ជូ ជេត ហៅស៊ី និងអ៊ុំ ណេង ហៅវ៉ង់ ឬវី ជាសមាជិក។ ការផ្លាស់ប្តូរសមាសភាពដឹកនាំនេះ បានធ្វើឡើងនៅក្នុងកិច្ចប្រជុំមួយនៅក្នុងផ្ទះរបស់ នៃ សារ៉ាន់ ហៅយ៉ា ឬម៉ែន សាន ហៅ អាចារ្យសៀង។ តែនៅក្នុងកិច្ចប្រជុំនោះ ជូ ជេត អវត្តមាន ។

ក្នុងអង្គប្រជុំ កែវ មាស បានបញ្ជាក់ថា ការផ្លាស់ប្តូរសមាសភាពដឹកនាំនេះ បានទទួលការសម្រេចពីសមមិត្ត ទូ សាមុត (ជាអនុលេខាគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍ខ្មែរ ដែលបានបង្កើតឡើង នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១)។

នង សួន បានលើកឡើងថា កាលសម័យគណបក្សប្រជាជន ចូលរួមបោះឆ្នោតជាលើកដំបូង ឆ្នាំ១៩៥៥ សមាជិកគណបក្សជាច្រើន ដែលធ្លាប់តស៊ូដោយអាវុធ ត្រូវអាជ្ញាធរសម្តេចសីហនុ ចាប់យកទៅដាក់គុក ចាប់យកទៅសម្លាប់ចោលយ៉ាងសាហាវព្រៃផ្សៃបំផុត។ នៅជនបទ ដោយសារគណបក្សប្រជាជន មានកាសែតមួយ គឺកាសែតប្រជាជន ជួយផ្សព្វ-ផ្សាយបំភ្លឺ ធ្វើឲ្យប្រជាជនតស៊ូកែប្រែជីវភាពរបស់ខ្លួន, ទាមទារដីធ្លីដែលពួកម្ចាស់ដីហួងហែង, ទាមទារចងការបំណុលបុលបណ្តាក់ឲ្យថយចុះដាលំដាប់ ជាដើម...។

ជាមួយគ្នានោះ សមាជិកគណបក្សប្រជាជន ក៏បានប្រយុទ្ធពុះពារជាមួយពួកកាន់អំណាចប្រតិកិរិយាគ្រប់កាលវេលា រហូតត្រូវពួកវាចាប់ដាក់គុកច្រវាក់ និងឈានទៅបាញ់សម្លាប់ទៀតផង ក៏ពួកយើងនៅតែមិនរាថយ គឺបន្តការតស៊ូនយោបាយ រហូតដល់ជីវិតចុងក្រោយ។

ទីបំផុត នៅក្នុងឆ្នាំ១៩៦២ នង សួន ត្រូវសមត្ថកិច្ចចាប់ខ្លួន ពីបទប៉ុនប៉ងធ្វើរដ្ឋប្រហាររម្លំរាជបល្ល័ង្ក និងដណ្តើមអំណាចពីសម្តេចសីហនុ ហើយត្រូវតុលាការសឹកកាត់ទោសប្រហារជីវិត តែក្រោយមកសម្តេចសីហនុ បានបន្ធូរបន្ថយទោស ឱ្យមកនៅត្រឹមជាប់ពន្ធនាគារអស់មួយជិវិតវិញ។

រវបត់នយោបាយ

នងសួនរម្លឹកថាទោះបីពួកកាន់អំណាចប្រតិកិរិយាបង្រ្កាបពួកគាត់សាហាវឃោរឃៅព្រៃផ្សៃយ៉ាងណាក៏ដោយ ក៏គាត់នៅតែសង្ឃឹមជានិច្ចថា៖ គណបក្សប្រជាជន ពិតជាមិនរលំរលាយដោយប្រការណាមួយបានឡើយ ព្រោះពួកគាត់ម្នាក់ៗ មានឧត្តមគតិបម្រើផលប្រយោជន៍ប្រជាជាតិ និងប្រជាជន ដែលត្រូវគេជិះជាន់ទូទាំងប្រទេស ហើយតាមរយៈសកម្មភាពរបស់ពួកគាត់កន្លងមក ត្រូវបានប្រជាជននៅជនបទនាំគ្នាជួយឧបត្ថម្ភគាំទ្រទាំងស្មារតីសម្ភារៈ ទាំងកម្លាំងកាយចិត្តដោយស្មោះស្ម័គ្រ និងប្តូរផ្តាច់បំផុត។

នង សួន បានបញ្ជាក់ថា ពីឆ្នាំ១៩៦៦ ដល់១៩៦៧ នល់ លន់ បានឡើងធ្វើជានាយករដ្ឋមន្ត្រី។ ពេលនោះ គាត់កំពុងជាប់នៅក្នុងពន្ធនាគារនៅឡើយ គណបក្សប្រជាជនចេញសារាចរមួយ សំណូមពរដល់សមាជិកសកម្មទាំងអស់ រួមគ្នាបំផុសឲ្យមានចលនាធ្វើបាតុកម្មកូដកម្មតូចធំនៅគ្រប់ទីកន្លែង ដើម្បីប្រឆាំងនឹងរដ្ឋាភិបាល លន់ នល់។ ពេលនោះគាត់ក៏បានសម្រេចចិត្តធ្វើកូដកម្មអត់អាហារនៅក្នុងពន្ធនាគារ អស់រយៈពេល៧ថ្ងៃ ដើម្បីសម្រេចឱ្យបានតាមសំណូមពររបស់គណបក្ស ។

# ២២៤
# ប្រវត្តិតស៊ូ នៃ សារ៉ាន់ ហៅយ៉ា ហៅអាចារ្យសៀង



**នៃ សារ៉ាន់ ក្នុងទសវត្សរ៍ឆ្នាំ១៩៥០**

នៅដើមទសវត្សរ៍ឆ្នាំ១៩៥០ សោ ភឹម មេខ្មែរឥស្សរៈនៅក្នុងព្រៃស្រុកមោសហែក និង ស្រុកកំចាយមារ បាននាំគ្នាចេញពីព្រៃ ទៅចាប់ស្មៀនឃុំគគីរសោម ឈ្មោះសុំា ដែលជាឃុំ កំណើតរបស់សោ ភឹម នាំយកមកក្នុងព្រៃតស៊ូ។

ស្មៀនឃុំឈ្មោះសុំា នេះ មានស្រុកកំណើតនៅភូមិចិន ឃុំគគីរសោម ស្រុករំដួល ខេត្ត ស្វាយរៀង ជាមួយ សោ ភឹម ហើយធ្លាប់ស្គាល់គ្នាតាំងពីកុមារភាពមកដែរ ដូច្នេះពុំមាន នរណាវាយធ្វើបាបអ្វីឡើយ ហើយគាត់ ក៏បានចូលរួមក្នុងចលនាតស៊ូខ្មែរឥស្សរៈជាមួយសោ ភឹម ចាប់ពីពេលនោះមក។ កាលសម័យ តស៊ូប្រឆាំងនឹងបារាំង ឈ្មោះសុំា ជាអតីតស្មៀនឃុំ គគីរសោម រូបនេះ បានប្តូរឈ្មោះជាបន្តបន្ទាប់ គឺឈ្មោះនៃ សារ៉ាន់ ហៅយ៉ា ឬឈ្មោះ ម៉ែន សាន ហៅអាចារ្យសៀង ជាដើម។

រវបត់នយោបាយ

មិនយូរប៉ុន្មាន ដោយសារគាត់មានការឈ្លាសវៃ និងបានរៀនសូត្រចេះដឹងគួរសមដែរ គាត់ក៏បានមកធ្វើការជាមួយទូ សាមុត ជាអនុលេខាគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍ខ្មែរ នៅក្នុងជំរំតស៊ូមួយនៅភូមិសន្ទែ ក្នុងភូមិភាគបូព៌ា ក្បែរព្រំដែន វៀតណាម ។

ក្រោយពីមានកិច្ចព្រមព្រៀងក្រុងហ្សឺណែវ នៅក្នុងខែកក្កដា ឆ្នាំ១៩៥៤ សង្គ្រាមនៅឥណ្ឌូចិនទាំងមូលត្រូវបញ្ចប់។ កម្លាំងអ្នកតស៊ូខ្មែរនៅជំរំនៅភូមិសន្ទែ ក៏ដូចជាកម្លាំងអ្នកតស៊ូខ្មែរផ្សេងៗទៀត នៅទូទាំងប្រទេស ក៏ត្រូវប្រកាសរំសាយដែរ ហើយអ្នកតស៊ូខ្មែរជាង ១ពាន់នាក់ ត្រូវធ្វើដំណើរជាមួយកងទ័ពវៀតមិញ ទៅវៀតណាមភាគខាងជើង និងខ្លះទៀតត្រូវវិលទៅស្រុកកំណើតជួបជុំឪពុកម្តាយ ប្រពន្ធកូនវិញ។

នៅក្នុងខែកញ្ញា ឆ្នាំ១៩៥៤ ទូ សាមុត បានហៅវន វ៉េត និងសុខ ខ្នុល (ហៅពៀមហៅលីន) មកប្រាប់ថា ត្រូវវិលត្រលប់ទៅភ្នំពេញ វិញ តែត្រូវរង់ចាំនីរសារមកនាំផ្លូវចេញពីព្រៃតស៊ូនោះ ដើម្បីទៅរកផ្លូវជាតិ។ មុនពេលចេញដំណើរ ទូ សាមុត បានឲ្យ នៃ សារ៉ាន់ ហៅយ៉ា យកប្រាក់មកឲ្យវន វ៉េត និងសុខ ខ្នុល ម្នាក់ ១០០រៀល ទុកសម្រាប់ធ្វើដំណើរទៅភ្នំពេញ វិញ ហើយប្រាប់ថា ចាំចូលដល់ភ្នំពេញ ចាំរកខ្សែរយៈទាក់ទងគ្នាទៀត។

ក្រោយពីវន វ៉េត និងសុខ ខ្នុល ធ្វើដំណើរទៅភ្នំពេញ វិញ មិនយូរប៉ុន្មាន នៃ សារ៉ាន់ ហៅយ៉ា ក៏ចាកចេញពីទូ សាមុត ធ្វើដំណើរចូលទៅទីក្រុងភ្នំពេញ ដែរ។ នៅដើមឆ្នាំ១៩៥៥ មានការបង្កើតក្រុមប្រជាជន ដោយមានប៉ែន យុទ្ធ ជាប្រធាន ហើយក្រុមប្រជាជននេះ បានបង្កើតគណបក្សស្របច្បាប់មួយឈ្មោះគណបក្សប្រជាជន ដើម្បីចូលរួមបោះឆ្នោតប្រកួតប្រជែងជាមួយចលនាសង្គមរាស្ត្រនិយម របស់សម្តេចសីហនុ និងគណបក្សប្រជាធិបតេយ្យរបស់កេង វ៉ាន់សាក់ ជាដើម។

ពេលនោះ ប៉ែន យុទ្ធ ជាប្រធានក្រុមប្រជាជន គិតតែពីរឿងអបាយមុខពាលាអាវ៉ាសែស្រីស្រាលោភលន់ ក៏បោះបង់ចលនាបដិវត្តន៍ ទៅចុះចូលជាមួយសម្តេចសីហនុ។ នៅចុងឆ្នាំ ១៩៥៥ គណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍ខ្មែរ ក៏បានចាត់តាំងកែវ មាស ឲ្យធ្វើជាប្រធានក្រុមប្រជាជន និងប្រធានគណបក្សប្រជាជន ជំនួសវិញ ដោយមាននង សួន និងដូ ជេត

ជាសមាជិក។ ក្រៅពីនោះក៏មានណុប បូផាន់ ជាបណ្ណាធិការកាសែតប្រជាជន ផងដែរ។ តែក្រោយមក ណុប បូផាន់ ត្រូវលន់ នល់ ឱ្យគេចាប់យកទៅសម្លាប់ចោលនៅក្រោយវត្តលង្កា នៅក្នុងក្រុងភ្នំពេញ។

តាមឯកសារដែលនៃ សារ៉ាន់ ហៅយ៉ា បានបន្សល់ទុក បានឱ្យដឹងថា នៅក្នុងឆ្នាំ១៩៥៥ នោះដែរ បក្សបានឱ្យគាត់ទៅទាក់ទងទូ សាមុត ដែលកំពុងបិតនៅក្នុងប្រទេសវៀតណាមខាងត្បូង បានម្តង។ ក្រោយមក ទូ សាមុត និងស៊ីវ ហេង ក៏បានចូលមកស្នាក់នៅប្រាសាទលែង ក្នុងទឹកដីខ្មែរវិញ។ ក្នុងឆ្នាំ១៩៥៦ បក្សបានឲ្យគាត់ទៅទាក់ទងទូ សាមុត នៅទីនោះបាន២ដងទៀត។

អំឡុងឆ្នាំ១៩៥៧ និង១៩៥៨ គាត់បានទិញសៀវភៅ និងកាសែតវៀតណាមដោយខ្លួនឯង ដើម្បីគ្រាន់យកមកអានប៉ុណ្ណោះ ពុំមានការចាត់តាំងជាអង្គការអ្វីនោះទេ។ពេលនោះ កែវ មាស ជាអ្នកទាក់ទងជាមួយវៀតណាម ដើម្បីសុំការណែនាំអ្វីផ្សេងៗពិសេសខាងមាគ៌ានយោបាយ និងដំណើរការកាសែតស្របច្បាប់។

ប្រហែលជាក្នុងឆ្នាំ១៩៥៩ ឬ១៩៦០ គាត់ចាំមិនច្បាស់ ពេលនោះ រាជរដ្ឋាភិបាលសម្តេចសីហនុ បានអនុញ្ញាតឲ្យគណៈប្រតិភូកាសែតមួយក្រុមទៅបំពេញទស្សនកិច្ចនៅទីក្រុងហាណូយ ក្នុងនោះក៏មានកាសែតប្រជាជនមួយដែរ។ ក្រុមប្រជាជនបានជ្រើសរើសឱ្យនងសួន និងជី គឹមអាន ដែលជាបណ្ណាធិការកាសែតប្រជាជន ឱ្យទៅបំពេញទស្សនកិច្ចនោះ។

នៅពេលទៅបំពេញទស្សនកិច្ចនៅទីក្រុងហាណូយនោះ មេដឹកនាំវៀតណាម បានឲ្យជី គឹមអាន ប្រាប់គេឯងថាខ្លួនឈឺ ហើយឲ្យចូលសម្រាកនៅមន្ទីរពេទ្យមួយ ដើម្បីឲ្យថាច់សឿង (កាលជំនាន់តស៊ូ៩ឆ្នាំ គឺពីឆ្នាំ១៩៤៥ ដល់ឆ្នាំ១៩៥៤ ជាមេដឹកនាំកងទ័ពវៀតមិញនៅវៀតណាមខាងត្បូង និងកម្ពុជា)និងសឹង ង៉ុកមិញ ទៅជួបក្នុងមន្ទីរពេទ្យនោះ។

ពេលត្រលប់មកដល់ក្រុងភ្នំពេញវិញ ជី គឹមអាន បានរាយការណ៍ថាឈ្មោះថាច់ សឿង បានបន្ទោសថា កិច្ចដំណើរការតស៊ូក្នុងប្រទេសកម្ពុជា បែកឆ្វេងហើយ ព្រោះតស៊ូមិនស្របច្បាប់។ ថាច់ សឿង បានណែនាំឲ្យអ្នកតស៊ូនៅកម្ពុជា កែលម្អ និងតម្រែតម្រង់ដំណើរកាសែត

ស្របច្បាប់ឡើងវិញ។ និយាយសរុបឲ្យខ្លីទៅ ក្នុងរយៈពេលនោះដំណើរការតស៊ូ ពិសេសដំណើរការខាងកាសែត ស្ទើរតែរណបវៀតណាមទាំងស្រុង។

បន្ទាប់មក បណ្ដាសមមិត្តគ្រប់គ្រងកាសែតប្រជាជន មានការទាក់ទងផ្លាស់ប្ដូរមតិអំពីសកម្មភាព និងអំពីដំណើរការកាសែតប្រជាជន ប្រចាំខែ ប្រចាំអាទិត្យជាមួយកាសែតវៀតណាមឈ្មោះកាសែតទ្រឹងឡឹម (កាសែតអព្យាក្រឹត) នៅភ្នំពេញ ជាហូរហែចុះឡើងមិនសូវដាច់។

តំណាងកាសែតទ្រឹងឡឹម នេះ មានឈ្មោះទុង ជាអ្នកចេញមុខផ្ទាល់។ ក្នុងរយៈពេលនោះ អត្ថបទផ្សេងៗដែលទាក់ទងដល់សកម្មភាពថ្នាក់ដឹកនាំវៀតណាមខាងជើង ដូចជា ទ្បេ យន់ និងទ្រឿង ជិញ ជាដើម ត្រូវបានគេផ្ញើតាមផ្លូវស្របច្បាប់មកឲ្យក្រុមប្រជាជន និងកាសែតប្រជាជនជាបន្តបន្ទាប់ តាមរយៈកាសែតទ្រឹងឡឹម នេះ។

ជាមួយគ្នានោះ ក៏មានឯកសារភាគច្រើននិយាយពីមាគ៌ានយោបាយតស៊ូស្របច្បាប់ក្នុងរយៈកាលថ្មី ក្រោយសន្និសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៥៤ និងបទពិសោធពីការធ្វើកាសែតស្របច្បាប់ក្នុងរយៈកាលមុនសន្និសញ្ញាក្រុងហ្សឺណែវ និងរយៈកាលក្រោយសន្និសញ្ញាក្រុងហ្សឺណែវ នៅក្រុងព្រៃនគរ ជាដើម ក៏ត្រូវបានគេផ្ញើតាមរយៈកាសែតទ្រឹងឡឹម នេះដែរ។

នៃ សារ៉ាន់ ហៅយ៉ា បានឱ្យដឹងដែរថា កាលនោះ សាខាបក្សប្រជាជន (បក្សប្រជាជនបដិវត្តន៍ខ្មែរ) ការពិតគឺជាសាខាកាសែតប្រជាជន ដែលមុនដំបូងមាន កែវ មាស ជាលេខាសាខាបក្ស ។ តែក្រោយបោះឆ្នោត១៩៥៥ សភាពការណ៍កាន់តែតានតឹងខ្លាំងឡើងៗ កែវ មាស ត្រូវលាក់ខ្លួនជាសម្ងាត់ រូបគាត់(នៃ សារ៉ាន់) ជាអ្នកទទួលជាលេខាសាខាបក្សជំនួសវិញ ហើយបក្ខជនជាសមាជិកនៅក្នុងសាខាបក្សនេះទាំងអស់សុទ្ធតែមកពីចលនាខ្មែរឥស្សរៈមាននិន្នាការរណបវៀតណាម។

សាខាបក្សនេះមានភារកិច្ចដឹកនាំការចេញផ្សាយកាសែតប្រជាជន ស្របច្បាប់ ហើយនៅក្នុងសាខានេះដែរ គឺគាត់ជាអ្នកទាក់ទងផ្ទាល់ជាមួយអង្គការ និងពីអង្គការទៅក្រុមកាសែតប្រជាជន។ ជាមួយគ្នានោះ គាត់ក៏ជាអ្នកគិតគូរពីផ្ទះសម្ងាត់សម្រាប់ធ្វើការប្រជុំសាខាបក្ស ឬប្រជុំក្រុមប្រជាជន ផងដែរ។ ជាក់ស្ដែង គាត់បានយកផ្ទះសួស នៅ ហៅឈូក នៅទួលគោក

ជាផ្ទះសម្ងាត់។ ពេលនោះឈូក ជាអនុរក្សនៅវិទ្យាល័យកម្ពុជបុត្រ។ ផ្ទះគ្រូសំរិត ហេង និង ផ្ទះគ្រូថាច់ ថៃ (គ្រូនៅវិទ្យាល័យចំរើនវិជ្ជា) ព្រមទាំងផ្ទះគាត់ផ្ទាល់ ធ្វើជាផ្ទះសម្ងាត់សម្រាប់ធ្វើការប្រជុំសាខាបក្ស ឬប្រជុំក្រុមប្រជាជន និងទទួលពួកកម្មាភិបាលដែលមកពីឆ្ងាយៗឲ្យស្នាក់នៅផងដែរ។

គ្រូសំរិត ហេង ជាអ្នកតស៊ូជើងចាស់ និងគ្រូថាច់ ថៃ ចេះអក្សរវៀតណាម អាចឱ្យទៅទាក់ទងជាមួយវៀតណាម នៅកាសែតទ្រឹង ឡឹម បាន។

ពេលនោះ កែវ មាស តែងតែមកសម្រាកនៅផ្ទះគាត់ ហើយគាត់ក៏ដូចជាសួស នៅ ហៅឈូក ដែរ គឺទទួលឥទ្ធិពលផ្ទាល់ពីកែវ មាស។ ពួកគាត់គោរព និងធ្វើតាមការណែនាំរបស់កែវ មាស ជានិច្ច។ កែវ មាស ឲ្យទៅទំនាក់ទំនងនៅវៀតណាម ពួកគាត់ក៏ទៅ... ។ នៃ សារ៉ាន់ ហៅយ៉ា បានឱ្យដឹងថា ថាច់ ថៃ ជាអ្នកកម្ពុជាក្រោម មកបួសនៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ។ ក្រោយពីសឹកមកវិញ ក៏សុំទៅបង្រៀននៅអនុវិទ្យាល័យចំរើនវិជ្ជា។ គាត់ស្គាល់ ថាច់ ថៃ នេះ តាមរយៈអាចារ្យវិញ កឿង នៅវត្តឧណ្ណាលោម។ ក្រោយពេលបង្រៀននៅវិទ្យាល័យចំរើនវិជ្ជា បានមួយឆ្នាំ ឃើញចម្រើនមកខាងក្រុមប្រជាជន គាត់ក៏បានស្នើសុំបញ្ចូលថាច់ ថៃ ជាបក្ខជន។

ចំណែក ឈ្មោះវិញ ថាច់ ខ្មែរកម្ពុជាក្រោមនៅបាក់លីវ រត់មកពីវៀតណាមខាងត្បូងមកភ្នំពេញ ដោយមកសុំស្នាក់នៅកុដិអាចារ្យវិញ កឿង។ ពេលនោះ ថាច់ ថៃ ជាសិស្សថ្នាក់ទី១។ អាចារ្យវិញ កឿង បានទំនាក់ទំនងគាត់ស្នើឲ្យវិញ ថាច់ បានចូលបង្រៀន គណិតសាស្ត្រនៅវិទ្យាល័យចំរើនវិជ្ជា គាត់ក៏បានរៀបចំម៉ោងឲ្យបាន៥-៦ម៉ោង ក្នុងមួយអាទិត្យ។

បន្ទាប់មក អាចារ្យវិញ កឿង បានជួយថាច់ ថៃ ឲ្យមានការងារធ្វើមួយទៀត គឺអ្នកបកប្រែភាសាខ្មែរ-បារាំង នៅស្ថានទូតសហភាពសូវៀត នៅទីក្រុងភ្នំពេញ។

ក្នុងឆ្នាំ១៩៥៦ ស្រាប់តែគាត់ឃើញសោ ភឹម ដែលបានធ្វើដំណើរជាមួយកងទ័ពវៀតមិញទៅវៀតណាមភាគខាងជើង ក្រោយសន្ធិសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៩៥៤នោះ បាននាំប្រពន្ធកូនមករកគាត់ដល់ផ្ទះ នៅទីក្រុងភ្នំពេញ។ពេលនោះ គាត់សួរសោ ភឹម ថា ហេតុអី បានជា

បងត្រលប់មកវិញ ?

សោ ភឹម ប្រាប់ថា បក្សមានផែនការឲ្យគាត់ត្រលប់មកវិញ។ តែដោយសារផ្លូវចូលមកប្រទេសកម្ពុជា មានការលំបាកខ្លាំង ពេលនោះវៀតណាម ក៏បាននាំគាត់តាមទូកទៅដាក់នៅជ្រោយទឹកខ្មៅ(កម្ពុជាក្រោម) រួចទើបបន្តដំណើរចូលមកស្រុកកំណើតគាត់។ ក្រោយពីបានជួបគ្នា សោ ភឹម និងប្រពន្ធកូនបានស្នាក់នៅនឹងផ្ទះគាត់នៅម្តុំខាងត្បូងវត្តទួលទំពូង ក្បែរទំនប់ពីក្បាលថ្នល់ទៅស្ទឹងមានជ័យ។ ដោយពេលថ្ងៃ សោ ភឹម ដើរស៊ីឈ្នួលធ្វើផ្ទះឱ្យគេ។ ពេលយប់សម្រាកនៅក្នុងផ្ទះរបស់គាត់ ឬទៅជុំគ្នាពិភាក្សាពីបញ្ហាតស៊ូ។

នៅក្នុងឆ្នាំ១៩៦២ នង សួន ត្រូវតុលាការសឹកកាត់ទោសប្រហារជីវិត។ តែត្រូវសម្តេចសីហនុ បន្ធូរបន្ថយទោសមកនៅត្រឹមជាប់ពន្ធនាគារអស់មួយជីវិតវិញ។ ចំណែកសោ ភឹម ក៏គេចបាត់ពីផ្ទះគាត់ដែរ។ គាត់ដឹងថា សោ ភឹម គេចទៅជនបទ។ ប៉ុន្តែប្រពន្ធកូន សោ ភឹម ទុកនៅនឹងផ្ទះគាត់សិន។ លុះក្រោយមក ទើបប្រពន្ធកូនសោ ភឹម ធ្វើដំណើរត្រលប់ទៅស្រុកកំណើតនៅស្រុកកំចាយមារ ខេត្តព្រៃវែង វិញ។

ពេលនោះ ដោយសារសមត្ថកិច្ចរាជរដ្ឋាភិបាល ធ្វើសកម្មភាពតាមរកចាប់ពួកអ្នកតស៊ូខ្លាំងក្លាពេក អ្នកតស៊ូក្នុងគណបក្សប្រជាជន និងនៅក្រុមកាសែតប្រជាជន នាំគ្នារត់ខ្ចាត់ខ្ចាយ ហើយថ្នាក់ដឹកនាំសាខាបក្សនៅទីក្រុងភ្នំពេញ ក៏ដាច់ខ្សែរយៈគ្នា មិនដឹងទៅទីណាបាត់អស់។ ពេលនោះ កែវ មាស បានណែនាំគាត់(នៃ សារ៉ាន់) និងសួស នៅ ហៅឈូក ឲ្យប្រមែប្រមូលគ្នីគ្នា ដើម្បីឲ្យដំណើរការកាសែតប្រជាជន បន្តទៀត។ ប៉ុន្តែ មិនយូរប៉ុន្មាន កែវ មាស គេចខ្លួនពីទីក្រុងភ្នំពេញ នៅក្នុងឆ្នាំ១៩៦២ នោះដែរ នៅសល់តែគាត់(នៃ សារ៉ាន់) និងសួស នៅ ហៅឈូក បន្តដឹកនាំការតស៊ូទៅមុខទៀត។

ពេលនោះ គាត់ចាត់តាំងសួស នៅ ហៅឈូក ឲ្យប្រជុំបងប្អូនដែលទៅរកស៊ីធ្វើកម្មករសំណង់ផ្សេងៗនៅទួលគោក ឱ្យមកដំណើរការបោះពុម្ពកាសែតប្រជាជន ឡើងវិញ។ ចំណែកគាត់(នៃ សារ៉ាន់) ប្រជុំបងប្អូនក្រុមកាសែតប្រជាជន ដែលធ្វើការនៅកណ្តាលក្រុងភ្នំពេញ។ សមាសភាពចូលរួមប្រជុំនៅពេលនោះគឺគ្រូមួយចំនួននៅវិទ្យាល័យចំរើនវិជ្ជា និងវិទ្យាល័យ

កម្ពុជបុត្រ រួមមាន ផាត់ ផៃ, ជន, សាំង, ស៊ឹម ដឹងហាយ, សំរិត ហេង, សារឿន, ហាន (សិស្សវិទ្យាល័យចំរើនវិជ្ជា) សូផាត (សិស្សកម្ពុជបុត្រ), គ្រូខែត (វិទ្យាល័យចំរើនវិជ្ជា) និងកម្មករផ្សេងៗមួយចំនួនទៀត។

រវាងខែសីហា ដល់ខែកញ្ញា ឆ្នាំ១៩៦៤ នៃ សារ៉ាន់ ហៅយ៉ា ត្រូវបក្សឱ្យចាកចេញពីទីក្រុងភ្នំពេញ ទៅតស៊ូនៅជំរំក្នុងព្រៃ។ តែ សួស នៅ ហៅឈូក បក្សមិនទាន់ឱ្យចាកចេញពីទីក្រុងភ្នំពេញ ទេ។ ពេលទៅដល់ក្នុងព្រៃ គាត់បានជួបគណៈដឹកនាំមជ្ឈិម ដូចជា សាឡុត ស, អៀង សារី និងសុន សេន ព្រមទាំងកម្មាភិបាលមួយចំនួន ទៀត ពិសេសគាត់បានជួប កែវមាស ដែលបានចាកចេញពីទីក្រុងភ្នំពេញ កាលពីឆ្នាំ១៩៦២ នោះផងដែរ។

នៃ សារ៉ាន់ ហៅយ៉ា បានឱ្យដឹងថា ជំរំតស៊ូដំបូងនេះស្ថិតនៅក្នុងព្រៃនៃទឹកដីវៀតណាមខាងត្បូង មិនឆ្ងាយប៉ុន្មានពីខ្សែបន្ទាត់ព្រំដែនកម្ពុជា-វៀតណាម។ ស្ថានការណ៍ពេលនោះ គឺមេដឹកនាំគណៈកម្មាធិការមជ្ឈិមបក្ស និងកម្មាភិបាលទាំងអស់ ត្រូវរណបវៀតណាមខាងជើង ទាំងខាងជីវភាពរស់នៅ ទាំងខាងសម្ភារៈទាំងខាងសន្តិសុខ ទាំងខាងរបៀបរបបធ្វើការ... ឧទាហរណ៍ យើងចង់ទៅធ្វើការនៅកន្លែងណាមួយ ក៏ត្រូវរាយការណ៍ និងសុំកងការពារវៀតណាមឱ្យជូនទៅ។ មជ្ឈិមបក្សចង់ប្រជុំ ឬធ្វើសន្និបាតក៏ត្រូវតែរាយការណ៍សុំមតិពីវៀតណាមជាមុន។ បើវៀតណាម ឲ្យ ទើបអាចធ្វើបាន ព្រោះគេជាម្ចាស់ទឹកដី។ ឯយើងជាភ្ញៀវត្រូវតែស្តាប់គេ។

ដោយឡែក បញ្ហានយោបាយសតិអារម្មណ៍ និងចាត់តាំង មជ្ឈិមបក្សបានម្ចាស់ការជាបណ្តើរៗ ដោយមានមាគ៌ានយោបាយ និងមាគ៌ាចាត់តាំង ឈរលើគោលជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន។

ដើមឆ្នាំ១៩៦៥ បងលេខា(សាឡុត ស) ដឹកនាំគណៈប្រតិភូរបស់បក្សកុម្មុយនិស្តកម្ពុជា ចេញទៅទស្សនកិច្ចនៅបរទេស គាត់ត្រូវបានចាត់តាំងជាជំនួយការរបស់មជ្ឈិមបក្ស។ ក្រោយពេលបងលេខា(សាឡុត ស) ចេញទៅបាត់ បងៗសមាជិកគណៈមជ្ឈិមបក្ស បានចាត់តាំងប្រជុំ និងរៀនសូត្រជាបន្តបន្ទាប់។ តែយើងស្ថិតនៅក្នុងសភាពបាត់ម្ចាស់ការជាប់

ព្រោះអ្វីៗត្រូវវៀតណាមទាំងអស់។ ម្យ៉ាងទៀតសកម្មភាពយន្តហោះបេ៥២(B-52) របស់អាមេរិក ក៏ចាប់ផ្តើមទម្លាក់គ្រាប់បែកមកលើព្រៃតស៊ូនោះទាំងយប់ទាំងថ្ងៃ។ លើសពីនេះទៅទៀត ទីតាំងមន្ទីរនីមួយៗក៏សុទ្ធតែរបស់វៀតណាម។

ដើមឆ្នាំ១៩៦៦ ចក្រពត្តិអាមេរិក បើកយុទ្ធនាការវាយកម្ទេចតំបន់រំដោះរបស់វៀតកុង-វៀតណាមខាងជើង ពេលនោះ ពួកគាត់ទាំងអស់ជាគណៈមជ្ឈិមបក្ស ត្រូវវៀតណាម ជម្លៀសឱ្យចូលជ្រៅទៅក្នុងតំបន់ព្រៃភ្នំរបស់វៀតណាម។ ពួកគាត់បានសំណូមពរសុំឱ្យគេជម្លៀសពួកគាត់ចូលមកខាងក្នុងទឹកដីកម្ពុជា វិញដែរ តែគេមិនព្រម គេលើកហេតុផលថា បើគេជម្លៀសពួកគាត់ចូលមកក្នុងខាងទឹកដីកម្ពុជា គឺខាងសម្តេចសីហនុ ចាប់ពួកគាត់បាន នឹងធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនងការទូតរបស់សីហនុ ជាមួយពួកគេជាមិនខាន។ ដូច្នេះពួកគាត់ត្រូវតែស្តាប់គេ។

ក្រោយជម្លៀសឱ្យចូលជ្រៅទៅក្នុងទឹកដីរបស់វៀតណាម អស់រយៈពេលប្រហែល៨ខែ គឺរហូតដល់ខែ កញ្ញា ឆ្នាំ១៩៦៥ ទើបវៀតណាម ជូនពួកគាត់ត្រលប់មកជំរំចាស់ នៅជិតព្រំដែនកម្ពុជាវិញ។

នៅដើមឆ្នាំ១៩៦៦ បងលេខា(សាឡុត ស) បានត្រលប់មកពីបំពេញទស្សនកិច្ចនៅបរទេសវិញ គណៈកម្មាធិការមជ្ឈិមបក្សក៏បើកប្រជុំទូលាយមួយ ដោយមានតំណាងបក្សទូទាំងប្រទេសចូលរួម។ គណៈកម្មាធិការមជ្ឈិមបក្សសម្រេចអនុម័តប្រកាន់យកមាគ៌ានយោ-បាយ ដោយឈរលើគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួន និងបំផុសការតស៊ូស្របច្បាប់ពាក់កណ្តាល និងមិនស្របច្បាប់ពាក់កណ្តាល នៅទូទាំងប្រទេសឲ្យបានខ្លាំងក្លា តាមមាគ៌ាបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ។

ពេលនោះ គណៈកម្មាធិការមជ្ឈិមបក្ស ក៏បានសម្រេចផ្លាស់ប្តូរឈ្មោះបក្សពលករ កម្ពុជាទៅជាបក្សកុម្មុយនិស្តកម្ពុជា ចាប់ពីពេលនោះមក។ ពេលនោះដែរ មជ្ឈិមបក្ស ក៏សម្រេចចាត់តាំងបញ្ជូនកម្មាភិបាលជាច្រើនឲ្យទៅកាន់ជួរមុខ ដើម្បីចាប់ផ្តើមដឹកនាំចលនាតស៊ូ គ្រប់តំបន់គ្រប់ភូមិភាគ។ បន្ទាប់មក មជ្ឈិមបក្សបានសម្រេចបង្កើតគណៈកម្មាធិការបក្សភូមិភាគ

ឦសាន(ភូមិភាគ១០២) រួមមាន ខេត្តរតនគិរី ខេត្តស្ទឹងត្រែង និងខេត្តមណ្ឌលគិរី ហើយបានចាត់តាំងអៀង សារី ជាលេខាបក្ស, សុន សេន ជាអនុលេខាបក្ស, គាត់ (នៃ សារ៉ាន់) និងកែវ មាស ជាសមាជិក។

នៅពាក់កណ្តាលខែធ្នូ ឆ្នាំ១៩៦៦ អៀង សារី, សុន សេន, គាត់(នៃ សារ៉ាន់), កែវ មាស និងបណ្តាកម្មាភិបាលជាច្រើនទៀត បានធ្វើដំណើរទៅដល់ខេត្តរតនគិរី។ ពេលនោះចលនាតស៊ូបានដំណើរសកម្មភាពក្នុងទឹកដីកម្ពុជា ដោយឯករាជ្យម្ចាស់ការ។ ចំណែកទំនាក់ទំនងជាមួយភូមិភាគខ្លង់រាបរបស់វៀតណាម ដែលនៅជិតនោះ គឺមានតែអៀង សារី ជាលេខាបក្សភូមិភាគឦសានប៉ុណ្ណោះ ជាអ្នកទាក់ទង។ ចំណែកមេដឹកនាំផ្សេងទៀត គ្មានសិទ្ធិទាក់ទងជាមួយវៀតណាម រហេតរហូតបានទេ។

ពីខែធ្នូ ឆ្នាំ១៩៦៦ កែវ មាស ចាប់ផ្តើមមានជំងឺ។ រហូតដល់ខែកញ្ញា ឆ្នាំ១៩៦៧ កែវ មាស ឈឺកាន់តែធ្ងន់ទៅៗ អង្គការក៏សម្រេចឲ្យទៅព្យាបាលនៅបរទេស (វៀតណាមខាងជើង)។

នៃ សារ៉ាន់ ហៅយ៉ា បានបន្តថា ក្នុងឆ្នាំ១៩៦៧ ភូមិភាគឦសាន បានបំផុសចលនាតស៊ូនយោបាយដោយប្រើហិង្សានយោបាយរួមផ្សំអាវុធ តាមមាគ៌ារបស់មជ្ឈិមបក្សយ៉ាងខ្លាំងក្លា។ ពេលនោះពួកវៀតកុង-វៀតណាមខាងជើង ដួលអាក្បត់លន់ នល់ ឱ្យដឹកអង្ករឲ្យវាតាមផ្លូវជាតិលេខ១៩ (រតនគិរី-ស្ទឹងត្រែង)។ ការតស៊ូរបស់ប្រជាជននៅភូមិភាគឦសានបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការដឹកជញ្ជូនរបស់ពួកវៀតកុង-វៀតណាមខាងជើង។

ដោយហេតុនេះហើយ បានជាពួកវៀតកុង-វៀតណាមខាងជើង ប្រឆាំងជំទាស់នឹងមាគ៌ាតស៊ូរបស់ប្រជាជនកម្ពុជាយ៉ាងខ្លាំង។ វៀតណាមសំណូមពរ កុំឲ្យកម្ពុជា តស៊ូខ្លាំងពេក ព្រោះបើតស៊ូខ្លាំងពេក ពួកអាក្បត់លន់ នល់ មិនហ៊ានដឹកអង្ករឲ្យពួកគេទេ។ តែពេលនោះ យើងរក្សាជំហរឯករាជ្យម្ចាស់ការរបស់បក្សបានជាប់រហូត។ ពេលនោះ យើងត្រៀមរៀបចំលក្ខណៈសម្បត្តិផ្ទុះអាវុធតស៊ូសង្គ្រាមផ្ទៃក្នុងនៅឆ្នាំ១៩៦៨។

លុះដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៦៨ ភូមិភាគឦសាន បានផ្ទុះអាវុធ និងប្រកាស

សង្គ្រាមផ្ទៃក្នុង។ ប្រជាជនគ្រប់ជនជាតិបានជម្លៀសចេញពីភូមិកំណើតនៅក្បែរផ្លូវជាតិទាំងអស់ ឱ្យទៅតាំងភូមិថ្មីនៅក្នុងព្រៃជ្រៅ ដែលជាការចាំបាច់ក្នុងការតស៊ូដោយអាវុធនោះ។

តែពួកវៀតកុង-វៀតណាមខាងជើង ប្រឆាំងជំទាស់នឹងចលនាសង្គ្រាមផ្ទៃក្នុងរបស់យើងយ៉ាងខ្លាំងក្លា។ ពួកវាទាមទារកុំឲ្យយើងតស៊ូអាវុធយ៉ាងនេះ វាថា បើតស៊ូយ៉ាងនេះ ការធ្វើសង្គ្រាមបដិវត្តន៍នៅវៀតណាមខាងត្បូង របស់ពួកវាមិនអាចយកជ័យជម្នះបានទេ ព្រោះ ខ្វះប្រកតពស្បៀង។ តែយើងនៅតែឯករាជ្យម្ចាស់ការ ហើយទំនាក់ទំនងរវាងយើង និងពួកវាត្រូវធ្វើដោយស្មើភាពគ្នា គោរពអធិបតេយ្យភាពគ្នាទៅវិញទៅមក ព្រមទាំងមានប្រយោជន៍ទាំងសងខាង។

# ២២៥
# ប្រវត្តិតស៊ូរបស់មេខ្មែរក្រហម សួស នៅ ហៅឈូក

នៅក្នុងឆ្នាំ១៩៤៩ ដោយសារមានជម្លោះឈ្លោះប្រកែកគ្នា ហើយក្មេងនៅវត្តជូចគ្នាបង្អត់បាយ សួស នៅ ហៅឈូក ក៏បានស្ម័គ្រចិត្តចូលបម្រើក្នុងចលនាតស៊ូឥស្សរៈខ្មែរ-វៀតមិញ នៅស្រុករមាសហែក ខេត្តស្វាយរៀង ជាមួយមិត្តភក្តិគាត់ពីរនាក់ទៀត គឺឈ្មោះទុំ និងឈ្មោះកាន តាមរយៈបងជីដូនមួយឈ្មោះលី។

ដំបូង សួស នៅ ហៅឈូក ត្រូវបានថ្នាក់លើចាត់តាំងឱ្យធ្វើជាក្រុមស៊ើបការណ៍។ លុះចូលដល់ឆ្នាំ១៩៥០ គាត់ត្រូវបានថ្នាក់លើចាត់តាំងឱ្យធ្វើជាបុគ្គលិកពេទ្យ នៅក្នុងព្រៃ។ ពេលនោះ សួស នៅ ហៅឈូក ខិតខំរៀនវិជ្ជាពេទ្យផង និងរៀននិយាយភាសា និងសរសេរអក្សរវៀតណាម ផង ព្រោះបុគ្គលិកទាំងអស់នៅក្នុងមន្ទីរពេទ្យនោះសុទ្ធសឹងតែជនជាតិវៀតណាម។

នៅក្នុងឆ្នាំ១៩៥២ គាត់ត្រូវថ្នាក់លើប្តូរឱ្យទៅនៅស្រុកមេមត់ ធ្វើជាអ្នកបកប្រែនៅក្នុងមន្ទីរពេទ្យ និងជាស្មៀនឲ្យលេខាបក្សស្រុកមេមត់ ជាជនជាតិវៀតណាមឈ្មោះ បាត់ដាំង។ នៅស្រុកមេមត់នោះ គាត់មានជំងឺគ្រុនចាញ់ធ្ងន់ធ្ងរស្ទើរបាត់បង់ជីវិត។

មួយឆ្នាំក្រោយមក គឺនៅក្នុងឆ្នាំ១៩៥៣ គាត់ត្រូវថ្នាក់លើបញ្ជូនទៅធ្វើបុគ្គលិកពេទ្យនៅក្នុងកងឈ្លបនៅឃុំពាមជីលាំង ខេត្តកំពង់ចាម (បច្ចុប្បន្នជាខេត្តត្បូងឃ្មុំ)។ នៅចុងឆ្នាំដដែលនោះ ថ្នាក់លើឲ្យគាត់ទៅធ្វើបុគ្គលិកនៅមន្ទីរពេទ្យនៅមូលដ្ឋានតស៊ូសន្ទៃ ក្បែរព្រំដែនវៀតណាម។ តែពេលទៅដល់មន្ទីរពេទ្យនោះ គាត់ត្រូវមេដឹកនាំវៀតណាមប្រគល់ភារកិច្ចឲ្យទៅកាប់ចម្ការដាំស្រូវទៅវិញ ធ្វើឱ្យគាត់មានការអាក់អន់ចិត្តយ៉ាងខ្លាំង។

នៅដើមឆ្នាំ១៩៥៤ អង្គការតស៊ូខ្មែរចាត់តាំងឱ្យសួស នៅ ហៅឈូក ធ្វើជាពេទ្យផងនីរសារផង និងកងការពារនៃ សារ៉ាន់ ហៅយ៉ា ជាកម្មាភិបាលជាន់ខ្ពស់នៅជាមួយ ទូ សាមុត។ ប៉ុន្តែ ប៉ុន្មានខែក្រោយមក ក៏មានកិច្ចព្រមព្រៀងសន្ធិសញ្ញាក្រុងហ្សឺណែវ កងទ័ពវៀតមិញ

ត្រូវដេកចេញពីកម្ពុជា ចលនាតស៊ូខ្មែរត្រូវរំសាយជាបណ្តោះអាសន្នសិន គាត់ត្រូវចូលទៅទីក្រុងភ្នំពេញ ហើយត្រូវអង្គការចាត់តាំងឲ្យលីបាវស្រូវនៅកំពង់ផែគីឡូលេខ៦អស់រយៈពេល៣ខែ ដើម្បីរកលុយមកចិញ្ចឹមឈ្មោះកែវ ហែម និងឈ្មោះយុត យុន ជាអ្នកតស៊ូជើងចាស់។

យុត យុន ជាអតីតអ្នកដឹកនាំចលនាតស៊ូឥស្សរៈខ្មែរ-វៀតមិញ ប្រចាំស្រុកកោះដ៍យ (ស្រុកព្រះស្តេច)ខេត្តព្រៃវែង។ ក្រោយមក មេឃុំកំពង់ប្រាសាទ ស្រុកពាមជរ ខេត្តព្រៃវែង ត្រូវជាប្អូនថ្លៃ បានយកតាយុត យុន ទៅធ្វើជាស្មៀនឃុំកំពង់ប្រាសាទនោះ។ បន្ទាប់ពីរដ្ឋ ប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ភ្លាម កងទ័ពវៀតកុង-វៀតណាមខាងជើង បានចាត់តាំងយុត យុន ឲ្យធ្វើជាប្រធានរណសិរ្សប្រចាំអាគ្នេយ៍ទិស។

ពេលនោះ ដោយសារការងារលីបាវស្រូវនៅកំពង់ផែគីឡូលេខ៦ មានការនឿយហត់លំបាកខ្លាំងពេក គាត់ទៅជួបនៃ សារ៉ាន់ ហៅយ៉ា ជាមេដឹកនាំគាត់កាលតស៊ូនៅក្នុងព្រៃ ដើម្បីឲ្យជួយដោះស្រាយរកកន្លែងធ្វើការណាដែលធូរស្រាលជាងនេះបន្តិច។ នៃ សារ៉ាន់ ហៅយ៉ា ក៏បានជួយធ្វើអន្តរាគមន៍ទៅអង្គការ ឲ្យឈូក ទៅរស់នៅជាមួយកែវ សុវណ្ណ នៅផ្ទះរបស់តាហ៊ី ជាជាងធ្វើកង់នៅម្តុំពេទ្យចិន ដើម្បីធ្វើជានីរសារសម្រាប់ទាក់ទងទៅប្រទេសវៀតណាម។

ពេលនោះ គាត់សុំកង់១គ្រឿង ដើម្បីជិះធ្វើការ។ ប៉ុន្តែ កែវ សុវណ្ណ មិនឱ្យ។ គាត់ក៏មានការអាក់អន់ស្រពន់ចិត្តយ៉ាងខ្លាំង។ ដល់ពេលបោះឆ្នោតឆ្នាំ១៩៥៥ អង្គការឲ្យគាត់ទៅនៅស្នាក់ការកាសែតប្រជាជាតិ ឲ្យធ្វើជានីរសារនាំកាសែតទៅចែកនៅមូលដ្ឋានខេត្តស្វាយរៀង។

ក្រោយបោះឆ្នោតចប់ភ្លាម ដោយសាររាជការសម្តេចសីហនុ រាតត្បាតខ្លាំងពេក ថ្នាក់លើនៅស្នាក់ការកាសែតប្រជាជាតិនោះ នាំគ្នារត់គេចខ្លួនបាត់អស់ នៅសល់តែសួស នៅ ហៅឈូក និងមិត្តគាត់២នាក់ទៀតប៉ុណ្ណោះ ធ្វើឱ្យគាត់មានអារម្មណ៍តែលតោលមិនដឹងទៅណា? ម្យ៉ាងភ័យខ្លាចអាជ្ញាធរចាប់ដាក់គុក។ ម្យ៉ាងអន់ចិត្តអង្គការដែលមិនគិតគូរដល់ពួកគាត់។

ពួកគាត់ក៏នាំគ្នាដើរស្រាយខ្សែ និងបដាឃោសនារបស់គណបក្សប្រជាជន ដែលចង

នៅតាមផ្លូវសាធារណៈ យកទៅលក់បានប្រាក់៥០រៀលមកចែកគ្នា ដើម្បីធ្វើសោហ៊ុយវិលត្រលប់ទៅរស់នៅជាមួយឪពុកម្តាយនៅស្រុកកំណើត ឯខេត្តស្វាយរៀង វិញ។

ឆ្នាំ១៩៥៦ សួស នៅ ហៅឈូក បានរៀបការប្រពន្ធ។ បន្ទាប់មកនៅចុងឆ្នាំ១៩៥៧ គាត់បានភ្ជាប់ខ្សែរយៈទាក់ទងជាមួយចលនាតស៊ូវិញ ហើយបានធ្វើសកម្មភាពតស៊ូបន្តទៅទៀត រហូតដល់អាជ្ញាធរតាមរកចាប់ខ្លួននៅស្រុកកំណើតខ្លាំងពេក គាត់ក៏គេចខ្លួនមកនៅទីក្រុងភ្នំពេញ វិញ ដោយស្នាក់នៅផ្ទះបងប្អូននៅសង្កាត់ទឹកល្អក់ និងប្រកបមុខរបរដើរលក់នំប៉័ង។

ក្រោយពីដើរលក់នំប៉័ងបាន៣ខែ គាត់ក៏បានរកការងារជាកម្មកររោងចក្រផលិតទឹកក្រូចសញ្ញាខ្លា៥ រយៈពេលពីរខែ ក៏មានគំនិតដឹកនាំបងប្អូនកម្មករជាមួយគ្នាដើបប្រឆាំងមិនឲ្យធ្វើការហួសម៉ោង និងទាមទារប្រាក់កម្រៃបន្ថែម។

ពេលនោះ ថៅកែរោងចក្រផលិតទឹកក្រូច ដេញចេញពីការងារ គាត់ក៏ទៅស្នាក់ការកាសែតប្រជាជន នៅខាងត្បូងវត្តលង្កា ដើម្បីជួបថ្នាក់ដឹកនាំកាសែត។ ពេលនោះថ្នាក់ដឹកនាំក៏ទទួលស្គាល់គាត់ ហើយយកទៅនៅផ្ទះដូ ដេត ឲ្យជួយសង់ផ្ទះផងដែរ។ ដូ ដេត ជាកម្មាភិ-បាលតស៊ូជាន់ខ្ពស់។ ក្រោយពួកខ្មែរក្រហមទទួលជ័យជម្នះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដូ ដេត ជាលេខាបក្សភូមិភាគបស្ចិម។

បន្ទាប់ពីសាងសង់ផ្ទះដូ ដេត រួចរាល់ហើយ គាត់ត្រូវបានគេបញ្ជូនឲ្យទៅនៅផ្ទះអ្នកតស៊ូសម្ងាត់ម្នាក់ទៀត ឈ្មោះ ឃ្លាំង នៅទួលគោក និងធ្វើកម្មករសង់ផ្ទះថ្មឱ្យកម្មាភិបាលតស៊ូជាន់ខ្ពស់ឈ្មោះសៀង អាន ដើម្បីចិញ្ចឹមជីវិត។

ក្រោយមកទៀត សៀង អាន បានយកគាត់ឲ្យទៅធ្វើជាស្មៀននៅវិទ្យាល័យកម្ពុជបុត្រជាមួយប៉ែន យុទ្ធ ជាអគ្គានុរក្សវិទ្យាល័យ។ កាលនោះ គាត់ក៏បានជាប់ខ្សែចាត់តាំងបក្សដោយមាននៃ សារ៉ាន់ ហៅយ៉ា មេដឹកនាំគាត់កាលនៅក្នុងព្រៃ ជាលេខាសាខាបក្សប្រចាំវិទ្យាល័យនោះ។

ឈូក ធ្វើការនៅវិទ្យាល័យកម្ពុជបុត្រផង និងទទួលការដឹកនាំធ្វើសកម្មភាពបំផុសសិស្ស

ឲ្យធ្វើបាតុកម្មប្រឆាំងទូតអាមេរិក។ ក្រៅពីនោះ គាត់ខិតខំរកប្រាក់ជួយចិញ្ចឹមប្អូនៗដែល មករៀនសូត្រនៅភ្នំពេញផង, ជួយដល់ពួកកម្មករជាអ្នកតស៊ូផង ជួយកាសែតប្រជាជនផង ព្រមទាំងជួយនង សួន ដែលកំពុងជាប់ពន្ធនាគារព្រៃស និងកូនៗរបស់នង សួន ទៀតផង។

នៅក្នុងឆ្នាំ១៩៦៣ ដោយសាររាជការសម្តេចសីហនុ តាមដានខ្លាំងពេក ឈូក សម្រេចចិត្តសុំអង្គការឈប់ធ្វើការនៅវិទ្យាល័យកម្ពុជបុត្រ ទៅធ្វើសកម្មភាពតស៊ូជាសម្ងាត់វិញ។

ដល់ដើមឆ្នាំ១៩៦៥ អង្គការបានប្រគល់ភារកិច្ចឲ្យឈូក គ្រប់គ្រងបណ្តាញអ្នកតស៊ូនៅក្នុងក្រុមប្រជាជន, អ្នកតស៊ូនៅក្នុងក្រុមសមាគមសន្សំបុណ្យទឹកល្អក់ និងអ្នកតស៊ូនៅក្នុងក្រុមកំពង់ផែកំពង់សោម ដើម្បីដឹកនាំបំផុសឱ្យធ្វើសកម្មភាពបដិវត្តន៍ ។ បណ្តាញអ្នកតស៊ូនៅក្នុងក្រុមទាំង៣ ដែលឈូក ជាអ្នកដឹកនាំនេះ ក៏បិតនៅក្រោមការដឹកនាំផ្ទាល់របស់វន វេត ដែលពេលនោះជាលេខាគណៈកម្មាធិការបក្សទីក្រុងភ្នំពេញ។

ដល់ចុងឆ្នាំ១៩៦៥ អង្គការបានឲ្យឈូក ទៅនៅស្រុកកោះជ័យ (ស្រុកព្រះស្តេច) ដើម្បីបង្កប់ខ្លួនធ្វើសកម្មភាពនៅទីនោះ។

# ២២៦
# ជីវិតតស៊ូរបស់មេខ្មែរក្រហម វន វ៉េត



**វន វ៉េត**

វន វ៉េត មានស្រុកកំណើតនៅខេត្តសៀមរាប ជាកូនកសិករ។ កាលនៅវ័យកុមារ គាត់រៀននៅសាលាបឋមសិក្សានៅស្រុកកំណើត ក្នុងខេត្តសៀមរាប។ លុះដល់ឆ្នាំ១៩៤៨ គាត់បានផ្លាស់ទៅរៀននៅវិទ្យាល័យបាត់ដំបង។ បន្ទាប់ពីប្រលងជាប់ឌីប្លូម ឆ្នាំ១៩៥២ គាត់បានបន្តការសិក្សានៅទីក្រុងភ្នំពេញ ដោយស្នាក់នៅផ្ទះម្ដាយមីងឈ្មោះ យឿន មានប្ដីឈ្មោះ សឹង ស៊ន ហើយផ្ទះនេះក៏ជាទីស្នាក់ការកាសែតប្រជាធិបតេយ្យផងដែរ។ ពេលនោះ សឹង ស៊ន ជាពូថ្លៃរបស់គាត់តែងតែយកកាសែតប្រជាធិបតេយ្យមកឲ្យគាត់អាន និងបានអប់រំ ជារឿយៗ អំពីប្រជាធិបតេយ្យ និងឯករាជ្យជាតិ។

បន្ទាប់ពីបានអានកាសែតប្រជាធិបតេយ្យ និងទទួលការអប់រំពីពូថ្លៃយូរៗទៅ ធ្វើឱ្យគាត់កាន់តែចូលចិត្តចង់ស្ដាប់រឿងនយោបាយខ្លាំងឡើងៗ ក៏សម្រេចចិត្ត ចូលរួមចលនាតស៊ូទាមទារឯករាជ្យពីបារាំង ដែលដឹកនាំធ្វើដោយក្រុមសិស្សនិស្សិត។ ដោយសារនៅវ័យក្មេង

# របត់នយោបាយ

ខ្ញុំ មិនសូវចេះគិតអ្វីវែងឆ្ងាយ ក្នុងខែកក្កដា ឆ្នាំ១៩៥៣ វន វ៉េត បានបោះបង់ការសិក្សា ហើយចាកចេញពីទីក្រុងភ្នំពេញ ទៅចូលរួមក្នុងចលនាតស៊ូខ្មែរឥស្សរៈសាវ៉ាង វង្ស នៅក្នុងព្រៃម្ដុំស្លាបលែង ក្នុងខេត្តកំពង់ស្ពឺ។

ក្រោយពេលរស់នៅជាមួយចលនាតស៊ូខ្មែរឥស្សរៈសាវ៉ាង វង្ស បានរយៈពេល៣ខែ គាត់បានស្គាល់អ្នកតស៊ូជើងចាស់ម្នាក់ឈ្មោះ មាស សម័យ មានវ័យច្រើនជាងគាត់។ ពីមុន មាស សម័យ នេះ ជាអ្នកតស៊ូនៅក្នុងចលនាតស៊ូឥស្សរៈខ្មែរ-វៀតមិញ តែត្រូវពួកខ្មែរឥស្សរៈសាវ៉ាង វង្ស ចាប់បាន។ ដោយសារ មាស សម័យ ធ្លាប់បួសរៀនចេះដឹងជ្រៅជ្រះ និងសរសេរអក្សរស្អាតល្អទៀត សាវ៉ាង វង្ស ក៏ទុកមាស សម័យ ឱ្យជួយសរសេរលិខិតស្នាម និងឯកសារផ្សេងៗជាប្រយោជន៍ដល់ចលនាតស៊ូរបស់ពួកគេ។

មាស សម័យ ចេះតែលួចខ្សឹបប្រាប់គាត់ និងឈ្មោះសុខា ព្រមទាំងឈ្មោះសេង ម្ដងហើយម្ដងទៀតថា ចលនាតស៊ូឥស្សរៈសាវ៉ាង វង្ស នេះ ជាពួកឥស្សរៈចោរ ហើយបារាំង ជាអ្នកបង្កើតពួកឥស្សរៈនេះឡើង ដើម្បីបំភាន់ភ្នែកប្រជាជនតែប៉ុណ្ណោះ។ ដូច្នេះ កុំនៅជាមួយពួកវាតទៅទៀត យើងត្រូវរត់ទៅចូលរួមជាមួយចលនាតស៊ូឥស្សរៈដឹកនាំដោយសឺង ង៉ុកមិញ វិញ។

នៅចុងខែវិច្ឆិកា ឆ្នាំ១៩៥៣ មាស សម័យ បាននាំពួកគាត់ទាំង៣នាក់ រត់ចេញពីចលនាតស៊ូឥស្សរៈសាវ៉ាង វង្ស នៅស្លាបលែង សំដៅទៅភ្នំផុង ជាតំបន់តស៊ូឥស្សរៈដឹកនាំដោយសឺង ង៉ុកមិញ។ ប៉ុន្តែ ពេលរត់ជិតដល់ភ្នំផុង ទៅហើយ ស្រាប់តែពួកសាវ៉ាង វង្ស ដេញតាមទាន់ ក៏ចាប់បានពួកគាត់៣នាក់ យកទៅដាក់គុកនៅខាងលិចភ្នំស្រង់។ ចំណែក មាស សម័យ ស្គាល់ភូមិសាស្ត្រច្បាស់ រត់រួចខ្លួន។

ដល់ខែមីនា ឆ្នាំ១៩៥៤ សាវ៉ាង វង្ស ទម្លាក់អាវុធចុះចូលជាមួយសម្ដេចសីហនុ និងពួកបារាំង គេក៏ដោះលែងពួកគាត់ឲ្យមានសេរីភាពវិញ ហើយគាត់ក៏បានវិលត្រលប់មកស្នាក់នៅផ្ទះម្ដាយមីងឈ្មោះ យឿន ទីស្នាក់ការកាសែតប្រជាធិបតេយ្យ នៅក្រុងភ្នំពេញ វិញ។

ក្រោយពេលមកស្នាក់នៅផ្ទះម្ដាយមីងបាន៣-៤ថ្ងៃ ស្រាប់តែមានខ្សែរយៈតស៊ូសម្ងាត់ម្នាក់ឈ្មោះពឹង សយ ដែលគាត់មិនដែលស្គាល់ទាល់តែសោះ ដឹងច្បាស់ថា គាត់ទើបចេញ

ពីព្រៃ ក៏បានស្គាល់មកជួបគាត់សួរពីដំណើរដើមទង និងគោលបំណងគាត់ចប់សព្វគ្រប់មក ក៏ណែនាំគាត់ថា បើប្អូនឯងមានបំណងចង់ទៅតស៊ូនៅក្នុងព្រៃ ត្រូវទៅនៅជាមួយចលនាមុត្តៈគាហៈ(ចលនាតស៊ូឥស្សរៈដឹកនាំដោយសឹង ង៉ុកមិញ)វិញ ព្រោះចលនាតស៊ូឥស្សរៈនេះជាអ្នកស្នេហាជាតិវាយបារាំង ដណ្ដើមឯករាជ្យពិតប្រាកដ។ ពេលនោះ គាត់ក៏បានយល់ព្រម ព្រោះគាត់បានឮមាស សម័យ ប្រាប់គាត់កាលពីគាត់ទៅនៅជាមួយចលនាតស៊ូឥស្សរៈសារ៉ាំង វង្ស នៅស្លាបលែងនោះដែរ។

នៅដើមខែមេសា ឆ្នាំ១៩៥៤ គាត់បានជិះរថយន្តឈ្នួលចាកចេញពីភ្នំពេញ ទៅស្រុកព្រៃឈរ ដើររកផ្ទះកសិករម្នាក់ឈ្មោះឈុំ ជាបណ្ដាញសម្ងាត់របស់ចលនាតស៊ូ។ គាត់ដើរសួរអ្នកស្រុក រហូតដល់យប់ទើបរកឈ្មោះ ឈុំ ឃើញហើយ ឈ្មោះ ឈុំ ក៏បានជូនដំណើរគាត់កាត់ព្រៃទៅមន្ទីរសម្ងាត់របស់ចលនាតស៊ូស្រុកចម្ការលើ បន្តទៀត។ ពេលនោះ ក៏មានឈ្មោះសុខ ខ្នុល បានធ្វើដំណើរទៅជាមួយដែរ។ តែគាត់មិនដែលស្គាល់សុខ ខ្នុល ទេ ព្រោះម្នាក់នេះ ទើបតែមកពីប្រទេសបារាំង។

ពេលទៅដល់មន្ទីរសម្ងាត់របស់ស្រុកចំការលើ ដែលនៅក្នុងព្រៃជ្រៅនោះ គាត់ឃើញសុទ្ធតែយុទ្ធជនខ្មែរឥស្សរៈ និងវៀតមិញ។ បន្ទាប់មក គេបាននាំគាត់បន្តទៅមន្ទីរសម្ងាត់របស់ស្រុកស្ទឹងត្រង់ ទៀត។

ក្រោយពីពួកគាត់ស្នាក់នៅមន្ទីរសម្ងាត់របស់ស្រុកស្ទឹងត្រង់នោះ មួយរយៈខ្លីមក ពួកនីរសារវៀតមិញ ក៏មកនាំពួកគាត់ឆ្លងទន្លេមេកុង រួចនាំដើរកាត់ព្រៃ រហូតទៅដល់ជំរំតស៊ូមួយនៅភូមិសន្ទៃ ក្នុងភូមិភាគបូព៌ា ក្បែរព្រំដែនវៀតណាម ។ នៅជំរំតស៊ូនោះ គាត់ឃើញមានបញ្ញាជន៨-១០នាក់ ក្នុងនោះមានសាឡុត ស ម្នាក់ផងដែរ។

ចំណែក ទូ សាមុត មេដឹកនាំធំជាងគេ យូរៗមកមន្ទីរនោះម្ដង។ ពេលនោះហើយ ដែលគាត់បានជួប និងស្គាល់មុខទូ សាមុត។ ប៉ុន្តែ គាត់នៅទីនោះបានប្រហែល៣ខែ ស្រាប់តែនៅក្នុងខែកក្កដា ឆ្នាំ១៩៥៤ ក៏មានកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ដើម្បីបញ្ចប់សង្គ្រាមនៅឥណ្ឌូចិនទាំងមូល។ មេដឹកនាំតស៊ូនៅទីនោះ ក៏បានយកឯកសារខ្លឹមសារនៃកិច្ចព្រមព្រៀង

ក្រុងហ្សឺណែវនោះ មកអប់រំផ្សព្វផ្សាយឱ្យពួកគាត់បានដឹង និងបានយល់ ហើយអ្នកតស៊ូខ្មែរនៅជំរំនោះទាំងអស់ក៏ត្រូវប្រកាសរំសាយផងដែរ។

នៅក្នុងខែកញ្ញា ឆ្នាំ១៩៥៤ ទូ សាមុត បានហៅគាត់ និងសុខ ខ្នុល មកប្រាប់ថា នឹងឲ្យពួកគាត់វិលត្រលប់ទៅភ្នំពេញ វិញ តែត្រូវរង់ចាំនីរសារមកនាំផ្លូវចេញពីព្រៃតស៊ូនោះទៅរកផ្លូវជាតិ។ មុនពេលចេញដំណើរ ទូ សាមុត បានឲ្យ នៃ សារ៉ាន់ ហៅយ៉ា យកប្រាក់មកឲ្យគាត់ និងសុខ ខ្នុល ម្នាក់ ១០០រៀល ទុកសម្រាប់ធ្វើដំណើរទៅភ្នំពេញ វិញ ហើយប្រាប់ពួកគាត់ថា ចាំចូលដល់ភ្នំពេញ ចាំរកខ្សែរយៈទាក់ទងគ្នាទៀត។

លុះដល់ចុងខែតុលា ឆ្នាំដដែល វន វ៉េត និងសុខ ខ្នុល បានធ្វើដំណើរតាមផ្លូវជាតិលេខ ១ ពីខេត្តស្វាយរៀង មកដល់ទីក្រុងភ្នំពេញ ហើយបែកគ្នានៅត្រង់ក្បាលស្ពានព្រះមុនីវង្ស។ គាត់ទៅស្នាក់នៅផ្ទះម្ដាយមីងគាត់នៅទីស្នាក់ការកាសែតប្រជាធិបតេយ្យ ដូចមុនដដែល។ គាត់រស់នៅជាមួយម្ដាយមីងនោះ បានប៉ុន្មានថ្ងៃ ក៏បានជួបពឹង សយ ជាថ្មីម្ដងទៀត។ តាមរយៈពឹង សយ គាត់បានជាប់ខ្សែជាមួយសាឡុត ស ចាប់ពីពេលនោះមក។ សាឡុត ស បានណែនាំគាត់ឲ្យចូលបង្រៀននៅវិទ្យាល័យឯកជនចំរើនវិជ្ជា។

ក្នុងខែធ្នូ ឆ្នាំ១៩៥៤នោះ សាឡុត ស ក៏បានបញ្ចូលគាត់ជាបក្ខជននៅសាខាបក្សជាមួយម៉ី ផាត។ បន្ទាប់មក គាត់មានទំនាក់ទំនងជាមួយផ្លែក ភឿន បន្តទៀត។

ចាប់ពីឆ្នាំ១៩៥៦មក គាត់តែងតែធ្វើសកម្មភាពបំផុសមហាជនឲ្យប្រឆាំងសន្ធិសញ្ញាយោធាខ្មែរ-អាមេរិក។ ឆ្នាំ១៩៥៩ គាត់បានចូលក្នុងជួរមេដឹកនាំចលនាតស៊ូប្រចាំក្រុងភ្នំពេញ។

ឆ្នាំ១៩៦០ គាត់បានដឹកនាំអង្គការមហាជនឲ្យឃោសនានយោបាយដោយចំហ រហូតដល់អាជ្ញាធរសម្ដេចសីហនុ ធ្វើការបង្ក្រាបរាតត្បាតយ៉ាងសាហាវឃោរឃៅបំផុត។ ក្នុងខែកុម្ភៈ ឆ្នាំ១៩៦៣ ក្នុងពេលប្រារព្ធពិធីមហាសន្និបាតបក្ស គាត់ត្រូវបានចាត់តាំងជាសមាជិកគណៈ-កម្មាធិការមជ្ឈិមបក្ស។ ក្នុងខែកុម្ភៈ ឆ្នាំ១៩៦៣នោះ មេដឹកនាំសំខាន់ៗមួយចំនួនត្រូវគេចខ្លួនចេញទៅជនបទ គាត់នៅទទួលខុសត្រូវសកម្មភាពចលនាតស៊ូបដិវត្តន៍ប្រចាំក្រុងភ្នំពេញ។

ពេលនោះ គាត់ខិតខំកសាង និងពង្រីកកម្លាំងយុវកប(យុវជនប្រជាធិបតេយ្យ)ដើម្បី

ចូលរួមជាកម្លាំងចលនាបដិវត្តន៍។ កម្លាំងដែលគាត់កសាងបានពេលនោះ រួមមាន អ៊ិត ហេង, ហេង ធី, ម៉ែន ជន ហៅហឹង្ស និងសូ ភាគ ជាដើម ហើយឆក់ឱកាសបានល្អ ពេលសម្តេចសីហនុប្រកាសឈប់ទទួលជំនួយអាមេរិក ចលនាបដិវត្តន៍កាន់តែមានកម្លាំងខ្លាំងក្លាថែមទៀត។

ពីឆ្នាំ១៩៦៤មក គាត់ដឹកនាំចលនាតស៊ូនៅក្នុងក្រុងភ្នំពេញ គាត់ទទួលខាងបក្ស និងមិត្តកឺ ទទួលខាងយុវជន និងចេង អន (ធ្វើការនៅរោងពុម្ពយុវពាណិជ្ជភ្នំពេញ)ទទួលខុសត្រូវខាងកម្មករ។

គាត់ស្គាល់មិត្តកឺ ឈ្មោះដើម គង់ សុផល តាំងពីឆ្នាំ១៩៥៦ ពេលនៅទឹកល្អក់ជាមួយគ្នា។ ក្រោយមក មិត្តកឺ បានចូលជាបក្ខជន តាមរយៈសុន សេន ហៅខៀវ ហើយធ្លាប់ប្រជុំជីវភាពបក្ស និងរៀនសូត្រជាមួយគ្នាញឹកញាប់ទៀតផង។ ចំណែកចេង អន ធ្លាប់ធ្វើការជាមួយគាត់យូរហើយ។ ចេង អន គោរពស្រលាញ់គាត់ណាស់។ គាត់ចង់ណែនាំយ៉ាងណា ក៏ចេង អន ធ្វើតាមការណែនាំរបស់គាត់ដែរ។

ក្រោយពីមានការបង្ក្រាបរបស់អាជ្ញាធរសម្តេចសីហនុ នៅចុងឆ្នាំ១៩៦៤ មិត្តកឺ ត្រូវចេញទៅតំបន់ជនបទ ខាងភូមិភាគពាយ័ព្យ។ បន្ទាប់មក ចេង អន ក៏ត្រូវដកទៅតំបន់ជនបទខាងភូមិភាគនិរតីដែរ ខណៈយុវជនមួយចំនួន ត្រូវអាជ្ញាធរសម្តេចសីហនុ ចាប់ដាក់គុក ហើយមួយចំនួនទៀត ត្រូវចេញទៅតំបន់ជនបទជាបន្តបន្ទាប់។ ពេលខ្វះកម្លាំង វន វ៉េត ជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស និងជាលេខាបក្សទីក្រុងភ្នំពេញ បានសុំកម្លាំងកម្មាភិបាលមួយចំនួន ដូចជា ៖ នួន យាង, តឹក គឹមអន និងលាង គឹមហួត ជាដើម ពីភូមិភាគឧត្តរ។

បន្ទាប់ពីដកកម្មាភិបាលមួយចំនួនទៅជនបទ គណៈកម្មាធិការបក្សក្រុងភ្នំពេញ ត្រូវបានរៀបចំជាថ្មី ដោយមានរូបគាត់ជាលេខាដដែល, ដាំ ផេង អនុលេខា និងលាង គឹមហួត (ដែលកុយ ធួន ហៅធុច លេខាភូមិភាគឧត្តរ ឲ្យមកពីខេត្តកំពង់ចាម) ជាសមាជិក ចលនាបដិវត្តន៍ចេះតែមានសន្ទុះទៅមុខជាលំដាប់។

ឆ្នាំ១៩៦៤នោះដែរ នៃ សារ៉ាន់ ហៅយ៉ា ត្រូវដកឱ្យទៅនៅជាមួយសាឡុត ស នៅមូលដ្ឋានតស៊ូក្នុងខេត្តតៃនិញ វៀតណាមខាងត្បូង។ នៃ សារ៉ាន់ ហៅយ៉ា បានប្រគល់កម្លាំង

របស់ខ្លួនមួយចំនួនមកឲ្យគាត់គ្រប់គ្រងបន្ត ក្នុងនោះ រួមមាន៖ សួស នៅ ហៅឈូក, សៅ កង និងស៊ាត ឆៃ ហៅអាចារ្យទុំ។ លុះដល់ឆ្នាំ១៩៦៥ សួស នៅ ហៅឈូក និងស៊ាត ឆៃ ហៅអាចារ្យទុំ ត្រូវដកទៅមូលដ្ឋានតស៊ូក្នុងជនបទ និងនៅក្នុងព្រៃទៀត។

ឆ្នាំ១៩៦៦ គាត់បានជិះឡានជាមួយ សោ ភឹម លេខាបក្សភូមិភាគបូព៌ា ទៅខេត្តសៀមរាប។ សោ ភឹម ផឹកស្រាជាប់ជាប្រចាំ។ ពេលនោះ គាត់ក៏បានស្គាល់ទីវ អុល ដែលធ្លាប់ទាក់ទងជាមួយម៉ី ផាត។

ឆ្នាំ១៩៦៧ ខណៈការតស៊ូរបស់ប្រជាជនកាន់តែមានសន្ទុះខ្លាំងឡើងៗ រហូតមានការផ្ទុះអាវុធជាជំហានដំបូង នៅស្រុកសំឡូត ខេត្តបាត់ដំបង គាត់បានបំផុសចលនាតស៊ូនយោបាយ រួមផ្សំនឹងចលនាតស៊ូរបស់កសិករនៅបាត់ដំបង នោះដែរ និងបន្តជំរុញចលនាបដិវត្តន៍នៅក្រុងភ្នំពេញ បន្ថែមទៀត។

នៅក្នុងឆ្នាំ១៩៦៨ នៅជនបទ ចលនាតស៊ូបដិវត្តន៍ ផ្ទុះអាវុធស្ទើរតែពាសពេញផ្ទៃប្រទេស ហើយត្រូវការកម្លាំងពីក្រុងភ្នំពេញ បន្ថែមទៀត គាត់ក៏បានបញ្ចេញអាចារ្យកង, សាយ, ម៉ៅ, សី, សុន, វ៉ែន និងអ្នកផ្សេងទៀត ទៅភូមិភាគនិរតី ព្រោះខាងភូមិភាគនិរតី ស្រួលទាក់ទងជាងភូមិភាគឯទៀតៗ។

ខែកក្កដា ឆ្នាំ១៩៦៨ នៅក្រុងភ្នំពេញ កម្លាំងសមត្ថកិច្ចរបស់សម្តេចសីហនុ បង្កើនការបង្ក្រាបចលនាតស៊ូនៅទីក្រុងភ្នំពេញ ខ្លាំងក្លាពេក ចលនាតស៊ូបាត់ខ្សែរយៈមូលដ្ឋានផ្ទៃក្នុងខ្លះត្រូវរត់ចោលផ្ទះ ទាក់ទងគ្នាមិនបានអស់មួយរយៈ ហើយគាត់ក៏ត្រូវកម្លាំងសមត្ថកិច្ច រកចាប់ខ្លួន។ គាត់គេចខ្លួនទៅស្នាក់នៅផ្ទះឈ្មោះខ្មៅ មួយរយៈ។

ប្រហែល២ខែក្រោយមក ទើបទាក់ទងមូលដ្ឋានយុវជន និងកម្មករតស៊ូ បានខ្លះៗ គាត់ក៏បានចេញពីផ្ទះឈ្មោះខ្មៅ ទៅនៅផ្ទះខាងយុវជនតស៊ូវិញ។ នៅក្នុងខែសីហា ឆ្នាំ១៩៦៨ ដាំ ផេង អនុលេខាគណៈកម្មាធិការបក្សក្រុងភ្នំពេញ និងជាលេខាសម្ព័ន្ធយុវកក (យុវកុម្មុយនីស្តកម្ពុជា) ក្រុងភ្នំពេញ ត្រូវកម្លាំងសមត្ថកិច្ចចាប់យកទៅធ្វើទារុណកម្មសួរចម្លើយយ៉ាងសាហាវឃោរឃៅបំផុត រហូតដល់បាត់បង់ជីវិតនៅក្នុងបន្ទប់ឃុំឃាំង។

ឆ្នាំ១៩៦៩ ដោយអស់អ្នកតស៊ូជួយធ្វើការ គាត់បានយកមិត្តហង្ស ឲ្យមកធ្វើជាជំនួយការចលនាតស៊ូក្រុងភ្នំពេញ ព្រោះមិត្តហង្ស មិនទាន់បែកមុខ អាចដើរទាក់ទងមូលដ្ឋានតស៊ូក្នុងក្រុងភ្នំពេញ ជាចំហបានស្រួលជាងគាត់។ ពេលនោះ ចលនាតស៊ូដែលរប៉ាត់រប៉ាយត្រូវបានប្រមូលមកវិញ ហើយចាប់ផ្ដើមដំណើរការបំផុសចលនាតស៊ូក្នុងជួរយុវជនបានជាបណ្ដើរៗឡើងវិញ។

ចុងឆ្នាំ១៩៦៩ គាត់ចេញពីក្រុងភ្នំពេញ ទៅប្រជុំរៀនសូត្រនៅភ្នំឱរ៉ាល់ ភូមិភាគនិរតី។ ពេលនោះ គាត់ឃើញកម្លាំងចលនាតស៊ូមានសន្ទុះផុសផុលខ្លាំងណាស់។ គាត់យល់ឃើញថាទៅអនាគត ពួកចក្រពត្តិអាមេរិក និងវណ្ណៈកាន់អំណាច មិនអាចទប់ទល់បានឡើយ។ តែគាត់ក៏មានជំងឺគ្រុនចាញ់អស់ច្រើនខែ នៅភ្នំឱរ៉ាល់ នោះដែរ។

នៅពេលគាត់ទៅប្រជុំរៀនសូត្រ នៅភ្នំឱរ៉ាល់ ការងារដឹកនាំចលនាតស៊ូនៅក្រុងភ្នំពេញ មិត្តហង្ស ជាអ្នកចាត់ចែងជំនួស។

នៅដើមខែមីនា ឆ្នាំ១៩៧០ ទើបគាត់ត្រលប់មកដល់ទីក្រុងភ្នំពេញ វិញ ហើយរាយការណ៍ឱ្យម៉ី ផាត បានដឹងពីសភាពការណ៍តស៊ូនៅជនបទ។ ម៉ី ផាត បានជំរុញឱ្យគាត់ខិតខំពង្រីក និងពង្រឹងកម្លាំងចលនាតស៊ូនៅក្រុងភ្នំពេញ ឱ្យកាន់តែខ្លាំងក្លាថែមទៀត។ ក្រោយជ័យជម្នះថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ វន វ៉េត បានឡើងឋានៈជាសមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា និងជាឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីសេដ្ឋកិច្ច។

# ២២៧
# សាស្ត្រាចារ្យ កុយ ធួន ក្លាយជាមេខ្មែរក្រហម



**កុយ ធួន កាលនៅជាសាស្ត្រាចារ្យ ថតជាមួយម្តាយឪពុក និងប្រពន្ធកូន**

ឆ្នាំ១៩៤៩ ដល់ឆ្នាំ១៩៥០ កុយ ធួន ចូលរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ។ ពេលនោះទើបគាត់ស្គាល់មុខអ៊ុង ស៊ីម រៀនថ្នាក់ទីបញ្ចប់ និងរស់ សារិន រៀនថ្នាក់ទី១ ទំនើប ដែលល្បីថា សកម្មបំផុតក្នុងពេលមានបាតុកម្ម និងកូដកម្មប្រឆាំងរាជការ និងពួកអាណានិគមនិយមបារាំង ម្តងៗ។

លុះគាត់រៀនដល់ថ្នាក់ទី៣ទំនើប គាត់បានជួបមិត្តភក្តិចាស់ម្នាក់មកពីខេត្តកំពង់ចាមជាមួយគ្នា ឈ្មោះអ៊ឹង យុនហ៊ាង (រៀនថ្នាក់ទី២ ទំនើប) ជាមិត្តរាប់អានគ្នារាក់ទាក់ជិតស្និទ្ធ ហើយនាំគាត់ដើរលេងស៊ីចុកជាញឹកញាប់។ បន្ទាប់មក អ៊ឹង យុនហ៊ាង ក៏ឃោសនាអប់រំគាត់ និងលើកសរសើរអំពីពួកប្រជាចលនារួមខ្មែរបម្រើជាតិរបស់សឹង ង៉ុកថាញ់ ដែលហៅកាត់ថាពួកប្រជាចលនា។

ដោយសារ កុយ ធួន មានកំហឹងជាមួយពួកស្តេចផង ហើយក៏ធ្លាប់ទទួលឥទ្ធិពលកាលស្នាក់នៅក្នុងវត្តផង គាត់ក៏ទទួលឥទ្ធិពលអប់រំពីឈ្មោះអ៊ឹង យុនហ៊ាង យ៉ាងឆាប់រហ័ស។

ក្រោយមក អ៊ឹង យុនហ៊ាង ក៏បានណែនាំឲ្យគាត់ស្គាល់ឈ្មោះរស់ សារិន ដាមេដឹកនាំសិស្ស ឱ្យធ្វើបាតុកម្ម និងកូដកម្មនោះ ហើយអ៊ឹង យុនហ៊ាង បានប្រាប់គាត់ថា រស់ សារិន ជាមិត្តចាស់របស់គេរាប់អានគ្នាយូរមកហើយ។

ក្នុងឆ្នាំ១៩៥៣ អ៊ឹង យុនហ៊ាង បាននាំគាត់ទៅផ្ទះហង្ស ធុនហាក់ នៅខាងក្រោយវិទ្យាល័យព្រះស៊ីសុវត្ថិ។ ពេលចូលទៅដល់ផ្ទះ គាត់ឃើញហង្ស ធុនហាក់ និងរស់ សារិន កំពុងអង្គុយរង់ចាំគាត់ ហើយទទួលគាត់ដោយរាក់ទាក់។ បន្ទាប់មក អ៊ឹង យុនហ៊ាង ក៏បានឧទ្ទេសនាមឲ្យហង្ស ធុនហាក់ ស្គាល់គាត់ ហើយឱ្យគាត់មកធ្វើការជាមួយហង្ស ធុនហាក់ នៅពេលក្រោយៗទៀត។

ក្រោយមក គាត់ក៏បានមកជួបហង្ស ធុនហាក់ ម្ដងទៀត ហើយហង្ស ធុនហាក់ ក៏បានឧទ្ទេសនាមអំពីកម្មវិធីនយោបាយនៃអង្គការប្រជាចលនា( ប្រជាចលនារួមខ្មែរបម្រើជាតិ ដឹកនាំដោយសឹង ង៉ុកថាញ់) ឲ្យគាត់ស្ដាប់ និងបានពិភាក្សាគ្នាយ៉ាងល្អិតអន់។ បន្ទាប់មក ហង្ស ធុនហាក់ ក៏បានប្រគល់ភារកិច្ចឲ្យគាត់ជួយឃោសនាកម្មវិធីនយោបាយរបស់ អង្គការប្រជាចលនា ក្នុងចំណោមយុវជនដូចគ្នា និងត្រូវរក្សាការសម្ងាត់ផងដែរ។ កន្លះខែម្ដង គាត់តែងតែទៅជួបហង្ស ធុនហាក់ នៅផ្ទះខាងក្រោយវិទ្យាល័យព្រះស៊ីសុវត្ថិនោះ ពិភាក្សាគ្នាជាងមួយម៉ោង ឬពីរម៉ោង ទើបចប់ ។ ជួនកាល អ៊ឹង យុនហ៊ាង ក៏ទៅពិភាក្សាជាមួយដែរ។

បន្ទាប់មក គាត់ក៏បាននាំមិត្តបីនាក់ទៀត គឺឈ្មោះសារ៉េត, បាន និងខន ដែលនៅវត្តលង្កា និងជាសិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ ជាមួយគ្នាទៅជួបហង្ស ធុនហាក់ ហើយទាំង៤នាក់ ហង្ស ធុនហាក់ ឱ្យធ្វើការក្នុងខ្សែចាត់តាំងតែមួយ។ ក្រោយមក ដោយមានការជឿទុកចិត្តហើយ ហង្ស ធុនហាក់ ក៏ចាត់តាំងពួកគាត់ទាំង៤នាក់ឲ្យចូលជាសមាជិកនៃអង្គការប្រជាចលនា។

ចាប់ពីពេលនោះមក ពួកគាត់ក៏មានលុយកាក់ចាយវាយហូរហៃ ដោយហង្ស ធុនហាក់ ជាអ្នកជួយផ្គត់ផ្គង់។ បន្ទាប់មកទៀត នៅវិទ្យាស្ថានជាតិគរុកោសល្យ ក៏មាន លាង ហាប់អាន, មាស សាន និងយ៉ៅ ម៉ាឡាំង ជាដើម ក៏ចូលជាសមាជិកក្នុងអង្គការប្រជាចលនានេះដែរ។

# របត់នយោបាយ

ឆ្នាំ១៩៥៤ កុយ ធួន បានប្រលងជាប់ជាគ្រូបង្រៀន(បឋមសិក្សា) ត្រូវទៅនៅធ្វើការនៅស្រុកសំបូរ ខេត្តក្រចេះជាមួយមិត្តភក្តិគាត់៣នាក់ ក្នុងនោះ ពីរនាក់មកពីខេត្តព្រៃវែង និងម្នាក់ទៀតមកពីខេត្តស្វាយរៀង។

ដោយសារ ស្រុកសំបូរ នៅឆ្ងាយដាច់ស្រយាល ការទាក់ទងរវាងគាត់ជាមួយហង្ស ធុនហាក់ ក៏រយាលទៅៗ។ ២ ឬ៣ខែ ទើបគាត់អាចឡើងទៅជួបគ្នាម្តង។ នៅស្រុកសំបូរ គាត់យកចិត្តទុកដាក់ឃោសនាអប់រំកម្មវិធីនយោបាយអង្គការប្រជាចលនា បានមួយកម្រិតដែរ។ តែមិនទាន់បានធ្វើការចាត់តាំងអ្វីជាធំដុំទេ ព្រោះគាត់មិនធ្លាប់មានបទពិសោធ។

ក្រោយមក គាត់អប់រំបានមនុស្សមួយចំនួន ដូចជា ពូទូង តាំងឡេង ជាគ្រូបង្រៀន, ចាប លន់ ជាគ្រូបង្រៀន, ឈឺ ស៊ុយឡាង ជាគ្រូបង្រៀន, សំអាត ជាគ្រូបង្រៀន, ចាប សុខ ជាគ្រូបង្រៀន, រ៉េ ឆោមឌឿន ជាគ្រូបង្រៀន...។

ក្នុងឆ្នាំ១៩៥៥ មានការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ឈ្មោះឈុំ ដែលជាឪពុកមារបស់រ៉ែន ប៉េងគិត បានឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្ររបស់ក្រុមប្រជាចលនា ជ្រកក្រោមផ្លាកគណបក្សប្រជាធិតេយ្យ នៅស្រុកស្រីសន្ធរ។ ពេលនោះ រ៉ែន ប៉េងគិត បាននាំកុយ ធួន, អ៊ុំវ យ៉ាង និងអ៊ុង ស៊ីម ទៅជួយឃោសនាដែរ។

កុយ ធួន ក៏បានយកចិត្តទុកដាក់ជួយឃោសនាតាមការណែនាំរបស់ហង្ស ធុនហាក់ដែរ។ តែការបោះឆ្នោតនោះត្រូវចាញ់ចលនាសង្គមរាស្ត្រនិយម ហើយគាត់ក៏ត្រូវចៅហ្វាយស្រុករកឃាត់ខ្លួន ក៏រត់ទៅស្រុកសំបូរខេត្តក្រចេះ វិញ។

ក្រោយពេលបោះឆ្នោតនោះមក អង្គការប្រជាចលនារបស់សឹង ង៉ុកថាញ់ ដែលជ្រកក្រោមផ្លាករបស់គណបក្សប្រជាធិបតេយ្យត្រូវបែកការណ៍ អ្នកដែលគាត់អប់រំឱ្យជឿលើអង្គការប្រជាចលនារបស់សឹង ង៉ុកថាញ់ នៅស្រុកសំបូរ ក៏មានការភ័យខ្លាច ហើយគាត់ក៏មានការព្រួយបារម្ភដែរ។

ពេលនោះ ស្រាប់តែចៅហ្វាយខេត្តក្រចេះ ឈ្មោះទេព ស៊ុន្នី បានហៅគាត់ទៅព្រមានឱ្យឈប់ចូលរួមក្នុងអង្គការប្រជាចលនា (ខ្មែរសេរី) និងគណបក្សប្រជាធិបតេយ្យ ឲ្យងាក

មកជួយចលនាសង្គមរាស្ត្រនិយម របស់សម្តេចសីហនុ វិញ។ នៅក្នុងឆ្នាំ១៩៥៦ កុយ ធួន ត្រូវបានរាជការតែងតាំងជានាយតំបន់សិក្សា នៅទីរួមខេត្តក្រចេះ ហើយនៅដំណាច់ឆ្នាំសិក្សា ១៩៥៧-១៩៥៨ ក្រោយប្រលងជាប់ជានិស្សិតសាស្ត្រាចារ្យ គាត់ត្រូវត្រលប់ទៅទីក្រុងភ្នំពេញ ដើម្បីចូលរៀននៅវិទ្យាស្ថានជាតិគរុកោសល្យ។

នៅពេលចូលរៀននៅវិទ្យាស្ថានជាតិគរុកោសល្យនោះ គាត់ក៏បានទាក់ទងជាមួយសុន សេន (ជាសាស្ត្រាចារ្យឆ្វេងនិយមនៅវិទ្យាស្ថានជាតិនោះ) និងទីវ អុល ជាគរុនិស្សិតដូចគ្នា ចូលរួមចលនាតស៊ូសម្ងាត់របស់បក្សពលករកម្ពុជា ចាប់ពីពេលនោះមក។

ដោយសារគាត់សកម្មក្នុងចលនាតស៊ូសម្ងាត់ នៅខែកក្កដា ឆ្នាំ១៩៦០ គាត់ក៏ត្រូវបាន សុន សេន និងទីវ អុល ឧទ្ទេសនាមបញ្ចូលជាបក្ខជន។ ក្រោយពីបានក្លាយខ្លួនទៅជាបក្ខជន មក គាត់ត្រូវនៅក្នុងសាខាបក្សជាមួយសុន សេន និងថាច់ ខែត។ ក្រោយមក គាត់ត្រូវបាន បក្សពលករកម្ពុជា ចាត់តាំងជាលេខាបក្សភូមិភាគឧត្តរ។

ចំណែក ជិន អ៊ា ហៅស៊ូ ជាប្អូនប្រុសបានចាកចេញពីឪពុកម្តាយ និងស្រុកកំណើត នៅខេត្តក្រចេះ នៅក្នុងឆ្នាំ១៩៥០ ទៅរស់នៅទីក្រុងភ្នំពេញ ជាមួយបងប្រុសគាត់ឈ្មោះ កុយ ធួន ហៅធុច។ លុះដល់ឆ្នាំ១៩៥៥ គាត់បានវិលត្រលប់មករៀននៅខេត្តក្រចេះវិញ។ លុះដល់ឆ្នាំ១៩៦០ គាត់បានត្រលប់ទៅរៀនទីក្រុងភ្នំពេញ ម្តងទៀត រៀននៅវិទ្យាល័យព្រះ យុគន្ធរ។ ម្តងនេះ កុយ ធួន ជាបងប្រុសគាត់បានអប់រំពីបញ្ហានយោបាយឲ្យយល់ដឹងពី លទ្ធិមូលធននិយម និងលទ្ធិកុម្មុយនិស្តនិយម។

រៀននៅវិទ្យាល័យព្រះយុគន្ធរ បានតែ២ឆ្នាំ បងប្រុសក៏ឱ្យគាត់ក៏វិលត្រលប់ទៅរៀន នៅវិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម វិញ ដោយផ្ញើគាត់ឲ្យស្នាក់នៅផ្ទះរបស់ឈ្មោះទិន គឹមហុង និងតឹក គឹមអុន ជាបណ្តាញតស៊ូសម្ងាត់របស់ពួកអ្នកតស៊ូ ហើយអ្នកទាំងពីរនេះ ក៏បានអប់រំណែនាំគាត់ឲ្យយល់ពីរបបសេរី និងរបបកុម្មុយនិស្ត ដូចកុយ ធួន ជាបងប្រុស របស់គាត់ដែរ។

ចុងឆ្នាំ១៩៦៤ គាត់បានត្រលប់មកទីក្រុងភ្នំពេញវិញ និងបានធ្វើជាគ្រូបង្រៀននៅ

វិទ្យាល័យឯកជនចំរើនវិជ្ជា។ ពេលនោះ គាត់បានទាក់ទងធ្វើសកម្មភាពតស៊ូជាមួយសូ សាផល និងតាំង ខៃត ជាគ្រូបង្រៀននៅវិទ្យាល័យជាមួយគ្នានោះដែរ។ លុះដល់ឆ្នាំ១៩៦៨ គាត់ក៏ផ្លាស់ទៅបង្រៀននៅវិទ្យាល័យកម្ពុជបុត្រ និងខិតខំធ្វើសកម្មភាពបម្រើចលនាតស៊ូខ្មែរក្រហមយ៉ាងសកម្ម។

នៅដើមឆ្នាំ១៩៦៩ គាត់ត្រូវកម្លាំងសមត្ថកិច្ចរាជការសម្ដេចសីហនុ ចាប់យកទៅដាក់គុកព្រៃស រហូតដល់ក្រោយរដ្ឋប្រហារថ្ងៃ១៨ មីនា ឆ្នាំ១៩៧០ ទើបគាត់បានរួចពីគុកវិញ ដោយសារពួកលន់ នល់ មេដឹកនាំរដ្ឋ ប្រហារមានគោលការណ៍ដោះលែងអ្នកទោសនយោបាយទាំងអស់ចេញពីពន្ធនាគារវិញ។

ពេលសង្គ្រាមផ្ទុះឡើង គាត់មិនបានចាកចេញពីទីក្រុងភ្នំពេញ ទៅតំបន់រំដោះនៅភូមិភាគឧត្តរ ដែលមានបងប្រុសគាត់ឈ្មោះកុយ ធួន ជាលេខាបក្សទេ។ រហូតដល់ឆ្នាំ១៩៧១ ទើបមាននីរសារជាបណ្ដាញតស៊ូខ្មែរក្រហមម្នាក់ឈ្មោះហេង បានមកនាំគាត់ទៅជួបស៊ាត ឆែ ហៅទុំ (អតីតសិស្សជំនិតរបស់សាឡុត ស និងខៀវ ប៉ុណ្ណារី) ជាលេខាបក្សតំបន់២២ ភូមិភាគបូព៌ា ដែលមានទីតាំងនៅភូមិមហាលាភ ឃុំមហាលាភ ស្រុកកោះសូទិន។ ក្រោយមក ជិន អ៊ា ហៅស៊ូ ត្រូវបានចាត់តាំងជាប្រធានពាណិជ្ជកម្មតំបន់២២។

ក្នុងអំឡុងចុងទសវត្សរ៍ឆ្នាំ១៩៦០ ទោះបីរាជរដ្ឋាភិបាលចលនាសង្គមរាស្ត្រនិយមរបស់សម្ដេចសីហនុ បង្ក្រាបចលនាតស៊ូខ្មែរក្រហមយ៉ាងណា ក៏ដោយ ក៏នៅតែមានសាស្ត្រាចារ្យ, គ្រូបង្រៀន និងសិស្សនិស្សិត ជាច្រើនបានស្ម័គ្រចិត្តលះបង់អ្វីៗគ្រប់យ៉ាងចូលរួមក្នុងចលនាតស៊ូកុម្មុយនិស្ត កាន់តែច្រើនឡើងៗ ក្នុងនោះ ក៏មានសិស្សម្នាក់នៅវិទ្យាល័យព្រះអង្គឌួង ឈ្មោះហែម សុត ហៅសៀន ផងដែរ។

ហែម សុត ហៅសៀន កើតនៅក្នុង ឆ្នាំ១៩៤៩ នៅភូមិក្រចាប់ក្រោម ឃុំពាមមន្ទា ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ នៅក្នុងឆ្នាំ១៩៥៨ គាត់បានចូលរៀននៅសាលាបឋមសិក្សាក្រចាប់ក្រោម ស្ថិតនៅក្នុងភូមិកំណើត។

ឆ្នាំ១៩៦៥ គាត់បានចូលរៀននៅវិទ្យាល័យព្រះអង្គឌួង ក្នុងទីរួមខេត្តព្រៃវែង។ ពេលនោះ

គាត់ត្រូវបានឈ្មោះសួន ជាសិស្សថ្នាក់ទី១ អប់រំគាត់ឲ្យចូលរួមក្នុងចលនាតស៊ូខ្មែរក្រហម និងបានណែនាំគាត់ឲ្យស្គាល់ខ្សែរយៈតស៊ូម្នាក់ទៀតឈ្មោះសោ នៅកំពង់សោម។

ក្រោយមកទៀត ឈ្មោះសួន ក៏បាននាំគាត់ទៅជ្រោយថ្ម ក្រុងកំពង់ចាម ដើម្បីជួបឈ្មោះឈឿន និងលាន ជាខ្សែរយៈតស៊ូរបស់ខ្មែរក្រហមដែរ។ នៅក្នុងឆ្នាំ១៩៦៩ ឈឿន និងលាន បានចាត់តាំងគាត់ជាយុវកក (យុវជនកុម្មុយនិស្តកម្ពុជា) នៅផ្ទះឈ្មោះឈឿន ក្នុងភូមិជ្រោយថ្មក្រុងកំពង់ចាមនោះ ហើយបានប្រគល់ភារកិច្ចឲ្យគាត់ធ្វើជានីរសារ(អ្នកនាំសំបុត្រ)ពីឈឿន ទៅឱ្យឈ្មោះស្រេង (អនុលេខាភូមិភាគឧត្តរ) នៅព្រៃទទឹង ក្នុងស្រុកព្រៃឈរ និងទៅឲ្យឈ្មោះសួន នៅវាលវង់ ក្រុងកំពង់ចាម និងភារកិច្ចមួយទៀត គឺការពារឈ្មោះឈឿន និងលាន ជាមេខ្មែរក្រហមនោះផងដែរ។

ក្នុងអំឡុងពេលពួកខ្មែរក្រហមធ្វើសង្គ្រាមផ្តួលរម្លំរបបសាធារណរដ្ឋខ្មែររបស់សេនាប្រមុខលន់ នល់ ពីឆ្នាំ១៩៧០ រហូតដល់បង្កើតរបបកម្ពុជាប្រជាធិបតេយ្យ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហែម សុត ហៅសៀន ជាប្រធានឧស្សាហកម្មភូមិភាគឧត្តរ (ឧត្តរចាស់)។

# ២២៨
# ចាន់ ម៉ុន ហៅ តុល ចូលខ្មែរក្រហម
# តាមរយៈ កែ ពក

ចាន់ ម៉ុន ហៅ តុល កើតនៅក្នុងឆ្នាំ១៩៣៨ ទីកន្លែងកំណើតនៅភូមិដោម ឃុំក្រវ៉ា (បច្ចុប្បន្នឃុំបាក់ស្នា) ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ នៅក្នុងឆ្នាំ១៩៦៤ ពេលមានអាយុ ២៦ឆ្នាំ គាត់បានចូលបម្រើចលនាតស៊ូបដិវត្តន៍ ដោយមានមេខ្មែរក្រហមឈ្មោះ កែ ពក ជាអ្នកដឹកនាំ។ កែ ពក បានចាត់តាំងគាត់ឲ្យធ្វើសកម្មភាពសម្ងាត់នៅក្នុងភូមិរបស់គាត់។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៦៤ កែ ពក បានចាត់តាំងគាត់ឱ្យធ្វើការនៅក្នុងអង្គការសមាគមកសិករភូមិ។

រយៈពេលមួយឆ្នាំក្រោយមក គឺនៅក្នុងឆ្នាំ១៩៦៥ មេខ្មែរក្រហម កែ ពក និង ចន បានបញ្ចូលគាត់ជាបក្ខជន។ នៅដើមឆ្នាំ១៩៦៧ កែ ពក បានហៅគាត់មកជួយធ្វើការ និងអប់រំរៀនសូត្រឱ្យគាត់បានយល់អំពីសភាពការណ៍ និងទស្សនៈបដិវត្តន៍ ព្រមទាំងផែនការរបស់ខ្មែរក្រហម(បក្សកុម្មុយនិស្តកម្ពុជា)ដែលរៀបចំធ្វើចលនាតស៊ូវាយដណ្ដើមយកអាវុធពីទាហាន-ប៉ូលិសរបស់រាជរដ្ឋាភិបាល។

បន្ទាប់មក កែ ពក បានចាត់តាំងគាត់ឲ្យដឹកនាំកម្លាំងចំនួន៤០នាក់ ទៅវាយដណ្ដើមយកអាវុធពីពួកប៉ូលិសនៅប៉ុស្តិ៍តាប្រ៉ុក ស្រុកចម្ការលើ យកអាវុធបានចំនួន៤ដើម គឺ កាំភ្លើងសេកាសេ(CKC )ចំនួន៣ដើម និងកាំភ្លើងកាប៉ីន ចំនួន១ដើម។ ក្រោយពីបានកាំភ្លើង៤ដើមនោះ គាត់នាំកម្លាំងរបស់គាត់ទៅជួប កែ ពក នៅក្នុងព្រៃដែលជាមូលដ្ឋានបង្អែករបស់ចលនាតស៊ូ។

ពេលនោះ ចាន់ ម៉ុន ហៅ តុល ក៏បានស្នាក់នៅក្នុងព្រៃជាមួយ កែ ពក រយៈពេល១អាទិត្យ ទើបកែ ពក ចាត់តាំង ឈ្មោះចន និងគាត់ ឲ្យទៅពិនិត្យមើលសភាពការណ៍ប៉ូលិសនៅប៉ុស្តិ៍បាក់ស្នា ស្រុកបារាយណ៍។ ពេលត្រលប់មករាយការណ៍វិញ កែ ពក បានបញ្ជាឱ្យ

ពួកគាត់ដឹកនាំកម្លាំងទៅវាយប៉ូលិសនៅប៉ុស្តិ៍បាក់ស្នានោះ ដោយបានសម្លាប់ប៉ូលិសចំនួន៨នាក់ទៀត។

ចាប់ពីខែសីហា ឆ្នាំ១៩៦៧ កែ ពក បានឲ្យគាត់ និងឈ្មោះចន ចុះទៅធ្វើការនៅតាមភូមិប្រជាជនមួយចំនួនជាមូលដ្ឋានបង្អែកបដិវត្តន៍ បន្តទៀត។ រហូតដល់ខែមិថុនា ឆ្នាំ១៩៦៨ ចាន់ ម៉ុន ហៅ តុល និង ចន ត្រូវកម្លាំងប៉ូលិសរាជរដ្ឋាភិបាលចាប់ខ្លួនបាន នៅពេលពួកគាត់ចូលទៅលួចអង្ករប្រជាជននៅភូមិដោម ឃុំបាក់ស្នា រួចបញ្ជូនពួកគាត់យកទៅដាក់ពន្ធនាគារ នៅខេត្តកំពង់ធំ។

ក្រោយពីជាប់ឃុំក្នុងពន្ធនាគារនៅខេត្តកំពង់ធំ រយៈពេល២ថ្ងៃ ប៉ូលិសជំនាញក៏បាននាំចាន់ ម៉ុន ហៅ តុល ទៅសួរចម្លើយ។ ពេលនោះ ចាន់ ម៉ុន ហៅ តុល បានឆ្លើយប្រាប់ប៉ូលិសថា មូលហេតុដែលគាត់រត់ចូលព្រៃទៅនៅជាមួយពួកខ្មែរក្រហម ដោយសារមានពួកទាហានចូលមកក្នុងភូមិដេញចាប់ និងបាញ់ប្រជាជន។

ប៉ូលិសជំនាញបានសួរគាត់ថា ក្រុមឯងឬ ដែលនាំគ្នាទៅវាយដណ្តើមយកកាំភ្លើងពីប៉ូលិសនៅប៉ុស្តិ៍តាប្រ៉ុក និងនៅប៉ុស្តិ៍បាក់ស្នា? គាត់ឆ្លើយថា មិនមែនពួកគាត់ទេ ព្រោះគាត់មានគ្នាតែពីរនាក់ មិនអាចវាយប៉ូលិសនៅប៉ុស្តិ៍តាប្រ៉ុក និងនៅប៉ុស្តិ៍បាក់ស្នា បានឡើយ។ ក្រោយមក ចាន់ ម៉ុន ហៅ តុល និងឈ្មោះចន បានទាក់ទងទាហានសក្តិ៣ម្នាក់ ឈ្មោះឈុំ នៅខេត្តកំពង់ធំ សុំធ្វើលិខិតមួយច្បាប់ ដើម្បីសុំចុះចូលជាមួយរាជរដ្ឋាភិបាល ដោយសង្ឃឹមថា សមត្ថកិច្ចអាចសម្រាលទោស និងដោះលែងពួកគាត់វិញ។

ពួកគាត់បានជូនប្រាក់ទាហានសក្តិ៣នោះ ចំនួន១៥០០រៀល ដើម្បីឱ្យជួយសរសេរសំបុត្រសុំចុះចូលម្នាក់មួយច្បាប់។ ប៉ុន្តែពេលពួកគាត់ទទួលបានសំបុត្រចុះចូលរួច ស្រាប់តែនៅខែសីហា ឆ្នាំ១៩៦៨ ពួកប៉ូលិសបានបញ្ជូនពួកគាត់យកទៅដាក់ពន្ធនាគារព្រៃស នៅជាយក្រុងភ្នំពេញ បន្តទៀត។

ពេលទៅដល់ពន្ធនាគារព្រៃស ពួកប៉ូលិស ក៏បានសួរចម្លើយពួកគាត់ម្តងទៀត គឺសួរសំណួរដូចកាលនៅពន្ធនាគារនៅខេត្តកំពង់ធំ ដែរ ហើយពួកគាត់ក៏នៅតែឆ្លើយចម្លើយដដែលៗ

ដូចពីមុន។

នៅខែវិច្ឆិកា ឆ្នាំ១៩៦៩ ចាន់ ម៉ុន ហៅ តុល និងឈ្មោះចន ព្រមទាំងអ្នកទោសនៅខេត្តកំពង់ធំ ចំនួន២០នាក់ និងអ្នកទោសនៅខេត្តកំពង់ចាម ចំនួន១៦នាក់ ត្រូវបានគេដោះលែងពីពន្ធនាគារព្រៃស វិញ។

ក្រោយគេដោះលែងពីពន្ធនាគារ ចាន់ ម៉ុន ហៅ តុល បានមករស់នៅជាមួយគ្រួសារ ជួយធ្វើស្រែចម្ការម្ដាយឪពុកនៅស្រុកកំណើតវិញ រហូតដល់ក្រោយមានព្រឹត្តិការណ៍រដ្ឋប្រហារ ឆ្នាំ១៩៧០ ចាន់ ម៉ុន ហៅ តុល និងឈ្មោះចន បានទាក់ទងជាមួយកែ ពក ធ្វើសង្គ្រាមប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែររបស់លន់ នល់ និងបានឡើងឋានៈជាបន្តបន្ទាប់ រហូតទទួលតំណែងជាលេខាបក្សតំបន់៤២ ក្នុងភូមិភាគឧត្តរ។

# ២២៩
# តូច ភឿន មិនសូវចូលចិត្ត
# ភោគ ឆាយ ជាអ្នកតស៊ូដូចគ្នា

ក្រោយពេលគណបក្សប្រជាជន ចាញ់ឆ្នោតក្នុងឆ្នាំ១៩៥៥ តូច ភឿន ហៅភិន ជាមេដឹកនាំម្នាក់របស់គណបក្សប្រជាជន មានសតិអារម្មណ៍ស្មុគស្មាញជាខ្លាំង រហូតដល់មានសតិអារម្មណ៍ពីរ គឺម្យ៉ាងចង់រស់នៅស្រណុកសុខស្រួលហ៊ឺហាមានឡានជិះ មានផ្ទះថ្មប្រាក់កាសគ្រប់គ្រាន់ និងម្យ៉ាងទៀតចង់រក្សាឈ្មោះជាអ្នកតស៊ូធ្វើបដិវត្តន៍ តែមិនចង់លំបាក។ ឯបងប្អូនក្រុមគ្រួសាររបស់គាត់ក៏ចេះតែណែនាំពន្យល់គាត់ថា កុំចង់ទ្រផែនដីម្នាក់ឯង ទ្រមិនរួចទេ។

តាំងពីមុនបោះឆ្នោតមកម្ល៉េះ គាត់ជាអ្នកតស៊ូជិតស្និទ្ធជាមួយក្រុមប្រជាជនទាំងអស់ រួមមាន កែវ មាស, នង សួន, ជី គឹមអាន, នៃ សារ៉ាន់(ម៉ែន សាន)ហៅយ៉ា និងកង ចាប (ចាន់ សំ) ហៅសែ (មុនឆ្នាំ១៩៧៦ កង ចាប ហៅសែ ជាលេខាបក្សតំបន់៣៥ ភូមិភាគនិរតី។ ឆ្នាំ១៩៧៧ គាត់ឡើងជាលេខាបក្សភូមិភាគឧត្តរថ្មី ឬភូមិភាគ៨០១)។

តូច ភឿន ឧស្សាហ៍ទៅលេងផ្ទះកែវ មាស ដែលជួលគេនៅខាងក្រោយផ្ទះរបស់ចាន់កន នៅផ្លូវព្រះមុនីវង្ស ដើម្បីពិភាក្សាគ្នាពីបញ្ហាថាតើត្រូវធ្វើសកម្មភាពអ្វីទៀត?។

កែវ មាស ថា វៀតណាម អាចជួយយើងទៅថ្ងៃក្រោយ។ តែបច្ចុប្បន្ននេះ គេត្រូវការឲ្យសីហនុ ជួយគេសិន គេជួយយើងមិនបានទេ។ បើក្រឡេកទៅមើលផែនទីអាស៊ីអាគ្នេយ៍ ប្រទេសកម្ពុជាយើង ត្រូវឯកោ ដោយអាមេរិក។ អ៊ីចឹងហើយយើងតស៊ូវណ្ណៈតែម្នាក់ឯង មិនបានទេ ត្រូវសម្របសម្រួលជាមួយសភាពការណ៍ជាក់ស្តែង។

ឆ្នាំ១៩៥៦ គាត់បានរៀបការ។ ពេលមានប្រពន្ធ គាត់ត្រូវមានផ្ទះនៅ ទោះបីផ្ទះជួលគេក៏ដោយ ហើយបើជួលផ្ទះគេនៅ ត្រូវតែមានប្រាក់។ ដូច្នេះគាត់ត្រូវការរកស៊ីដោយខ្លួនឯង មិនចាំតែមិត្តភក្តិៗជួយចិញ្ចឹមនោះទេ។ ដំបូងគាត់សុំចូលធ្វើរាជការវិញដែរ តែសីហនុ មិនឱ្យ គាត់ក៏បែកប្រាជ្ញាទៅធ្វើជាគ្រូបង្រៀននៅវិទ្យាល័យកម្ពុជបុត្រ រួចចេញរកស៊ីម៉ៅការសង់ផ្ទះ

គូរប្លង់បេតុងជាមួយសាន់ អឿន ដោយគ្មានការអនុញ្ញាតពីបក្ស(បក្សប្រជាជនបដិវត្តន៍ខ្មែរ) ឡើយ។

បន្ទាប់មក គាត់ធ្វើជាទីប្រឹក្សាបច្ចេកទេសឲ្យសហគ្រាសឯកជនមួយ។ ចុងក្រោយបំផុត គាត់បានបង់ប៉ាតង់រកស៊ីម៉ៅការសង់ផ្ទះ ចំណេញបានប្រាក់កាសរាប់លានរៀលក្នុងផ្ទះមួយៗ។ នៅដើមឆ្នាំ១៩៥៨ គាត់ត្រូវបញ្ចូលជាបក្ខជនជាថ្មីម្តងទៀតនៅផ្ទះរបស់ចាន់ កន ជាជនចំរើន (សកម្មជនរបស់បក្ស) និងជាពួកក្បាលដំរីចាស់ (គណបក្សប្រជាធិបតេយ្យ) នៅខេត្តកំពង់-ចាម ក្នុងពេលឈ្មោះចាន់ កន ធ្វើពិធីបុណ្យផ្កាមួយនៅក្នុងបរិវេណផ្ទះក្បឿងមួយខ្នងមានដើមស្លាជាច្រើននៅជុំវិញ មុំកំពង់ចម្លងទន្លេបិទ ក្រុងកំពង់ចាម។

ពេលនោះ គាត់បានជួបមេដឹកនាំចលនាតស៊ូសម្ងាត់ម៉ី ផាត់, ចាន់ អឿន, ចាន់ អុល ជាគ្រូបង្រៀន និងមហាជនមួយចំនួនទៀត មកពីនៅព្រៃទទឹង ស្រុកជើងព្រៃ ដែលបានទៅចូលរួមក្នុងពិធីបុណ្យនោះដែរ។ ពិសេស គាត់បានជួបកុយ ធួន ជាលើកដំបូង និងបានពិភាក្សាគ្នាពីបញ្ហាតស៊ូនយោបាយ។

គាត់ពិនិត្យឃើញថា កុយ ធួន និយាយពីបញ្ហានយោបាយបានល្អគ្រាន់បើដែរ។ មុនពេលលាគ្នា កុយ ធួន ផ្តាំគាត់ថា ឧស្សាហ៍មកលេង និងជួយណែនាំបំភ្លឺរឿងនយោបាយឱ្យគេផង។ កុយ ធួន មានវ័យក្មេងជាងគាត់។

លុះដល់ខែកញ្ញា ឆ្នាំ១៩៥៨ គាត់ក៏ឆ្លៀតឱកាសទៅចូលរួមពិធីមង្គលការមិត្តភក្តិម្នាក់នៅក្រុងកំពង់ចាម និងសម្រាកមួយយប់ជាមួយកុយ ធួន នៅផ្ទះក្បឿងមួយទៀត នៅខាងក្រោយផ្ទះដែលគាត់បានទៅចូលរួមក្នុងពិធីបុណ្យផ្កាកាលពីដើមឆ្នាំនោះ។ គាត់បានពិភាក្សាគ្នាជាមួយ កុយ ធួន យ៉ាងល្អិតល្អន់ពីសភាពការណ៍សកលលោក និងសភាពការណ៍នយោបាយរបស់ប្រទេសជាតិ។

ក្នុងអំឡុងខែកញ្ញា ឆ្នាំ១៩៥៨ នោះដែរ នៅក្រុងភ្នំពេញ កែវ មាស បានរើផ្ទះទៅជួលនៅមុំខាងលិចវិទ្យាល័យព្រះយុគន្ធរ វិញ។ ពេលតូច គឿន ទៅជួបម្តងៗ ឃើញកែវ មាស អង្គុយស្តាប់ និងកត់ព័ត៌មានសំខាន់ៗរបស់ការផ្សាយវិទ្យុហាណូយ ជាភាសាវៀតណាម។

តែគាត់មិនសូវឃើញ នង សួន និងនៃ សារ៉ាន់ ហៅយ៉ា មកផ្ទះដួលរបស់កែវ មាស ទេ។ ចំណែក សៀង អាន និងជី គឹមអាន នៅផ្ទះផ្សេង។

ថ្ងៃមួយ នៅក្នុងខែធ្នូ ឆ្នាំ១៩៥៨ កែវ មាស បានហៅគាត់ឱ្យទៅជួប។ ពេលទៅដល់ គាត់ឃើញកែវ មាស, នង សួន, នៃ សារ៉ាន់ ហៅយ៉ា, ជី គឹមអាន, សៀង អាន និងមនុស្ស ដែលគាត់មិនធ្លាប់ស្គាល់២នាក់ទៀត កំពុងជជែក ពិភាក្សាគ្នាដល់វិធានការទប់ស្កាត់និន្នាការ ឆ្វេងនិយមក្នុងបក្ស។ កែវ មាស ប្រាប់គាត់ថា ២នាក់នោះជាមិត្តភក្តិគេ ក្នុងនោះ ម្នាក់មកពី ស្រុកឈូក និងម្នាក់ទៀតមកពីតានី «ស្រុកអង្គរជ័យ» ខេត្តកំពត។

ពេលនោះ ការពិភាក្សាពីបញ្ហាតាក់តែងលក្ខន្តិកៈថ្មីរបស់បក្ស និងយុទ្ធវិធីរបស់បក្ស និងការតស៊ូវណ្ណៈត្រូវដាក់បញ្ចូលទៅក្នុងលក្ខន្តិកៈថ្មីនោះ។ ឯបញ្ហាជ្រើសរើសគណៈកម្មាធិការ មជ្ឈិមបក្សថ្មី ក៏មានបញ្ហាចោទដែរ។ ដូច្នេះការពិភាក្សាគ្នាកាន់តែបែកជាអូរ ហូរជាស្ទឹងយូរ ទៅៗ។

អ្នកខ្លះថា យើងត្រូវតែចូលព្រៃតស៊ូ។ អ្នកខ្លះថា ចូលព្រៃតស៊ូយ៉ាងម៉េច បើយើង គ្មានអាវុធមួយដើមផង ហើយបើយើងបំផុសចលនាហិង្សាបដិវត្តន៍នៅតាមផ្លូវថ្នល់ ក៏ទៅ មិនរួចដែរ បើប្រជាជនយើងសព្វថ្ងៃនៅតែផឹកទឹកត្នោត និងរាំឡាំថូនពាលាអាវាសៃ អាសអាភាស យ៉ាងនេះ។ យើងមានតែធ្វើនយោបាយដោយសន្តិវិធីចូលកៀកសីហនុ ហើយកាច់កគាត់ ទាំងរស់ នៅពេលណាមួយប៉ុណ្ណោះ។

កែវ មាស បានប្រាប់តូច ភឿនថា មិត្តភឿនឯងមានលទ្ធភាពច្រើនណាស់ ដូច្នេះត្រូវ អប់រំ និងអូសទាញមហាជន ពិសេសបក្ខជនយើងតាមគ្រប់រូបភាព កុំឲ្យពួកគេប្រើហិង្សា នយោបាយ ឬអាវុធប្រឆាំងនឹងសម្តេចសីហនុ។ ជាមួយគ្នានេះដែរ មិត្តភឿនឯង មានគ្នាយើង ធ្វើកម្មករ សំណង់ជាមួយច្រើន ត្រូវអប់រំពួកគេឲ្យស្គាល់ច្បាប់ទម្លាប់ប្រទេសផងដែរ។ បន្ទាប់ពី មានការ ប្រជុំនោះមក នៅក្នុងការដ្ឋានសាងសង់ផ្ទះដែលដេញថ្លៃបាន តូច ភឿន ឲ្យសកម្មជន របស់បក្សដែលគ្មានការងារធ្វើ មកធ្វើជាកម្មករសំណង់នៅក្នុងការដ្ឋានរបស់គាត់បានច្រើន បង្គួរ។

## របត់នយោបាយ

ក្រោយពីបានប្រាក់ខែ សកម្មជនទាំងនោះមានផ្ទះនៅ មានកង់ជិះមកធ្វើការ ក៏លែងចង់ត្រលប់ទៅជនបទជាមូលដ្ឋានតស៊ូរបស់ពួកគេវិញ។ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៦០ កុយ ធួន បានមកជួបគាត់ ហូបបាយ និងសម្រាកមួយយប់នៅផ្ទះគាត់ ដើម្បីពិភាក្សាគ្នាយ៉ាងល្អិតល្អន់ពីបញ្ហាសភាពការណ៍នៅកម្ពុជាបច្ចុប្បន្ន និងបញ្ហាត្រូវតស៊ូប្រឆាំងសីហនុ ផង។ ពួកគាត់ឯកភាពគ្នាថា ការតស៊ូប្រឆាំងសីហនុ ត្រូវតែមានខ្នងបង្អែកឲ្យបានរឹងមាំ។ តែកុយ ធួន និយាយថា បើសីហនុ ចាប់បងឯង។ ទូតចិន មិនហ៊ានជួយបងឯងទេ។

រហូតដល់ឆ្នាំ១៩៦៦ ទើបគាត់ឮដំណឹងថា កែវ មាស និងនៃ សារ៉ាន់ ហៅយ៉ា ព្រមទាំងអ្នកតស៊ូជាច្រើនទៀតរត់ចូលព្រៃជាបន្តបន្ទាប់។ ពេលនោះ ជាគោលការណ៍ គាត់ចៀសវាងមិនទៅទាក់ទងអ្វីឲ្យជាប់លាប់ជាមួយ ជួន ប្រាសិទ្ធ និងឱក សុគន្ធ ជាមេដឹកនាំបណ្តាញតស៊ូសម្ងាត់របស់ពួកខ្មែរក្រហមដូចគ្នា នៅស្ថានីយរថភ្លើង នោះទេ ដោយសារដឹងថា កន្លែងនោះចលនាតស៊ូកំពុងកើនឡើងខ្លាំង ហើយអង្គការក៏អញ្ជើញទៅធ្វើការខ្លះៗដែរ។ ម្យ៉ាងជួន ប្រាសិទ្ធ មានប្រពន្ធជាជនជាតិបារាំង ហើយគាត់មិនសូវទុកចិត្តផង។ ចំណែកខាងសមាគមមិត្តភាពកម្ពុជា-ចិន ក៏គាត់មិនសូវរវីរវល់ដែរ ព្រោះដឹងថា ពួកនេះឆ្វេងជ្រុល មុខជាសម្តេចសីហនុ យកលេសបង្ក្រាបជាមិនខាន។

ក្នុងអំឡុងពេលតស៊ូសម្ងាត់ជាមេខ្មែរក្រហមបង្កប់ខ្លួននៅក្នុងក្រុងភ្នំពេញ នៅពាក់-កណ្តាលទសវត្សរ៍ឆ្នាំ១៩៦០ ជាមួយភោគ ឆាយ ហៅមិត្តណាង ហៅមិត្តទូច នោះ តូច ភឿន សង្កេតឃើញថា ភោគ ឆាយ ជាបុគ្គលមានអំនួតខ្លាំងណាស់ មើលឃើញតែថ្នាក់លើ ច្រើនតែអែបអបអ្នកធំ ហើយមើលស្រាលអ្នកតូចតាច។

ប្រពន្ធភោគ ឆាយ ជាកូនកាត់ចិន នៅត្រពាំងជង ខេត្តពោធិ៍សាត់ រកស៊ីខាងប្រមូលទិញស្រូវ និងកិនស្រូវ។ ដើម្បីប្រកបរបរនេះបាន ត្រូវមានប្រាក់កាសច្រើន និងមានអ្នកធំនៅឯក្រុងភ្នំពេញ ជាខ្នងបង្អែក។ ខ្នងបង្អែករបស់ឪពុកក្មេកភោគ ឆាយ គឺ ស៊ីសុវត្ថិ សិរិមតៈ និងនាយទុនកុំប្រាឌ័រម្នាក់ឈ្មោះ ងុយ កាន់ ជាប្រធានក្រុមហ៊ុននាំអង្ករចេញ និងនាំទំនិញប្រណីតៗ ចូលក្នុងប្រទេសវិញ។

តាមរយៈស៊ីសុវត្ថិ សិរិមតៈ នេះហើយ ដែលឪពុកម្តាយ និងក្រុមគ្រួសារប្រពន្ធភោគ ឆាយ អាចសុំចូលគាល់ព្រះមាតារបស់សម្តេចសីហនុ ដើម្បីសុំលើកលែងទោសឲ្យ ភោគ ឆាយ បានរួចចេញពីពន្ធនាគារវិញ។

តូច ភឿន រម្លឹកថា ភោគ ឆាយ រៀនច្បាប់ដើម្បីធ្វើជាមេធាវីការពារផលប្រយោជន៍ឲ្យងុយ កាន់ ប្រធានក្រុមហ៊ុននាំអង្ករចេញ និងនាំទំនិញប្រណីតៗចូល។ ក៏ប៉ុន្តែ ភោគ ឆាយ មានចំណុចល្អមួយ គឺមិនចូលចិត្តស្រីស្រាទេ។ គាត់ទាក់ទងជាមួយភោគ ឆាយ តាំងពីភោគ ឆាយ ឡើងជាអគ្គនាយកនៅក្រុមហ៊ុនសូណាព្រឹមមក។ មុននេះ គាត់ចង់ទាក់ទងភោគ ឆាយ ដែរ តែមិត្តភក្តិទាំងអស់ មិនឱ្យទាក់ទង ដោយសារ ភោគ ឆាយ ធ្វើឫកសម្បើមពេក។ ម្យ៉ាងទៀត ការតស៊ូបដិវត្តន៍ ភោគ ឆាយ ក៏មិននៅខ្សែជាមួយគាត់ដែរ។

នៅឆ្នាំ១៩៦៨ សម្តេចសីហនុ បានតែងតាំងភោគ ឆាយ ឲ្យធ្វើជាអគ្គនាយកក្រុមហ៊ុនសូណាព្រឹម គាត់ចាប់ផ្តើមទៅទាក់ទងភោគ ឆាយ ពិភាក្សាគ្នាយ៉ាងល្អិតល្អន់បំផុតអំពីការធ្វើបដិវត្តន៍លើសកលលោក, អំពីឥទ្ធិពលលទ្ធិម៉ាក្ស ឡេនីន និងគំនិត ម៉ៅ សេទុង ព្រមទាំងអប់រំសតិអារម្មណ៍បដិវត្តន៍ ភោគ ឆាយ ជាញឹកញាប់។ តែមិនមែនជាការងាយស្រួលទេ ពីព្រោះភោគ ឆាយ តាំងខ្លួនឯងជាគ្រូអាចារ្យប្រដៅគេទាំងឡាយទាំងពួង។ នៅវេលានោះហើយ ពួកគាត់ក៏មានទិសដៅបំផ្លាញរបស់ដែលហៅថា ជាតួបនីយកម្មរបស់សម្តេចសីហនុចោលដែរ។

ក្រុមហ៊ុនសូណាព្រឹមជាក្រុមហ៊ុនរដ្ឋ លក់ផ្តាច់មុខដែក, ស៊ីម៉ងត៍, ក្រណាត់, ស័ង្កសី, ក្រដាស, កង់ឡានជាដើម ដែលសុទ្ធតែជាវត្ថុចាំបាច់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន។ ពួកគាត់បានធ្វើវិច្ឆេទកម្មលើគ្រប់ផ្នែក ដូចជាបានប័ណ្ណទិញអីវ៉ាន់ហើយ ទៅបើកអីវ៉ាន់ នៅឯឃ្លាំងមិនបាន។ ពេលខ្លះក្នុងប័ណ្ណដាក់ថា បើកអីវ៉ាន់ប្រភេទក តែខាងឃ្លាំងបើកប្រភេទខ ឲ្យជំនួសវិញ។ តែសំខាន់បំផុត គឺលាក់ទំនិញស្តុកទុកមិនបញ្ចេញឲ្យអស់ ដើម្បីបញ្ចេញតាមទ្វារក្រោយទៅឲ្យឈ្មួញកណ្តាលវិញ។ ដូច្នេះ ទំនិញអ្វីដែលគ្មាននៅក្នុងក្រុមហ៊ុនសូណាព្រឹម ប្រជាជនត្រូវទៅរកទិញចិននៅហាងជិតៗនោះ គឺថ្លៃលើសតម្លៃរដ្ឋកំណត់ពី២

ទៅ៣ដង។ ឧទាហរណ៍ ស៊ីម៉ងត៍ រដ្ឋកំណត់ឲ្យលក់៩១រៀល ក្នុងមួយបាវ។ បើទិញនៅហាង ចិន ថ្លៃដល់ទៅ២០០រៀលក្នុងមួយបាវ។ បញ្ហានេះ ធ្វើឲ្យមហាជនក្តៅក្រហាយយ៉ាងខ្លាំង និងនយោបាយជាតូបនីយកម្ម(ពាណិជ្ជកម្មរដ្ឋ)របស់សម្តេចសីហនុ ហើយទាមទារឲ្យរំលាយ ក្រុមហ៊ុនសូណាព្រីម ចោលវិញ។ នេះជាជោគជ័យមួយធំណាស់ដែលពួកគាត់ជាកម្លាំងបង្កប់ របស់ខ្មែរក្រហម ជំរុញឲ្យសម្តេចស៊ីហនុ ឆាប់ដួលរលំ។ នៅចុងឆ្នាំ១៩៦៨ ពួកនាយទុន កុំប្រាឌ័រ នាំគ្នារុកកួនទម្លាក់ភោគ ឆាយ ចេញពីអគ្គនាយកក្រុមហ៊ុនសូណាព្រីម។

ក្នុងឆ្នាំ១៩៦៩ គាត ឈន់ ឡើងជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម គាត់បានទៅធ្វើជំនួយ ការឲ្យមួយរយៈ ហើយគ្មានគោលបំណងអ្វីក្រៅពីជួយការងារគាត ឈន់ និងចង់បានមុខមាត់ ពិសេសចង់បានគម្រោងសាងសង់រោងព្រះពន្លា(វេទិកា)សម្រាប់សម្តេចសីហនុ ទៅសម្ពោធ រោងចក្រនានា ដូចជារោងចក្រក្រដាសនៅឆ្លូង (ក្រចេះ), រោងចក្រកែវ នៅដង្កោ ជាយក្រុង ភ្នំពេញ, រោងចក្រចម្រាញ់ប្រេងកាត នៅកំពង់សោម និងរោងចក្រផ្សេងៗទៀត នៅកោះកុង និងបាត់ដំបង ជាដើម។ ព្រះពន្លា(វេទិកា)សម្រាប់សម្តេចសីហនុ ទៅសម្ពោធរោងចក្រនីមួយៗ មានតម្លៃពី៨សែន ទៅ១លានរៀល។

ពេលនោះដែរ គាត់ទាក់ទងជាមួយឈាន រ៉ម និងជួន ជុំ (ជាបងថ្លៃ និងប្អូនបង្កើត របស់ជួន ជឿន) ជាទៀងទាត់បង្គួរដែរ ដើម្បីរកកាសែតបារាំង និងប្រាក់កាសខ្លះបញ្ជូនទៅ មូលដ្ឋានតស៊ូនៅក្នុងព្រៃតាមរយៈនីរសាររបស់វន វ៉េត ជាអ្នកទទួលខុសត្រូវចលនាតស៊ូសម្ងាត់ របស់ខ្មែរក្រហមនៅក្នុងក្រុងភ្នំពេញ។

# ២៣០
# ប្រវត្តិតស៊ូរបស់ជូ ជេត ហៅស៊ី
# បក្ខជននៃបក្សកុម្មុយនិស្តឥណ្ឌូចិន

ជូ ជេត ហៅស៊ី មានឪពុកឈ្មោះឃុ ជូ និងម្ដាយឈ្មោះអ៊ិន ប៊ូ ។ មានបងប្អូនតែពីរនាក់។ បងប្រុសគាត់ឈ្មោះ ជូ ជា ស្លាប់តាំងពីអាយុ២០ឆ្នាំ។ ប្រពន្ធជូ ជេត ហៅស៊ី ឈ្មោះ អ៊ឹម ណោន ហៅលី។

កាលពីអាយុ៦ឆ្នាំ ជូ ជេត បានចូលរៀននៅសាលាវត្តបន្ទាយថ្មី ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ លុះដល់ឆ្នាំ១៩៣៨ គាត់អាយុ១៥ឆ្នាំ បានបួសនេន រៀនភាសាបាលីជាមួយអាចារ្យកាន់ ឯល នៅវត្តរកាកោង។

ឆ្នាំ១៩៤០ គាត់ទៅរៀនបន្តនៅថ្នាក់ទី៣សាលាបាលីជាន់ខ្ពស់នៅវត្តកែវព្រះភ្លើង ទីក្រុងភ្នំពេញ។ ក្នុងឆ្នាំ១៩៤១ ដោយសារនៅទីក្រុងភ្នំពេញ ខ្លាចការទម្លាក់គ្រាប់បែករបស់កងទ័ពអាកាសរបស់ជប៉ុន គាត់ក៏ទៅរស់នៅស្រុកបារាយណ៍ ខេត្តកំពង់ធំ ហើយបានប្រលងជាប់សាលាបាលីរងនៅទីនោះ។

ក្រោយមក គាត់ក៏បានត្រលប់មកទីក្រុងភ្នំពេញវិញ ដើម្បីប្រលងចូលរៀនសាលាបាលីជាន់ខ្ពស់បន្តទៀត។ ប៉ុន្តែប្រលងមិនជាប់ គាត់ក៏ត្រលប់ទៅបង្រៀនភាសាបាលីនៅឯខេត្តកំពង់ធំ វិញ។

ក្នុងឆ្នាំ១៩៤៩ គាត់បានទៅនៅខេត្តតាកែវ ដើម្បីបន្តការសិក្សានៅសាលាបាលីជាន់ខ្ពស់ខ្លួនឯងផង និងបង្រៀនព្រះសង្ឃនៅសាលាបាលីរងផង។ ដើមឆ្នាំ១៩៥០ គាត់ត្រលប់មកចាកសិក្ខាបទនៅស្រុកកំណើតឯខេត្តកំពង់ចាម។ នៅក្នុងខែមេសា ឆ្នាំ ១៩៥០ គាត់បានចូលរួមក្នុងជួរកងទ័ពឥស្សរៈខ្មែរ-វៀតមិញ ដែលដឹកនាំដោយចៅ យិន។ បន្ទាប់មក គាត់បានធ្វើដំណើរទៅប្រទេសវៀតណាម ដើម្បីរៀនសូត្រនយោបាយ។

មួយឆ្នាំក្រោយមក គឺនៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៥១ គាត់បានចូលជាបក្ខជននៃ

បក្សកុម្មុយនិស្តឥណ្ឌូចិន តាមរយៈកម្មាភិបាលវៀតណាម ២នាក់ គឺឈ្មោះទី ហុង និងកឹង ហើយបានវិលត្រលប់មកប្រទេសកម្ពុជាវិញ ក្នុងឆ្នាំ១៩៥២ ។ លុះដល់នៅដើមឆ្នាំ១៩៥៤ គាត់បានរៀបការប្រពន្ធឈ្មោះណេន។

នៅក្នុងខែកក្កដា ឆ្នាំ១៩៥៤ ក្រោយពីសន្និសញ្ញាក្រុងហ្សឺណែវ គាត់បានធ្វើជាសមាជិកគណៈកម្មាធិការត្រួតពិនិត្យចម្រុះវៀតណាម-កម្ពុជាប្រចាំខេត្តស្វាយរៀង ជាមួយនង សួន, កែវ មាស, ជី គឹមអាន, សៀង អាន និងសក្ដិ៥វៀតណាមម្នាក់ឈ្មោះថាញ់ សឹង ។

ក្នុងខែមេសា ឆ្នាំ១៩៥៥ គាត់ត្រលប់ពីខេត្តស្វាយរៀង ទៅក្រុងភ្នំពេញ ធ្វើការនៅកាសែតប្រជាជនជាមួយប៉ែន យុទ្ធ។ ក្រោយពេលចេញផ្សាយកាសែតប្រជាជន បានតែ១ខែប៉ុណ្ណោះ ស្រាប់តែនៅក្នុងខែឧសភា រាជការសម្ដេចសីហនុ ក៏ចាប់ជី គឹមអាន ដាក់គុក ធ្វើឲ្យបុគ្គលិកផ្សេងៗទៀតភ័យឆ្អែឆ្អា។ ចំណែករូបគាត់អស់សង្ឃឹម ក៏ឈប់ធ្វើអ្វីទាំងអស់ គឺគិតតែពីដើរលេង។

បន្ទាប់ពីថ្ងៃបោះឆ្នោត នៅខែសីហា ឆ្នាំ១៩៥៥ មក ប៉ែន យុទ្ធ បានបង្កើតកាសែតមួយឈ្មោះកាសែតប្រជាជាតិ និងបានបង្កើតកាសែត២ទៀត គឺកាសែតឯកភាព និងកាសែតមិត្តភាព។ លុះដល់ឆ្នាំ១៩៥៨ គាត់បានចូលរួមជាមួយនៃ សារ៉ាន់ និងកុយ ធួន ធ្វើការតស៊ូបន្តទៀត។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូ ជេត ហៅស៊ី ជាលេខាបក្សភូមិភាគបស្ចិម ចំណែកប្រពន្ធគាត់ឈ្មោះ អ៊ឹម ណេន ហៅ លី ជាលេខាបក្សស្រុកឧដុង្គ តំបន់៣២។

# ២៣១
# សាស្ត្រាចារ្យពីរនាក់ប្តីប្រពន្ធ ទីវ អុល និងឡេង ស៊ឹមហាក់ ស្មោះស្ម័គ្រធ្វើបដិវត្តន៍

ទីវ អុល កើតនៅឆ្នាំ១៩៣៤ ជាអ្នកសង្វាតក្នុងការសិក្សារៀនសូត្រ។ អាជីពដំបូងបង្អស់របស់គាត់គឺ គ្រូបង្រៀនសាលាបឋមសិក្សា ។ នៅឆ្នាំ១៩៥៨ គាត់បានប្រលងជាប់ជាសិស្សសាស្ត្រាចារ្យនៅវិទ្យាស្ថានគរុកោសល្យ ក្រុងភ្នំពេញ ។ ក្នុងអំឡុងពេលសិក្សានៅវិទ្យាស្ថានគរុកោសល្យនោះ គាត់ក៏បានជឿជាក់លើលទ្ធិកុម្មុយនិស្តនិយម ហើយបានចូលរួមក្នុងចលនាតស៊ូជាមួយសុន សេន ដែលកំពុងបម្រើការងារនៅវិទ្យាស្ថាននោះ។

ក្រោយបញ្ចប់ការសិក្សា គាត់បានឡើងឋានៈពីគ្រូបឋមសិក្សាទៅជាសាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរ ទៅបង្រៀននៅវិទ្យាល័យអង្គឌួង ខេត្តព្រៃវែង ។ ទោះបីមានមុខងារជាសាស្ត្រាចារ្យភាសាខ្មែរហើយក៏ដោយ ក៏គាត់នៅតែស្រលាញ់ការសិក្សា ហើយគាត់បានសិក្សាបន្តនៅមហាវិទ្យាល័យអក្សរសាស្ត្រ-មនុស្សសាស្ត្រ នៅក្រុងភ្នំពេញ បន្តទៀត។

ក្នុងអំឡុងពេលទីវ អុល កំពុងសិក្សានៅវិទ្យាស្ថានគរុកោសល្យនៅទីក្រុងភ្នំពេញ ក្រមុំឈ្មោះឡេង ស៊ឹមហាក់ ជាមួយមិត្តភក្តិស្រីម្នាក់ឈ្មោះសាន់ សំអាត ក៏បានចូលរៀនវិទ្យាស្ថានគរុកោសល្យនោះដែរ។

តាមរយៈការអានកាសែតមួយចំនួន ពិសេសកាសែតឯកភាព និងកាសែតប្រជាជនរបស់ចលនាតស៊ូ ពួកគាត់ទាំង២នាក់ ក៏បានយល់ពីមាគ៌ាបដិវត្តន៍ខ្លះៗ ហើយក៏មានការទាក់ទងស្គាល់គ្នាជាមួយទីវ អុល ពេលរៀននៅវិទ្យាស្ថាននោះ តែពុំមែនទាក់ទងស្គាល់គ្នាក្នុងរឿងស្នេហាទេ។

ក្រោយបញ្ចប់ការសិក្សានៅវិទ្យាស្ថានគរុកោសល្យ សាស្ត្រាចារ្យក្រមុំឡេង ស៊ឹមហាក់ និងសាស្ត្រាចារ្យក្រមុំសាន់ សំអាត បានចេញទៅបង្រៀននៅអនុវិទ្យាល័យសួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម( សព្វថ្ងៃដូរមកជាខេត្តត្បូងឃ្មុំ)។ ចាប់ពីពេលនោះមក ពួកគាត់ទាំងពីរនាក់

ក៏បានចូលរួមនៅក្នុងចលនាបដិវត្តន៍ជាបណ្តើរៗ ដោយបានអប់រំសិស្សស្រីម្នាក់គឺឈ្មោះតាំង ហ្គេចគារ និងសិស្សប្រុសម្នាក់ឈ្មោះអេង ម៉េងហ៊ាង ឱ្យចូលរួមក្នុងចលនាបដិវត្តន៍។

ក្នុងឆ្នាំ១៩៦០ នាងសម្រេចចិត្តចូលរួមជាមួយចលនាតស៊ូបដិវត្តន៍ពេញទំហឹង និងបានចូលជាបក្ខជន ដោយមាន អៀង សារី, កុយ ធួន និងឈ្មោះសៀន គ្រូបង្រៀននៅព្រៃទទឹង ជាអ្នកទទួលស្គាល់។

ក្នុងឆ្នាំ១៩៦១ នាងបានរៀបការជាមួយសាស្ត្រាចារ្យទីវ អុល នៅក្នុងទីក្រុងភ្នំពេញ។ ក្រោយពេលរៀបការ ទីវ អុល ជាប្តីបានណែនាំឱ្យស្គាល់ខ្សែរយៈជាក្រុមសាស្ត្រាចារ្យតស៊ូបដិវត្តន៍មួយចំនួន ដូចជា សាស្ត្រាចារ្យខៃក ប៉ែន ហៅសមមិត្តស៊ូ (ក្រោយមកជាលេខាបក្សតំបន់៤ ភូមិភាគពាយ័ព្យ), សាស្ត្រាចារ្យកែ គឹមហួត (ក្រោយមកជាលេខាបក្សតំបន់៧ ភូមិភាគពាយ័ព្យ), សាស្ត្រាចារ្យសាំង រិន, សាស្ត្រាចារ្យគង់ សុគន្ធ, សាស្ត្រាចារ្យពឹង សយ, សាស្ត្រាចារ្យសេង ប៊ុនថន, សាស្ត្រាចារ្យម៉ី លន់, សាស្ត្រាចារ្យរៀម យស្សា, សាស្ត្រាចារ្យតាន់ អឹម, សាស្ត្រាចារ្យកាន់, សាស្ត្រាចារ្យសឹង ភាត់ ជាដើម។

ឆ្នាំ១៩៦២ ដល់១៩៦៣ ឡេង ស៊ីមហាក់ បានផ្លាស់មកបង្រៀននៅវិទ្យាល័យខ្មែរ-អង់គ្លេស បឹងត្របែក ក្រុងភ្នំពេញ។ ឆ្នាំ១៩៦៣នោះដែរ នាងបានឃោសនាអប់រំកសាងកម្លាំងតស៊ូបដិវត្តន៍បានមួយចំនួន ដូចជា ព្រំ សំអារ ជាសាស្ត្រាចារ្យខ្មែរ-អង់គ្លេស, ហុង, ប្រពន្ធម៉ៅ ជឿន ជាគ្រូពេទ្យ និងសិស្សឈ្មោះហាក់ ចាន់តារា។

ទីវ អុល ជាសមាជិកក្រុមប្រឹក្សានៃសមាគមទូទៅនិស្សិតខ្មែរផងដែរ បានចូលរួមក្នុងពិធីបុណ្យចូលឆ្នាំនៅសាកលវិទ្យាល័យសង្គមរាស្ត្រនិយមរៀបចំឡើងដោយ ភោគ ឆាយ ដែលនៅក្នុងពិធីបុណ្យនោះ ពួកនិស្សិតបានច្រៀងចម្រៀងបដិវត្តន៍ចិន គឺជាចម្រៀង ដែលធ្វើឲ្យសម្តេច សីហនុ ពិរោធជាខ្លាំង ។

នៅយប់មួយក្នុងខែមិថុនា ឆ្នាំ១៩៦៧ ទីវ អុល បានចូលរួមប្រជុំក្នុងកម្មវិធីមួយរៀបចំដោយសាស្ត្រាចារ្យកុយ ធួន ហៅធុច ក្នុងផ្ទះបណ្តែតទឹកមួយនៅជ្រោយអំពិល។ អ្នកចូលរួមប្រជុំមាន៨នាក់ គឺ ហ៊ូ យន់ ប្រធានអង្គប្រជុំ, ហ៊ូ នឹម, កុយ ធួន, ប៉ុក ដឺសកុមារ, ទីវ អុល,

វ៉ាន់ ទិព្វសុវណ្ណ, ភោគ ឆាយ និងក្រឡាបញ្ជីម្នាក់ទៀត ដែលមិនស្គាល់ឈ្មោះ ដើម្បីពិភាក្សាគ្នាពីការធ្វើសកម្មភាពបដិវត្តន៍។

នៅចុងខែវិច្ឆិកា ឆ្នាំ១៩៦៧ ទីវ អុល ត្រូវបានបណ្ដាញតស៊ូខ្មែរក្រហមឈ្មោះហ៊ុល សេងថៃ និងកង សារ៉ន ព្រមទាំងនីរសារខ្មែរក្រហមម្នាក់ទៀត មកនាំគាត់ជិះរថយន្តទៅទីរួមខេត្តកំពង់ចាម។ ពេលទៅដល់ទីរួមខេត្តកំពង់ចាម កុយ ធួន បានមកទទួលគាត់ និងកង សារ៉ន ទៅចុះកាណូត ដើម្បីបន្តដំណើរតាមដងទន្លេមេគង្គទាំងកណ្ដាលអធ្រាត្រ ឆ្ពោះទៅកាន់ខេត្តក្រចេះ។

ពេលធ្វើដំណើរទៅដល់ភូមិកំពង់គរ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ពួកគាត់បានសំណាក់នៅផ្ទះឈ្មោះសៀន ដែលជាកម្មាភិបាលតស៊ូបដិវត្តន៍មួយរូប។ បន្ទាប់មក កុយ ធួន បានចាត់តាំងឲ្យមិត្តយ៉ែម និងមិត្តចាំ ជាកម្មាភិបាលប្រចាំតំបន់នោះ នាំផ្លូវទីវ អុល បន្តដំណើរទៅមុខទៀត។ ចំណែកកង សារិន ត្រូវត្រលប់មកភ្នំពេញ វិញ។ ២-៣ថ្ងៃក្រោយមក មាននីរសារម្នាក់មកទទួល ទីវ អុល ទៅសំណាក់នៅផ្ទះសម្ងាត់មួយទៀតនៅជាយភូមិអន្លង់វៀន ខេត្តក្រចេះ ជាមួយកម្មាភិបាលតស៊ូបដិវត្តន៍៣នាក់ផ្សេងទៀត រួមមាន មិត្តមឿន, មិត្តដួង និងមិត្តហេង ដែលកំពុងរង់ចាំនីរសារមកនាំផ្លូវធ្វើដំណើរទៅមុខទៀត។ ក្នុងពេលស្នាក់នៅក្នុងភូមិអន្លង់វៀននោះ ទីវ អុល មានជំងឺគ្រុនចាញ់។

ក្រោយពេលស្នាក់នៅអន្លង់វៀនមួយរយៈមក ក៏មាននីរសារអង្គការ២នាក់ទៀត គឺមិត្តកង និងមិត្តយ៉ែម បានមកនាំផ្លូវ ទីវ អុល, មិត្តមឿន, មិត្តដួង និងមិត្តហេង ធ្វើដំណើរបន្តទៅមុខទៀតជាមួយនឹងជនជាតិព្នងជាឪពុកធម៌របស់មិត្តកង ទៅដល់ខេត្តមណ្ឌលគិរី ហើយស្នាក់នៅក្នុងចម្ការឪពុកធម៌របស់មិត្តកងនោះ ដើម្បីរង់ចាំនីរសាររបស់អង្គការមកនាំផ្លូវតទៅមុខទៀត។

បន្ទាប់ពីសម្រាកនៅចម្ការឪពុកធម៌មិត្តកង មួយរយៈមក មិត្តកង ក៏នាំមិត្តឡាំង (កម្មាភិបាលជាន់ខ្ពស់ភូមិភាគឦសាន) ព្រមទាំងយុទ្ធជនខ្មែរក្រហមមួយចំនួនទៀត មកជួបពួកគាត់ ដើម្បីនាំទៅខេត្តរតនគិរី។ នៅក្នុងរយៈពេលនោះ ទីវ អុល ខំតស៊ូធ្វើដំណើរទាំងមានជំងឺ

## របត់នយោបាយ

គ្រូនចាញ់អស់ជាច្រើនថ្ងៃជាមួយមិត្តឡាំង និងមិត្តកង ទៅដល់មន្ទីរ១០២ របស់ នៃ សារ៉ាន់ ហៅយ៉ា នៅពេលយប់។ មន្ទីរនេះនៅមិនឆ្ងាយប៉ុន្មានពីមន្ទីរ១០៤ របស់សាឡុត ស លេខាគណៈកម្មាធិការមជ្ឈិមបក្ស។

លុះភ្លឺឡើង ទើបនៃ សារ៉ាន់ ហៅយ៉ា បានមកជួបស្វាគមន៍ទីវ អុល ហើយរម្លឹកពីអនុស្សាវរីយ៍កាលធ្លាប់បង្រៀននៅវិទ្យាល័យចំរើនវិជ្ជា ជាមួយគ្នា។ នៃ សារ៉ាន់ ហៅយ៉ា ឲ្យទីវ អុល សម្រាកព្យាបាលជំងឺនៅមន្ទីររបស់ខ្លួនមួយរយៈសិន ហើយក៏បានធ្វើដំណើរឡើងទៅរាយការណ៍ឲ្យសាឡុត ស ពីការមកដល់របស់ទីវ អុល ។ បន្ទាប់ពីការព្យាបាលជំងឺគ្រុនចាញ់នៅមន្ទីរនៃ សារ៉ាន់ បានជាសះស្បើយមក នៃ សារ៉ាន់ ក៏បាននាំទីវ អុល ទៅជួបសាឡុត ស នៅមន្ទីរមជ្ឈិមបក្ស ដែលហៅថាមន្ទីរអង្គការនោះ ហើយសាឡុត ស ក៏ទុក ទីវ អុល ឲ្យធ្វើការនៅមន្ទីរមជ្ឈិមបក្សនោះតែម្តងទៅ។

ទម្រាំធ្វើដំណើរចេញពីទីក្រុងភ្នំពេញ ទៅដល់មន្ទីរអង្គការមជ្ឈិមនៅភូមិភាគឦសាននោះ ទីវ អុល បានចំណាយពេលវេលាអស់រយៈពេលដល់ទៅ៧ខែ ទើបទៅដល់។ ពេលបានធ្វើការនៅមន្ទីរមជ្ឈិមនោះភ្លាម ទីវ អុល ដែលជាសាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរ និងជាអ្នកនិពន្ធសៀវភៅមួយចំនួនដែរនោះ បានលើកគម្រោងសុំអង្គការកែប្រែអក្សរសាស្ត្រមួយចំនួន តែអង្គការបដិសេធ ដោយចាត់ទុកថា ដំណាក់កាលនេះត្រូវការប្រមូលកម្លាំងវាយខ្មាំងជាអាទិភាព ហើយអង្គការបានចាត់តាំងឲ្យ ទីវ អុល ទទួលភារកិច្ចចម្លងឯកសារ, សារាចរណែនាំ និងសរសេរបដាផ្សេងៗជាដើមវិញ។

បន្ទាប់មកទៀត អង្គការបានចាត់តាំង ទីវ អុល ឱ្យទៅនៅក្នុងក្រុមគ្រូបង្រៀនដែលមានឈ្មោះយ៉ាង ជួន ហៅមិត្តទឹម ជាមេក្រុម ចុះទៅបង្រៀនអក្សរដល់កម្មាភិបាលនៅតាមមូលដ្ឋានតស៊ូ ផ្សេងៗទៀត។ ទន្ទឹមនោះដែរ អង្គការបានចាត់តាំង ទីវ អុល ឲ្យជួយបើកវគ្គសិក្សាអប់រំនយោបាយសម្រាប់យោធា និងកម្មាភិបាលជាជនជាតិភាគតិចនៅតាមស្រុកនានាក្នុងភូមិភាគឦសាន ផងដែរ។

ចុងឆ្នាំ១៩៦៧ ឡេង ស៊ីមហាក់ ប្រពន្ធ ទីវ អុល ត្រូវរៀនបំប៉នគរុកោសល្យមួយឆ្នាំ

ទៀត ខណៈទីវ អុល ជាប្តីបានចេញទៅព្រៃតស៊ូ។ នៅក្នុងឆ្នាំ១៩៦៨ គាត់ទៅបង្រៀននៅខេត្តកំពង់ចាម បាន៤ខែ ក៏មានបំណងចេញទៅតាមប្តីនៅក្នុងព្រៃតស៊ូដែរ ប៉ុន្តែ មិនបានសម្រេច។ រហូតនៅដើមឆ្នាំ១៩៦៩ ទើបគាត់ចេញដំណើរទៅសំងំលាក់ខ្លួនជាសម្ងាត់នៅក្នុងខេត្តក្រចេះ អស់រយៈពេលមួយខែ ទើបបន្តដំណើរកាត់ព្រៃទៅខេត្តរតនគិរី ភូមិភាគឦសាន ក៏បានជួបប្តី ដែលកំពុងនៅមន្ទីរអង្គការក្នុងព្រៃតស៊ូនោះ។

២ខែក្រោយមក អង្គការក៏ចាត់តាំងឲ្យគាត់ធ្វើការនៅមន្ទីរបង្កបង្កើនផល (មន្ទីរ.ក១៧) ក្នុងនាមជាសមាជិកធម្មតា។ នៅចុងឆ្នាំ១៩៦៩ អង្គការបានចាត់តាំងឲ្យគាត់ធ្វើជាប្រធានមន្ទីរសេដ្ឋកិច្ចមួយ ដែលមានឈ្មោះឆាំ ជាលេខាសាខាបក្សរបស់មន្ទីរនោះ។

ឡេង ស៊ឹមហាក់ ហៅសី ប្រពន្ធទីវ អុល មានបងប្រុសម្នាក់ និងប្អូនប្រុស៦នាក់ទៀត។

ឆ្នាំ១៩៦៨ បងប្រុសឈ្មោះឡេង ប៊ុនសា ធ្វើកងរាជតម្រួតនៅខេត្តកំពង់ចាម។ ប្អូនប្រុសទី១ ឈ្មោះឡេង ប៊ុនសុង ជាខ្សែរយៈតស៊ូបដិវត្តន៍របស់កុយ ធួន លេខាបក្សភូមិភាគឧត្តរ ត្រូវអាជ្ញាធរសម្តេចសីហនុ ចាប់យកទៅសម្លាប់ចោល នៅក្នុងឆ្នាំ១៩៦៨នោះដែរ ។

ក្រោយជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឡេង ស៊ឹមហាក់ ហៅសី ត្រូវបានចាត់តាំងជាប្រធានមន្ទីរពេទ្យ១៧មេសា (អតីតមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត)។

---

# ២៣២
# គង់ សុផល ហៅកឺ ក្មួយអាចារ្យហែម ចៀវ ទៅតស៊ូនៅភ្នំវាយចាប

គង់ សុផល ហៅកឺ កើតនៅក្នុងឆ្នាំ១៩២៧ នៅឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង។ នៅពេលគាត់មានអាយុ៦ឆ្នាំ ឪពុកគាត់ក៏នាំប្រពន្ធកូនត្រលប់ទៅរស់នៅស្រុកកំណើតរបស់គាត់នៅភូមិបាត់ដឹង ក្នុងស្រុកឧដុង្គ វិញ។

ឆ្នាំ១៩៣៥ គាត់បានចូលរៀននៅវត្តដំបូកល័ក។ ដល់ឆ្នាំ១៩៣៨ ព្រះគ្រូអាចារ្យហែម ចៀវ ត្រូវជាឪពុកមា បាននាំគាត់ និងបងប្អូនជីដូនមួយគាត់ម្នាក់ទៀតទៅនៅទីក្រុងភ្នំពេញ ដើម្បីរៀនភាសាបារាំង និងភាសាបាលី នៅវត្តឧណ្ណាលោម ដោយស្នាក់នៅកុដិសម្តេចព្រះសង្ឃរាជជួន ណាត ។

លុះមកដល់ឆ្នាំ១៩៤២ ពួកអាណានិគមនិយមបារាំង ក៏ចាប់ព្រះគ្រូអាចារ្យហែម ចៀវ យកទៅដាក់គុកកោះត្រឡាចបាត់ទៅ។ គាត់នៅតែបន្តការសិក្សាទៅមុខទៀត រហូតដល់ឆ្នាំ១៩៤៥ ក៏បានប្រលងចូលរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ។ ឆ្នាំ១៩៥៥ ចេញទៅធ្វើគ្រូបង្រៀននៅសាលាជីកូ ខេត្តស្វាយរៀង។

ឆ្នាំ១៩៥២ គាត់ផ្លាស់ទៅបង្រៀននៅសាលាកំពង់កន្ទួត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល វិញ និងបានរៀបការប្រពន្ធនៅទីនោះតែម្តងទៅ។ នៅឆ្នាំ១៩៥២នោះដែរ គាត់បានស្គាល់គ្រូបង្រៀនម្នាក់ឈ្មោះថាច់ ខែត ហើយថាច់ ខែត នេះ បានអប់រំណែនាំគាត់ឲ្យស្រលាញ់ និងគាំទ្រសឹង ង៉ុកថាញ់ ជាមេដឹកនាំចលនាតស៊ូទាមទារឯករាជ្យ ពីពួកអាណានិគមបារាំង។

រហូតដល់ឆ្នាំ១៩៥៧ ថាច់ ខែត ក៏បាននាំគាត់ទៅជួបសុន សេន ដើម្បីធ្វើជាជនបង្គោលដល់ចលនាបដិវត្តន៍។ ពេលនោះ កម្លាំងបង្កប់របស់ចលនាតស៊ូបដិវត្តន៍មាននៅគ្រប់ទីកន្លែងដូចជានៅក្នុងសមាគមទឹកល្អក់ មានវន វ៉េត និងអ៊ុច វ៉ែន មកពីប្រទេសបារាំង។ ចំណែកខាងយុវជន មានស៊ាត ឆែ ហៅទុំ និងកែ គឹមហួត ហៅ សុត ជាដើម។

នៅក្នុងឆ្នាំ១៩៥៨ គាត់ត្រូវបានអង្គការបញ្ចូលជាបក្ខជននៃបក្សពលករកម្ពុជា នៅផ្ទះសុន សេន ដោយមានសុន សេន និងអៀង សារី ជាអ្នកឧទ្ទេសនាម ហើយសាឡុត ស ជាអ្នកទទួលស្គាល់។

ក្រោយពីបានក្លាយខ្លួនទៅជាបក្ខជនមក អង្គការបានចាត់តាំងគាត់ឲ្យទៅនៅក្នុងសាខាបក្សនៅវិទ្យាល័យព្រះស៊ីសុវត្ថិ និងវិទ្យាល័យព្រះយុគន្ធរ ព្រមទាំងចាត់តាំងគាត់ឲ្យធ្វើជានីរសាររបស់អៀង សារី សម្រាប់អៀង សារី ប្រើឱ្យទៅទាក់ទងការងារសម្ងាត់ផ្សេងៗចុះឡើងជាមួយ ពៅ យូឡេង នៅសាលាវិចិត្រសិល្បៈ ដែលហង្ស ធុនហាក់ ជាចាងហ្វាង។

នៅឆ្នាំដដែលនោះដែរ គាត់បានទទួលឋានៈជាសមាជិកគណៈកម្មាធិការបក្សទីក្រុងភ្នំពេញ និងជាប្រធានយុវជន និងយុវនារីក្រុងភ្នំពេញ ជាមួយអ្នកតស៊ូបដិវត្តន៍៤នាក់ទៀត គឺឆាយ គឹមហ៊ា ហៅមិត្តហុក នៅវិទ្យាស្ថានជាតិគរុកោសល្យ, មិត្តគឺនៅវិទ្យាល័យកម្ពុជបុត្រ, ស៊ាត ឆែ ហៅមិត្តទុំ និងពេជ ធន ហៅមិត្តសោម នៅវិទ្យាល័យចំរើនវិជ្ជា។

ដើមឆ្នាំ១៩៦២ គាត់បានប្តូរផ្ទះពីទឹកល្អក់ ទៅនៅម្តុំផ្សារអូឡាំពិក ហើយបានចូលរួមធ្វើសកម្មភាពតស៊ូសម្ងាត់ក្រោមការដឹកនាំរបស់ឈ្មោះទុំ សុនហេង ។ ពេលនោះ គាត់បានទាក់ទងគ្រប់បណ្តាញជាកម្លាំងតស៊ូទាំងអស់។ នៅខាងកម្លាំងកាសែតឯកភាព មានឈ្មោះសឹម ផឹងហាយ និងនៅខាងកាសែតមេគង្គ មានឈ្មោះហ៊ឹម រ៉េត ឯផ្នែកកម្មករមានឈ្មោះវន។

អង្គការបានឲ្យគាត់ទៅទាក់ទងសាស្ត្រាចារ្យទីវ អុល និងហុក នៅសាលាគរុកោសល្យ ដើម្បីបង្កើនចលនាតស៊ូបន្ថែមទៀត។ តែពេលនោះ មានគិញ(ភ្នាក់ងារសម្ងាត់)ឈ្មោះហោ និងម្នាក់ទៀតមុខខ្មួត តាមសម្លុតគម្រាមកំហែងគាត់ជាប់។

មកដល់ចុងឆ្នាំ១៩៦២ ក្រុមមិត្តវ៉ាញ នៅតាកែវ និងមិត្តហុក នៅភ្នំពេញ ត្រូវកម្លាំងសមត្ថកិច្ចរបស់សម្តេចសីហនុ ចាប់ខ្លួនបាន។ ឯមិត្តអន(ចេង អន)ត្រូវរត់ចោលផ្ទះ។

គង់ សុផល ហៅកឺ បានរម្លឹកថា ក្នុងឆ្នាំ១៩៦៣ នួន ជា, វន វ៉េត និងគាត់បានជួបពិភាក្សាគ្នាពីបញ្ហាបញ្ចេញពួកបញ្ញាជន និងសិស្សដែលបែកមុខ (បែកការណ៍សមត្ថកិច្ចដឹងថា ជាអ្នកតស៊ូ)ឱ្យទៅជនបទ។ ក្នុងខែកុម្ភៈ ឆ្នាំ១៩៦៤ អង្គការបានចាត់តាំងគាត់ឲ្យទៅ

តស៊ូនៅក្នុងព្រៃនៃភូមិភាគពាយ័ព្យ។ នៅពេលគាត់ទៅដល់ទីរួមខេត្តបាត់ដំបង មាននីរសារឈ្មោះ ទាត់ បានមកនាំផ្លូវគាត់ទៅមន្ទីរភូមិភាគពាយ័ព្យដែលនៅក្នុងព្រៃជ្រៅ។

ពេលទៅដល់មន្ទីរភូមិភាគនោះ គាត់បានធ្វើការជាមួយមិត្តស៊ុយ ជាប្រធានមន្ទីរភូមិភាគ និងកម្មាភិបាលម្នាក់ទៀត ឈ្មោះសុខ។ នៅក្នុងខែកុម្ភៈនោះដែរ ឈ្មោះថាច់ គឹមសឺង, ខែក ប៉ែន និងវ៉ាញ បានចេញពីទីក្រុងភ្នំពេញ មកដល់មន្ទីរនោះដែរ ហើយបានជួបគាត់នៅផ្ទះសំណាក់របស់នីរសារភូមិភាគ។

នៅចុងឆ្នាំ១៩៦៤ អង្គការបានបើកសន្និបាតមួយនៅក្នុងព្រៃ ដើម្បីអប់រំបំពាក់គោលជំហរគាត់ និងកម្មាភិបាលមួយចំនួនទៀត ឱ្យយល់ជ្រួតជ្រាបពីនយោបាយតស៊ូហិង្សា និងគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន។ ក្រោយបញ្ចប់សន្និបាតនោះ អង្គការបានចាត់តាំងពួកគាត់ក៏បានចុះទៅរៀបចំកម្លាំងតស៊ូនៅតាមមូលដ្ឋាន។

នៅដើមខែមករា ឆ្នាំ១៩៦៧ មូល សម្បត្តិ ហៅរស់ ញឹម លេខាបក្សភូមិភាគ និងគាត់បានរៀបចំផែនការឱ្យកម្លាំងតស៊ូបើកការវាយប្រហារពួកទាហានរាជរដ្ឋាភិបាលនៅស្ពានអូរដាំ។ ប៉ុន្តែពេលនោះ អង្គការបានឱ្យមូល សម្បត្តិ ហៅរស់ ញឹម លេខាបក្សភូមិភាគ ទៅប្រជុំរៀនសូត្របាត់ទៅ ធ្វើឱ្យគាត់គ្រប់គ្រងសភាពការណ៍លែងបាន បណ្តាលឲ្យចលនាតស៊ូបដិវត្តន៍បាត់ម្ចាស់ការ...។ ក្នុងអំឡុងពេលបាត់បង់ម្ចាស់ការនោះ កម្មាភិបាលផ្សេងៗទៀតមាន ម៉ែន ជុន ហៅហឹង្ស, មិត្តស៊ុយ និងមិត្តសាយ នាំគ្នាមកសួរគាត់ថា ត្រូវធ្វើយ៉ាងម៉េចទៀត? គាត់ក៏សម្រេចថា ត្រូវរៀបចំបំផុសប្រជាជននៅតាមភូមិ ឱ្យងើបឡើងបះបោរធ្វើកុបកម្មដណ្តើមអាវុធពីពួកប៉ូលិសទាហានរបស់សម្តេចសីហនុ។

លុះដល់ខែកុម្ភៈ ឆ្នាំ១៩៦៧ដដែល មូល សម្បត្តិ ហៅរស់ ញឹម លេខាបក្សភូមិភាគក៏ត្រលប់ពីប្រជុំរៀនសូត្រ មកដល់មន្ទីរភូមិភាគវិញ មិនបានប៉ុន្មានថ្ងៃផង អង្គការក៏ឱ្យមូល សម្បត្តិ ហៅរស់ ញឹម ទៅប្រជុំរៀនសូត្រម្តងទៀត។

ពេលរៀនសូត្រនោះ មូល សម្បត្តិ ហៅរស់ ញឹម ប្រាប់ថា អង្គការសម្រេចឱ្យផ្អាកការតស៊ូដោយបំផុសប្រជាជននៅតាមភូមិឱ្យងើបឡើងបះបោរធ្វើកុបកម្មនោះហើយ ព្រោះបើ

ធ្វើកុបកម្មនៅខេត្តបាត់ដំបង តែម្នាក់ឯង ខ្លាចរាជរដ្ឋាភិបាលប្រតិកម្មមកវិញ គឺកម្ទេចបដិវត្តន៍នៅទូទាំងប្រទេសជាមិនខាន។

នៅចុងឆ្នាំ១៩៦៧ នួន ជា អនុលេខាបក្សកម្មុយនិស្តកម្ពុជា បានចាត់តាំងគាត់ឲ្យឡើងទៅទីក្រុងភ្នំពេញ ដើម្បីជួបប្រជុំជាមួយ វន វ៉េត និងមេខ្មែរក្រហមម្នាក់ទៀតឈ្មោះប៉ាង នៅផ្ទះដែលគាត់ធ្លាប់ស្នាក់នៅឯផ្សារអូរឫស្សី។ នៅពេលប្រជុំនោះ វន វ៉េត និងឈ្មោះប៉ាង បានណែនាំដាក់ផែនការណ៍ឱ្យគាត់ថា ពេលត្រលប់ទៅវិញ ត្រូវបំផុសប្រជាជននៅតាមភូមិឱ្យងើបឡើងបះបោរធ្វើកុបកម្មចុះ ព្រោះអង្គការបានឯកភាពឱ្យធ្វើសង្គ្រាមឈ្លបហើយ។

ក្រោយទទួលផែនការនេះហើយ គាត់ក៏ប្រញាប់វិលត្រលប់ទៅកាន់មូលដ្ឋានតស៊ូនៅភូមិភាគពាយ័ព្យវិញទាំងយប់ ដើម្បីយកផែនការនេះទៅឆ្លងមូល សម្បត្តិ ហៅរស់ ញឹម លេខាបក្សភូមិភាគ ដើម្បីផ្សព្វផ្សាយដល់កម្មាភិបាលដឹកនាំផ្សេងៗទៀត និងត្រៀមអាវុធ ត្រៀមកម្លាំង ដើម្បីបះបោរធ្វើកុបកម្មនោះ។

គង់ សុផល ហៅកឺ អនុលេខាភូមិភាគពាយ័ព្យ បានបញ្ជាក់ថា នៅព្រឹកថ្ងៃ១៨ ខែមករា ឆ្នាំ១៩៦៨ ពួកគាត់បានដឹកនាំកម្លាំងកងឈ្លប (ខ្មែរក្រហម) វាយដណ្តើមអាវុធពីទាហានរាជរដ្ឋាភិបាលនៅបាយដំរាំ ស្រុកបាណន់ រហូតដល់ពេលល្ងាច ដកកម្លាំងចេញពីបាយដំរាំ ត្រលប់ទៅមូលដ្ឋានតស៊ូនៅសាំងរាំង និងភ្នំវាយចាប វិញ។ ប៉ុន្តែ ៣ខែក្រោយមក គឺនៅក្នុងខែមេសា មេទាហានរាជរដ្ឋាភិបាលម្នាក់ ឈ្មោះសេក សំអៀត បាននាំពលទាហានជាច្រើនមកឡោមព័ទ្ធភ្នំវាយចាប។

ពេលនោះ មិត្តសាយ, មិត្តទាត់ និងមិត្តយ៉ន ជាបញ្ជាការកងឈ្លបស្រុកនាំគ្នាមកសុំយោបល់គាត់។ គាត់ក៏ឱ្យពួកគេទៅប្រមូលកម្លាំងកងឈ្លបទាំងអស់ បើកការវាយប្រហារទៅលើទីតាំងទាហានរាជរដ្ឋាភិបាលនៅភូមិកណ្តាល វិញ តែត្រូវបរាជ័យ។

នៅក្នុងខែឧសភា ឆ្នាំ១៩៦៨ គាត់សម្រេចចិត្តប្រមូលកម្លាំងកងឈ្លប និងប្រជាជនតស៊ូវាយសម្រុកបុកទម្លាយការឡោមព័ទ្ធរបស់ទាហានរាជរដ្ឋាភិបាលនៅភ្នំវាយចាប នោះ តាមផ្លូវថ្មក្រោក ដើម្បីរកច្រកចេញទៅទឹកផ្អឹម និងស្ទឹងតូច ទាល់តែពួកគាត់ និងប្រជាជនជាង

៤៥០០នាក់ បានចេញផុតពីភ្នំវាយចាប នៅសល់តែ៥០នាក់ប៉ុណ្ណោះ។

ពេលបានចេញមកដល់ទឹកផ្អឹម និងស្ទឹងតូច គាត់ឲ្យប្រជាជននាំគ្នាជីកដំឡូងហូបជំនួសបាយ និងឲ្យរស់នៅជាក្រុមៗនៅក្នុងព្រៃ។ លុះដល់ខែសីហា គាត់ប្រមូលកម្លាំងបាន២កងវរៈ ដើររកវាយពួកទាហាន និងប៉ូលិសរាជរដ្ឋាភិបាល ដើម្បីដណ្តើមយកកាំភ្លើង។ នៅក្នុងខែវិច្ឆិកា គាត់បានដឹកនាំកម្លាំងទៅរកមូលសម្បត្តិ ហៅរស់ ញឹម, ខែក ប៉ែន ហៅស៊ូ, ម៉ែន ជន ហៅហ៊ីង្ស និងកម្មាភិបាលភូមិភាគមួយចំនួយទៀតដែលបានគេចខ្លួនទៅទីតាំងថ្មីមួយទៀតហៅថា មន្ទីរក្រញូង។

២ថ្ងៃក្រោយមក យុទ្ធមិត្តរបស់គាត់ម្នាក់ទៀត ឈ្មោះកន្ទុល ក៏បានមកដល់មន្ទីរក្រញូងនេះដែរ។ ប៉ុន្តែ ពេលរស់នៅក្នុងមន្ទីរនោះ បញ្ហាហូបចុកមានការលំបាកខ្លាំងណាស់។ លុះដល់ខែធ្នូ យុទ្ធមិត្តរបស់គាត់៤នាក់ទៀត គឺ មិត្តសាយ, មិត្តទាត់, មិត្តកុត និងមិត្តស៊ុយ ក៏មកដល់មន្ទីរក្រញូង បន្ថែមទៀត។

ដើមឆ្នាំ១៩៦៨ ក្រោយពេលទាហានរាជរដ្ឋាភិបាលដកថយទៅវិញអស់ គាត់បានត្រលប់ទៅភ្នំវាយចាប វិញ។ បន្ទាប់មក គាត់បានទាក់ទងសុំអង្គការធ្វើដំណើរទៅរកប្រពន្ធនៅស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដោយមាននីរសារម្នាក់ឈ្មោះមិត្តប៉ូ ទៅជាមួយគាត់ដែរ។

ពេលទៅដល់ជាយភូមិដែលប្រពន្ធគាត់រស់នៅក្នុងស្រុកឧដុង្គនោះ គាត់មិនហ៊ានចូលទៅក្នុងភូមិភ្លាមៗទេ គឺត្រូវក្តាប់សភាពការណ៍សិន។ ពេលនោះ មានបណ្តាញតស៊ូ ២នាក់ ឈ្មោះតេង និងឈ្មោះឌុច បាននាំគាត់ទៅលាក់ខ្លួនក្នុងគុម្ពោតព្រៃក្បែរអូរមួយ។ ប្រពន្ធគាត់ក៏បានមកជួបគាត់នៅទីនោះ សភាពការណ៍ល្អ ប្រពន្ធក៏នាំគាត់ចូលមកផ្ទះតែម្តង។

ចៃដន្យអ្វី មកជួបប្រពន្ធមិនបានប៉ុន្មានថ្ងៃផង គាត់ក៏ចាប់ផ្តើមក្អួតធ្លាក់ឈាមយ៉ាងច្រើន។ បងស្រីគាត់ឈ្មោះផេន ក៏បាននាំគាត់ទៅសម្រាកព្យាបាលផ្ទះពេទ្យមួយនៅផ្សារបាត់ដឹង។ ពេលនោះ នួន ជា និងវន វ៉េត នៅឯទីក្រុងភ្នំពេញ ដឹងថាគាត់មានជំងឺ ក៏ឱ្យបណ្តាញអ្នកតស៊ូម្នាក់ឈ្មោះមិត្តសេង បើករថយន្តមកដល់កន្លែងគាត់សម្រាកព្យាបាលនៅផ្សារបាត់ដឹងនោះ នៅវេលាម៉ោង១២អធ្រាត្រ ដើម្បីដឹកគាត់យកទៅទីក្រុងភ្នំពេញ។

ដំបូង មិត្តសេង បានបើករថយន្តដឹកគាត់ទៅជួបវន វ៉េត នៅម្តុំបុរីកីឡា សិន។ ក្រោយពីជួបសួរសុខទុក្ខគ្នាហើយ វន វ៉េត ឱ្យគាត់ស្នាក់នៅម្តុំបុរីកីឡានោះមួយយប់ ទើបបញ្ជូនគាត់ទៅកន្លែងបណ្តាញអ្នកតស៊ូម្នាក់ទៀត ឈ្មោះមិត្តយ៉ាត នៅផ្លូវអូហ៊ីយេ ( សព្វថ្ងៃជាផ្លូវព្រះអង្គអេង ឬផ្លូវលេខ១១៣ )ដើម្បីសម្រាកព្យាបាលជំងឺ។

បន្តិចក្រោយមក នួន ជា ក៏បានមកសួរសុខទុក្ខគាត់ដែរ។ គាត់សម្រាកព្យាបាលនៅកន្លែងមិត្តយ៉ាត បានមួយអាទិត្យ ទើប នួន ជា ណែនាំគាត់ឲ្យភ្ជាប់ខ្សែរយៈតស៊ូបដិវត្តន៍ឡើងវិញ កុំឲ្យដាច់។ ក្រោយពេលបានជាសះស្បើយ មុនពេលធ្វើដំណើរវិលត្រលប់ទៅមូលដ្ឋានតស៊ូនៅភ្នំវាយចាបវិញ នួន ជា បានប្រគល់គ្រាប់កាំភ្លើងជាច្រើនកេស និងកាំភ្លើងខ្លី ម៉ាកប៉េអាកុល មួយដើម ព្រមទាំងប្រាក់មួយចំនួនដល់គាត់។

ក្នុងខែកុម្ភៈ ឆ្នាំ១៩៦៩ គាត់ និងគ្រាប់កាំភ្លើងជាច្រើនកេសនោះបានទៅដល់ភ្នំវាយចាប។ បន្ទាប់មក គាត់បានធ្វើការបែងចែកគ្រាប់នោះទៅតាមអង្គភាពកងឈ្លបនីមួយៗ។ ប៉ុន្មានខែក្រោយមក នួន ជា បានហៅគាត់ឲ្យទៅជួបនៅទីក្រុងភ្នំពេញ ដើម្បីប្រជុំពិភាក្សាគ្នាមួយថ្ងៃ ស្តីពីទស្សនៈសភាពការណ៍។ ក្នុងពេលប្រជុំនោះដែរ នួន ជា បានដាក់ផែនការឱ្យគាត់រៀបចំខ្សែរយៈនីរសារ ដើម្បីទាក់ទងកម្លាំងតស៊ូពីភ្នំឱរ៉ាល់(ខេត្តកំពង់ស្ពឺ) ទៅស្រុកមោងឫស្សី(ខេត្តបាត់ដំបង )ផងដែរ។

បន្ទាប់ពីប្រជុំជាមួយនួន ជា ចប់ ម្តងនេះគាត់មិនធ្វើដំណើរតាមផ្លូវជាតិលេខ៥ មកមូលដ្ឋានតស៊ូនៅភ្នំវាយចាប ខេត្តបាត់ដំបង វិញ ដូចលើកមុនៗទេ គឺគាត់ធ្វើដំណើរតាមផ្លូវជាតិលេខ៤ ម្តង។ ពេលទៅដល់មូលដ្ឋានតស៊ូនៅកំពង់ឆ្នាំង ដឹកនាំដោយតាម៉ុក លេខាបក្សភូមិភាគនិរតី គាត់ត្រូវសម្រាកមួយរយៈ ដើម្បីរង់ចាំមិត្តរ៉េន ប្រធានយោធាភ្នំវាយចាប និងឈ្មោះខ្ទួងមកនាំផ្លូវដើរកាត់ព្រៃភ្នំបន្តដំណើរទៅភ្នំវាយចាប វិញ។ នៅមូលដ្ឋានតស៊ូកំពង់ឆ្នាំងនោះ គាត់ក៏បានជួបឈ្មោះដូ ដេត ហៅស៊ុំ (ក្រោយមក ជាលេខាបក្សភូមិភាគបស្ចិម )ផងដែរ។

ក្រោយស្នាក់នៅកំពង់ឆ្នាំង បានមួយរយៈ មិត្តរ៉េន ប្រធានយោធាភ្នំវាយចាប និងឈ្មោះខ្ទួង បានមកដល់ គាត់ក៏លាតាម៉ុក និងដូ ដេត ធ្វើដំណើរកាត់តាមព្រៃភ្នំក្នុងខេត្តពោធិ៍សាត់

ដោយមានកម្មាភិបាលភូមិភាគនិរតី ទៅជាមួយផង។ មុនពេលចេញដំណើរ តាម៉ុក ក៏បានផ្ដល់កាំភ្លើង និងគ្រាប់មួយចំនួនឲ្យគាត់បន្ថែមទៀត។ ពួកគាត់ធ្វើដំណើរកាត់ព្រៃអស់រយៈពេល ១៣យប់១៣ថ្ងៃ ទើបទៅដល់ព្រៃតស៊ូនៅភ្នំវាយចាប។ បន្ទាប់មកគាត់បានរាយការណ៍ទៅថ្នាក់លើនៅក្រុងភ្នំពេញ វិញថា ខាងគាត់អាចដំណើរការតស៊ូដោយអាវុធបានហើយ។

តែនៅក្នុងខែតុលា ឆ្នាំ១៩៦៩ ថ្នាក់លើបានឱ្យរស់ ញឹម ហៅមូល សម្បត្តិ ដឹកនាំកម្មាភិបាលសំខាន់ៗមួយចំនួន រួមមាន គាត់(គង់ សុផល ហៅកឺ), កន្ទុល, វ៉ាញ, សាន, វ៉ាង, អ៊ីន, ទាត់, តូច, គូ... ទៅប្រជុំនៅភូមិភាគនិរតី។

ពួកគាត់បានធ្វើដំណើរពីភ្នំវាយចាប កាត់ព្រៃអស់រយៈពេល៨យប់៨ថ្ងៃ ទើបទៅដល់ភ្នំឱរ៉ាល់ ជាទីតាំងមន្ទីរភូមិភាគនិរតី។ នៅភ្នំឱរ៉ាល់នោះ នួន ជា អនុលេខាបក្សគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា និងវន វ៉េត សមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា និងជាលេខាបក្សក្រុងភ្នំពេញ បានបើកវគ្គរៀនសូត្រនយោបាយអស់រយៈពេលចំនួន ១០ថ្ងៃ ដល់កម្មាភិបាលសំខាន់ៗរបស់ភូមិភាគនិរតី និង៣យ័ព្យ។

ក្រោយពីបញ្ចប់វគ្គនយោបាយនោះមក នួន ជា បានទុកគាត់ឱ្យនៅជាមួយនៅភ្នំឱរ៉ាល់នោះមួយរយៈសិន ដើម្បីជួយដឹកនាំកងឈ្លបបដិវត្តន៍ទប់ទល់ជាមួយពួកទាហាន-ប៉ូលិសរបស់រាជរដ្ឋាភិបាល ដែលចូលទៅរាតត្បាតចលនាតស៊ូនៅភូមិភាគនិរតីនោះ។ ឯកម្មាភិបាលភូមិភាគ៣យ័ព្យផ្សេងទៀតទាំងអស់ ត្រូវត្រលប់ទៅភូមិភាគ៣យ័ព្យ វិញ។

ពេលនោះ កម្លាំងទាហាន-ប៉ូលិសរបស់រាជរដ្ឋាភិបាល បានបើកប្រតិបត្តិការហ៊ុមព័ទ្ធនៅភ្នំឱរ៉ាល់ ដើម្បីកម្ទេចពួកគាត់ដែរ។ តែមុនពេលកម្លាំងទាហាន-ប៉ូលិសហ៊ុមព័ទ្ធនោះ នួន ជា មានជំងឺក៏បានចេញផុតពីភ្នំឱរ៉ាល់ ត្រលប់ទៅក្រុងភ្នំពេញវិញបាត់។ ចំណែក វន វ៉េត ឈឺធ្ងន់ក៏ជាប់នៅលើភ្នំនោះ។

ក្រោយពីសភាពការណ៍បានធូរស្រាលឡើងវិញ គាត់ក៏ឡើងទៅជួបវន វ៉េត និងតាម៉ុកនៅលើភ្នំឱរ៉ាល់ ដើម្បីសុំវិលត្រលប់ទៅភូមិភាគ៣យ័ព្យវិញ។ ពេលនោះវន វ៉េត និងតាម៉ុកបានឱ្យកាំភ្លើងគាត់ថែមមួយចំនួនទៀត។

# ២៣៣
# សាស្ត្រាចារ្យខែក ប៉ែន ហៅស៊ូ
# បំផុសកូនសិស្សឱ្យរត់ចូលព្រៃ

ខែក ប៉ែន ហៅស៊ូ កើតនៅក្នុងឆ្នាំ១៩៤៥។ គាត់បានចូលរៀនថ្នាក់បឋមសិក្សានៅសាលាវត្តតាទេក ស្រុកពួក ខេត្តសៀមរាប។ ក្រោយពីបញ្ចប់ថ្នាក់បឋមសិក្សា គាត់បានប្រលងចូលរៀនថ្នាក់មធ្យមសិក្សានៅខេត្តបាត់ដំបង បន្តទៀត។ រហូតដល់ឆ្នាំ១៩៥៣ គាត់ក៏បានប្រលងជាប់ចូលរៀនសាលាគរុកោសល្យ និងបានរៀនថ្នាក់ជាមួយកុយ ធួន, កែ គឹមហួត, លាង ហាប់អាន ដោយមានសាស្ត្រាចារ្យអ៊ុច វ៉ែន ជាអ្នកជួយអប់រំណែនាំឱ្យយល់ដឹងពីការតស៊ូធ្វើបដិវត្តន៍ ។

ក្នុងឆ្នាំ១៩៥៤ គាត់បានចេញទៅបង្រៀននៅខេត្តសៀមរាប បានរយៈពេលមួយឆ្នាំក៏ផ្លាស់មកធ្វើជាគ្រូកីឡានៅវិទ្យាល័យព្រះស៊ីសុវត្ថិ ដែលកាលនោះមានចាងហ្វាង ឈ្មោះដួង សារិន និងចាងហ្វាងរង ឈ្មោះខៀវ កុមារ។

ឆ្នាំ១៩៦០ គាត់បានប្រលងជាប់ជានិស្សិតសាស្ត្រាចារ្យ ហើយទៅរៀនសាលាគរុកោសល្យជាន់ខ្ពស់ គាត់បានជួប ទីវ អុល, កុយ ធួន,កែ គឹមហួត និងលាង ហាប់អាន ម្តងទៀត ។ ពេលនោះ ទីវ អុល និងកុយ ធួន បានចេញទៅធ្វើជាសាស្ត្រាចារ្យហើយ។ ឯគាត់ និងកែ គឹមហួត បានចូលជានិស្សិតសាស្ត្រាចារ្យជាមួយគ្នា។

ថ្ងៃមួយ កុយ ធួន ហៅធុច បានហៅគាត់ឲ្យទៅជួបនៅផ្ទះ ហើយបាននិយាយអប់រំពន្យល់គាត់ពីបញ្ហាប្រទេសជាតិ ដែលមិនរីកចម្រើន ដោយសារតែរបបសក្តិភូមិហួសសម័យជាអ្នកគ្រប់គ្រង។ គាត់ក៏ឯកភាពពីបញ្ហានេះដែរ។

បន្ទាប់មកទៀត ទីវ អុល ក៏បានផ្តាំផ្ញើតាមរយៈសាស្ត្រាចារ្យយី យ៉ុន ឲ្យគាត់ទៅជួបម្តងទៀត។ ពេលគាត់ទៅដល់ ទីវ អុល ទទួលគាត់ដោយរាក់ទាក់ ព្រមទាំងបង្ហាញពីគំនិតចង់ផ្តួលរម្លំរបបសក្តិភូមិ ហើយផ្លាស់ប្តូររបបថ្មីជំនួសវិញ។

## របត់នយោបាយ

ឆ្នាំ១៩៦២ ទីវ អុល បានអប់រំណែនាំគាត់ឲ្យយល់ដឹងពីទ្រឹស្តីបដិវត្តន៍ ហើយសង្កត់ធ្ងន់ថា បើយើងធ្វើបដិវត្តន៍ ប្រជាជាតិយើងនឹងបានរីកចម្រើនសម្បូរសប្បាយ។

នៅក្នុងឆ្នាំ១៩៦៣ គាត់ និងសាស្ត្រាចារ្យកែ សុខន, ម៉ៃ លន់, យី យ៉ុន, កែ គឹមហួត ក៏បានសម្រេចចិត្តចូលរួមតស៊ូធ្វើបដិវត្តន៍តាមការដឹកនាំរបស់ទីវ អុល ។

ក្រោយមកទៀត គាត់បានជួបមិត្តភក្តិចាស់ម្នាក់ ធ្លាប់រៀនជាមួយគ្នាឈ្មោះហេង ហ៊ី បានបបួលគាត់ទៅដាក់ពាក្យធ្វើការនៅស្ថានទូតអាមេរិក។ ប៉ុន្តែដោយសារគាត់មិនចេះភាសាអង់គ្លេស ហើយការងារជាសាស្ត្រាចារ្យដែលគាត់កំពុងធ្វើនោះ ក៏មានប្រាក់ខែច្រើនគួរសមដែរ គាត់មិនទៅតាមការបបួលមិត្តភក្តិម្នាក់នោះទេ។

ខែក ប៉ែន ហៅស៊ូ បានរម្លឹកថា គាត់ចាប់ផ្តើមធ្វើបដិវត្តន៍ដំបូង នៅក្នុងឆ្នាំ១៩៦៣។ ឆ្នាំ១៩៦៤ តាមការណែនាំរបស់ទីវ អុល គាត់បានចូលរួមសកម្មភាពជាមួយឈ្មោះហូ គឹមហេង ជាខ្សែតស៊ូរបស់ម៉ៃ លន់ នៅសមាគមគ្រូបង្រៀន ធ្វើសកម្មភាពបំផុសសិស្សនិស្សិតឲ្យប្រឆាំងនឹងរបបសក្តិភូមិ។ ហូ គឹមហេង នេះ ជាអតីតពួកប្រជាចលនា(អង្គការប្រជាចលនារួមខ្មែរបម្រើជាតិ របស់មេដឹកនាំខ្មែរសេរី សឺង ង៉ុកថាញ់)។ ឆ្នាំ១៩៦៤ គាត់បានចូលជាបក្ខជននៅទីស្នាក់ការសមាគមសាស្ត្រាចារ្យ ដោយមាន កែ សុខន និងម៉ៃ លន់ ជាអ្នកទទួលស្គាល់ ហើយអ្នកដែលបានចូលបក្ខជនជាមួយគាត់នៅពេលនោះ គឺយី យ៉ុន និងកែ គឹមហួត។

នៅឆ្នាំដដែលនោះ ពេលទៅបង្ហាត់កីឡានៅវិទ្យាល័យព្រះយុគន្ធរ គាត់បានកសាងកម្លាំងបដិវត្តន៍បានពីរនាក់គឺឈ្មោះសុត ហៅសៀន និងឡាយ ឡេងហួ ហៅប៉ូពាំ។ ក្រោយមកឈ្មោះសុត ហៅសៀន បានចេញទៅតស៊ូនៅភូមិភាគពាយ័ព្យ។ ចំណែក ឡាយ ឡេងហួ ហៅប៉ូពាំ ចេញទៅតស៊ូខាងភូមិភាគនិរតី។

នៅក្នុងឆ្នាំ១៩៦៥ គាត់បានផ្លាស់ទៅបង្រៀននៅវិទ្យាល័យព្រះអង្គឌួង ខេត្តព្រៃវែង។ ពេលនោះ ទីវ អុល ដែលទៅបង្រៀននៅវិទ្យាល័យព្រះអង្គឌួង នោះដែរ បានឧទ្ទិសនាមគាត់ឲ្យទាក់ទងជាមួយ កែ សុខន ជាចាងហ្វាងវិទ្យាល័យនោះ ដើម្បីអប់រំយុវជនជាសិស្សឲ្យបានយល់ដឹងពីបដិវត្តន៍ និងការតស៊ូវណ្ណៈ។

នៅខេត្តព្រៃវែងនោះ គាត់បានកសាងកម្លាំង២នាក់ គឺម្នាក់ឈ្មោះ ហែម យន ហៅសែម នៅភូមិភាគឧត្តរ និងម្នាក់ទៀតឈ្មោះហម ចេញទៅព្រៃតស៊ូនៅភូមិភាគពាយ័ព្យ។

ក្រោយមក ទីវ អុល បានឱ្យគាត់សុំរាជការផ្លាស់ចេញពីខេត្តព្រៃវែង ទៅបង្រៀននៅខេត្តកំពង់ស្ពឺវិញ ព្រមទាំងបានណែនាំគាត់ឲ្យទាក់ទងសាស្ត្រាចារ្យឃី យ៉ុន ដើម្បីធ្វើសកម្មភាពបដិវត្តន៍។

នៅខេត្តកំពង់ស្ពឺ គាត់ និងសាស្ត្រាចារ្យឃី យ៉ុន បានធ្វើសកម្មភាពបដិវត្តន៍អូសទាញយុវជននៅវិទ្យាល័យសុទ្ធិពល បានបីនាក់ គឺឈ្មោះឈូ សារ៉េត ហៅបាង, ខៀវ វ៉ាន់ហុន និងសេន តាមរយៈមនោសញ្ចេតនា និងជួយឧបត្ថម្ភប្រាក់កាសដល់ពួកគេ ដើម្បីទិញសម្ភារៈរៀនសូត្រ។ ក្រោយមក គាត់ក៏បានបញ្ចូលយុវជនទាំងបីនេះជាបក្ខជន ដោយមានទីវ អុល ជាអ្នកគ្រប់គ្រង។

ប៉ុន្តែមិនយូរប៉ុន្មាន គាត់បានផ្លាស់ចេញពីខេត្តកំពង់ស្ពឺ ក៏ប្រគល់យុវជនទាំង៣នាក់នោះទៅឱ្យឃី យ៉ុន ជាអ្នកគ្រប់គ្រងបន្ត។ ឆ្នាំ១៩៦៧ គាត់ផ្លាស់ពីខេត្តកំពង់ស្ពឺ មកបង្រៀននៅវិទ្យាល័យឥន្ទ្រទេវី នៅទួលគោក ក៏បានជួបទីវ អុល, កង សារ៉ន, ចាន់ស សេរី រួមគ្នាធ្វើសកម្មភាពបំផុសយុវជនឲ្យរត់ចូលព្រៃតស៊ូ។

នៅដើមឆ្នាំ១៩៦៧ ទីវ អុល បានប្រាប់គាត់ឲ្យដឹងពីសភាពការបដិវត្តន៍មានការប្រែប្រួលពិសេសមានកម្មាភិបាលជាច្រើនបានចាកចេញពីទីក្រុង ទៅជនបទ។ ដូច្នេះ គាត់ក៏ត្រូវចាកចេញពីក្រុងភ្នំពេញ ទៅជនបទ ដើម្បីតស៊ូធ្វើបដិវត្តន៍ដែរ។ ពេលនោះ ទីវ អុល ក៏ប្រាប់គាត់ឱ្យស្គាល់មេដឹកនាំថ្មីរបស់គាត់ដែលនៅក្នុងព្រៃតស៊ូនោះ ឈ្មោះថន និងក្រុមថ្មីរបស់គាត់មានឈ្មោះជា ហួន ហៅវ៉ាញ (ក្រោយមកជាលេខាបក្សតំបន់១ ភូមិភាគពាយ័ព្យ), ម៉ែន ជុន ហៅហឹង្ស (ក្រោយមកជាលេខាបក្សតំបន់៥ ភូមិភាគពាយ័ព្យ) ។

នៅថ្ងៃចាកចេញពីទីក្រុងភ្នំពេញ ចូលព្រៃតស៊ូនោះ គាត់បានទៅកន្លែងណាត់ជួបគ្នាជាមួយឈ្មោះគិន ហៅគុន ដែលជាអ្នកមកជួប និងណែនាំគាត់ឱ្យស្គាល់នីរសារម្នាក់មកពីភូមិភាគពាយ័ព្យ ឈ្មោះដូ ហើយដូ ក៏នាំគាត់ជិះរថយន្តឈ្នួលចេញពីក្រុងភ្នំពេញ ទៅភូមិ

ភាគពាយ័ព្យ (ខេត្តបាត់ដំបង)តែម្តង។

ពេលទៅដល់ខេត្តបាត់ដំបង ឈ្មោះសារិន និងសាន មកទទួលគាត់បន្តដំណើរទៅភ្នំវាយចាប ហើយបានជួបថន មេដឹកនាំថ្មី នៅទីនោះ ដូចដែល ទីវ អុល ប្រាប់គាត់។ បន្ទាប់ពីស្នាក់នៅភ្នំវាយចាប មួយរយៈមក ឈ្មោះសាន ក៏បាននាំគាត់ធ្វើដំណើរចេញពីភ្នំវាយចាបទៅភ្នំសំឡូត ដោយចំណាយពេលអស់រយៈពេលមួយអាទិត្យ ទើបដល់មន្ទីរភូមិភាគពាយ័ព្យដោយមានកម្មាភិបាលទទួលខុសត្រូវនៅទីនោះទទួលគាត់យ៉ាងរាក់ទាក់។

ឆ្នាំ១៩៦៨អង្គការបដិវត្តន៍បានបើកវគ្គរៀនសូត្រនយោបាយមួយ ក្រោមអធិបតីភាពរបស់មិត្តសាយ តំណាងអង្គការភូមិភាគ រូបគាត់(ខែក ប៉ែន ហៅស៊ូ), សៀន, សាន, វ៉ាញ និងហ៊ឹង្ស(ម៉ែន ជុន) ក៏បានចូលរួមដែរ។ ពេលនោះមិត្តសាយ បានលើកឡើងនូវទ្រឹស្តីមួយថា មិនវាយខ្មាំង គឺសំងំសុខ, រកស្បៀង គឺសំងំរស់។

ចំណែកមិត្តសៀន ក៏បានលើកឡើងពីបញ្ហាសាមគ្គីភាពរវាងអ្នកតស៊ូមកពីទីក្រុងភ្នំពេញ និងអ្នកតស៊ូនៅក្នុងព្រៃតាំងពីដើមមកថា អង្គការភូមិភាគមានការចង្អៀតចង្អល់ចំពោះអ្នកតស៊ូមកពីទីក្រុង។ ឯមិត្តវ៉ាញ បានលើកឡើងពីទំនាក់ទំនងរវាងកម្មាភិបាលជាកសិករនៅជនបទ និងកម្មាភិបាលមកពីទីក្រុង។ ពេលចប់វគ្គ មិត្តសាយ បានណែនាំឲ្យអង្គប្រជុំទាំងអស់ឲ្យបំពេញភារកិច្ចបដិវត្តន៍ឲ្យបានត្រឹមត្រូវតាមមាគ៌ាបដិវត្តន៍។

ខែក ប៉ែន ហៅស៊ូ បានបញ្ជាក់ថា ពេលនោះ មិត្តសាយ គាត់ និងមិត្តវ៉ាញ ដឹកនាំកងឈ្លបមួយក្រុម។ តែដោយសារដាច់ស្បៀងអាហារខ្លាំងពេក ពួកគាត់ក៏ដឹកនាំកងឈ្លបទាំងអស់នោះ ទៅជីកក្តួចហូប ដោយមិនបានគិតគូរពីរឿងវាយខ្មាំងទេ គឺគិតគូរតែពីរឿងធ្វើក្តួចហូបវិញ។

ជាមួយគ្នានោះ មិត្តវ៉ាញ និងគាត់បានសរសេរអត្ថបទចុះផ្សាយព្រឹត្តិបត្របដិវត្តន៍ ដោយរៀបរាប់ពីប្រវត្តិតស៊ូនៅក្នុងព្រៃហូបតែក្តួចនោះផងដែរ។ តែការសរសេរនេះ គ្រាន់តែដើម្បីបង្ហាញពីស្មារតីប្រយុទ្ធតស៊ូវណ្ណៈរបស់កម្មករ និងកសិករប៉ុណ្ណោះ។

# ២៣៤
# សាស្ត្រាចារ្យ អ៊ុំ ឈឿន ហៅម៉ៃ
# បោះបង់ប្រាក់ខែ-ប្រពន្ធកូន ទៅតស៊ូនៅភ្នំឱរ៉ាល់

អ៊ុំ ឈឿន ហៅម៉ៃ មានស្រុកកំណើតនៅភូមិចម្រុះ ឃុំរំចេក ស្រុកបាភ្នំ (សព្វថ្ងៃឃុំរំចេកស្ថិតនៅក្នុងស្រុកព្រះស្ដេច)ខេត្តព្រៃវែង។ ឪពុកឈ្មោះអ៊ុំ ប៉ែក ជាស្មៀនឃុំចាស់ ក្រោយមករកស៊ីធ្វើស្រែ និងម្ដាយឈ្មោះអ៊ិន ផ្លឹង។

ពីឆ្នាំ១៩៤៥ ដល់ឆ្នាំ១៩៤៦ គាត់បានចូលរៀននៅសាលាវត្តសទ្ធា ក្នុងឃុំរំចេក។ ពីឆ្នាំ១៩៤៧ គាត់ទៅរៀននៅសាលាបឋមសិក្សាឈើកាច់ (ស្រុកបាភ្នំ)។ ដល់ឆ្នាំ១៩៥៣ រៀនចប់សាលាបឋម គាត់ក៏បានទៅប្រលងនៅខេត្តស្វាយរៀង ដើម្បីសិក្សានៅថ្នាក់មធ្យមសិក្សាបន្តទៀត តែប្រលងធ្លាក់។ ទោះបីយ៉ាងណា ខាងសាលាក៏បានជ្រើសរើសសិស្ស ១០ នាក់ ក្នុងចំណោមសិស្សដែលប្រលងធ្លាក់ទាំងអស់ ក្នុងនោះមានគាត់ម្នាក់ដែរ ឲ្យទៅរៀនសាលាគរុកោសល្យនៅក្រុងភ្នំពេញ។

ចាប់ពីឆ្នាំ១៩៥៣ គាត់បានទៅរៀនសាលាគរុកោសល្យនៅទីក្រុងភ្នំពេញ ហើយបានចេញធ្វើជាគ្រូបង្រៀនថ្នាក់បឋមសិក្សា រហូតដល់ឆ្នាំ១៩៦១គាត់បានធ្វើជាសាស្ត្រាចារ្យទៅបង្រៀននៅវិទ្យាល័យកំពង់ធំ ទៀតផង។

នៅក្នុងឆ្នាំ១៩៦៥ គាត់ក៏បានផ្លាស់មកធ្វើជាសាស្ត្រាចារ្យនៅវិទ្យាល័យតាខ្មៅ វិញ។ នៅវិទ្យាល័យតាខ្មៅ គាត់ទទួលបាននូវការស្រលាញ់រាប់អានពីសាស្ត្រាចារ្យឈ្មោះកែ គឹមហួត (ជាអ្នកតស៊ូបដិវត្តន៍ ក្រោយមក កែ គឹមហួត ហៅ សមមិត្តសុត ជាលេខាបក្សតំបន់៧ ភូមិភាគពាយ័ព្យ) និងសាស្ត្រាចារ្យឈ្មោះសាំង រិន (ជាអ្នកតស៊ូបដិវត្តន៍ ក្រោយមក នៅឆ្នាំ១៩៧៤ ជាលេខាតំបន់៣៥ នៅភូមិភាគនិរតី) និងសាស្ត្រាចារ្យម្នាក់ទៀតឈ្មោះធុច រិន ហៅឌិក គ្រិន (ជាអ្នកតស៊ូបដិវត្តន៍ សម័យសង្គ្រាម ពីឆ្នាំ១៩៧០ ជាសមាជិកគណៈកម្មាធិការបក្សភូមិភាគនិរតី។ ក្រោយថ្ងៃជ័យជម្នះ ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ជាប្រធានកំពង់ផែកំពង់សោម)។

## របត់នយោបាយ

ក្រោយពីបានស្រលាញ់រាប់អានគ្នាមក សាស្ត្រាចារ្យឈ្មោះកែ គឹមហួត តែងតែនិយាយបញ្ចុះបញ្ចូលឲ្យគាត់យល់ពីការតស៊ូបដិវត្តន៍ ដើម្បីបង្កើតរបបកុម្មុយនិស្តមួយ ដែលមានភាពស្មើគ្នា កម្មករ កសិករគ្មានការជិះជាន់។ មិនយូរប៉ុន្មាន គាត់ក៏បានស្ម័គ្រចិត្តចូលរួមចលនាតស៊ូធ្វើបដិវត្តន៍ រហូតត្រូវបានអង្គការបញ្ចូលជាបក្ខជន នៅក្នុងខែមិថុនា ឆ្នាំ១៩៦៦។

កែ គឹមហួត មានប្រពន្ធជាគ្រូបង្រៀនដែរ។ ប្ដីប្រពន្ធ២នាក់នេះ គឺជាគ្រូរបស់កាំង ហ្កិចអ៊ាវ ហៅឌុច (មេគុកទួលស្លែង) កាលពីឌុច រៀនសាលាបឋមសិក្សា នៅស្រុកកំណើត ឯស្រុកស្ទោង ខេត្តកំពង់ធំ ផងដែរ។

អ៊ុំ ឈឿន ហៅម៉ែ បានរម្លឹកថា នៅពេលចូលបវេសនកាលឆ្នាំ១៩៦៧ តំណាងអង្គការបដិវត្តន៍ម្នាក់ បានមកជួបគាត់ដល់ផ្ទះ ហើយប្រាប់ថា ឈឿនឯងត្រូវចេញទៅធ្វើបដិវត្តន៍នៅជនបទ ជាមួយកែ គឹមហួត។ គាត់ក៏ដូចកែ គឹមហួត ដែរ ក្នុងនាមជាបក្ខជន បានសម្រេចចិត្តបោះបង់តួនាទីជាសាស្ត្រាចារ្យ បោះបង់ប្រាក់ខែ បោះបង់ប្រពន្ធកូន ដើម្បីបុព្វហេតុបដិវត្តន៍។

លុះដល់វេលាម៉ោង៧យប់ នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៦៧ ស្មៀនរបស់សមាគមសាស្ត្រាចារ្យខ្មែរ ដែលមានឈ្មោះបដិវត្តន៍ថាគុន បានមករង់ចាំទទួលពួកគាត់នៅកន្លែងណាត់ជួបគ្នានៅជ្រុងខាងត្បូងចៀងខាងកើតសាលាបឋមសិក្សាសន្ធរម៉ុក ហើយពួកគាត់ទាំង២នាក់ ក៏បានទៅកន្លែងណាត់ជួបគ្នាតាមពេលវេលាកំណត់ដែរ។ ពេលនោះ ឈ្មោះគុន បាននាំគាត់ទាំង២នាក់ ទៅជិះឡានហ្ស៊ីបមួយគ្រឿង ដោយមាននីរសារខ្មែរក្រហមម្នាក់ឈ្មោះសេង និងគ្រូបង្រៀននៅសាលាគរុកោសល្យ ឈ្មោះថៃ ជាអ្នកជូនដំណើរ។

យប់នោះពួកគាត់ត្រូវបានគេដឹកតាមរថយន្ត ទៅដល់ភូមិមួយឈ្មោះភូមិគោល ក្នុងឃុំវាលពន់ ស្រុកថ្លង ខេត្តកំពង់ស្ពឺ ដោយមានអ្នកបដិវត្តន៍ជើងចាស់ម្នាក់ឈ្មោះប៉ាល់ មកទទួលយកគាត់ទៅធ្វើការជាមួយនៅក្នុងព្រៃតស៊ូ។ មិនយូរប៉ុន្មាន អង្គការបានប្រគល់ភារកិច្ចឱ្យគាត់ និងកែ គឹមហួត ចេញចូលធ្វើការនៅភូមិមួយឈ្មោះភូមិត្រពាំងស្រងែ ក្នុងឃុំខ្នារឆ្មារ ខេត្តកំពង់ឆ្នាំង។

លុះដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៦៨ ជាថ្ងៃដែលអ្នកតស៊ូវាយដណ្ដើមអាវុធពីទាហាន

រាជរដ្ឋាភិបាលនៅភូមិភាគនិរតី តាប៉ាល់ ជាមេដឹកនាំចលនាតស៊ូជើងចាស់ បានដឹកនាំកម្លាំង ១០នាក់ ឡើងទៅតាំងមូលដ្ឋានតស៊ូនៅលើភ្នំឱរ៉ាល់ ក្នុងនោះមាន រូបគាត់  និងកែ គឹមហួត។

# ២៣៥
# ម៉ែន ជុន ហៅហឹង្ស មន្ត្រីធនាគារជាតិ ចូលព្រៃតស៊ូ

ម៉ែន ជុន ហៅហឹង្ស មានស្រុកកំណើតនៅភូមិកំពង់ចិន ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ។ ក្នុងឆ្នាំ១៩៤៩ គាត់បានចូលរៀនថ្នាក់កុមារដ្ឋាន នៅសាលាបឋមសិក្សាស្ទោង។

ឆ្នាំ១៩៥០ ឪពុកម្តាយគាត់បានផ្លាស់ទីលំនៅទៅរស់នៅក្នុងភូមិថ្មគរ ឃុំថ្មគរ ស្រុកល្វាឯម ខេត្តកណ្តាល បានរយៈពេលមួយឆ្នាំ ឪពុកគាត់ក៏ផ្លាស់ប្តូរទីលំនៅមករស់នៅម្តុំបឹង-កេងកង ទីក្រុងភ្នំពេញ ដើម្បីប្រកបមុខរបរជាជាងមាស ហើយគាត់បានចូលរៀននៅសាលាបឋមសិក្សាបឹងកេងកង បន្តទៀត។

លុះដល់ឆ្នាំ១៩៥៦ គាត់បានទៅរៀនគួរនៅវិទ្យាល័យកម្ពុជបុត្រ(រៀនគួរត្រៀមប្រលងចូលថ្នាក់ទី៦ទំនើបជាតិ)។ ពេលនោះ គាត់បានទទួលការអប់រំពីឈ្មោះទួន សុវណ្ណ ដែលមានបងថ្លៃ ធ្លាប់រត់ទៅចូលរួមតស៊ូជាមួយប្រជាចលនារួមខ្មែរបម្រើជាតិ របស់សឺង ង៉ុកថាញ់ នៅព្រំដែនប្រទេសថៃ។

ក្នុងឆ្នាំ១៩៥៧ គាត់បានប្រលងជាប់ចូលរៀនថ្នាក់ទី៦ទំនើបជាតិ នៅសាលាឧបសម្ព័ន្ធវិទ្យាល័យព្រះស៊ីសុវត្ថិ និងបានចូលរួមជាក្រុមកីឡាបាល់ទះប្រចាំសាលា ដែលមានគង់ សុផល ជាអ្នកបង្ហាត់ (គង់ សុផល ជាមេដឹកនាំខ្មែរក្រហមម្នាក់ដែរ។ ក្រោយមក នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គង់ សុផល ហៅសមមិត្តកឹ ជាអនុលេខាបក្សភូមិភាគពាយ័ព្យ)។

ម៉ែន ជុន ហៅហឹង្ស បានរម្លឹកថា នៅដើមឆ្នាំ១៩៦៤ ដាំ ផេង (ពេលនោះ ដាំ ផេង កំពុងរៀនថ្នាក់ទី២នៅវិទ្យាល័យព្រះយុគន្ធរ បានបោះបង់ការសិក្សា ហើយស្ម័គ្រចិត្តធ្វើសកម្ម-ភាពតស៊ូបដិវត្តន៍យ៉ាងប្តូរផ្តាច់) បានណែនាំគាត់ ពុត ជា, ថាច់ ញឹង និងថាច់ គឹមសឺង ឲ្យទៅចូលរួមធ្វើបាតុកម្មមួយ។

ក្រោយពីធ្វើបាតុកម្មនោះមក លន់ នល់, គូ រុន និងកុយ ស៊ីអ៊ី បានហៅពួកគាត់ទាំង ៥នាក់ (គាត់, ដាំ ផេង ,ពុត ជា, ថាច់ ញឹង និងថាច់ គឹមសឺង នៅសាលាគរុកោសល្យ) ទៅ

ជួប ហើយសម្លុតគំរាមកំហែងឲ្យឈប់ធ្វើសកម្មភាពបះបោរទៀត និងឲ្យពួកគិញ (ភ្នាក់ងារសម្ងាត់) តាមដានពួកគាត់ជាប់ជានិច្ចទៀតផង។

ដោយសារមូលហេតុនេះហើយ អង្គការបក្សក៏បានសម្រេចឱ្យគាត់ឈប់រៀន ហើយឲ្យចូលធ្វើការសម្ងាត់តាមរយៈឈ្មោះគៀត វិញ។ នៅក្នុងខែកក្កដា ឆ្នាំ១៩៦៥ គាត់បានចូលធ្វើការនៅធនាគារជាតិ។

ក្រោយមក វ៉ាន់ ពីនី ហៅទិត និងឈ្មោះកន (អ្នកតស៊ូបដិវត្តន៍រៀមច្បង) ក៏បានរៀបចំឧទ្ទេសនាមឲ្យគាត់ចូលជាបក្ខជន។ បន្ទាប់ពីបានចូលជាបក្ខជនមក វ៉ាន់ ពីនី ក៏បានណែនាំគាត់ឲ្យទាក់ទងជាមួយម៉ៃ សាខន, ឈុន សុខងួន, ទួន សុខផល្លា, ងួន ឃៀង និងម៉ែន សិទ្ធី (សុទ្ធតែអ្នកតស៊ូសម្ងាត់) ដើម្បីសហការគ្នាធ្វើសកម្មភាពបដិវត្តន៍។

ម៉ែន ជុន ហៅហឹង្ស បានរម្លឹកបន្តថា ចំណែកនៅធនាគារជាតិ គាត់ក៏បានទាក់ទងជាមួយយ៉ង់ ហ៊ន សិស្សថ្នាក់ទី១ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ដើម្បីណែនាំអប់រំឱ្យចូលរួមក្នុងចលនាតស៊ូជាមួយគាត់ដែរ។

ក្នុងខែកញ្ញា ឆ្នាំ១៩៦៥ ប្រធានធនាគារឥណទានជាតិ ក៏បានផ្លាស់គាត់ឲ្យទៅធ្វើការនៅសាខាធនាគារឥណទានជាតិ នៅខេត្តកំពង់ធំ។ នៅទីនោះគាត់បានទាក់ទងជាមួយឈ្មោះព្រុំ ពុយ ជាម្ចាស់ឱសថស្ថានមួយនៅផ្សារកំពង់ធំ, ឈ្មោះអេង និងឈ្មោះព្រំ ធន ជាគ្រូបង្រៀន ដើម្បីកសាងកម្លាំងបដិវត្តន៍ឲ្យចូលរួមចលនាតស៊ូដែរ។

បន្ទាប់មកគាត់ក៏បាននាំអ្នកទាំង៣(ព្រុំ ពុយ, អេង និងឈ្មោះព្រំ ធន) ឡើងមកទីក្រុងភ្នំពេញ ដើម្បីទៅជួបវ៉ាន់ ពីនី ឲ្យទទួលស្គាល់ និងដាក់ផែនការឲ្យពួកគាត់បន្តកសាងកម្លាំងបដិវត្តន៍ថែមទៀត នៅក្នុងចំណោមអ្នកធ្វើការជាមួយគ្នា និងសិស្សសាលាផងដែរ។

នៅក្នុងខែធ្នូ ឆ្នាំ១៩៦៥តាមរយៈមិត្តកន អង្គការបក្សបានសម្រេចឲ្យគាត់ចេញទៅបន្តការតស៊ូនៅជនបទ។ ពេលនោះ គាត់ក៏បានរាយការណ៍ទៅឲ្យវ៉ាន់ ពីនី បានដឹងដែរ ហើយវ៉ាន់ ពីនី ក៏បានឧទ្ទេសនាមគាត់ឱ្យស្គាល់ឈ្មោះសៀន ជាស្មៀនរបស់មូល សម្បត្តិ ហៅរស់ ញឹម ជាលេខាបក្សភូមិភាគពាយ័ព្យ។

## របត់នយោបាយ

ក្នុងខែមករា ឆ្នាំ១៩៦៦ គាត់បានចាកចេញពីទីក្រុងភ្នំពេញ ទៅខេត្តបាត់ដំបង (ភូមិភាគពាយ័ព្យ) ហើយបានជួបមិត្តទាត់ (ក្រោយមក មិត្តទាត់ នេះ ជាលេខាបក្សតំបន់១)។ បន្ទាប់មក នៅស្រុកសង្កែ មិត្តទាត់ ក៏បានឧទ្ទេសនាមឱ្យគាត់បានស្គាល់មូល សម្បត្តិ ហៅរស់ ញឹម ជាលេខាបក្សភូមិភាគពាយ័ព្យ។

បន្ទាប់មកទៀត គាត់ក៏បានជួបមិត្តសៀន ជាស្មៀនរបស់មូល សម្បត្តិ ហៅរស់ ញឹម ហើយ មិត្តសៀន ក៏បានឧទ្ទេសនាមឲ្យគាត់បានស្គាល់មិត្តសាយ សមាជិកគណៈភូមិភាគ និងមិត្តស៊ុយ ជំនួយការគណៈភូមិភាគ និងជាអនុលេខាបក្សតំបន់៤ ទៀតផង។ ពេលនោះ មូល សម្បត្តិ ហៅរស់ ញឹម បានណែនាំគាត់ឱ្យធ្វើជាកូនចិញ្ចឹមរបស់តាក្តុល សមាជិកគណៈភូមិភាគ ហើយតាក្តុល បានចាត់តាំងគាត់ឲ្យចូលជាសមាជិកសាខាបក្សមួយ ដែលមានមិត្តគីម ជាលេខាសាខាបក្សនោះ។ នៅសាខាបក្សនោះ គាត់មានតួនាទីជាអ្នកឧទ្ទេសនាមឯកសារ ដើម្បីអប់រំសមាជិកក្នុងសាខាបក្ស។

នៅពាក់កណ្តាលឆ្នាំ១៩៦៦ គាត់ទៅធ្វើការនៅស្រុកសំឡូត បានមួយខែកន្លះ ក៏មានជំងឺគ្រុនចាញ់ ទើបអង្គការឲ្យត្រលប់មកសម្រាកព្យាបាលនៅភូមិស្រែខ្វាវ វិញ ដោយមានមិត្តសាយ និងមិត្តស៊ុយ ជាអ្នកជួយថែទាំ។ ក្រោយពីបានសះស្បើយពីជំងឺគ្រុនចាញ់ គាត់ក៏ត្រលប់ទៅធ្វើការនៅស្រុកសំឡូត វិញ។

ក្នុងខែកុម្ភៈ ឆ្នាំ១៩៦៧ មិត្តកី បានបើកវគ្គរៀនសូត្រនយោបាយមួយនៅជិតភូមិសំរោង ដោយមានមិត្តសាយ, មិត្តស៊ុយ មិត្តវ៉ាញ និងគាត់បានចូលរួមដែរ។ ក្រោយមក ម៉ែន ផុន ហៅសមមិត្តហឹង្ស បានឡើងឋានៈជាលេខាបក្សតំបន់៥ ភូមិភាគពាយ័ព្យ។

# ២៣៦
# ហួត សម្បត្តិ បែកបាក់សាមគ្គីគ្នាជាមួយ សម សារី



**ហួត សម្បត្តិ**

បើតាមឯកសារដែលបានបន្សល់ទុកនៅគុកទួលស្លែង(មន្ទីរ.២១) ហួត សម្បត្តិ បានសរសេររៀបរាប់ថា បន្ទាប់ពីបងប្រុសរបស់គាត់ម្នាក់ឈ្មោះហួត សុវណ្ណ ត្រូវបាត់បង់ជីវិតដោយសារស្នាដៃពួកអាណានិគមនិយម គាត់ជាប្អូនបានចេញទៅបន្តការសិក្សានៅ ប្រទេសបារាំង។ នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៤៩ គាត់បានទៅដល់ប្រទេសបារាំង ហើយព្យាយាមស្វែងរកឌុក រ៉ាស៊ី ដែលជាមិត្តភក្តិជិតស្និទ្ធធ្លាប់រៀនសូត្រជាមួយបងប្រុសគាត់(ហួត សុវណ្ណ) ពីមុនមក។

ក្រោយពីបានជួបគ្នា ឌុក រ៉ាស៊ី ក៏បានណែនាំគាត់ឲ្យស្គាល់សម សារី និងម៉ៅ សាយជាបន្តទៀត។ ពេលកំពុងសិក្សានៅប្រទេសបារាំងនោះ គាត់ក៏ចង់តស៊ូបណ្ដេញពួកអាណានិគមនិយមបារាំងឲ្យចេញពីប្រទេស ដើម្បីបន្តបេសកកម្មតស៊ូប្រឆាំងនឹងបារាំង ពីបងប្រុសរបស់គាត់(ហួត សុវណ្ណ)ដែលត្រូវបារាំង សម្លាប់នោះដែរ។

នៅទីក្រុងប៉ារីស គាត់បានជួបទាក់ទងជាមួយសាក់ ឌុយក្លូ និងអង់ជ្រេ ម៉ាទី ជាសមាជិក

គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តបារាំង។ មេដឹកនាំបក្សកុម្មុយនិស្តបារាំងទាំងពីរនាក់នេះ ក៏បានឲ្យគាត់ទៅជួបតំណាងបក្សកុម្មុយនិស្តឥណ្ឌូចិន ជាជនជាតិវៀតណាមម្នាក់។

ពេលនោះ គាត់ចេះតែឆ្ងល់ថា ហេតុអ្វី បានជាមេដឹកនាំបក្សកុម្មុយនិស្តបារាំង ឲ្យគាត់ទៅជួបជនជាតិវៀតណាម ជាតំណាងបក្សកុម្មុយនិស្តឥណ្ឌូចិន ដូច្នេះទៅវិញ? តើបារាំងចង់ឲ្យកម្ពុជា ធ្វើរណបវៀតណាមឬ?។

តែសម សារី និងម៉ៅ សាយ បានប្រាប់គាត់ថា យើងមានផ្លូវតែម្យ៉ាងទេ គឺត្រូវតែចូលដៃជាមួយអាមេរិក ពីព្រោះមានតែអាមេរិកទេ ដែលអាចបង្ខំបារាំង ឲ្យប្រគល់ឯករាជ្យមកឲ្យប្រទេសយើងវិញបាន។ ឯពួកកុម្មុយនិស្តគ្មានលទ្ធភាពបណ្ដេញពួកបារាំង បានឡើយ។ ពេលនោះ គាត់មិនដឹងថា សម សារី, ម៉ៅ សាយ និងឌុក រ៉ាស៊ី ជាអ្វីទេ គឺគ្រាន់តែដឹងថា ពួកគេជាអ្នកប្រឆាំងនឹងពួកកុម្មុយនិស្ត ។

រហូតមកដល់ឆ្នាំ១៩៥៨ ទើបគាត់ដឹងថា សម សារី ជាអ្នកបម្រើនយោបាយឲ្យអាមេរិក ព្រោះសម្ដេចសីហនុ តាមរកចាប់ សម សារី ក៏រត់គៀសខ្លួនទៅនៅវៀតណាមខាងត្បូង ចូលរួមជាមួយចលនាតស៊ូខ្មែរសេរី របស់សឺង ង៉ុកថាញ់។

ហួត សម្បត្តិ រម្លឹកថា កាលនៅរៀនប្រទេសបារាំង គាត់គ្មានទាក់ទងអ្វីជាមួយភ្នាក់ងារសេអ៊ីអាទេ។ តែគាត់មានទំនាក់ទំនងយូរៗម្ដងជាមួយសម សារី, ម៉ៅ សាយ និងឌុក រ៉ាស៊ី។

ក្នុងឆ្នាំ១៩៥០ គាត់បានផ្ញើសំបុត្រមួយតាមរយៈមន្ត្រីអាមេរិកម្នាក់ឈ្មោះបែន សាមាំង ដែលបានមករួមប្រជុំធំមួយនៅក្រុងប៉ារីស ទៅឲ្យរដ្ឋមន្ត្រីការបរទេសអាមេរិក ឈ្មោះអែន ជីសុន ឱ្យដឹងថា ប្រជាជនខ្មែរទូទៅចង់បានឯករាជ្យ ដោយបណ្ដេញពួកអាណានិគមបារាំង ឲ្យចេញពីប្រទេសកម្ពុជា។ ប៉ុន្តែរដ្ឋមន្ត្រីការបរទេសអាមេរិករូបនោះ មិនបានឆ្លើយតបមកគាត់វិញទេ។

នៅក្នុងឆ្នាំ១៩៥២ នាយករដ្ឋមន្ត្រីប៉ែន នុត បានទាក់ទងឱ្យគាត់ជួយកាត់ទំព័រកាសែតបារាំង ដែលចុះផ្សាយពីព័ត៌មានសំខាន់ៗដែលទាក់ទងនឹងប្រទេសកម្ពុជា ផ្ញើមកឲ្យប៉ែន នុត ដែលនៅក្នុងប្រទេស ក្នុងរយៈពេលមួយសប្ដាហ៍ម្ដងៗ។ ចំណែកនាយករដ្ឋមន្ត្រីប៉ែន នុត ក៏តែងតែផ្ញើប្រាក់កាសឲ្យគាត់ទិញកាសែត និងឲ្យថ្លៃផ្ញើទំព័រកាសែតបារាំង តាមប្រអប់សំបុត្រ

ជារៀងរាល់ខែដែរ ហើយយូរៗម្ដង ប៉ែន នុត បានផ្ញើប្រាក់ ៥ពាន់ ឬ១ម៉ឺនហ្វ្រង់ សម្រាប់ឲ្យគាត់ចំណាយផ្ទាល់ខ្លួនផងដែរ។

នៅក្នុងឆ្នាំ១៩៥៣ គាត់បានដកខ្លួនចេញពីសមាគមនិស្សិតខ្មែរនៅប្រទេសបារាំង ដោយគាត់យល់ឃើញថា សមាគមនេះបានធ្វើសកម្មភាពបំបែកបំបាក់ពួកនិស្សិតខ្មែរនៅប្រទេសបារាំង កាន់តែខ្លាំងឡើងៗ។

នៅក្នុងឆ្នាំ១៩៥៤ ប៉ែន នុត បានឲ្យគាត់ធ្វើការតាមដានកាសែតណាដែលចុះផ្សាយពីព័ត៌មានសំខាន់ៗនៃកិច្ចប្រជុំនៅសន្និសីទក្រុងហ្សឺណែវ រួចកាត់ទំព័រនោះផ្ញើទៅឲ្យប៉ែន នុត នៅក្រុងភ្នំពេញ។

នៅឆ្នាំ១៩៥៤នោះដែរ មានការរៀបចំសន្និសីទមួយស្តីពីបញ្ហាសេដ្ឋកិច្ចនៅក្រុងប៉ារីស ដោយមានតំណាង៤ប្រទេស បានចូលរួម គឺ កម្ពុជា, វៀតណាមខាងត្បូង,ឡាវ និងបារាំងជាម្ចាស់ផ្ទះ។ ពេលនោះនាយករដ្ឋមន្ត្រី ប៉ែន នុត បានតែងតាំងគាត់ឲ្យធ្វើជាអ្នកទាក់ទងអ្នកកាសែតបារាំង។

គួររម្លឹកដែរថា នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៥៤ ព្រះមហាក្សត្រសីហនុ បានតែងតាំង ចាន់ ណាក ជាអតីតនាយករដ្ឋមន្ត្រី ដឹកនាំគណៈប្រតិភូមួយក្រុម ក្នុងនោះមាន សម សារី និងសឺន សាន ផងដែរ ទៅចូលរួមក្នុងសន្និសីទចតុភាគី បារាំង កម្ពុជា វៀតណាមខាងត្បូង ឡាវ នៅទីក្រុងប៉ារីស ដើម្បីដោះស្រាយបញ្ហារូបិយវត្ថុ នៅឥណ្ឌូចិន ក្រោយពីប្រទេសបារាំងប្រគល់ឯករាជ្យឱ្យមកវិញ ។

ពេលនោះ សម សារី មានតួនាទីជាលេខាធិការរបស់គណៈប្រតិភូកម្ពុជា បានប្រើពាក្យសម្ដីមិនគួរគប្បី ទៅលើគណៈប្រតិភូប្រទេសផ្សេងៗទៀត ធ្វើឱ្យសន្និសីទនោះត្រូវផ្អាកទៅវិញ។

នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៥៤ ព្រះមហាក្សត្រសីហនុ ក៏បានយាងទៅបំពេញព្រះរាជទស្សនកិច្ច នៅក្រុងប៉ារីសដែរ។ ក្រោយពីបានដឹងរឿងនេះ ព្រះអង្គបានត្រាស់បង្គាប់ឱ្យ ចាន់ ណាក ជាប្រធានគណៈប្រតិភូ រកវិធីយ៉ាងណា ដើម្បីឱ្យសន្និសីទចតុភាគី ស្តីពីបញ្ហារូបិយវត្ថុនៅឥណ្ឌូចិន ដែលជាប់គាំងដោយសារសម សារី ប្រើពាក្យសម្ដីមិនគួរគប្បីទៅលើគណៈប្រតិភូ

ប្រទេសផ្សេងទៀត ជាច្រើនខែមកហើយនោះ បានបើកដំណើរការប្រជុំឡើងវិញ ឱ្យបានឆាប់រហ័សបំផុត។

១៦ថ្ងៃក្រោយមក គឺនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៥៤ សន្និសីទចតុភាគី ស្ដីពីបញ្ហារូបិយវត្ថុនៅឥណ្ឌូចិន នៅក្រុងប៉ារីស នោះ បានចាប់ផ្ដើមដំណើរការឡើងវិញ។ ពេលនោះដែរ នាយករដ្ឋមន្ត្រី ប៉ែន នុត បានផ្ញើសារទូរលេខមួយច្បាប់ ពីទីក្រុងភ្នំពេញ ទៅប្រាប់សឺន សាន ជាសមាជិកគណៈប្រតិភូ កំពុងស្ថិតនៅក្នុងក្រុងប៉ារីស នោះ ឱ្យបានដឹងថា ព្រះមហាក្សត្រសីហនុ សព្វព្រះទ័យតែងតាំងគាត់(សឺន សាន) ជាអគ្គទេសាភិបាលធនាគារជាតិកម្ពុជា ដែលត្រូវបង្កើតឡើងនៅពេលខាងមុខនេះហើយ។

មុននេះ សម សារី មានតួនាទីជាលេខាធិការគណៈប្រតិភូខ្មែរ ទៅចូលរួមសន្និសីទនៅក្រុងប៉ារីសនោះ សង្ឃឹមថា គាត់នឹងត្រូវទទួលការតែងតាំងជាអគ្គទេសាភិបាលធនាគារជាតិកម្ពុជា នោះ។ ប៉ុន្តែ ព្រះមហាក្សត្រសីហនុ បែរជាផ្លាស់ប្តូរព្រះទ័យ តែងតាំង សឺន សាន ទៅវិញ។

ហួត សម្បត្តិ បន្តទៀតថា នៅចុងខែមីនា ឆ្នាំ១៩៥៥ គាត់វិលត្រលប់មកមាតុប្រទេសវិញ ហើយបានចូលបម្រើការងារជាមន្ត្រីនៅក្រសួងការបរទេស ដែលពេលនោះចក្រពត្តិអាមេរិកកំពុងធ្វើសកម្មភាពអូសទាញប្រទេសកម្ពុជា ឲ្យចូលជាសមាជិកអង្គការកតិកាសញ្ញាអាស៊ីអាគ្នេយ៍ ហៅកាត់ថាអង្គការសេអាតូ(SEATO) ជាអង្គការយោធា និងសន្តិសុខមួយនៅអាស៊ីអាគ្នេយ៍ ដែលអាមេរិក បង្កើតឡើងដើម្បីទប់ទល់នឹងឥទ្ធិពលរបស់កុម្មុយនិស្តចិន។ តែអង្គការនេះ ត្រូវបានរលាយទៅវិញនៅចុងទសវត្សរ៍ឆ្នាំ១៩៦០ ហើយបានបង្កើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថាអាស៊ាន(ASEAN)ជំនួសវិញ។

ក្នុងអំឡុងចុងឆ្នាំ១៩៥៥ សម្ដេចសីហនុ បានតែងតាំងគាត់ជារដ្ឋលេខាធិការក្រសួងការបរទេស។ ពេលនោះ ទីប្រឹក្សាស្ថានទូតអាមេរិក ប្រចាំក្រុងភ្នំពេញ ឈ្មោះម៉ាទីន ហេត្ឧស្សាហ៍មកទាក់ទងសួរនាំគាត់អំពីសភាពការណ៍នយោបាយនៅក្នុងប្រទេសកម្ពុជា ដែរ ប៉ុន្តែក្រោយពីចាកចេញពីប្រទេសកម្ពុជា ទៅសហរដ្ឋអាមេរិកវិញ ទីប្រឹក្សាស្ថានទូតអាមេរិករូបនេះ

បានសរសេរសៀវភៅមួយរិះគន់វាយប្រហារសម្តេចសីហនុ យ៉ាងធ្ងន់ធ្ងរ ធ្វើឲ្យព្រះអង្គពិរោធយ៉ាងខ្លាំង។

អំឡុងឆ្នាំ១៩៥៥-១៩៥៦ សភាពការណ៍នៅក្រុងភ្នំពេញ មានការច្របូកច្របល់ខ្លាំង ដោយសារស្ថានទូតបរទេសមួយចំនួន នៅទីក្រុងភ្នំពេញ នាំគ្នាបង្កើតភ្នាក់ងារសម្ងាត់ប្រចាំស្ថានទូតតែរៀងៗខ្លួន កាន់តែមានច្រើនឡើងៗ ពិសេសនៅស្ថានទូតអាមេរិក និងស្ថានទូតបារាំង។ តែទោះបីយ៉ាងណា គាត់មិនបានធ្វើជាភ្នាក់ងារសម្ងាត់ឲ្យស្ថានទូតបរទេស ណាមួយឡើយ។

នៅក្នុងឆ្នាំ១៩៥៦ គាត់មានការបែកបាក់សាមគ្គីគ្នាជាមួយសម សារី និងម៉ៅ សាយ ព្រោះគាត់ចាត់ទុកសម សារី និងម៉ៅ សាយ ជាជនពុករលួយ។ ប្រហែល៣ឆ្នាំក្រោយមក សម សារី ត្រូវបានសម្តេចសីហនុ បញ្ជូនឲ្យទៅធ្វើទូតនៅប្រទេសអង់គ្លេស។ ចំណែកម៉ៅ សាយ និងគាត់បានរួមគ្នាជាមួយមន្ត្រីជាន់ខ្ពស់ផ្សេងទៀត ទម្លាក់ហ៊ូ យន់ ចេញពីតំណែងរដ្ឋមន្ត្រីក្រសួងផែនការ។

ចាប់ពីឆ្នាំ១៩៥៧ ដល់ឆ្នាំ១៩៦២ គាត់ឈប់ធ្វើការនៅក្នុងជួររាជរដ្ឋាភិបាលទៅធ្វើតំណាងរាស្ត្រប្រចាំមណ្ឌលស្វាយរៀង វិញ។ ពីឆ្នាំ១៩៦២ ដល់ឆ្នាំ១៩៦៤ ពេលប្រទេសកម្ពុជា កំពុងមានជម្លោះជាមួយសហរដ្ឋអាមេរិក កាន់តែខ្លាំងឡើងៗ គាត់ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងការបរទេសម្តងទៀត។

ពេលនោះ រាជរដ្ឋាភិបាលកម្ពុជា បានប្តឹងសហរដ្ឋអាមេរិក និងរបបក្រុងព្រៃនគរ ទៅអង្គការសហប្រជាជាតិ ហើយគាត់ត្រូវបានបញ្ជូនទៅឲ្យធ្វើជាតំណាងរាជរដ្ឋាភិបាលកម្ពុជាប្រចាំអង្គការសហប្រជាជាតិ ដើម្បីប្តឹងសហរដ្ឋអាមេរិក និងស្នើសុំឲ្យក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ថ្កោលទោសសហរដ្ឋអាមេរិក។

អំឡុងពេលធ្វើជាតំណាងរាជរដ្ឋាភិបាលកម្ពុជា ប្រចាំអង្គការសហប្រជាជាតិនោះ គាត់បានទាក់ទងជាមួយលេខាធិការបក្សកុម្មុយនិស្តឥណ្ឌូណេស៊ី ឈ្មោះអាជិត ដើម្បីទាក់ទាញការគាំទ្រផងដែរ។ ក្នុងឆ្នាំ ១៩៦៣ គាត់បានទៅជួបផ្ទាល់ជាមួយហូ ជីមិញ និងផាំ វ៉ាន់ដុង

នៅទីក្រុងហាណូយ។ លុះដល់ឆ្នាំ១៩៦៥ គាត់ត្រូវបានតែងតាំងជាឯកអគ្គរាជទូតប្រទេសកម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិ ហើយនៅក្នុងឆ្នាំ១៩៦៥នោះដែរ ប្រទេសកម្ពុជាបានផ្តាច់ចំណងទំនាក់ទំនងការទូតទាំងស្រុងជាមួយសហរដ្ឋអាមេរិក។ ប៉ុន្តែមុននឹងផ្តាច់ចំណងទាក់ទងការទូតនេះ តំណាងរាស្ត្រអាមេរិកកាំងម្នាក់ ឈ្មោះម៉ីក មេនហ្វេល បានមកជួបគាត់ក្នុងគោលបំណង ដើម្បីដោះស្រាយបញ្ហានេះដែរ តែគាត់មិនព្រមដោះស្រាយជាមួយ។

ក្រោយពីផ្តាច់ចំណងការទូតជាមួយសហរដ្ឋអាមេរិកមក គាត់បានទទួលបញ្ជាពីក្រសួងការបរទេសនៅទីក្រុងភ្នំពេញ ឱ្យគាត់បញ្ចុះបញ្ចូល និងបំផុសមហាជនអាមេរិក ជួយគាំទ្រប្រទេសកម្ពុជា និងប្រឆាំងនឹងការរំលោភឈ្លានពានរបស់កងទ័ពអាមេរិក មកលើប្រទេសកម្ពុជា ផងដែរ។

ហួត សម្បត្តិ បញ្ជាក់ថា លុះដល់ឆ្នាំ១៩៦៩ សម្តេចសីហនុ ក៏បានចាប់ផ្តើមស្តារទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក សាជាថ្មីឡើងវិញ។ បញ្ហានេះ ជាបញ្ហាមួយធ្វើឲ្យគាត់ដែលជាតំណាងប្រទេសកម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិ មានការលំបាកធ្វើការជាខ្លាំង ព្រោះពីមុនធ្លាប់តែស្អប់ខ្ពើម និងរិះគន់បកអាក្រាតអាមេរិក ដល់ពេលនោះត្រូវនិយាយល្អពីរដ្ឋាភិបាលអាមេរិក វិញ។

# ២៣៧
# ហេង ពេជ្រ ហៅ ឆន និស្សិតមកពីសហភាពសូវៀត ប៉ូលិសឃាត់ខ្លួននៅពោធិ៍ចិនតុង



**អាកាសយានដ្ឋានពោធិ៍ចិនតុង កសាងពីឆ្នាំ១៩៥៧**

ហេង ពេជ្រ ហៅ ឆន កើតនៅឆ្នាំ១៩៤៣ មានស្រុកកំណើតនៅភូមិសំរោង ឃុំធ្លក ស្រុកទ្រាំង ខេត្តតាកែវ។ ពីឆ្នាំ១៩៥២ ដល់ឆ្នាំ១៩៥៤ គាត់រៀននៅវត្តក្នុងភូមិកំណើត។ ពីឆ្នាំ១៩៥៥ ដល់១៩៥៩ គាត់បានទៅរៀនសាលាបឋមសិក្សាបំពេញវិជ្ជាព្រៃសណ្តែក នៅទីរួមស្រុកទ្រាំង។

ឆ្នាំ១៩៥៩ គាត់ប្រលងជាប់សញ្ញាបត្របឋមសិក្សា រួចក៏បន្តការសិក្សានៅវិទ្យាល័យព្រះឧទ័យ រហូតដល់១៩៦៤ ប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិភាគ១ (បាក់អង)។ ឆ្នាំ១៩៦៥ គាត់បានបន្តការសិក្សានៅថ្នាក់ទីបញ្ចប់ផ្នែកគណិតវិទ្យា នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្រុងភ្នំពេញ និងបានប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិភាគ២ (បាក់ឌុប) ផ្នែក

គណិតវិទ្យា។ នៅក្នុងខែតុលា ឆ្នាំ១៩៦៥ ក្រសួងអប់រំ បានជ្រើសរើសគាត់ឲ្យទៅបន្តការសិក្សាផ្នែកសំណង់ នៅសហភាពសូវៀត។

បើតាមឯកសារដែលបានបន្សល់ទុកនៅគុកទួលស្លែង(មន្ទីរ.២១) ហេង ពេជ្រហៅ ធន បានសរសេររៀបរាប់ថា ក្រោយពេលទៅដល់សហភាពសូវៀត មិនទាន់បានមួយខែផង ហាក់ សៀងឡាយនី ជានិស្សិតនៅទីនោះយូរឆ្នាំមកហើយ បានណែនាំគាត់ឲ្យចូលជាសមាជិកសហភាពខេមរៈនិស្សិត ដែលជាអង្គការនិស្សិតមាននិន្នាការទៅរកពួកកុម្មុយនិស្ត។ សហភាពនិស្សិតនេះ បានបង្កើតឡើងនៅក្នុងឆ្នាំ១៩៦២ ដោយមានការទទួលស្គាល់ពីរាជរដ្ឋាភិបាលនៅភ្នំពេញ ផងដែរ។

នៅក្នុងឆ្នាំ១៩៦៦ ដោយសារនិស្សិតមាននិន្នាការទៅរកពួកកុម្មុយនិស្តភាគច្រើនជាអ្នកដឹកនាំសហភាពខេមរៈនិស្សិតនេះ ទើបរាជរដ្ឋាភិបាលនៅភ្នំពេញ បញ្ជាឲ្យហ៊ុយ កន្ធុល ជាឯកអគ្គរាជទូតខ្មែរប្រចាំក្រុងមូស្គូ បង្កើតសមាគមនិស្សិតថ្មីមួយទៀត មានឈ្មោះថា សមាគមទូទៅនៃនិស្សិត និងអាណិកជនខ្មែរនៅសហភាពសូវៀត ជំនួសវិញ ហើយចោទប្រកាន់ថា សហភាពខេមរៈនិស្សិតនេះ សុទ្ធតែជាពួកខ្មែរក្រហម។

មុនដំបូង គាត់ត្រូវរៀនភាសារុស្ស៊ី នៅក្រុងមូស្គូរយៈពេលជិត១ឆ្នាំ ទើបចេះអាន និងសរសេរអក្សររុស្ស៊ី។ នៅក្នុងខែកក្កដា ឆ្នាំ១៩៦៦ ដោយមានការណែនាំពីហាក់ សៀងឡាយនី គាត់ក៏សម្រេចចិត្តចូលរៀនមហាវិទ្យាល័យសំណង់ថ្នាក់ឆ្នាំទី១ គឺស្របនឹងបំណងរបស់គាត់ដែលប្រាថ្នាដល់ពេលរៀនចប់ ចង់ទៅធ្វើជាសាស្ត្រាចារ្យនៅវិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់មិត្តភាពខ្មែរ-សូវៀត(សាលាតិចណូ)នៅទីក្រុងភ្នំពេញ។

ពេលនោះដែរ ហាក់ សៀងឡាយនី បានឱ្យគាត់រៀនទ្រឹស្តីម៉ាក្ស ឡេនីន និងឯកសារបដិវត្តន៍សូវៀត ព្រមទាំងឲ្យធ្វើសកម្មភាពផ្សេងៗ ដើម្បីប្រឆាំងនឹងរាជរដ្ឋាភិបាលភ្នំពេញទៀតផង។ នៅក្នុងមហាវិទ្យាល័យ គាត់ស្នាក់នៅក្នុងបន្ទប់មួយជាមួយនិស្សិតរុស្ស៊ី ២នាក់ ដែលមានអាយុពី២៥ ទៅ៣០ឆ្នាំ។ និស្សិតរុស្ស៊ី ២នាក់នេះ តែងតែជួយបង្រៀនភាសារុស្ស៊ី និងទ្រឹស្តីកុម្មុយនិស្ត ដល់គាត់បន្ថែមទៀត រហូតធ្វើឲ្យគាត់ជឿជាក់ថា អ្នកធ្វើបដិវត្តន៍ទាំងអស់

នៅលើសកលលោក ត្រូវតែពឹងផ្អែកលើសហភាពសូវៀត ហើយគាត់ជឿជាក់ថា មានតែសហភាពសូវៀតទេ ដែលអាចទ្រទ្រង់បដិវត្តន៍សកលលោកបាន។

បន្ទាប់មក គាត់កាន់តែជឿជាក់លើលទ្ធិម៉ាក្ស ឡេនីន រហូតហ៊ានលះបង់អ្វីៗទាំងអស់ដើម្បីបដិវត្តន៍ និងលទ្ធិកុម្មុយនិស្តអន្តរជាតិ។ ជាញឹកញាប់ ហាក់ សៀងឡាយនី ចេះតែមកសួរគាត់ថា ម៉េចល្មមចូលអង្គការបដិវត្តន៍អន្តរជាតិ បានហើយឬនៅ? ទីបំផុតគាត់ក៏យល់ព្រម។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៦៦ ហាក់ សៀងឡាយនី បាននាំគាត់ចូលទៅជួបគ្រូបង្រៀនភាសារុស្ស៊ី របស់គេឈ្មោះធីនណាអាឡិចហ្សង់ ដ្រូណា ហើយគ្រូម្នាក់នេះក៏បាននាំគាត់ឱ្យទៅជួបឈ្មោះគីសជៀស កូវស្គី ជាប្រធានការិយាល័យទំនាក់ទំនងការងារជាមួយនិស្សិតបរទេសនៅក្នុងការិយាល័យនោះតែម្តង។

ការិយាល័យទំនាក់ទំនងការងារជាមួយនិស្សិតបរទេសនេះ បង្កើតឡើងសម្រាប់ជួយនិស្សិតបរទេសទាំងផ្នែកបច្ចេកទេស និងផ្នែកនយោបាយ ព្រមទាំងជួយសម្រួលដល់ជីវភាពនិស្សិតបរទេស ផងដែរ។ ពេលនោះឈ្មោះគីសជៀស កូវស្គី បានទទួលស្គាល់គាត់ថានិស្សិតកុម្មុយនិស្ត ចាប់ពីពេលនោះមក។ មុនពេលលាគ្នា ប្រធានការិយាល័យទំនាក់ទំនងការងារជាមួយនិស្សិតបរទេសរូបនេះ បានចាប់ដៃគាត់យ៉ាងណែន និងបានជូនពរគាត់ឲ្យទទួលជ័យជម្នះគ្រប់ភារកិច្ច ព្រមទាំងផ្តាំផ្ញើថា បើមានបញ្ហាអី សូមឲ្យគាត់ទាក់ទង និងរាយការណ៍ទៅហាក់ សៀងឡាយនី។

នៅដើមឆ្នាំ១៩៦៧ ហាក់ សៀងឡាយនី បានណែនាំអប់រំគាត់ឲ្យយល់ដឹងពីបញ្ហារបស់ប្រទេសសង្គមនិយម និងប្រទេសកំពុងរីកចម្រើននានា ដែលត្រូវពឹងផ្អែកសហភាពសូវៀតមានកាន់តែច្រើនឡើងៗ ហើយបើប្រទេសទាំងអស់នោះចង់ធ្វើអ្វីមួយ ត្រូវសួរមតិសហភាពសូវៀត ជាមុនសិន បើសហភាពសូវៀត យល់ព្រម ទើបអាចធ្វើបាន។

ហាក់ សៀងឡាយនី បានណែនាំគាត់ពីវិធីគ្រប់គ្រងវិទ្យាស្ថានបច្ចេកទេសថា៖ ទី១. ត្រូវលើកកម្ពស់អត្ថិភាពសហភាពសូវៀត តាមការយល់ដឹង និងអនុវត្តបច្ចេកវិទ្យា តាមរបៀបសហភាពសូវៀត ធ្វើយ៉ាងណា ឱ្យគេមើលឃើញថា មានតែបច្ចេកទេសរបស់សូវៀតទេ ដែល

មានកម្រិតខ្ពស់ និងស៊ីជម្រៅជាងគេ និងជាមហាអំណាចខាងបច្ចេកទេសលើសគេនៅលើសាកលលោក។ ទី២.ត្រូវយកបច្ចេកទេសរបស់សហភាពសូវៀត ទៅអនុវត្តតាមរោងចក្រសហគ្រាស និងការដ្ឋានសំណង់ផ្សេងៗដើម្បីឲ្យសហភាពសូវៀត កាន់តែមានឥទ្ធិពលខ្លាំង និងយូរអង្វែងទៅមុខទៀត។

ហេង ពេជ្រ ហៅ ធន បានរម្លឹកថា នៅចុងឆ្នាំ១៩៦៨ ហាក់ សៀងឡាយនី បានឲ្យគាត់លាឈប់ពីសមាជិកសហភាពខេមរៈនិស្សិត ដើម្បីរៀបចំខ្លួនវិលត្រលប់មកមាតុប្រទេសវិញ ព្រោះបើគាត់នៅជាសមាជិកសហភាពខេមរៈនិស្សិត ដែលរាជរដ្ឋាភិបាលនៅភ្នំពេញចាត់ទុកថា ជាពួកកុម្មុយនិស្តខ្មែរក្រហមនោះ គឺគាត់មិនអាចចូលប្រទេស វិញ បានទេ។

ពេលនោះ គាត់ក៏ដាក់ពាក្យលាឈប់ពីសហភាពខេមរៈនិស្សិត តាមការណែនាំរបស់ហាក់ សៀងឡាយនី ហើយហាក់ សៀងឡាយនី បានឲ្យគាត់ទៅធ្វើការសម្របសម្រួលជាមួយមន្ត្រីទូតខ្មែរនៅទីនោះថា គាត់មិនមានអ្វីពាក់ព័ន្ធជាមួយសហភាពខេមរៈនិស្សិតទៀតទេ។

មន្ត្រីទូតខ្មែរ ក៏រាប់រកស្វាគមន៍គាត់ដោយរាក់ទាក់ ព្រោះពួកគេក៏សប្បាយរីករាយណាស់ដែរ នៅពេលអូសទាញនិស្សិតជាពួកកុម្មុយនិស្តឲ្យចុះចូលជាមួយរាជរដ្ឋាភិបាលវិញ។

នៅដើមឆ្នាំ១៩៦៩ គណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជាមួយក្រុម ដឹកនាំដោយឡុង បូរ៉េត បានទៅបំពេញទស្សនកិច្ចនៅសហភាពសូវៀត។ ពេលនោះ ក៏មានកម្មវិធីបញ្ចាំងខ្សែភាពយន្តមួយនៅក្រុងមូស្គូ គាត់ក៏ប្រាប់ហាក់ សៀងឡាយនី ថា កាលនៅតូច គាត់នៅវត្តជាមួយគ្រូសូត្រព្រះនាមហ៊ូ ត្រូវជាបងប្អូនឡុង បូរ៉េត នេះដែរ។

ប៉ុន្មានថ្ងៃក្រោយមក ស្ថានទូតខ្មែរនៅក្រុងមូស្គូ ក៏បានអញ្ជើញគណៈប្រតិភូ ដឹកនាំដោយឡុង បូរ៉េត និងនិស្សិតដែលមាននិន្នាការគាំទ្ររាជរដ្ឋាភិបាលភ្នំពេញទាំងអស់ ឲ្យចូលរួមក្នុងពិធីជប់លៀងមួយ។ ពេលនោះ ជា សាន ឯកអគ្គរាជទូតខ្មែរ ក៏បានឧទ្ទេសនាមពីសភាពការណ៍និស្សិតខ្មែរនៅសហភាពសូវៀតប្រាប់ឡុង បូរ៉េត ថា សព្វថ្ងៃនេះ មាននិស្សិតខ្មែរក្រហម បានចុះចូលជាមួយខ្លួនខ្លះៗហើយ ដូចជារូបគាត់ជាដើម...។

ពេលនោះដែរ គាត់ក៏ឆ្លៀតឱកាសជួបសំណេះសំណាលជាមួយឡុង បូរ៉េត ថា៖ ខ្ញុំ

ធ្លាប់ឃើញលោក កាលនៅវត្តព្រៃមៀន ជាមួយព្រះតេជគុណហ៊ូ ដែលត្រូវជាបងប្អូនរបស់លោក។ ឡុង បូរ៉េត ក៏តបវិញថា ល្អហើយ ដែលប្អូនបានត្រលប់មកខាងរាជរដ្ឋាភិបាលវិញ។

នៅក្នុងខែមិថុនា ឆ្នាំ១៩៦៩ ឯកអគ្គរាជទូតខ្មែរ ជា សាន បានហៅគាត់ឲ្យចូលជាសមាជិកចលនាសង្គមរាស្ត្រនិយម និងចូលជាសមាជិកសមាគមទូទៅនៃនិស្សិត និងអាណិកជនខ្មែរ នៅសហភាពសូវៀត ដើម្បីរាយការណ៍ទៅរាជរដ្ឋាភិបាលនៅភ្នំពេញ ថា គាត់មិនជាប់ពាក់ព័ន្ធជាមួយពួកនិស្សិតខ្មែរក្រហមទៀតទេ។

លុះមកដល់ខែកក្កដា ហាក់ សៀងឡាយនី បានចាត់តាំងគាត់ឲ្យចូលទៅក្នុងប្រទេស ដើម្បីស្តាប់សភាពការណ៍នៅវិទ្យាស្ថានបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត ដោយបានណែនាំឲ្យគាត់ទាក់ទងជាមួយសាស្ត្រាចារ្យសូវៀតម្នាក់នៅវិទ្យាស្ថាននោះ ឈ្មោះ គូឌីស៊ីន ដែលធ្លាប់បង្រៀនគាត់នៅមហាវិទ្យាល័យសំណង់នៅក្រុងមូស្គូ ពីមុនមកដែរ។

ក្រោយពីទទួលការចាត់តាំងរបស់ហាក់ សៀងឡាយនី គាត់ក៏បានទាក់ទងជាមួយឯកអគ្គរាជទូត ជា សាន ឲ្យជួយផ្តល់ទិដ្ឋាការឲ្យគាត់ ដោយកុហកថា ត្រូវទៅមើលឪពុកឈឺធ្ងន់នៅក្នុងប្រទេស។ ពេលនោះ ជា សាន ក៏បានផ្តល់ទិដ្ឋាការឲ្យគាត់ ហើយថែមទាំងប្រគល់លិខិតធានាតូចមួយឲ្យគាត់កាន់មកជាមួយទៀតផង។ តែគាត់មិនសូវទុកចិត្តនឹងលិខិតធានានោះ ក៏សូមខ្ចីលុយជា សាន ចំនួន១០០ដុល្លារ ដើម្បីឲ្យកក់ក្តៅបន្តិច។

លុះដល់ពាក់កណ្តាលខែកក្កដា ឆ្នាំ១៩៦៩ គាត់ក៏បានឡើងយន្តហោះពីក្រុងមូស្គូមកកាន់ទីក្រុងភ្នំពេញ។ តែមុនពេលចេញដំណើរ ហាក់ សៀងឡាយនី បានប្រគល់កាំភ្លើងខ្លីមួយដើមឱ្យគាត់គ្រាន់ទុកការពារខ្លួន។ តែពេលមកដល់អាកាសយានដ្ឋានពោធិ៍ចិនតុង កម្លាំងសមត្ថកិច្ចឆែកឃើញកាំភ្លើងខ្លីនោះ ក៏ឃាត់ខ្លួនគាត់ និងដកកាំភ្លើងខ្លីនោះទុក រួចបញ្ជូនទៅស្នងការដ្ឋានប៉ូលិសពិសេស តែម្តង។

ពេលនោះយប់ជ្រៅទៅហើយ កម្លាំងសមត្ថកិច្ចក៏បានឱ្យបងប្រុសបង្កើតគាត់ម្នាក់ ឈ្មោះ ហេង សុច្ចរ៉ា ជាអ្នកបច្ចេកទេសនៅក្រុមហ៊ុនអាកាសចរណ៍ស៊ីវិល នៅអាកាសយានដ្ឋានពោធិ៍ចិនតុងនោះ ឲ្យមកធានាគាត់ឲ្យនៅក្រៅឃុំ ដោយឱ្យបងប្រុសគាត់យកគាត់ទៅសម្រាក

នៅផ្ទះមួយយប់សិន ។ លុះព្រឹកឡើង កម្លាំងសមត្ថកិច្ច បានឲ្យបងគាត់នាំគាត់ត្រលប់មក ស្នងការដ្ឋាននប៉ូលិសពិសេសវិញ ដើម្បីសាកសួរ។

សមត្ថកិច្ច បានចោទប្រកាន់ថា គាត់ជាពួកខ្មែរក្រហម ហើយបានសួរពីប្រវត្តិរូបគាត់ និងពីសភាពការណ៍និស្សិតនៅក្រុងមូស្គូ ដែលមាននិន្នាការទៅរកពួកកុម្មុយនិស្ត ផងដែរ។

គាត់បានសារភាពថា ពីមុនគាត់បានចូលរួមជាមួយពួកខ្មែរក្រហមពិតមែន តែឥឡូវ គាត់បានចុះចូលជាមួយស្ថានទូតខ្មែរនៅក្រុងមូស្គូហើយ។ សមត្ថកិច្ចថា ពួកគេមិនទាន់ឃើញ មានសេចក្តីរាយការណ៍របស់ស្ថានទូតស្តីពីការចុះចូលរបស់គាត់ទេ។ តែយ៉ាងណា ក៏ពួកគេ ក៏ឲ្យគាត់នៅក្រៅឃុំសិនដែរ។

ឆ្លៀតឱកាសក្នុងពេលនៅក្រៅឃុំនោះ គាត់បានបង្វេងដានកម្លាំងសមត្ថកិច្ច ដោយធ្វើ ដំណើរទៅសួរសុខទុក្ខឪពុកនៅស្រុកកំណើតឯខេត្តតាកែវ ២-៣ថ្ងៃ ទើបត្រលប់មក ក្រុងភ្នំពេញ ហើយបានទៅជួបស្ត្រាចារ្យសូវៀតឈ្មោះគូឌីស៊ីន នៅមន្ទីរស្រាវជ្រាវផ្នែកសំណង់ នៅវិទ្យាស្ថាន បច្ចេកទេសមិត្តភាពខ្មែរ-សូវៀត តាមបណ្តាំរបស់ហាក់ សៀងឡាយនី ។

ពេលនោះ សាស្ត្រាចារ្យគូឌីស៊ីន បានពន្យល់ណែនាំគាត់យ៉ាងយូរអំពីគ្រោះថ្នាក់របស់ សហភាពសូវៀត នៅពេលអនាគត ដែលសហភាពសូវៀត ចង់យកវិទ្យាស្ថានបច្ចេកទេស មិត្តភាពខ្មែរ-សូវៀតនេះ ធ្វើជាមជ្ឍមណ្ឌលដើម្បីបម្រើនយោបាយកុម្មុយនិស្តរបស់ខ្លួន។

ចំពោះបញ្ហាបច្ចេកទេសសំណង់វិញ សាស្ត្រាចារ្យគូឌីស៊ីន បានណែនាំគាត់ឲ្យព្យាយាម ស្រាវជ្រាវប្លង់អគាររោងចក្រ ព្រមទាំងបញ្ហារ៉ែ ដែលសហភាពសូវៀត មានផែនការរុករក និង បញ្ហាថាមពលប្រេងកាត ដែលសហភាពសូវៀត ចង់ជួយខ្វងយកផងដែរ។

លុះដល់ខែសីហា ឆ្នាំ១៩៦៩ ដើម្បីចាកចេញទៅសហភាពសូវៀតវិញ គាត់ក៏បាន បង្ហាញសំបុត្រធានារបស់ឯកអគ្គរាជទូតជា សាន ដែលសរសេរបញ្ជាក់ថា គាត់មកសួរសុខ ទុកឪពុកឈឺធ្ងន់នោះ។ តែកម្លាំងសមត្ថកិច្ចបានគំរាមកំហែងគាត់ថា បើនៅតែធ្វើខ្មែរក្រហម ទៀត ពេលត្រលប់មកប្រទេសវិញលើកក្រោយ ពួកគេនឹងសម្លាប់គាត់ចោល។

នៅពេលទៅដល់ក្រុងមូស្គូវិញ គាត់បានរាយការណ៍ប្រាប់ ហាក់ សៀងឡាយនី ពីអ្វីៗ

ដែលកើតមានឡើងពេលគាត់មកដល់មាតុប្រទេសនោះ។

ក្រោយព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ហេង ពេជ្រហៅ ឆន ត្រូវបានតែងតាំងជាអនុរដ្ឋលេខាធិការក្រសួងសម្ភារៈសឹក នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។

# ២៣៨
# ហៃ គឹមស៊ាង និស្សិតក្រហមនៅសូវៀត សុំចូលជាសមាជិកចលនាសង្គមរាស្ត្រនិយម

ហៃ គឹមស៊ាង កើតនៅឆ្នាំ១៩៤៥ នៅភូមិទន្លេបិទ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម(សព្វថ្ងៃជាខេត្តត្បូងឃ្មុំ)។ នៅដើមឆ្នាំ១៩៦៣ គាត់បានទទួលអាហារូបករណ៍ទៅសិក្សាផ្នែកគរុកោសល្យនៅសហភាពសូវៀត ជាមួយនិស្សិតខ្មែរ៥ រូបទៀត គឺតាន់ ផៃហេង, គ្រិន លាន, ទីវ យ៉ាវ, ចាន់ ប៊ិន និងតិចផៃ អៀមជូ។

នៅក្នុងខែតុលា ឆ្នាំ១៩៦៣ ពួកគាត់ទាំង៦នាក់បានចូលរៀនភាសារុស្ស៊ី នៅមហាវិទ្យាល័យនិស្សិតបរទេសនៃសាកលវិទ្យាល័យមូស្គូ។ ប៉ុន្តែដោយសារមាននិន្នាការនយោបាយផ្ទុយគ្នា ពួកគាត់ទាំង៦នាក់ត្រូវបាក់បែកចែកគ្នាជាពីរក្រុមផ្សេងគ្នា គឺក្រុមទី១ មានរូបគាត់, តាន់ ផៃហេង និងគ្រិន លាន។ ឯក្រុមទី២ មានទីវ យ៉ាវ, ចាន់ ប៊ិន និងតិចផៃ អៀមជូ។

ចុងឆ្នាំ១៩៦៣ គាត់បានចូលជាសមាជិកសហភាពខេមរៈនិស្សិត ដែលជាសមាគមនិស្សិតខ្មែរតែមួយគត់នៅសហភាពសូវៀត។ ប៉ុន្មានថ្ងៃក្រោយមក តាន់ ផៃហេង ក៏បានណែនាំគាត់ឲ្យស្គាល់និស្សិត ៣នាក់ ទៀតគឺ ហាក់ សៀងឡាយនី, អៀង សីហា និងប៉ែន ថោងអាន។

បន្ទាប់មកទៀត និស្សិតទាំង៣នាក់នោះ ក៏បានបញ្ចុះបញ្ចូលគាត់ឲ្យចូលក្នុងក្រុមនិស្សិតជឿនលឿន(និស្សិតក្រហម)ដែលនៅក្នុងសហភាពខេមរៈនិស្សិតនោះដែរ។ ពេលនោះក្រុមនិស្សិតជឿនលឿនមានគ្នា១៥នាក់ ដោយមាន ប៉ែន ថោងអាន ជាប្រធានក្រុម និងហាក់ សៀងឡាយនី ជាអនុប្រធាន។

និន្នាការពួកនេះ គឺសូវៀតនិយម។ ហាក់ សៀងឡាយនី ពូកែខាងទ្រឹស្តី។ ឯប៉ែន ថោងអាន ពូកែខាងចាត់តាំង។ នៅក្នុងឆ្នាំ១៩៦៤ គាត់បានចូលរៀននៅមហាវិទ្យាល័យថាមពល នៅក្រុងមូស្គូ និងប្រាស្រ័យទាក់ទងជិតស្និទ្ធជាមួយក្រុមនិស្សិតជឿនលឿន (និស្សិត

ក្រហម) នោះ។

ពេលនោះ តាំង ថោងអាន និងហាក់ សៀងឡាយនី ឲ្យពួកគាត់រៀនទ្រឹស្ដីម៉ាក្ស ឡេនីន និងធ្វើជាអ្នកដឹកនាំការពិភាក្សា ដោយបានលើកយកឧទាហរណ៍ច្រើនអំពីសហភាពសូវៀត។ ប៉ុន្តែដើម្បីឲ្យមានឯកភាពគ្នាក្នុងក្រុមនិស្សិតជឿនលឿននោះ ពួកគាត់បានចៀសវាងមិនលើកយកបញ្ហាទំនាស់រវាងចិន និងសហភាពសូវៀត មកធ្វើការពិភាក្សាក្នុងអង្គប្រជុំទេ។

ពួកគាត់ប្រជុំរៀនសូត្រទ្រឹស្ដីម៉ាក្ស ឡេនីន ២អាទិត្យ ឬមួយខែម្ដង ទៅតាមសភាពជាក់ស្ដែង។ តាមរយៈការពិភាក្សាទ្រឹស្ដីម៉ាក្ស ឡេនីន គាត់យល់ឃើញថា សហភាពសូវៀតជាមិត្តដ៏ធំមួយរបស់ប្រជាជាតិ ដែលកំពុងក្រោកឡើងតស៊ូប្រឆាំងនឹងចក្រពត្តិនិយម និងពួកអាណានិគមនិយមទាំងចាស់ទាំងថ្មី ហើយគាត់ស្រមើស្រមៃចង់ឲ្យប្រទេសកម្ពុជា ក្លាយទៅជាប្រទេសសង្គមនិយម សម្បូរសប្បាយ តែគ្មានអ្វីច្បាស់លាស់ឡើយ។

នៅក្នុងសហភាពខេមរៈនិស្សិត គាត់ត្រូវបានគេជ្រើសរើសឲ្យធ្វើជាអ្នកទទួលខុសត្រូវខាងសង្គមកិច្ច វប្បធម៌ និងកីឡា មានភារកិច្ចរៀបចំពិធីប្រគំតន្ត្រីក្នុងពិធីផ្សេងៗ ដូចជាពិធីបុណ្យឯករាជ្យជាតិ ថ្ងៃ៩ ខែវិច្ឆិកា និងបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ជាដើម។

ចាប់ពីឆ្នាំ១៩៦៤ ដល់ឆ្នាំ១៩៦៩ ពួកគាត់សិក្សាទ្រឹស្ដីម៉ាក្ស ឡេនីន ជាហូរហែ ដោយមុនដំបូងមានការផុលផុសណាស់។ ប៉ុន្តែបន្ទាប់មក ក៏មានការរយីករយាកទៅៗ ស្ទើរបោះបង់ចោល ព្រោះម្នាក់ៗ ជាប់រវល់ខិតខំរៀនសូត្រ ហើយសមាជិកក្រុមនៅសល់តិចទៅៗ។ តែក្រុមនេះមានវិន័យ និងការចាត់តាំងតាមលំនាំគណបក្សនយោបាយមួយដែរ។

លុះដល់ដើមឆ្នាំ១៩៧០ គាត់បានលាឈប់ពីសមាជិកសហភាពខេមរៈនិស្សិត ទៅចូលជាសមាជិកសមាគមទូទៅនិស្សិត និងអាណិកជនខ្មែរនៅសហភាពសូវៀត ដែលរាជរដ្ឋាភិបាលនៅក្រុងភ្នំពេញ ជាអ្នកបង្កើតវិញ ហើយគាត់ក៏បានសុំចូលជាសមាជិកចលនាសង្គមរាស្ត្រនិយមរបស់សម្ដេចសីហនុ ក្នុងគោលបំណងដើម្បីវិលត្រលប់មកមាតុប្រទេសវិញ បានការងារល្អធ្វើ។ ប៉ុន្តែមិនទាន់បានវិលត្រលប់មកមាតុប្រទេសវិញផង ក៏មានព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។

# ២៣៩
# ខ្មែរក្រហមបង្កការរអុកឡុកខាងក្នុង កងទ័ពវៀតកុង ចូលមកកាន់តែច្រើន



**កងទ័ពវៀតកុង ចូលវាយក្រុងព្រៃនគរ ខែកុម្ភៈ ឆ្នាំ១៩៦៨**

នៅក្នុងថ្ងៃបុណ្យចូលឆ្នាំចិន-វៀតណាម ខែកុម្ភៈ ឆ្នាំ១៩៦៨ កងទ័ពរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង (វៀតកុង) បានបើកយុទ្ធនាការវាយប្រហារទៅលើកងទ័ពអាមេរិក និងកងទ័ពរដ្ឋការវៀតណាមខាងត្បូងព្រមៗគ្នា ទៅទូទាំងប្រទេស ក្នុងគោលបំណងបំផុសទឹកចិត្តប្រជាជនវៀតណាម ឱ្យងើបឡើងបះបោរ ដើម្បីដណ្ដើមយកជោគជ័យ ផ្ដាច់ព្រ័ត្រទៅលើពួករដ្ឋការ ក្រុងព្រៃនគរ និងសហរដ្ឋអាមេរិក។ ប៉ុន្តែ យុទ្ធនាការផ្ដាច់ព្រ័ត្រនេះ មិនបានទទួលជោគជ័យដូចការរំពឹងទុកទេ ព្រោះត្រូវកងទ័ពអាមេរិក វាយបកបណ្ដាលឱ្យស្លាប់ និងរបួស យ៉ាងច្រើនសន្ធឹកសន្ធាប់ ហើយមេដឹកនាំវៀតណាមខាងជើង ក៏បានបញ្ជូនកងទ័ព

របស់ខ្លួន ចូលមកតាមទឹកដីកម្ពុជា កាន់តែច្រើនថែមទៀត ដើម្បីឱ្យជួយអន្តរាគមន៍។

សម្តេចសីហនុ ក៏មានការព្រួយបារម្ភខ្លាច ពួកវៀតកុង-វៀតណាមខាងជើង មានបំណងកាន់កាប់ត្រួតត្រាភូមិស្រុកមួយចំនួន ពិសេសគឺនៅក្នុងភូមិភាគបូព៌ា( ស្វាយរៀង ព្រៃវែង និងត្បូងឃ្មុំ) ដែលពួកគេកំពុងឈរជើងនៅទីនោះ ដែរ ។

នៅខេត្តរតនគិរី ជនជាតិព្រៅ នៅឡាបានសៀក បាននាំគ្នាងើបបះបោរប្រឆាំងនឹងរាជរដ្ឋាភិបាល តាំងពី២ឆ្នាំមុនមកម៉្លេះ ដោយសារតែចៅហ្វាយខេត្តឈ្មោះអ៊ុង ញ៉ាច បានប្រើកម្លាំងទាហានបណ្តេញជនជាតិនៅទីនោះ ឱ្យចាកចេញពីភូមិក ផ្ទះសម្បែង ដើម្បីយកដីធ្លីរបស់ពួកគាត់ធ្វើជាចម្ការកៅស៊ូ។ ពួកអ្នកភូមិបានលើកគ្នាទៅតវ៉ាដល់សាលាខេត្តដែរ តែត្រូវគេដេញឱ្យត្រលប់ទៅផ្ទះវិញ។ លុះពេលមកដល់ផ្ទះសម្បែង ក៏ឃើញពួកទាហានកំពុងដុតបំផ្លាញផ្ទះ និងប្រមូលយកទ្រព្យសម្បត្តិ ធ្វើឱ្យពួកគាត់ឈឺចាប់ កាន់តែខ្លាំងថែមទៀត។

ដោយសារកំហឹងឈឺចាប់នេះ ពួកគាត់ក៏បានប្រមូលគ្នីគ្នា ខ្លះកាន់ដាវ លំពែង ធ្នូ ស្នា និងបានដាក់ចម្រូងឫស្សី កប់នៅក្នុងដី វាយប្រហារតបត សងសឹកទៅលើពួកទាហានរាជរដ្ឋាភិបាលវិញ។

កាលផ្ទុះហេតុការណ៍ដំបូងនោះ រាជរដ្ឋាភិបាល ក៏បានធ្វើការសន្និដ្ឋានថា ការបះបោរនៅឡាបានសៀកនោះ មិនមែនដោយសារមនោគមវិជ្ជាកុម្មុយនិស្តទេ គឺគ្រាន់តែជាការតវ៉ាទាមទារឱ្យអាជ្ញាធរប្រគល់ផ្ទះសម្បែង និងដីធ្លីឱ្យពួកអ្នកស្រុកវិញតែប៉ុណ្ណោះ។

សម្តេចសីហនុ ក៏ឈ្វេងយល់ដែរថា ហេតុការណ៍នៅខេត្តរតនគិរី នោះ ពុំមែនជាសកម្មភាពធ្វើវិទ្ធង្សនាអ្វីទេ គឺមកពីនៅទីនោះមានប្រជារាស្ត្រតិច ហើយព្រះអង្គមានគម្រោងកសាងផ្លូវថ្នល់ទៅដល់ទីនោះ និងបញ្ជូនប្រជារាស្ត្រនៅខេត្តផ្សេងៗទៀត ដែលមានមនុស្សច្រើនកកកុញឱ្យទៅរស់នៅទីនោះ ដោយមានការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលផងដែរ ។

តែទោះបីយ៉ាងណាក៏ដោយ ចូលដល់ដើមឆ្នាំ១៩៦៨ ពួកខ្មែរក្រហមនៅខេត្តរតនគិរីនោះបានចំណេញនយោបាយយ៉ាងច្រើន ហើយពួកគេក៏បានឃោសនាបញ្ចុះបញ្ចូល និងបំផុសជនជាតិទាំងឡាយដែលនៅក្នុងខេត្តនោះ ឱ្យមានកំហឹងឈឺចាប់ជាមួយរាជរដ្ឋាភិបាល

កាន់តែខ្លាំងក្លាថែមទៀត និងអូសទាញឱ្យមកចូលរួមធ្វើបដិវត្តន៍ ជាមួយពួកគេយ៉ាងផុលផុស ទៀតផង។

ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៦៨ ពួកខ្មែរក្រហមបានបើកយុទ្ធនាការវាយប្រហារព្រមៗគ្នា ទៅលើបន្ទាយ និងប៉ុស្តិ៍ប៉ូលិសរបស់រាជរដ្ឋាភិបាល ព្រមទាំងដណ្តើមកាំភ្លើងបាន៥០ដើម។

សម្តេចសីហនុ បានថ្លែងថា ការវាយប្រហារទៅលើបន្ទាយទាហាន និងប៉ុស្តិ៍ប៉ូលិស តូចៗ នៅតំបន់ព្រៃភ្នំដាច់ស្រយាលឆ្ងាយៗ នៅក្នុងខេត្តបាត់ដំបង, តាកែវ, កំពត, កោះកុង, កំពង់ឆ្នាំង និងកំពង់ស្ពឺ នៅថ្ងៃទី២៥ កុម្ភៈនោះ ជាប្រតិបត្តិការមួយដែលមានកិច្ច- សហការ និងបញ្ជាដោយមេខ្មែរក្រហម ដែលជាបញ្ញវន្តមួយចំនួនតូច។

រយៈពេលប្រហែលកន្លះខែក្រោយមកទៀត នៅភូមិភាគពាយ័ព្យ និងភូមិភាគនិរតី ពួកខ្មែរក្រហម ក៏បានធ្វើសកម្មភាពវាយប្រហារដោយរបៀបវាយឈ្លប និងវាយឆ្មក់ ទៅលើ បន្ទាយទាហាន និងប៉ុស្តិ៍ប៉ូលិសតូចៗបន្តទៀត។ នៅខេត្តកោះកុង មេខ្មែរក្រហម ឈ្មោះ ប្រាស៊ីត បានដឹកនាំកម្លាំងវាយប្រហារដោយបានសម្លាប់ចៅហ្វាយស្រុក និងភូឈ្មួយស្រុក ចំនួន៧ នាក់។

នៅភូមិភាគនិរតី មេខ្មែរក្រហម ឈិត ជឿន ហៅម៉ុក ក៏បានដឹកនាំកម្លាំងធ្វើសង្គ្រាម ឈ្លបនោះដែរ។ ជាមួយគ្នានេះ នៅខេត្តបាត់ដំបង និងកំពង់ឆ្នាំង ក៏ល្បីថាមានប្រជារាស្ត្រ ជាច្រើនពាន់នាក់ បាននាំគ្នារត់ចូលព្រៃ តាមការឃោសនារបស់ពួកមេខ្មែរក្រហម។

នៅដើមខែមីនា ឆ្នាំ១៩៦៨ សម្តេចសីហនុ បានប្រកាសថា នេះជាការបង្កសង្គ្រាម ពេញទី។ ចំណែកនៅភូមិភាគបូព៌ាវិញ គេពុំឃើញមានសកម្មភាពតស៊ូដោយប្រើអាវុធវាយ ប្រហារទៅលើពួកទាហាន និងប៉ូលិសរបស់រាជរដ្ឋាភិបាលណាមួយគួរឱ្យកត់សម្គាល់ទេ ហើយ ក៏គ្មានព័ត៌មានថា បានដណ្តើមកាំភ្លើងពីពួកទាហាន ប៉ូលិស នៅទីនោះបានមួយដើម។ ពួក គេបានត្រៀមលក្ខណៈប្រយុទ្ធតែនៅតាមតំបន់ណាដែលមានព្រៃក្រាស់ប៉ុណ្ណោះ ។

ពេលនោះ ថ្នាក់ដឹកនាំមជ្ឈិម ក៏បានបញ្ជូនលិខិតណែនាំមួយទៅឱ្យសោ ភឹម លេខា គណៈកម្មាធិការបក្សភូមិភាគបូព៌ា ឱ្យបើកការវាយប្រហារទៅលើបន្ទាយទាហាន និងប៉ុស្តិ៍

ប៉ូលិសតូចៗ ដែលនៅតំបន់ដាច់ស្រយាល ដើម្បីដណ្តើមកាំភ្លើងឱ្យបាន ដូចនៅបណ្តាភូមិភាគផ្សេងៗទៀត។ ប៉ុន្តែ រហូតដល់ខែសីហា ទើបពួកខ្មែរក្រហមនៅភូមិភាគបូព៌ា បើកការវាយប្រហារទៅលើកងស្វ័យត្រាណការពារភូមិឃុំ១០នាក់ និងដណ្តើមកាំភ្លើងបានមួយចំនួនដែរ។

ដោយសារការវាយដណ្តើមយកអាវុធពីពួកទាហាន និងប៉ូលិស ពិសេសពួកកងស្វ័យ-ត្រាណពីសំណាក់ពួកខ្មែរក្រហមចេះតែកើតមានឡើងជាញឹកញាប់ សម្តេចសីហនុ ក៏បានបញ្ជាឱ្យដកអាវុធពីកងស្វ័យត្រាណ នៅតាមភូមិ ឃុំណាដែលមានពួកខ្មែរក្រហមធ្វើសកម្មភាព និងថា ការវាយប្រហាររបស់ពួកខ្មែរក្រហមនោះ មានជាប់ពាក់ព័ន្ធជាមួយពួកវៀតកុង-វៀតណាមខាងជើង ដែលបោះទីតាំងនៅក្បែរៗនោះ ហើយព្រះអង្គក៏បានដាក់កម្លាំងទាហានរៀបរយជំនួសកងស្វ័យត្រាណទាំងអស់នោះវិញ។

ពេលពួកឧទ្ទាមខ្មែរក្រហម បង្កើនការវាយប្រហារព្រមៗគ្នា ទៅតាមបណ្តាខេត្តមួយចំនួននៅក្នុងខែកុម្ភៈ នោះ សម្តេចសីហនុ ក៏បានប្តូរផ្លាស់ចៅហ្វាយខេត្តបាត់ដំបង ជាលើកទី៣ និងចៅហ្វាយខេត្តពោធិ៍សាត់ និងកំពត ជាលើកទី២ ដោយដាក់សុទ្ធតែជានាយទាហានជាន់ខ្ពស់មកជំនួសវិញ។

# ២៤០
# សម្តេចសីហនុ សម្លាប់ខ្មែរក្រហម មិនខ្លាចចុះនរកទេ



**សម្តេចសីហនុ យាងទៅសម្ពោធសមិទ្ធិនានានៅខេត្តរតនគិរី**

នៅក្នុងខែមករា ឆ្នាំ១៩៦៨ នោះដែរ បើទោះបីពួកខ្មែរក្រហម បានធ្វើសកម្មភាពវាយប្រហារទៅលើកងស្វ័យត្រាណ ដែលជាកម្លាំងការពារភូមិស្រុកដោយខ្លួនឯង និងទៅលើពួកទាហានប៉ូលិស ដែលឈរជើងនៅតាមបន្ទាយ និងប៉ុស្តិ៍តូចៗ ព្រមទាំងដណ្តើមកាំភ្លើងបានមួយចំនួនក៏ពិតមែន តែក៏ត្រូវពួកទាហាន និងប៉ូលិសរាជរដ្ឋាភិបាលបង្ក្រាបយ៉ាងសាហាវវិញដែរ ។

នៅខេត្តរតនគិរី កងរាជតម្រួតខេត្ត(ប៉ូលិសខេត្ត) បានរកឃើញទីតាំងមូលដ្ឋានខ្មែរ-ក្រហម ដែលលាក់នៅក្នុងព្រៃជាច្រើនកន្លែង ហើយសម្តេចសីហនុ ក៏បានសម្រេចព្រះទ័យយាងទៅខេត្តនោះ ដើម្បីឃោសនាកុំឱ្យប្រជារាស្ត្រ ជឿពាក្យឃោសនារបស់ពួកខ្មែរក្រហម និងលើកទឹកចិត្តដល់ពួកទាហាន ដែលកំពុងបើកប្រតិបត្តិការសឹកបោសសម្អាតពួកឧទ្ទាមខ្មែរក្រហមនៅទីនោះផងដែរ។

ព្រះអង្គបានចេញបញ្ជាឱ្យពួកទាហានទៅបង្ក្រាបពួកឧទ្ទាមខ្មែរក្រហមកុំត្រាប្រណីឱ្យសោះ ហើយព្រះអង្គប្រកាសថា ព្រះអង្គជាអ្នកជានាខុសត្រូវទាំងស្រុង ចំពោះការបង្ក្រាបនោះ និងទុកឱ្យតុលាការប្រជារាស្ត្រ ជាអ្នកវិនិច្ឆ័យទៅលើព្រះអង្គចុះ ។

ពេលនោះ ពួកទាហានក៏បានរុលចូលទៅដល់មាត់ច្រកចូលទៅមន្ទីររបស់មេដឹកនាំខ្មែរក្រហម និងប៊ិះចាប់សាឡុត ស បានទៅហើយ ប៉ុន្តែសំណាងល្អ សាឡុត ស បានគេចខ្លួនទាន់។

សម្តេចសីហនុ បានប្រកាសថា ពួកឧទ្ទាមខ្មែរក្រហមបានផ្តល់កាំភ្លើងកាប៉ីន ទៅឱ្យពួកខ្មែរលើ( ជនជាតិភាគតិច) និងបានបញ្ជាឱ្យពួកនេះ បាញ់មកលើកងទ័ពព្រះអង្គ។ តែព្រះអង្គ មិនបណ្តោយឱ្យពួកគេធ្វើដូច្នេះបានទេ ព្រះអង្គបានចេញបញ្ជាឱ្យគេកម្ទេច (សម្លាប់) ជនជាតិ ជាអ្នកស្រុកព្រៃភ្នំនោះ ចំនួន១៨០នាក់ និងចាប់មេដឹកនាំបះបោរចំនួន៣០នាក់ទៀត យកទៅបាញ់ចោលទាំងអស់ ហើយព្រះអង្គប្រកាសថា ការសម្លាប់នេះ ព្រះអង្គមិនខ្លាចចុះនរកទេ។ ព្រះអង្គនឹងដាក់សំណុំរឿងត្រឹមត្រូវឥតល្អៀងនេះ ថ្វាយទៅស្តេចយមរាជដោយផ្ទាល់ទៀតផង។

នៅខេត្តរតនគិរី នោះ ប៉ុស្តិ៍ទាហានតូចៗ ដែលដាក់ពង្រាយនៅដាច់ឆ្ងាយពីគ្នា ត្រូវបានប្រមូលផ្តុំគ្នាជាកម្លាំងធំ ដើម្បីកុំឱ្យពួកឧទ្ទាមវាយដណ្តើមអាវុធបានដោយងាយៗទៀត និងដើម្បីបើកប្រតិបត្តិការសឹកជាទ្រង់ទ្រាយធំបង្ក្រាបពួកឧទ្ទាម ដោយមានយន្តហោះ និងរថក្រោះ រថពាសដែក ចូលរួមផងដែរ ។

ពេលនោះ ចលនាតស៊ូរបស់ពួកឧទ្ទាមខ្មែរក្រហម ដែលមានជនជាតិព្រៅ ទំពួន ចារ៉ាយ

និងពួង ជាដើម ចូលរួមយ៉ាងសកម្មដែរនោះ ក៏បាននាំគ្នាកាប់ផ្តួលរម្លំដើមឈើធំៗ ដាក់ទទឹងផ្លូវ ដើម្បីរារាំងរថក្រោះ និងរថពាសដែក កុំឱ្យចូលទៅរកពួកគេបាន ។

ម្យ៉ាងទៀត ពួកទាហានដែលមិនធ្លាប់រស់នៅតំបន់ព្រៃភ្នំ ក៏ត្រូវជំងឺគ្រុនចាញ់រាតត្បាតធ្លាក់ខ្លួនឈឺជាច្រើននាក់ ។ ពួកឧទ្ទាមខ្មែរក្រហមក៏បាននាំគ្នាកាត់ផ្តាច់ផ្លូវ និងស្ពានជាច្រើនកន្លែង ។

សម្តេចសីហនុ ក៏បានចោទប្រកាន់ថា ពួកវៀតកុង-វៀតណាមខាងជើង និងពួកប៉ាថេតឡាវ(ពួកកុម្មុយនិស្តឡាវ) ជាអ្នកញុះញង់អុជអាលឱ្យពួកខ្មែរលើបះបោរបណ្តេញពួកទាហានព្រះអង្គឱ្យចេញពីខេត្តរតនគិរី នោះ ។

នៅក្នុងខែសីហា ឆ្នាំ១៩៦៨ សម្តេចសីហនុ បានប្រកាសថា ឧត្តមសេនីយ៍លន់ នល់ បានទូលព្រះអង្គថា កងទ័ពប៉ាថេតឡាវ (ពួកកុម្មុយនិស្តឡាវ)បានជ្រៀតចូលបន្តិចម្តងៗ មកក្នុងស្រុកសៀងប៉ាង ខេត្តស្ទឹងត្រែង។ ទាហានព្រះអង្គចាប់បានពួកប៉ាថេតឡាវជាង៤០នាក់ ហើយដំណោះស្រាយមានតែមួយ គឺបញ្ជូនពួកគេទៅឋាននរកទាំងអស់។ ប៉ុន្តែ មួយថ្ងៃក្រោយមក សម្តេចសីហនុ បានប្រកាសថា ការពិតពួកនោះ គឺជាពួកខ្មែរក្រហម ហើយពួកមេខ្មែរក្រហម៩ នាក់ទៀត ដែលបន្លំខ្លួនធ្វើជាពួកប៉ាថេតឡាវ ក៏ត្រូវសម្លាប់ចោលដែរ។

មេខ្មែរក្រហមប្រចាំខេត្តកំពង់ឆ្នាំង ឈ្មោះស៊ូ យឹម ត្រូវពួកទាហានរាជរដ្ឋាភិបាលបាញ់សម្លាប់នៅក្នុងខែមីនា ឆ្នាំ១៩៦៨ ហើយអនុប្រធានម្នាក់ឈ្មោះ អ៊ូ លុំ ដែលឡើងកាន់តំណែងបន្តពីគាត់ ក៏ត្រូវពួកទាហានសម្លាប់នៅក្នុងខែឧសភា ផងដែរ។

ពាក់ព័ន្ធករណីដែលសម្តេចសីហនុ ប្រកាសពីជោគជ័យរបស់ទាហានព្រះអង្គក្នុងការបង្ក្រាបសកម្មភាពរបស់ពួកឧទ្ទាមនៅក្នុងខេត្តរតនគិរី នោះ ក្រោយមក សាឡុត ស ជាមេដឹកនាំកំពូល ដែលរស់នៅក្នុងព្រៃ នៃខេត្តរតនគិរី នោះ បានអះអាងថា ពេលនោះ ចលនាតស៊ូរបស់គាត់មានតែអាវុធ៤–៥ដើម ដែលដណ្តើមបានពីកម្លាំងអាជ្ញាធរ គួបផ្សំនឹងអាវុធដែលមានពីមុនមកសម្រាប់ការពារមន្ទីរគណៈមជ្ឈិមបក្ស «មន្ទីរ១០៤» នោះ សរុបទាំងអស់មានប្រមាណ



**កងទ័ពប៉ាថេតលាវ** ( **ពួកកុម្មុយនិស្តលាវ** )

១០ដើមប៉ុណ្ណោះ សម្រាប់ធ្វើការទប់ទល់ជាមួយកម្លាំងអាជ្ញាធរវិញ។ ប៉ុន្តែ ដោយនៅទីនោះសុទ្ធតែជាភូមិសាស្ត្រមានព្រៃក្រាស់ កម្លាំងអាជ្ញាធរមិនមានលទ្ធភាពតាមរកចាប់ពួកគាត់បានឡើយ ។

នៅអំឡុងខែមីនា ឆ្នាំ១៩៦៨ មានរបាយការណ៍ថា ទាហានរាជរដ្ឋាភិបាល បានសម្លាប់កងទ័ពខ្មែរក្រហម១០៦នាក់ និង១០៨នាក់ទៀត ត្រូវចាប់ខ្លួនបាន។ ដោយឡែកនៅខេត្តបាត់ដំបង ប្រជារាស្ត្រជាអ្នកស្រុកប្រមាណ២០០០នាក់ ដែលបានរត់ទៅរស់នៅក្នុងព្រៃជាមួយពួកខ្មែរក្រហម បានសម្រេចចិត្តចេញមកសារភាព សុំមករស់នៅភូមិស្រុករបស់ពួកគេ ដូចមុនវិញ។

ជាមួយគ្នានោះ ឧត្តមសេនីយ៍ឯក លន់ នល់ ក៏បានស្នើសុំទៅសម្តេចសីហនុ ឱ្យទាហានជើងអាកាសធ្វើការទម្លាក់គ្រាប់បែកទៅលើជំរំពួកឧទ្ទាមខ្មែរក្រហមមួយចំនួន។

នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៦៨ ទាហានរាជរដ្ឋាភិបាល បានបើកប្រតិបត្តិការសឹក

បោសសម្អាតពួកឧទ្ទាមខ្មែរក្រហមនៅភ្នំវាយចាប ជាថ្មីម្តងទៀត ដោយប្រើកម្លាំងសរុបប្រមាណ ១០០០នាក់។ ពួកឧទ្ទាមខ្មែរក្រហម ចំនួន៨៩ នាក់ ត្រូវបាញ់សម្លាប់ និងចាប់ខ្លួនបាន ៣២ នាក់ រួមជាមួយអ្នកស្រុក ដែលរត់ទៅរស់នៅជាមួយពួកខ្មែរក្រហមនៅភ្នំវាយចាប ប្រមាណ ៧០០នាក់ ផងដែរ។ ចំណែកពួកខ្មែរក្រហម ដែលនៅសេសសល់បាននាំគ្នារត់ចេញពីភ្នំវាយចាប ដោយបែងចែកគ្នា ជា៥-៦ក្រុមតូចៗ ក្រុមខ្លះធ្វើដំណើរសំដៅទៅខេត្តពោធិ៍សាត់ ក្រុមខ្លះសំដៅទៅខេត្តកំពង់ឆ្នាំង និងក្រុមខ្លះទៀតសំដៅទៅខេត្តកំពង់ស្ពឺ ដើម្បីទាក់ទងខ្សែរយៈពួកខ្មែរក្រហមផ្សេងៗទៀត នៅតាមខេត្តទាំង៣នោះ។

ប្រតិបត្តិការសឹកបោសសម្អាតពួកខ្មែរក្រហមនៅក្នុងខេត្តបាត់ដំបង ចេះតែបន្តទៅមុខទៀត រហូតដល់ខែសីហា មេខ្មែរក្រហមប្រចាំភូមិភាគពាយ័ព្យម្នាក់ ដែលសម្តេចសីហនុ ប្រកាសថា បើនរណាកាត់ក្បាលគាត់បាន នឹងប្រគល់ប្រាក់រង្វាន់ជូន ៣០០០០០រៀលនោះ ត្រូវពួកទាហានចាប់ខ្លួនបាន រួចយកទៅសម្លាប់ចោលទាំងគ្រួសារ។

ប៉ុន្តែ មូល សម្បត្តិ ហៅរស់ ញឹម ជាលេខាគណៈកម្មាធិការបក្សភូមិភាគពាយ័ព្យ ដែលសម្តេចសីហនុប្រកាសថា បើនរណាកាត់ក្បាលគាត់បាន នឹងផ្តល់រង្វាន់ជាទឹកប្រាក់៩00000 (កៅសិបម៉ឺន) រៀលនោះ បានគេចខ្លួនដោយសុវត្ថិភាព។

ក្រោយមក ដោយសារតែតម្លៃក្បាលគាត់ថ្លៃកៅសិបម៉ឺនរៀលនោះ អ្នកស្រុកនៅទីនោះក៏ដាក់ឈ្មោះឱ្យគាត់មួយទៀត គឺតាកៅៗ ចាប់ពីពេលនោះមក។

នៅភូមិភាគនិរតី វិញ ទាហានរាជរដ្ឋាភិបាលក៏បានបើកប្រតិបត្តិការសឹកបោសសម្អាតមូលដ្ឋានតស៊ូរបស់ពួកខ្មែរក្រហម ប្រកបដោយជោគជ័យដែរ។

ចំណែក ហ៊ូ នឹម អតីតរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ក្នុងឆ្នាំ១៩៦២ បានរត់គេចខ្លួនពីរាជធានីភ្នំពេញ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៦៧ បានទៅរស់នៅក្នុងព្រៃជាមួយខៀវ សំផន និងហ៊ូ យន់ នៅភូមិភាគនិរតី។ ក្រោយពីបានរៀនសូត្រលក្ខន្តិកៈបក្សរួច ត្រូវបានមេដឹកនាំនៅភូមិភាគនោះ ធ្វើពិធីបញ្ចូលជាបក្ខជនរបស់បក្សកុម្មុយនិស្តកម្ពុជា នៅភ្នំដំរី ក្នុងឆ្នាំ១៩៦៨ នោះដែរ ។

នៅពេលដែលពួកទាហានរាជរដ្ឋាភិបាលបើកប្រតិបត្តិការសឹកបោសសម្អាតពួកខ្មែរក្រហមនៅភូមិភាគនិរតីនោះ ហ៊ូ នឹម និងខៀវ សំផន ស្នាក់នៅមូលដ្ឋានតស៊ូមួយក្នុងព្រៃដែលនៅក្បែរភូមិមួយឈ្មោះភូមិព្រៃធំ។ ប៉ុន្តែមិនយូរប៉ុន្មាន ពួកទាហានក៏បានចូលមកដល់ភូមិព្រៃធំនោះ ហើយធ្វើការឡោមព័ទ្ធបឹងមួយដែលនៅក្បែរនោះ ធ្វើឲ្យពួកគាត់ជួបការលំបាកយ៉ាងខ្លាំង ព្រោះមិនត្រឹមតែគ្មានបាយហូបនោះទេ សូម្បីតែទៅដងទឹកនៅក្នុងបឹងនោះផឹកក៏មិនបានផង។

ដោយមិនអាចស៊ូទ្រាំអត់បាយក្រហាយទឹក ជាច្រើនថ្ងៃមកហើយនោះ កម្មាភិបាលខ្មែរក្រហមម្នាក់ គឺមិត្តសៅ ក៏បាននាំយុទ្ធជនមួយក្រុមលបចូលទៅក្នុងភូមិ ដើម្បីរកអង្ករ មកដាំបាយហូប ប៉ុន្តែពេលវិលត្រលប់មកវិញ គ្មានបានអ្វីបន្តិចឡើយ។

មិត្តសៅ បាននិយាយប្រាប់ ហ៊ូ នឹម និងខៀវសំផន ថា ស្ថានការណ៍មិនល្អសោះ ខ្មាំងព័ទ្ធជុំវិញបឹង។ តែបញ្ហានេះមិនធ្ងន់ធ្ងរទេ មិត្តយើងបានឡោមព័ទ្ធពួកវាវិញ និងបាញ់តបតដែរ។ តែបញ្ហាសំខាន់ សូម្បីតែអង្ករមួយកំប៉ុង យើងរកមិនបានផង ហើយមិត្តហឿម (យុទ្ធជនខ្មែរក្រហមនៅក្រោមបញ្ជារបស់ឈ្មោះមិត្តសៅ) ដែលយើងចាត់តាំងឱ្យទៅរកអង្ករនោះ បានរត់ទៅចុះចូលជាមួយពួកខ្មាំងបាត់ទៀត។

ចំណែក ហ៊ូ យន់ វិញ ពេលនោះ កំពុងរស់នៅជាមួយពួកខ្មែរក្រហម នៅភ្នំឱរ៉ាល់ ក៏លំបាកវេទនាណាស់ដែរ។ ពួកខ្មែរក្រហមជាច្រើន ខ្លះមានជំងឺ ពិសេសជំងឺគ្រុនចាញ់ ខ្លះទៀតត្រូវស្លាប់ជាបន្តបន្ទាប់។ ពួកគេរស់បាន ដោយសារតែដើរសុំអង្ករបន្តិចបន្តួចពីពួកអ្នកស្រុកដែលរស់នៅតំបន់ជុំវិញភ្នំនោះ។ ប៉ុន្តែ អ្នកស្រុកនៅទីនោះ ក៏មានជីវភាពលំបាកតោកយ៉ាករកតែអង្ករប្រេកឆ្នាំងខ្លួនឯង ស្ទើរមិនចង់បានផង។

តាំងពីចុងខែកុម្ភៈ ឆ្នាំ១៩៦៨ មក សម្តេចសីហនុ បានប្រកាសថា ប្រសិនបើស្ថានការណ៍ក្នុងផ្ទៃប្រទេសចេះតែធ្លាក់ចុះដុនដាបទៅៗ ដោយសារតែសកម្មភាពវាយប្រហាររបស់ពួកឧទ្ទាមខ្មែរក្រហមនោះ ព្រះអង្គនឹងប្រគល់អំណាចឱ្យឧត្តមសេនីយ៍ឯកលន់ នល់ បំពេញតួនាទីជាអ្នកដឹកនាំការបង្ក្រាបពួកឧទ្ទាមខ្មែរក្រហម ដូចគ្នានឹងឧត្តមសេនីយ៍ស៊ូហារតូ (Suharto) នៅ

ប្រទេសឥណ្ឌូណេស៊ី ដែរ។

នៅក្នុងខែឧសភា សម្តេចសីហនុ បានថ្លែងថា សកម្មភាពរបស់ពួកឧទ្ទាម ត្រូវកងទ័ពខេមរភូមិន្ទបើកប្រតិបត្តិការសឹកបង្ក្រាបស្ទើរទាំងស្រុងទៅហើយ ឥឡូវនេះ នៅសល់តែការបើកប្រតិបត្តិការសឹកជាទ្រង់ទ្រាយធំពីរកន្លែងទៀតប៉ុណ្ណោះ គឺមួយនៅក្នុងខេត្តកោះកុង និងមួយទៀត នៅក្នុងខេត្តកំពង់ធំ។

នៅក្នុងខែមិថុនា ឆ្នាំ១៩៦៨ កងទាហានរបស់ព្រះអង្គ បានបើកប្រតិបត្តិការសឹកនៅស្រុកបារាយណ៍ ក្នុងខេត្តកំពង់ធំ ដោយសម្លាប់ពួកឧទ្ទាមខ្មែរក្រហម២១នាក់ និងចាប់ខ្លួនបានចំនួនប្រមាណ៨០នាក់ទៀត។

នៅខែសីហា ឆ្នាំ១៩៦៨ សម្តេចសីហនុ ប្រកាសជាសាធារណៈឱ្យដឹងពីការបើកប្រតិបត្តិការសឹករបស់ទាហានព្រះអង្គបន្តទៀត ដើម្បីបង្ក្រាបពួកឧទ្ទាមខ្មែរក្រហម នៅក្នុងខេត្តកោះកុង។ ដោយសារប្រតិបត្តិការសឹកនោះមានលក្ខណៈសាហាវឃោរឃៅខ្លាំងពេកនោះ ធ្វើមជ្ឈដ្ឋានអ្នកនយោបាយមួយចំនួនថ្កោលទោសព្រះអង្គ ផងដែរ។

# ២៤១
# ក្រោយពីរួចផុតជីវិត
# ទៀ សង្វាន ត្រូវបានដូរឈ្មោះមកជា ទៀ បាញ់



**រូបថតក្នុងខ្សែភាពយន្តរឿងជនត្រូវគេបាញ់**

ទៀ សង្វាន កើតនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៤៥ នៅភូមិកោះស្រឡៅ ឃុំកោះកាពិ ស្រុកកោះកុង ខេត្តកោះកុង ក្នុងគ្រួសារកសិករដ៏ក្រីក្របំផុតមួយ ដែលមានឪពុកឈ្មោះ ទៀ តិក និងម្ដាយឈ្មោះ នូ ផេងចិន្ដា មុខរបរធ្វើស្រែ និងកាប់អុសលក់។ មានបងប្អូនបង្កើត ៥ នាក់។

នៅក្នុងឆ្នាំ១៩៥១ ក្រោយពីឪពុកស្លាប់ចោលដោយសារជំងឺ កុមារទៀ សង្វាន ដែលទើបមានអាយុ១១ឆ្នាំ ខំប្រឹងតស៊ូដើរស៊ីឈ្នួលឡើងបេះផ្លែស្លាឲ្យអ្នកភូមិ និងរកត្រី ដើម្បីរកប្រាក់មកជួយដោះស្រាយការលំបាករបស់ម្ដាយជាស្រីមេម៉ាយ។

## របត់នយោបាយ

នៅឆ្នាំ១៩៥៧ ទៀ សង្វាន ត្រូវបានម្តាយបញ្ជូនឲ្យទៅនៅវត្ត ដើម្បីសិក្សារៀនសូត្រនឹងគេ។ ថ្ងៃមួយ ក្នុងឆ្នាំ១៩៦០ នៅមុខផ្ទះមានពួកប៉ូលិស និងកងជីវពលភូមិ ៦ទៅ៧នាក់ មកសម្លុតគំរាមម្តាយ សង្វាន ឲ្យប្រគល់ប្អូនស្រីរបស់គាត់ ដែលទើបមានអាយុ១៣ឆ្នាំ យកទៅឱ្យនាយប៉ូលិសជាមេរបស់ពួកវា ដើម្បីលេងសើចកំដរអារម្មណ៍។ ពេលនោះ សង្វាន បានប្រកែកតវ៉ា មិនឲ្យពួកវាយកប្អូនស្រីគេទៅដាច់ខាត ទោះបីគេត្រូវប្តូរជីវិតក៏ដោយ ។

ដោយសារការឈឺចាប់ពីរឿងនេះផងដែរ នៅឆ្នាំ១៩៦១ ទៀ សង្វាន បានលួចទាក់ទង និងផ្តល់ស្បៀងអាហារដល់កម្លាំងតស៊ូដែលលាក់ខ្លួនក្នុងព្រៃក្បែរៗភូមិ។ ដើម្បីរក្សាការសម្ងាត់ក្នុងការទំនាក់ទំនងជាមួយកម្លាំងតស៊ូ សង្វាន ត្រូវបានគេដាក់ឈ្មោះមួយផ្សេងទៀត គឺផៃវ៉ាន់។

ពេលនោះដែរ មេភូមិតាចាត (មេភូមិរាជការ) ឈ្មោះហឿង ជាប់ជាសាច់ញាតិបងប្អូនគាត់ដែរតែមិនចេះអក្សរ តែងតែពឹងគាត់ឲ្យជួយអានលិខិតស្នាមផ្សេងៗ ដែលអាជ្ញាធរថ្នាក់ឃុំ ថ្នាក់ស្រុកផ្ញើមកឱ្យអនុវត្ត។

ជាញឹកញាប់ ពេលឃើញអាជ្ញាធរថ្នាក់ឃុំ ថ្នាក់ស្រុកធ្វើសកម្មភាពរំលោភបំពានជិះជាន់ប្រជាជនខ្លាំងពេក សង្វាន តែងតែតវ៉ាប្រឆាំងផងដែរ។ រហូតមានពេលមួយ គាត់ត្រូវអាជ្ញាធរឃុំទួលគគីរ មកចាប់ខ្លួន។ តែដោយមានអ្នកភូមិជាច្រើន នាំគ្នាចេញមុខទៅជួយតវ៉ាទាមទារ ទើបអាជ្ញាធរដោះលែងគាត់វិញ។

តែក្រោយពីស៊ើបដឹងថា សង្វាន តែងតែលួចនាំយកស្បៀងអាហារទៅឱ្យចលនាតស៊ូនៅក្នុងព្រៃ ស្រាប់តែថ្ងៃមួយ ក្រុមប៉ូលិស និងជីវពលភូមិ ក៏បានចុះមកចាប់ចងគាត់នាំទៅសួរចម្លើយ។ នៅពេលសួរចម្លើយ ពួកគេបានធ្វើទារុណកម្មវាយដំ និងចងស្លាបសេកលើកគាត់ព្យួរជាមួយខ្សែព្ួរ ថ្លក់ទៅនឹងរ៉កមួយ ទាញស្រាវឡើងលើ ដើម្បីបំបាក់ស្មារតី។

ក្រោយពីសួរចម្លើយ មិនបានទទួលលទ្ធផលអ្វី ពួកគេក៏បានយកគាត់ទៅឃុំទុកនៅសាលាឃុំ( សម័យនោះ សាលាឃុំគ្មានអគារត្រឹមត្រូវទេ ) គឺគេយកផ្ទះរបស់ស្មៀនម្នាក់ នៅក្បែរវត្តទួលគគីរ ធ្វើជាសាលាឃុំតែម្តង។

ដំបូង ពួកគេដាក់គាត់ឲ្យនៅក្រោមផ្ទះមួយគ្មានមនុស្សនៅ ដោយចងស្លាបសេក ជាមួយអ្នកជាប់ពាក់ព័ន្ធចលនាតស៊ូ មានវ័យចំណាស់ៗ ៦នាក់ទៀតគឺ ឈ្មោះណោម, ឈ្មោះម៉ក់, ឈ្មោះយ៉េ, ឈ្មោះវ៉េ, ឈ្មោះឡឹត និងឈ្មោះកៅ សរុបទាំងអស់៧នាក់។ យប់មួយ ដោយសារទ្រោមខ្លួនពីការទទួលទណ្ឌកម្មធ្ងន់ធ្ងរពីពេលថ្ងៃ ពួកអ្នកតស៊ូចាស់ៗនាំគ្នាដេកលង់លក់អស់ ចំណែករូបគាត់ដេកមិនលក់សោះ ដាចែដន្យ ស្រាប់តែឃើញមនុស្សបួននាក់ឡើងលើផ្ទះនោះ ហើយឮសំឡេងជជែកគ្នាតិចៗ។ ក្នុងនោះមាន តាហឿង ជាមេភូមិតាចាត និងមេឃុំទួលគគីរ ឈ្មោះវៃ ត្រូវជាក្មួយរបស់តាហឿង។

ពេលនោះ មានម្នាក់និយាយតិចៗថា ពិបាករកចាប់ពួកវាណាស់ ព្រោះអាអ្នកសំខាន់ៗបានដឹងខ្លួន ហើយរត់គេចចេញពីភូមិអស់។ ឥឡូវយើងចាប់បានតែអាអ្នកចុងដួច...។ សំឡេងម្នាក់ទៀត តបវិញថា យើងត្រូវតែចាប់ពួកអាតូចៗមកសួរចម្លើយ ដើម្បីស្រាវជ្រាវរកពួកអាធំៗ...។

ដោយសារនៅសាលាឃុំទួលគគីរ (ផ្ទះរបស់ស្មៀន) គ្មានកន្លែងដាក់អ្នកទោស កងជីវពលឃុំបានបណ្ដើរពួកគាត់ទាំង៧នាក់ ឱ្យចូលព្រៃទៅកាប់ដើមកោងកាង មកធ្វើជាគុក មានទំហំ៦ គុណនឹង៧ម៉ែត្រសម្រាប់ដាក់ពួកគាត់ ដើម្បីទុកសួរចម្លើយបន្តទៀត។ តែពួកគាត់មិនព្រមសារភាព ពេលខ្លះគេឲ្យពួកគាត់អង្គុយកន្ធែកជើងផ្ទាល់នឹងដី យកខ្សែភ្លើងមកចងភ្ជាប់នឹងមេជើង រួចគេបញ្ជាឲ្យអ្នកទោសម្នាក់ទៀត ចុចកុងតាក់ឌីណាម៉ូដែលកំពុងវៃដោយដៃ ធ្វើឲ្យចរន្តចភ្លើងឆក់អ្នកទោសញ័រប្រកាច់ស្ទើរស្លាប់ស្ទើររស់។

ជារៀងរាល់ថ្ងៃ អ្នកយាមម្នាក់ឈ្មោះម៉ុន សិរិ តែងមកដោះសោច្រវាក់ឱ្យពួកអ្នកទោសទាំងអស់ចេញមកដាំបាយនៅខាងមុខគុកនោះ។ តែឈ្មោះម៉ុន សិរិ នេះជាមនុស្សចិត្តល្អ ម្យ៉ាងដោយឃើញសង្វាន មានវ័យក្មេងផង ម៉ុន សិរិ តែងលួចហុចចំណីអាហារឱ្យគាត់ ហើយបានឱ្យកន្ទេល និងក្បួយចាស់មួយឱ្យគាត់ទៀតផង។ ថ្ងៃមួយពួកទាហាននៅកងវរសេនាតូចលេខ២២ ចុះមកត្រួតពិនិត្យពួកគាត់ជាអ្នកទោសកំពុងនៅក្នុងគុកដូចទ្រុងជ្រូកនោះ។ ពួកទាហានឈរពីក្រៅ សម្លឹងមើលមុខយុវជនសង្វាន រួចក៏សួរទៅមេឃុំទួលគគីរ ថា ចុះអាម្នាក់

នេះនៅក្មេង ហើយតូចយ៉ាងនេះចាប់វាមកធ្វើអ្វី? មេឃុំប្រាប់ថា កុំមើលងាយវាណា! អាក្មេងហ្នឹងខ្លាំងជាងគេ។

នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៦៥ យុវជនទៀ សង្វាន និងតាកៅ ត្រូវបានគេដោះលែងឲ្យមកផ្ទះវិញ។ តែមិនមែនដោះលែងដោយងាយៗនោះទេ។ ម្តាយសង្វាន បានប្រាប់ថា អាជ្ញាធរឃុំបានទារប្រាក់ចំនួន៥០០០រៀលជាថ្នូរនឹងការដោះលែងនេះ ហើយប្រាក់នេះ ម្តាយគាត់ត្រូវលក់ក្របីមួយក្បាល បាន១៥០០រៀល និងលក់ខ្សែកប្អូនស្រីគាត់ទម្ងន់ ៥ជីទៀត។

ខ្សែកទម្ងន់៥ជីនោះ ប្អូនស្រីគាត់បានមកពីការខំសន្សំប្រាក់ស៊ីឈ្នួលមើលកូនឲ្យថៅកែឡជ្សូងម្នាក់ ដែលគាត់ធ្លាប់កាប់ដើមកោងកាងទៅលក់ឱ្យដែរ។ សរុបប្រាក់បានមកពីលក់ក្របីមួយក្បាល និងខ្សែកប្អូនស្រីគាត់៥ជី បានប្រាក់តែ២០០០រៀលប៉ុណ្ណោះ យកទៅឱ្យអាជ្ញាធរឃុំសិន។ ឯតាកៅ វិញ គាត់ជាអ្នកមានគួរសម គាត់មានក្របីដល់ទៅជាង២០ក្បាល អាជ្ញាធរឃុំទារពីគាត់ដល់ទៅ៣ម៉ឺនរៀល គាត់ក៏ព្រមផ្តល់ឲ្យគ្រប់ចំនួន។

ក្រោយដោះលែង យុវជនសង្វាន និងតាកៅ បានបួនថ្ងៃ ស្រាប់តែឮដំណឹងថា អ្នកជាប់ឃុំជាមួយគាត់បួននាក់ទៀត គឺឈ្មោះម៉ក់, ឈ្មោះយ៉េ, ឈ្មោះណោម, ឈ្មោះឡឹត ត្រូវគេយកទៅបាញ់ចោលនៅចុងភូមិតាម៉ាន អស់ហើយ។

ព្រឹកថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៦៥ គឺរយៈពេលតែមួយសប្តាហ៍ប៉ុណ្ណោះ ក្រោយពីដោះលែងវិញ ស្រាប់តែប្អូនប្រុសសង្វាន ឈ្មោះទៀ វិញ បានរត់ត្រហេបត្រហបទៅប្រាប់គាត់ឲ្យរត់គេចខ្លួនភ្លាមៗទៅ ព្រោះមានកម្លាំងប៉ូលិស និងកងជីវពលនាំគ្នាមកចាប់គាត់ និងតាកៅ ទៀតហើយ។

ពេលនោះ សង្វាន ប្រញាប់ប្រញាល់ទៅជួបឈ្មោះកៅ ដែលធ្លាប់ជាប់គុក និងដោះលែងវិញជាមួយគ្នា។ តាកៅ ក៏មានការងឿងឆ្ងល់ដែរថា គាត់បានឲ្យប្រាក់អាជ្ញាធរឃុំ ៣០០០០រៀលគ្រប់ចំនួនហើយ ហេតុអ្វីបានមករកចាប់គាត់ទៀត? ហើយម្តាយសង្វាន ក៏បាន ឲ្យគេ២០០០រៀលហើយដែរ តែនៅខ្វះ ៣០០០រៀលទៀត។ ដូច្នេះ ពួកគាត់ក៏នាំគ្នាដើរកាត់ភ្លៀង ដើម្បីទៅសួរមេឃុំមើល តើហេតុដូចម្តេច បានទៅជាយ៉ាងនេះ?។

ពេលពួកគាត់ដើរចេញពីភូមិបានបន្តិច ស្រាប់តែមានកម្លាំងប៉ូលិស និងកងជីវពលមួយក្រុមបានចូលមកដល់ផ្ទះពួកគាត់។ ក្រោយពីរុករកពួកគាត់មិនឃើញ ក៏ប្រញាប់ចាកចេញទៅវិញ។ មិនយូរប៉ុន្មាន ប៉ូលិស២នាក់ និងកងជីវពល៥នាក់មានកាំភ្លើង៤ដើម បានរត់តាមទាន់ពួកគាត់នៅពាក់កណ្ដាលផ្លូវទៅសាលាឃុំ ហើយចាប់ពួកគាត់យកខ្សែវេញពីផ្ចៃទំហំប៉ុនម្រាមកូនដៃចងស្លាបសេករឹតយ៉ាងតឹង។ ប៉ូលិស២នាក់ និងកងជីវពល៥នាក់នោះ ជាអ្នករស់នៅភូមិជិតៗគ្នា ហើយពួកគាត់ក៏ស្គាល់ឈ្មោះទាំងអស់ដែរ។

ក្រោយពេលចងបណ្ដើរពួកគាត់ឆ្លងស្ពានមួយ ដែលមានតែកំណាត់ឈើវែង២ ដាក់ពីលើទៅដល់ផ្លូវបំបែកជាពីរ ផ្លូវមួយទៅសាលាឃុំ និងផ្លូវមួយទៀតទៅកាន់ភ្នំកោះអណ្ដែត ពួកប៉ូលិស និងកងជីវពលខ្លះដើរចូលក្នុងព្រៃកាប់វល្លិផ្ដៅមកចងរឹតគាត់បន្ថែមទៀត ហើយបង្ខំឲ្យពួកគាត់ ដើរទៅមុខឲ្យលឿនៗ សំដៅទៅរកជើងភ្នំកោះអណ្ដែត ខណៈភ្លៀងធ្លាក់កាន់តែខ្លាំងឡើងៗ។

ពេលទៅដល់គោលដៅ កងជីវពលឈ្មោះសួ បានលើកកាំភ្លើងបាញ់តាកៅ លាន់សូរផាំងៗ ចំនួនពីរគ្រាប់ផ្ទួនៗគ្នា បណ្ដាលឲ្យតាកៅ ដួលផ្កាប់មុខនៅក្បែរជើងយុវជនសង្វាន បណ្ដាលឱ្យសង្វាន ភ័យញ័រជើងទទ្រើក។ ភ្លាមនោះដែរ កងជីវពលឈ្មោះដាំ បានលើកកាំភ្លើងបាញ់យុវជនសង្វាន លាន់សូរផាំង បណ្ដាលឱ្យដួលផ្កាប់មុខទៅលើដីក្បែរតាកៅ នោះដែរ។

កងជីវពលទាំង៥នាក់ ក៏នាំគ្នាជីករណ្ដៅប្ដូរវេនគ្នាម្នាក់ម្ដងៗ ខណៈភ្លៀងធ្លាក់កាន់តែខ្លាំងឡើងៗ ទឹកពីលើកំពូលភ្នំបានហូរកាត់មកលើដងខ្លួនសង្វាន ជាជនរងគ្រោះ ដោយនាំទាំងឈាមតាកៅ ហូរមកលើខ្លួនគាត់ទៀតផង។ ពេលនោះ សង្វាន បានដឹងខ្លួនឡើងវិញតិចៗ តែដូចជាមិនមានអាការៈឈឺចាប់អ្វីប៉ុន្មានទេ។ គាត់ឮសំឡេងពួកប៉ូលិស និងកងជីវពលនិយាយគ្នាតិចៗថា យើងលោតរំលងខ្មោចពួកវាទៅ ដើម្បីកុំឲ្យខ្មោចពួកវាតាមជិះកយើងវិញ។

ពេលនោះ ហាក់ដូចជាមានអ្វីមួយជួយផ្ដល់ថាមពលដល់សង្វាន ឱ្យស្ទុះងើបទាំងជាប់ចំណងស្លាបសេក។ កងជីវពលឈ្មោះដាំ ស្រែកខ្លាំងៗថា វាមិនទាន់ងាប់ទេ! រួចក៏ទាញកាំភ្លើងដែលផ្អែកនៅគល់ដើមឈើ បាញ់មកលើគាត់។ តែបាញ់មិនផ្ទុះ គាត់រត់ចូលព្រៃកាត់

បន្លាផ្តៅរពាក់ក៏មិនដឹងឈឺ រហូតទាល់តែយប់ងងឹត ទើបហ៊ានឈប់។

សង្វាន ក៏មិនដឹងថាមូលហេតុអ្វី បានជាគាត់មិនមានរបួសអ្វីបន្តិចដោយសារគ្រាប់កាំភ្លើងពួកប៉ូលិស និងជីវពលនោះដែរ។ គាត់ឃើញដើមឈើតូចល្មមមួយដើមមានសម្បកគ្រើមៗ ក៏ផ្អែកខ្នងដាក់ចំណាងស្លាបសេកទៅត្រដុសចុះឡើងនឹងដើមឈើនោះ ឱ្យដាច់សឹកបន្តិចម្តងៗ លុះត្រារបូតរលាអស់ រួចគាត់បន្តដំណើរកាត់ភ្លៀងទាំងយប់ មករកភូមិព្រៃក្តួចហើយសម្ងំក្នុងព្រៃក្បែរភូមិនោះ ដោយប្រុងប្រយ័ត្ន។

លុះព្រឹកឡើង គាត់ក៏រកដើមកោងកាង ដែលមានស្លឹកស៊ុបទ្រុប ឡើងទៅពួនសម្ងំរហូតដល់យប់ទើបហ៊ានចុះមកដី រកមើលអ្នកតស៊ូដែលតែងតែនាំគ្នាដើរធ្វើសកម្មភាពក្នុងព្រៃពេលយប់ស្ងាត់។ ដល់ថ្ងៃទី២ ទើបគាត់ដឹងថា ទីនោះជាព្រៃដែលគាត់ធ្លាប់លួចយកស្បៀងអាហារមកផ្តុំងទុកឲ្យអ្នកតស៊ូកាលពីមុនមក។

គាត់បានដាក់កំប៉ុងទឹកដោះគោធ្វើជាសញ្ញាដូចពីពេលមុន ដើម្បីឲ្យអ្នកតស៊ូដឹងថាគាត់កំពុងនៅក្នុងព្រៃនេះដែរ។ តែទន្ទឹងរង់ចាំអត់បាយអត់ទឹកចំនួន ៣ថ្ងៃ ៣យប់ មកហើយមិនបានជួបនរណាម្នាក់ឡើយ។ ដោយសារហត់ហេវខ្លាំងពេក គាត់ក៏ប្រថុយលបដើរ សំដៅទៅរកផ្ទះគាត់នៅក្នុងភូមិ។ ពេលទៅដល់ ឃើញផ្ទះស្ងាត់ជ្រងំ គ្មានមនុស្សម្នាក់សោះ គាត់មានការងឿងឆ្ងល់ និងព្រួយបារម្ភពីសុវត្ថិភាពម្តាយ និងបងប្អូនគាត់យ៉ាងខ្លាំង។

គាត់ចូលទៅក្នុងផ្ទះ រាវរកអង្ករ ឬរបស់អ្វីដែលអាចហូបបាន តែគ្មានប្រទះអ្វីសោះ។ គាត់ក៏បានដើរតម្រង់ទៅផ្ទះអ្នកជិតខាងម្នាក់ឈ្មោះតយ ដែលមានបងប្អូនម្នាក់ជាអ្នកតស៊ូក្នុងព្រៃដែរ តែមិនឃើញទៀត។ គាត់គិតថា បើទៅលបចាំនៅវាលមួយដែលពូតយ ធ្លាប់តែយកក្របីទៅចងឲ្យស៊ីស្មៅនៅទីនោះ ប្រហែលជាបានជួប។

លុះព្រឹកឡើង គាត់ក៏បានឃើញពូតយ ដើរមកចងក្របីឱ្យស៊ីស្មៅនៅវាលនោះមែន ពូតយ បានប្រាប់គាត់ឱ្យដឹងថា កម្លាំងសមត្ថកិច្ចនៅតែស្វែងរកគាត់ មិនឈប់ទេ តែពួកគេពុំហ៊ានចូលព្រៃជ្រៅឡើយ។ ក្រោយពីតាមរកគាត់មិនឃើញ ពួកប៉ូលិស និងជីវពលបានមកចាប់ម្តាយគាត់យកទៅធ្វើទារុណកម្មធក់ខ្សែភ្លើង ដើម្បីសួរចម្លើយបាត់ហើយ។

ពេលនោះ ភ្លើងកំហឹងរបស់យុវជនទៀ សង្វាន កាន់តែឆាបឆេះខ្លាំងថែមទៀត។ គាត់បានស្នើសុំពួតយ ឲ្យជួយទៅយកអង្ករ ថ្នាំង ពីក្នុងភូមិមកឱ្យគាត់។ ពួតយ ក៏បានចូលទៅយកអង្ករ និងថ្នាំងដាក់បាយឆ្អែមួយមកឱ្យគាត់ដូចបំណង។ តែគាត់នៅខ្វះកាំបិត ដែកកេះថ្មដែកកេះ និងចាក់ប្រេងដែកកេះទៀត គាត់ក៏ស្នើសុំពួតយ ឲ្យជួយគាត់ទៀត។ ពួតយ ក៏ព្រមទៅយកមកឲ្យគាត់ទៀត តែនៅភ្លេចអំបិល មួយមុខទៀត ពួតយ ក៏ព្រមទៅយកអំបិលឱ្យគាត់ម្តងទៀត។

ក្រោយពីបានអង្ករ អំបិល កាំបិត និងដែកកេះមក ហើយគាត់ក៏ប្រញាប់ចូលព្រៃជ្រៅដើម្បីរកកន្លែងដែលមានសុវត្ថិភាព។ ថ្ងៃនោះ ជាថ្ងៃដែលគាត់បានបាយទទួលទានឡើងវិញក្រោយពីដាច់បាយចំនួន៤ថ្ងៃមកហើយ។

ចូលដល់ថ្ងៃទី៥ ពេលមានកម្លាំងបន្តិច គាត់ក៏ដើរទៅរកព្រៃកោងកាងជាកន្លែងដែលគាត់ពួនរង់ចាំជួបអ្នកតស៊ូនោះម្តងទៀត។ តែមិនបានជួបនរណាម្នាក់សោះ ធ្វើឱ្យគាត់ព្រួយបារម្ភ និងអស់សង្ឃឹមយ៉ាងខ្លាំង។

លុះដល់ថ្ងៃទី៦ ពេលគាត់កំពុងពួនសម្ងំនៅលើដើមកោងកាងមានស្លឹកស៊ុបទ្រុប ស្រាប់តែឃើញមនុស្ស៤នាក់ដើរចូលមក។ គាត់ខំប្រឹងសម្លឹងតាំងពីចម្ងាយស្ទើរពុំហ៊ានប្រិចភ្នែក។ លុះចូលមកកាន់តែជិត គាត់ស្គាល់ច្បាស់ គឺឈ្មោះហ៊ិន, ឈ្មោះសៀង, ឈ្មោះចន និងឈ្មោះទិតដែលគាត់ធ្លាប់លួចយកស្បៀងអាហារមកផ្តល់ឲ្យកាលពីមុននោះ។

គួររម្លឹកថា ឈ្មោះសៀង បានរត់គេចខ្លួនទៅចូលរួមជាមួយចលនាតស៊ូនៅក្នុងព្រៃមុនគេ។ ៤-៥ខែក្រោយមក អាជ្ញាធរក៏បានរកចាប់អ្នកភូមិ២នាក់ទៀត គឺ ឈ្មោះទៀ សុទ្ធ (ជាបងប្រុសទី២របស់ទៀ សង្វាន) និងឈ្មោះចន។ ពេលនោះ ឈ្មោះទៀ សុទ្ធ ក៏បានបបួលឈ្មោះចន និងអ្នកភូមិ២នាក់ទៀត គឺឈ្មោះហ៊ិន ជាបងរបស់ពួតយ និងឈ្មោះទិតជាកូនរបស់តាឡុង រត់គេចខ្លួនទៅចូលរួមជាមួយចលនាតស៊ូនៅក្នុងព្រៃដែរ។

ចាប់ពីពេលនោះមក យុវជនទៀ សង្វាន ក៏បានចាប់ផ្តើមចូលរួមក្នុងចលនាតស៊ូជាមួយបងប្រុសគាត់ និងអ្នកនៅភូមិជាមួយគ្នាទាំងអស់នោះដោយឆន្ទៈមោះមុតបំផុត។ នៅក្នុង

## របត់នយោបាយ

ព្រែតស៊ូ ដោយដឹងថាទៀ សង្វាន ត្រូវពួកប៉ូលិស និងកងជីវពលចងបណ្ដើរយកទៅបាញ់ចោល តែមិនស្លាប់ ហើយរត់គេចខ្លួនបានរួចជីវិតនោះ ពួកមេដឹកនាំតស៊ូចាស់ៗ ក៏ដាក់ឈ្មោះថ្មីមួយទៀតឱ្យគាត់ គឺឈ្មោះទៀ បាញ់ រហូតមក។

# ២៤២
# ទៀ បាញ់ ដឹកនាំកម្លាំងចូលរោងចក្រអាររណៅ របស់ប្អូនញ៉ឹក ជូឡុង ដើម្បីរកស្បៀង



សម្តេចសីហនុ យាងទៅសម្ពោធគិលានដ្ឋាន នៅក្រុងខេមរភូមិន្ទ ខេត្តកោះកុង ខែមីនា ឆ្នាំ១៩៦៨

ក្រោយពីចាប់យុវជនទៀ សង្វាន ហៅទៀ បាញ់ យកទៅបាញ់សម្លាប់ចោល តែសង្វាន មិនស្លាប់ ហើយរត់ទៅចូលរួមជាមួយចលនាតស៊ូមក អាជ្ញាធរឃុំទួលគគីរ បានបណ្តេញ ប្រជាជនទាំងអស់នៅភូមិព្រែកក្តួច និងភូមិតាចាត ឲ្យរុះរើផ្ទះសម្បែងទៅរស់នៅភូមិទួលគគីរ វិញ ដើម្បីកាត់ផ្តាច់ទំនាក់ទំនងអ្នកភូមិជាមួយចលនាតស៊ូនៅក្នុងព្រៃ។

មិនត្រឹមតែឲ្យរុះរើផ្ទះសម្បែងទេ សូម្បីដើមចេករបស់អ្នកភូមិនៅតាមចម្ការនានា ក៏ ត្រូវពួកអាជ្ញាធរកាប់បំផ្លាញចោលអស់ដែរ ព្រោះខ្លាចពួកអ្នកតស៊ូនៅក្នុងព្រៃចូលទៅកាប់ផ្លែ ឬគល់ចេកយកទៅស្ងោរហូបជំនួសបាយ។

## របត់នយោបាយ

នៅពេលទៅរស់នៅក្នុងព្រៃជាច្រើនខែមក ដោយសារនឹករឭកម្តាយជាទីស្រលាញ់ខ្លាំងពេក ទៀ បាញ់ ក៏បានលបជួបអ្នកភូមិវ័យចំណាស់ម្នាក់ ដែលគាត់មានទំនុកចិត្តបំផុតឲ្យជួយទៅប្រាប់ម្តាយគាត់ផងថា គាត់នៅរស់ទេ ហើយឲ្យម្តាយគាត់មកជួបគាត់នៅព្រែកមួយ ឈ្មោះព្រែកកាត នៅក្នុងព្រៃកោងកាង វេលាថ្ងៃត្រង់។

ទោះបីស្ថិតក្នុងសភាពគ្រោះថ្នាក់លំបាកវេទនាយ៉ាងណា ក៏ដោយ នៅពេលបានជួបមុខអ្នកមានគុណ គាត់រំភើបសប្បាយរីករាយរហូតទប់ទឹកភ្នែកមិនបាន។ ចំណែកម្តាយគាត់ក៏ស្រក់ទឹកភ្នែក ដោយខ្លោចចិត្តអាណិតកូនដែលរស់នៅតស៊ូលំបាកវេទនាហូបតែគល់ចេកគល់ល្ពុងនៅក្នុងព្រៃនោះខ្លាំងណាស់។ តែមុនពេលបែកគ្នា ម្តាយគាត់ខំប្រឹងញញឹមដាក់គាត់។ គាត់គិតថា ស្នាមញញឹមនេះបញ្ជាក់ថា ម្តាយគាត់គាំទ្រចំពោះឆន្ទៈតស៊ូប្តូរផ្តាច់របស់គាត់ដើម្បីបុព្វហេតុប្រទេសជាតិ និងប្រជាជន។

ក្នុងអំឡុងពេលទៀ បាញ់ ទៅតស៊ូនៅក្នុងព្រៃដំបូងនោះ មានតាឡុង (ជាឪពុករបស់ឈ្មោះទិត) ជាអ្នកដឹកនាំធំ និងមានវ័យចាស់ជាងគេ ហើយតស៊ូនៅក្នុងព្រៃយូរជាងគេទៀតផង។

លុះដល់ឆ្នាំ១៩៦៦ ពួកគាត់បានទទួលបញ្ជាពីថ្នាក់លើឲ្យភៀសខ្លួនទៅកាន់ប្រទេសថៃ មួយរយៈសិន។ ពេលចូលទៅដល់ទឹកដីប្រទេសថៃ ដំបូង ត្រូវពួកតម្រួតអន្តោប្រវេសន៍ថៃហៅពួកគាត់ទៅសួរនាំថា តើមូលហេតុអ្វី បានជាចូលមកក្នុងទឹកដីប្រទេសថៃ? ពួកគាត់ ក៏ឆ្លើយថា ដោយសាររស់នៅក្នុងប្រទេសខ្មែរ មានជីវភាពលំបាកខ្លាំងពេក ទើបពួកគាត់រត់មកធ្វើការងារនៅប្រទេសថៃ។ តែសំណាងល្អ ដោយសារពួកគាត់ចេះនិយាយភាសាថៃ បានល្អដូចជនជាតិថៃ ផងនោះ ទើបពួកតម្រួតអន្តោប្រវេសន៍ថៃ មិនរករឿងឃាត់ខ្លួនពួកគាត់។ មិនតែប៉ុណ្ណោះ ថៅហ្វាយស្រុកថៃ បានឲ្យប្រាក់ពួកគាត់ម្នាក់ ២០បាត ដើម្បីទិញម្ហូបចំណីទៀតផង។

ក្រោយពេលទទួលបានសិទ្ធិរស់នៅក្នុងប្រទេសថៃ ទៀ បាញ់ បានដូរឈ្មោះមួយទៀតជាភាសាថៃ គឺឈ្មោះប៊ុន ឈួយ ដែលមានន័យជាភាសាខ្មែរថា បុណ្យជួយ។ ពួកគាត់

រស់នៅលើទូក និងប្រកបរបរនេសាទ ដើម្បីចិញ្ចឹមជីវិតផង និងរង់ចាំបញ្ជាពីថ្នាក់លើឱ្យចូលទៅធ្វើសកម្មភាពតស៊ូនៅក្នុងប្រទេស វិញផង។

នៅលើទូកដែលទៀ បាញ់ (ប៊ុន ឈួយ)រស់នៅ មានគ្នា៧នាក់ ក្នុងនោះមានតាឡុតជាអ្នកតស៊ូជើងចាស់ម្នាក់ ដែលបានចូលទៅរស់នៅប្រទេសថៃ មុនគេ ប្រកបមុខរបរជាអ្នកនេសាទ និងជាអ្នកចាំទទួលអ្នកតស៊ូដែលរត់គៀសខ្លួនមកពីក្នុងប្រទេសខ្មែរ។

លុះមកដល់ឆ្នាំ១៩៦៨ ថ្នាក់លើបានបញ្ជាឲ្យពួកគាត់វិលត្រលប់មកកាន់មូលដ្ឋានតស៊ូនៅខេត្តកោះកុង វិញ ដើម្បីធ្វើសង្គ្រាមឈ្លបទូទាំងប្រទេស។

ក្រោយពីនាំគ្នាចូលមកដល់ក្នុងព្រៃតស៊ូនៅឃុំទួលគគីរ វិញ សមមិត្តប្រាសុីត ជាលេខាបក្សតំបន់១១(ខេត្តកោះកុង) បានចាត់តាំងឈ្មោះផាន់ (ជានិស្សិតអ្នកតស៊ូមកពីក្រុងភ្នំពេញ) ជានីរសារ និងជាជំនួយការ ឲ្យចុះមកទាក់ទងស្រាវជ្រាវប្រមូលកម្លាំងតស៊ូរបស់ពួកគាត់ ដើម្បីធ្វើសង្គ្រាមឈ្លបដណ្តើមអាវុធ និងគ្រាប់កាំភ្លើងពីខ្មាំង។

ជាការចាប់ផ្តើមធ្វើសង្គ្រាមឈ្លបដំបូង សមមិត្តប្រាសុីត ហៅតាចុង លេខាបក្សតំបន់១១ (ខេត្តកោះកុង) បានប្រជុំបែងចែកមុខសញ្ញាដើម្បីបើកការវាយប្រហារដណ្តើមកាំភ្លើងពីពួកខ្មាំងសត្រូវ (អាជ្ញាធរភូមិឃុំ ទាហាន ប៉ូលិស កងជីវពល)។ ពេលនោះ យុវជនទៀ បាញ់មានកាំភ្លើងខ្លីផ្ទាល់ខ្លួន១ដើម ដែលគាត់បានទិញពីប្រទេសថៃមក តែអ្នកខ្លះទៀតកាន់កាំភ្លើងវែង អ្នកខ្លះកាន់កាំបិតផ្គាក់ អ្នកខ្លះទៀតកាន់ស្នា និងធ្នូប៉ុណ្ណោះ។

ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៦៨ ទៀ បាញ់ ដឹកនាំកម្លាំង១ក្រុមទៅវាយដណ្តើមកាំភ្លើងពីពួកប៉ូលិសនៅភូមិតាម៉ាន ពួកគាត់នាំគ្នាទៅព័ទ្ធផ្ទះប៉ូលិសម្នាក់ឈ្មោះសៃហ្វ ឈឺន ដកកាំភ្លើង និងកាទុសសៀរ ព្រមទាំងគ្រាប់បែកផ្សេងផងដែរ។

បន្ទាប់មក ពួកគាត់បាននាំគ្នាបន្តដំណើរចូលទៅភូមិទួលគគីរ មានទាហាន៤នាក់ តែពុំមានទាហានណាម្នាក់ ហ៊ានតដៃជាមួយពួកគាត់ឡើយ ព្រោះក្រុមតស៊ូ១ក្រុមទៀតដឹកនាំដោយចា រៀង បានធ្វើសកម្មភាពនៅទីនោះមុនរួចស្រេចទៅហើយ។ ថ្ងៃនោះ កម្លាំងអ្នកតស៊ូនៅតំបន់១១(ខេត្តកោះកុង) គ្រប់មុខសញ្ញាទាំងអស់ វាយដណ្តើមអាវុធ បានចំនួន

៤០ ដើម, គ្រាប់កាំភ្លើង ព្រមទាំងគ្រាប់បែកផ្សែងមួយចំនួន ពីពួកទាហាន និងប៉ូលិសរបស់រាជរដ្ឋាភិបាល។

តែក្រោយពីវាយដណ្ដើមអាវុធនោះមក ពួកទាហានវរសេនាតូចលេខ២២ របស់រាជរដ្ឋាភិបាលនៅខេត្តកោះកុង ក៏បានបើកប្រតិបត្តិការសឹកតាមកម្ទេចពួកគាត់វិញដែរ។ ពេលនោះកម្លាំងពួកគាត់ក៏ចាប់ផ្ដើមបំបែកគ្នា ដោយសមមិត្តប្រាសុីត ហៅតាចុង លេខាបក្សតំបន់១១ ដឹកនាំកម្លាំងមួយផ្នែក ក្នុងនោះមាន នារីមួយចំនួនផង ចូលទៅព្រៃជ្រៅ ដើម្បីគេចពីការតាមកម្ទេចរបស់ពួកទាហាន និងកម្លាំងមួយផ្នែកទៀតសុទ្ធតែជាអ្នកមានកាំភ្លើង ក្នុងនោះមាន ទៀ បាញ់ ម្នាក់ដែរ ត្រូវសំងំនៅក្នុងព្រៃក្បែរៗភូមិតាម៉ាន ដើម្បីចក់ឱកាសធ្វើសកម្មភាពរកស្បៀងផង និងវាយរំខានពួកទាហានវរសេនាតូចលេខ២២ នោះផង។

ពេលនោះ អ្នកបញ្ជារួម គឺតាណាប៉ា និងតារុង ដែលសុទ្ធតែជាអតីតកងទ័ពឥស្សរៈធ្លាប់វាយបារាំងតាំងពីសម័យមុន ក៏បានរៀបចំកម្លាំងជាអង្គភាពកងទ័ពបណ្ដើរៗ។ ទៀ បាញ់ ត្រូវបានចាត់តាំងជាប្រធានក្រុម។

ទៀ បាញ់ បានរម្លឹកថា ព្រឹកមួយ តាណាប៉ា បានដឹកនាំបញ្ជាពួកគាត់ឲ្យវាយប្រយុទ្ធជាមួយទាហានរាជរដ្ឋាភិបាលនៅវាលទទឹង។ ពេលនោះ ពួកគាត់បានសម្លាប់ពួកទាហាន ៤ នាក់ និងចាប់បានទាហានម្នាក់។ ចំណែករូបគាត់វិញ ត្រូវរបួសត្រង់ក និងគ្នាគាត់ម្នាក់ទៀត ជាពូថ្លៃរបស់ តេង ឈួន (បច្ចុប្បន្ន នាយឧត្តមសេនីយ៍ តេង ឈួន រដ្ឋលេខាធិការក្រសួង ការពារជាតិ) ត្រូវរបួសត្រង់ទ្រូង ។

លុះដល់វេលារសៀល នៅវាលវែង កម្លាំងទាហានពួនស្ទាក់នៅតាមព្រៃ បានវាយប្រហារមកលើពួកគាត់ម្ដងទៀត បណ្ដាលឲ្យគ្នាគាត់ម្នាក់ ឈ្មោះ សន ឆៃ ត្រូវរបួសត្រង់ក្បាល។ ដោយសារអត់បាយផង និងមិនអាចប្រយុទ្ធតស៊ូតទៅទៀតបានផង ពួកគាត់ក៏នាំគ្នាអូសអ្នករបួស និងអ្នកជំងឺ ដើម្បីគេចខ្លួន តែត្រូវពួកទាហានពួកស្ទាក់បាញ់នៅយាយសែន ពួកគាត់ក៏នាំគ្នាត្រលប់ចូលព្រៃកខ្សាច់ វិញ។

យប់នោះ ដោយឃ្លានបាយខ្លាំងពេក ពួកគាត់ក៏នាំគ្នាលួចចូលភូមិបេះផ្លែដូង ពួក

ទាហានដឹង ក៏ដេញបាញ់ពួកគាត់ ឱ្យរត់ចេញពីភូមិវិញ។ ព្រឹកឡើង ពួកគាត់ក៏នាំគ្នាចេញពីព្រៃកខ្សាច់ មកស្រែកណ្តាល ក៏បានប្រយុទ្ធគ្នាជាមួយពួកទាហានម្តងទៀត។ ពេលប្រយុទ្ធគ្នានោះ ពួកគាត់បាញ់ងាប់ទាហានពាក់សក្តិ៣ម្នាក់ ទើបពួកគាត់ដកថយចូលព្រៃកខ្សាច់ វិញ។

ដោយសារដាច់ស្បៀងអាហារខ្លាំងពេក ពួកគាត់គ្មានជម្រើសអ្វីក្រៅពីសម្រេចចិត្តវាយទីតាំងទាហានរាជរដ្ឋាភិបាលនៅជ្រោយប្រស់ នោះឡើយ។ ពេលនោះ ពួកគាត់មានគ្នាតែ ៦នាក់។ ពេលយប់ជ្រៅបន្តិច ពន្លឺព្រះច័ន្ទភ្លឺព្រាលៗ ដោយមានតាណាប៉ា ជាអ្នកដឹកនាំពួកគាត់ក៏ចាប់ផ្តើមវាយសំរុកតែម្តង។ លុះភ្លឺឡើង ឃើញពួកទាហានស្លាប់៥នាក់ និង២នាក់ទៀតរត់បាត់។ តែគួរឲ្យស្តាយ ពេលនោះ តាណាប៉ា និងផៃ យ៉ាប់ (ជាអនាគតបងថ្លៃគាត់) ក៏ត្រូវបាត់បង់ជីវិតនៅពេលនោះដែរ។

ការបាត់បង់ជីវិតតាណាប៉ា ជាមេដឹកនាំចលនាតស៊ូសំខាន់ម្នាក់ ធ្វើឱ្យសមមិត្តប្រាសុីត ហៅតាចុង ជាលេខាបក្សតំបន់១១ (ខេត្តកោះកុង) មាន ការសោកស្តាយជាខ្លាំង។

ទៀ បាញ់ បានរម្លឹកបន្តទៀតថា អស់ពីតាណាប៉ាទៅ ការដឹកនាំស្ថិតនៅលើ តារុង, តាឆែម ហៅតាវ៉ន (ជាអនាគតឪពុកក្មេករបស់គាត់) និងរូបគាត់ បានរៀបចំកម្លាំងតូចៗស្ទាក់រថយន្តឈ្នួលនៅតាមផ្លូវជាតិលេខ៤៨ ដើម្បីដោះស្រាយបញ្ហាស្បៀងអាហារតែប៉ុណ្ណោះគឺដាច់ខាត មិនឲ្យប៉ះពាល់ជីវិតមនុស្សឡើយ។ លុះដល់រដូវវស្សា លិចទឹកល្ហល្ហេវ ពួកគាត់ពុំអាចឈរជើងនៅតាមផ្លូវជាតិលេខ៤៨ នោះបាន ពួកគាត់ត្រូវបំបែកកម្លាំងឲ្យទៅរស់នៅជាក្រុមតូចៗ និងឆ្ងាយៗពីគ្នា តែអាចទាក់ទងគ្នាបានតាមរយៈនីរសារ។ ពេលនោះ ពួកគាត់រស់នៅលំបាកវេទនាខ្លាំងណាស់ គ្មានតង់កៅស៊ូជ្រក ពេលភ្លៀងម្តងៗរងាញ័រញាក់ៗ គ្មានសម្លៀកបំពាក់គ្រាន់ផ្លាស់ប្តូរ ពិសេសមិនដែលបានហូបបាយម្តងណាទេ គឺហូបតែបបរលាយគល់ចេកគល់ល្ហុងជាមួយអំបិលតែប៉ុណ្ណោះ។

ក្នុងអំឡុងខែមករា ដល់ខែកុម្ភៈ ឆ្នាំ១៩៦៩ ពួកគាត់ត្រូវរស់នៅចល័តពីភូមិថ្មស, ភូមិតានួន ភូមិព្រៃកស្វាយ រហូតដល់ភូមិសោអ៊ុយ និងដើរបំផុសចលនាបដិវត្តន៍ ដោយពេលខ្លះក្លែងខ្លួនជាអ្នកដើរទិញក្របីផងដែរ។

## របត់នយោបាយ

ដើម្បីបានស្បៀងអាហារ ពួកគាត់បានសម្រេចចិត្តនាំគ្នាចូលទៅក្នុងរោងចក្រអារឈើ ជាកម្មសិទ្ធិរបស់មន្ត្រីជាន់ខ្ពស់ម្នាក់។ ពេលចូលទៅដល់ក្នុងរោងចក្រនោះ ពួកគាត់បានប្រមូលបុគ្គលិករោងចក្រនិងកម្មករទាំងអស់ដាក់មួយកន្លែងរួចដើរចូលទៅក្នុងការិយាល័យរដ្ឋបាល ក៏ឃើញមានតាំងផ្ទាំងរូបថតមនុស្សម្នាក់ មានដាក់អក្សរបញ្ជាក់ឋានៈ និងតួនាទីនៅពីក្រោមថា ញឹក ផុន តំណាងរាស្ត្រ។ ឈ្មោះញឹក ផុន ជាប្អូនបង្កើតរបស់ឧត្តមសេនីយ៍ឯកញឹក ជូឡុង។

បន្ទាប់ពីឃើញផ្ទាំងរូបថតមនុស្សម្នាក់នោះមក គាត់ក៏បានចេញពីការិយាល័យរដ្ឋបាល ត្រលប់ទៅរកឈ្មោះញឹក ផុន នៅកន្លែងប្រមូលផ្តុំបុគ្គលិករោងចក្រ និងកម្មករនោះវិញ។លុះរកឈ្មោះញឹក ផុន ឃើញហើយ គាត់ក៏ជួបពិភាក្សាគ្នា ដោយគាត់ជានាសន្យាថា មិនប្រើកម្លាំងវាយប្រហារលើរោងចក្រអារឈើនេះទេ។ តែម្ចាស់រោងចក្រឈ្មោះញឹក ផុន នេះ ត្រូវជួយផ្តល់អង្ករ, អំបិល, ស្ករត្នោត, ថ្នាំពេទ្យ និងម្ហូបក្រៀមមួយចំនួន ជារៀងរាល់ខែដល់ចលនាតស៊ូរបស់គាត់វិញ។ ពេលនោះ ម្ចាស់រោងចក្រឈ្មោះញឹក ផុន ក៏យល់ព្រម។

ប៉ុន្តែ ក្រោយពីយល់ព្រមផ្តល់ស្បៀងអាហារ និងសម្ភារៈផ្សេងៗបានតែ២លើកប៉ុណ្ណោះ គាត់ទទួលព័ត៌មានមកថា ម្ចាស់រោងចក្រឈ្មោះ ញឹក ផុន បានក្បត់នឹងកិច្ចសន្យា ដោយបានលួចនាំពួកទាហានជាច្រើនមកការពារទីតាំងរោងចក្ររបស់ខ្លួនទៅវិញ។

ក្រោយពីទទួល បានព័ត៌មាននេះ គាត់បានដឹកនាំកម្លាំងវាយប្រហារទៅលើរោងចក្រនេះដែរ តែដោយសារពួកទាហានរាជរដ្ឋាភិបាល មានគ្នាច្រើន និងគ្រឿងសព្វាវុធគ្រាប់រំសេវទំនើបៗ ពួកគាត់មិនអាចវាយប្រហារទៅលើរោងចក្រនោះ ដូចបំណងប្រាថ្នាឡើយ។

នៅរដូវប្រាំង នាឆ្នាំ១៩៦៩ កម្លាំងតស៊ូរបស់គាត់មានគ្នាជាង១០០នាក់ បានចល័តដល់ភូមិតានួន និងតាអុក ដោយពេលខ្លះ ពួកគាត់បានទិញស្រូវ និងក្របីរបស់អ្នកភូមិមកកាប់យកសាច់ធ្វើជាស្បៀងអាហារ។ តែពេលខ្លះ ក៏បានលួចចាប់ក្របីរបស់អ្នកភូមិដែលដើររកស៊ីស្មៅនៅទីឆ្ងាយៗ ទៅកាប់យកទាំងសាច់ទាំងក្បាលទាំងកន្ទុយ ដើម្បីហាលងៀតទុកធ្វើជាស្បៀងអាហារ។

ក្នុងឆ្នាំ១៩៦៩ នោះដែរ តាប្រាសុីត ហៅតាចុង លេខាបក្សតំបន់១១ (ខេត្តកោះកុង)

បានចាត់តាំងគាត់ឱ្យធ្វើជាប្រធានកងការពារ និងរៀបចំកម្លាំង១០នាក់ និងអាវុធមួយចំនួន ដើម្បីជូនដំណើរតាប្រាស៊ីត ពីខេត្តកោះកុង ទៅប្រជុំនៅភូមិជ្រាវ ភ្នំឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដែលជាមូលដ្ឋានតស៊ូរបស់ភូមិភាគនិរតី។

ក្រោយពីសមមិត្តប្រាស៊ីត ហៅតាចុង ប្រជុំរៀនសូត្រនៅភ្នំឱរ៉ាល់នោះ បានរយៈពេលមួយខែ ពួកគាត់ក៏ត្រៀមខ្លួនវិលត្រលប់ទៅខេត្តកោះកុង វិញ។ ពេលនោះ មេដឹកនាំភូមិភាគបានប្រគល់កម្លាំងនៅភ្នំឱរ៉ាល់ នោះ ឲ្យគាត់៣០នាក់បន្ថែមទៀត ហើយកម្លាំង៣០នាក់នោះពុំមែនសុទ្ធតែជាកម្លាំងប្រយុទ្ធទាំងអស់នោះទេ ក្នុងនោះមានម្នាក់ឈ្មោះ ស្ដើង ជានិស្សិតមកពីទីក្រុងភ្នំពេញ មានសមត្ថភាពខ្ពស់ផ្នែកនយោបាយ។

ពេលនោះដែរ មាននារីម្នាក់ឈ្មោះគឿន មានប្ដីធ្វើការនៅស្ថានីយរាជាយស្វ័យយាននៅក្រុងភ្នំពេញ ត្រូវបានចាត់តាំងជាបុគ្គលិកពេទ្យ។ ក្រៅពីនោះមានឈ្មោះវី, ឈ្មោះរឿន និងឈ្មោះផាន់ ដែលសុទ្ធតែជាពួកអនុជន បញ្ញាជនអ្នកចេះដឹងផងដែរ។

មុនដំបូង មេដឹកនាំភូមិភាគ បានផ្ដល់កាំភ្លើងអាកា-៤៧(AK-47)មកឱ្យពួកគាត់ចំនួន ៥ដើម តែក្រោយមក មេដឹកនាំភូមិភាគ ក៏សុំប្ដូរជាកាំភ្លើងកាប៊ីនថ្មីៗ ចំនួន៣០ដើម និងគ្រាប់ជាច្រើនទៀត ជំនួសកាំភ្លើងអាកា-៤៧(AK-47) ចំនួន៥ដើមនោះវិញ។ ក្រោយពីបានទទួលកម្លាំងបន្ថែម ចំនួន៣០នាក់ និងបំពាក់អាវុធយ៉ាងច្រើននោះមក គាត់មានការរំភើបរីករាយ និងកាន់តែមានស្មារតីប្រយុទ្ធកាន់តែខ្លាំងក្លាថែមទៀត។

ពីខែធ្នូ ឆ្នាំ១៩៦៩ ដល់ដើមឆ្នាំ១៩៧០ នៅភ្នំឱរ៉ាល់ ធាតុអាកាសត្រជាក់ ខ្លាំងណាស់ ពួកគាត់ត្រូវចំណាយពេលអស់២៥ថ្ងៃ ធ្វើដំណើរកាត់ព្រៃ និងបានវាយប្រយុទ្ធគ្នាជាច្រើនលើក ជាមួយទាហានរាជរដ្ឋាភិបាលផងដែរ ទើបទៅដល់មូលដ្ឋានតស៊ូរបស់ពួកគាត់ នៅខេត្តកោះកុង វិញ។

# ២៤៣
# ខ្មែរក្រហមធ្វើសង្គ្រាមឈ្លប សម្តេចសីហនុ ឲ្យទាហានចេញបង្ក្រាប



**សម្តេចសីហនុ ចុះសួរសុខទុក្ខទាហាន និងប្រជាពលរដ្ឋ ដែលពួកខ្មែរក្រហមបាញ់ឲ្យរងរបួស**

យប់ថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៦៨ វិទ្យុក្រុងភ្នំពេញ បានផ្សាយថា៖ មានពួកឧទ្ទាមខ្មែរក្រហមប្រមាណ៣០០នាក់ បានចូលមកអុកឡុកក្នុងភូមិចំនួន៣ នៅក្នុងស្រុកបារាយណ៍ (ខេត្តកំពង់ធំ) ហើយបានសម្លាប់ប្រជាកសិករជាអ្នកភូមិអស់ចំនួន ៧នាក់ ។

ការចាប់ផ្តើមសម្លាប់ប្រជាកសិករនេះ ត្រូវបានគេសង្ស័យថា ជាទង្វើរបស់មេខ្មែរក្រហម ឈ្មោះកែ ពក ជាអនុលេខាគណៈកម្មាធិការបក្សភូមិភាគឧត្តរ ។

នៅខេត្តកំពង់ចាម ញៀន ធៀង ជាចៅហ្វាយខេត្តនេះ ក៏បានបញ្ជាឱ្យពួកទាហាន

ប៉ូលិសនៅក្រោមឱវាទរបស់គាត់ តាមចាប់ជនទាំងឡាយណាដែលសង្ស័យថា ជាពួកខ្មែរក្រហមយ៉ាងសកម្មដែរ។

ជនសង្ស័យម្នាក់ ឈ្មោះម៉ុន ត្រូវជាមិត្តភក្តិជិតស្និទ្ធរបស់សោ ភឹម លេខាគណៈកម្មាធិការបក្សភូមិភាគបូព៌ា ត្រូវកម្លាំងអាជ្ញាធរខេត្តចាប់ខ្លួនបាននៅកណ្តោលជ្រុំ ស្រុកពញាក្រែក ហើយនាំយកទៅក្នុងព្រៃបុះ ដើម្បីឱ្យប្រាប់ពីកន្លែងលាក់ខ្លួនរបស់សោ ភឹម តែរកមិនឃើញ។ ឆ្លៀតឱកាសនោះ ឈ្មោះម៉ុន ក៏រត់គេចខ្លួនចូលព្រៃ តែត្រូវកម្លាំងទាហាន-ប៉ូលិស តាមរុករកចាប់បានវិញ រួចយកទៅកាត់ក្បាល និងវះពោះយ៉ាងសាហាវឃោរឃៅបំផុត។

នៅជ្រៃវៀន ស្រុកព្រៃឈរ ដែលជាមណ្ឌលហ៊ូ នឹម ធ្លាប់ជាប់ឆ្នោតធ្វើតំណាងរាស្ត្រ២អាណត្តិនោះ ក៏មានលេចឮថា ក្មេងប្រុសជំទង់២នាក់ ត្រូវកម្លាំងអាជ្ញាធរចាប់ខ្លួនយកទៅអារកនឹងជាងត្នោត ដោយសារសង្ស័យក្មេងប្រុសទាំងនេះជានីរសារ (អ្នកនាំសំបុត្រ) របស់ពួកខ្មែរក្រហម។

ប្រភពព័ត៌មានមួយទៀត បានអះអាងថា នៅខេត្តកំពត គ្រូបង្រៀនចំនួន៣០នាក់ ដែលគេសង្ស័យថា ជាប់ពាក់ព័ន្ធជាមួយពួកខ្មែរក្រហម ព្រោះនាំគ្នាដើរឃោសនាប្រឆាំងនឹងសម្តេចសីហនុ ត្រូវព្រះអង្គបញ្ជាឱ្យគេចងដៃចងជើង ដឹកយកទៅទម្លាក់ចោលពីលើកំពូលភ្នំបូកគោ។

នៅក្នុងខែមិថុនា ឆ្នាំ១៩៦៨ តំណាងរាស្ត្រម្នាក់នៅក្នុងមណ្ឌលមួយនៃខេត្តកំពង់ស្ពឺ ក៏បានធ្វើការរិះគន់ថា ប្រជារាស្ត្រគ្មានទោសពៃរ៍អ្វីសោះ គ្រាន់តែសង្ស័យថា ជាពួកខ្មែរក្រហម ត្រូវគេចាប់យកទៅសម្លាប់ចោលដែរ។ តំណាងរាស្ត្រនោះចាត់ទុកថា ទង្វើនេះគឺជាការប្រព្រឹត្តផ្ទុយពីរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា និងច្បាប់អន្តរជាតិ ។

ជាមួយយុទ្ធនាការបង្ក្រាបចលនាខ្មែរក្រហមដ៏ក្តៅគគុកនេះ សម្តេចសីហនុ ក៏បានរៀបចំឱ្យមានបាតុកម្មប្រឆាំងនឹងពួកខ្មែរក្រហម ព្រមទាំងខ្មែរសេរីរបស់សឺង ង៉ុកថាញ់ ផងដែរ តែពួកមន្ត្រីស្តាំនិយម ( ពួកមន្ត្រីលម្អៀងទៅខាងអាមេរិក ) ក៏ឆ្លៀតឱកាសទូលព្រះអង្គថា ចិន និងពួកវៀតកុង-វៀតណាមខាងជើង ជាអ្នកជួយគាំទ្រសកម្មភាពរបស់ពួកខ្មែរក្រហម។

ព្រះអង្គក៏ចាប់ផ្តើមចោទសួរជាសាធារណៈថា មិត្តចិន និងមិត្តវៀតណាមរបស់ព្រះអង្គ ពិតជាបានគាំទ្រពួកខ្មែរក្រហមមែនដែរឬទេ? ហើយព្រះអង្គបានស្នើសុំឱ្យគណៈកម្មាធិការត្រួតពិនិត្យអន្តរជាតិ ចូលមកស៊ើបអង្កេតពីរឿងពួកវៀតកុង-វៀតណាមខាងជើង ដែលថាបានរំលោភបំពានបូរណភាពទឹកដីកម្ពុជា ផងដែរ។ តែការពិត ព្រះអង្គប្រាកដជាបានដឹងរឿងនេះអស់ទៅហើយ។

ពេលនោះដែរ ប្រភពស៊ើបការណ៍សម្ងាត់របស់សហរដ្ឋអាមេរិក បានរាយការណ៍មកពីទីក្រុងព្រៃនគរថា កងទ័ពវៀតកុង-វៀតណាមខាងជើង បានបង្កើនការប្រើប្រាស់ទឹកដីកម្ពុជាធ្វើជាកន្លែងប្រមូលផ្តុំកងទ័ពកាន់តែច្រើនឡើងៗ។

ប្រភពដដែលបានបញ្ជាក់ថា អាវុធ និងគ្រាប់រំសេវថ្មីៗ ត្រូវបានគេដឹកជញ្ជូនតាមរថយន្តគ្របដំបូលជិតរបស់ទាហានរាជរដ្ឋាភិបាលកម្ពុជា យកទៅឱ្យពួកវៀតកុង-វៀតណាមខាងជើងដែលនៅក្នុងទឹកដីកម្ពុជា។ ចាប់ពីខែវិច្ឆិកា ឆ្នាំ១៩៦៧ ការដឹកជញ្ជូនអាវុធគ្រាប់រំសេវទៅព្រំដែនខាងកើតនេះ បានកើនឡើងមួយទ្វេជាបី ហើយឥឡូវនេះកងទ័ពវៀតកុង-វៀតណាមខាងជើង មានឃ្លាំងសម្រាប់ដាក់អាវុធគ្រាប់រំសេវ, មានមន្ទីរពេទ្យ, មានកន្លែងឃុំឃាំងឈ្លើយសឹក, មានឃ្លាំងផ្ទុកស្បៀងអាហារ និងមានកន្លែងហ្វឹកហ្វឺនកងទ័ពទៀតផង។

ប្រភពស៊ើបការណ៍សម្ងាត់នេះ បានឱ្យដឹងទៀតថា កងទ័ពវៀតកុង-វៀតណាមខាងជើងបានធ្វើដំណើរចុះឡើង កាត់ពីមុខពួកទាហានរាជរដ្ឋាភិបាលកម្ពុជា ដោយគ្មានបញ្ហាអ្វីបន្តិចឡើយ ហើយថ្ងៃមួយមាននាយទាហានជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាម្នាក់ មានឋានន្តរសក្តិជាវរសេនីយ៍ត្រី បានបើករថយន្តហ្សេអឹមសេកង់១០ ដឹកអាវុធយកទៅលក់ឱ្យពួកវៀតកុង-វៀតណាមខាងជើង នោះទៀតផង។ ប៉ុន្តែសម្តេចសីហនុ បែរជាមានបន្ទូលថា ព្រះអង្គមិនបានដឹងពីរឿងកងទ័ពវៀតកុង-វៀតណាមខាងជើង មកបោះទីតាំងនៅក្នុងទឹកដីរបស់ព្រះអង្គទេ។

ជាមួយគ្នានេះ ប្រភពស៊ើបការណ៍របស់អាមេរិក ប្រចាំនៅទីក្រុងព្រៃនគរ ប្រទេសវៀតណាមខាងត្បូង ក៏បានឱ្យដឹងថា នៅដើមខែឧសភា នៅតំបន់បាធូ (ព្រំដែនកម្ពុជា និង



**កន្លែងហ្វឹកហ្វឺនកងទ័ពវៀតកុង នៅក្នុងព្រៃ**

វៀតណាមខាងត្បូង) កងវរសេនាតូចលេខ៣០៨ របស់កងទ័ពវៀតកុង-វៀតណាមខាងជើង បានឆ្លងព្រំដែនចូលទៅក្នុងទឹកដីកម្ពុជា ដោយដើរកាត់ព្រៃឫស្សី រហូតដល់ផ្លូវលំតូចមួយ មានផ្ទះតៀមប្រក់ស្លឹកតូចៗរបស់ជនជាតិវៀតណាម ជាជនស៊ីវិលដែលស្មោះត្រង់ជាមួយពួកកុម្មុយនិស្ត ជាច្រើនខ្នងនៅអមសង មានទាំងតៀមលក់កាហ្វេផងដែរ។ ជនជាតិវៀតណាមទាំងនោះ បានភៀសខ្លួនមកពីក្នុងទឹកដីវៀតណាមខាងត្បូង មកតាំងលំនៅនៅទីនោះ ដើម្បីរួមចំណែកតស៊ូជាមួយកងទ័ពវៀតកុង-វៀតណាមខាងជើង។

ពេលនោះ មានរទេះគោជាច្រើនគ្រឿង ដឹកកាំភ្លើងអាកា៤៧ (AK-47) ផលិតនៅប្រទេសសូវៀត និងកាំភ្លើងបាញ់គ្រាប់រ៉ុក្កែត មកពីភូមិត្រពាំងរុន និងមានរទេះគោដឹកគ្រាប់កាំភ្លើងត្បាល់ និងគ្រាប់បែកជាច្រើនទៀត មកពីភូមិសេដ្ឋា ដែលជាភូមិរបស់កម្ពុជា ក៏បានមកដល់ទីនោះដែរ។

ការគប់គិតគ្នាឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ចូលមកបោះទីតាំងនៅក្នុងទឹកដីកម្ពុជានេះ ក៏ធ្វើឱ្យប្រជារាស្ត្រខ្មែរដែលរស់នៅតាមតំបន់ព្រំដែន មានការរងទុក្ខវេទនាខ្លាំង



**កងឧទ្ធម្ភាគចក្ររបស់សហរដ្ឋអាមេរិក**
**តាមរុករកពួកវៀតកុង នៅតាមបឹងបួ**

ណាស់ដែរ។

អ្នកឆ្លើយឆ្លងព័ត៌មានបរទេសម្នាក់ បានរាយការណ៍ថា នៅភូមិព្រៃទួល ឃុំដូង ស្រុករមាសហែក ខេត្តស្វាយរៀង ប្រជារាស្ត្រខ្មែរមានការខឹងសម្បានឹងកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលចូលមកបោះទីតាំងឈរជើងនៅលើទឹកដីភូមិឃុំរបស់ពួកគាត់កាន់តែច្រើនឡើងៗជាលំដាប់។

អ្នកភូមិនិយាយថា ឥឡូវនេះ គេមិនបាច់សង្ស័យអ្វីទៀតទេ គឺកងទ័ពវៀតកុង-វៀតណាមខាងជើង បានធ្វើដំណើរឆ្លងកាត់ និងបោះទីតាំងឈរជើងនៅលើទឹកដីកម្ពុជា ពេញបន្ទុកហើយ។ ពួកអ្នកការទូត និងអ្នកសង្កេតការណ៍មកពីគ្រប់មជ្ឈដ្ឋាន បាននិយាយជាសាធារណៈថា កងទ័ពវៀតកុង-វៀតណាមខាងជើង ជាច្រើនកងពលធំ កំពុងបោះទីតាំងឈរជើងនៅលើទឹកដីកម្ពុជា។ ប្រភពដដែលបានបន្តថា ដោយសារវត្តមានកងទ័ពវៀតកុង-វៀតណាមខាងជើង ដ៏ច្រើនសន្ធឹកសន្ធាប់នោះហើយ ទើបកងទ័ពរដ្ឋការវៀតណាមខាងត្បូង និងកងទ័ពសហរដ្ឋអាមេរិក ដេញតាមវាយកម្ទេច ធ្វើឱ្យប្រជារាស្ត្រកម្ពុជា ដែលរស់នៅតាមបណ្តោយ

ព្រំដែន រងទុក្ខវេទនាឥតស្រាកស្រាន្ត។

នៅដើមខែវិច្ឆិកា ឆ្នាំ១៩៦៨ ជាមួយនឹងការដាក់ក័ស្តុតាងបង្ហាញចំពោះក្រុមអ្នកកាសែតជាតិ និងអន្តរជាតិ ព្រមទាំងគណៈកម្មការត្រួតត្រាអន្តរជាតិ (ICC) ដែលរួមមានតំណាងមកពីប្រទេសឥណ្ឌា ប៉ូឡូញ និងកាណាដានោះ មន្ត្រីរាជរដ្ឋាភិបាលកម្ពុជា បានថ្លែងថា នៅយប់ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៦៨ កងឧទ្ធម្ភាគចក្ររបស់វៀតណាមខាងត្បូង និងសហរដ្ឋអាមេរិក ជាច្រើនគ្រឿង បានបើកការវាយប្រហារមកលើភូមិព្រៃទួល (ស្រុករមាសហែក ខេត្តស្វាយរៀង) បណ្តាលឱ្យប្រជារាស្ត្រខ្មែររស់នៅភូមិនោះស្លាប់ម្នាក់ និងរបួស២៣នាក់។

មន្ត្រីរាជរដ្ឋាភិបាលកម្ពុជាដដែល បានបញ្ជាក់ថា នេះជាការរំលោភឈ្លានពាន មិនអាចប្រកែកបានពីសំណាក់កងទ័ពវៀតណាមខាងត្បូង និងសហរដ្ឋអាមេរិក មកលើបូរណភាពទឹកដីកម្ពុជា ក៏ដូចជាការបង្កសោកនាដកម្មចំពោះមនុស្សជាតិ ផងដែរ។

ប៉ុន្មានថ្ងៃក្រោយមក សម្តេចសីហនុ ក៏បានចេញសេចក្តីប្រកាសមួយ ដើម្បីឆ្លើយតបចំពោះផែនការរកដំណោះស្រាយសន្តិភាពរបស់ រ៉ាស្ក (Rusk) រដ្ឋមន្ត្រីការបរទេសរបស់អាមេរិក ដែលបានលើកឡើងកាលថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៦៨។

ផែនការសន្តិភាពនោះ គឺរ៉ាស្ក(Rusk) រដ្ឋមន្ត្រីការបរទេសរបស់អាមេរិក បានស្នើទៅភាគីវៀតណាមខាងជើង ឱ្យធ្វើការចរចាគ្នា ដើម្បីរកដំណោះស្រាយសន្តិភាពនៅតំបន់អាស៊ីអាគ្នេយ៍ឡើងវិញ និងឈប់ជួយពួកខ្មែរក្រហមទៀត ។

សម្តេចសីហនុ បានប្រកាសថា កម្ពុជា ជារដ្ឋមានអធិបតេយ្យភាព ដែលអាចតទល់ដោយខ្លួនឯង ក្នុងការប្រឆាំងរាល់សកម្មភាពវិទ្ធង្សនាពីពួកបរទេស ទោះបីពួកបរទេសនោះមកពីទីណាក៏ដោយ។ ដូច្នេះ ដើម្បីធានាដល់ការការពារសន្តិសុខផ្ទៃក្នុងរបស់ខ្លួន កម្ពុជាមិនចាំបាច់ត្រូវការរ៉ាស្ក(Rusk) ឬអាមេរិកនោះឡើយ ហើយថា សេចក្តីប្រកាសទាំងប៉ុន្មានរបស់រ៉ាស្ក(Rusk)គ្រាន់តែជាការឃោសនាបំភ្លៃប៉ុណ្ណោះ។ ការពិត រ៉ាស្ក(Rusk) រដ្ឋមន្ត្រីការបរទេសរបស់អាមេរិក បានចូលជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋឯករាជ្យ និងអធិបតេយ្យភាពមួយនេះរួចទៅហើយ ។

## របត់នយោបាយ

ចុងក្រោយនៃសេចក្ដីប្រកាសនោះ សម្ដេចសីហនុ បានសង្កត់ធ្ងន់ថា គ្រោះថ្នាក់ចម្បង បង្អស់របស់កម្ពុជា មិនមែនដោយសារមកពីការធ្វើវិទ្ធង្សនារបស់ពួកកុម្មុយនិស្តទេ គឺដោយសារ ការឈ្លានពានរបស់កងទ័ពអាមេរិក និងវៀតណាមខាងត្បូង ដែលកំពុងទទួលបរាជ័យហើយ បរាជ័យទៀត។

អ្នកវិភាគនយោបាយបរទេសខ្លះ យល់ថា ការដែលសម្ដេចសីហនុ ហ៊ានចេញសេចក្ដី ប្រកាសបែបនេះ ប្រហែលជាព្រះអង្គឈ្វេងយល់ថា អាមេរិក នឹងដកកងទ័ពរបស់ខ្លួនចេញពី វៀតណាមខាងត្បូង នៅពេលចរចាសន្តិភាព ដែលគ្រោងធ្វើនៅពេលដ៏ខ្លីខាងមុខនេះ ជាមិនខាន ហើយក្រោយពីរបបរដ្ឋការក្រុងព្រៃនគរ ដែលព្រះអង្គចាត់ទុកថា ជារបបអាយ៉ងរបស់អាមេរិក ដួលរលំទៅ ព្រះអង្គនឹងនៅតែកាន់អំណាច ដោយសុខសាន្តជាមួយនឹងពួកវៀតណាមកុម្មុយ-និស្ត ដែលនឹងឡើងទៅដឹកនាំប្រទេសវៀតណាមខាងត្បូង នោះ។

# ២៤៤
# ទាហានរាជរដ្ឋាភិបាល បោសសម្អាតពួកខ្មែរក្រហម, ប៉ះទង្គិចគ្នាជាមួយពួកវៀតកុង



**សម្តេចសីហនុ ថតជាមួយនាយទាហានជាន់ខ្ពស់របស់ព្រះអង្គនៅ ខេត្តរតនគិរី ក្នុងខែមករា ឆ្នាំ១៩៦៨**

នៅក្នុងខែសីហា ឆ្នាំ១៩៦៨ នៅទីក្រុងភ្នំពេញ ពេលយប់ស្ងាត់ មានជនអនាមិក បានដើរបាញ់កាំភ្លើងនៅតាមផ្លូវមួយចំនួននៅកណ្តាលទីក្រុងភ្នំពេញ បង្កឱ្យមានការចលាចល។ កម្លាំងសមត្ថកិច្ចក៏បានចាប់ខ្លួនសកម្មជនរបស់ចលនាតស៊ូខ្មែរក្រហម៤០នាក់ ក្នុង

នោះភាគច្រើន ជាសិស្ស និងជាមន្ត្រីរាជការ ដែលបានធ្វើសកម្មភាពឃោសនានយោបាយនៅក្នុងមជ្ឈដ្ឋានកម្មករ និងខ្លះទៀតដើរបាចខិត្តប័ណ្ណ។

ប្រភពព័ត៌មានមួយទៀតបានឱ្យដឹងថា មេខ្មែរក្រហម ដែលដឹកនាំឱ្យធ្វើសកម្មភាពបង្កចលាចល នោះ ឈ្មោះគៀវ ហាក់ ហើយមិនយូរប៉ុន្មាន កម្លាំងសមត្ថកិច្ចក៏ចាប់ជនឈ្មោះគៀវ ហាក់ នេះបាន រួចហើយក៏បាត់ខ្លួនសូន្យឈឹងតាំងពីពេលនោះមក។

នៅក្នុងខែកក្កដា មេខ្មែរក្រហម ថ្នាក់សមាជិកគណៈកម្មាធិការមជ្ឈិមបក្សម្នាក់ទៀត ឈ្មោះវន វ៉េត មានឈ្មោះដើមថា ពេញ ធួក ឬសុក ធួក ដែលល្បីថា ពូកែខាងញុះញង់បំផុសឱ្យសិស្សនិស្សិតធ្វើបាតុកម្មប្រឆាំងរាជរដ្ឋាភិបាល និងសម្តេចសីហនុ នោះ ក៏ត្រូវកម្លាំងសមត្ថ-កិច្ចតាមរកចាប់ខ្លួនដែរ។

ពេលនោះមានខ្សែរយៈខ្មែរក្រហមម្នាក់ ឈ្មោះកាក់ ស៊ីម បានយកវន វ៉េត ទៅលាក់ទុកនៅក្នុងផ្ទះរបស់ខ្លួន។ តែពួកប៉ូលិសរបស់សម្តេចសីហនុ តាមរកឃើញ។ ពេលនោះឈ្មោះកាក់ ស៊ីម មានកាំភ្លើងខ្លីនៅជាប់នឹងខ្លួន ក៏បានបាញ់ពួកប៉ូលិសនោះឱ្យរងរបួសម្នាក់ និងស្លាប់ម្នាក់ ទើបរត់ទៅប្រាប់ប្រពន្ធវន វ៉េត ឱ្យទៅជម្លៀសខៀវ ប៉ុណ្ណារី ជាប្រពន្ធរបស់សាឡុត ស ចេញពីក្រុងភ្នំពេញ ដើម្បីទៅជួបសាឡុត ស ជាប្តីនៅក្នុងព្រៃតស៊ូ។

នៅដើមខែកញ្ញា ឆ្នាំ១៩៦៨ ខ្សែរយៈខ្មែរក្រហមឈ្មោះ កាក់ ស៊ីម នោះ ត្រូវពួកប៉ូលិសតាមរកឃើញ និងបាញ់សម្លាប់ភ្លាមៗ ដោយមិនចាំបាច់បញ្ជូនទៅឱ្យតុលាការសឹកកាត់ទោសឡើយ ហើយអ្នករួមធ្វើសកម្មភាពជាមួយគាត់៦ នាក់ទៀត ក៏ត្រូវសម្លាប់ចោល ខណៈគ្រូបង្រៀនជាង១០នាក់ ក៏ត្រូវប៉ូលិសចាប់ដាក់ពន្ធនាគារដែរ។

ចំណែកនៅភូមិភាគបូព៌ាវិញ បណ្តាញខ្មែរក្រហម ឈ្មោះហេង សំរិន នៅស្រុកពញាក្រែក ខេត្តកំពង់ចាម ព្រមទាំងជា ស៊ីម និងប្រុក សារី នៅក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង បាននាំគ្នារត់ចូលព្រៃតាំងពីឆ្នាំ១៩៦៧ មកម្ល៉េះ។

នៅឆ្នាំ១៩៦៨ អតីតព្រះសង្ឃឈ្មោះគង់ សូតន់ ហៅទុយ ជាសកម្មជនខ្មែរក្រហមម្នាក់ នៅក្នុងស្រុកកំចាយមារ ខេត្តព្រៃវែងនោះ ក៏បានសម្រេចចិត្តរត់ចូលព្រៃដែរ ព្រោះឃើញ

ពួកប៉ូលិសរាជរដ្ឋាភិបាល ចេះតែមកប្រវើលក្បែរៗផ្ទះគាត់។

សោ ភឹម លេខាគណៈកម្មាធិការបក្សភូមិភាគបូព៌ា និងសយ ស៊ីសាផុន ហៅភួង ជាអនុលេខា ព្រមទាំងកម្មាភិបាលជាច្រើនទៀត បាននាំគ្នាទៅរស់នៅក្រោមការគ្រប់គ្រងរបស់កងទ័ពវៀតកុង-វៀតណាមខាងជើង ក្នុងទឹកដីវៀតណាម ក្បែរព្រំដែនកម្ពុជា ។

របាយការណ៍មួយបានសរសេរថា ពេលនោះ សោ ភឹម បើកវគ្គរៀនសូត្រ ដោយឧទ្ទេសនាមពីសភាពការណ៍នយោបាយ និងការតស៊ូធ្វើបដិវត្តន៍ យុទ្ធសាស្ត្រ និងយុទ្ធវិធីនៃការធ្វើសង្គ្រាមឈ្លបដល់ពួកកម្មាភិបាលដែលស្ថិតនៅក្រោមការដឹកនាំរបស់គាត់ និងបញ្ជាក់ពីសហប្រតិបត្តិការជាមួយវៀតណាម ប្រឆាំងនឹងពួកចក្រពត្តិនិយមអាមេរិក ដោយមានដាក់តាំងរូបថតកាល់ម៉ាក្ស ឡេនីន និងហូ ជីមិញ នៅកន្លែងប្រជុំរៀនសូត្រនោះទៀតផង ។

សួស នៅ ហៅសមមិត្តឈូក ក៏បានចូលរៀនសូត្រក្នុងវគ្គនោះដែរ។ ឈូក បានចូលរួមក្នុងចលនាតស៊ូតាំងពីឆ្នាំ១៩៤៩ មកម្ល៉េះ ហើយសកម្មក្នុងការបាចខិត្តប័ណ្ណ និងបំផុសឱ្យសិស្សធ្វើបាតុកម្មប្រឆាំងនឹងស្ថានទូតសហរដ្ឋអាមេរិក កាលពីឆ្នាំ១៩៦៤ និង ១៩៦៥។

នៅចុងឆ្នាំ១៩៦៥ ដដែលនោះ គាត់ត្រូវបានថ្នាក់លើចាត់តាំងឱ្យទៅធ្វើសកម្មភាពបដិវត្តន៍នៅស្រុកព្រះស្តេច ខេត្តព្រៃវែង។

នៅក្នុងវគ្គរៀនសូត្រនោះ ក៏មានមេខ្មែរក្រហមម្នាក់ទៀត ឈ្មោះចាន់ ចក្រី ហៅសមមិត្តមាន ដែលបានសុំចុះចូលជាមួយទាហានរាជរដ្ឋាភិបាល កាលបើកយុទ្ធនាការបង្ក្រាបពួកខ្មែរក្រហមនៅតំបន់សំឡូត ខេត្តបាត់ដំបង នៅក្នុងឆ្នាំ១៩៦៧ ហើយបានរត់គេចខ្លួនមកចូលព្រៃនៅក្នុងខេត្តព្រៃវែង ដើម្បីធ្វើការតស៊ូបន្តទៀត។

នៅតំបែរ និងគោកស្រុក ខេត្តកំពង់ចាម នៅប៉ែកខាងជើងផ្លូវជាតិលេខ៧ ពួកខ្មែរក្រហមមានកងទ័ពតែ៣០នាក់ប៉ុណ្ណោះ ដឹកនាំដោយ សយ ស៊ីសាផុន ហៅសមមិត្តភួង (អនុលេខាបក្សភូមិភាគ) និងមាស សេងហុង ហៅសមមិត្តចាន់ (លេខាបក្សតំបន់២១)។ ចំណែកនៅព្រៃក្របៅ ក្នុងស្រុកកំចាយមារ តំបន់២០) មានគ្នា៩០នាក់ ដឹកនាំផ្ទាល់ដោយ សោ ភឹម លេខាគណៈកម្មាធិការបក្សភូមិភាគ។

ពេលនោះ សោ ភឹម បានស្នើសុំពួកមេដឹកនាំវៀតកុង-វៀតណាមខាងជើង ជួយផ្តល់អាវុធ និងគ្រាប់រំសេវ មកឱ្យពួកគាត់ ដើម្បីធ្វើសង្គ្រាមឈ្លបប្រឆាំងនឹងរាជរដ្ឋាភិបាលដែរ តែពួកមេដឹកនាំវៀតកុង-វៀតណាមខាងជើង បានប្រាប់ សោ ភឹម ថា សមមិត្តមិនគួរធ្វើការប្រយុទ្ធនៅពេលនោះទេ ហើយក៏មិនគួរសុំអាវុធពីយើងដែរ។ សមមិត្តគួរតែរង់ចាំដល់ពេលយើងទទួលបានជ័យជម្នះទាំងស្រុងសិន ចាំចាប់ផ្តើមប្រយុទ្ធ។

នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៦៨ ជាថ្ងៃប្រារព្ធខួបឆ្នាំទី១៥ នៃពិធីបុណ្យឯករាជ្យជាតិ នៅទីក្រុងភ្នំពេញ គេពុំឃើញមានការហែក្បួនទាហានគ្រប់ប្រភេទ កងកាំភ្លើងធំ កងរថក្រោះរថពាសដែក ឱ្យគគ្រឹកគគ្រេងដូចបណ្តាឆ្នាំកន្លងមកទេ ព្រោះពួកទាហានសរុបដែលមាននៅក្នុងប្រទេសកម្ពុជា ប្រមាណ៣៥០០០ នាក់នោះ ត្រូវបញ្ជាឱ្យចេញទៅបើកប្រតិបត្តិការសឹកបោសសម្អាតពួកឧទ្ទាមខ្មែរក្រហម នៅតាមបណ្តាខេត្តនានាទូទាំងប្រទេស។

ទន្ទឹមគ្នានោះ នៅប៉ែកខាងត្បូង និងខាងជើងប្រទេស ក៏មានសេចក្តីរាយការណ៍មកថា មានការប៉ះទង្គិចគ្នា រវាងទាហានរាជរដ្ឋាភិបាល ជាមួយកងទ័ពវៀតកុង-វៀតណាមខាងជើង ហើយរាជរដ្ឋាភិបាល ក៏បានប្រកាសពីរឿងប៉ះទង្គិចគ្នានេះដែរ។

ទីភ្នាក់ងារព័ត៌មានខ្មែរ (AKP) បានដកស្រង់សេចក្តីប្រកាសរបស់ក្រសួងការពារជាតិថា ពួកយួនប្រដាប់អាវុធ (កងទ័ពវៀតកុង-វៀតណាមខាងជើង) ដែលបោះទីតាំង នៅក្នុងភូមិចំនួន៩ នៅខេត្តស្វាយរៀង បានបង្កឲ្យមានការប្រទូសរ៉ាយគ្នាជាមួយអាជ្ញាធរស្រុក- ខេត្ត និងប្រជារាស្ត្រនៅទីនោះ កាន់តែខ្លាំងក្លាជាងពេលមុនៗ ពិសេស គឺនៅតំបន់ចំពុះទា ហើយថា កាលពីពេលថ្មីៗនេះ ទាហានរាជរដ្ឋាភិបាលបានប្រយុទ្ធគ្នាជាមួយកងទ័ពវៀតកុង- វៀតណាមខាងជើងទាំងនោះ ដោយបានសម្លាប់ពួកគេ ៥នាក់ និងបាញ់ឲ្យរងរបួស៧នាក់ទៀត។

សម្តេចសីហនុ ក៏មានបន្ទូលដែរថា ពួកយួនកុម្មុយនិស្ត(កងទ័ពវៀតកុង-វៀតណាមខាងជើង) កំពុងកាន់កាប់ចំណែកខ្លះនៃទឹកដីកម្ពុជា។ ពួកគេកំពុងតែជ្រៀតចូល ហើយយើងកំពុងខ្វះកម្លាំងដើម្បីទៅការពារ និងត្រួតពិនិត្យមើលពួកគេនៅតាមតំបន់ដែលគ្របដណ្តប់ដោយព្រៃក្រាស់។ ពួកគេបានបង្ខំឱ្យពួកខ្មែរលើ(ជនជាតិភាគតិច) នៅខេត្តរតនគិរី ពួនស្ទាក់

វាយប្រហារមកលើទាហានយើង ហើយពួកគេបានប្រកាសថា ទឹកដីដែលពួកគេកំពុងឈរជើងនោះ មិនមែនជាទឹកដីខ្មែរទៀតផង។

តែទោះបីយ៉ាងនេះក៏ដោយ ក៏សម្តេចសីហនុ បញ្ជាក់ថា ព្រះអង្គមិនត្រូវការវត្តមានកងទ័ពសហរដ្ឋអាមេរិក លើទឹកដីខ្មែរទេ។ ប៉ុន្តែ ព្រះអង្គក៏មិនជំទាស់ចំពោះវត្តមានកងទ័ពរបស់ប្រទេសមហាអំណាចមួយនេះ ទៅលើទឹកដីប្រទេសថៃ ហ្វីលីពីន និងជប៉ុនដែរ ហើយព្រះអង្គបានព្រលយបន្ទូលទៀតថា បើក្រុងហាណូយ និងពួកវៀតកុង បំពានលើភាពស្មោះត្រង់របស់ខ្លួននោះ ព្រះអង្គនឹងអំពាវនាវរកជំនួយពីសហរដ្ឋអាមេរិក។

នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៦៨ កាសែតអេភី(AP)របស់សហរដ្ឋអាមេរិក បានចុះផ្សាយពីការកើនឡើងនៃសកម្មភាពរបស់ពួកឧទ្ទាមខ្មែរក្រហម ដែលធ្វើឱ្យរាជរដ្ឋាភិបាលភ្នំពេញ មានការព្រួយបារម្ភខ្លាំងថែមទៀត។ ពួកឧទ្ទាមបានធ្វើកម្មភាពក្នុងខេត្ត១១ ក្នុងចំណោមខេត្តទាំង១៩ នៅកម្ពុជា ហើយពួកនេះ ត្រូវចោទប្រកាន់ថា បានបង្កវិច្ឆេទកម្មនយោបាយវាយប្រហារទីតាំងកងកម្លាំងរាជរដ្ឋាភិបាល នៅតាមតំបន់ជនបទដាច់ស្រយាល។

តាមការប៉ាន់ស្មាន ជាផ្លូវការរបស់រាជរដ្ឋាភិបាលភ្នំពេញ បានឱ្យដឹងថា ពួកខ្មែរក្រហមមានចំនួនមិនលើសពី១០០០ នាក់ទេ ហើយអ្នកដែលស្មោះស្ម័គ្រជាមួយពួកគេ ក៏ប្រហែលតិចជាង១ភាគរយ នៃប្រជារាស្ត្រខ្មែរសរុបជិត ៧លាននាក់។

បើតាមរបាយការណ៍របស់ក្រសួងសន្តិសុខជាតិ ដែលមានសុស្តែន ហ្វៃណង់ដេសជារដ្ឋលេខាធិការនោះ បានឱ្យដឹងថា ពួកខ្មែរក្រហម មានគ្នាជាង១០០ នាក់ កំពុងស្ថិតនៅក្នុងទឹកដីវៀតណាមខាងត្បូង ក្រោមការជួយឧបត្ថម្ភគាំពាររបស់ពួកវៀតកុង-វៀតណាមខាងជើង។

ចំណែកពួកកុម្មុយនិស្តថៃ ដែលមានឈ្មោះថា រណសិរ្សមាតុភូមិសៀម មាននិន្នាការម៉ៅនិយម និងទទួលឥទ្ធិពលពីមន្ត្រីទូតចិន នៅក្រុងភ្នំពេញ ដែលរាជរដ្ឋាភិបាលក្រុងបាងកកអំពាវនាវឱ្យសហរដ្ឋអាមេរិក មកជួយបង្ក្រាបនោះ ក៏បានផ្តល់ការគាំទ្រចំពោះពួកខ្មែរក្រហមដែលកំពុងធ្វើសកម្មភាពនៅក្នុងខេត្តមួយចំនួននៅជាប់ព្រំដែនខាងលិច ខណៈដែលពួកកុម្មុយ-

និស្តប៉ាថេតលាវ ក៏បានគាំទ្រពួកខ្មែរក្រហមនៅភាគខាងជើងប្រទេសកម្ពុជា ដែរ ។

ជាមួយនឹងការបើកប្រតិបត្តិការសឹកបង្ក្រាបចលនាតស៊ូខ្មែរក្រហម សម្តេចសីហនុ បានបង្កើតឱ្យមានអនុខេត្តមួយចំនួនដូចជា អនុខេត្តកំពង់សិលា និងអនុខេត្តថ្មកែវ អនុខេត្តអណ្តូងពេជ្រ អនុខេត្តស្រែកានាគ អនុខេត្តផ្កាវំចេក អនុខេត្តរតនមណ្ឌល និងអនុខេត្តកំចាយមារ ។

ទន្ទឹមនេះ ព្រះអង្គក៏បានសាងសង់មន្ទីរពេទ្យ មណ្ឌលសុខភាព សាលារៀន ស្ពានថ្នល់ រាជសហករណ៍ និងភូមិគំរូជាច្រើនទៀត នៅតាមអនុខេត្តទាំងឡាយណា ដែលពួកខ្មែរក្រហមធ្វើសកម្មភាពគំរាមកំហែងខ្លាំងផងដែរ។

នៅក្នុងខែកញ្ញា ឆ្នាំ១៩៦៨ ដោយមានអន្តរាគមន៍របស់ពួកមូលធនផងនោះ រាជរដ្ឋាភិបាលបានដំឡើងថ្លៃស្រូវឱ្យខ្ពស់ជាងមុន ដើម្បីកុំឱ្យប្រជាកសិករមានការខឹងសម្បា។ តែការដំឡើងថ្លៃស្រូវនេះ អ្នកដែលទទួលផលចំណេញច្រើនជាងគេនោះ គឺមានតែពួកឈ្មួញប៉ុណ្ណោះ ពោលគឺនៅពេលច្រូតកាត់ស្រូវរួច ប្រជាកសិករ ចាប់ផ្តើមលក់ស្រូវទៅឱ្យពួកឈ្មួញជាហូរហែ លុះដល់ខែមិថុនា ខែកញ្ញា ពាក់កណ្តាលរដូវវស្សា ប្រជាកសិករនាំគ្នាទិញស្រូវ ពួកឈ្មួញក្នុងតម្លៃខ្ពស់យកមកទទួលទានវិញ ។

# ២៤៥
# ខ្មែរក្រហម មានសមត្ថភាព
# ត្រឹមតែធ្វើសង្គ្រាមឈ្លបប៉ុណ្ណោះ



**ពួកខ្មែរក្រហមដាក់ចម្រូងការពារទីតាំងតស៊ូ នៅខេត្តរតនគិរី**

នៅក្នុងឆមាសទី២ ឆ្នាំ១៩៦៨ មេខ្មែរក្រហមឈ្មោះកែវ មាស បានធ្វើដំណើរទៅទីក្រុងហាណូយ ដើម្បីបញ្ចុះបញ្ចូលអតីតពួកខ្មែរវៀតមិញ ដែលបានទៅរស់នៅទីនោះតាំងពីក្រោយកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ ឱ្យវិលត្រលប់មកប្រទេសកម្ពុជាវិញ ដើម្បីចូលរួម

ក្នុងការប្រយុទ្ធតស៊ូជាមួយពួកគាត់ដែរ។ ប៉ុន្តែ មេដឹកនាំវៀតណាមខាងជើង និងសឹង ង៉ុកមិញ ដែលជាមេដឹកនាំអតីតបក្សប្រជាជនបដិវត្តន៍ខ្មែរ បានបដិសេធមិនព្រមឱ្យពួកខ្មែរនៅទីនោះ វិលត្រលប់មកចូលរួមប្រយុទ្ធតស៊ូជាមួយពួកខ្មែរក្រហមនៅក្នុងប្រទេសនោះទេ ព្រោះខ្លាច ប៉ះពាល់ដល់ទំនាក់ទំនងការទូតជាមួយរាជរដ្ឋាភិបាលសម្តេចសីហនុ ដែលកំពុងបើកដៃឱ្យ វៀតកុង-វៀតណាមខាងជើង បោះទីតាំងនៅលើទឹកដីរបស់ព្រះអង្គ។

ពេលនោះ កែវ មាស ស្តីបន្ទោសសឹង ង៉ុកមិញ និងខ្មែរតស៊ូដែលរស់នៅទីក្រុងហាណូយ នោះថា ពួកនោះគិតតែរឿងរស់នៅដេកស្រួល ស៊ីស្រួលយ៉ាងសុខសាន្ត គ្មានគិតដល់ការ លំបាកវេទនារបស់អ្នកតស៊ូនៅក្នុងប្រទេស ដែលកំពុងរងនូវការបង្ក្រាប បោសសម្អាតពីសំណាក់ សម្តេចសីហនុ អ្វីបន្តិចទឡើយ។

ថ្វីបើនៅដើមឆ្នាំ១៩៦៨ ប្រទេសចិន ក៏ដូចជាសហភាពសូវៀតដែរ បានផ្តល់ជំនួយ ជាយន្តហោះចម្បាំង កាំភ្លើងធំ កាំភ្លើងយន្ត និងគ្រាប់រំសេវជាច្រើនមកឱ្យរាជរដ្ឋាភិបាល កម្ពុជា ក៏ដោយ ក៏កែវ មាស និងមេដឹកនាំខ្មែរក្រហម ផ្សេងៗទៀត មិនហ៊ានតវ៉ារិះគន់ចំពោះ មេដឹកនាំប្រទេសមហាអំណាចកុម្មុយនិស្តទាំង២ នេះដែរ គឺពួកគេហ៊ានត្រឹមតែរិះគន់ និង ខឹងសម្បាមេដឹកនាំវៀតណាមខាងជើង ដែលមិនព្រមជួយពួកគេក្នុងការតស៊ូដោយអាវុធ នោះប៉ុណ្ណោះ។

ចូលដល់ឆ្នាំ១៩៦៩ ក្រុមឧទ្ទាមខ្មែរក្រហមនៅស្រុកតំបែរ តំបន់២០ ដឹកនាំដោយ សយ ស៊ីសាផុន ហៅសមមិត្តភួង(អនុលេខាបក្សភូមិភាគបូព៌ា) និងមាស សេង ហុង ហៅ សមមិត្តចាន់ (លេខាបក្សតំបន់២១) បានកើនកម្លាំងប្រយុទ្ធពី៣០ ទៅប្រហែល១០០ នាក់ ក៏ពិតមែន តែត្រូវកម្លាំងទាហានរាជរដ្ឋភិបាលចូលទៅបោសសម្អាត និងរុញច្រានឱ្យចេញពី ក្នុងព្រៃនៃស្រុកតំបែរ។

ពេលនោះ ពួកគេអស់ទាំងស្បៀងអាហារ ថ្នាំសង្កូវ ត្រូវដកថយ ឆ្លងកាត់ស្រុកមេមត់ ដើម្បីឆ្លងដែនចូលទៅក្នុងទឹកដីវៀតណាមខាងត្បូង ដែលពួកវៀតកុង-វៀតណាមខាងជើង កំពុងកាន់កាប់នៅទីនោះ ដោយបានប៉ះទង្គិចគ្នាជាមួយពួកទាហានការពារព្រំដែនរបស់រាជ

រដ្ឋាភិបាលផងដែរ។ ប៉ុន្តែ ក្រោយមក មេខ្មែរក្រហមទាំង២នាក់នេះ ក៏បានទាក់ទងធ្វើការសម្របសម្រួលគ្នាជាមួយពួកវៀតកុង-វៀតណាមខាងជើងនៅទីនោះ ទើបមានការយល់ព្រមឱ្យពួកគេចូលជ្រៅទៅក្នុងទឹកដីវៀតណាមខាងត្បូង ដែលមានចម្ងាយពីព្រំដែនប្រមាណ៥-៦គីឡូម៉ែត្រ និងលាក់ការណ៍មិនឱ្យទាហានរាជរដ្ឋាភិបាកម្ពុជា ដឹងឡើយ ហើយពួកវៀតកុង-វៀតណាមខាងជើង ក៏បានជួយផ្តល់អង្ករ និងសាច់ជ្រូកឱ្យពួកខ្មែរក្រហមទាំងនោះបានហូបចុក ព្រមទាំងផ្តល់ស្បែកជើងកង់ឡាន ផងដែរ។

ក្រោយពីឈប់សម្រាកនៅទីនោះបាន៣-៤ ថ្ងៃ ពួកវៀតណាមកុម្មុយនិស្តនៅទីនោះ ក៏បាននាំកងទ័ពរបស់សយ ស៊ីសាផុន ហៅសមមិត្តភួង និងមាស សេង ហុង ហៅសមមិត្តចាន់ ធ្វើដំណើរកាត់ព្រៃមកទិសខាងត្បូង ទៅជួបសោ ភឹម ជាលេខាគណៈកម្មាធិការបក្សភូមិភាគបូព៌ា និងកងទ័ពគាត់ប្រមាណ២០០នាក់ ដែលកំពុងបោះទីតាំងនៅព្រៃត្នោត (ខេត្តតៃនិញ) មានចម្ងាយពីព្រំដែនប្រហែលមួយគីឡូម៉ែត្រប៉ុណ្ណោះ។ ពេលនោះ សោ ភឹម ក៏បានបញ្ចូលកម្លាំងទាំង២ក្រុមនេះ ឱ្យទៅជាអង្គភាពកងទ័ពតែមួយរបស់ភូមិភាគបូព៌ា ដោយចែកចេញជា ៣កងអនុសេនាធំ។

នៅក្នុងខែតុលា ឆ្នាំ១៩៦៩ អគ្គសេនាធិការដ្ឋានកងទ័ពរាជរដ្ឋាភិបាល បានធ្វើការប៉ាន់ស្មានថា កងទ័ពខ្មែរក្រហមនៅភូមិភាគបូព៌ាបានកើនឡើងពី៤០០ ទៅ៥០០នាក់ កំពុងបោះទីតាំងនៅក្នុងទឹកដីវៀតណាម និងទទួលការហ្វឹកហ្វឺនពីពួកវៀតកុង-វៀតណាមខាងជើង។

ដើមឆ្នាំ១៩៦៩ ឧត្តមសេនីយ៍ លន់ នល់ បានធ្វើការប៉ាន់ប្រមាណថា កងទ័ពឧទ្ទាមខ្មែរក្រហមនៅទូទាំងប្រទេស សរុបទាំងអស់មានប្រមាណ២៤០០នាក់។

ប៉ុន្តែ ក្រោយពីបានឡើងកាន់អំណាចក្នុងឆ្នាំ១៩៧៥ មេដឹកនាំខ្មែរក្រហម សាឡុត ស បានអះអាងថា កាលចុងទសវត្សរ៍ឆ្នាំ១៩៦០ គាត់មានកងទ័ពចំនួន៥០០០នាក់ នៅទូទាំងប្រទេស។ ប៉ុន្តែ នៅខេត្តរតនគិរី ភូមិភាគឦសាន ជាកន្លែងដែលគាត់ស្នាក់នៅនោះ មានកងទ័ពចំនួន១៥០នាក់ប៉ុណ្ណោះ។ តែបើតាមរបាយការណ៍របស់ពួកសេអ៊ីអា(CIA)របស់អាមេរិកថា ពួកខ្មែរក្រហម មានកងទ័ពចំនួន១០០០០ នាក់។ ដោយឡែករបាយការណ៍ពួកវៀតកុង-

វៀតណាមខាងជើង បានអះអាងថា កងទ័ពខ្មែរក្រហម ពេលនោះមានតែ៨០០នាក់ប៉ុណ្ណោះ។

ទោះបីចំនួនកងទ័ពរបស់ពួកខ្មែរក្រហម ត្រូវបានគេរាយការណ៍ខុសៗគ្នាក៏ដោយ ក៏អ្នកវិភាគមួយចំនួនចាត់ទុកថា របាយការណ៍របស់ពួកវៀតកុង-វៀតណាមខាងជើង ដែលអះអាងថា កាលនោះ ខ្មែរក្រហមមានកងទ័ពតែ៨០០ នាក់នោះ វាជាតួលេខមួយដែលគួរឱ្យជឿ និងទទួលយកបាន។

ទោះបីកាលនោះ គេមិនដឹងថាពួកខ្មែរក្រហមមានកងទ័ពប៉ុន្មានពិតប្រាកដក៏ដោយ ក៏តាមការពិនិត្យសកម្មភាពវាយប្រហាររបស់ពួកគេនៅពេលនោះ គឺនៅទន់ខ្សោយនៅឡើយ ហើយក៏មិនអាចវាយផ្តួលរម្លំរបបគ្រប់គ្រងសម្តេចសីហនុ បានដែរ ព្រោះសូម្បីតែទីប្រជុំជនតូចណាមួយក៏ពួកគេមិនមានលទ្ធភាពវាយដណ្តើមកាន់កាប់បានផង គឺពួកគេមានសមត្ថភាពត្រឹមតែធ្វើសង្គ្រាមឈ្លបនៅតាមតំបន់ជនបទ ព្រៃភ្នំប៉ុណ្ណោះ។

# ២៤៦
# ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម និងប៉ុក ដឹសកុមារ ជួបជុំគ្នានៅលើខ្នងភ្នំឱរ៉ាល់




នៅក្នុងខែមករា ឆ្នាំ១៩៦៨ ល្ងាចមួយ មានកងឈ្លប៣នាក់ ដែលធ្លាប់ជូនដំណើរ ខៀវ សំផន ពីមុននោះ បានមកប្រាប់ឱ្យគាត់រៀបចំសម្ពាយខោអាវព្រោះពេល វេលាកំណត់ បានមកដល់ហើយ។ លុះដល់ព្រលប់បន្តិច ពួកគេក៏នាំគាត់ដើរចេញពីភូមិដែលគាត់ស្នាក់ នៅ។ នៅតាមផ្លូវ អ្នកទាំង៣នោះ បានប្រាប់គាត់ឱ្យដឹងពីក្រុមពួកគេផ្សេងៗទៀត ដែលមាន ភារកិច្ចឡោមព័ទ្ធ និងវាយប្រហារទៅលើបន្ទាយទាហានមួយកន្លែង នៅតាមបណ្តោយផ្លូវ ជាតិលេខ៤ គឺបន្ទាយកាប់កង់ ស្ថិតនៅក្បែរភ្នំត្រពាំងក្រឡឹង ខេត្តកំពង់ស្ពឺ។ តែគាត់មិន បានចូលរួមក្នុងការវាយប្រហារនោះទេ គឺនៅរង់ចាំស្តាប់សភាពការណ៍ និងស្នូរកាំភ្លើងនៅក្នុង ព្រៃឆ្ងាយពីបន្ទាយនោះ ពេញមួយយប់។

លុះព្រលឹមស្រាងៗឡើង កងឈ្លបជាក្រុមតូចៗទាំងអស់នោះ បាននាំគ្នាដើរវិលត្រលប់មកវិញ ដោយនិយាយឆ្ការដៃឆ្ការជើងដាក់គ្នា ក្នុងភាពសប្បាយរីករាយ ព្រោះពួកគេដណ្តើមបានកាំភ្លើង៥០ដើម និងគ្រាប់ច្រើនស្បោងទៀតពីពួកទាហាននៅបន្ទាយកាប់កង់នោះ។

ខៀវ សំផន បានឱ្យដឹងថា ការតស៊ូដោយអាវុធ បានចាប់ផ្តើមឡើង ចាប់ពីពេលនោះមក ដោយកងឈ្លបជាក្រុមៗ ធ្វើការវាយឆ្មក់ ដើម្បីដណ្តើមកាំភ្លើងពីពួកទាហាន និងពួកជីវពលនៅតាមភូមិស្រុកនានាជាបន្តបន្ទាប់។ ប៉ុន្តែ ពួកគាត់ត្រូវប្រឈមនឹងការខ្វះស្បៀងអាហារយ៉ាងខ្លាំង។ កងឈ្លប ត្រូវទៅទាក់ទងប្រជាជន ដែលនៅតាមភូមិក្បែរៗកន្លែងពួកគេលាក់ខ្លួន។ ពេលយប់ ប្រជាជនបានលួចស្ពាយអង្ករ និងអំបិលស្ងាត់ៗ និងគេចពីការឆែកឆេររបស់ពួកទាហាន ដើម្បីយកមកឱ្យកងឈ្លប ហើយពេលខ្លះក៏មានត្រីងៀតដែរ ពិសេសគឺថ្នាំជក់។

ក្រោយមក នៅព្រៃធំខាងជើងផ្លូវជាតិលេខ៤ ដែលនៅឆ្ងាយពីបន្ទាយកាប់កង់នោះ ពួកទាហានក៏បានឡោមព័ទ្ធភូមិជុំវិញ អស់រយៈពេលជាច្រើនខែ ប្រជាជនមិនអាចលួចយកអង្ករមកផ្គត់ផ្គង់បាន ពួកគាត់ត្រូវហូបក្តួចជំនួសបាយ។ តែដោយសារមានអូរទឹកមួយ កងឈ្លបដែលមានបទពិសោធក្នុងជីវភាពជាកសិករ អាចចាប់ត្រីក្នុងអូរនេះបាន មកទទួលទាន ដោយមិនចាំបាច់ប្រើឧបករណ៍នេសាទអ្វីឡើយ។ ពេលនោះ ក៏មានឆ្កែពូកែៗជួយរកសត្វអណ្តើក និងសត្វត្រកួតយកមកធ្វើម្ហូបស្មើរាល់ថ្ងៃទៀតផង។

កងឈ្លប ត្រូវរងរបួស ថ្នាំសង្កូវក៏ខ្វះខាត ត្រូវធ្វើការវះកាត់ដោយគ្មានថ្នាំសណ្តំ និងថ្នាំស្ពឹក ធ្វើឱ្យអ្នកត្រូវរបួសនោះស្រែកពេទ័ខ្លាំងៗ ហើយកន្លែងវះកាត់នោះ មានតែគ្រែរនាបឫស្សីមួយ និងមុងគ្របពីលើប៉ុណ្ណោះ ហើយបើទោះបីគាត់ដើរទៅចងអង្រឹងដេកឱ្យឆ្ងាយពីកន្លែងវះកាត់នោះ នៅតែឮសម្រែកអ្នករបួសនោះ ស្រែកពេទ័ដដែល។

ខៀវ សំផន បានឱ្យដឹងទៀតថា នៅដើមឆ្នាំ១៩៦៩ រូបគាត់ ហ៊ូ យន់, ហ៊ូ នឹម ត្រូវបានគេប្រមូលមកឱ្យជុំគ្នានៅមន្ទីររបស់តាម៉ុក នៅភ្នំឱរ៉ាល់ ហើយមួយខែក្រោយមក ប៉ុក ដឺសកុមារ ជាមន្ត្រីជាន់ខ្ពស់នៅក្រសួងការបរទេស នៅក្រុងភ្នំពេញ ក៏បានមកដល់ទីនោះដែរ ធ្វើឱ្យគាត់មានការភ្ញាក់ផ្អើលជាខ្លាំង។

# ២៤៧
# សឺន សាន លាឈប់ពីតំណែង ឧបនាយករដ្ឋមន្ត្រី ទៅរក្សាសីលទាន



**សឺន សាន ពេលជួបពិភាក្សាគ្នាជាមួយ ឆេស្ទ័រ បូវឡេស**
**ទីប្រឹក្សាធានាធិបតី ចន កេណ្ណឌី ឆ្នាំ១៩៦១**

ពេលប្រឈមមុខនឹងការបង្កសង្គ្រាមឈ្លបរបស់ចលនាតស៊ូខ្មែរក្រហមផង និងព្រួយព្រះទ័យ ដោយសារតែកងទ័ពវៀតកុង-វៀតណាមខាងជើង ចូលមកបោះទីតាំងនៅក្នុងទឹកដីកម្ពុជាកាន់តែច្រើនឡើងៗ ផងនោះ សម្ដេចសីហនុ ក៏មានព្រះទ័យចង់ផ្សារទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក ឡើងវិញ។

ជាមួយគ្នានោះ ព្រះអង្គបានធ្វើកំណែទម្រង់ ដោយព្រះអង្គលាចេញពីតំណែងនាយករដ្ឋមន្ត្រី ហើយបានរៀបចំរាជរដ្ឋាភិបាលថ្មីមួយ ដោយប្រសិទ្ធនាមថា រាជរដ្ឋាភិបាលសំណាង

ចុងក្រោយ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៦៨។

រាជរដ្ឋាភិបាលសំណាងចុងក្រោយនោះ មានប៉ែន នុត ជានាយករដ្ឋមន្ត្រី, សឺន សាន ជាឧបនាយករដ្ឋមន្ត្រីទី១ ទទួលបន្ទុកក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ, អ៊ឹង ហុងសាធ ឧបនាយករដ្ឋមន្ត្រីទី២ ទទួលបន្ទុកក្រសួងមហាផ្ទៃ ធម្មការ និងទំនាក់ទំនងសភា, ទូច គឹម ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងហិរញ្ញវត្ថុ និងផែនការ, ព្រះអង្គម្ចាស់នរោត្តម ភូរិស្សារ៉ា រដ្ឋមន្ត្រីក្រសួងការបរទេស, ទិប ម៉ម (ស្រី)ជារដ្ឋមន្ត្រីសាធារណសុខាភិបាល ការងារ និងសង្គមកិច្ច, វណ្ណ ម៉ូលីវណ្ណ ជារដ្ឋមន្ត្រីក្រសួងអប់រំ, ងួន ឆាយគ្រី ជារដ្ឋមន្ត្រីក្រសួងសាធារណការ និងទូរគមនាគមន៍, ឧត្តមសេនីយ៍ ដួង សំអុល ជារដ្ឋមន្ត្រីក្រសួងការពារជាតិ, អ៊ិន តាំ ជារដ្ឋមន្ត្រីក្រសួងកសិកម្ម, ទេព ហ៊ុន ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌, គាត ឈន់ ជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម, ជិន រ៉ែន(ស្រី) រដ្ឋលេខាធិការក្រសួងឃោសនាការ, លោកស្រីអ៊ឹង មឹង (ប្រពន្ធអ៊ឹង មឹង) ជារដ្ឋលេខាធិការក្រសួងទេសចរណ៍, អ៊ុំ ម៉ាន្នូរិន ជារដ្ឋលេខាធិការក្រសួងការពារលើផ្ទៃប្រទេស, សុស្តែន ហ្វៀណង់ ដេស ជារដ្ឋលេខាធិការក្រសួងសន្តិសុខជាតិ, អ៊ុក ម៉ូត ជាអនុរដ្ឋលេខាធិការក្រសួងធម្មការ, កែវ អន ជាអនុរដ្ឋលេខាធិការទូរគមនាគមន៍, ប៉ាវ អ៊ិត ជាអនុរដ្ឋលេខាធិការអមទីស្ដីការគណៈរដ្ឋមន្ត្រី និងជាបេសកជនពិសេស, ទេព ឈីវខេង ជាអនុរដ្ឋលេខាធិការទទួលបន្ទុកសារព័ត៌មាន ។

នៅពេលប្រកាសសមាសភាព រាជរដ្ឋាភិបាលសំណាងចុងក្រោយនេះ សម្ដេចសីហនុ ជាព្រះប្រមុខរដ្ឋ បានចេញព្រះរាជសារណែនាំ ជាលាយលក្ខណ៍អក្សរច្បាស់លាស់ទៅប៉ែន នុត ជានាយករដ្ឋមន្ត្រី និងសឺន សាន ជាឧបនាយករដ្ឋមន្ត្រីទី១ ថា៖ អស់លោក! ត្រូវតែប្រយុទ្ធប្រឆាំងនឹងគ្រោះចង្រៃធំចំពោះប្រទេសជាតិ៣សំខាន់ៗ គឺ "បង្ក្រាបល្បែងស៊ីសង ការរត់ពន្ធគយ និងអំពើពុករលួយលួចបន្លំ កេងប្រវ័ញ្ចទ្រព្យសម្បត្តិជាតិ" ។

រាជរដ្ឋាភិបាលសំណាងចុងក្រោយ ក៏បានចាប់ផ្ដើមធ្វើការបង្ក្រាបកន្លែងបើកបនល្បែងខុសច្បាប់ ដែលភាគច្រើន គឺជាពួកជនជាតិចិន ជាអ្នកមានទ្រព្យសម្បត្តិជាអ្នកបើកនោះយ៉ាងសកម្ម។ សមត្ថកិច្ចប៉ូលិសតែងតែចាប់ពួកមេបនល្បែងនោះបានរាល់ថ្ងៃ និងបានបញ្ជូនទៅ

ឱ្យតុលាការផ្តន្ទាទោស ទៅតាមនីតិវិធី។ ប៉ុន្តែ ពេលទៅដល់តុលាការ ពួកមេបនល្បែងទាំងនោះត្រូវបានរួចខ្លួនគ្រប់ៗគ្នា ដោយសារពួកគេសូកលុយកាក់ ឬគ្រាន់តែទទួលការផាកពិន័យបន្តិចបន្តួចប៉ុណ្ណោះ។

ដើម្បីទប់ទល់នឹងបញ្ហាអសកម្មនេះ រាជរដ្ឋាភិបាលសំណាងចុងក្រោយ បានដាក់វិធានការទៅអគ្គស្នងការនគរបាលជាតិ ឱ្យស្រង់ឈ្មោះមេបនល្បែងធំៗទាំងអស់ ពិសេសជនជាតិចិន ឱ្យធ្វើកិច្ចសន្យា ហើយប្រាប់ពួកគេឱ្យបញ្ឈប់ការបើកបនល្បែងខុសច្បាប់តទៅទៀត បើមិនដូច្នេះទេ ពួកគេនឹងលែងចាប់បញ្ជូនទៅឱ្យតុលាការដូចមុនៗទៀតហើយ គឺត្រូវប្រឈមក្នុងការបណ្តេញចេញពីប្រទេសកម្ពុជាតែម្តង។

ដើម្បីអនុវត្តវិធានការណ៍នេះ ឱ្យមានប្រសិទ្ធភាព ឧបនាយករដ្ឋមន្ត្រីសឺន សាន ក៏បានសុំ រាជានុញ្ញាតពីសម្តេចសីហនុ បណ្តេញឈ្មួញទុច្ចរិត ឈ្មោះកុក អាន ដែលនៅតែចចេសរឹងរូសក្នុងការបើកបនល្បែងខុសច្បាប់នោះទៀត ឱ្យចាកចេញពីប្រទេស ដើម្បីជាការព្រមានដល់មេបនល្បែងខុសច្បាប់ផ្សេងៗទៀតដែរ។ ប៉ុន្តែ មិនយូរប៉ុន្មាន ដោយសារតែពួកបរិវារអែបអបនៅព្រះរាជដំណាក់ចម្ការមន ចាក់រុកផ្តិះផ្តៀលនោះ ស្រាប់តែសម្តេច សីហនុ បានចេញព្រះរាជសារមួយឱ្យនាយករដ្ឋមន្ត្រី ប៉ែន នុត ដកចេញនូវវិធានការបណ្តេញមេបនល្បែងខុសច្បាប់ជាជនជាតិចិន ចេញពីប្រទេសនោះវិញ។

ទន្ទឹមនឹងបញ្ហាខាងលើនេះ រាជរដ្ឋាភិបាលសំណាងចុងក្រោយ ដែលមានប៉ែន នុត ជាប្រមុខនោះ ក៏ជួបបញ្ហាលំបាក២ធំៗ ទៀត គឺ៖ ទី១ រាជរដ្ឋាភិបាលបានបំពាក់អាវុធឱ្យប្រជារាស្ត្រ ដែលរស់នៅតាមតំបន់ជនបទដាច់ស្រយាលជាច្រើន ដែលមិនសូវមានសន្តិសុខសុវត្ថិភាព ដើម្បីការពារខ្លួនឯង នៅពេលមានបញ្ហាអាសន្នណាមួយកើតឡើងភ្លាមៗ ទម្រាំកងកម្លាំងសមត្ថកិច្ចខេត្តស្រុកទៅជួយទាន់ពេល។

ពេលកិច្ចការនេះកំពុងអនុវត្តមានប្រសិទ្ធភាពទៅហើយ ស្រាប់តែអ្នកជំនាញខាងយុទ្ធសាស្ត្រ ដែលនៅព្រះរាជដំណាក់ចម្ការមន ជាមួយសម្តេចសីហនុ បានជំទាស់ថា ការប្រគល់អាវុធទៅឱ្យអ្នកភូមិបែបនេះ អាចធ្វើឱ្យពួកខ្មែរក្រហមវាយប្រហារទៅលើភូមិទាំងឡាយណា

ដែលចាត់តាំងកម្លាំងការពារមិនបានល្អ ហើយដណ្តើមយកអាវុធដែលរាជរដ្ឋាភិបាលបំពាក់ឱ្យនោះ គឺដូចជាយកកាំភ្លើងទាំងអស់នោះទៅឱ្យពួកខ្មែរក្រហមដែរ។

ដោយសារសម្តេចសីហនុ ជឿលើពួកជំនាញការខាងយុទ្ធសាស្ត្រនៅក្នុងព្រះរាជដំណាក់ចម្ការមននោះ ព្រះអង្គបានចេញព្រះរាជបញ្ជាជាលាយលក្ខណ៍អក្សរឱ្យប្រមូលអាវុធដែលរាជរដ្ឋាភិបាលយកទៅបំពាក់ឱ្យអ្នកភូមិ នៅតំបន់ជនបទដាច់ស្រយាលទាំងប៉ុន្មាននោះ យកមកចូលឃ្លាំងវិញទាំងអស់។

សូមរំឭកថា ទាក់ទងដល់បញ្ហាប្រមូលអាវុធយកមកវិញនេះ សាឡុត ស បានប្រជុំសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស កាលពីចុងឆ្នាំ១៩៦៧ ដើម្បីចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្រតស៊ូនយោបាយ រួមផ្សំអាវុធ និងប្រគល់សិទ្ធិឱ្យមេដឹកនាំភូមិភាគនីមួយៗ ប្រើគំនិតច្នៃប្រតិដ្ឋតាមសភាពជាក់ស្តែង តាមភូមិភាគរៀងៗខ្លួន ពិសេសត្រូវស្វែងរកអាវុធខ្លួនឯង ដោយវាយដណ្តើមយកអាវុធពីពួកខ្មាំង គឺអាវុធរបស់រាជរដ្ឋាភិបាល ដែលបំពាក់ឱ្យកងស្វ័យត្រាណនៅតាមតំបន់ជនបទដាច់ស្រយាល ដែលពួកខ្មែរហម ធ្វើសកម្មភាពវាយឈ្លបនោះឯង។ពេលនោះ ពួកខ្មែរក្រហមដែលមានកាំភ្លើងបួនដប់ដើម មិនហ៊ានវាយប្រហារដណ្តើមកាំភ្លើងពីកងទ័ពរបស់រាជរដ្ឋាភិបាលទេ គឺមានតែវាយដណ្តើមអាវុធពីពួកកងស្វ័យត្រាណ ដែលមានកាំភ្លើងមួយភូមិ៤–៥ដើមប៉ុណ្ណោះ។

បញ្ហាទី២ គឺនៅពេលឃើញប្រជារាស្ត្រខ្មែរកាន់តែច្រើនឡើង នាំគ្នាសុំទិដ្ឋាការទៅលេងកម្សាន្តនៅទីក្រុងហុងកុង។ លុះពេលត្រលប់មកវិញឆ្លៀតរត់ពន្ធទំនិញមួយចំនួនបានប្រាក់ចំណេញច្រើននោះ សម្តេចសីហនុ ក្នុងនាមជាព្រះប្រមុខរដ្ឋ បានធ្វើព្រះរាជសារជាលាយលក្ខណ៍អក្សរមួយច្បាប់ បញ្ជាទៅនាយករដ្ឋមន្ត្រី ប៉ែន នុត ឱ្យយកលុយថ្លៃសុំទិដ្ឋាការ៣០០០០ រៀល (កាលនោះស្មើនឹង៨៦០ដុល្លារអាមេរិក) នោះ ទៅថ្វាយព្រះអង្គ ហើយព្រះអង្គបញ្ជាក់ថា មិនចាំបាច់មានច្បាប់ពីរឿងយកថ្លៃទិដ្ឋាការនេះទេ។

ពេលនោះ ក្នុងនាមជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សឺន សាន ក៏បានប្រាប់នាយករដ្ឋមន្ត្រីប៉ែន នុត ថា៖ ចាំបាច់ ត្រូវមានច្បាប់មួយ ដើម្បីកាត់យកថវិកាថ្លៃ

សុំទិដ្ឋាការនេះមកចូលថវិកាជាតិ បើមិនដូច្នេះទេ យើងអាចនឹងត្រូវគេចោទថា លួចបន្លំលុយជាតិជាមិនខាន។

ចំណែកវិធានការបង្ក្រាបការរត់ពន្ធវិញ រាជរដ្ឋាភិបាលសំណាងចុងក្រោយ រកឃើញមានជាប់ពាក់ព័ន្ធជាមួយពួកមេទាហាន និងមេប៉ូលិសធំៗ ពិសេសមន្ត្រី ឈ្មោះ ជុំ ម៉ៃ ដែលពេលនោះ កំពុងកាន់តំណែងជានាយកទីចាត់ការគយ និងរដ្ឋាករ និងពួកមនុស្សដែលស្និទ្ធនឹងព្រះរាជដំណាក់ចម្ការមន របស់សម្ដេចសីហនុ។

ដើម្បីអនុវត្តវិធានការទប់ស្កាត់ និងបង្ក្រាបអំពើរត់ពន្ធឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលសំណាងចុងក្រោយ ក៏បានសម្រេចដក ជុំ ម៉ៃ ចេញពីតួនាទីជានាយកទីចាត់ការគយ និងរដ្ឋាករ ហើយដាក់ឧត្ដមសេនីយ៍សូ ខាំខូយ ដែលល្បីថា ជាឥស្សរជនស្អាតស្អំ សុចរិត ទៀងត្រង់ត្រឹមត្រូវជំនួសវិញ ដើម្បីប្រយុទ្ធប្រឆាំងនឹងពួកមេរត់ពន្ធធំៗ ដែលមានពួកនាយ ទាហានជាន់ខ្ពស់មួយចំនួន ធ្វើជាខ្នងបង្អែក។

ក្រោយពេលចូលកាន់តំណែងជានាយកទីចាត់ការគយ និងរដ្ឋាករនោះមក បើទោះបីជា សូ ខាំខូយ ប្រមូលប្រាក់ពន្ធចូលថវិកាជាតិបានច្រើនជាងកាលពីពេល ជុំ ម៉ៃ ធ្វើជានាយកក៏ដោយ ក៏មន្ត្រីអែបអបនៅព្រះរាជដំណាក់ចម្ការមន ព្រមទាំង ជុំ ម៉ៃ ផងដែរ បានធ្វើការរិះគន់វាយប្រហាររបៀបច្រណែនឈ្នានីសថា សូ ខាំខូយ មិនបានប្រមែប្រមូលពន្ធគយឱ្យបានច្រើនទេ។

សឺន សាន និងក្រុមមន្ត្រីអែបអបនៅព្រះរាជដំណាក់ចម្ការមន មិនសូវស៊ីសង្វាក់គ្នាទេ គឺកាច់កុងគ្នាមិនចេះចប់។ ក្រោយពីឪពុកក្មេករបស់សឺន សាន ទទួលមរណភាពទៅ កូនប្រុសច្បងរបស់គាត់ម្នាក់ទៀត ឈ្មោះសឺន ស៊ែរភី ក៏ត្រូវបាត់បង់ជីវិតក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍។ ពេលនោះ ពួកមន្ត្រីអែបអបនៅវិមានរដ្ឋចម្ការមន ក៏បាននាំគ្នានិយាយចំអកថាការបាត់បង់ជីវិតនោះ គឺដោយសារតែ សឺន ស៊ែរភី ចូលចិត្តដើរលេងឥតប្រយោជន៍...។

ចាប់ពីពេលនោះមក សឺន សាន ក៏បានដាក់ចិត្តដាក់កាយជាអ្នករក្សាសីលទាន ( សីល ៥ ) ហើយបានដាក់ពាក្យថ្វាយសម្ដេចសីហនុ ជាព្រះប្រមុខរដ្ឋ សុំលាឈប់ពីតំណែងឧបនាយក

រដ្ឋមន្ត្រីទទួលបន្ទុលសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សម្តេចសីហនុ ក៏បានយល់ព្រមឱ្យគាត់លាឈប់ពីតំណែង តាមការស្នើសុំនោះដែរ។ តែសំណូមពរឱ្យគាត់នៅទទួលតួនាទីជាអគ្គទេសាភិបាលធនាគារជាតិកម្ពុជា ដដែល។

ពេលនោះដែរ អ៊ុំ ម៉ាន្នូរិន ជារដ្ឋលេខាធិការក្រសួងការពារលើផ្ទៃប្រទេស និងសុស្តែន ហ្វៃណង់ដេស រដ្ឋលេខាធិការក្រសួងសន្តិសុខជាតិ ក៏បានរាយការណ៍ទៅថ្វាយសម្តេចសីហនុថា ថៅ សៅ អគ្គនាយកធនាគារឥណទានជាតិ ដែលជាសាខាធនាគារជាតិ បានយកលុយប្រភេទក្រដាស ៥០០រៀលថ្មីៗជាច្រើនទៅជួយដល់ពួកខ្មែរក្រហម។ ព្រះអង្គក៏បានបញ្ជាឱ្យគេចាប់ថៅ សៅ ភ្លាមៗដែរ។

បញ្ហានេះ ធ្វើឱ្យអ្នកមានៗដែលយកលុយមកផ្ញើទុកនៅធនាគារឥណទានជាតិនោះមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះពួកគេបានឮពាក្យចចាម អារ៉ាមថា ថៅ សៅ បានយកលុយនៅក្នុងធនាគារឥណទាននោះ ទៅផ្តល់ឱ្យពួកខ្មែរក្រហមអស់ហើយ។

ភ្លាមៗនោះដែរ គណៈកម្មការចម្រុះមួយ ត្រូវបានបង្កើតឡើង ដោយមានតំណាងនគរបាលជាតិ ក្រសួងសេដ្ឋកិច្ច និងសឺន សាន ជាសមាជិក ដើម្បីធ្វើការស៊ើបអង្កេតស្រាវជ្រាវពីរឿងបាត់លុយនោះដែរ។ ប៉ុន្តែ នៅទីបំផុត ពុំមានការបាត់បង់លុយកាក់នៅក្នុងធនាគារដូចការចោទប្រកាន់នោះទេ។

ក្រោយពីថៅ សៅ ត្រូវចាប់ខ្លួន សឺន សាន អគ្គទេសាភិបាលធនាគារជាតិកម្ពុជា បានតែងតាំងឱ្យទ្រឿង កៀនខៃ (ប្អូនប្រុសរបស់ទ្រឿង កាង) ជាអគ្គលេខាធិការធនាគារជាតិកម្ពុជាឱ្យឡើងធ្វើជាអគ្គនាយកធនាគារឥណទានជាតិនោះ ជំនួស ថៅ សៅ បន្តទៀត។

តែទោះបីយ៉ាងនេះក៏ដោយ ក៏សម្តេចសីហនុ នៅតែមិនបាត់ខ្ញាល់នឹងសឺន សាន ដែរ តែសឺន សាន ក៏មិនបានដឹងច្បាស់ ថា តើព្រះអង្គនៅខ្ញាល់នឹងគាត់ពីរឿងអ្វីទៀតដែរ ព្រោះលុយកាក់នៅក្នុងធនាគារនោះទាំងប៉ុន្មាន មិនបាត់បង់ផង ?។

ទីបំផុត សឺន សាន បានសម្រេចចិត្តដាក់ពាក្យសុំលាឈប់ពីមុខតំណែងជាអគ្គទេសាភិបាលធនាគារជាតិកម្ពុជា ថ្វាយទៅសម្តេចសីហនុ ជាព្រះប្រមុខរដ្ឋ តាមរយៈនាយករដ្ឋ



**សម្តេចសីហនុ ប្រទានគោរមងារជូនឧត្តមសេនីយ៍ញឹក ជូឡុង ជាសម្តេចចក្រីកុញ្ជរាធិបតី**

មន្ត្រី ប៉ែន នុត។ ប៉ុន្តែការសុំលាលែងពីតំណែងនេះ ត្រូវរងនូវការថ្កោលទោស ហើយត្រូវចាក់ផ្សាយតាមវិទ្យុជាតិដដែលៗ ជាច្រើនលើកច្រើនសាក្នុងមួយថ្ងៃ។ មិនតែប៉ុណ្ណោះ គេបានចាត់តាំងឱ្យអ្នកបច្ចេកទេសខាងគ្រប់គ្រងរូបិយប័ណ្ណម្នាក់ ទៅធ្វើការស្រាវជ្រាវការគ្រប់គ្រងសាច់ប្រាក់របស់សឺន សាន នៅធនាគារជាតិកម្ពុជា ទៀតផង។

ទោះបី ពេលនោះ សឺន សាន បានលាឈប់ពីតំណែងអគ្គទេសាភិបាលធនាគារជាតិកម្ពុជា ក៏ពិតមែន តែគាត់នៅមានតំណែងមួយទៀត គឺប្រធានសមាគមមិត្តភាពខ្មែរ-សូវៀត ហើយមួយឆ្នាំក្រោយមកទៀត ទើបសម្តេចសីហនុ ឈប់ខ្វាល់នឹងគាត់ ហើយបានប្រទានគោរមងារ ជាសម្តេចបវរសេដ្ឋាធិបតីសឺន សាន (សម្តេចបវរសេដ្ឋាធិបតី មានន័យថា អ្នកសេដ្ឋកិច្ចដ៏ខ្ពង់ខ្ពស់)។

ជាមួយគ្នានោះ សម្តេចសីហនុ ក៏បានប្រទានគោរមងារជូនឧត្តមសេនីយ៍ញឹក ជូឡុង ជាសម្តេចចក្រីកុញ្ជរាធិបតី ញឹក ជូឡុង (សម្តេចចក្រីកុញ្ជរាធិបតី មានន័យថា អ្នកការពារ

ជាតិដ៏ខ្ពង់ខ្ពស់) នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៦៨ នៅរាជបណ្ឌិត្យសភាភូមិន្ទយោធា ផងដែរ។

## ជីវប្រវត្តិសង្ខេបរបស់ ញឹក ជូឡុង

ញឹក ជូឡុង កើតនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩០៨ នៅក្រុងភ្នំពេញ ក្នុងត្រកូលអ្នកជំនួញខ្មែរកាត់ចិនម្នាក់។ ឪពុកគាត់ឈ្មោះញឹក ថៃកុង មានងារជាឧកញ៉ា និងជាអតីតអភិបាលខេត្តជើងព្រៃ និងម្តាយឈ្មោះ អ៊ឹង សាឡែត មានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងព្រះរាជវាំង។ ក្រោយបញ្ចប់ការសិក្សានៅអនុវិទ្យាល័យព្រះស៊ីសុវត្ថិ គាត់បានបន្តការសិក្សានៅវិទ្យាល័យហ្សាស្សឺលូ ឡូបា (Chasseloup-Laubat) នាទីក្រុងព្រៃនគរ និងបានប្រលងជាប់សញ្ញាបត្រមធ្យម សិក្សាទុតិយភូមិ ផ្នែកទស្សនវិជ្ជា។

បន្ទាប់ពីបញ្ចប់ការសិក្សា គាត់បានចូលបម្រើការងាររាជការ ក្នុងឋានៈជាអនុមន្ត្រី នាឆ្នាំ១៩៣២ និងបានឡើងតំណែងបន្តបន្ទាប់ រួមមាន៖ ជាភូឈួយខេត្តព្រៃវែង, ជាចៅហ្វាយស្រុកបាភ្នំ និងជាភូឈួយខេត្តតាកែវ។ ឆ្នាំ១៩៣៧ គាត់បានឡើងជាចៅហ្វាយខេត្តពោធិ៍សាត់ និងពីឆ្នាំ១៩៣៩ ដល់ ១៩៤៤ ជាចៅហ្វាយខេត្តកំពង់ចាម។

បន្ទាប់ពីរដ្ឋប្រហាររបស់ជប៉ុន ដណ្តើមអំណាចពីបារាំង (ថ្ងៃទី០៩ ខែមីនា ១៩៤៥) គាត់ត្រូវបានតែងតាំងជាអភិបាលក្រុងភ្នំពេញ ។ នៅក្នុងគណៈរដ្ឋមន្ត្រីរបស់ស៊ឺង ង៉ុកថាញ់ ពីថ្ងៃទី១៤ ខែសីហា ដល់ថ្ងៃទី១៦ ខែតុលា ១៩៤៥ គាត់បានទទួលតំណែងជារដ្ឋមន្ត្រីក្រសួងអប់រំជាតិ ។

បន្ទាប់ពីបារាំង ចាប់ខ្លួនស៊ឺង ង៉ុកថាញ់ ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៤៥ បញ្ជូនទៅឃុំខ្លួននៅប្រទេសបារាំង គាត់ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ នៅក្នុងគណៈរដ្ឋមន្ត្រីរបស់ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត បន្តទៀត ពីថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៤៥ ដល់ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៤៦។ ពីខែមេសា ដល់ខែមិថុនា ឆ្នាំ១៩៤៦ គាត់បានអមព្រះរាជដំណើរសម្តេចសីហនុ ក្នុងឱកាសយាងទៅបំពេញព្រះរាជទស្សនកិច្ចនៅប្រទេសបារាំង ផងដែរ។

នាថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៤៦ សម្តេចសីហនុ បានតែងតាំងគាត់ធ្វើជាព្រះរាជតំណាង

ព្រះមហាក្សត្រ ទៅចូលរួមក្នុងពិធីប្រគល់ខេត្តបាត់ដំបង មកប្រទេសកម្ពុជាវិញ បន្ទាប់ពីប្រទេសសៀម បានដណ្ដើមយកកាន់កាប់ដោយខុសច្បាប់អស់រយៈពេល៥ឆ្នាំមក។ គាត់បានចូលរួមក្នុងពិធីចុះហត្ថលេខាស្ដីពីការចាកចេញរបស់មន្ត្រីសៀម ក្នុងរដ្ឋបាលខេត្តបាត់ដំបង និងបានដាក់មន្ត្រីខ្មែរ ជំនួសវិញ។

នាថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៤៩ សម្ដេចសីហនុ បានតែងតាំងគាត់ជាមេបញ្ជាការកងយោធពលខេមរភូមិន្ទ។ នៅចុងខែធ្នូ ឆ្នាំ១៩៤៩ គាត់បានលាចេញពីតំណែងនេះ ដោយសារគាត់ត្រូវបានតែងតាំងឲ្យធ្វើជាតំណាងរាជរដ្ឋាភិបាលកម្ពុជា ប្រចាំនៅសាធារណរដ្ឋបារាំង ជំនួសទ្រៀង កាង។ ខែឧសភា ឆ្នាំ១៩៥០ គាត់ត្រូវបានព្រះមហាក្សត្រ តែងតាំងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអភិបាលខេត្តបាត់ដំបង និងមានឋានៈស្មើរដ្ឋមន្ត្រី។

ពីថ្ងៃទី១ ខែមករា ដល់ទី២ ខែមីនា ឆ្នាំ១៩៥១ គាត់ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ក្នុងគណៈរដ្ឋមន្ត្រីរបស់ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីពង្ស និងបានបន្តតំណែងជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ដដែលនេះ នៅក្នុងគណៈរដ្ឋមន្ត្រីរបស់អ៊ុម ឈាងស៊ុន (គណៈរដ្ឋមន្ត្រីទី១៤) ពីថ្ងៃទី៣ ខែមីនា ដល់ ពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៥១។ ពីថ្ងៃទី១៤ ខែឧសភា ដល់ ថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៥១ ត្រូវបានតែងតាំងជារដ្ឋមន្ត្រីទទួលបន្ទុកព័ត៌មាននៅក្នុងគណៈរដ្ឋមន្ត្រីរបស់អ៊ុម ឈាងស៊ុន បន្តទៀត។

ឆ្នាំ១៩៥២ គាត់ត្រូវបានតែងតាំងជាសមាជិកគណៈប្រតិភូព្រះរាជអាណាចក្រកម្ពុជានៅក្នុងសន្និសីទសាន់ហ្វ្រាន់ស៊ីស្កូ ស្ដីពីកិច្ចព្រមព្រៀងសន្តិភាព ជាមួយជប៉ុន។

ពីខែមិថុនា ដល់វិច្ឆិកា ឆ្នាំ១៩៥៣ នៅក្នុងរយៈពេលស្នាក់អាស្រ័យរបស់ព្រះមហាក្សត្រសម្ដេច សីហនុ នៅខេត្តបាត់ដំបង និងសៀមរាប ដើម្បីទាមទារឯករាជ្យពីបារាំង គាត់ជាអ្នកទទួលខុសត្រូវខាងព័ត៌មាន។ នៅក្នុងគណៈរដ្ឋមន្ត្រីរបស់សម្ដេចសីហនុ ពីថ្ងៃទី២៩ ខែកក្កដា ដល់ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៥៣ គាត់ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងសាធារណការ និងទូរគមនាគមន៍។

ពីចុងខែធ្នូ ឆ្នាំ១៩៥៣ ដល់ដើមឆ្នាំ១៩៥៤ គាត់ត្រូវបានតែងតាំងជាអភិបាលក្រុង

ភ្នំពេញ ម្តងទៀត និងបានចូលរួមនៅក្នុងការចរចាជាមួយបារាំង នៅក្នុងការផ្ទេរអំណាចមកឲ្យរាជរដ្ឋាភិបាលកម្ពុជា វិញ ។

នៅក្នុងគណៈរដ្ឋមន្ត្រីរបស់សម្តេចសីហនុ ពីថ្ងៃទី៧ ខែមេសា ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៥៤ គាត់ត្រូវបានតែងតាំងជារដ្ឋមន្ត្រី ទទួលបន្ទុកការបរទេស និងសន្និសីទ ( សម្រាប់សន្និសីទទីក្រុងហ្សឺណែវ ) ។

នៅក្នុងគណៈរដ្ឋមន្ត្រីរបស់ប៉ែន នុត ពីថ្ងៃទី១៨ ខែមេសា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៥៤ គាត់ត្រូវបានតែងតាំងជារដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ និងបានដឹកនាំគណៈប្រតិភូយោធាជាន់ខ្ពស់នៃប្រទេសកម្ពុជា មួយក្រុម ក្នុងនោះរួមមាន ទ្រង់នរោត្តម ចន្ទរង្សី, ដាប ឈួន និងពុត ឆាយ ទៅចុះហត្ថលេខាស្តីពីបទឈប់បាញ់គ្នាជាមួយឧត្តមសេនីយវៀតមិញ ឈ្មោះ តា ក្វាងប៊ូ ( TA QUANG BUU ) នៅក្នុងកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ផងដែរ។

នៅក្នុងខែឧសភា ឆ្នាំ១៩៥៥ គាត់ត្រូវបានតែងតាំងជាឯកអគ្គរាជទូតព្រះរាជអាណាចក្រកម្ពុជា ប្រចាំប្រទេសជប៉ុន និងនៅឆ្នាំ១៩៥៧ ប្រចាំសហភាពសូវៀត, ប៉ូឡូញ និងឆេកូស្លូវ៉ាគី។ គាត់ត្រលប់មកប្រទេសកម្ពុជាវិញ នៅឆ្នាំ១៩៥៨។

នៅក្នុងគណៈរដ្ឋមន្ត្រី ដែលមានប៉ែន នុត ជានាយករដ្ឋមន្ត្រី ពីថ្ងៃទី២២ ខែមករា ដល់ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៥៨ គាត់ជារដ្ឋមន្ត្រីទទួលបន្ទុកមហាផ្ទៃ, សន្តិសុខជាតិ និងព័ត៌មាន។ នៅក្នុងគណៈរដ្ឋមន្ត្រី ដែលមានស៊ឹម វ៉ា ជានាយករដ្ឋមន្ត្រី ពីថ្ងៃទី៣០ ខែមេសា ដល់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៥៨ គាត់ជាទេសរដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងផែនការ ផលិតកម្ម និងកិច្ចការសេដ្ឋកិច្ច។ នៅក្នុងគណៈរដ្ឋមន្ត្រី ដែលមានសម្តេចសីហនុ ជានាយករដ្ឋមន្ត្រី ពីថ្ងៃទី១៨ ខែកុម្ភៈ ដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៥៩ គាត់ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, យុត្តិធម៌, ព័ត៌មាន, ផែនការ និងអនាម័យទូទៅ។

នៅក្នុងគណៈរដ្ឋមន្ត្រី ដែលមានសម្តេចសីហនុ ជានាយករដ្ឋមន្ត្រី ពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៥៩ ដល់ ថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៦០ គាត់ជារដ្ឋមន្ត្រីក្រសួងសិក្សាធិការ, ផែនការ និងទេសចរណ៍។




ញឹក ជូឡុង ចុះហត្ថលេខាជាមួយឧត្តមសេនីយវៀតមិញ ឈ្មោះតា ក្វាងប៊ូ

នៅក្នុងគណៈរដ្ឋមន្ត្រី ដែលមានផូ ព្រឿង ជានាយករដ្ឋមន្ត្រី ពីថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៦០ ដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៦១ គាត់ជារដ្ឋមន្ត្រីក្រសួងផែនការ ទេសចរណ៍ ផលិតកម្ម ការងារសាធារណៈ និងទូរគមនាគមន៍។

នៅក្នុងគណៈរដ្ឋមន្ត្រី ដែលមានប៉ែន នុត ជានាយករដ្ឋមន្ត្រី ពីថ្ងៃទី២៩ ខែមករា ឆ្នាំ ១៩៦១ ដល់ថ្ងៃទី ០៦ ខែសីហា ឆ្នាំ ១៩៦២ គាត់ជារដ្ឋមន្ត្រីក្រសួងកិច្ចការបរទេស និង ទេសចរណ៍។

នៅក្នុងខែតុលា ឆ្នាំ១៩៦២ គាត់ត្រូវបានតែងតាំងជាអភិបាលក្រុងគីរីរម្យ។ ឆ្នាំ១៩៦៥ គាត់បានចូលរួមសម្តែងជាតួភាពយន្តរឿង «អប្សរា» ដែលដឹកនាំរឿងដោយសម្តេចសីហនុ។ លុះដល់ខែតុលា ឆ្នាំ១៩៦៦ គាត់ទទួលតំណែងជានាយអគ្គសេនាធិការកងទ័ព ជំនួសឧត្តម សេនីយ៍លន់ នល់ ។

នៅឆ្នាំ១៩៦២ ដោយសារវីរភាពស្មោះស្ម័គ្ររបស់គាត់ចំពោះជាតិ សាសនា និងព្រះ-

**របត់នយោបាយ**

មហាក្សត្រ សម្តេចសីហនុ បានកសាងបុរីទេសចរណ៍មួយនៅគិរីរម្យ ដោយដាក់ឈ្មោះថា "បុរីជូឡុង" ដើម្បីជាការផ្តល់ជាកិត្តិយសដល់រូបគាត់។

ជាមួយគ្នានោះដែរ នៅរាជធានីភ្នំពេញ ក៏មានដាក់ឈ្មោះវិថីមួយ គឺ វិថីឧកញ៉ាញឹក ជូឡុង (ផ្លូវលេខ៤៦៦) ផងដែរ ។

ក្រោយចូលនិវត្តន៍នៅក្នុងឆ្នាំ១៩៦៩ គាត់បានទៅរស់នៅប្រទេសបារាំង និងបានចូលសញ្ជាតិបារាំង ចាប់ពីពេលនោះមក។

គួរបញ្ជាក់ដែរថា ញឹក ជូឡុង រៀបការជាមួយភរិយាទី១ មានកូនចំនួនពីរនាក់ គឺៈ ឈ្មោះ ជូឡុង ប៉ូលីន (ស្រី) និងឈ្មោះ ជូឡុង បូរមី (ប្រុស)។

បន្ទាប់មក គាត់បានរៀបការជាមួយប្រពន្ធទី២ ឈ្មោះមាសកេត សម្ពស្ស និងមានកូនចំនួន ៧នាក់ សុទ្ធតែស្រី ក្នុងនោះ មានជូឡុង សូម្ប៉ា ជាប្រពន្ធ សម រង្ស៊ី ម្នាក់ដែរ ។

# ២៤៨
# មេដឹកនាំថៃ ដាក់ សុង សាក់ ជនជាតិថៃ ជាមេខ្មែរសេរីជំនួស ឡឹក សំអឿន ហៅផ្កាយព្រឹក



**នាយករដ្ឋមន្ត្រីថៃ ថ្នម គិតតិខ:ចន ព្រះមហាក្សត្រភូមិពុល អាប់ឌុលយ៉ាដេត**

អំឡុងពេលមានការបះបោររបស់ពួកខ្មែរក្រហម នៅស្រុកសំឡូត ក្នុងខែមេសា ឆ្នាំ ១៩៦៧ ស្រាប់តែមានថ្ងៃមួយ មន្ត្រីជាន់ខ្ពស់ថៃ ជាអ្នកទទួលខុសត្រូវលើចលនាតស៊ូខ្មែរសេរី បានអញ្ជើញឡឹក សំអឿន ដែលកំពុងដឹកនាំកម្លាំងតស៊ូនៅភ្នំដងរែក ឲ្យទៅជួបគេជាបន្ទាន់ នៅទីក្រុងបាងកក ព្រោះមានការចាំបាច់ត្រូវពិភាក្សាគ្នា។

ដោយសារមានការសង្ស័យអាចមានបញ្ហាមិនស្រួលហើយ ទើបបានជាមន្ត្រីជាន់ខ្ពស់ថៃ ឲ្យគាត់ទៅជួបគេជាបន្ទាន់បែបនេះ មុនថ្ងៃចេញដំណើរ គាត់បានអញ្ជើញអស់លោកជាមេបញ្ជាការជំរំតស៊ូទាំងអស់មកប្រជុំគ្នានៅជំរំកាប់គោ។

គាត់បានបញ្ជាក់ប្រាប់អង្គប្រជុំថា ការតស៊ូរបស់ពួកយើងនៅរណសិរ្សយោធាភ្នំដងរែក នេះ មានប្រទេសថៃ ជាអ្នកជួយយើងដោយផ្ទាល់ ដូច្នេះបើគេជួយយើង គេប្រាកដជាចង់បាន

ផលប្រយោជន៍ឱ្យប្រទេសជាតិគេផងដែរ។ បច្ចុប្បន្ននេះ ថៃ ជាមិត្តនឹងយើង។ ថ្ងៃណាមួយ អ្នកដែលជួយយើងនេះក្លាយទៅជាសត្រូវរបស់យើង ក៏អាចថាបាន។

មេបញ្ជាការជំរំតស៊ូទាំងអស់ មានការសង្ស័យដូចគាត់ដែរ ហើយបានឯកភាពគ្នាថា បើសិនមានហេតុការណ៍អ្វីមួយកើតឡើង ដែលអាចនាំឲ្យមានគ្រោះថ្នាក់ដល់ចលនាខ្មែរសេរីក្តី ដល់ផលប្រយោជន៍របស់ប្រទេសជាតិក្តី ពួកគេនឹងមិនសហការជាមួយមន្ត្រីថៃ ទៀតឡើយ។ បន្ទាប់មក គាត់បានប្រកាសឲ្យមេបញ្ជាការឈ្មោះវង្ស សូត នៅទទួលខុសត្រូវមូលដ្ឋានឧត្តរទិសនោះ ជំនួសគាត់។

លុះស្អែកឡើង គាត់ក៏ធ្វើដំណើរទៅទីក្រុងបាងកក ជួបឧត្តមសេនីយ៍ថៃម្នាក់ ជាអ្នកទទួលខុសត្រូវក្នុងកិច្ចប្រតិបត្តិការជាមួយចលនាខ្មែរសេរី នៅក្រសួងសន្តិសុខជាតិថៃ។ ឧត្តមសេនីយ៍ថៃរូបនោះ បានណែនាំគាត់ថា ស្ថានការណ៍នៅក្នុងប្រទេសកម្ពុជា សព្វថ្ងៃកាន់តែធ្លាក់ចុះដុនដាបទៅៗទាំងផ្នែកសេដ្ឋកិច្ច ទាំងផ្នែកនយោបាយ។ ខាងភាគីថៃ យល់ឃើញថា ស្ថានការណ៍នេះ បានហុចផលឱ្យចលនាតស៊ូខ្មែរសេរី ដូច្នេះ លោកត្រូវតែសើរើរៀបចំផែនការសាជាថ្មី ដើម្បីគាបសង្កត់រាជរដ្ឋាភិបាលសីហនុ ឱ្យដាច់ខ្យល់តែម្តង។

ផែនការថ្មី ដែលឧត្តមសេនីយ៍ថៃរូបនោះ រៀបចំឱ្យគាត់អនុវត្តនោះ គឺ៖

១.ទីស្នាក់ការកណ្តាលរបស់ចលនាតស៊ូខ្មែរសេរី ត្រូវប្តូរទីតាំងពីភ្នំដងរែក មកនៅក្នុងទីក្រុងបាងកក វិញ ដើម្បីឲ្យងាយស្រួលទាក់ទងជាមួយមន្ត្រីថៃ និងចាត់ចែងការងារឲ្យទាន់សភាពការណ៍។ ចំណែកមូលដ្ឋានបស្ចិមទិស គួរប្រគល់ឲ្យសុង សាក់ ជាទីប្រឹក្សានៃចលនាតស៊ូខ្មែរសេរី ជួយមើលការខុសត្រូវ។ ឯរូបគាត់គ្រប់គ្រងតែមូលដ្ឋានឧត្តរទិសតែមួយប៉ុណ្ណោះបានហើយ។

២.នៅតាមជំរំនីមួយៗគួរដាក់ទីប្រឹក្សាថៃ ពីររូប គឺនាយទាហានមួយរូប និងនាយទាហានរងមួយរូប ឲ្យជួយផ្តល់យោបល់ដល់មេបញ្ជាការជំរំ ព្រោះត្រូវបង្កើនសកម្មភាពទ្វេដងថែមទៀត។

៣.ដោយមានសេចក្តីអនុញ្ញាតពីរាជរដ្ឋាភិបាលថៃ ផងដែរ ត្រូវជ្រើសរើសយកពលរដ្ឋស្ម័គ្រចិត្ត ដែលនៅតាមជាយដែនខ្មែរ-ថៃ ជាពិសេសពលរដ្ឋខ្មែរនៅក្នុងទឹកដីថៃ យកមក

ហ៊ឹកហ៊ឺន ដើម្បីបង្កើនកងកម្លាំងត្រៀមបើកវាយប្រហារផ្តាច់ព្រ័ត្រ។

ឧត្តមសេនីយ៍ថៃ ក៏បានសួរយោបល់ឡឹក សំអឿន ហៅផ្កាយព្រឹក អំពីផែនការនោះដែរ។ គាត់ក៏ឆ្លើយតបទៅវិញថា នេះជាផែនការប្រពៃបំផុត ដែលគាត់ក្នុងនាមនៃចលនាតស៊ូខ្មែរសេរី និងក្នុងនាមសឹង ង៉ុកថាញ់ ជាប្រមុខ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល និងប្រជាជនថៃ ដែលមានចិត្តសប្បុរសជួយសហប្រតិបត្តិការដល់ចលនាតស៊ូខ្មែរសេរី ដើម្បីការពារវាសនាអនាគតនៃប្រជាពលរដ្ឋ និងប្រទេសខ្មែរ ឲ្យរួចផុតពីការឈ្លានពានរបស់ពួកកុម្មុយនិស្ត ដែលមានគំនិតលេបទឹកដីខ្មែរ ហើយដែលជាមហន្តរាយដល់សន្តិសុខនៃប្រទេសថៃ ផងដែរ។

គាត់បានជម្រាបឧត្តមសេនីយ៍ថៃ ថា គាត់នឹងធ្វើដំណើរទៅមូលដ្ឋានបស្ចិមទិសជាមុន ដើម្បីជូនដំណឹងនេះទៅមេបញ្ជាការជំរំនៅទីនោះ ឲ្យធ្វើសហប្រតិបត្តិការឲ្យបានជិតស្និទ្ធ ជាមួយទីប្រឹក្សាថៃ។ តែឧត្តមសេនីយ៍ថៃ បានតបមកគាត់វិញថា មិនបាច់ទៅមូលដ្ឋានបស្ចិមទិសនោះទេ ទុកឱ្យ សុង សាក់ ទៅបានហើយ។ ឯគាត់គួរតែត្រលប់ទៅមូលដ្ឋានភ្នំដងរែក ពីរបីថ្ងៃ រួចប្រញាប់វិលត្រឡប់មករៀបចំទីស្នាក់ការកណ្តាលរបស់ចលនាតស៊ូខ្មែរសេរីថ្មី នៅក្រុងបាងកកវិញ។

ស្អែកឡើង នៅពេលយប់ គាត់ក៏បានជិះរថយន្តចេញពីក្រុងបាងកក ឆ្ពោះទៅខេត្តឧប៊ុន រួចឆ្លងព្រំដែនទៅដល់ជំរំកាប់ជើង នៅវេលាម៉ោង៩ ព្រឹក។ លុះដល់វេលារសៀល គាត់ក៏ប្រជុំអស់លោកនាយទាហានគ្រប់ផ្នែក ផ្សព្វផ្សាយពីផែនការថ្មី ដែលគាត់បានប្រជុំយល់ព្រមជាមួយឧត្តមសេនីយ៍ថៃ នោះ។ គាត់បានសុំឲ្យអស់លោកមេជំរំ និងនាយទាហានគ្រប់ផ្នែក ខិតខំអប់រំពន្យល់សហការីក្រោមបង្គាប់របស់ខ្លួនឲ្យប្រុងប្រយ័ត្ន កុំឲ្យភ្លេចខ្លួន កុំជឿទៅតាមការបញ្ចុះបញ្ចូលរបស់អ្នកដទៃ(ថៃ) និងបានផ្តាំផ្ញើថា ទៅថ្ងៃមុខ គាត់ប្រហែលជាមិនបានមកធ្វើទស្សនកិច្ចតាមជំរំតស៊ូពួកយើងដោយសេរី ដូចមុនៗទៀតបានទេ។ តែប្រសិនបើបានមក ពួកយើងក៏មិនអាចនិយាយពិភាក្សាគ្នាពីរឿងសម្ងាត់បានដែរ។ ដូច្នេះអស់លោកត្រូវតែហ៊ានធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង ទៅតាមហេតុការណ៍ជាក់ស្តែងដែលកើតមានឡើង

នៅតាមជំរំនីមួយៗ ដោយមិនចាំបាច់រង់ចាំបញ្ជាពីគាត់ទេ។ ជាមួយគ្នានោះ ត្រូវតែប្រុងប្រយ័ត្នពាក្យសម្ដីក្នុងការជជែកវែកញែកជាមួយទីប្រឹក្សាថៃ ដោយត្រូវប្រើអាការៈទន់ភ្លន់ជានិច្ច ដើម្បីជាប្រយោជន៍ដល់ចលនាតស៊ូយើង តទៅទៀត។

ស្អែកឡើង គាត់បានស្នើឱ្យមេបញ្ជាការជំរំ ឈ្មោះថាច់ ស៊ុន ធ្វើពិធីជប់លៀងមួយនៅពេលល្ងាច ដោយមានច្រៀងលេងកម្សាន្តរហូតដល់ម៉ោង២២យប់។ លុះដល់ព្រឹកឡើងវេលាម៉ោង៨ គាត់ និងវង្ស សូត ព្រមទាំងសហការីគាត់មួយចំនួនទៀត បានធ្វើដំណើរទៅជំរំតាទុំ ដោយមានមេបញ្ជាការជំរំ ឈ្មោះព្រាប អ៊ិន (ព្រាប អ៊ិន ជាប្អូនប្រុសរបស់ព្រាប អ៊ិន ដែលត្រូវសម្ដេចសីហនុ ឱ្យតុលាការសឹកកាត់ទោស យកទៅចងបាញ់ប្រហារជីវិតនៅភ្នំត្រពាំងក្រឡឹង កាលពីដើមឆ្នាំ១៩៦៤)។ នៅជំរំតាទុំនោះ ពួកគាត់បានឱ្យមានការរៀបចំធ្វើកម្មវិធីជប់លៀង ដូចនៅជំរំកាប់ជើង ដែរ។

ក្រោយពីសម្រាកនៅជំរំតាទុំនោះ អស់រយៈពេលបីថ្ងៃមក ពួកគាត់ក៏ត្រលប់ទៅជំរំកាប់ជើង វិញ។ លុះដល់ស្អែកឡើង វេលារសៀល គាត់ព្រមទាំងនាយទាហានពីរនាក់ និងនាយទាហានរងបីនាក់ទៀត ក៏បានធ្វើដំណើរទៅក្រុងសុរិន្ទ ហើយមាននាយទាហានថៃម្នាក់ជូនដំណើរពួកគាត់ឡើងរថភ្លើង ដើម្បីទៅធ្វើការនៅទីស្នាក់ការកណ្ដាល របស់ចលនាតស៊ូខ្មែរសេរីថ្មី នៅទីក្រុងបាងកក។

ចាប់ពីពេលនោះមក គាត់បានដឹងច្បាស់ថា ពួកមន្ត្រីថៃ កាន់តែជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ចលនាខ្មែរសេរីខ្លាំងឡើងៗ។ នៅទីក្រុងបាងកក គាត់ហាក់ដូចជាត្រូវពួកមន្ត្រីថៃ ដកយកមកបញ្ឈរជើងចោលដែរ ព្រោះគេមិនឱ្យគាត់ដឹងពីស្ថានការណ៍នៅជំរំតស៊ូនៅរណសិរ្សភ្នំដងរែក សូម្បីបន្តិចឡើយ។

ក្រោយពេលគាត់មកនៅទីស្នាក់ការកណ្ដាល ក្នុងទីក្រុងបាងកក បានប្រហែលមួយខែស្រាប់តែពួកទីប្រឹក្សាថៃ បានចោទប្រកាន់ឈ្មោះវង្ស សូត ថា មិនធ្វើសកម្មភាពតស៊ូអ្វីទេ និងវ៉ាន់ ឈួង មេបញ្ជាការជំរំបុកអម្ពិល ថា នៅសំងំស្ងៀមតែក្នុងបន្ទាយ ហើយញុះញង់កងទ័ពឲ្យមានការរំដើបរំជួលនៅតាមជំរំទៀតផង។

ឧត្តមសេនីយ៍ថៃម្នាក់ បាននាំឈ្មោះវ៉ាន់ ឈួង មេបញ្ជាការជំរំបុកអម្ពិល មកប្រគល់ឲ្យគាត់នៅទីស្នាក់ការកណ្តាល ដើម្បីស្នើឱ្យគាត់បញ្ជូនវ៉ាន់ ឈួង និងឈ្មោះវង្ស សូត នេះទៅរណសិរ្សឃោជាវាលភក់(វៀតណាមខាងត្បូង) ហើយឲ្យគាត់តែងតាំងមេបញ្ជាការថ្មីម្នាក់ទៀត នៅជំរំបុកអម្ពិល ជំនួសឈ្មោះវ៉ាន់ ឈួង។ ពេលនោះ គាត់ក៏បានតែងតាំងឈ្មោះតោ ខាញ់ មានដើមកំណើតនៅកម្ពុជាក្រោម ជាមេបញ្ជាការរងនៅជំរំបុកអម្ពិលនោះស្រាប់ ឱ្យឡើងជាមេបញ្ជាការជំរំបុកអម្ពិល តែម្តងទៅ។

ដើម្បីឱ្យឈ្មោះវ៉ាន់ ឈួង និងឈ្មោះវង្ស សូត រួចផុតពីគ្រោះថ្នាក់ផ្សេងៗ គាត់ក៏បានរៀបចំឲ្យពួកគេធ្វើដំណើរទៅរណសិរ្សវាលភក់ (កម្ពុជាក្រោម) តាមការស្នើសុំរបស់ថៃ។ឈ្មោះវ៉ាន់ ឈួង យល់ព្រមសុខចិត្តត្រលប់ទៅរណសិរ្សវាលភក់វិញ។ ចំណែកឈ្មោះវង្ស សូត មិនព្រមត្រឡប់ទៅវិញជាដាច់ខាត ទោះបីគាត់ខំពន្យល់ពីគ្រោះថ្នាក់ ដែលអាចកើតមានដល់អាយុជីវិតគេយ៉ាងណា ក៏គេមិនព្រមត្រលប់ទៅរណសិរ្សវាលភក់វិញដែរ។

ក្រោយមក នៅថ្ងៃមួយ ឈ្មោះវង្ស សូត ចេញដំណើរទៅផ្សារម្នាក់ឯង ក៏បាត់ខ្លួនមិនឃើញត្រលប់មកស្នាក់ការវិញ ចាប់ពីពេលនោះមក។ គាត់ក៏បានរាយការណ៍ និងស្នើសុំទៅឲ្យខាងសមត្ថកិច្ចថៃ ឲ្យជួយធ្វើអន្តរាគមន៍តាមរកឈ្មោះនេះដែរ តែពួកគេគ្រាន់តែជួយធ្វើអន្តរាគមន៍ ដើម្បីជាការបង្គ្រប់កិច្ចតែប៉ុណ្ណោះ។

បន្ទាប់ពីបាត់ខ្លួន វង្ស សូត មក ពួកយុទ្ធជននៅរណសិរ្សភ្នំដងរែក មានការសង្ស័យរំជើបរំជួល មិនទុកចិត្តពួកមន្រ្តីថៃកាន់តែខ្លាំងឡើងៗ ឡឹក សំអឿន ក៏បានរួមដំណើរទៅជាមួយឧត្តមសេនីយ៍តំណាងរាជរដ្ឋាភិបាលថៃទៅធ្វើទស្សនកិច្ចនៅមូលដ្ឋានភ្នំដងរែក ដើម្បីលើកទឹកចិត្តពួកយុទ្ធជននៅទីនោះឡើងវិញ។

នៅក្នុងជំរំនីមួយៗ ឧត្តមសេនីយ៍តំណាងរាជរដ្ឋាភិបាលថៃ បានកោតសរសើរពីវីរភាពតស៊ូរបស់យុទ្ធជននៅមូលដ្ឋានភ្នំដងរែក ហើយបានសន្យាថា៖ ទី១.នឹងមានការរៀបចំកម្មវិធីឲ្យពួកយុទ្ធជននៅមូលដ្ឋានភ្នំដងរែក បានទៅសម្រាកលំហែកាយនៅក្នុងប្រទេសថៃ។ ទី២. នឹងមានការជូនរង្វាន់ដល់យុទ្ធជនណាដែលមានថ្វីដៃក្នុងការបំពេញបេសកកម្មតស៊ូ និងទី៣.

បង្កើនជំនួយគ្រប់ប្រភេទបន្ថែមទៀតចំពោះដំរំណាដែលបានធ្វើប្រតិបត្តិការពង្រីកទឹកដី តស៊ូឲ្យបានធំទូលាយ។

ចំណែក យុទ្ធជននៅតាមជំរំនីមួយៗ ក៏បានស្នើសុំឧត្តមសេនីយ៍តំណាងរាជរដ្ឋាភិបាលថៃ ថា យ៉ាងយូរ ក្នុងរយៈពេលមួយខែម្តង សូមឲ្យគាត់( ឡឹក អឿន ) ទៅធ្វើទស្សនកិច្ចនៅតាមជំរំពួកគេ ម្តង។ ឧត្តមសេនីយ៍ថៃ ក៏បានយល់ស្របតាមការស្នើសុំនោះដែរ។ ប៉ុន្តែ មួយខែក្រោយពីទស្សនកិច្ចនោះមក ស្ថានការណ៍នៅជំរំនានាគ្មានការប្រែប្រួល ការជ្រួលច្របល់នៅតែកើតមាន ខាងថៃ បានសម្រេចចិត្តអញ្ជើញសឺង ង៉ុកថាញ់ នៅរណសិរ្សយោជាវាលភក់ ( វៀតណាមខាងត្បូង ) ឱ្យមកជួយដោះស្រាយ។

ពេល សឺង ង៉ុកថាញ់ មកដល់ទីស្នាក់ការកណ្តាលរបស់ចលនាតស៊ូខ្មែរសេរី នៅទីក្រុងបាងកក ឡឹក សំអឿន ក៏បានរាយការណ៍លម្អិតជូនពីផែនការថ្មីរបស់ថៃ ដែលកំពុងអនុវត្តនៅរណសិរ្ស យោធាភ្នំដងរែក និងហេតុការណ៍ផ្សេងទៀត មានជាអាទិ៍គឺរឿងបាត់ខ្លួន វង្ស សូត និងការបញ្ជូន វ៉ាន់ ឈួង ឱ្យទៅនៅរណសិរ្សយោធាវាលភក់( វៀតណាមខាងត្បូង ) វិញផងដែរ។

លុះស្អែកឡើងម៉ោង១០ព្រឹក ឧត្តមសេនីយ៍ថៃក៏បានអញ្ជើញមេដឹកនាំចលនាតស៊ូខ្មែរសេរីតែពីរនាក់ប៉ុណ្ណោះ គឺសឺង ង៉ុកថាញ់ និងសុង សាក់ ឱ្យទៅប្រជុំពិភាក្សាការងារជាមួយគ្នានៅក្រសួងសន្តិសុខជាតិថៃ។ ដោយឡែក គាត់ជាមេដឹកនាំចលនាតស៊ូខ្មែរសេរីបន្ទាប់ពីសឺង ង៉ុកថាញ់ គេមិនឱ្យទៅចូលរួមប្រជុំនោះទេ។

បន្ទាប់ពីការប្រជុំពិភាក្សានោះមក សឺង ង៉ុកថាញ់ បានឱ្យគាត់ដឹងថា ឧត្តមសេនីយ៍ថៃបានរៀបរាប់ពីសភាពការណ៍នយោបាយសំខាន់ៗ ដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជា ( សីហនុ ចង់ងាកទៅរកអាមេរិកវិញ ? ) និងពីបញ្ហាជ្រួលច្របល់នៅតាមជំរំតស៊ូនៅភ្នំដងរែក។ ជាមួយគ្នានោះ ឧត្តមសេនីយ៍ថៃ បានលើកឡើងពីគម្រោងការថ្មីមួយចំនួន ដើម្បីឱ្យចលនាតស៊ូខ្មែរសេរី យកទៅអនុវត្ត។ ពិសេស ឧត្តមសេនីយ៍ថៃ បានស្នើសុំសឺង ង៉ុកថាញ់ ឱ្យតែងតាំងសុង សាក់ ដែលជាទីប្រឹក្សាចលនាតស៊ូខ្មែរសេរី នៅព្រំដែនថៃ ធ្វើជាមេដឹកនាំនៅរណសិរ្ស

យោធាភ្នំដងរែក ជំនួសគាត់( ឡឹក សំអឿន )វិញ។

សឺង ង៉ុកថាញ់ បានឯកភាពថា សភាពការណ៍នយោបាយដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជា គឺដូចអ្វីដែលឧត្តមសេនីយ៍ថៃ បានលើកឡើងពិតមែន។ រីឯគម្រោងការថ្មីដែលឧត្តមសេនីយ៍ថៃ ឱ្យចលនាតស៊ូខ្មែរសេរី យកទៅអនុវត្តនោះ គឺជាការហុចផលទៅឲ្យពួកកុម្មុយនិស្ត ជាសត្រូវរួមរបស់យើងទៅវិញទេ។

សឺង ង៉ុកថាញ់ បានបន្ថែមថា គោលនយោបាយរបស់ចលនាខ្មែរសេរី ដែលប្រឆាំងនឹងនយោបាយរបស់រាជរដ្ឋាភិបាលសម្តេចសីហនុ នោះ ក៏ព្រោះតែសម្តេចសីហនុ បានងាកទៅរកប្លុកកុម្មុយនិស្ត បម្រើផលប្រយោជន៍កុម្មុយនិស្ត បណ្តាលឲ្យមានភ្លើងសង្គ្រាមឆាបឆេះរាលដាលចូលមកក្នុងទឹកដីខ្មែរ ហើយភ្លើងសង្គ្រាមនេះ មុខជានឹងឆាបឆេះរាលដាលចូលមកក្នុងទឹកដីថៃ និងបណ្តាប្រទេសទាំងអស់នៅអាស៊ីភាគអាគ្នេយ៍ ជាមិនខាន។

បច្ចុប្បន្ននេះ ការរំជើបរំជួលដែលកើតមានឡើងដោយសារអំពើវិទ្ធង្សនារបស់កុម្មុយនិស្តយួន ធ្វើឱ្យពលរដ្ឋខ្មែរទូទាំងប្រទេស រួមទាំងសម្តេចសីហនុ ផងដែរ មានការព្រួយបារម្ភថាពួកកុម្មុយនិស្តយួន នឹងលេបទឹកដីខ្មែរ។ ដូច្នេះ សម្តេចសីហនុ បានចាត់វិធានការបង្ក្រាបពួកកុម្មុយនិស្តខ្មែរ ដែលជាកូនជើងរបស់ពួកកុម្មុយនិស្តយួន នៅទូទាំងប្រទេសកម្ពុជា ព្រមទាំងពួកកុម្មុយនិស្តខ្មែរ ដែលបង្កប់ខ្លួននៅក្នុងជួររាជរដ្ឋាភិបាលទៀតផង។ ដូច្នេះ ការតស៊ូរបស់ចលនាខ្មែរសេរី បានញ៉ាំងឲ្យសម្តេចសីហនុ ភ្ញាក់ខ្លួន រួចទទួលស្គាល់ថា ការពឹងផ្អែកទៅលើពួកកុម្មុយនិស្តចិន-យួន របស់ព្រះអង្គ គឺជាការនាំមកនូវមហន្តរាយដល់ប្រទេសជាតិ ដូចចលនាខ្មែរសេរី បានប្រកាសប្រាប់តាំងពីឆ្នាំ១៩៥៧ ប្រាកដមែន។ អាស្រ័យហេតុនេះ តើយើងត្រូវជួយរាជរដ្ឋាភិបាលខ្មែរ ដែលកំពុងប្រយុទ្ធបង្ក្រាបពួកកុម្មុយនិស្ត ឬមួយត្រូវសង្កត់កថែម?។

ចំណែកបញ្ហាផ្ទៃក្នុងរបស់ចលនាខ្មែរសេរីវិញ សឺង ង៉ុកថាញ់ បានបញ្ជាក់ប្រាប់ទៅឧត្តមសេនីយ៍ថៃ ថា បញ្ហាផ្លាស់ប្តូរតែងតាំងសុង សាក់ ឱ្យធ្វើជាមេដឹកនាំនៅរណសិរ្សយោធាភ្នំដងរែក ជំនួសគាត់( ឡឹក សំអឿន )នោះ លោកពុំអាចធ្វើកើតទេ ដោយហេតុថា មិនទាន់

មានការផ្លាស់ប្ដូរជាផ្លូវការផង ស្រាប់តែមានការរីករាលដាលច្របូកច្របល់នៅតាមជំរំនានានៅភ្នំដងរែក ប៉ុណ្ណឹងទៅហើយ ចុះទម្រាំបើមានការផ្លាស់ប្ដូរតែងតាំងសុង សាក់ ឲ្យធ្វើជាមេដឹកនាំ តើនៅរណសិរ្សយោធាភ្នំដងរែកនោះ នឹងមានការរីករាលដាលច្របូកច្របល់ខ្លាំងយ៉ាងណាទៅ?។

ដូច្នេះ សឺង ង៉ុកថាញ់ បានស្នើសុំកុំឲ្យខាងភាគីថៃ លូកដៃចូលជ្រៀតជ្រែកដល់កិច្ចការផ្ទៃក្នុងរបស់ចលនាខ្មែរសេរីឲ្យសោះ បើពុំនោះទេ វាអាចនឹងនាំឲ្យមានផលអាក្រក់ដល់គម្រោងការរបស់យើងជាមិនខាន ហើយលោកនឹងមិនទទួលខុសត្រូវក្នុងរឿងនេះទេ។

បន្ទាប់ពីបានឮសឺង ង៉ុកថាញ់ លើកហេតុផលដូច្នេះ សុង សាក់ ក៏ប្រតិកម្មស្ទុះក្រោកឈរឡើងថា បើចលនាខ្មែរសេរី មិនត្រូវការរូបគេទេ គេនឹងសុំលាឈប់ពីតំណែងជាទីប្រឹក្សានៃចលនាខ្មែរសេរី...។ សឺង ង៉ុកថាញ់ ឆ្លើយទៅវិញភ្លាមថា លោកយល់ព្រមតាមការស្នើសុំរបស់សុង សាក់ ។ រំពេចនោះ បរិយាកាសអាប់អួរនៅក្នុងអង្គប្រជុំបានកើតមានឡើង។ ចំណែកឧត្តមសេនីយ៍ថៃ ក៏កប់យោបល់ នៅស្ងៀម។ ដូច្នេះ បញ្ហាឧត្តមសេនីយ៍ថៃ ស្នើសុំផ្លាស់ប្ដូរតែងតាំងសុង សាក់ ឱ្យទៅធ្វើជាមេដឹកនាំចលនាខ្មែរសេរី ជំនួសគាត់ នៅរណសិរ្សយោធាភ្នំដងរែកនោះ មិនបានសម្រេចដូចបំណងឡើយ។

មុនបិទអង្គប្រជុំ ឧត្តមសេនីយ៍ថៃ បានសុំឲ្យសឺង ង៉ុកថាញ់ ទៅធ្វើទស្សនកិច្ចនៅតាមជំរំតស៊ូនានានៅភ្នំដងរែកដែរ។ ប៉ុន្តែ លោកបានបដិសេធ ដោយសំអាងថា មានកិច្ចការ មមាញឹកក្នុងកិច្ចសហប្រតិបត្តិការជាមួយសម្ព័ន្ធមិត្ត (វៀតណាមខាងត្បូង) នៅឯរណសិរ្សយោធាវាលភក់ (កម្ពុជាក្រោម)។

បន្ទាប់ពីវិលត្រលប់មកដល់សណ្ឋាគារស្នាក់នៅវិញ សឺង ង៉ុកថាញ់ និងគាត់ មិនបាននិយាយអ្វីជាការសម្ងាត់ទេ ព្រោះកងរក្សាសន្តិសុខថៃ នៅយាមត្រៀបត្រា។ ស្អែកឡើង ម៉ោង ៦ព្រឹក មុននឹងឡើងយន្តហោះត្រលប់ទៅរណសិរ្សយោធាវាលភក់(កម្ពុជាក្រោម)វិញ សឺង ង៉ុកថាញ់ បានផ្ដាំគាត់ថា បើយើងអាចធ្វើសហប្រតិបត្តិការជាមួយពួកគេកើត ក៏ធ្វើទៅចុះ តែបើមិនកើតទេ យើងចាំជួបគ្នានៅភ្នំពេញ។

# ២៤៩
# កងទ័ពខ្មែរសេរី ដែលថៃ គ្រប់គ្រង នាំគ្នាមកចុះចូលជាមួយសម្ដេចសីហនុ



**សម្ដេចសីហនុ**

ចាប់ពីពេលនោះមក សឹង ង៉ុកថាញ់ ក៏ឈប់ទាក់ទងមករក ឡឹក សំអឿន ហើយមិនដឹងថា នរណាជាអ្នកទទួលខុសត្រូវចលនាតស៊ូនៅរណសិរ្សភ្នំដងរែកដែរ។ ចំណែក ឡឹក សំអឿន វិញ ក៏ពុំអាចទៅធ្វើទស្សនកិច្ចនៅមូលដ្ឋានបស្ចិមទិស នៅឯភ្នំម៉ាឡៃ បានទៀតដែរ។ ប៉ុន្តែយ៉ាងណា គាត់បានដឹងថា ភាគីថៃ បានផ្ដល់ជំនួយច្រើនជាងមុន និងបាននាំយុទ្ធជនរបស់គាត់ទៅដើរកម្សាន្តសប្បាយនៅតាមទីក្រុងផ្សេងៗ ព្រមទាំងមានការហ្វឹកហ្វឺនកងកម្លាំងបម្រុង ដូចដែលឧត្ដមសេនីយ៍ជាតំណាងរាជរដ្ឋាភិបាលថៃ បានសន្យានៅពេលធ្វើទស្សនកិច្ចនៅមូលដ្ឋានភ្នំដងរែក កាលពីលើកមុននោះប្រាកដមែន។ ដោយឡែក ចំពោះមេបញ្ជាការជំរំ និងនាយទាហាន ត្រូវបានគេយកចិត្តទុកដាក់ជាពិសេស។

លុះមកដល់ពាក់កណ្ដាលខែតុលា ឆ្នាំ១៩៦៩ គឺក្រោយបង្កើតរាជរដ្ឋាភិបាលស្រោច

ស្រង់ជាតិ ដែលមានឧត្តមសេនីយ៍លន់ នល់ ជានាយករដ្ឋមន្ត្រី បានបីខែ ស្រាប់តែថ្ងៃមួយ មានវរសេនីយ៍ឯកម្នាក់នៅក្រសួងសន្តិសុខថៃ និងជាសមាជិកនៃគណៈកម្មការសហប្រតិបត្តិការជាមួយចលនាខ្មែរសេរីម្នាក់ដែរនោះ បានមកជួបគាត់ រួចសុំឲ្យគាត់ធ្វើដំណើរជាមួយគេទៅធ្វើទស្សនកិច្ចនៅមូលដ្ឋានតស៊ូនៅភ្នំដងរែក។

នៅថ្ងៃដដែលនោះ គាត់ក៏បានចេញដំណើរតាមរថភ្លើងពីក្រុងបាងកក ទៅដល់ស្ថានីយសុរិន្ទ វេលាម៉ោង៦ល្ងាច ឃើញរថយន្តហ្ស៊ីបមួយគ្រឿងមករង់ចាំទទួលគាត់ ដើម្បីបន្តដំណើរទៅបន្ទាយតម្រួតថៃមួយ ឈ្មោះបន្ទាយកាប់ជើង។

នៅទីនោះ គាត់បានទទួលដំណឹងថា កងកម្លាំងតស៊ូខ្មែរសេរីរបស់គាត់ទាំងអស់នៅជំរំភ្នំត្រងិល និងនៅជំរំបោកប៉ុស្រីស្រណោះ បាននាំគ្នាចាកចេញពីជំរំ ចុះពីលើភ្នំកាលពីល្ងាចម្សិលមិញ ទៅចុះចូលជាមួយសម្ដេចសីហនុ អស់ហើយ។ ឯនៅជំរំភ្នំស្រួចវិញ មិនទាន់ដឹងជាយ៉ាងណាទេ ?

ពេលនោះវរសេនីយ៍ឯកថៃ បានឱ្យតម្រួតថៃនៅបន្ទាយកាប់ជើងនោះ ទាក់ទងទៅតម្រួតថៃនៅភូមិតាទុំ ឲ្យទៅឈ្លបយកការណ៍ពីកងកម្លាំងតស៊ូខ្មែរសេរីរបស់គាត់នៅជំរំតាទុំតើយ៉ាងណាដែរ ?។

មួយម៉ោងក្រោយមក តម្រួតថៃ នៅភូមិតាទុំ ក៏បានរាយការណ៍មកវិញថា កងកម្លាំងខ្មែរសេរីនៅទីនោះមិនទាន់ចាកចេញទៅណាទេ។ វរសេនីយ៍ឯកថៃ បានស្នើសុំឱ្យគាត់ ( ឡឹក សំអឿន ) ទៅជួបទាក់ទងធ្វើយ៉ាងណា កុំឲ្យកម្លាំងខ្មែរសេរីទាំងនោះ ទៅចុះចូលជាមួយសម្ដេចសីហនុ ដូចនៅជំរំភ្នំត្រងិល និងនៅជំរំបោកប៉ុស្រីស្រណោះទៀត ហើយវរសេនីយ៍ឯកថៃ បានសន្យាថា បើកម្លាំងខ្មែរសេរីទាំងនោះស្នើសុំឱ្យមានលក្ខខណ្ឌអ្វី រាជការថៃ នឹងយល់ព្រមទទួលយកទាំងអស់។ គាត់បានយល់ព្រមថា គាត់នឹងព្យាយាមទៅបញ្ចុះបញ្ចូលពួកគេសាកមើល តែបានសម្រេច ឬមិនបានសម្រេចនោះ គាត់មិនហ៊ានធានាទេ។

បន្ទាប់មក គាត់ និងតម្រួតថៃមួយក្រុម ក៏បានជិះរថយន្តហ្ស៊ីបពីរគ្រឿងទៅដល់ភូមិតាទុំ ហើយគាត់ពឹងអ្នកនាំផ្លូវម្នាក់ដែលធ្លាប់ចេញចូលជំរំតាទុំ ឲ្យជូនគាត់ទៅ ដោយទុកពួក

មន្ត្រីថៃ ឲ្យនៅរង់ចាំនៅភូមិតាទុំនោះ។

វេលាម៉ោង៥ល្ងាច គាត់ក៏បានចូលទៅដល់ក្នុងជំរំ ឃើញពួកយុទ្ធជនរៀបចំខ្លួនជាស្រេច ដើម្បីចេញដំណើរចុះពីលើភ្នំដែរ តែត្រូវនៅរង់ចាំពួកគេមួយក្រុមទៀត ដែលចុះទៅធ្វើប្រតិបត្តិការ មិនទាន់ត្រលប់មកវិញ។

ពេលនោះ គាត់បានប្រមូលមេបញ្ជាការជំរំ និងនាយទាហានគ្រប់ផ្នែក ឲ្យមកអង្គុយជុំគ្នា ហើយបានថ្លែងនូវការគោរពកោតសរសើរចំពោះការសម្រេចចិត្តទៅចុះចូលជាមួយសម្ដេចសីហនុ របស់ពួកគេ។ តែគាត់បានពន្យល់ហេតុផលថា៖

ទី១. តំណាងរាជការថៃ បានស្នើសុំឱ្យគាត់មកជួបទាក់ទងជាមួយពួកគេ ឃាត់កុំឲ្យទៅចុះចូលជាមួយសម្ដេចសីហនុ ធ្វើអ្វី ដោយខាងរាជការថៃ បានសន្យាថា នឹងធ្វើតាមសំណូមពររបស់ពួកគេហើយ។

ទី២. ក្នុងឋានៈគាត់ជាអ្នកទទួលខុសត្រូវនៅរណសិរ្សយោធាភ្នំដងរែក គាត់មានភារកិច្ចត្រូវដោះស្រាយយ៉ាងណា កុំឲ្យមានផលអាក្រក់ដល់វាសនាអនាគតរបស់សមាជិកខ្មែរសេរី ដែលកំពុងស្ថិតនៅឯទីស្នាក់ការកណ្ដាលនៅក្រុងបាងកក ដែលជាមិត្តរួមអាវុធរបស់យើងគ្រប់គ្នា។ បើគាត់មិនមកជួបនិយាយហេតុផលជាមួយគ្នាយើងនៅជំរំតាទុំនេះ តាមការស្នើសុំរបស់រាជការថៃ ទេនោះ គាត់ជឿថា មិត្តភក្តិយើងចំនួន១៧នាក់ រួមមានក្រុមបញ្ជាការ និងក្រុមវិទ្យុ នៅឯក្រុងបាងកក នោះ ប្រាកដជាមានបញ្ហាជាមិនខានឡើយ។

ក្រោយពីស្ដាប់ការលើកហេតុផលរបស់ឡឹក សំអឿន ដូចខាងលើរួចមក មេបញ្ជាការជំរំ និងនាយទាហានទាំងអស់ ក៏បានយល់ព្រមប្ដូរចិត្ត មិនទៅចុះចូលជាមួយសម្ដេចសីហនុវិញដែរ តែពួកគេដាក់លក្ខខណ្ឌជាមួយរាជការថៃ ចំនួន៥ចំណុចគឺ ៖ ទី១. សុំឱ្យរាជការថៃ ជួយដឹកជញ្ជូនយុទ្ធជនទាំងឡាយណា ដែលមានបំណងចង់ទៅរស់នៅឯរណសិរ្សយោធាវាលកក់ ត្រូវបញ្ជូនពួកគេទៅកម្ពុជាក្រោមវិញ។ ទី២. យុទ្ធជនទាំងឡាយណា មានដើមកំណើតនៅក្នុងប្រទេស ថៃនោះ សុំឱ្យរាជការថៃ បញ្ជូនត្រលប់ទៅស្រុកកំណើតពួកគេវិញ ដោយមិនមានយកទោស ពៃរ៍ អ្វីឡើយ។ ចំណែកយុទ្ធជនទាំងឡាយណា មិនមានស្រុកកំណើតនៅប្រទេស

ថៃ តែបើពួកគេចង់រស់នៅក្នុងប្រទេសថៃ នោះ សុំឱ្យរាជការថៃ អនុញ្ញាត និងការជួយផ្ទុងផ្តើម ពួកគេឲ្យមានមុខរបររកស៊ីផង។

ទី៣. គ្រឿងអាវុធយុទ្ធភណ្ឌរបស់ពួកខ្មែរសេរីទាំងអស់ ដែលត្រូវវិលត្រលប់ទៅរស់នៅកម្ពុជាក្រោម នឹងត្រូវប្រគល់ឲ្យខាងភាគីថៃ វិញ នៅថ្ងៃឡើងយន្តហោះវិលត្រលប់ទៅកម្ពុជាក្រោមវិញ។

ទី៤. មន្ត្រី និងយុទ្ធជននៅទីស្នាក់ការកណ្តាល នៅក្រុងបាងកក ដែលត្រូវទៅរស់នៅកម្ពុជាក្រោមវិញ ត្រូវយកមកឱ្យស្នាក់នៅជុំគ្នាក្នុងជំរំបណ្តោះអាសន្នមួយ ដើម្បីរង់ចាំចេញដំណើររួមគ្នា។

ទី៥. ក្នុងរយៈពេលដែលរង់ចាំនេះដែរ មេបញ្ជាការភ្នំដងរែក ត្រូវទាក់ទងជាមួយរាជការថៃ ហើយត្រូវមកស្នាក់នៅក្នុងជំរំបណ្តោះអាសន្ននេះដែរ។

បន្ទាប់មក គាត់ក៏បានចេញទៅជួបពិភាក្សាជាមួយយុទ្ធជនទាំងអស់ក្នុងជំរំ ដោយបានលើកឡើងពីមូលហេតុដែលនាំឲ្យកងកម្លាំងខ្មែរសេរីនៅគ្រប់ជំរំក្នុងមូលដ្ឋានឧត្តរទិសសម្រេចចិត្តទៅចុះចូលជាមួយសម្តេចសីហនុ និងរាជរដ្ឋាភិបាលស្រោចស្រង់ជាតិថា នេះជាការសម្រេចចិត្តដ៏ត្រឹមត្រូវ។ ជាគំនិតអ្នកជាតិនិយមពិតប្រាកដ ដែលគាត់សូមកោតសរសើរអស់ពីដួងចិត្ត។

បន្ទាប់មកទៀត គាត់ក៏បាននាំមេបញ្ជាការជំរំ និងនាយទាហានគ្រប់ផ្នែក ទៅជួបផ្ទាល់ជាមួយវរសេនីយ៍ឯក ជាតំណាងរាជការថៃ ដើម្បីពិភាក្សាគ្នាអំពីលក្ខខណ្ឌទាំងអស់ដែលពួកគេបានស្នើសុំនោះ រួចក៏បានកំណត់ពេលវេលារយៈពេល៣ខែទៀត នឹងយករថយន្តមកដឹកជញ្ជូនពួកគេទាំងអស់ទៅកាន់ជំរំបណ្តោះអាសន្នមួយ នៅក្នុងទឹកដីថៃ។

លុះមកដល់ថ្ងៃកំណត់ តំណាងរាជការថៃ និងគាត់ ( ឡឹក សំអឿន ) ក៏បានយករថយន្តហ្សេអឹមសេ ចំនួន១០ គ្រឿង ទៅដឹកពួកគេចូលមកក្នុងទឹកដីប្រទេសថៃ។ យុទ្ធជនណាមានស្រុកកំណើតនៅក្នុងប្រទេសថៃ និងអ្នកដែលស្ម័គ្រចិត្តរស់នៅក្នុងប្រទេសថៃ ត្រូវដឹកយកទៅឲ្យស្នាក់នៅបណ្តោះ អាសន្ននៅក្នុងបន្ទាយតម្រួតកាប់ជើង របស់ថៃ មុននឹងធ្វើដំណើរ

ទៅភូមិកំណើតពួកគេវិញ។

ឯយុទ្ធជន ដែលត្រូវវិលត្រលប់ទៅរណសិរ្សវាលភក់(កម្ពុជាក្រោម)ត្រូវដឹកយកទៅឲ្យស្នាក់នៅជាបណ្តោះអាសន្ននៅឯជំរំស្តុត(ជំរំកាយរិទ្ធ)មួយ ក្នុងព្រៃដាច់ស្រយាលមួយក្នុងខេត្តបុរីរ៉ាំ ចំងាយប្រមាណ២០គីឡូម៉ែត្រ ពីព្រំដែនខ្មែរ។ ចំណែកឯយុទ្ធជន ដែលនៅទីស្នាក់ការកណ្តាលក្រុងបាងកកចំនួន១៧រូប ត្រូវត្រលប់ទៅរណសិរ្សយោធាវាលភក់វិញដែរនោះ ក៏ត្រូវបានគេដឹកជញ្ជូនឲ្យទៅស្នាក់នៅជំរំស្តុត(ជំរំកាយរិទ្ធ)នោះដែរ។

ក្នុងរយៈពេលតែពីសប្តាហ៍ប៉ុណ្ណោះ គេបានបញ្ជូនកម្លាំងខ្មែរសេរីទាំងអស់នៅប្រទេសថៃ ទៅកម្ពុជាក្រោម(ប្រទេសយួនខាងត្បូង)តាមយន្តហោះសេ១២៣ របស់កងទ័ពអាកាសយួនខាងត្បូង។ ពេលនោះហើយដែលគ្រឿងអាវុធយុទ្ធភណ្ឌទាំងអស់ ត្រូវប្រគល់ឲ្យខាងរាជការថៃ វិញ ។

ចំណែក ឡឹក សំអឿន ព្រមទាំងអ៊ឹង ម៉េងគ្រុយ និងប្រពន្ធ ដែលសុំរស់នៅប្រទេសថៃ ត្រូវបានឧត្តមសេនីយ៍តម្រួតថៃ ឆណៈ សមុទ្ទ ផាណិជ ជាអ្នកមើលការខុសត្រូវ ហើយខាងរាជការថៃ បានជួយឧបត្ថម្ភថវិកាសម្រាប់ចំណាយទៅលើការជួលផ្ទះស្នាក់នៅ និងម្ហូបអាហារជាបណ្តោះអាសន្ន ទម្រាំរកការងារបានធ្វើចិញ្ចឹមជីវិតដោយខ្លួនឯង។ ប៉ុន្តែ បានតែរយៈពេលមួយអាទិត្យប៉ុណ្ណោះ ស្រាប់តែព្រឹកមួយ ឧត្តមសេនីយ៍តម្រួតថៃ ឆណៈ សមុទ្ទ ផាណិជ បានមកនាំឡឹក សំអឿន និងអ៊ឹង ម៉េងគ្រុយ យកទៅក្រសួងសន្តិសុខជាតិថៃ ដោយគាត់ពុំបានដឹងថា មានរឿងអ្វីឡើយ?។

នៅពេលទៅដល់ក្រសួងសន្តិសុខជាតិនោះ គ្រាន់តែចុះពីលើរថយន្តភ្លាម ស្រាប់តែមានកងរាជអាវុធហត្ថពីរនាក់ នាំពួកគាត់យកទៅបញ្ចូលក្នុងកន្លែងឃុំឃាំងអស់រយៈពេលបីថ្ងៃបីយប់ ដោយពុំបានសួរនាំអ្វីបន្តិចឡើយ។ ពួកគាត់ព្រួយបារម្ភក្នុងចិត្តឥតឧបមា លើកដៃបួងសួងបន់ស្រន់នឹកដល់គុណម្តាយឪពុក គុណព្រះពុទ្ធព្រះធម៌ព្រះសង្ឃ អារុក្ខរក្សទេវតាឥន្ទ្រព្រហ្មសូមជួយពួកគាត់ឱ្យបានរួចផុតពីទុក្ខទោសផង។

លុះដល់ថ្ងៃទី៤ វេលាម៉ោង១០ព្រឹក ឧត្តមសេនីយ៍តម្រួតថៃ ឆណៈ សមុទ្ទ ផាណិជ

ក៏បានមកទទួលពួកគាត់ទាំងពីរនាក់យកទៅផ្ទះវិញ។

នៅលើរថយន្តតាមផ្លូវ ឧត្តមសេនីយ៍តម្រួតថៃរូបនេះ បានបញ្ជាក់ប្រាប់ពួកគាត់ថា មូលហេតុដែលនាំឲ្យពួកគេចាប់ពួកគាត់យកមកឃុំឃាំងនេះ គឺដោយសារពួកខ្មែរសេរីនៅមូលដ្ឋានបស្ចិមទិស ដែលបាននាំគ្នាទៅចុះចូលជាមួយសម្តេចសីហនុ បានចាប់វរសេនីយ៍ត្រីថៃម្នាក់ និងពលបាលឯកថៃម្នាក់ទៀត ជាទីប្រឹក្សាចលនាតស៊ូខ្មែរសេរី ទៅជាមួយផងដែរ។ រឿងនេះគេសង្ស័យថា គាត់ និងអ៊ឹង ម៉េងគ្រុយ ជាអ្នកបញ្ជាឲ្យធ្វើ។

ដូច្នេះ ក្រសួងសន្តិសុខជាតិថៃ ត្រូវតែចាប់គាត់ និងអ៊ឹង ម៉េងគ្រុយ យកទៅឃុំ ដើម្បីទុកធ្វើជាថ្នូរដូរយកវរសេនីយ៍ត្រី និងពលបាលឯកថៃ ពីរនាក់នោះពីសម្តេចសីហនុ មកវិញ។ ប៉ុន្តែ រាជរដ្ឋាភិបាលថៃ មិនយល់ស្របតាមគំនិតរបស់ក្រសួងសន្តិសុខជាតិថៃ បែបនេះទេ។

បន្ទាប់មក រាជរដ្ឋាភិបាលថៃ បានទាក់ទងស្នើឱ្យមន្ត្រីស្ថានទូតភូមាប្រចាំប្រទេសកម្ពុជា ជួយទាក់ទងរាជរដ្ឋាភិបាលខ្មែរ ដើម្បីធ្វើយ៉ាងណាឱ្យដោះលែងតម្រួតថៃពីរនាក់ជាទីប្រឹក្សាចលនាតស៊ូខ្មែរសេរីនោះវិញ។ ជាមួយគ្នានោះ រាជរដ្ឋាភិបាលថៃ ក៏បានប្រកាសថា បើជនណាម្នាក់ អាចជួយធ្វើអន្តរាគមន៍ឱ្យរាជរដ្ឋាភិបាលខ្មែរ ដោះលែងតម្រួតថៃពីរនាក់នោះមកវិញ រាជរដ្ឋាភិបាលថៃ នឹងជូនប្រាក់រង្វាន់ចំនួន២សែនបាត (ស្មើនឹង១ម៉ឺនដុល្លារអាមេរិក)។

មួយអាទិត្យក្រោយមក គាត់ក៏រកការងារបានធ្វើនៅស្ថានទូតបារាំង ប្រចាំប្រទេសថៃ ដោយបានប្រាក់ខែ ល្មមរស់បាន ដោយមិនចាំបាច់ពឹងផ្អែកលើប្រាក់ជំនួយរាជការថៃ ទៀតទេ។ ចំណែក អ៊ឹង ម៉េងគ្រុយ និងភរិយា ក្រោយពីព្យាយាមរកការងារនៅទីក្រុងបាងកក រយៈពេលមួយខែពុំបានសម្រេចដូចបំណង បាននាំគ្នាធ្វើដំណើរទៅរស់នៅឯទីក្រុងព្រៃនគរ (វៀត-ណាមខាងត្បូង) វិញ។

ចាប់ពីពេលនោះមក ទំនាក់ទំនងរវាងចលនាតស៊ូខ្មែរសេរី និងរាជរដ្ឋាភិបាលថៃ ព្រមទាំងសកម្មភាពតស៊ូទាំងអស់នៅរណសិរ្សយោធាភ្នំដងរែក ត្រូវបានបញ្ចប់ជាស្ថាពរ។ រីឯរណសិរ្សវាលភក់ នៅកម្ពុជាក្រោម នៅតែធ្វើសកម្មភាពរបស់ខ្លួនបន្តទៀត។

ឡឹក សំអឿន បញ្ជាក់ថា ទាក់ទងដល់ការបញ្ជូនកម្លាំងខ្មែរសេរីទាំងអស់នៅប្រទេស

ថៃ ទៅកម្ពុជាក្រោម(ប្រទេសយួនខាងត្បូង) នោះ គាត់ក៏មិនដឹងថា កម្លាំងខ្មែរសេរីទាំងអស់ នោះ គេដឹកយកទៅប្រគល់ឲ្យសឹង ង៉ុកថាញ់ នៅរណសិរ្សវាលភក់នោះ ឬមួយគេយកទៅ រំសាយឲ្យទៅនៅតាមភូមិកំណើតរៀងៗខ្លួន វិញ ឬយ៉ាងណានោះ គាត់ក៏មិនដឹងដែរ។ ប៉ុន្តែ រហូតទាល់តែដល់ខែមេសា ឆ្នាំ១៩៧០ គឺ ក្រោយថ្ងៃធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ បានមួយខែ ទើបគាត់បានដឹងថា ពួករដ្ឋការ យួនខាងត្បូង បានយកយន្តហោះសេ១២៣ មកដឹកកម្លាំងខ្មែរសេរី ពីប្រទេសថៃនោះ មិន មែនយកទៅប្រគល់ឲ្យសឹង ង៉ុកថាញ់ ឬយក ទៅរំសាយឲ្យទៅនៅតាមភូមិកំណើតរៀងៗ ខ្លួនវិញទេ គឺគេយកទៅដាក់នៅគុកកោះត្រឡាច ហើយបានដោះលែងឲ្យមានសេរីភាពវិញ ក្រោយព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចសីហនុ ក្នុងខែមីនា នោះ។


**មេខ្មែរសេរីឈ្មោះជី ប៊ុនសខ**

នៅដើមខែមករា ឆ្នាំ១៩៦៩ វិទ្យុផ្សាយសំឡេងភ្នំពេញ បានផ្សព្វផ្សាយព័ត៌មានថា ពីថ្ងៃទី០៤ ដល់ថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៦៩ កងកម្លាំងខ្មែរសេរីចំនួន២០៥នាក់ ដឹកនាំ ដោយ ជី ប៊ុនសង បាននាំគ្នាទៅចុះចូលជាមួយសម្តេចសីហនុ នៅខេត្តបាត់ដំបង ជាបន្តបន្ទាប់ ដោយនាំយកនូវអាវុធយុទ្ធភណ្ឌ និងគ្រឿងចក្រឈូសឆាយដីមួយចំនួន មកជាមួយផង។ ពិសេសបាននាំតម្រួតថៃពីរនាក់ជាទីប្រឹក្សាចលនាតស៊ូខ្មែរសេរីនោះ ទៅជាមួយផង។

នៅថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៦៩ នៅទីក្រុងភ្នំពេញ មានរៀបចំធ្វើពិធីទទួលកងទ័ពខ្មែរ សេរី ដែលមកចុះចូលនោះ ជាផ្លូវការនៅទីលានវាលព្រះមេរុ។ ក្នុងពិធីនោះ សម្តេចសីហនុ ចាត់ទុកការចុះចូលនោះ គឺជាប្រវត្តិសាស្ត្រដ៏អស្ចារ្យមួយ និងចាត់ទុកថានេះជាមហាជ័យជម្នះ

មួយ នៃនយោបាយបង្រួបបង្រួមជាតិរបស់ព្រះអង្គ។

បន្ទាប់មកទៀត នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ ១៩៦៩ កងទ័ពខ្មែរសេរីចំនួន២៩៤នាក់ទៀត ក៏បាននាំគ្នាចេញពីទីតាំងរបស់ពួកគេនៅភ្នំម៉ាឡៃ ខេត្តបាត់ដំបង មកចុះចូលជាមួយសង្គមជាតិវិញ។ ពិធីទទួលស្វាគមន៍កងទ័ពខ្មែរសេរី ទាំង២៩៤នាក់នោះ បានប្រារព្ធធ្វើឡើងនៅទីលានវាលព្រះមេរុ យ៉ាងអធិកអធម ក្រោមព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចសីហនុ ជាព្រះប្រមុខរដ្ឋ។

ក្នុងអំឡុងនៃការចុះចូលរបស់កងទ័ពខ្មែរសេរីនោះដែរ ក៏មានពួកទាហានខ្មែរកម្ពុជាក្រោមដែលជាកងទ័ពពិសេស នៅប្រទេសវៀតណាមខាងត្បូង ក៏បាននាំគ្នារត់ភៀសខ្លួនមកសុំជ្រកកោនជាមួយសម្តេចសីហនុ ជាបន្តបន្ទាប់ ដោយនាំគ្នាមកជាក្រុមតូចៗ មានគ្នាពី១០ ទៅ៤០នាក់ ជាមួយនូវអាវុធតូចធំ និងសម្ភារសឹកផ្សេងៗទៀត។

សម្តេចសីហនុ បានវាយតម្លៃជាសាធារណៈថា ការចុះចូលមករួមរស់នៅក្នុងសង្គមជាតិរបស់ពួកអ្នកទាំងអស់នេះ គឺបង្ហាញពីទឹកចិត្តស្នេហាជាតិ ស្នេហាមាតុភូមិ ដ៏បរិសុទ្ធរបស់ពួកគេផងដែរ។

---

# ២៥០
# ជីវិតរបស់ សម រង្ស៊ី
# ពេលទៅដល់ក្រុងប៉ារីស ដំបូង



**សម រង្ស៊ី (រូបតូចជាងគេ) និងម្តាយ ព្រមទាំងបងៗទាំង៤**

ពេលទៅដល់ស្ថានីយរថភ្លើងលីយ៉ុង លោកឡេអុង ស្ទែហ្ស៍ម៉ារតាំង ប្រាប់ពួកគាត់ឱ្យបំបែកគ្នា ដោយបងប្រុសគាត់ទាំង៣នាក់ គឺអេម៉្មារិទ្ធ, មិជារី និងអេម៉្មារ៉ា ទៅស្នាក់នៅបណ្តោះអាសន្ននៅផ្ទះរបស់លោក។ ចំណែកគាត់(សម រង្ស៊ី), បងស្រីអេម៉្មារ៉ាន និងម្តាយគាត់ត្រូវទៅស្នាក់នៅបណ្តោះអាសន្នជាមួយគ្រួសារហ្សែកដង់ នៅក្បែរទីលានត្រូកាដឺរ៉ូ (Trocadero)។ នៅតាមផ្លូវមានអ្នកដំណើរជាច្រើននាំគ្នាតាមសម្លឹងមើលពួកគាត់ជាជនភៀសខ្លួនអាស៊ីដំបូងគេ ដែលមានរ៉ាលិសសំពីងសំពោងនោះ ប្រៀបដូចពួកគាត់ជាមនុស្សចម្លែកយ៉ាងដូច្នេះដែរ។

ជីវភាពរស់នៅក្នុងទីក្រុងប៉ារីសដំបូង ពួកគាត់មានការខ្វះខាត សម្លៀកបំពាក់ក្រាស់ៗ ដើម្បីទប់ទល់នឹងភាពត្រជាក់ខ្លាំង ដែលខុសប្លែកពីអាកាសធាតុនៅកម្ពុជា និងវៀតណាម

ខាងត្បូង។ តែមានមិត្តភក្តិជនជាតិបារាំង បាននាំពួកគាត់ទៅរកជំនួយពីអង្គការសង្គ្រោះរបស់សាសនាកាតូលិក ហើយអង្គការនេះ បានផ្តល់ខោអាវជំនំ រួមមានអាវធំ, អាវយឺត, ស្រោមជើង និងខោ ចំនួន២ឡាំង មកឲ្យពួកគាត់។

ទោះបីខោអាវជំនំទាំងអស់នោះ មានខ្លះធំពេក ខ្លះខើចពេក ខ្លះតូចចង្អៀតឬទូលាយពេកក៏ដោយ ក៏ពួកគាត់ត្រូវតែនាំគ្នាយកមកស្លៀកពាក់ ដើម្បីបំបាត់ភាពត្រជាក់បានដែរ។ ពេលពួកគាត់ចេញដើរកម្សាន្តម្តងៗ ពួកគាត់ពាក់អាវធំស្ទើរតែលុបក្បាលបាត់ និងស្លៀកខោជើងធំវែងអូសដី មើលទៅដូចជាសត្វខ្លាឃ្មុំកំពុងដើរអញ្ចឹង។ ពួកគាត់លែងជាកូនៗរបស់មន្ត្រីជាន់ខ្ពស់ និងវណ្ណៈគហបតីនៅទីក្រុងភ្នំពេញ ទៀតហើយ។

គ្រួសារហ្សេកដង់ មានកូនពីរនាក់។ ម្នាក់ៗ មានបន្ទប់ដាច់ដោយឡែករៀងៗខ្លួន។ ម្តាយគាត់ និងបងស្រីអេម៉្មារ៉ាន សម្រាកនៅក្នុងបន្ទប់ទទួលភ្ញៀវ។ ចំណែកគាត់ ដេកជាមួយអ្នកបម្រើជាជនជាតិអាស៊ីម្នាក់នៅក្នុងបន្ទប់តូចមួយ។

នៅក្នុងបន្ទប់អ្នកបម្រើដ៏តូចចង្អៀតនោះ មានគ្រែពីរត្រួតលើគ្នា មានកន្លែងលុបលាងមុខមួយ និងតុមួយដែលអ្នកបម្រើនោះទុកឱ្យគាត់គ្រាន់អង្គុយរៀន។ គាត់មិនប្រៀបធៀបស្ថានភាពជីវភាពរស់នៅរបស់គាត់ជាមួយនឹងស្ថានភាពអ្នកដទៃនោះឡើយ។ អ្វីដែលសំខាន់សម្រាប់គាត់ គឺការចាប់ផ្តើមរៀនថ្នាក់ទីបញ្ចប់ឡើងវិញ នៅវិទ្យាល័យហ្សង់សុង.ដឺសាយ្សី ( Janson de Sailly ) ។ ការសិក្សាដំបូង មានការលំបាកខ្លះដែរ ដោយសារគាត់បោះបង់ការសិក្សាថ្នាក់ទីបញ្ចប់នេះ អស់រយៈពេលជិត១ឆ្នាំមកហើយ និងចូលរៀនក្រោយគេ ២ខែ។ តែយ៉ាងណា គាត់ត្រូវព្យាយាមប្រឹងប្រែងសិក្សា ដើម្បីឲ្យទាន់សិស្សបារាំងផ្សេងទៀត។ ចាប់ពីត្រីមាសទី២ទៅ ការសិក្សារបស់គាត់ស្ទើរតែល្អប្រសើរទាំងអស់។

ពេលគាត់ត្រលប់មកពីរៀននៅវិទ្យាល័យយឺតបន្តិច គាត់ត្រូវតែទទួលទានបាយជាមួយស៊ុតជាមួយអ្នកបម្រើនោះនៅក្នុងបន្ទប់ដាំបាយ។ ប៉ុន្តែ គាត់មិនដែលតូចចិត្តតូចថ្លើមចំពោះការរស់នៅ និងទទួលទានបាយជាមួយអ្នកបម្រើនោះម្តងណាឡើយ។

សម រង្ស៊ី បានឱ្យដឹងថា មុននឹងក្លាយជាភរិយារបស់ឧបនាយករដ្ឋមន្ត្រី ជីវិតរបស់

ម្ដាយគាត់មានការលំបាកជាច្រើន។ ម្ដាយគាត់ធំដឹងក្ដីនៅក្នុងគ្រួសារមន្ត្រីរាជការ និងពាណិជ្ជករ តែម្ដាយគាត់បាត់បង់ម្ដាយតាំងពីក្មេងវ័យ និងត្រូវរស់នៅជាមួយម្ដាយចុងក្នុងភាពល្វឹងជូរចត់បំផុត ហើយជីតាគាត់ក៏រកស៊ីខាតទៀត។ តែម្ដាយគាត់តស៊ូពុះពារគ្រប់បែបយ៉ាង។

មុនពេលគាត់ចាប់កំណើត (ឆ្នាំ១៩៤៩) ឪពុកគាត់ត្រូវចេញទៅសិក្សានៅទីក្រុងប៉ារីសជាច្រើនឆ្នាំនោះ ម្ដាយគាត់តស៊ូទៅបង្រៀននៅតាមសាលាឯកជនជាច្រើន ដើម្បីរកថវិកាមកដោះស្រាយជីវភាពគ្រួសារ។ នៅពេលល្ងាច ក្រោយចេញពីសាលា ម្ដាយគាត់ឆ្លៀតលក់ទឹកកក និងភេសជ្ជៈផ្សេងៗបន្ថែមទៀត។

ផ្ទះសាមញ្ញមួយខ្នងដំបូងរបស់គ្រួសារគាត់ គឺម្ដាយគាត់ម្នាក់ឯងជាអ្នករ៉ាប់រងកសាងឡើងបន្តិចម្ដងៗ។ ច្រើនឆ្នាំក្រោយមក ទើបលទ្ធភាពសាងសង់ផ្ទះវីឡាមួយនៅផ្លូវត្រសក់ផ្អែម។ ម្ដាយគាត់ជាស្រីម្នាក់ចេះធ្វើអ្វីៗគ្រប់បែបយ៉ាង។ ពេលមករស់នៅទីក្រុងប៉ារីស ដំបូង ម្ដាយគាត់ធ្វើការជាអ្នករៀបចំផ្ទះឲ្យគេ។

ក្រោយមក ម្ដាយគាត់រកបានការងារមួយមិនសូវហត់នឿយដូចមុន ហើយស័ក្ដិសមនឹងចំណេះដឹងរបស់គាត់ទៀតផង គឺអ្នករក្សាបណ្ណាសារនៅក្លឹបតួរីញបារាំង (Touring Club de France) ហើយបងប្រុសទាំងពីរនាក់របស់គាត់ គឺអេម្ម៉ារិទ្ធ និងមិជារី ក៏ចូលធ្វើការ ដើម្បីបានប្រាក់ខែដែរ ដោយមិនបានបន្តការសិក្សាទៀតឡើយ។

ម្ដាយ និងបងៗ សង្ឃឹមថា គាត់រៀនពូកែជាងគេ ហើយបានលះបង់គ្រប់យ៉ាងដើម្បីឲ្យគាត់បានរៀនសូត្រវែងឆ្ងាយ តាមដែលអាចធ្វើទៅបាន។ អេម្ម៉ារិទ្ធ និងមិជារី ដែលទទួលបានប្រាក់ខែម្នាក់ៗតែ៥០០ហ្វ្រង់នោះ ជួយបង់ថ្លៃផ្ទះ និងថ្លៃម្ហូបអាហារ ព្រមទាំងជួយទិញសៀវភៅសិក្សា និងសម្លៀកបំពាក់ឱ្យគាត់ផងដែរ។ ពេលនោះជីវិតជានិស្សិតរបស់គាត់មិនត្រឹមតែមិនដែលខ្វល់ខ្វាយពីរឿងខ្វះខាតក្នុងជីវភាពទេ គឺថែមទាំងត្រូវម្ដាយ និងបងៗ ទម្រើសទំយើទៀតផង។ គាត់មិនចាំបាច់ពិបាករកសុំអាហារូបករណ៍ដើម្បីសិក្សានៅមហាវិទ្យាល័យឡើយ ហើយគាត់មិនចាំបាច់ធ្វើការក្រៅម៉ោងពេលល្ងាច ឬធ្វើការនៅពេលសម្រាក វិស្សមកាល ដើម្បីរកលុយមកចំណាយលើការសិក្សារបស់គាត់ដែរ។

រូបតនយោបាយ

ដោយសារការលះបង់របស់ម្តាយ និងបងៗនេះហើយ ទើបគាត់មានឱកាសទទួលបានជោគជ័យក្នុងការសិក្សា និងបានអភិវឌ្ឍបន្ថែមនូវចំណេះដឹងទាក់ទងនឹងអរិយធម៌ អក្សរសាស្ត្រអង់គ្លេស ទៀតផង។ បន្ទាប់មក គាត់បានពង្រីកចំណេះដឹងខាងប្រវត្តិសាស្ត្រសេដ្ឋកិច្ច និងនយោបាយនៅក្នុងមជ្ឈដ្ឋាននៃលទ្ធិប្រជាធិបតេយ្យអាស្រ័យសភា ក្នុងបំណងបោះជំហានតាមដានជីវិតនយោបាយរបស់ឪពុកគាត់ជាបណ្តើរៗផងដែរ។

# ២៥១
# សម រង្ស៊ី ចាប់ចិត្តស្នេហា លើ សូម្ហ៊ុរ៉ា តាំងពីអាយុ១០ឆ្នាំ



ជូឡុង សូម្ហ៊ុរ៉ា

សម រង្ស៊ី រម្លឹកថា ក្រោយពីឪពុកគាត់(សម សារី)ចាកចេញពីទីក្រុងភ្នំពេញ ដោយមានការចោទប្រកាន់ថា ជាជនក្បត់ជាតិនោះ ក្នុងចំណោមមន្ត្រីជាន់ខ្ពស់តូចធំទាំងអស់ មានតែគ្រួសារញឹក ជូឡុង មួយប៉ុណ្ណោះ ពិសេសភរិយារបស់ញឹក ជូឡុង នៅតែរាប់អានអាណិតអាសូរចំពោះពួកគាត់ និងតែងតែព្យាយាមលើកទឹកចិត្តម្ដាយគាត់ជានិច្ច។

សម រង្ស៊ី បានសរសើរថា ទោះបី ញឹក ជូឡុង មានភាពស្មោះស្ម័គ្របួរផ្តាច់ជាមួយសម្ដេចសីហនុ យ៉ាងណាក៏ដោយ ក៏លោកឲ្យភរិយារបស់លោករាប់អានម្ដាយគាត់ ជាមិត្តចាស់ពីកុមារភាព ដោយមិនខ្លាចសម្ដេចសីហនុ ដកតំណែងរបស់លោកឡើយ។

គ្រួសារញឹក ជូឡុង រស់នៅក្នុងគេហដ្ឋានដ៏ប្រណីតមួយខ្ទង់នៅក្រោយពេទ្យចិន។

ភរិយារបស់ញ៉ឹក ជូឡុង ឈ្មោះមាស កេត សម្ផស្ស។

ថ្ងៃមួយក្នុងឆ្នាំ១៩៥៩ គាត់មានអាយុ១០ឆ្នាំប៉ុណ្ណោះ ម្ដាយរបស់គាត់ នាំគាត់ទៅលេងផ្ទះគ្រួសារញ៉ឹក ជូឡុង ជាលើកទីមួយ។ ពេលម្ដាយគាត់ និងភរិយារបស់ញ៉ឹក ជូឡុង កំពុងនិយាយសំណេះសំណាលគ្នានៅក្នុងបន្ទប់ទទួលភ្ញៀវ រូបគាត់ដែលកំពុងអង្គុយជិតម្ដាយ រមួលខ្លួនដោយការអៀនប្រៀននោះ ស្រាប់តែមានក្មេងស្រីម្នាក់អាយុប្រហែល៩ឆ្នាំ បានចេញពីបន្ទប់មួយក្បែរនោះ ដើរមួយជុំពួកគាត់ រួចក៏ចាកចេញទៅវិញបាត់។ តែគាត់នៅតែស្លុងអារម្មណ៍ចំពោះការចេញមកបង្ហាញខ្លួនរបស់ក្មេងស្រីម្នាក់នេះ។

អ្នកស្រីជូឡុង ប្រាប់ម្ដាយគាត់ថា នាងឈ្មោះសូម្ហ៉ា ជាកូនទី៤ ក្នុងចំណោមកូនស្រីទាំង៧នាក់របស់គាត់។ គាត់ឃើញនាងពិតជាស្អាត ធ្វើឲ្យគាត់ភ្លឹកស្មារតីលង់អារម្មណ៍អណ្ដែតអណ្ដូងយ៉ាងខ្លាំង។ គាត់មិនធ្លាប់មានអារម្មណ៍បែបនេះពីមុនមកសោះ។

ប៉ុន្មានថ្ងៃក្រោយមកទៀត ម្ដាយគាត់ក៏នាំគាត់ជាកូនពៅទៅលេងផ្ទះភរិយារបស់ញ៉ឹក ជូឡុង ជាលើកទីពីរ។ ពេលនោះ គាត់ឃើញសូម្ហ៉ា ស្លៀកសំពត់ខៀវ អាវស-កឱប និងអាវកាក់ពណ៌ខៀវ ព្រមទាំងក្រងសក់ពាក់បូរ និងពាក់វ៉ែនតាទៀតផង កំពុងអង្គុយនៅតុបាយដោយដក់អានសៀវភៅរឿងតាំងតាំង។  នាងនិយាយជាមួយពួកគាត់ដោយមិនទាំងបែរមុខចេញពីសៀវភៅរឿងតាំងតាំងនោះផង។ គាត់យល់ថា អាកប្បកិរិយាបែបនេះ បង្ហាញឱ្យឃើញថា នាងរាងប្រទើ្បសបើសឆ្មើងឆ្មៃបន្តិច។ តែទោះបីគាត់មានការអៀនប្រៀន មិនហ៊ានមើលមុខនាងចំយ៉ាងណាក៏ដោយ ក៏គាត់ចង់ឲ្យនាងចាប់អារម្មណ៍មកលើគាត់ថា សេចក្ដីស្នេហារបស់គាត់កំពុងតែឆាបឆេះចំពោះរូបនាង។

ក្រោយពេលចេញពីផ្ទះញ៉ឹក ជូឡុង វិញ ម្ដាយគាត់ទូន្មានគាត់ថា អ្នកស្រីជូឡុង ទម្រើសកូនស្រីគាត់ជ្រុលពេកហើយ។ នៅឯផ្ទះយើងវិញ ពេលមានភ្ញៀវមកលេង បើកូនណាម្នាក់មិនចេះសម្ដែងការគួរសម ដោយប្រើអាកប្បកិរិយាដូចសូម្ហ៉ា បែបនេះ ប្រាកដជាត្រូវទទួលទណ្ឌកម្មជាមិនខាន។ នៅពេលមានភ្ញៀវសំខាន់ណាម្នាក់មកផ្ទះ យើងត្រូវតែឱនសំពះ...។

តែចំពោះសម រង្ស៊ី គិតថា គាត់ពេញចិត្តនឹងភាពសោះអង្អើយរបស់សូម្ហ៉ា នោះទៅវិញ។

ក្រោយពីត្រឡប់មកពីផ្ទះសូម្ប៉ា វិញ យប់នោះ គាត់យល់សប្តិឃើញពេលគាត់កំពុងនៅក្នុងផ្ទះសូម្ប៉ា នោះ ស្រាប់តែមានព្យុះសង្ឃរាមួយបានបក់បោកយ៉ាងខ្លាំង។ ពេលនោះ សូម្ប៉ា បានដាក់សៀវភៅដែលនាងកំពុងអានចុះ ហើយរត់មកក្បែរគាត់ ដើម្បីឱ្យគាត់ជួយនាង។ ចាប់ពីពេលនោះមក គាត់តែងតែស្រមៃឃើញសូម្ប៉ា ជានិច្ច ដោយគ្មានថ្ងៃណាដែលថាគាត់មិនស្រមៃឃើញនាងនោះទេ។

ទន្ទឹមគ្នានោះដែរ ពេលទៅរៀននៅសាលាជាមួយគ្នា ក៏គ្មានពេលណាដែលថាគាត់មិនតាមមើលនាងនោះដែរ ឱ្យតែដល់ម៉ោងចេញលេងម្តងៗ ឃើញនាងចេញពីបន្ទប់រៀនជាមួយមិត្តភក្តិស្រីៗរបស់នាង គាត់ក៏ប្រញាប់ចេញពីបន្ទប់រៀនគាត់ ដើរទៅចូលក្នុងចំណោមមិត្តភក្តិរួមថ្នាក់របស់នាង ដើម្បីបានសម្លឹងមើលមុខនាង រហូតដល់ពេលកណ្តឹងរោទ៍ឱ្យចូលរៀនវិញ។ ពិសេស បើនាងអង្គុយកន្លែងណាមួយនៅក្នុងបរិវេណសាលា គាត់តែងព្យាយាមរកកន្លែងណាមួយ ដើម្បីបានអង្គុយក្បែរនាងដែរ។ ប៉ុន្តែរាល់ការប្រឹងប្រែងព្យាយាមទាំងប៉ុន្មាននេះ គាត់នៅតែមិនបានទទួលផលអ្វីបន្តិចឡើយ ព្រោះនាងហាក់ដូចជាមិនចាប់អារម្មណ៍ជាមួយគាត់ម្តងណាសោះ។ តែទោះជាយ៉ាងណា ពេលបានឃើញមុខនាងម្តងៗ គាត់គិតថាជីវិតគាត់ពិតជាមានសេចក្តីសុខណាស់ទៅហើយ។

សម រង្ស៊ី រម្លឹកបន្តថា រាល់ពេលគាត់ធ្វើដំណើរតាមវិថីនានា ក្នុងទីក្រុងភ្នំពេញម្តងៗ ភ្នែកគាត់តែងរំពៃមើល ក្រែងឃើញរថយន្តរបស់គ្រួសារត្រកូលជូឡុង គឺរថយន្តវ៉ុលវ៉ាហ្គែន (Voldswagen)ពណ៌ក្រហម មានបីបាំង ដែលគាត់ស្គាល់ផ្លាកលេខរថយន្តនោះច្បាស់ណាស់។

ថ្ងៃមួយ គាត់ឃើញរថយន្តវ៉ុលវ៉ាហ្គែន(Voldswagen)នោះ ជូនសូម្ប៉ា មករៀនគួរភាសាខ្មែរនៅក្បែរផ្ទះគាត់ ហើយចតដើម្បីរង់ចាំនាងចេញពីរៀនគួរវិញ នៅក្បែរផ្ទះគាត់នោះដែរ។ ពេលនោះ គាត់នៅឈរចាំមើល រហូតនាងចេញពីរៀនគួរវិញ ដោយមានស្រីអ្នកបម្រើម្នាក់ជូននាងរហូតដល់រថយន្ត ហើយបើកទ្វារខាងក្រោយឲ្យនាងដោយការគោរព។

ក្រោយពីគាត់គៀសខ្លួនទៅទីក្រុងព្រៃនគរ រហូតទៅដល់ទីក្រុងប៉ារីស គាត់នៅតែយល់សប្តិឃើញសូម្ប៉ា ជានិច្ច។ គាត់គិតថា ពេលនេះ នាងនឹងទៅជាយ៉ាងណាហើយ?។ បំណង

ប្រាថ្នាដែលគាត់ប៉ងតាំងពីកាលអាយុ១០ឆ្នាំ ថា គាត់ និងនាងនឹងក្លាយជាប្តីប្រពន្ធនឹងគ្នានៅថ្ងៃណាមួយនោះ គឺមិនអាចទៅរួចទេ។

នៅដើមឆ្នាំ១៩៦៧ ពេលគាត់កំពុងសិក្សានៅថ្នាក់ទីបញ្ចប់ នៅវិទ្យាល័យហ្សង់សុង ដឺ សាយ្សី (Janson de Sailly) នោះ ស្រាប់តែគាត់បានទទួលដំណឹងថា គ្រួសារញ៉ើក ជូឡុង បានទិញផ្ទះមួយនៅសង្កាត់ទី១៥ ក្នុងទីក្រុងប៉ារីស ហើយផ្ទះល្វែងមួយនេះ ក៏នៅមិនឆ្ងាយប៉ុន្មានពីផ្ទះរបស់គាត់ដែលនៅតាមដងផ្លូវហ្សាវែល (Javel)នោះប៉ុន្មានដែរ។

ថ្ងៃមួយ អ្នកស្រីមាសកេត សម្ផស្ស ជាម្ដាយរបស់សូម្ប៉ា បានសរសេរសំបុត្រមួយមកប្រាប់ម្ដាយគាត់ថា អ្នកស្រីនឹងឆៀងចូលលេងទីក្រុងប៉ារីស បន្ទាប់ពីអ្នកស្រីធ្វើដំណើរទៅទីក្រុងប្រាក (ប្រទេសឆេកូស្លូវ៉ាគី) ដែលបងប្រុសនាងធ្វើជាឯកអគ្គរាជទូតនៅទីនោះ។ ឮដូច្នេះគាត់មានក្ដីរំភើបរីករាយជាទីបំផុត ព្រោះសង្ឃឹមថា នឹងបានឃើញមុខសូម្ប៉ា ជាថ្មីម្ដងទៀតមិនខាន។

ពេលម្ដាយសូម្ប៉ា មកដល់ផ្ទះរបស់នាងនៅសង្កាត់ទី១៥ ក្នុងទីក្រុងប៉ារីស គាត់បានផ្ញើកន្ត្រកអាហារខ្មែរមួយមកឱ្យម្ដាយគាត់។ ប៉ុន្មានថ្ងៃក្រោយមក ម្ដាយគាត់ក៏បានអញ្ជើញម្ដាយសូម្ប៉ា ឲ្យមកទទួលទានអាហារពេលល្ងាចជុំគ្នាម្ដង។

ពេលជុំគ្នាទទួលទានអាហារពេលល្ងាចនោះ សូម្ប៉ា ក៏មកជាមួយម្ដាយនាងដែរ។ ពេលនោះ គាត់មិនបានផ្ដោតអារម្មណ៍ទៅលើរសជាតិអាហារ ដែលនៅលើតុបន្តិចសោះឡើយ អារម្មណ៍គាត់ផ្ដោតតែទៅលើសូម្ប៉ា ម្នាក់ប៉ុណ្ណោះ។ រូបរាងសូម្ប៉ា មានការផ្លាស់ប្ដូរច្រើន។ នាងក្លាយជាយុវតីដ៏ស្រស់ប្រិមប្រិយម្នាក់ធ្វើឲ្យគាត់ចាប់ចិត្តគយគន់មិនដាក់ភ្នែក។ តែគាត់ក៏មានការអៀនខ្មាសណាស់ដែរ ដោយសារតែចាញ់សម្រស់របស់នាងខ្លាំងពេក។

ក្រោយពេលទទួលទានអាហាររួច ចាស់ៗ បានដាក់កំណត់ឱ្យគាត់ជាអ្នកលាងចាន ឯសូម្ប៉ា ជាអ្នកជូតចាននៅក្នុងបន្ទប់ដាំបាយ។ នេះជាលើកទីមួយហើយ ដែលគាត់ និងនាងនៅក្បែរគ្នាតែពីរនាក់បែបនេះ។ ពួកគាត់អឹមអៀន មិនដឹងថា ត្រូវចាប់ផ្ដើមនិយាយពីរឿងអ្វីនោះដែរ។

សម រង្ស៊ី នៅចាំបានថា ពេលនោះ ដោយគិតថា នៅក្នុងផ្ទះតូចចង្អៀតបែបនេះ សូរសំឡេងលាងចានអាចរំខានដល់ម្ដាយពួកគាត់ទាំងពីរ ដែលកំពុងអង្គុយពិភាក្សាគ្នាពីរឿងរ៉ាវផ្សេងៗមិនចេះចប់នោះ សូម្ប៉ា បានប្រាប់គាត់ឱ្យបិទទ្វារបន្ទប់ដាំបាយ។ គាត់ចាប់ផ្ដើមសួរនាង ពីការសិក្សារបស់នាង។ នាងប្រាប់ថា ពេលវិលត្រលប់ទៅប្រទេសវិញ នាងនឹងចូលរៀនថ្នាក់ទីបញ្ចប់នៅវិទ្យាល័យដេកាដ ហើយនាងក៏សួរពីជីវិតជានិស្សិតរបស់គាត់នៅប្រទេសបារាំងនេះដែរ។ តែទោះបីយ៉ាងណា ក៏គាត់មិនហ៊ានសារភាពពីអាថ៌កំបាំងនៅក្នុងបេះដូងគាត់ប្រាប់នាងឡើយ គឺបានត្រឹមតែគិតស្រមៃថា តើគួរចាប់ដៃនាង ហើយឱបក្រសោបនាងដូចគាត់ធ្លាប់ឃើញនៅក្នុងខ្សែភាពយន្ត ឬយ៉ាងណា?។

គាត់ក៏ដឹងចិត្តនាងដែរថា នាងចង់ឱ្យគាត់សារភាពថា គាត់ស្រលាញ់នាងដោយត្រង់ៗដែរ តែគាត់មិនហ៊ាន។ គាត់បែរជានិយាយពីទឹកចិត្តស្នេហាជាតិរបស់គាត់ និងពីអារម្មណ៍សោកសៅនៅពេលគាត់ត្រូវឃ្លាតពីប្រទេសជាតិទៅវិញ។

ទីបំផុត គាត់មានគំនិតចង់បង្កើតអនុស្សាវរីយ៍មួយដែលធ្វើឱ្យនាងមិនអាចបំភ្លេចបាន តែមិនដឹងថា ត្រូវបង្កើតអនុស្សាវរីយ៍អ្វីមួយនោះទេ? ពេលនោះ មិនដឹងជាមានអ្វីនាំមាត់គាត់ឱ្យនិយាយបបួលនាងទៅដើរលេងកម្សាន្តនៅទីក្រុងឡុងដ៍ ជាមួយគ្នា ព្រោះគាត់ត្រូវទៅសម្រាកវិស្សមកាល និងអនុវត្តភាសាអង់គ្លេស នៅទីក្រុងឡុងដ៍ នៅពេលខាងមុខនោះដែរ។ ឮដូច្នេះ នាងហាក់ដូចជាស្រឡាំងកាំងបន្តិច មិនឆ្លើយតបនឹងការបបួលនេះទេ ហើយក៏ប្ដូរទៅនិយាយពីរឿងផ្សេងវិញ។ គាត់គិតថា នាងប្រហែលជាអន់ចិត្តពីរឿងនេះហើយ។ តែទោះជាយ៉ាងណា គាត់សង្ឃឹមថា នាងនឹងមិនភ្លេចអនុស្សាវរីយ៍ពេលលាងចានតែពីរនាក់នេះទេ។

សម រង្ស៊ី បញ្ជាក់ថា នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ បើបុរសណាម្នាក់ហ៊ានបបួលកូនក្រមុំគេដើរលេងកម្សាន្តបែបនេះ គេនឹងចាត់ទុកថាមនុស្សឈ្លើយបំផុត។

ទាក់ទងរឿងសម រង្ស៊ី និយាយថា ពេលកំពុងលាងចានស្ងាត់ៗ តែពីរនាក់ សូម្ប៉ា បានប្រាប់គាត់ឱ្យបិទទ្វារបន្ទប់ដាំបាយនោះ ក្រោយមក សូម្ប៉ា បានបដិសេធថា គឺសម រង្ស៊ី

ទេ ជាអ្នកប្រាប់គាត់ឱ្យបិទទ្វារបន្ទប់ដាំបាយនោះ...។

ក្រោយពីមានអនុស្សាវរីយ៍ពេលលាងចានតែពីរនាក់នោះមក ពេលនាងត្រលប់ទៅដល់ប្រទេសកម្ពុជាវិញ នាងតែងតែផ្ញើសំបុត្រមកគាត់ជាបន្តបន្ទាប់។ នាងបានសរសេររៀបរាប់ពីការដើរកម្សាន្តនៅប្រទេសឆេកូស្លូវ៉ាគី។ ចំណែកគាត់វិញ ក៏បានសរសេររៀបរាប់ប្រាប់នាងខ្លះៗអំពីការសម្រាកវិស្សមកាល និងការអនុវត្តភាសាអង់គ្លេស នៅទីក្រុងឡុងដ៍ ព្រមទាំងសួរសុខទុក្ខគ្នាទៅវិញទៅមកជាបន្តបន្ទាប់ ក្នុងលក្ខណៈមិត្តភាពប៉ុណ្ណោះ។ គាត់ឲ្យយោបល់ថា ក្រោយពេលនាងប្រលងជាប់បាក់ឌុបហើយ គួរតែត្រៀមប្រលងចូលរៀនផ្នែកវិទ្យាសាស្រ្តនយោបាយ។ តែនាងប្រាប់វិញថា នាងចាប់អារម្មណ៍ទៅលើផ្នែកច្បាប់។

---

**សូមរង់ចាំអានភាគ៦ បន្តទៀត**
**សូមអរគុណ**

# ឯកសារយោង ៖


1. Le Cambodge de Sihanouk Espoir, Désillusions et Amertume. par Richard Sola .
2. Le mal Cambodge Histoire D´une société traditionnelle Face à ses Leaders Politiques 1946 – 1987. par Marie Alexandrine Martin .
3. Pol Pot Frère Numéro Un. par Davidp – Chandler.
4. Le Cambodge dans la tourmente: Le troisième conflit indochinois, 1978-1991. par Nicolus Regaud .
5. Cambodge : Rêves et Réalités. par Vandy Kaonn.
6. Histoire du Cambodge 1863 – 1992. par Vandy Kaonn .
7. Cambodia: Year Zero by Francois Ponchaud
8. Hun Sen strongman of Cambodia. by Harrish C. Metha Julie B. metha.
9. When the War Was Over by Elizabeth Becker
10. How Pol Pot to come Power. By Ben Kiernan .
11. Wikipedia The free encyclopedia .
12. Wikipedia Org. wiki.
13. DP. Pedia org. page.
14.Wikiwand.
15. U.S. Embassy in Cambodia document.
16. Cold war international history Project.
17. The New York Times newspaper.
18. Times Magazine.
19. The Far Eastern Economic Review Magazine.
20. Le Figaro newspaper.
21. Le Monde newspaper.

22. Les Echos newspaper.

23. Le Parisien newspaper.

24. L´ humanite newspaper.

25. Liberation newspaper.

26. Washington Post newspaper.

27. Pol Pot by Philip Short.

28. The Gate by Francois Bizot.

29. Haing Ngor: A Cambodian Odyssey by Haing S. Ngor with Roger Warner.

30. My War With the CIA by Norodom Sihanouk .

31. War and Hope: The Case for Cambodia by Norodom Sihanouk .

32. Flying Tigers Over Cambodia by Larry Partridge.

33. The United States and Cambodia, 1870-1969 By Kenton Clymer.

34 .L´histoire terrible mais inachevée de Norodom Sihanouk, roi du Cambodge (THEATRE) (French Edition).

35. Souvenir doux et amers  par Norodom Sihanouk.

36. គុកនយោបាយ  ដោយ ប៊ុណ្ណ ចន្ទម៉ុល.

37. ឧត្តមគតិ លោកអៀវ កើស ដោយ ង៉ែត ហៀង.

38. លោកព្រឹទ្ធាចារ្យ បណ្ឌិតជួន មុម្ម ដោយបណ្ឌិតពុទ្រ្ធី ទត់.

39. ជីវប្រវត្តិសង្ខេប ប៉ែន សុវណ្ណ និងបុព្វហេតុជាតិមាតុភូមិកម្ពុជា ដោយប៉ែន សុវណ្ណ និងនាង សារុន.

40. Des racines dans la pierre par Sam raingsy

41. ខ្មែរអ្នកជាតិនិយម ដោយឡឹក សំអឿន ហៅផ្កាយព្រឹក

42. The One Who Was Shot

# ជីវប្រវត្តិសង្ខេបរបស់អ្នកសិក្សាស្រាវជ្រាវ



**រូបថត ឆ្នាំ១៩៨៥**



**រូបថត បច្ចុប្បន្ន**

ឈ្មោះ **ឈឹម សេរីវឌ្ឍន** កើតថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៥៤ កើតនៅភូមិស្រម៉ជ្រំ សង្កាត់សង្ឃ័រ ក្រុងស្វាយរៀង ខេត្តស្វាយរៀង។ ឪពុកឈ្មោះ **ឈឹម ប៉ាវ** មានស្រុកកំណើតនៅខេត្តព្រៃវែង មុខរបរជាអ្នកថែសួននៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត។ ម្តាយឈ្មោះ **ទេព ឌុន** មានស្រុកកំណើតនៅខេត្តស្វាយរៀង មុខរបរជាមេផ្ទះ។ មានបង៣នាក់ ( ស្រី១ប្រុស២ ) និងប្អូន៣នាក់( ស្រី២ប្រុស១ )។

ឆ្នាំ១៩៦២ - ៦៣ ចូលរៀនថ្នាក់ទី១២ សាលាបឋមសិក្សាឯកជនសង្គមមានជ័យ នៅម្តុំខាងក្រោយសាលាបច្ចេកទេសថៃទាំវេជ្ជសាស្ត្រសព្វថ្ងៃ ។

ឆ្នាំ១៩៦៣ - ៦៩ រៀននៅសាលាបឋមសិក្សាចង្ក្រានតាព្រហ្មមានជ័យ (វត្តចង្ក្រានតាព្រហ្មស្ទឹងមានជ័យ )

ឆ្នាំ១៩៦៩ - ៧៤ រៀននៅវិទ្យាល័យឥន្ទ្រទេវី (វិទ្យាល័យទួលគោក )

ឆ្នាំ១៩៧៤ - ៧៥ រៀនថ្នាក់ទីបញ្ចប់ផ្នែកទស្សនវិជ្ជា នៅវិទ្យាល័យកែវ សង់គីម

(វិទ្យាល័យ១៨មីនា ១៩៧០ ឬវិទ្យាល័យព្រះយុគន្ធរ)។

**ប្រវត្តិការងារ៖**

-ពីឆ្នាំ១៩៧៩ -១៩៨៤ ជានាយកអប់រំឃុំព្រៃរំដេង ស្រុកមេសាង ខេត្តព្រៃវែង

-ពីឆ្នាំ១៩៨៤ -១៩៨៥ ជាអនុប្រធានការិយាល័យអប់រំស្រុកមេសាង ខេត្តព្រៃវែង

-ពីឆ្នាំ១៩៨៥ -១៩៨៦ ជាប្រធានការិយាល័យឃោសនាការ វប្បធម៌ និងព័ត៌មានស្រុកមេសាង

-ពីឆ្នាំ១៩៨៦ -១៩៨៧ ជាលេខាបក្សឃុំត្រពាំងស្រែ ស្រុកមេសាង ខេត្តព្រៃវែង

-ពីឆ្នាំ១៩៨៧ -១៩៩៣ ជាប្រធានមន្ទីរគណៈកម្មាធិការបក្សស្រុកមេសាង និងជាសមាជិកគណៈកម្មាធិការបក្សស្រុក មេសាង ខេត្តព្រៃវែង

-ដើមឆ្នាំ១៩៩៣ ជាជំនួយការមន្ត្រីរៀបចំការបោះឆ្នោតអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ(UNTAC) ប្រចាំស្រុកមេសាង ខេត្តព្រៃវែង

-ឆ្នាំ១៩៩៤ ជាមន្ត្រីនគរបាលនៅនាយកដ្ឋានជនបរទេស អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ

- ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ២០២២៖ ជាអ្នកនិពន្ធអត្ថបទវិភាគនយោបាយ វិចារណកថាបទបរិយាយ ឱ្យកាសែតចក្រវាឡ, កាសែតអរិយធម៌, កាសែតសំឡេងនិស្សិត, ទស្សនាវដ្តីកងរាជអាវុធហត្ថរាជធានីភ្នំពេញ។ ជានិពន្ធនាយកទស្សនាវដ្តីអង្គរធំ, ជានិពន្ធនាយកទស្ស-នាវដ្តីខេមរា, ជានិពន្ធនាយកទស្សនាវដ្តីសោភ័ណ, ជានិពន្ធនាយករងទស្សនាវដ្តីរថយន្ត, ជាទីប្រឹក្សាកាសែតនគរធំ, ជានិពន្ធនាយកគេហទំព័រTVFB, ជានិពន្ធនាយកគេហទំព័រKBN និងជាប្រធានផ្នែកព័ត៌មានជាតិ គេហទំព័រSBM News និងជាអ្នកសិក្សាស្រាវជ្រាវឯកសារប្រវត្តិសាស្ត្ររបត់នយោបាយ

-ឆ្នាំ២០២២ ជាទីប្រឹក្សាក្រសួងមហាផ្ទៃ

-ឆ្នាំ២០២៣ ជាអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ

UNITED NATIONS
UNITED NATIONS TRANSITIONAL AUTHORITY IN CAMBODIA
(UNTAC)

NATIONS UNIES
AUTORITE PROVISOIRE DES NATIONS UNIES AU CAMBODGE
(APRONUC)

# CERTIFICATE OF OUTSTANDING SERVICE

This certifies that Mr. Chhim Sery Phuon worked with UNTAC Electoral Component at the District of Mesang for more than eight months at different capacities. Initially, he was recruited as a Registration Team Leader (RTL) for four months. As he extraordinarily completed his contract as RTL, his contract was extended for two more months as Senior Election Assistant (SEA). Finally, after the completion of his contract as SEA, he was re-employed as a Presiding Officer for UNTAC Election in May 1993 in Combodia.

As a RTL, Mr. Chhim worked out Training Manual in Khemer, Trained the Local Staff about Registration Process and was a Team Leader of Eight other Registration Teams. I was really impressed with Mr. Chhim's training capabilities. Because of his fine training skill, we had no complains from the higher authorities regarding registration, despite complex and long procedures. His profound ability to teach others was also reflected during civic education campaign. He trained all the assistants for civic education regarding Paris Peace Agreement, UNTAC Electoral Law, Human Rights etc. so well that 99.3 % people turned over to express their opinion during the Election. He was the best PO in respect of due completion of all the technicalities during the election.

I am very much impressed of his originality, managerial skill and sincerity at work. In brief, he is a multidimensional personality with whom every one would love to work. I give him my highest regards and wish every success in his future assignments.

Sincerely,

H. Prasad

Hari Prasad, DES
Mesang, Prey Veng
COMBODIA

June 7, '93



# លិខិតថ្លែងអំណរគុណ

ឯកសារប្រវត្តិសាស្ត្រមានចំណងជើងថា**របត់នយោបាយ** តាំងពីភាគទី១ដល់ភាគទី៤ ត្រូវបានបោះពុម្ពជាសៀវភៅឡើងស្របតាមគតិបណ្ឌិត និងមនសិការប្រវត្តិសាស្ត្រជាតិដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង** តាំងពី**សម្តេច**នៅជាឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានចារបញ្ជាក់ថា៖ សំខាន់ចង់បានសៀវភៅប្រវត្តិសាស្ត្រមួយនេះ ទុកឲ្យកូនចៅរៀនសូត្រ...។

ពេលនេះ ទោះបី**សម្តេច** ត្រូវផ្លាស់ប្តូរតួនាទីមកជាសមាជិកឧត្តមទីប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ក៏**សម្តេច** នៅតែបន្តជួយឧបត្ថម្ភគាំទ្រទាំងស្រុង ក្នុងការបោះពុម្ពសៀវភៅ**របត់នយោបាយភាគទី៥** នេះ និងភាគបន្តៗទៀត រហូតដល់ភាគបញ្ចប់។

បើគ្មានការជួយឧបត្ថម្ភគាំទ្រពីសម្តេចក្រឡាហោមនោះទេក៏គ្មានវត្តមានសៀវភៅប្រវត្តិសាស្ត្រដ៏មានសារសំខាន់នេះដែរ។

ខ្ញុំបាទសូមលំឱនកាយគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅ និងសូមប្រសិទ្ធិពរជ័យជូន **សម្តេច** ជាទីគោរពដ៏ខ្ពង់ខ្ពស់ សូមមានសុខភាពល្អបរិបូរណ៍ អាយុយឺនយូរ បញ្ញាញាណភ្លឺថ្លា និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

សូម**សម្តេច**មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុត

ពីខ្ញុំបាទ **ឈឹម សេរីត្ធន**

9 789924 969846